ព្រះរាជក្រម

នស/រកម/០៦២៣/ ០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

រដ្ឋសភា
ចូល លេខ ៧៧ ថ្ងៃទី ៧ / ០៧ / ឆ្នាំ២០២៣ ម៉ោង ៩:៣០
បញ្ជូនទៅ ម.ធ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ក្រមបរិស្ថាននិងធនធានធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ក្រម

# បរិស្ថាននិងធនធានធម្មជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## គន្ថីទី១
## បទប្បញ្ញត្តិទូទៅ
## មាតិកាទោល
## បទប្បញ្ញត្តិទូទៅ
## ជំពូកទី១
## គោលបំណងនិងវិសាលភាព

**មាត្រា១ ._ គោលបំណង**

ក្រមនេះកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រតិបត្តិតាមក្នុងការពង្រឹង ធ្វើទំនើបកម្ម ធ្វើឱ្យមានសង្គតិភាព និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងលើកិច្ចគាំពារបរិស្ថាន ការអភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី ដើម្បីការរស់នៅនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២ ._ វិសាលភាព**

ក្រមនេះមានវិសាលភាពអនុវត្តលើ៖

ក- រាល់សកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធនឹងបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- រាល់សកម្មភាពរបស់បុគ្គលដែលធ្វើប្រតិបត្តិការទាំងក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា ដែលបង្កផលប៉ះពាល់ឬជះឥទ្ធិពលទៅលើបរិស្ថាន ធនធានធម្មជាតិ និងបេតិកភណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ ._ សទ្ទានុក្រម**

វាក្យសព្ទសំខាន់ៗដែលប្រើប្រាស់ក្នុងក្រមនេះ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃក្រមនេះ។

## ជំពូកទី២
## ការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធវិស័យបរិស្ថាន និងធនធានធម្មជាតិ និងការរៀបចំសេចក្តីព្រាងគោលនយោបាយពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ

### ផ្នែកទី១
### ការអនុវត្តតួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធវិស័យបរិស្ថាន និងធនធានធម្មជាតិ

**មាត្រា៤ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសមត្ថកិច្ចក្នុងការអនុវត្តតួនាទីនិងភារកិច្ចអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យនីមួយៗជាសមត្ថកិច្ចរបស់ខ្លួន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៥ .- តួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នដទៃផ្សេងទៀតដែលទទួលបន្ទុកវិស័យពាក់ព័ន្ធនឹងធនធានធម្មជាតិ**

ក្រសួងស្ថាប័នដទៃផ្សេងទៀតដែលទទួលបន្ទុកវិស័យពាក់ព័ន្ធនឹងធនធានធម្មជាតិ មានសិទ្ធិអំណាចក្នុងការអនុវត្តតួនាទីនិងភារកិច្ចអនុលោមតាមក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យនីមួយៗជាសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៦ .- តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

១- រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ចក្នុងការអនុវត្តតួនាទីនិងភារកិច្ចអនុលោមតាមក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- រាជរដ្ឋាភិបាល ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃផ្សេងទៀត អាចផ្ទេរឬផ្ទេរបន្ថែមឬកែប្រែមុខងារដែលបានផ្ទេរផ្សេងទៀតតាមវិស័យរបស់ខ្លួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី២
## ការរៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៧ .- ការរៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងនិងការអភិរក្សធនធានធម្មជាតិ ស្របតាមគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជានិងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៨ .- ការរៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិរបស់ក្រសួងស្ថាប័នដទៃផ្សេងទៀត**

ក្រសួងស្ថាប័នដទៃផ្សេងទៀតនិងរដ្ឋបាលថ្នាក់ក្រោមជាតិ អាចរៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការសកម្មភាពពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិតាមវិស័យនីមួយៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចគាំពារបរិស្ថាននិងអភិរក្សធនធានធម្មជាតិ ស្របតាមគោលនយោបាយនៃព្រះរាជាណាចក្រកម្ពុជានិងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៣
## គោលការណ៍ទូទៅ

**មាត្រា៩ .- គោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព**

គ្រប់សកម្មភាពអភិវឌ្ឍផ្នែកសេដ្ឋកិច្ចនិងសង្គមទាំងអស់ ត្រូវបំពេញតម្រូវការក្នុងការអភិវឌ្ឍនិងតម្រូវការផ្នែកបរិស្ថានរបស់មនុស្សជំនាន់បច្ចុប្បន្ននិងអនាគតប្រកបដោយសមធម៌និងដោយនិរន្តរភាព ដែលក្នុងនោះកិច្ចគាំពារបរិស្ថាននិងការអភិរក្សធនធានធម្មជាតិគឺជាផ្នែកដ៏ចាំបាច់នៃកិច្ចដំណើរការអភិវឌ្ឍ ហើយដែលមិនអាចបំបែកជារឿងដាច់ដោយឡែកពីគ្នាបានឡើយ។

**មាត្រា១០ .– គោលការណ៍នៃការបញ្ចៀសការខូចខាតបរិស្ថាននិងធនធានធម្មជាតិ**

បុគ្គលមិនត្រូវធ្វើសកម្មភាពណាមួយ ដែលបង្កឬអាចបង្កការខូចខាតដល់បរិស្ថាននិងធនធានធម្មជាតិឡើយ។ ក្នុងករណីដែលមិនអាចជៀសវាងបាន បុគ្គលនោះត្រូវចាត់វិធានការសមស្របក្នុងកិច្ចគាំពារបរិស្ថាននិងធនធានធម្មជាតិ និងត្រូវទប់ស្កាត់ឬកាត់បន្ថយការខូចខាតទាំងនោះឱ្យដល់កម្រិតអប្បបរមា។

**មាត្រា១១ .– គោលការណ៍នៃការចូលរួមជាសាធារណៈ**

បុគ្គលដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ឬប្រយោល ដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ឱ្យទាន់ពេលវេលា បន្ទាប់ពីទទួលបានព័ត៌មានតាមរយៈដំណើរការចូលរួមពីភាគីពាក់ព័ន្ធដោយមានតម្លាភាពនិងគណនេយ្យភាព មុនពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង។

**មាត្រា១២ .– គោលការណ៍នៃការទទួលបានព័ត៌មានបរិស្ថាននិងធនធានធម្មជាតិ**

១- បុគ្គលមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ។

២- រាល់ព័ត៌មានស្តីពីកិច្ចគាំពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជន ដើម្បីបង្កើតឱកាសឱ្យបានច្រើនសម្រាប់ការចូលរួមជាសាធារណៈនៅក្នុងការធ្វើផែនការនិងការធ្វើសេចក្តីសម្រេចដែលបង្កផលប៉ះពាល់ដល់សង្គមនិងបរិស្ថាន។

៣- សិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា១៣ .– គោលការណ៍នៃការទទួលខុសត្រូវរបស់បុគ្គលបំពុល**

បុគ្គលដែលបានបង្កឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលបន្ទុកក្នុងការចំណាយលើការជួសជុល និងលើវិធានការទប់ស្កាត់ បញ្ចៀស និងកាត់បន្ថយការខូចខាតបរិស្ថាន។

**មាត្រា១៤ .– គោលការណ៍នៃការបង់ថ្លៃរបស់អ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់ធនធានធម្មជាតិត្រូវបង់ថ្លៃចំណាយសម្រាប់ការប្រើប្រាស់ ឬផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិទាំងនោះ។

**មាត្រា១៥ .– គោលការណ៍នៃការប្រុងប្រយ័ត្នជាមុន**

ក្នុងករណីដែលមានការព្រួយបារម្ភថាមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់បរិស្ថានដែលមិនអាចស្តារឬជួសជុលឡើងវិញបាន មិនអាចយកកង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រមកធ្វើជាមូលហេតុក្នុងការពន្យារពេលនៃការចាត់វិធានការដើម្បីទប់ស្កាត់ការខូចខាតបានឡើយ។

**មាត្រា១៦ .– គោលការណ៍នៃការកាត់បន្ថយឬទប់ស្កាត់ការខូតខាតដល់បរិស្ថាន**

វិធានការនានានៃការកាត់បន្ថយឬទប់ស្កាត់ការខូចខាតបរិស្ថាន ត្រូវធ្វើឡើងមុនពេលការខូចខាតនោះកើតឡើង។ វិធានការនេះត្រូវធ្វើឡើងជាមុនដោយតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមប្រសើរជាងធ្វើការស្តារឬជួសជុលការខូចខាត។

**មាត្រា១៧ .– គោលការណ៍នៃការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង**

ព័ត៌មានដែលមានលក្ខណៈវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចប្រកបដោយតម្លាភាពទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៨ .- គោលការណ៍ផលប្រយោជន៍សាធារណៈ**

ផលប្រយោជន៍សាធារណៈត្រូវមានឧត្តមភាពជាងប្រយោជន៍បុគ្គលឯកជនឬនីតិបុគ្គលឯកជន នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៩ .- គោលការណ៍នៃសមាហរណកម្មផ្នែកបរិស្ថាន**

កិច្ចគាំពារបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ត្រូវដាក់បញ្ចូលទៅក្នុងការរៀបចំផែនការអភិវឌ្ឍ និងការធ្វើសេចក្តីសម្រេចទាំងក្នុងដំណាក់កាលដំបូងនិងដំណាក់កាលអនុវត្តន៍គោលនយោបាយនិងច្បាប់។

## គន្ថីទី២
## ការគ្រប់គ្រងបរិស្ថាននិងយន្តការប្រកបដោយនិរន្តរភាព
## មាតិកាទី១
## ការកាត់បន្ថយនិងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២០ .- គោលបំណង**

មាតិកានេះ មានគោលបំណងគ្រប់គ្រង បង្ការ កាត់បន្ថយគ្រោះមហន្តរាយ និងស្តារឡើងវិញនូវការខូចខាតនិង/ឬផលប៉ះពាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២១ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រង ការបង្ការ ការកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារឡើងវិញនូវការខូចខាតនិង/ឬផលប៉ះពាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា២២ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យគ្រោះមហន្តរាយ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងគ្រោះមហន្តរាយស្របតាមបទប្បញ្ញត្តិនៃក្រមនេះនិងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ។

**មាត្រា២៣ .- តួនាទីនិងភារកិច្ចក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យគ្រោះមហន្តរាយ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនានា និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ។

ខ- ធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធក្នុងការស្វែងរកមូលនិធិ ដើម្បីគាំទ្រដល់ការស្តារនិងការគ្រប់គ្រងគ្រោះមហន្តរាយ។

គ- ផ្តល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលក្នុងការដាក់ចេញនូវគោលនយោបាយនិងវិធានការនានាស្តីពីការត្រៀមបង្ការនិងការគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់និងធានាសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL

ឃ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការត្រៀមបម្រុងមូលនិធិ សម្ភារៈ និងធនធានមនុស្ស ដើម្បីត្រៀមបង្ការនិងធ្វើអន្តរាគមន៍ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញនូវរាល់ការខូចខាតនិង/ឬផលប៉ះពាល់មុនពេល ក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ។

ង- ផ្សព្វផ្សាយការងារគ្រប់គ្រងគ្រោះមហន្តរាយដល់ប្រជាពលរដ្ឋ និងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពការងារគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

**មាត្រា២៤ ._ កិច្ចសហការលើការគ្រប់គ្រងគ្រោះមហន្តរាយ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យគ្រោះមហន្តរាយ ត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បី៖

ក- រៀបចំផែនការគ្រប់គ្រងនិងផែនការកាត់បន្ថយគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយដែលបង្កឡើងដោយធម្មជាតិឬមនុស្ស។

ខ- ត្រៀមលក្ខណៈបង្ការនិងកាត់បន្ថយមុនពេលមានគ្រោះមហន្តរាយ ការឆ្លើយតបសង្គ្រោះបន្ទាន់ក្នុងពេលមានគ្រោះមហន្តរាយនិងការស្តារឡើងវិញនូវការខូចខាតនិង/ឬផលប៉ះពាល់ក្រោយពេលមានគ្រោះមហន្តរាយ។

គ- វាយតម្លៃមូលហេតុនៃភាពងាយរងគ្រោះដែលបណ្តាលមកពីគ្រោះមហន្តរាយ។

ឃ- ពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រង បង្ការ កាត់បន្ថយគ្រោះមហន្តរាយ និងស្តារឡើងវិញនូវការខូចខាតនិង/ឬផលប៉ះពាល់។

ង- ពិគ្រោះយោបល់និងប្រមូលធាតុចូលពីប្រជាពលរដ្ឋតាមតំបន់ ក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ដើម្បីបង្កើតភាពធន់ទៅនឹងគ្រោះមហន្តរាយ។

ច- លើកកម្ពស់ការយល់ដឹងជាសាធារណៈ រៀបចំការបណ្តុះបណ្តាល ការអប់រំ និងលើកទឹកចិត្តឱ្យមានការចូលរួម គ្រប់គ្រង បង្ការ កាត់បន្ថយគ្រោះមហន្តរាយ និងស្តារឡើងវិញនូវការខូចខាតនិង/ឬផលប៉ះពាល់។

## មាតិកាទី២

## ការគ្រប់គ្រងធនធានជីវៈចម្រុះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា២៥ ._ គោលបំណង**

មាតិកានេះ មានគោលបំណងគ្រប់គ្រងនិងអភិរក្សធនធានជីវៈចម្រុះនិងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

**មាត្រា២៦ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងនិងការអភិរក្សធនធានជីវៈចម្រុះ ការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងជីវសុវត្ថិភាព សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។



# ជំពូកទី២
# ស្ថាប័នទទួលខុសត្រូវ

**មាត្រា២៧ .– ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងនិងការអភិរក្សធនធានជីវៈចម្រុះ ការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព និងការគ្រប់គ្រងជីវសុវត្ថិភាព។

**មាត្រា២៨ .– តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- អនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងវិស័យបរិស្ថាន ធនធានជីវៈចម្រុះ និងជីវសុវត្ថិភាពដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ខ- សម្របសម្រួលរៀបចំរបាយការណ៍ជាតិ វាយតម្លៃស្ថានភាពជីវៈចម្រុះ និងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីនិងផ្តល់អនុសាសន៍ ដើម្បីពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានជីវៈចម្រុះនិងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

គ- ដឹកនាំកិច្ចចរចាជាលក្ខណៈអន្តរជាតិ ដើម្បីបង្ហាញជំហររបស់ព្រះរាជាណាចក្រកម្ពុជាស្តីពីជីវៈចម្រុះទៅកាន់ស្ថាប័នអន្តរជាតិ។

ឃ- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងកម្មវិធីគម្រោងសម្រាប់ការបង្កើតសួនរុក្ខឧទ្យាន សួនភូគព្ភសាស្ត្រ សួនរុក្ខជាតិ តិណាល័យធនាគារពន្ធុ និងទីតាំងអភិរក្សជីវៈចម្រុះ ក្រៅដែនជម្រកធម្មជាតិ ដើម្បីលើកកម្ពស់ការអភិរក្សការសិក្សាស្រាវជ្រាវ ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការអប់រំផ្សព្វផ្សាយបង្កើនចំណេះដឹងដល់សាធារណជន។

ង- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពវិធានការ កម្មវិធីអភិរក្ស អភិវឌ្ឍ កម្មវិធីពាក់ព័ន្ធនឹងការគ្រប់គ្រង កម្មវិធីសិក្សាស្រាវជ្រាវ ការប្រមូលនិងកំណត់អត្តសញ្ញាណ ការស្តារប្រភេទ ការវាយតម្លៃមុខងារ តួនាទីនិងគុណតម្លៃនៃធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការអភិរក្សនិងអភិវឌ្ឍប្រកបដោយចីរភាព។

ច- ផ្តល់យោបល់ ត្រួតពិនិត្យ តាមដាន និងអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព នៃការសិក្សាស្រាវជ្រាវពីធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីឱ្យមានប្រសិទ្ធភាព ដើម្បីជំរុញនិងលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល ការផ្សព្វផ្សាយ និងការផ្លាស់ប្តូរបច្ចេកវិទ្យា។

ឆ- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីស្តីពីការប្រមូលនិងចងក្រងទិន្នន័យធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី សម្រាប់រៀបចំរបាយការណ៍ស្ថានភាពជីវៈចម្រុះជាតិនិងតាមដានស្ថានភាពទាំងនោះ។

ជ- ផ្តល់យោបល់និងត្រួតពិនិត្យនីតិវិធី វិធីសាស្ត្រ និងឯកសារសម្រាប់ការស្រាវជ្រាវ និងផ្ទៀងផ្ទាត់លទ្ធផលនៃការស្រាវជ្រាវមុននឹងបោះពុម្ពផ្សាយជាឯកសារផ្សព្វផ្សាយថ្នាក់ជាតិ ព្រមទាំងសម្របសម្រួលដឹកនាំវេទិកាស្រាវជ្រាវជីវៈចម្រុះជាតិ ដើម្បីពង្រឹងកិច្ចសហការក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវនិងអ្នកផ្សព្វផ្សាយ។

ឈ- ផ្តល់ការគាំទ្រ ជំរុញនវានុវត្តន៍ ប្រមូលចងក្រងទិន្នន័យ សិក្សាស្រាវជ្រាវ អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលទៅដល់ក្រសួងស្ថាប័នពាក់ព័ន្ធ អំពីការគ្រប់គ្រងធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៣- បង្កើតយន្តការនិរន្តរភាពហិរញ្ញប្បទានសម្រាប់ការអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ដើម្បីធានាថា មុខងារ តួនាទី គុណតម្លៃរបស់ជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីត្រូវបានទទួលស្គាល់និងដាក់បញ្ចូលទៅក្នុងកិច្ចចរចាជាមួយនឹងដៃគូជាតិនិងអន្តរជាតិ និងផែនការតាមវិស័យនិងវិស័យឯកជន។

៨- សម្របសម្រួលលើការកៀរគរហិរញ្ញប្បទានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ឱ្យមានប្រសិទ្ធផលនិងប្រសិទ្ធភាពបំផុតដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូជាតិនិងអន្តរជាតិ។

៥- សម្របសម្រួលការងារបច្ចេកទេសជាមួយក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធ ដើម្បីបញ្ជ្រាបនវានុវត្តន៍ ជំរុញ ស្តារ តាមដាន ត្រួតពិនិត្យ និងអនុវត្តឱ្យមានប្រសិទ្ធភាពនូវការគ្រប់គ្រងធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។

៦- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការបញ្ជ្រាបនវានុវត្តន៍ តាមដាន និងត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

៧- ដឹកនាំសម្របសម្រួលរៀបចំគោលដៅនិងសូចនាករជីវៈចម្រុះជាតិ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រជីវៈចម្រុះសកល គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ក្របខណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ដោយឆ្លុះបញ្ចាំងពីស្ថានភាពនិងអាទិភាពជាតិ និងធនធានដែលមាន។

៨- ប្រមូល ផលិត ធ្វើបច្ចុប្បន្នកម្ម គ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីដោយសហការជាមួយក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធ។

**មាត្រា២៩ .- កិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ សហការនិងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីចាំបាច់នៅពេលអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួន។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចចុះកិច្ចព្រមព្រៀងស្តីពីការផលិតនិងការចែករំលែកទិន្នន័យជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចនិងនីតិបុគ្គលដទៃទៀត ដើម្បីបង្កើត ប្រើប្រាស់ និងចែករំលែកទិន្នន័យនិងព័ត៌មានស្តីពីជីវៈចម្រុះនិងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

**មាត្រា៣០ .- ផែនការយុទ្ធសាស្ត្រ**

ក្រសួងស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបញ្ជ្រាបនិងដាក់បញ្ចូលការអភិរក្សជីវៈចម្រុះនិងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ប្រកបដោយនិរន្តរភាព និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយសមភាពនិងសមធម៌ ទៅក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួននិងត្រូវដាក់ចេញ ហើយអនុវត្តគោលការណ៍ណែនាំនិងយន្តការចាំបាច់នានា ដើម្បីធានានិរន្តរភាពនៃធនធានជីវៈចម្រុះនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

**មាត្រា៣១ .- ការអនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងជីវៈចម្រុះ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត និងកម្មវិធីនានា ដើម្បីអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីជីវៈចម្រុះ ពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព ពិធីសារណាហ្គោយ៉ាស្តីពីការប្រមូល និងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយសមភាពនិងសមធម៌ និងលិខិតុបករណ៍អន្តរជាតិនានាពាក់ព័ន្ធនឹងជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលព្រះរាជាណាចក្រកម្ពុជាជាភាគី។

# មាតិកាទី៣
# ជីវសុវត្ថិភាព
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៣២ .- គោលបំណង**

មាតិកានេះ មានគោលបំណងធានាប្រសិទ្ធភាពនៃការអភិរក្សនិងការប្រើប្រាស់ធនធានជីវៈចម្រុះប្រកបដោយនិរន្តរភាព ដោយយកចិត្តទុកដាក់ចំពោះហានិភ័យពីការប្រើប្រាស់និងការបញ្ចេញសពាង្គកាយកែច្នៃរស់ទៅក្នុងបរិស្ថាននិងពីផលប៉ះពាល់ដល់សុខភាពមនុស្សតាមរយៈការអនុវត្តគោលការណ៍ប្រុងប្រយ័ត្នស្តីពីជីវសុវត្ថិភាព ការលើកកម្ពស់ការយល់ដឹងអំពីជីវបច្ចេកវិទ្យាទំនើប និងការទប់ស្កាត់ផលប៉ះពាល់អវិជ្ជមានទៅលើការអភិរក្សជីវៈចម្រុះនិងធនធានធម្មជាតិ។

**មាត្រា៣៣ .- វិសាលភាព**

១- មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពឬប្រតិបត្តិការដែលពាក់ព័ន្ធនឹងសពាង្គកាយកែច្នៃរស់ដូចជា ការនាំចូល ការនាំចេញ ការស្តុកទុក ការប្រើប្រាស់ក្នុងព្រំដែនកំណត់ ការបញ្ចូលទៅក្នុងបរិស្ថាន ការប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារឬចំណីសត្វ និងការកែច្នៃក្រោមរូបភាពផ្សេងៗទៀត។

២- សកម្មភាពឬប្រតិបត្តិការដូចមានចែងក្នុងកថាខណ្ឌទី១ មិនរួមបញ្ចូលការប្រើប្រាស់នូវសពាង្គកាយកែច្នៃរស់សម្រាប់ធ្វើជាឱសថទេ។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣៤ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសមត្ថកិច្ចត្រួតពិនិត្យរាល់សកម្មភាពនិង/ឬប្រតិបត្តិការដែលពាក់ព័ន្ធនឹងសពាង្គកាយកែច្នៃរស់។

**មាត្រា៣៥ .- តួនាទីនិងភារកិច្ចក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាស្ថាប័នបង្គោលជាតិទទួលបន្ទុកវិស័យគ្រប់គ្រងជីវសុវត្ថិភាព ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងជីវសុវត្ថិភាព។

ខ- ពិនិត្យនិងសម្រេចលើសំណើសុំនាំចូលនិងនាំចេញសពាង្គកាយកែច្នៃរស់។

គ- ធ្វើជាស្ថាប័នបង្គោលជាតិ ក្នុងការធ្វើទំនាក់ទំនងជំបូងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងលេខាធិការដ្ឋាននៃអនុសញ្ញាស្តីពីជីវៈចម្រុះ។

ឃ- ទទួលខុសត្រូវក្នុងការជូនដំណឹងទាន់ពេលវេលាទៅប្រទេសដទៃទៀត និងអង្គការអន្តរជាតិព្រមទាំងមណ្ឌលចែកចាយជីវសុវត្ថិភាពដែលពាក់ព័ន្ធទាំងឡាយ ក្នុងករណីមានហេតុការណ៍ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបណ្តាលមកពីចលនាឆ្លងដែនណាមួយដោយអចេតនានៃសពាង្គកាយកែច្នៃរស់។

ង- ជូនដំណឹងនិងផ្សព្វផ្សាយព័ត៌មានទាន់ពេលវេលាតាមរយៈយន្តការសម្របសម្រួល និងចែករំលែកព័ត៌មានស្តីពីជីវសុវត្ថិភាព។

**មាត្រា៣៦ .- កិច្ចសហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក- ត្រួតពិនិត្យលើរាល់សកម្មភាពនិង/ឬប្រតិបត្តិការពាក់ព័ន្ធជីវសុវត្ថិភាព។

ខ- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើពាក្យស្នើសុំវាយតម្លៃហានិភ័យនៃសកម្មភាពនិង/ឬប្រតិបត្តិការដែលពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់។

**មាត្រា៣៧ .- ការវាយតម្លៃហានិភ័យជាមុន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធានាឱ្យមានការវាយតម្លៃហានិភ័យដ៏សមស្របជាមុននៃរាល់សកម្មភាពនិង/ឬប្រតិបត្តិការដែលពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់ ដូចបានបញ្ញត្តក្នុងក្រមនេះ។

២- ម្ចាស់សំណើមានកាតព្វកិច្ចធ្វើការវាយតម្លៃហានិភ័យនៃសកម្មភាពនិង/ឬប្រតិបត្តិការដែលពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់របស់ខ្លួន។ រាល់ការចំណាយក្នុងការអនុវត្តកាតព្វកិច្ចនេះ ជាបន្ទុកទាំងស្រុងរបស់ម្ចាស់សំណើ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ពិនិត្យនិងសម្រេចលើសំណើសុំបន្ទាប់ពីទទួលបានរាល់ឯកសារពាក់ព័ន្ធ។

## ជំពូកទី៣
## សរីរាង្គកាយកែច្នៃរស់
### ផ្នែកទី១
### ការនាំចូលនិងនាំចេញសរីរាង្គកាយកែច្នៃរស់

**មាត្រា៣៨ .- នីតិវិធីមុននឹងនាំចូលសរីរាង្គកាយកែច្នៃរស់**

១- បុគ្គលដែលមានបំណងនាំចូលសរីរាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងទទួលបានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមុននឹងសុំការអនុញ្ញាតពីក្រសួងស្ថាប័នមានសមត្ថកិច្ចនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- នីតិវិធីក្នុងការស្នើសុំនិងលក្ខខណ្ឌតម្រូវក្នុងការជូនដំណឹងអំពីការស្នើសុំការអនុញ្ញាតនាំចូលលើកទីមួយនូវសរីរាង្គកាយកែច្នៃរស់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៩ .- ការនាំចូលសម្រាប់ការប្រើប្រាស់ក្នុងព្រំដែនកំណត់**

ការអនុញ្ញាតឱ្យមានការនាំចូលជាលើកទីមួយនូវសរីរាង្គកាយកែច្នៃរស់ មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ត្រូវធ្វើការវាយតម្លៃហានិភ័យនិងទទួលបានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បន្ទាប់ពីបានធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤០ .- ការនាំចូលសម្រាប់ការបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា**

ការនាំចូលសរីរាង្គកាយកែច្នៃរស់មកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនាត្រូវធ្វើការវាយតម្លៃហានិភ័យ និងទទួលបានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៤១ ._ ការនាំចូលសម្រាប់ការប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃ**

១- ការនាំចូលសពាង្គកាយកែច្នៃរស់លើកទីមួយមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃត្រូវធ្វើការវាយតម្លៃហានិភ័យនិងទទួលបានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មុននឹងស្នើសុំការអនុញ្ញាតនាំចូលពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

២- បុគ្គលដែលមានបំណងស្នើសុំការអនុញ្ញាតនាំចូលសពាង្គកាយកែច្នៃរស់តាមកថាខណ្ឌទី១ ខាងលើនេះត្រូវផ្តល់ជូនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិពិនិត្យនូវវិញ្ញាបនបត្រជាលាយលក្ខណ៍អក្សរពីក្រសួងស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនាំចេញ ដោយបញ្ជាក់ពីភាពត្រឹមត្រូវនៃព័ត៌មានទាក់ទងនឹងសពាង្គកាយកែច្នៃរស់ដែលត្រូវនាំចូល។

**មាត្រា៤២ ._ នីតិវិធីសម្រេចចិត្តសម្រាប់ការនាំចូល**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីយោបល់ថាយល់ព្រមជាមុនឬពុំយល់ព្រមទៅម្ចាស់សំណើវិញក្នុងរយៈពេលយ៉ាងយូរ៦៥(ហុកសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចផ្តល់ការឯកភាពដោយមានឬគ្មានលក្ខខណ្ឌ ស្នើសុំព័ត៌មានបន្ថែមឬបដិសេធចំពោះសំណើ បន្ទាប់ពីទទួលបានលទ្ធផលនៃការវាយតម្លៃហានិភ័យនិងឯកសារតម្រូវចាំបាច់ផ្សេងទៀត។

៣- ក្នុងរយៈពេលយ៉ាងយូរ១៨០(មួយរយប៉ែតសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើវិញ និងទៅបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាពស្តីពីសេចក្តីសម្រេចរបស់ខ្លួន។

៤- នៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បានសម្រេចយល់ព្រមចំពោះសពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃនោះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវជូនដំណឹងទៅសមាជិកទាំងឡាយនៃពិធីសារកាតាហេ្សណាតាមរយៈមណ្ឌលចែកចាយព័ត៌មានជីវសុវត្ថិភាពក្នុងរយៈពេល១០(ដប់)ថ្ងៃ។

៥- លិខិតឯកភាពជាគោលការណ៍របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវភ្ជាប់ការអនុញ្ញាតនាំចូលសពាង្គកាយកែច្នៃរស់។

៦- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខខណ្ឌនៃការសម្រេចចិត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤៣ ._ នីតិវិធីមុននឹងនាំចេញសពាង្គកាយកែច្នៃរស់**

១- បុគ្គលដែលមានបំណងនាំចេញនូវសពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅស្ថាប័នមានសមត្ថកិច្ចនៃប្រទេសដែលត្រូវនាំចូល មុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញពីក្រសួងស្ថាប័នមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

២- ក្រសួងស្ថាប័នមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតនាំចេញសពាង្គកាយកែច្នៃរស់ ពីព្រះរាជាណាចក្រកម្ពុជាបន្ទាប់ពីទទួលបានការឯកភាពជាលាយលក្ខណ៍អក្សរពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសនាំចូល។ លិខិតឯកភាព

ពីភាគីនាំចូលត្រូវភ្ជាប់ជាមួយនូវលិខិតអនុញ្ញាតនាំចេញ និងឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់និងការលើកដាក់នាំចេញ។

**មាត្រា៤៤ .- លិខិតបញ្ជាក់នាំចេញ**

អ្នកនាំចេញសពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា ត្រូវមានលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិពីភាពត្រឹមត្រូវនៃរាល់ព័ត៌មាន ដែលខ្លួនបានផ្តល់ទាក់ទងនឹងសពាង្គកាយកែច្នៃរស់ដែលត្រូវនាំចេញ។ លិខិតបញ្ជាក់នេះត្រូវភ្ជាប់ជាមួយលិខិតអនុញ្ញាតនាំចេញនិង/ឬឯកសារដទៃទៀតទាក់ទងនឹងការវេចខ្ចប់និងការលើកដាក់នាំចេញ។

**មាត្រា៤៥ .- ការរៀបចំឯកសារ**

១- លើកលែងតែមានបទប្បញ្ញត្តិច្បាប់ចែងដោយឡែកពីបុគ្គលដែលមានបំណងនាំចូលឬនាំចេញសពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលបំណងណាមួយ ត្រូវផ្តល់ឯកសារភ្ជាប់ជាមួយដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីអត្តសញ្ញាណសពាង្គកាយកែច្នៃរស់នោះ ពិតជាសពាង្គកាយកែច្នៃរស់ពិតប្រាកដមែនព្រមទាំងបញ្ជាក់អំពីលក្ខខណ្ឌតម្រូវសម្រាប់សុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក។

២- ឯកសារទាំងនេះត្រូវភ្ជាប់ជាមួយទំនិញក្នុងកំលុងពេលនៃការបំលាស់ទីឆ្លងដែននិងការដឹកជញ្ជូនទៅកាន់ប្រទេសចូល។

៣- ការនាំចូលឬការនាំចេញសពាង្គកាយកែច្នៃរស់ពីព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់ជាមួយនូវលក្ខខណ្ឌដូចខាងក្រោម៖

ក- ចំពោះសពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ផ្ទាល់ជាម្ហូបអាហារ ជាចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃ ត្រូវបញ្ជាក់ឱ្យបានច្បាស់ថាទំនិញទាំងនេះអាចផ្ទុកសពាង្គកាយកែច្នៃរស់ និងមិនមានបំណងបញ្ចូលទៅក្នុងបរិស្ថានដោយចេតនាឡើយ។

ខ- ចំពោះសពាង្គកាយកែច្នៃរស់ ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបញ្ជាក់ឱ្យច្បាស់អំពីអត្តសញ្ញាណ លក្ខណៈពាក់ព័ន្ធ លក្ខខណ្ឌតម្រូវសម្រាប់សុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក និងត្រូវបញ្ជាក់ផងដែរអំពីមន្ត្រីទំនាក់ទំនងដើម្បីទទួលព័ត៌មានបន្ថែម ព្រមទាំងបញ្ជាក់ថាការដឹកជញ្ជូនឆ្លងដែនសពាង្គកាយកែច្នៃរស់ ស្របតាមបទប្បញ្ញត្តិពិធីសារកាតាហេហ្សណាសម្រាប់អ្នកនាំចេញ។

គ- ចំពោះសពាង្គកាយកែច្នៃរស់ ដើម្បីប្រើប្រាស់ក្នុងព្រំដែនកំណត់ត្រូវកំណត់ឱ្យច្បាស់ថាជាសពាង្គកាយកែច្នៃរស់និងបញ្ជាក់ឱ្យដឹងពីលក្ខខណ្ឌតម្រូវសម្រាប់សុវត្ថិភាពក្នុងការវេចខ្ចប់ ការលើកដាក់ ការដឹកជញ្ជូន ការប្រើប្រាស់ និងការរក្សាទុក និងត្រូវបញ្ជាក់ផងដែរអំពីមន្ត្រីទំនាក់ទំនងដើម្បីទទួលព័ត៌មានបន្ថែម ក្នុងនោះត្រូវរៀបរាប់ពីឈ្មោះ អាសយដ្ឋានរបស់បុគ្គល និងស្ថាប័នដែលត្រូវប្រគល់សពាង្គកាយកែច្នៃរស់។

## ផ្នែកទី២

## ការទទួលខុសត្រូវចំពោះការខូចខាតនិងវិធានការឆ្លើយតប

**មាត្រា៤៦ .- កាតព្វកិច្ចដែលត្រូវបំពេញដោយបុគ្គលដែលបង្កផលប៉ះពាល់ឬការខូចខាត**

១- បុគ្គលដែលបានធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសពាង្គកាយកែច្នៃរស់ និងដែលបានបង្កផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម សេដ្ឋកិច្ច ជីវៈចម្រុះ សុខភាពមនុស្ស ឬទ្រព្យសម្បត្តិពីសកម្មភាពឬប្រតិបត្តិការរបស់ខ្លួន ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ជូនដំណឹងជាបន្ទាន់អំពីផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ខ- ធ្វើការវាយតម្លៃផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ចដំបូង។

គ- ចាត់វិធានការឆ្លើយតបសមរម្យដំបូង។

២- កាតព្វកិច្ចដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវបំពេញស្របតាមការណែនាំពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៤៧ .- ស្វ័យចំណាត់ការរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

១- បន្ទាប់ពីទទួលបានដំណឹងអំពីផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដូចមានចែងក្នុងមាត្រា៤៦(កាតព្វកិច្ចដែលត្រូវបំពេញដោយបុគ្គលដែលបង្កផលប៉ះពាល់ឬការខូចខាត)នៃក្រមនេះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចចាត់នូវរាល់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់ឬការខូចខាតទាំងនោះ ក្នុងករណីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ពិនិត្យឃើញថា វិធានការឆ្លើយតបដំបូងរបស់បុគ្គលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤៦(កាតព្វកិច្ចដែលត្រូវបំពេញដោយបុគ្គលដែលបង្កផលប៉ះពាល់ឬការខូចខាត)នៃក្រមនេះ មិនមានលក្ខណៈសមរម្យ។

២- រាល់ការចំណាយពាក់ព័ន្ធនឹងវិធានការចាំបាច់ខាងលើនេះ គឺជាបន្ទុកទាំងស្រុងរបស់បុគ្គលដែលបានធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសំណង់ការកែច្នៃរស់ និងដែលបានបង្កផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**មាត្រា៤៨ .- ការវាយតម្លៃផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការវាយតម្លៃផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលបង្កឡើងដោយបុគ្គលដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា៤៦(កាតព្វកិច្ចដែលត្រូវបំពេញដោយបុគ្គលដែលបង្កផលប៉ះពាល់ឬការខូចខាត)នៃក្រមនេះ។

**មាត្រា៤៩ .- ការទទួលខុសត្រូវចំពោះផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច**

បុគ្គលដែលបានធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសំណង់ការកែច្នៃរស់ ដែលបានបង្កផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម សេដ្ឋកិច្ច ជីវៈចម្រុះ សុខភាពមនុស្ស ឬទ្រព្យសម្បត្តិពីសកម្មភាពឬប្រតិបត្តិការរបស់ខ្លួន ត្រូវទទួលខុសត្រូវទាំងស្រុងទៅលើផលប៉ះពាល់ឬការខូចខាតទាំងនោះ។

**មាត្រា៥០ .- ការកំណត់អត្តសញ្ញាណបុគ្គលដែលត្រូវទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវដឹកនាំនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណបុគ្គល ដូចមានចែងក្នុងមាត្រា៤៩(ការទទួលខុសត្រូវចំពោះផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច)នៃក្រមនេះ។

**មាត្រា៥១ .- កិច្ចសហការគ្រប់គ្រងផលប៉ះពាល់ឬការខូចខាតក្នុងករណីប្រធានសក្តិ**

ក្នុងករណីប្រធានសក្តិ ដែលបណ្តាលឱ្យមានផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដែលកើតចេញពីសំណង់ការកែច្នៃរស់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធត្រូវសហការចាត់រាល់វិធានការដើម្បីគ្រប់គ្រង ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់ឬការខូចខាតទាំងនោះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៥២ ._ ការផ្តល់ព័ត៌មានអំពីការខូចខាតបរិស្ថាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវជូនដំណឹងជាសាធារណៈពីផលប៉ះពាល់ជាអវិជ្ជមាន ដែលអាចកើតមាននាពេលអនាគតបណ្តាលមកពីសំណង់ក្លាយកែច្នៃរស់ តែក្នុងករណីដំណឹងនេះមិនបង្កចលាចលដល់សណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខសង្គម។

## មាតិកាទី៤

## ការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៥៣ ._ គោលបំណង**

មាតិកានេះ មានគោលបំណងធានានិរន្តរភាពនិងការអភិរក្សជីវៈចម្រុះ តាមរយៈការបែងចែកផលប្រយោជន៍ដោយសមភាពនិងសមធម៌ ពីការប្រមូលនិងប្រើប្រាស់ធនធានពន្ធុ និស្សន្ទវត្ថុរបស់ធនធានពន្ធុ ឬចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ។

**មាត្រា៥៤ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះការប្រមូលធនធានពន្ធុ និស្សន្ទវត្ថុរបស់ធនធានពន្ធុ និងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ ដែលមានប្រភពដើមឬកំពុងមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬបានទទួលយកដោយព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលណាម្នាក់ដែលស្ថិតក្រោមយុត្តាធិការរបស់ខ្លួនសម្រាប់គោលបំណងនៃការប្រើប្រាស់ធនធានពន្ធុនិងចំណេះដឹងជាប្រពៃណីពាក់ព័ន្ធ។

### ជំពូកទី២

### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥៥ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសមត្ថកិច្ចគ្រប់គ្រងលើការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយសមភាពនិងសមធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥៦ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ គឺជាស្ថាប័នបង្គោលជាតិដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំបង្កើតនិងអនុវត្តគោលនយោបាយ ក្របខ័ណ្ឌការងារ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីពាក់ព័ន្ធនឹងការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ ដើម្បីធានានូវការអភិរក្សនិងការប្រើប្រាស់ធនធានពន្ធុប្រកបដោយនិរន្តរភាព។

ខ- រៀបចំបង្កើតនិងអនុវត្តយន្តការ បែបបទ នីតិវិធី និងវិធានចាំបាច់ ពាក់ព័ន្ធនឹងការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ។

គ- ដឹកនាំនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្តនានាដែលទាក់ទងនឹងការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុដោយសមភាពនិងសមធម៌។

ឃ- លើកកម្ពស់ការកសាងសមត្ថភាព ការសិក្សាស្រាវជ្រាវ ការផ្ទេរបច្ចេកវិទ្យា និងចំណេះដឹងរបស់សាធារណជនពាក់ព័ន្ធនឹងការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ។

២- យន្តការ បែបបទ និងនីតិវិធីនៃការប្រមូលនិងការបែងចែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ និងទោសប្បញ្ញត្តិចំពោះបទល្មើសពាក់ព័ន្ធ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។

# មាតិកាទី៥

# ការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៥៧ .- គោលបំណង**

មាតិកានេះ មានគោលបំណងធានាការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីគាំទ្រដល់ការអភិរក្សធនធាន ជីវៈចម្រុះដោយនិរន្តរភាព និងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥៨ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីទាំងក្នុងនិងក្រៅតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥៩ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវគ្រប់គ្រងលើការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

**មាត្រា៦០ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំបង្កើតនិងអនុវត្តគោលនយោបាយ ក្របខ័ណ្ឌការងារ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ខ- រៀបចំគោលការណ៍ លិខិតបទដ្ឋានគតិយុត្ត យន្តការ បែបបទ នីតិវិធីនិងលក្ខខណ្ឌតម្រូវ ដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

គ- សម្របសម្រួល ប្រមូល បែងចែក និងគ្រប់គ្រងលើដំណើរការអនុវត្តនៃការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី រួមទាំងការចរចាលើកិច្ចសន្យានិងការដោះស្រាយវិវាទពាក់ព័ន្ធ។

**មាត្រា៦១ .- គោលការណ៍ជាមូលដ្ឋាននៃការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី**

គោលការណ៍ជាមូលដ្ឋាននៃការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បី៖

ក- ធានាឱ្យមានការចូលរួមជាសាធារណៈក្នុងកិច្ចគាំពារនិងអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ខ- ធានាឱ្យមានការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៦២ .– ប្រភេទនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី**

ប្រភេទនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី មានជាអាទិ៍៖

ក- សេវាផ្គត់ផ្គង់៖ អាហារសម្រាប់មនុស្សសត្វ ផ្តល់ទឹកសាប ឱសថ និងវត្ថុធាតុដើម។

ខ- សេវានិយ័តកម្ម៖ រួមបញ្ចូលផលប្រយោជន៍ផ្សេងៗដែលទទួលបានពីដំណើរនិយ័តកម្មនៃប្រព័ន្ធអេកូឡូស៊ី ដូចជាការផលិតខ្យល់បរិសុទ្ធ ការចូលរួមក្នុងដំណើរលម្អងរបស់រុក្ខជាតិ។

គ- សេវាវប្បធម៌៖ សំដៅផលប្រយោជន៍ផ្សេងៗក្រៅពីវត្ថុធាតុដើម ដែលមនុស្សទទួលបានពីប្រព័ន្ធអេកូឡូស៊ី មានជាអាទិ៍ ភាពសម្បូរនៃគំនិត ទស្សនាទាន ការកម្សាន្ត និងសោភណភាព។

ឃ- សេវាគាំទ្រ៖ ជាភាពចាំបាច់នានា ដែលមនុស្ស រុក្ខជាតិ និងសត្វត្រូវការ មានជាអាទិ៍ ដំណើរស្នើសំយោគរបស់រុក្ខជាតិនិងវដ្តនៃការកកើតដីជាតិដី។

**មាត្រា៦៣ .– ការប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី**

១- បុគ្គលដែលប្រើប្រាស់សេវាកម្មប្រព័ន្ធអេកូឡូស៊ីត្រូវបង់កម្រៃសេវា ក្នុងករណីកាតព្វកិច្ចនេះត្រូវបានតម្រូវដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- កម្រៃសេវាដូចមានចែងក្នុងកថាខណ្ឌទី១ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣- លក្ខខណ្ឌនិងនីតិវិធីនៃការបង់កម្រៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## មាតិកាទី៦
## ការប្រែប្រួលអាកាសធាតុ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៦៤ .– គោលបំណង**

មាតិកានេះ មានគោលបំណងពង្រឹងនិងធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពបន្សាំនិងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុនិងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយ៖

ក- វាយតម្លៃភាពងាយរងគ្រោះនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ខ- ធ្វើបញ្ជីសារពើភណ្ឌនិងការគណនាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

គ- កៀរគរហិរញ្ញប្បទានអាកាសធាតុ។

**មាត្រា៦៥ .– វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់បទដ្ឋានគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៦៦ .– ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាសេនាធិការរាជរដ្ឋាភិបាលក្នុងការតាមដានការអនុវត្តលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៦៧.-** តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំនិងសម្របសម្រួលទស្សនវិស័យ ចក្ខុវិស័យ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។

ខ- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

គ- រៀបចំនិងផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ឃ- ដឹកនាំ សម្របសម្រួល និងអនុវត្តការងារក្នុងនាមជាស្ថាប័នបង្គោលនៃលិខិតុបករណ៍អន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ង- ពង្រឹងនិងលើកកម្ពស់កិច្ចសហការពាក់ព័ន្ធនឹងការរៀបចំ និងតាមដានការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ច- កៀរគរធនធាននិងជំនួយបច្ចេកទេសសម្រាប់ការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ឆ- គ្រប់គ្រង សម្របសម្រួល តាមដាន និងវាយតម្លៃ ការអនុវត្តផែនការសកម្មភាព កម្មវិធី និងគម្រោងនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ជ- ដឹកនាំ សម្របសម្រួល និងអនុវត្តផែនការសកម្មភាព ដើម្បីផ្តល់ព័ត៌មានវិទ្យាសាស្ត្រសម្រាប់គាំទ្រដល់ការរៀបចំនិងវាយតម្លៃការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ឈ- ដឹកនាំ សម្របសម្រួល និងរៀបចំបង្កើតប្រព័ន្ធទិន្នន័យ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវ និងសារមន្ទីរដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

## ជំពូកទី៣
## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
### ផ្នែកទី១
### គោលនយោបាយ យុទ្ធសាស្ត្រ និង
### ផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

**មាត្រា៦៨.-** ការធ្វើបច្ចុប្បន្នកម្មនិងការសម្របសម្រួលលើការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំធ្វើបច្ចុប្បន្នកម្មនិងសម្របសម្រួលលើការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ និងលិខិតុបករណ៍អន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុនិងការអភិវឌ្ឍប្រកបដោយចីរភាព ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៦៩.-** ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនិងថ្នាក់ក្រោមជាតិនិងយុទ្ធសាស្ត្រតាមវិស័យ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំផែនការ ត្រូវយកចិត្តទុកដាក់រៀបចំបញ្ជ្រាបនិងដាក់បញ្ចូលការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនិងថ្នាក់ក្រោមជាតិ និងយុទ្ធសាស្ត្រតាមវិស័យរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**មាត្រា៧០ ._ ការរៀបចំផែនការសកម្មភាពនិងផែនការថវិកាតាមវិស័យ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវយកចិត្តទុកដាក់ រៀបចំ កំណត់ និងដាក់បញ្ចូលការពិចារណាអំពីសកម្មភាព ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការសកម្មភាពនិងផែនការថវិកាតាមវិស័យ។

២- ការរៀបចំកំណត់និងដាក់បញ្ចូល ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងលិខិតុបករណ៍អន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៧១ ._ ការរៀបចំផែនការអភិវឌ្ឍនិងផែនការវិនិយោគ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំផែនការ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់រៀបចំ កំណត់ និងដាក់បញ្ចូលការពិចារណាអំពីផលប៉ះពាល់និងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់បញ្ជ្រាបនិងដាក់បញ្ចូលការពិចារណាអំពីផលប៉ះពាល់និងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគ្រប់ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។

## ផ្នែកទី២

## ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

**មាត្រា៧២ ._ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ**

ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

ក- វិធានការពាក់ព័ន្ធសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ មានជាអាទិ៍៖

- លើកកម្ពស់និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពថាមពល
- លើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់ថាមពលកកើតឡើងវិញ
- លើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់ ការដឹកជញ្ជូនដែលសន្សំសំចៃថាមពលឥន្ធនៈនិងបញ្ចេញកាបូនតិច
- លើកកម្ពស់ការស្តារ ការអភិរក្ស និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដើម្បីការពារអាងស្រូបកាបូននិងបង្កើនសមត្ថភាពស្រូបយកឧស្ម័នផ្ទះកញ្ចក់
- ជំរុញនិងកៀរគរការគាំទ្រការអនុវត្តយន្តការអភិវឌ្ឍស្អាត សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សមស្របថ្នាក់ជាតិ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងការរេចរឹលព្រៃឈើ ក៏ដូចជាការអភិរក្ស ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងកំណើនផលស្តុកកាបូនក្នុងព្រៃឈើ(រេដបូក) និងសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នានា
- លើកកម្ពស់ការយល់ដឹងនិងជំរុញការអនុវត្តទម្លាប់ការគ្រប់គ្រងការប្រើប្រាស់ដីឱ្យបានត្រឹមត្រូវដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។

ខ- វិធានការពាក់ព័ន្ធសម្រាប់ការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖

- វាយតម្លៃភាពងាយរងគ្រោះនៃប្រព័ន្ធជីវសាស្ត្រ សង្គម និងសេដ្ឋកិច្ច ចំពោះការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ វិស័យដែលងាយទទួលរងផលប៉ះពាល់ពីបញ្ហាអាកាសធាតុ និងតំបន់ភូមិសាស្ត្រដែលងាយទទួលរងគ្រោះមហន្តរាយដែលទាក់ទងនឹងអាកាសធាតុ និងកំណត់កាលានុវត្តភាពសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- រៀបចំ និងកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលមានភាពធន់ទៅនឹងអាកាសធាតុនិងដែលបញ្ចេញកាបូនតិច មានជាអាទិ៍ វិស័យកសិកម្ម ជលផល ដឹកជញ្ជូន និងថាមពលឧស្សាហកម្ម
- រៀបចំ និងអនុវត្តវិធានការគ្រប់គ្រង តំបន់ការពារធម្មជាតិ ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធប្រកាសអាសន្ន និងការផ្សព្វផ្សាយព័ត៌មានអាកាសធាតុទាន់ពេលវេលា និងលើកកម្ពស់ទម្លាប់នៃការរស់នៅប្រកបដោយចីរភាព ដែលបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

គ- ការកៀរគរ និងការផ្តល់ហិរញ្ញប្បទាន ការពង្រឹងសមត្ថភាព ការលើកកម្ពស់ការយល់ដឹង និងការផ្ទេរបច្ចេកវិទ្យា មានជាអាទិ៍៖

- កៀរគរហិរញ្ញវត្ថុអាកាសធាតុពីដៃគូអភិវឌ្ឍ និងមូលនិធិអាកាសធាតុពាក់ព័ន្ធនានា
- ពង្រឹងសមត្ថភាពបច្ចេកទេសនិងស្ថាប័ន ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ
- ពង្រឹងចំណេះដឹងអំពីទម្លាប់ និងបច្ចេកវិទ្យានានាក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា
- លើកកម្ពស់ការសិក្សាស្រាវជ្រាវ ការអប់រំ ការផ្ទេរបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការអន្តរជាតិលើការងារប្រែប្រួលអាកាសធាតុ
- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រែប្រួលអាកាសធាតុ។

## ផ្នែកទី៣
## ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទាននិងការកៀរគរហិរញ្ញប្បទាន

### មាត្រា៧៣ ._ ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទានសម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

១- ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវដាក់បញ្ចូលនូវ៖

ក- ការវិភាគអំពីតម្រូវការហិរញ្ញប្បទាន។

ខ- យុទ្ធសាស្ត្រក្នុងការបំពេញតម្រូវការហិរញ្ញប្បទាន ដែលប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងនិងក្រៅប្រទេស។

គ- វិធានការនៃការកសាងសមត្ថភាព។

ឃ- កំណែទម្រង់ស្ថាប័នឬយន្តការហិរញ្ញវត្ថុ ដើម្បីធ្វើការកៀរគរនិងគ្រប់គ្រងហិរញ្ញវត្ថុទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។

២- ការរៀបចំក្របខ័ណ្ឌហិរញ្ញប្បទាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### មាត្រា៧៤ ._ ការកៀរគរហិរញ្ញប្បទានពីក្រៅប្រទេសសម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសមត្ថកិច្ចធ្វើការសម្របសម្រួលដើម្បីកៀរគរហិរញ្ញប្បទានពីក្រៅប្រទេសសម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

២- សំណើសុំហិរញ្ញប្បទានពីក្រៅប្រទេស សម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ត្រូវដាក់មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ពិនិត្យនិងសម្រេច។

៣- នីតិវិធីនៃការពិនិត្យនិងសម្រេចលើសំណើសុំហិរញ្ញប្បទាន ដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៥ .-** ការកៀរគរហិរញ្ញប្បទានក្នុងប្រទេសសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការកៀរគរហិរញ្ញប្បទានក្នុងប្រទេស សម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដោយស្នើឱ្យក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្វើការពិចារណាលើសំណើសុំហិរញ្ញប្បទានរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៧៦ .-** ការផ្តល់របាយការណ៍ប្រើប្រាស់ហិរញ្ញប្បទានសម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឬម្ចាស់គម្រោង ត្រូវផ្តល់របាយការណ៍ប្រើប្រាស់ហិរញ្ញប្បទានសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុតាមការស្នើសុំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីប្រមូលព័ត៌មានទាក់ទងទៅនឹងការប្រើប្រាស់ហិរញ្ញប្បទានសម្រាប់អនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

## ផ្នែកទី៤
## ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

**មាត្រា៧៧ .-** គោលបំណងនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មានគោលបំណងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម បរិស្ថាន និងសុខុមាលភាពប្រជាពលរដ្ឋ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាពាក់ព័ន្ធនឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងអនុវត្តឱ្យបានសមស្របតាមលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៧៨ .-** ការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

## ជំពូកទី៤
## ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុនិងការរៀបចំរបាយការណ៍

## ផ្នែកទី១
## ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

**មាត្រា៧៩ .-** ការគ្រប់គ្រងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវ៖

ក- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំស្តីពីការផលិត និងការគ្រប់គ្រងទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ខ- រៀបចំនិងគ្រប់គ្រងប្រព័ន្ធព័ត៌មានដែលសាធារណជនអាចស្វែងរកបាន ដើម្បីប្រមូលផ្តុំព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ដែលផលិតដោយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងព័ត៌មានពីប្រភពផ្សេងទៀត។

២- ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិដើម្បីធ្វើបច្ចុប្បន្នកម្មស្តីពីការគ្រប់គ្រង និងដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធទៅនឹងវិស័យរបស់ខ្លួន។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចចុះកិច្ចព្រមព្រៀងស្តីពីការផលិត និងការចែករំលែកទិន្នន័យជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និង/ឬវិស័យឯកជន ដើម្បីពង្រឹងនិងបង្កើនសិទ្ធិក្នុងការទទួលបានទិន្នន័យនិងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ដែលពាក់ព័ន្ធនឹងការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ផ្នែកទី២
## ការរៀបចំរបាយការណ៍

**មាត្រា៨០ ._ ការរៀបចំរបាយការណ៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំរបាយការណ៍និងអាចរៀបចំផែនការនិងយុទ្ធសាស្ត្រដើម្បីអនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដូចខាងក្រោម៖

ក- របាយការណ៍ជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ខ- ផែនការការរួមចំណែករបស់ជាតិដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។

គ- របាយការណ៍តម្លាភាពស្តីពីការប្រែប្រួលអាកាសធាតុ។

ឃ- យុទ្ធសាស្ត្រអភិវឌ្ឍរយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន។

ង- របាយការណ៍អំពីការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

ច- របាយការណ៍ផ្សេងទៀតក្នុងករណីចាំបាច់។

**មាត្រា៨១ ._ ការរៀបចំរបាយការណ៍ជាតិស្តីពីការប្រែប្រួលអាកាសធាតុ**

របាយការណ៍ជាតិស្តីពីការប្រែប្រួលអាកាសធាតុត្រូវរៀបចំរៀងរាល់៤(បួន)ឆ្នាំម្តង ដើម្បីដាក់ជូនទៅលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

**មាត្រា៨២ ._ ផែនការរួមចំណែករបស់ជាតិដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ**

ផែនការរួមចំណែករបស់ជាតិដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុអាចរៀបចំរៀងរាល់៥(ប្រាំ)ឆ្នាំម្តង ដើម្បីដាក់ជូនទៅលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

**មាត្រា៨៣ ._ ការរៀបចំរបាយការណ៍តម្លាភាពស្តីពីការប្រែប្រួលអាកាសធាតុ**

របាយការណ៍តម្លាភាពស្តីពីការប្រែប្រួលអាកាសធាតុត្រូវរៀបចំ២(ពីរ)ឆ្នាំម្តង ដើម្បីដាក់ជូនទៅលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

**មាត្រា៨៤ ._ ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍរយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន**

យុទ្ធសាស្ត្រអភិវឌ្ឍរយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន អាចរៀបចំឡើងដើម្បីបង្ហាញពីការប្តេជ្ញាចិត្តក្នុងការរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា៨៥ .- ការរៀបចំរបាយការណ៍អំពីការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ**

១- ដើម្បីតាមដាន វាយតម្លៃ ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំរបាយការណ៍អំពីការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។

២- របាយការណ៍ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវដាក់បញ្ចូលនូវ៖

ក- សូចនាករពាក់ព័ន្ធសម្រាប់ក្របខ័ណ្ឌវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ស្តីពីការប្រែប្រួលអាកាសធាតុ។

ខ- ព័ត៌មានអំពី ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ ការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ និងតាមវិស័យ។

គ- ព័ត៌មានផ្សេងទៀតក្នុងករណីចាំបាច់។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសិទ្ធិស្នើសុំពីក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនូវរបាយការណ៍អំពីការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនេះ ដើម្បីប្រមូលផ្តុំព័ត៌មានសម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាលនិងរៀបចំរបាយការណ៍សម្រាប់ដាក់ជូនទៅលេខាធិការដ្ឋាននៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងដាក់ផ្សព្វផ្សាយឱ្យសាធារណជនអាចស្វែងយល់ និងចូលរួមអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

## មាតិកាទី៧
## ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៨៦ .- គោលបំណង**

មាតិកានេះ មានគោលបំណងលើកកម្ពស់ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព ដើម្បីចូលរួមលើកកម្ពស់ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព កាត់បន្ថយផលប៉ះពាល់បរិស្ថាន ប្រព័ន្ធអេកូឡូស៊ី និងសុខភាពសាធារណៈ ឈានទៅរកអភិក្រមសេដ្ឋកិច្ចវិលជុំ និងសេដ្ឋកិច្ចបៃតងក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨៧ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព មានជាអាទិ៍ លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព ការវាយតម្លៃប្រសិទ្ធផលធនធាន ការទទួលខុសត្រូវរបស់ផលិតករ ការដាក់ស្លាកសញ្ញាមេត្រីបរិស្ថាន ការផ្ទៀងផ្ទាត់ និងការវាយតម្លៃបច្ចេកវិទ្យាមេត្រីបរិស្ថាន។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៨៨ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវតាមដានការអនុវត្តការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៨៩ .‒ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ខ- រៀបចំផែនការគ្រប់គ្រងការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព។

គ- ចូលរួមសហការរៀបចំគោលការណ៍ណែនាំបច្ចេកទេសស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ឃ- រៀបចំកំណត់លក្ខណវិនិច្ឆ័យ ស្តង់ដារ និងបច្ចេកវិទ្យាមេត្រីបរិស្ថាន។

ង- ពិនិត្យនិងសម្រេចលើពាក្យស្នើសុំដាក់ស្លាកសញ្ញាមេត្រីបរិស្ថាន។

ច- ពិនិត្យនិងវាយតម្លៃលើផលិតផលនិងសេវាកម្ម ដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងស្តង់ដារមេត្រីបរិស្ថាន។

ឆ- រៀបចំបញ្ជីសារពើភណ្ឌផលិតផលនិងសេវាកម្មដែលទទួលបានការទទួលស្គាល់មេត្រីបរិស្ថាន។

ជ- វាយតម្លៃលើប្រសិទ្ធផលធនធាន ដើម្បីកាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន។

ឈ- រៀបចំគោលការណ៍ណែនាំលិខិតបទដ្ឋានគតិយុត្តសម្រាប់វាយតម្លៃប្រសិទ្ធផលធនធាន និងការវិនិយោគលើបច្ចេកវិទ្យាមេត្រីបរិស្ថាន។

ញ- ផ្ទៀងផ្ទាត់និងវាយតម្លៃលើការអនុវត្តបច្ចេកវិទ្យាមេត្រីបរិស្ថាន។

ដ- រៀបចំគោលការណ៍ណែនាំស្តីពីបច្ចេកវិទ្យាមេត្រីបរិស្ថាន។

## ជំពូកទី៣

## វិធាននៃការលើកកម្ពស់ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព

**មាត្រា៩០ .‒ វិធាននៃការលើកកម្ពស់ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព**

វិធាននៃការលើកកម្ពស់ការប្រើប្រាស់និងផលិតកម្មដោយនិរន្តរភាព មានជាអាទិ៍៖

ក- លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។

ខ- ការដាក់ស្លាកសញ្ញាមេត្រីបរិស្ថាន។

គ- ការវាយតម្លៃប្រសិទ្ធផលធនធាន។

ឃ- ការទទួលខុសត្រូវរបស់ផលិតករ។

ង- ការផ្ទៀងផ្ទាត់និងវាយតម្លៃបច្ចេកវិទ្យាមេត្រីបរិស្ថាន។

### ផ្នែកទី១

### លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព

**មាត្រា៩១ .‒ គោលបំណងលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព**

លទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាពមានគោលបំណងដូចខាងក្រោម៖

ក- លើកទឹកចិត្តចំពោះប្រសិទ្ធផលធនធាន។

ខ- កំណត់ប្រភេទនិងលំដាប់អាទិភាពនៃផលិតផលនិងសេវាកម្មទៅតាមលក្ខណវិនិច្ឆ័យ ដែលមានជាអាទិ៍បច្ចេកវិទ្យាមេត្រីបរិស្ថាន សុវត្ថិភាព និរន្តរភាព ហិរញ្ញវត្ថុបៃតង។

គ- កំណត់នូវលក្ខណវិនិច្ឆ័យបរិស្ថានអប្បបរមានិងលក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិ។

ឃ- កំណត់នូវលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍សម្រាប់ប្រភេទនៃផលិតផល សេវាកម្ម និងទំហំនៃលទ្ធកម្ម។

ង- ផ្តល់ការណែនាំសម្រាប់ការជ្រើសរើសអ្នកផ្គត់ផ្គង់ដែលមានលក្ខណៈសមស្រប។

ច- ផ្តល់ការណែនាំសម្រាប់ការធ្វើសេចក្តីសម្រេច ដោយយកចិត្តទុកដាក់ដល់បរិស្ថាន មានការថ្លឹងថ្លែងរវាងលក្ខណវិនិច្ឆ័យបរិស្ថាន ជាមួយនឹងលក្ខណវិនិច្ឆ័យនៃការទិញ មានជាអាទិ៍ ការគិតគូរដល់សេដ្ឋកិច្ច តម្លៃ គុណភាព ការប្រតិបត្តិការងារ និងការបោះចោលក្រោយពេលប្រើប្រាស់រួច។

ឆ- កំណត់ឱ្យបានច្បាស់នូវទណ្ឌកម្មសម្រាប់អ្នករំលោភបំពានទៅលើលក្ខខណ្ឌតម្រូវសម្រាប់ប្រតិបត្តិការនៃផលិតកម្មនិងសេវាកម្មដែលត្រូវយកចិត្តទុកដាក់ដល់បរិស្ថាន។

ជ- កំណត់ឱ្យបានច្បាស់នូវវិធានការសម្រាប់ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការងារលទ្ធកម្មដើម្បីលើកទឹកចិត្ត និងជួយដល់ភាគីពាក់ព័ន្ធក្នុងការទទួលខុសត្រូវចំពោះការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។

**មាត្រា៩២ ._ ការរៀបចំនីតិវិធីនិងបែបបទស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំនីតិវិធីនិងបែបបទស្តីពីលទ្ធកម្មសាធារណៈប្រកបដោយនិរន្តរភាព។

## ផ្នែកទី២

## ការដាក់ស្លាកសញ្ញាមេត្រីបរិស្ថាន

**មាត្រា៩៣ ._ ស្លាកសញ្ញាមេត្រីបរិស្ថាន**

១- ស្លាកសញ្ញាមេត្រីបរិស្ថាន គឺជាស្លាកសញ្ញាសម្រាប់ប្រើប្រាស់លើផលិតផល និងសេវាកម្ម ដែលអាចជួយដល់អ្នកប្រើប្រាស់ និងអ្នកទិញនូវលក្ខណវិនិច្ឆ័យសមិទ្ធកម្មបរិស្ថាន។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំលក្ខណវិនិច្ឆ័យនិងស្តង់ដារស្លាកសញ្ញាមេត្រីបរិស្ថាន។

**មាត្រា៩៤ ._ ពាក្យស្នើសុំស្លាកសញ្ញាមេត្រីបរិស្ថាន**

១- បុគ្គលអាចដាក់ពាក្យស្នើសុំស្លាកសញ្ញាមេត្រីបរិស្ថាន ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ពាក្យស្នើសុំស្លាកសញ្ញាមេត្រីបរិស្ថានដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

៣- ក្រោយពីទទួលបានពាក្យស្នើសុំស្លាកសញ្ញាមេត្រីបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវពិនិត្យ និងវាយតម្លៃលើផលិតផល និងសេវាកម្មដោយផ្អែកលើលក្ខណវិនិច្ឆ័យ និងស្តង់ដារមេត្រីបរិស្ថាន។ ក្នុងករណីចាំបាច់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ។

៤- នីតិវិធីនៃការសម្រេចផ្តល់ឬមិនផ្តល់ស្លាកសញ្ញាមេត្រីបរិស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៩៥ ._ បញ្ជីសារពើភណ្ឌផលិតផលនិងសេវាកម្មដែលទទួលបានស្លាកសញ្ញាមេត្រីបរិស្ថាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំបញ្ជីសារពើភណ្ឌផលិតផលនិងសេវាកម្មដែលទទួលបានស្លាកសញ្ញាមេត្រីបរិស្ថាន ហើយធ្វើការផ្សព្វផ្សាយបញ្ជីនោះជាសាធារណៈ។

## ផ្នែកទី៣
## ការវាយតម្លៃប្រសិទ្ធផលធនធាន

**មាត្រា៩៦ ._ គោលបំណង**

ការវាយតម្លៃប្រសិទ្ធផលធនធានមានគោលបំណងរួមចំណែកសន្សំសំចៃការប្រើប្រាស់ធនធានតិច លើកកម្ពស់ផលិតភាពនៃផលិតផល កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន។

**មាត្រា៩៧ ._ ការរៀបចំគោលការណ៍ណែនាំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការវាយតម្លៃពីប្រសិទ្ធផលធនធាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំគោលការណ៍ណែនាំ លិខិតបទដ្ឋានគតិយុត្ត បែបបទ នីតិវិធី និងវិសាលភាពសម្រាប់ការវាយតម្លៃប្រសិទ្ធផលធនធាន។

**មាត្រា៩៨ ._ ការរៀបចំរបាយការណ៍វាយតម្លៃប្រសិទ្ធផលធនធាន**

១- បុគ្គលដែលប្រើប្រាស់ធនធានហើយធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ត្រូវរៀបចំរបាយការណ៍វាយតម្លៃប្រសិទ្ធផលធនធាន។

២- ការរៀបចំរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងដោយទីប្រឹក្សាវាយតម្លៃពីប្រសិទ្ធផលធនធាន ដែលបានទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- សោហ៊ុយចំណាយលើទីប្រឹក្សារៀបចំរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាន ជាបន្ទុករបស់បុគ្គលដែលបង្កការប៉ះពាល់ដល់បរិស្ថាន។

៤- របាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ បុគ្គលដែលបង្កការប៉ះពាល់ដល់បរិស្ថាន ត្រូវដាក់ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៩៩ ._ ការពិនិត្យលើរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវពិនិត្យលើរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាន៖

- ក- ក្នុងករណីរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធានមានព័ត៌មានគ្រប់គ្រាន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃនោះ។
- ខ- ក្នុងករណីរបាយការណ៍វាយតម្លៃពីប្រសិទ្ធផលធនធាននោះពុំមានព័ត៌មានគ្រប់គ្រាន់ ឬមានការសង្ស័យ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើសវនកម្មប្រសិទ្ធផលធនធាន ដើម្បីធ្វើការផ្ទៀងផ្ទាត់។

**មាត្រា១០០ ._ ការរៀបចំគោលការណ៍ណែនាំដើម្បីទទួលបានហិរញ្ញប្បទាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំគោលការណ៍ណែនាំ ដើម្បីជំរុញឱ្យស្ថាប័នហិរញ្ញវត្ថុផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងអនុវត្តប្រសិទ្ធផលធនធាននិងការវិនិយោគលើបច្ចេកវិទ្យាមេត្រីបរិស្ថាន។

## ផ្នែកទី៤
## ការទទួលខុសត្រូវរបស់ផលិតករ

**មាត្រា១០១ ._ ការទទួលខុសត្រូវរបស់ផលិតករ**

ដើម្បីជំរុញឱ្យផលិតករមានការទទួលខុសត្រូវចំពោះសំណល់ដែលមានហានិភ័យខ្ពស់ដល់បរិស្ថានក្រោយពេលប្រើប្រាស់រួច ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ឱ្យមានយន្តការ និងវិធានការដូចខាងក្រោម៖

ក- ការចូលរួមដោយស្ម័គ្រចិត្ត ឬជាកាតព្វកិច្ចក្នុងការទទួលខុសត្រូវរបស់ផលិតករដែលអនុវត្តលើផលិតផល ក្រុមផលិតផល និងលំហូរសំណល់។

ខ- គោលដៅសម្រាប់ការប្រមូល ការកែច្នៃ ការចម្រាញ់ និងការប្រើប្រាស់ឡើងវិញ។

គ- ការកម្រិតកំណត់ចំនួនសម្រាប់ការយកផលិតផលត្រឡប់មកវិញ។

ឃ- ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនៅក្នុងខ្សែសង្វាក់នៃការផ្គត់ផ្គង់ មានជាអាទិ៍ ផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផល និងគ្រឿងបច្ចេកវិទ្យាពីបរទេស។

ង- ការអភិវឌ្ឍសមត្ថភាពសម្រាប់អ្នកពាក់ព័ន្ធ។

ច- ការទទួលខុសត្រូវរបស់ផលិតករ និងក្រុមផ្សេងទៀតដែលជាប់កាតព្វកិច្ចតាមផ្លូវច្បាប់។

## ផ្នែកទី៥
## ការផ្ទៀងផ្ទាត់និងវាយតម្លៃបច្ចេកវិទ្យាមេត្រីបរិស្ថាន

**មាត្រា១០២ ._ គោលបំណង**

ការផ្ទៀងផ្ទាត់និងវាយតម្លៃបច្ចេកវិទ្យាមេត្រីបរិស្ថាន មានគោលបំណងទទួលបាននូវបច្ចេកវិទ្យាមេត្រីបរិស្ថានដែលមានលក្ខណៈសន្សំសំចៃ ងាយស្រួលអនុវត្តក្នុងការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព។

**មាត្រា១០៣ ._ ការបង្កើតយន្តការសម្រាប់ផ្ទៀងផ្ទាត់និងវាយតម្លៃបច្ចេកវិទ្យាមេត្រីបរិស្ថាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវ៖

ក- បង្កើតយន្តការសម្រាប់ផ្ទៀងផ្ទាត់និងវាយតម្លៃ ដោយផ្អែកលើការអនុវត្តល្អៗ ស្របតាមបរិបទជាតិ និងអន្តរជាតិ ដើម្បីទទួលបានបច្ចេកវិទ្យាមេត្រីបរិស្ថាន។

ខ- រៀបចំគោលការណ៍ណែនាំអំពីបញ្ជី នីតិវិធី និងបែបបទនៃការចុះបញ្ជីបច្ចេកវិទ្យាមេត្រីបរិស្ថាន។

# មាតិកាទី៨
# ការរៀបចំផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងនិរន្តរភាព

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១០៤ ._ គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់វិធានលើការគ្រប់គ្រង ការប្រើប្រាស់ដី ការរៀបចំនគរូបនីយកម្ម និងសំណង់ដែលយកចិត្តទុកដាក់ដល់មេត្រីបរិស្ថាន និងទីក្រុងនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា១០៥ ._ វិសាលភាព

មាតិកានេះ មានវិសាលភាពអនុវត្តលើគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការប្រើប្រាស់ដី ផែនការគ្រប់គ្រងដី និងសកម្មភាពនៃការប្រើប្រាស់ដី ធនធានដី និងសំណង់ ដែលយកចិត្តទុកដាក់ដល់មេត្រីបរិស្ថាន និងទីក្រុងនិរន្តរភាពក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

មាត្រា១០៦ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងនិងការប្រើប្រាស់ដីនៅក្នុងតំបន់ការពារធម្មជាតិ។

មាត្រា១០៧ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការប្រើប្រាស់ដីក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ខ- ចូលរួមផ្តល់យោបល់លើផែនការប្រើប្រាស់ដីនិងទីក្រុងនិរន្តរភាពជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

គ- ចូលរួមបណ្តុះបណ្តាល ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីដោយយកចិត្តទុកដាក់លើមេត្រីបរិស្ថាន និងទីក្រុងនិរន្តរភាព។

មាត្រា១០៨ ._ ការរៀបចំផែនការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាននិងទីក្រុងនិរន្តរភាព

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសេចក្តីព្រាងគោលនយោបាយ និងផែនការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងនិរន្តរភាព។

២- ការរៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការប្រើប្រាស់ដី និងទីក្រុងនិរន្តរភាព ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវផ្អែកលើព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រជាក់លាក់ និងដាក់បញ្ចូលចំណុចដូចខាងក្រោម៖

ក- ការអភិរក្សបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព។

ខ- យន្តការសម្រាប់គាំពារ គ្រប់គ្រង និងកាត់បន្ថយហានិភ័យបរិស្ថាន។

គ- ការចូលរួមជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មានពីការគ្រប់គ្រងនិងប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន និងទីក្រុងនិរន្តរភាព។

## ជំពូកទី៣

## ការគ្រប់គ្រងនិងការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន

មាត្រា១០៩ ._ កិច្ចសហការក្នុងការគ្រប់គ្រងនិងប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចូលរួម

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គ្រប់គ្រង និងប្រើប្រាស់ដីនិងសំណង់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍនិងការប្រើប្រាស់ដីនិងធនធានដីប្រកបដោយប្រសិទ្ធភាព និរន្តរភាព តម្លាភាព សមធម៌ បរិយាបន្ន សុខដុមនីយកម្ម និងសមាហរណកម្ម។

## ជំពូកទី៤
## ការរៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន

**មាត្រា១០ .-** ការរៀបចំគោលការណ៍ណែនាំនិងលក្ខខណ្ឌនៃការរៀបចំផែនការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំគោលការណ៍ណែនាំនិងលក្ខខណ្ឌនៃការរៀបចំផែនការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន។

២- ការរៀបចំផែនការប្រើប្រាស់ដីដោយយកចិត្តទុកដាក់ដល់បរិស្ថាន ត្រូវបំពេញលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក- ត្រូវមានកិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធលើផែនការប្រើប្រាស់ដីរបស់ម្ចាស់គម្រោង។

ខ- ត្រូវធ្វើការពិគ្រោះយោបល់ជាមុនជាមួយប្រជាជនក្នុងមូលដ្ឋាន ដែលទទួលរងនូវផលប៉ះពាល់ពីការអនុវត្តគម្រោង។

គ- ត្រូវមានការបញ្ជាក់អំពីភាពត្រឹមត្រូវរបស់គម្រោងដែលបានស្នើសុំ ដោយភ្ជាប់ជាមួយនឹងផែនការគ្រប់គ្រងការប្រើប្រាស់ដី និងផែនការមេស្តីពីការប្រើប្រាស់ដី។

ឃ- ត្រូវមានការស្រាវជ្រាវនិងមានទិន្នន័យលម្អិតនៅទីតាំងដាក់លាក់អំពីលក្ខណៈពិសេសនៃតំបន់ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ដី មានជាអាទិ៍ បញ្ជីសារពើភណ្ឌធនធានដី ព័ត៌មានទាក់ទងនឹងការចុះបញ្ជីដី ការប្រើប្រាស់ដីបច្ចុប្បន្ន ហេដ្ឋារចនាសម្ព័ន្ធ ស្ថានភាពប្រជាសាស្ត្រ សិទ្ធិកាន់កាប់ដី សិទ្ធិដែលត្រូវបានទទួលស្គាល់ដោយវិធានទំនៀមទម្លាប់ រចនាសម្ព័ន្ធ សង្គម វប្បធម៌ជាតិ ការធ្វើចលនាឆ្លងដែនរបស់សត្វព្រៃ ការរំខានដោយធម្មជាតិ មុខងារជលសាស្ត្រ ចរន្តថាមពល និងរាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

ង- មានការប្រើប្រាស់បច្ចេកវិទ្យាសមស្របក្នុងការកំណត់ផែនទី តំបន់ទេសភាព មានជាអាទិ៍ ការកំណត់ទីតាំង ការវាយតម្លៃពីធនធានធម្មជាតិ និងសេវាកម្មពាក់ព័ន្ធទៅនឹងធនធានធម្មជាតិ ទិន្នន័យនៃការប្រើប្រាស់ដី សិទ្ធិកាន់កាប់ដី និងតំបន់បេតិកភណ្ឌវប្បធម៌ដែលស្ថិតនៅក្នុងតំបន់អភិវឌ្ឍ។

ច- ផ្តល់ដំណោះស្រាយសមស្របក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងដោះស្រាយការប្រែប្រួលអាកាសធាតុ។

ឆ- ដាក់បញ្ចូលនូវវិធានការនៃការលើកកម្ពស់ការគ្រប់គ្រងដោយនិរន្តរភាពលើព្រៃឈើនៅក្នុងទីតាំងអនុវត្តគម្រោង។

ជ- ដាក់បញ្ចូលនូវគោលដៅវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងវិធានការសម្រាប់ការថែរក្សានូវតម្លៃធនធានប្រវត្តិសាស្ត្រ វប្បធម៌ ដែលស្ថិតនៅក្នុងទីតាំងអនុវត្តគម្រោង។

ឈ- កំណត់ភាតព្វកិច្ចនិងការទទួលខុសត្រូវរបស់ម្ចាស់គម្រោង ក្នុងករណីមានការប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ។

**មាត្រា១១ .-** ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលក្ខខណ្ឌនៃការប្រើប្រាស់ដីរបស់គម្រោង

ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលក្ខខណ្ឌនៃការប្រើប្រាស់ដីរបស់គម្រោងជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១១២ ._ ការកែសម្រួលផែនការប្រើប្រាស់ដី**

១- រាល់ការកែសម្រួលផែនការប្រើប្រាស់ដីនៃទីតាំងអនុវត្តគម្រោង អាជ្ញាធរមានសមត្ថកិច្ច ឬម្ចាស់គម្រោង ត្រូវដាក់ពាក្យស្នើសុំទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២- ពាក្យស្នើសុំដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ ខាងលើនេះត្រូវភ្ជាប់ជាមួយនូវឯកសារដូចខាងក្រោម៖

ក- ត្រូវមានព័ត៌មានអំពីហេតុផលផ្នែកសេដ្ឋកិច្ចសង្គមនិងវិទ្យាសាស្ត្រដែលនាំឱ្យមានការកែសម្រួលផែនការប្រើប្រាស់ដី។

ខ- បង្ហាញពីការខិតខំដើម្បីរក្សានូវស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន។

គ- បង្ហាញពីផលប៉ះពាល់ទៅលើរបបចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាននិងធុរកិច្ចនានា។

ឃ- បង្ហាញព័ត៌មានផ្សេងៗទៀតដែលចាំបាច់។

## ជំពូកទី៥

## ទីក្រុងនិរន្តរភាព

**មាត្រា១១៣ ._ ការរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព។

**មាត្រា១១៤ ._ យន្តការទីក្រុងនិរន្តរភាព**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបង្កើតយន្តការទីក្រុងនិរន្តរភាពដោយ៖

ក- កំណត់ភាពងាយរងគ្រោះនៃទីក្រុង។

ខ- រៀបចំផែនការដឹកជញ្ជូននិរន្តរភាពសម្រាប់ទីក្រុង។

គ- រៀបចំផែនការនិរន្តរភាពសម្រាប់ទីក្រុង។

ឃ- រៀបចំផែនការផលិតកម្មប្រកបដោយនិរន្តរភាពសម្រាប់ទីក្រុង។

ង- រៀបចំផែនការគ្រប់គ្រងសំណល់រឹង រាវសម្រាប់ទីក្រុង។

ច- រៀបចំផែនការលំហបៃតងសាធារណៈ និងបេតិកភណ្ឌវប្បធម៌។

ឆ- រៀបចំផែនការសំណង់អគារបៃតង។

ជ- រៀបចំផែនការទីជម្រាលនិងប្រព័ន្ធអេកូឡូស៊ី ទីក្រុងសម្រាប់ប្រភពទឹកនិងជីវៈចម្រុះទីក្រុង។

**មាត្រា១១៥ ._ ការរៀបចំ ការអនុវត្ត និងការកែប្រែផែនការសកម្មភាពទីក្រុងនិរន្តរភាព**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាពទីក្រុងនិរន្តរភាពស្របតាមផែនការយុទ្ធសាស្ត្រទីក្រុងនិរន្តរភាព។

២- រដ្ឋបាលថ្នាក់ក្រោមជាតិ អាចធ្វើការកែសម្រួលផែនការសកម្មភាពទីក្រុងនិរន្តរភាពអាស្រ័យតាមការប្រែប្រួលស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍសេដ្ឋកិច្ច បរិស្ថាន ប្រជាសាស្ត្រ និងសង្គម ដោយមានការឯកភាពពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# មាតិកាទី៩

# អគារបៃតង

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១១៦ .- គោលបំណង**

មាតិកានេះ មានគោលបំណងរៀបចំយន្តការនៃការគ្រប់គ្រងប្រព័ន្ធវាយតម្លៃនិងជំរុញប្រតិបត្តិការអគារបៃតង ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសមធម៌សង្គម ដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាអតិបរមាដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

**មាត្រា១១៧ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើការវាយតម្លៃអគារចាប់ពីការរចនា ការសាងសង់ ការប្រើប្រាស់ ការជួសជុល ការរុះរើ និងការគ្រប់គ្រងសកម្មភាពជំនាញនៃវិស័យពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា១១៨ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវដូចខាងក្រោម៖

ក- សហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រៀបចំគោលការណ៍ណែនាំនិងប្រព័ន្ធវាយតម្លៃអគារបៃតងដោយកំណត់នូវដំណោះស្រាយសម្រាប់ការរៀបចំផែនការ ការសាងសង់ ការប្រើប្រាស់និងជួសជុល និងការរុះរើអគារ ផ្អែកលើទិដ្ឋភាពនិរន្តរភាពបរិស្ថាន សេដ្ឋកិច្ច សង្គម វប្បធម៌ និងដោយឈរលើគោលការណ៍ស្ម័គ្រចិត្ត ក្នុងគោលបំណងគាំពារបរិស្ថាន លើកកម្ពស់ប្រសិទ្ធភាពថាមពល សន្សំសំចៃទឹក ប្រើប្រាស់សម្ភារៈសំណង់ និងបរិក្ខារមេត្រីបរិស្ថាន កាត់បន្ថយសំណល់និងជំរុញសេដ្ឋកិច្ចវិលជុំ និងចូលរួមកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ព្រមទាំងផ្តល់នូវផាសុខភាព និងលើកកម្ពស់សុខភាពរបស់អ្នកប្រើប្រាស់អគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ- សហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំប្រព័ន្ធលើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុសម្រាប់សំណង់ និងអគារដែលប្រតិបត្តិតាមគោលការណ៍ណែនាំ និងវិញ្ញាបនបត្រកម្មអគារបៃតង។

**មាត្រា១១៩ .- លក្ខណវិនិច្ឆ័យក្នុងការរៀបចំគោលការណ៍ណែនាំវិញ្ញាបនបត្រកម្មអគារបៃតងនិងសកម្មភាពប្រតិបត្តិអគារបៃតង**

១- គោលការណ៍ណែនាំនិងវិញ្ញាបនបត្រកម្មអគារបៃតង ត្រូវដាក់បញ្ចូលលក្ខណវិនិច្ឆ័យមួយចំនួនដូចខាងក្រោម៖

ក- លក្ខណវិនិច្ឆ័យ សូចនាករ និងយន្តការវាយតម្លៃអគារបៃតង។

ខ- ស្ថាប័ន គណៈកម្មាធិការ ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងលេខាធិការដ្ឋានប្រតិបត្តិ។

គ- ស្លាកសញ្ញាសម្គាល់សម្រាប់ជានិមិត្តសញ្ញាអគារបៃតងនិងកម្រិតគុណភាពនៃពានរង្វាន់អគារបៃតង។

ឃ- លក្ខខណ្ឌតម្រូវសម្រាប់ការផ្តល់អាជ្ញាបណ្ណដល់សវនករនិងទីប្រឹក្សាអគារបៃតង។

២- ការរៀបចំគោលការណ៍ណែនាំ វិញ្ញាបនបត្រកម្មអគារបៃតង និងសកម្មភាពសម្រាប់គ្រប់គ្រងអគារបៃតងត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១២០ ._ ការកែសម្រួលគោលការណ៍ណែនាំនិងវិញ្ញាបនបត្រកម្មអគារបៃតង**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើការកែសម្រួលគោលការណ៍ណែនាំ វិញ្ញាបនបត្រកម្មអគារបៃតង និងការប្រតិបត្តិនានាពាក់ព័ន្ធនឹងអគារបៃតង តាមការប្រែប្រួលនៃស្ថានភាពបរិស្ថាននិងការរីកចម្រើនសេដ្ឋកិច្ចសង្គម និងធានាឱ្យមានប្រសិទ្ធភាពនៃការអនុវត្ត។

## មាតិកាទី១០
## ថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១២១._ គោលបំណង**

មាតិកានេះ មានគោលបំណងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាមេត្រីបរិស្ថាន ថាមពលកកើតឡើងវិញ និងថាមពលបរមាណូស៊ីវិលនៅក្នុងការគ្រប់គ្រង និងរៀបចំក្របខ័ណ្ឌការងារសម្រាប់ការផ្គត់ផ្គង់ និងសេវាកម្មអគ្គិសនី។

**មាត្រា១២២ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពនៃការលើកកម្ពស់ ការប្រើប្រាស់អគ្គិសនី ថាមពលកកើតឡើងវិញ និងថាមពលបរមាណូស៊ីវិលនៅក្នុងការផ្គត់ផ្គង់ ការផ្តល់សេវា និងការប្រើប្រាស់ថាមពលអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា១២៣ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវទទួលខុសត្រូវលើការរៀបចំគោលនយោបាយ ផែនការអភិវឌ្ឍ និងការគ្រប់គ្រង ការប្រើប្រាស់ថាមពលអគ្គិសនី ថាមពលកកើតឡើងវិញ និងថាមពលបរមាណូស៊ីវិល។

**មាត្រា១២៤ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- សម្របសម្រួលនិងផ្តល់យោបល់ដល់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ពាក់ព័ន្ធជាមួយថាមពលប្រកបដោយការទទួលខុសត្រូវ។

ខ- ចូលរួមចំណែកលើកកម្ពស់ការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលបរមាណូស៊ីវិល។

គ- ចូលរួមអប់រំនិងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ថាមពលថាមពលកកើតឡើងវិញ និងថាមពលបរមាណូស៊ីវិល។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឃ- លើកកម្ពស់លើការប្រើប្រាស់បច្ចេកវិទ្យាថាមពលមេត្រីបរិស្ថាននៅក្នុងវិស័យថាមពល។

ង- ចូលរួមចំណែកផ្តល់យោបល់លើបញ្ហាបរិស្ថាន បញ្ហាចីរភាពថាមពល បញ្ហាប្រែប្រួលអាកាសធាតុក្នុងការរៀបចំផែនការ និងគម្រោងវិនិយោគក្នុងវិស័យថាមពល។

**មាត្រា១២៥ .- គោលការណ៍នៃថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំគោលការណ៍នៃថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ។ ថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ គឺជាថាមពលអគ្គិសនីមួយដែលបានអភិវឌ្ឍស្របតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- បំពេញតម្រូវការអគ្គិសនីឱ្យបានគ្រប់គ្រាន់និងទាន់តាមកំណើន។

ខ- ផ្តល់ការផ្គត់ផ្គង់អគ្គិសនីមួយអាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យដល់អ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់ទីកន្លែងនៃព្រះរាជាណាចក្រកម្ពុជា។

គ- យកចិត្តទុកដាក់បង្កើនការអភិវឌ្ឍថាមពលស្អាតដែលរួមមានថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពលឱ្យបានជាអតិបរមាតាមដែលអាចធ្វើទៅបាន។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវធានាថារាល់គម្រោងអភិវឌ្ឍក្នុងវិស័យថាមពលត្រូវអនុវត្តតាមគោលការណ៍នៃថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវខាងលើ។

**មាត្រា១២៦ .- វិធានដើម្បីសម្រេចបានថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ**

ដើម្បីសម្រេចបានថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ ត្រូវអនុវត្តវិធានដូចខាងក្រោម៖

ក- ក្នុងការរៀបចំផែនការអភិវឌ្ឍអគ្គិសនី ត្រូវជ្រើសរើសយកជម្រើសដែលអាចបំពេញទាំងលក្ខខណ្ឌសន្តិសុខថាមពលនិងទាំងលក្ខខណ្ឌចីរភាពថាមពលបានប្រសើរជាងគេ។

ខ- ការផ្តល់អាទិភាពចំពោះការវិនិយោគត្រូវផ្តល់ដល់គម្រោងទាំងឡាយណា ដែលស្ថិតក្នុងជម្រើសផែនការអភិវឌ្ឍដែលផ្តល់ទាំងសន្តិសុខថាមពល និងទាំងចីរភាពថាមពលបានប្រសើរជាងគេ។

គ- លើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាដែលបង្កផលប៉ះពាល់តិចដល់បរិស្ថាន។

ឃ- វាយតម្លៃ និងអនុម័តលើផែនការអភិវឌ្ឍគម្រោងក្នុងវិស័យថាមពលប្រកបដោយការទទួលខុសត្រូវទាំងលើសន្តិសុខថាមពលនិងទាំងលើចីរភាពថាមពល។

## ជំពូកទី៣
## ការរៀបចំផែនការយុទ្ធសាស្ត្រថាមពលអគ្គិសនី
## ប្រកបដោយការទទួលខុសត្រូវនិងការអនុវត្ត

**មាត្រា១២៧ .- ការលើកកម្ពស់បច្ចេកវិទ្យាថាមពលមេត្រីបរិស្ថាន**

១- ក្នុងការរៀបចំផែនការអភិវឌ្ឍថាមពល ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវលើកទឹកចិត្តនិងផ្តល់អាទិភាពដល់គម្រោងដែលប្រើប្រាស់បច្ចេកវិទ្យាថាមពលប្រកបដោយប្រសិទ្ធផល ការបញ្ចេញកាបូនតិច និងសំណល់មិនឱ្យលើសពីស្តង់ដារបរិស្ថានដែលបានកំណត់។

២- ស្តង់ដារបរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ។

៣- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវផ្តល់អាទិភាពអភិវឌ្ឍដល់គម្រោងថាមពលអគ្គិសនីណាដែលស្ថិតក្នុងជម្រើសផែនការអភិវឌ្ឍណាដែលផ្តល់ទាំងសន្តិសុខថាមពល និងទាំងចីរភាពថាមពលបានប្រសើរជាងគេ។

**មាត្រា១២៨ ._ បច្ចេកវិទ្យាមានប្រសិទ្ធភាពខ្ពស់ដែលអាចស្វែងរកបាននិងជម្រើសដែលមានផលប៉ះពាល់តិច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មិនត្រូវផ្ដល់ការឯកភាពលើរបាយការណ៍ វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬពេញលេញសម្រាប់គម្រោងដែលបង្កឱ្យមានផលប៉ះពាល់បរិស្ថានធ្ងន់ធ្ងរឡើយ។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលមិនត្រូវផ្ដល់ការឯកភាពឱ្យអភិវឌ្ឍសម្រាប់គម្រោងណាដែលប្រើប្រាស់បច្ចេកវិទ្យាមិនមានប្រសិទ្ធភាពខ្ពស់ឡើយ។

២- ម្ចាស់គម្រោងត្រូវដាក់ជម្រើសក្នុងការបញ្ចេញសំណល់តិចនិងបញ្ចេញកាបូនតិចក្នុងដំណាក់កាលរចនាគម្រោង ដើម្បីសម្រេចបាននូវគោលបំណងនៃគម្រោង។

**មាត្រា១២៩ ._ ការលើកកម្ពស់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងសិទ្ធិអ្នកប្រើប្រាស់**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវជំរុញនិងលើកកម្ពស់ដល់ការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយដែលមានគ្រប់គ្រាន់ មាននិរន្តរភាព ស្ថិរភាព គុណភាព និងថ្លៃសមរម្យ នៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាការផ្គត់ផ្គង់ចេញមកពីបណ្ដាញជាតិឬការផ្គត់ផ្គង់តាមបែបប្រព័ន្ធទោលក៏ដោយ។

២- អ្នកប្រើប្រាស់អគ្គិសនីត្រូវបានអនុញ្ញាតឱ្យរៀបចំការផ្គត់ផ្គង់ជាប្រព័ន្ធទោល សម្រាប់បំពេញតម្រូវការអគ្គិសនីរបស់ខ្លួនផ្ទាល់ ត្រូវស្នើសុំការអនុញ្ញាតជាមុននិងត្រូវអនុវត្តតាមបទប្បញ្ញត្តិ នីតិវិធី និងស្ដង់ដារបច្ចេកទេស សុវត្ថិភាពដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

៣- អ្នកប្រើប្រាស់អគ្គិសនីមានសិទ្ធិជ្រើសរើសការផ្គត់ផ្គង់ណាដែលអ្នកប្រើប្រាស់អគ្គិសនីយល់ថាសមស្របនិងដែលមានប្រយោជន៍ចំពោះខ្លួនផ្ទាល់។

**មាត្រា១៣០ ._ ការផលិតនិងប្រើប្រាស់ថាមពលកកើតឡើងវិញតាមផ្ទះ**

ការផលិតនិងប្រើប្រាស់ថាមពលកកើតឡើងវិញតាមផ្ទះ ត្រូវអនុលោមតាមគោលការណ៍ណែនាំរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ក្នុងករណីការដំឡើងនិងការប្រើប្រាស់ទាំងនេះមិនបានតភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់រួមដែលធ្វើឱ្យប៉ះពាល់ដល់ប្រតិបត្តិការនិងសុវត្ថិភាពនៃប្រព័ន្ធផ្គត់ផ្គង់រួម។

## ជំពូកទី៤

## គ្របខណ្ឌទៅតាមប្រភេទថាមពលឬគម្រោងថាមពលអគ្គិសនី

### ផ្នែកទី១

### ថាមពលកកើតឡើងវិញ

**មាត្រា១៣១ ._ ករណីអនុគ្រោះពន្ធចំពោះសម្ភារៈបម្រើការដំឡើងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ**

គ្រប់សម្ភារៈនានាដែលប្រើសម្រាប់តែការដំឡើងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ ត្រូវទទួលបានការលើកទឹកចិត្តតាមរយៈការអនុគ្រោះពន្ធស្របតាមបទប្បញ្ញត្តិស្ដីពីការវិនិយោគជាធរមាន។

**មាត្រា១៣២ ._ ការគ្រប់គ្រងនិងការប្រើប្រាស់អគ្គិសនីបន្ថែមពីលើការផ្គត់ផ្គង់បណ្ដាញជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកគ្រប់គ្រងលើការផលិត ការបញ្ជូន ការចែកចាយអគ្គិសនី និងគ្រប់គ្រងលើការប្រើប្រាស់ថាមពលអគ្គិសនី ត្រូវរៀបចំការគ្រប់គ្រង ការបន្ថែម និងការផ្គត់ផ្គង់អគ្គិសនីពីលើការផ្គត់ផ្គង់ពីបណ្ដាញជាតិ តាមរយៈការដំឡើងថាមពលពន្លឺព្រះអាទិត្យលើដំបូលភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់របស់បណ្ដាញជាតិ។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំគោលនយោបាយនិងលិខិតបទដ្ឋានដើម្បីគ្រប់គ្រងការផ្គត់ផ្គង់

បន្ថែមខាងលើនេះ។ បុគ្គលឯកជនដែលមានបំណងដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួនបន្ថែម ហើយមានបំណងតភ្ជាប់ទៅនឹងប្រព័ន្ធផ្គត់ផ្គង់បណ្តាញជាតិ ត្រូវតែអនុវត្តតាមគោលនយោបាយនិងលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រង ការផ្គត់ផ្គង់បន្ថែមដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបានរៀបចំខាងលើ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំបទប្បញ្ញត្តិបច្ចេកទេស សេដ្ឋកិច្ច និងសុវត្ថិភាពពាក់ព័ន្ធជាមួយការគ្រប់គ្រងការប្រើប្រាស់អគ្គិសនីបន្ថែមពីលើការផ្គត់ផ្គង់ពីប្រព័ន្ធបណ្តាញ។

**មាត្រា១៣៣ .- យន្តការទូទាត់ថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់អគ្គិសនីដែលដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីយន្តការទូទាត់ថ្លៃអគ្គិសនីសម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ដែលបានតភ្ជាប់ជាមួយប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ ស្របតាមគោលនយោបាយនិងលិខិតបទដ្ឋានសម្រាប់ការគ្រប់គ្រង ការផ្គត់ផ្គង់បន្ថែមដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបានរៀបចំខាងលើ និងស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៣៤ .- លក្ខខណ្ឌនៃការភ្ជាប់ប្រព័ន្ធពន្លឺព្រះអាទិត្យណាមួយទៅនឹងបណ្តាញផ្គត់ផ្គង់របស់បណ្តាញជាតិ**

ប្រព័ន្ធពន្លឺព្រះអាទិត្យរបស់បុគ្គលដែលមានបំណងតភ្ជាប់ទៅនឹងបណ្តាញផ្គត់ផ្គង់របស់បណ្តាញជាតិ ត្រូវអនុវត្តតាមគោលនយោបាយ លិខិតបទដ្ឋាន បទប្បញ្ញត្តិបច្ចេកទេស សេដ្ឋកិច្ច និងសុវត្ថិភាពជាធរមាន ដែលរៀបចំដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

**មាត្រា១៣៥ .- ប្រព័ន្ធអនុគ្រោះពន្ធសាកល្បងលើថាមពលកកើតឡើងវិញ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធអនុគ្រោះពន្ធលើថាមពលកកើតឡើងវិញក្នុងរយៈពេល១(មួយ)ឆ្នាំនៃការសាកល្បង។

២- លិខិតបទដ្ឋានគតិយុត្តនេះត្រូវដាក់បញ្ចូលនូវខ្លឹមសារមួយចំនួនដូចខាងក្រោម៖

ក- ការផ្តល់ថវិកាវដ្តដើម្បីប៉ះប៉ូវដោយរាជរដ្ឋាភិបាលផ្តល់ជាអត្រាថេរមួយសម្រាប់ការជាវអគ្គិសនី ដែលផលិតចេញពីប្រភពពីកន្លែងផ្តល់ថាមពលពន្លឺព្រះអាទិត្យឬប្រព័ន្ធផលិតថាមពលដែលកកើតឡើងវិញ។

ខ- ធានាឱ្យបាននូវកម្រិតថ្លៃថាមពលសម្រាប់រយៈពេលណាមួយ ក្នុងគោលបំណងកាត់បន្ថយថ្លៃដែលត្រូវបង់ដោយអ្នកប្រើប្រាស់ចុងក្រោយ និងសម្រួលដល់ការស្តារឡើងវិញនូវចំណាយវិនិយោគរបស់ម្ចាស់គម្រោង និងចំណាយថែទាំ។

គ- ការបង្កើតបញ្ជីថ្លៃលក់អគ្គិសនីមួយ ដែលអ្នកប្រើប្រាស់អគ្គិសនីត្រូវបង់ថ្លៃប្រើប្រាស់អគ្គិសនីពីប្រភពថាមពលកកើតឡើងវិញក្នុងរយៈពេលនៃការសាកល្បង។

## ផ្នែកទី២
## ថាមពលបរមាណូស៊ីវិល

**មាត្រា១៣៦ .- ការគ្រប់គ្រងថាមពលបរមាណូស៊ីវិល**

១- ថាមពលបរមាណូស៊ីវិលត្រូវបង្កើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រងនិងកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ដែលមានក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលជាសេនាធិការ ដោយមានការគ្រប់គ្រងនិងប្រតិបត្តិការតាមស្តង់ដារអន្តរជាតិនៃកិច្ចគាំពារផ្នែកសុខភាព សុវត្ថិភាព សន្តិសុខ និងបរិស្ថាន។

២- រាជរដ្ឋាភិបាលដោយមានក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលជាសេនាធិការ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីថាមពលបរមាណូស៊ីវិល។

៣- រាជរដ្ឋាភិបាលមិនត្រូវទទួលយកសំណល់ថាមពលបរមាណូស៊ីវិលពីប្រទេសដទៃជាដាច់ខាតទោះបីតាមលក្ខខណ្ឌឬកាលៈទេសៈណាក៏ដោយ។

៤- រាជរដ្ឋាភិបាលត្រូវបញ្ជូនទៅប្រទេសដើមវិញនូវរាល់ឧបករណ៍ សម្ភារៈ និងបរិក្ខារ ដែលប្រឡាក់និង/ឬប៉ះពាល់នឹងសារធាតុវិទ្យុសកម្មដែលត្រូវបានបញ្ឈប់ពីការប្រើប្រាស់ ឬអស់សុពលភាពនៃការប្រើប្រាស់។

**មាត្រា១៣៧ ._ ការអប់រំ ផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្សស្តីពីថាមពលបរមាណូស៊ីវិល**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលបរមាណូស៊ីវិល ត្រូវរៀបចំកម្មវិធី ដើម្បីកសាងនិងអភិវឌ្ឍសមត្ថភាពវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាដល់បុគ្គលិកខ្លួននិងស្ថាប័នពាក់ព័ន្ធ ដោយសហការជាមួយស្ថាប័នថាមពលបរមាណូអន្តរជាតិ និងភាគីពាក់ព័ន្ធ។

២- ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីការប្រើប្រាស់បច្ចេកវិទ្យាថាមពលបរមាណូស៊ីវិលតាមរយៈការអប់រំ ការផ្សព្វផ្សាយ និងការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ និងមជ្ឈមណ្ឌលព័ត៌មានស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូស៊ីវិល ដើម្បីកសាងនិងអភិវឌ្ឍធនធានមនុស្ស។

**មាត្រា១៣៨ ._ កម្មវិធីស្រាវជ្រាវស្តីពីបរមាណូស៊ីវិលសម្រាប់គោលបំណងសន្តិភាព**

ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំកម្មវិធីស្រាវជ្រាវដើម្បី៖

ក- កំណត់អត្តសញ្ញាណថាមពលបរមាណូស៊ីវិលមេត្រីបរិស្ថានដែលមានលក្ខណៈច្នៃប្រឌិតថ្មី។

ខ- វាយតម្លៃផលប៉ះពាល់ដែលអាចកើតឡើងដោយការអភិវឌ្ឍថាមពលបរមាណូស៊ីវិលចំពោះវិស័យបរិស្ថាននិងវិស័យពាក់ព័ន្ធ។

គ- កំណត់អំពីលក្ខខណ្ឌនៃកិច្ចគាំពារផ្នែកសុខភាព សុវត្ថិភាព សន្តិសុខ និងបរិស្ថាននៃការបោះបង់ចោលនូវសំណល់វិទ្យុសកម្ម។

**មាត្រា១៣៩ ._ លក្ខខណ្ឌតម្រូវនៃប្រសិទ្ធផលនៃប្រព័ន្ធបណ្តាញចែកចាយ**

គម្រោងបណ្តាញផ្គត់ផ្គង់អគ្គិសនីនានា ត្រូវប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយប្រសិទ្ធផល ដើម្បីកាត់បន្ថយការបាត់បង់ថាមពលអគ្គិសនីលើប្រព័ន្ធបណ្តាញ។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលអគ្គិសនីត្រូវទទួលបន្ទុកសិក្សាអំពីកម្រិតនៃបច្ចេកវិទ្យា ដែលត្រូវប្រើប្រាស់ជាមួយនឹងប្រសិទ្ធភាពសេដ្ឋកិច្ចនៃការវិនិយោគ ដើម្បីបន្ថយថ្លៃអគ្គិសនីនិងកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបន្ទុកពិនិត្យនិងសម្រេចលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងការប្រើប្រាស់បច្ចេកវិទ្យាមេត្រីបរិស្ថាននៅពេលដាក់ពាក្យស្នើសុំ។

**មាត្រា១៤០ ._ ការពង្រីកបណ្តាញជាតិ**

១- ការពង្រីកបណ្តាញជាតិទៅកាន់តំបន់នានាទូទាំងប្រទេស ត្រូវមានការពិចារណាផ្នែកបរិស្ថាន សេដ្ឋកិច្ចនិងសង្គម ដោយថ្លឹងថ្លែងជាមួយការពិចារណាអំពីភាពមានគ្រប់គ្រាន់ និរន្តរភាព ស្ថិរភាព គុណភាព និងតម្លៃសមរម្យរបស់បណ្តាញជាតិ។

២- រាជរដ្ឋាភិបាលអាចបញ្ឈប់រាល់ការពង្រីកបណ្តាញជាតិទៅកាន់តំបន់ជាក់លាក់ណាមួយក្នុងប្រទេស ប្រសិនបើការពង្រីកនេះ ពិតជាបានប៉ះពាល់ដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គមធ្ងន់ធ្ងរ។ ក្នុងករណីនេះរាជរដ្ឋាភិបាលត្រូវផ្តល់ដំណោះស្រាយផ្គត់ផ្គង់អគ្គិសនីតាមបែបវិមជ្ឈការ ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នោះ។

**មាត្រា១៤១ .- សិទ្ធិទទួលបានព័ត៌មានស្តីពីថាមពលអគ្គិសនី**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពលត្រូវពិនិត្យអំពីលទ្ធភាពក្នុងការវាស់វែងនិងផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានអំពីតង់ស្យុងនិងគុណភាពអគ្គិសនីដែលបានផ្គត់ផ្គង់ ដើម្បីការពារការខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធនៃប្រព័ន្ធចែកចាយ ឬការរអាក់រអួលក្នុងការផ្គត់ផ្គង់អគ្គិសនី។

## មាតិកាទី១១
## ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១៤២ .- គោលបំណង**

មាតិកានេះ មានគោលបំណងពង្រឹងនិងកែលម្អនូវការគ្រប់គ្រង កិច្ចគាំពារ ការអភិរក្ស និងការស្តារឡើងវិញនូវការដ្ឋានឧស្សាហកម្មនិស្សារណកម្ម ដោយកំណត់នូវការកម្រិតលើគម្រោងនិស្សារណកម្ម និងការបង្ហាញព័ត៌មានពាក់ព័ន្ធ។

**មាត្រា១៤៣ .- វិសាលភាព**

មាតិកានេះ មានវិសាលភាព អនុវត្តលើធនធានឧស្សាហកម្មនិស្សារណកម្ម មានជាអាទិ៍ ប្រេង ឧស្ម័ន រ៉ែ វត្ថុធាតុកូគព្ភវិទ្យាផ្សេងៗដែលយកចេញពីដីនិងពីប្រភពផ្សេងៗទៀត ដែលបង្កើតឡើងដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា១៤៤ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវតាមដានការអនុវត្តគម្រោងឧស្សាហកម្មនិស្សារណកម្មដែលអាចប៉ះពាល់ដល់ធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា១៤៥ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ត្រួតពិនិត្យនិងសម្រេចលើការវាយតម្លៃបរិស្ថាន និងយុទ្ធសាស្ត្រពាក់ព័ន្ធនឹងឧស្សាហកម្មនិស្សារណកម្ម។

ខ- ត្រួតពិនិត្យនិងផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះបរិស្ថានលើគម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ការពារធម្មជាតិ។

គ- តាមដានការអនុវត្តបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើគម្រោងឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា១៤៦ .- ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូច**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើអាជីវកម្មខ្នាតតូច និងធ្វើជាលក្ខណៈសិប្បកម្មដើម្បី៖

ក- កំណត់ពីសិទ្ធិនៃការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូចរបស់ប្រជាពលរដ្ឋ។
ខ- ធានាថាសកម្មភាពនៃការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូចធ្វើឡើងដោយនិរន្តរភាពបរិស្ថាន សុវត្ថិភាព និងប្រសិទ្ធផល។
គ- ជំរុញនិងអនុវត្តតាមស្តង់ដារ និងការអនុវត្តដ៏ល្អបំផុតជាអន្តរជាតិក្នុងការគ្រប់គ្រង ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មនិងខ្នាតតូច។
ឃ- បង្កើតដំណើរការនៃការកំណត់តំបន់សម្រាប់ការធ្វើប្រតិបត្តិការធនធានរ៉ែជាលក្ខណៈសិប្បកម្មដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។
ង- តម្រូវនិងផ្តល់ជំនួយសម្រាប់អ្នកធ្វើប្រតិបត្តិការធនធានរ៉ែលក្ខណៈសិប្បកម្មក្នុងការបង្កើត និងអនុវត្តផែនការសុវត្ថិភាពនិងសន្តិសុខ។

**មាត្រា១៤៧ ._ ការបញ្ចៀសការខូចខាតបរិស្ថាន**

ម្ចាស់គម្រោងត្រូវបញ្ចៀសការបង្កឱ្យមានការបំពុល ឬការខូចខាតដល់បរិស្ថានធ្ងន់ធ្ងរដោយប្រើប្រាស់បច្ចេកវិទ្យាល្អៗដែលអាចស្វែងរកបាននិងការអនុវត្តល្អៗ ដើម្បីបង្កើនប្រសិទ្ធផលជាអតិបរមានៅពេលអនុវត្តសកម្មភាពឧស្សាហកម្មនិស្សារណកម្ម។

**មាត្រា១៤៨ ._ កាតព្វកិច្ចផ្តល់ឯកសារបញ្ជាក់ពីការប្រើប្រាស់ស្យានីតនិងបារត**

ម្ចាស់គម្រោងនៃគម្រោងអាជីវកម្មរ៉ែមាសនិងប្រាក់ត្រូវផ្តល់ឯកសារទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ តាមរយៈក្រសួងស្ថាប័នទទួលបន្ទុករ៉ែ ដើម្បីបញ្ជាក់ថាស្យានីតនិងបារតដែលត្រូវប្រើប្រាស់នៅក្នុងប្រតិបត្តិការនៃការធ្វើអាជីវកម្មរ៉ែមាសនិងប្រាក់ត្រូវបានជាវនៅក្នុងលក្ខណៈដែលមានសុវត្ថិភាព និងមិនប៉ះពាល់ដល់បរិស្ថាន។

**មាត្រា១៤៩ ._ លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ស្យានីតនិងបារត**

ការប្រើប្រាស់ស្យានីតនិងបារតនៅក្នុងគម្រោងអាជីវកម្មរ៉ែមាសនិងប្រាក់ ម្ចាស់គម្រោងត្រូវធានាថាកន្លែងដែលរក្សាទុកសារធាតុទាំងនេះត្រូវមានសុវត្ថិភាពនិងមិនប៉ះពាល់បរិស្ថាន ស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងស្យានីតនិងបារត។

## គន្ថីទី៣
## កិច្ចគាំពារបរិស្ថាន
## មាតិកាទី១
## គោលការណ៍ទូទៅលើកិច្ចគាំពារបរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៥០ ._ គោលបំណង**

មាតិកានេះ មានគោលបំណងពង្រឹងប្រសិទ្ធភាពគ្រប់គ្រងសំណល់ ការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន តាមរយៈការកំណត់គោលការណ៍ទូទៅអំពីកាតព្វកិច្ចនិងការទទួលខុសត្រូវ និងការកំណត់វិធានការនានាសម្រាប់អនុវត្តលើការគ្រប់គ្រងសំណល់ សារធាតុបំពុល និងការបំពុលបរិស្ថាន សំដៅធានាកិច្ចគាំពារសុខភាពសាធារណៈនិងគុណភាពបរិស្ថាន។

**មាត្រា១៥១ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពគ្រប់គ្រងសំណល់ សារធាតុបំពុល និងសកម្មភាពការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា១៥២ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើកិច្ចគាំពារបរិស្ថានដើម្បីការពារ ទប់ស្កាត់ និងកាត់បន្ថយការបំពុលបរិស្ថាន និងការប៉ះពាល់ដល់សុខភាពសាធារណៈ។

**មាត្រា១៥៣ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន។

ខ- សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ការអនុវត្តផែនការត្រៀមបង្ការនិងឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះថ្នាក់បំពុលបរិស្ថាន និងការស្តារគុណភាពបរិស្ថាន។

គ- គ្រប់គ្រងទិន្នន័យគុណភាពបរិស្ថានទឹក ដី ខ្យល់ និងទិន្នន័យប្រភពបំពុល សំណល់ សារធាតុបំពុល រួមទាំងទិន្នន័យអេឡិចត្រូម៉ាញ៉េទិក។

ឃ- ចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចលើទីតាំងឬមធ្យោបាយនៃផលិតកម្ម អាជីវកម្មឬសេវាកម្មដែលពាក់ព័ន្ធនឹងការបង្កើត ការផលិត ការប្រើប្រាស់ ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម ការបញ្ចេញចោល និងការទុកដាក់ចុងក្រោយនៃសំណល់ សារធាតុបំពុល ការបញ្ចេញសំឡេង រំញ័រ និងអេឡិចត្រូម៉ាញ៉េទិក រួមទាំងការចុះត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងការបំពុលបរិស្ថាននៃគម្រោងវិនិយោគ។

ង- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថានលើគម្រោងវិនិយោគសាធារណៈ និងឯកជន។

ច- សិក្សា ស្រាវជ្រាវ និងវាយតម្លៃអំពីការសាយភាយសារធាតុគីមីពុលចូលក្នុងបរិស្ថាន វាយតម្លៃកម្រិតនៃការបំពុលបរិស្ថាននិងផលប៉ះពាល់ទៅលើសុខភាពសាធារណៈ។

ឆ- ផ្តល់ការណែនាំនិងការគាំទ្របច្ចេកទេស ធនធាន និងមធ្យោបាយនានាដល់រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការងារគ្រប់គ្រងសំរាម សំណល់រឹង ទឹកកខ្វក់ទីប្រជុំជន និងធ្វើការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ជ- គ្រប់គ្រងការផ្តល់សេវាសាធារណៈពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាននិងសេវាមន្ទីរពិសោធន៍បរិស្ថាន។

ឈ- ជំរុញនិងលើកទឹកចិត្តការវិនិយោគ និងការកៀរគរធនធានសម្រាប់ការងារកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងសំណល់ ការទប់ស្កាត់ការបំពុលបរិស្ថាន និងការស្តារគុណភាពបរិស្ថាន។

ញ- អភិវឌ្ឍសមត្ថភាពជំនាញកិច្ចគាំពារបរិស្ថានដល់មន្ទីរបរិស្ថានរាជធានី ខេត្ត អង្គភាពពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ង- បំពេញការកិច្ចជាអង្គភាពបង្គោលជាតិ ជំរុញនិងសម្របសម្រួលការអនុវត្តលិខិតុបករណ៍អន្តរជាតិ និងការងារសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងវិស័យកិច្ចគាំពារបរិស្ថាន។

## ជំពូកទី៣
## កាតព្វកិច្ចគ្រប់គ្រងសំណល់

**មាត្រា១៥៤ ._ កាតព្វកិច្ចគ្រប់គ្រងសំណល់**

ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចទទួលខុសត្រូវលើការគ្រប់គ្រងសំណល់របស់ខ្លួន តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៥៥ ._ កាតព្វកិច្ចបង់ថ្លៃសេវាសំណល់**

ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ថ្លៃសេវាប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម និងទុកដាក់សំណល់តាមការកំណត់របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៥៦ ._ អនុលោមភាពស្តង់ដារបញ្ចេញសំណល់**

១- ការបញ្ចេញចោលសំណល់ឬសារធាតុបំពុលទៅក្នុងបរិស្ថាន ត្រូវមានអនុលោមភាពតាមស្តង់ដារបញ្ចេញសំណល់។

២- បុគ្គលដែលធ្វើសកម្មភាពផ្ទាល់ បញ្ជា ឬផ្តល់ការសម្របសម្រួលឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះអំពើល្មើសនេះ។

**មាត្រា១៥៧ ._ ការដាក់តម្លៃលើអ្នកប្រើប្រាស់**

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ ឬមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈទាំងនោះ។

២- ថវិកាដែលប្រមូលបានពីការដាក់តម្លៃលើអ្នកប្រើប្រាស់ ត្រូវប្រើសម្រាប់គោលដៅធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់និងការទាញយកធនធានពីសំណល់។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត និងជំរុញការអនុវត្តការប្រមូល និងការគ្រប់គ្រងថវិកានៃការដាក់តម្លៃលើអ្នកប្រើប្រាស់ ដូចមានចែងក្នុងកថាខណ្ឌទី១ និងកថាខណ្ឌទី២ ខាងលើនេះ។

**មាត្រា១៥៨ ._ ការទទួលខុសត្រូវរបស់អ្នកផលិត នាំចូល ឬផ្គត់ផ្គង់ផ្តាច់មុខ**

បុគ្គលដែលផលិត នាំចូល ឬផ្គត់ផ្គង់ផ្តាច់មុខនូវឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ ដែលត្រូវបានចាត់ទុកជាសំណល់គ្រោះថ្នាក់ពេលក្លាយទៅជាសំណល់ត្រូវទទួលខុសត្រូវរៀបចំនិងអនុវត្តប្រព័ន្ធប្រមូលយកសំណល់នៃឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ត្រឡប់ទៅប្រទេសដើមវិញ ឬធ្វើប្រព្រឹត្តិកម្ម កែច្នៃ កម្ទេចចោលនៅក្នុងស្រុកដោយមិនបង្កគ្រោះថ្នាក់បរិស្ថានឬសុខភាពសាធារណៈ។

**មាត្រា១៥៩ ._ ការហាមឃាត់ការបោះចោលសំណល់ល្មើសច្បាប់**

១- ហាមឃាត់ការបោះចោល បញ្ចេញចោល ឬកម្ទេចចោលសំណល់ល្មើសនឹងបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២- បុគ្គលដែលធ្វើសកម្មភាពផ្ទាល់ បញ្ជា ឬផ្តល់ការសម្របសម្រួលឱ្យមានការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ ត្រូវទទួលខុសត្រូវចំពោះអំពើល្មើសនេះ។

## ជំពូកទី៤

## ការទទួលខុសត្រូវលើការបំពុលបរិស្ថាន

**មាត្រា១៦០ .–** កាតព្វកិច្ចមិនបង្កការបំពុលបរិស្ថាន

បុគ្គលមិនត្រូវធ្វើសកម្មភាពដែលនាំឱ្យមានការបំពុលបរិស្ថាន ទឹក ដី ខ្យល់ ឬបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពឬផលប្រយោជន៍សាធារណៈឬឯកជន។

**មាត្រា១៦១ .–** កាតព្វកិច្ចមិនបង្ករការរំខានដោយសំឡេង រំញ័រ ឬក្លិន

បុគ្គលមិនត្រូវធ្វើសកម្មភាពបញ្ចេញសំឡេង រំញ័រ ឬក្លិន ដែលបង្កឱ្យមានការរំខានដល់ការរស់នៅបង្កឱ្យមានផលប៉ះពាល់ដល់សុខភាព ផលប្រយោជន៍សាធារណៈឬឯកជន។

**មាត្រា១៦២ .–** ការទទួលខុសត្រូវលើបញ្ហាការបំពុលបរិស្ថានឬការបង្កគ្រោះថ្នាក់

បុគ្គលដែលបង្កបញ្ហាបំពុលបរិស្ថានត្រូវទទួលខុសត្រូវលើសំណងផលប៉ះពាល់ដល់សុខភាព អាយុជីវិត ឬការខូចខាតទ្រព្យសម្បត្តិ ដែលបណ្តាលមកពីឥទ្ធិពលនៃបញ្ហាបំពុលបរិស្ថាន និងត្រូវទទួលខុសត្រូវលើសំណងការខូចខាតបរិស្ថាន និងការស្តារការបំពុលបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៦៣ .–** កាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន

បុគ្គលដែលធ្វើសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងបរិស្ថានតាមរយៈការផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬការបញ្ចេញចោលសំណល់ ត្រូវមានកាតព្វកិច្ចបង់ថ្លៃបំពុលបរិស្ថាន។

**មាត្រា១៦៤ .–** ការបង់ប្រាក់កក់សំណល់

ការប្រើប្រាស់ផលិតផល ឧបករណ៍ គ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ ដែលក្រោយពេលប្រើប្រាស់រួចឬលែងប្រើបានក្លាយជាសំណល់គ្រោះថ្នាក់ តម្រូវឱ្យមានការបង់ប្រាក់កក់សំណល់ដោយអ្នកប្រើប្រាស់ និងដែលត្រូវសងត្រឡប់នៅពេលយកសំណល់មកប្តូរ។

**មាត្រា១៦៥ .–** ការគ្រប់គ្រងនិងប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន

១- ថវិកាដែលប្រមូលបានពីការបង់ថ្លៃបំពុលបរិស្ថាន ត្រូវប្រើប្រាស់សម្រាប់គោលដៅសិក្សាស្រាវជ្រាវ និងការធ្វើឱ្យប្រសើរឡើងនូវគុណភាពបរិស្ថាន ឬការស្តារបរិស្ថានដែលទទួលរងការបំពុល។

២- ការគ្រប់គ្រងនិងការប្រើប្រាស់ថវិកាពីការបង់ថ្លៃបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៥
# វិធានការត្រួតពិនិត្យការបំពុលបរិស្ថាន
## ផ្នែកទី១
## ស្តង់ដារគាំពារបរិស្ថាន

### មាត្រា១៦៦ ._ ស្តង់ដារគាំពារបរិស្ថាន

១- ស្តង់ដារគាំពារបរិស្ថាន មានជាអាទិ៍៖

ក- ស្តង់ដារគុណភាពបរិស្ថាន។

ខ- ស្តង់ដារបញ្ចេញសំណល់។

គ- ស្តង់ដារសំឡេងនិងរំញ័រ។

ឃ- ស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល។

ង- ស្តង់ដារពាក់ព័ន្ធកិច្ចគាំពារបរិស្ថានផ្សេងទៀត ស្របតាមការអភិវឌ្ឍបច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍។

២- ស្តង់ដារគាំពារបរិស្ថានដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា១៦៧ ._ ស្តង់ដារគុណភាពបរិស្ថាន

ត្រូវចាត់ទុកជាស្តង់ដារគុណភាពបរិស្ថាន ចំពោះស្តង់ដារពាក់ព័ន្ធនឹងគុណភាពទឹកសាធារណៈ គុណភាពដី គុណភាពខ្យល់បរិយាកាសនិងស្តង់ដាគុណភាពខ្យល់ក្នុងអគារ ដែលកំណត់នូវកម្រិតបរិមាណសារធាតុគីមី ឬសារធាតុបំពុលដែលមិនបង្កហានិភ័យដល់សុខភាពសាធារណៈ សម្រាប់ធ្វើការវាយតម្លៃស្ថានភាពគុណភាពទឹក ដី និងខ្យល់។

### មាត្រា១៦៨ ._ ស្តង់ដារបញ្ចេញសំណល់

ត្រូវចាត់ទុកជាស្តង់ដារបញ្ចេញសំណល់ចំពោះស្តង់ដារពាក់ព័ន្ធការបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ ការបញ្ចេញសារធាតុបំពុលខ្យល់ ការបញ្ចេញសំណល់រឹង ការបញ្ចេញសារធាតុឬសំណល់គ្រោះថ្នាក់ ការបញ្ចេញវិទ្យុសកម្ម ដែលកំណត់នូវកម្រិតបរិមាណសារធាតុគីមី ឬសារធាតុបំពុលអាចអនុញ្ញាតឱ្យបញ្ចេញចូលទៅក្នុងបរិស្ថាន ដែលមិនបង្កហានិភ័យដល់បរិស្ថាននិងសុខភាពសាធារណៈ ដោយត្រូវធ្វើការផ្ទៀងផ្ទាត់និងវាយតម្លៃស្របតាមស្តង់ដារដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា១៦៩ ._ ស្តង់ដារសំឡេងនិងរំញ័រ

ត្រូវចាត់ទុកជាស្តង់ដារសំឡេងនិងរំញ័រ ចំពោះស្តង់ដារពាក់ព័ន្ធការបញ្ចេញសំឡេងនិងរំញ័រ ដែលកំណត់នូវកម្រិតសំឡេងនិងកម្រិតរំញ័រអាចអនុញ្ញាតឱ្យបញ្ចេញក្នុងអគារឬទីចំហរ ដែលមិនបង្ករការរំខានដល់ការរស់នៅ និងមិនបង្កគ្រោះថ្នាក់ដល់សុខភាព ឬការខូចខាតទ្រព្យសម្បត្តិ និងសម្រាប់ការផ្ទៀងផ្ទាត់វាយតម្លៃការអនុវត្តច្បាប់។

### មាត្រា១៧០ ._ ស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល

ត្រូវចាត់ទុកជាស្តង់ដារសារធាតុគ្រោះថ្នាក់នៅក្នុងផលិតផល ចំពោះស្តង់ដារពាក់ព័ន្ធគុណភាពផលិតផលដែលអាចមានផ្ទុកឬប្រឡាក់សារធាតុគ្រោះថ្នាក់ ក្នុងកម្រិតអាចអនុញ្ញាតដែលមិនបង្កហានិភ័យដល់សុខភាពអ្នកប្រើប្រាស់និងបរិស្ថានសម្រាប់ការផ្ទៀងផ្ទាត់វាយតម្លៃការអនុវត្តច្បាប់។

### មាត្រា១៧១ ._ ការធ្វើបច្ចុប្បន្នកម្មស្តង់ដារគាំពារបរិស្ថាន

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើបច្ចុប្បន្នកម្មស្តង់ដារគាំពារបរិស្ថានឱ្យស្របទៅតាមស្ថានភាពរីកចម្រើនសេដ្ឋកិច្ចជាតិ ស្ថានភាពបរិស្ថានជាតិឬលក្ខខណ្ឌតម្រូវនានា និងផលប្រយោជន៍សាធារណៈ។

ROYAUME DU CAMBODGE / LE MINISTRE DU PALAIS ROYAL

**មាត្រា១៧២ .‒ សិទ្ធិទទួលបានព័ត៌មានអំពីស្តង់ដារគាំពារបរិស្ថាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រព័ន្ធទិន្នន័យស្តង់ដារគាំពារបរិស្ថានឱ្យគ្រប់ភាគីពាក់ព័ន្ធ និងសាធារណជនអាចស្វែងរក និងទទួលបានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី២

## លិខិតអនុញ្ញាតសំណល់

**មាត្រា១៧៣ .‒ ការស្នើសុំនិងប្រភេទនៃលិខិតអនុញ្ញាតសំណល់**

១- បុគ្គលដែលមានបំណងបញ្ចេញសំណល់ឬធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ប្រភេទនៃលិខិតអនុញ្ញាតសំណល់មានដូចខាងក្រោម៖

ក- លិខិតអនុញ្ញាតបញ្ចេញសំណល់ មានជាអាទិ៍ លិខិតអនុញ្ញាតបញ្ចេញសំណល់រឹង លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ លិខិតអនុញ្ញាតបញ្ចេញសំណល់រាវ លិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ លិខិតអនុញ្ញាតបញ្ចេញសំឡេង និងលិខិតអនុញ្ញាតបញ្ចេញរំញ័រ។

ខ- លិខិតអនុញ្ញាតអាជីវកម្មសំណល់ មានជាអាទិ៍ លិខិតអនុញ្ញាតធ្វើសេវាកម្មសំណល់ ឬលិខិតអនុញ្ញាតធ្វើអាជីវកម្មប្រមូលសំណល់ លិខិតអនុញ្ញាតដឹកជញ្ជូនសំណល់ លិខិតអនុញ្ញាតស្តុកទុកសំណល់ លិខិតអនុញ្ញាតធ្វើអាជីវកម្មកែច្នៃនិងទាញយកធនធានពីសំណល់ លិខិតអនុញ្ញាតធ្វើប្រព្រឹត្តិកម្មឬលិខិតអនុញ្ញាតការទុកដាក់សំណល់ចុងក្រោយ។

៣- នីតិវិធីទាក់ទងនឹងការស្នើសុំលិខិតអនុញ្ញាតសំណល់ ដូចមានចែងនៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- ទោះបីជាមានបញ្ញត្តក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ នៃមាត្រានេះក៏ដោយ ចំពោះការបញ្ចេញសំណល់ពីទីតាំងរស់នៅប្រចាំថ្ងៃជាលក្ខណៈគ្រួសារដែលមិនមានគោលបំណងធ្វើអាជីវកម្ម មិនតម្រូវឱ្យសុំលិខិតអនុញ្ញាតឡើយ ហើយត្រូវអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៧៤ .‒ លក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតសំណល់**

លិខិតអនុញ្ញាតសំណល់អាចផ្តល់ឱ្យលុះត្រាតែ៖

ក- មានសម្ភារៈ បរិក្ខារ និងមធ្យោបាយត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសសម្រាប់ការបញ្ចេញសំណល់ ឬសម្រាប់ការធ្វើសេវាកម្ម ឬអាជីវកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម ឬទីលានទុកដាក់សំណល់ ដែលធានាមិនបង្កឱ្យមានការបំពុលបរិស្ថាន។

ខ- មានអនុលោមភាពតាមស្តង់ដារបញ្ចេញសំណល់ ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

គ- គោរពតាមលក្ខខណ្ឌនៃវិធានការទប់ស្កាត់ការបំពុលបរិស្ថាន ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឃ- បានបង់កម្រៃសេវាសាធារណៈសម្រាប់ការផ្តល់លិខិតអនុញ្ញាតសំណល់ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា១៧៥ .‒ ការព្យួរឬការដកហូតលិខិតអនុញ្ញាតសំណល់**

លិខិតអនុញ្ញាតសំណល់នឹងត្រូវព្យួរបណ្តោះអាសន្នឬដកហូតជាស្ថាពរ ប្រសិនបើ៖

ក- ប្រើប្រាស់សម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការបញ្ចេញសំណល់ និងការធ្វើអាជីវកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម ឬទីលានទុកដាក់សំណល់មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស។

ខ- មិនបានអនុវត្តត្រឹមត្រូវតាមស្តង់ដារបរិស្ថាននិងវិធានសុវត្ថិភាពបរិស្ថាន។

គ- មានការធ្វេសប្រហែសឬបង្កបទល្មើសក្នុងការគ្រប់គ្រងសំណល់បង្កឱ្យមានការបំពុលបរិស្ថានឬគ្រោះថ្នាក់ដល់សុខភាព។

ឃ- ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវ ដែលកំណត់ក្នុងលិខិតអនុញ្ញាតសំណល់។

## ផ្នែកទី៣
## ការគ្រប់គ្រងការបំពុលបរិស្ថាន

**មាត្រា១៧៦ ._ ការគ្រប់គ្រងការបំពុលបរិស្ថាន**

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលបង្កើតនិងបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រត្រូវទទួលខុសត្រូវៈ

ក- បំពាក់សម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយគ្រប់គ្រងសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងការបញ្ចេញឱ្យឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញសំណល់។

គ- រៀបចំឱ្យមានអ្នកឯកទេសឬបុគ្គលិកបច្ចេកទេសឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុលសំឡេង ឬរំញ័ររបស់ទីតាំងផ្ទាល់។

**មាត្រា១៧៧ ._ ការទទួលស្គាល់អ្នកឯកទេសឬបុគ្គលិកបច្ចេកទេសគ្រប់គ្រងការបំពុលបរិស្ថាន**

១- អ្នកឯកទេសឬបុគ្គលិកបច្ចេកទេស ដែលត្រូវចាត់តាំងឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រងនិងការបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រ ដូចមានចែងក្នុងចំណុច គ មាត្រា១៧៦(ការគ្រប់គ្រងការបំពុលបរិស្ថាន)នៃក្រមនេះ ត្រូវមានការទទួលស្គាល់ជាផ្លូវការពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនៃការទទួលស្គាល់ជាផ្លូវការដល់អ្នកឯកទេសឬបុគ្គលិកបច្ចេកទេសដែលត្រូវចាត់តាំងឱ្យទទួលខុសត្រូវការងារគ្រប់គ្រងការបំពុលបរិស្ថាន និងដំណើរការសម្ភារៈ បរិក្ខារ និងមធ្យោបាយសម្រាប់ការគ្រប់គ្រង និងការបញ្ចេញសំណល់ សារធាតុបំពុល សំឡេង ឬរំញ័រ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ផ្នែកទី៤
## ការអនុវត្តស្វ័យត្រួតពិនិត្យនិងស្វ័យរាយការណ៍

**មាត្រា១៧៨ ._ ការអនុវត្តស្វ័យត្រួតពិនិត្យការបំពុលបរិស្ថាន**

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលការបញ្ចេញសំណល់អាចបង្កហានិភ័យបំពុលបរិស្ថានក្នុងកម្រិតខ្ពស់ ត្រូវអនុវត្តស្វ័យត្រួតពិនិត្យការបំពុលបរិស្ថាននៅក្នុងទីតាំងរបស់ខ្លួន ដោយត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៧៩ .– ការអនុវត្តស្វ័យរាយការណ៍អំពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់និងសំណល់គ្រោះថ្នាក់**

បុគ្គលឬម្ចាស់ទីតាំងផលិត ធ្វើអាជីវកម្ម ឬសេវាកម្មដែលផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬពាក់ព័ន្ធការបង្កើតសំណល់គ្រោះថ្នាក់ត្រូវអនុវត្តវិធានការស្វ័យរាយការណ៍អំពីការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់នៅក្នុងទីតាំងរបស់ខ្លួន ដោយត្រូវអនុលោមតាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៨០ .– ការរាយការណ៍អំពីការសាយភាយនិងសារធាតុបំពុលចូលទៅក្នុងបរិស្ថាន**

១- បុគ្គលឬម្ចាស់ទីតាំងផលិត ឬធ្វើអាជីវកម្ម ដែលនៅក្នុងសកម្មភាពផលិតកម្ម ឬអាជីវកម្មរបស់ខ្លួនបង្កឱ្យមានការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលទៅក្នុងបរិស្ថាន ត្រូវផ្តល់របាយការណ៍ទិន្នន័យភ្លាមៗអំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ប្រភេទទីតាំងផលិតកម្ម ឬអាជីវកម្ម ដែលជាប់កាតព្វកិច្ចផ្តល់របាយការណ៍ទិន្នន័យភ្លាមៗអំពីការសាយភាយ និងការបន្លាស់ទីសារធាតុបំពុលចូលក្នុងបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៨១ .– សិទ្ធិទទួលបានព័ត៌មានពីប្រព័ន្ធទិន្នន័យការសាយភាយនិងការបន្លាស់ទីសារធាតុបំពុល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវដាក់ឱ្យសាធារណជនអាចចូលមើលឬទាញយកព័ត៌មានពីប្រព័ន្ធទិន្នន័យពាក់ព័ន្ធការត្រួតពិនិត្យការបំពុលបរិស្ថាន និងការសាយភាយនិងការបន្លាស់ទីសារធាតុបំពុលស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី៥
## ការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន

**មាត្រា១៨២ .– យន្តការជាតិគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចនិងយន្តការពាក់ព័ន្ធ ត្រូវរៀបចំបង្កើតយន្តការជាតិការគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន ដែលមានភារកិច្ចដូចខាងក្រោម៖

ក- ធ្វើការកំណត់ហានិភ័យការបំពុលបរិស្ថាន ឬការប៉ះពាល់សុខភាពសាធារណៈនៅតំបន់ដែលងាយទទួលរងការបំពុលពីសកម្មភាពអភិវឌ្ឍ ឬពីធម្មជាតិ។

ខ- លើកស្នើវិធានការទប់ស្កាត់ហានិភ័យការបំពុលបរិស្ថាន ឬការប៉ះពាល់សុខភាពសាធារណៈ។

គ- ធ្វើការវាយតម្លៃផលប៉ះពាល់ដល់សុខភាពសាធារណៈ និងការខូចខាតបរិស្ថានពីគ្រោះឧបទ្ទវហេតុដែលបង្កឱ្យមានការសាយភាយសារធាតុពុល ឬសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន។

ឃ- កំណត់និងសម្របសម្រួលការអនុវត្តវិធានការឆ្លើយតបនិងការសង្គ្រោះបន្ទាន់ នៅពេលកើតមានគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន។

២- ការបង្កើតយន្តការជាតិគ្រប់គ្រងការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។



125

**មាត្រា១៨៣ .- ផែនការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថាន**

បុគ្គលឬម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ដែលត្រូវបានកំណត់ថាអាចបង្កហានិភ័យបំពុលបរិស្ថានក្នុងកម្រិតខ្លាំង ត្រូវរៀបចំផែនការឆ្លើយតបបន្ទាន់ សម្រាប់ករណីកើតមានគ្រោះឧបទ្ទវហេតុបង្កការបំពុលបរិស្ថានពីសកម្មភាពផលិតកម្ម អាជីវកម្មឬសេវាកម្មរបស់ខ្លួនតាមការតម្រូវរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## មាតិកាទី២
## ការត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១៨៤ .- គោលបំណង**

មាតិកានេះ មានគោលបំណងត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់តាមរយៈការដាក់ចេញនូវវិធានការនានាដើម្បីពង្រឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់តាមវិធានសុវត្ថិភាពបរិស្ថាន សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា១៨៥ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនៃការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា១៨៦ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការដឹកនាំត្រួតពិនិត្យលើការគ្រប់គ្រងនិងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន។

**មាត្រា១៨៧ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព សម្រាប់គ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន និងសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ ការលេចធ្លាយសារធាតុគ្រោះថ្នាក់។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ក្នុងផលិតផល សម្រាប់ជំរុញការត្រួតពិនិត្យការសាយភាយនិងបញ្ហាបំពុលបរិស្ថានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់។

គ- រៀបចំបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលត្រូវហាមឃាត់ និងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យមានការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់ដោយមានលក្ខខណ្ឌ។

ឃ- រៀបចំនិងគ្រប់គ្រងទិន្នន័យសារធាតុគ្រោះថ្នាក់ដែលផលិត នាំចូល ចែកចាយ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE * LE MINISTÈRE DU PALAIS ROYAL

ង- រៀបចំគោលការណ៍ណែនាំបច្ចេកទេសគ្រប់គ្រងការសាយភាយសារធាតុគ្រោះថ្នាក់ និងឆ្លើយតបបន្ទាន់ សម្រាប់ទប់ស្កាត់និងកាត់បន្ថយការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដែលត្រូវអនុវត្តចំពោះទីតាំង ឬសកម្មភាពដែលពាក់ព័ន្ធការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុកទុក ការចែកចាយ ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់។

ច- ចុះត្រួតពិនិត្យទីតាំង ឬសកម្មភាពពាក់ព័ន្ធការផលិត ការនាំចូល ការដឹកជញ្ជូន ការស្តុកទុក ការចែកចាយ ការប្រើប្រាស់ និងការបោះបង់ចោលសារធាតុគ្រោះថ្នាក់។

ឆ- សិក្សាស្រាវជ្រាវពីកម្រិតសាយភាយសារធាតុគ្រោះថ្នាក់នៅក្នុងបរិស្ថាន ក្នុងសំណាកជីវសាស្ត្រ និងក្នុងផលិតផលអាហារ សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង។

ជ- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា១៨៨ ._ ការសិក្សាស្រាវជ្រាវ តាមដាន និងត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសិក្សាស្រាវជ្រាវនិងត្រួតពិនិត្យទីតាំងផលិត ស្តុក និងប្រើប្រាស់សារធាតុគ្រោះថ្នាក់ និងផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដើម្បីជំរុញការអនុវត្តវិធានការទប់ស្កាត់ការសាយភាយឬកាត់បន្ថយហានិភ័យដល់សុខភាពសាធារណៈនិងបរិស្ថាន។

២- លទ្ធផលនៃការសិក្សាស្រាវជ្រាវនិងត្រួតពិនិត្យការសាយភាយសារធាតុគ្រោះថ្នាក់ត្រូវផ្សព្វផ្សាយ និងផ្តល់ព័ត៌មានដល់សាធារណជន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ជំពូកទី៣
## ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់និងផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

**មាត្រា១៨៩ ._ ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់**

១- បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវធ្វើការចុះបញ្ជិកានៅក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

២- ប្រភេទសារធាតុគ្រោះថ្នាក់ ឬផលិតផលសារធាតុគីមីមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលត្រូវធ្វើការចុះបញ្ជិកាពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៩០ ._ ការផ្តល់ព័ត៌មានការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់**

បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមីដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលបានធ្វើការចុះបញ្ជិកាដូចមានចែងក្នុងមាត្រា១៨៩(ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់) នៃក្រមនេះ ត្រូវផ្តល់ច្បាប់ចម្លងនៃការចុះបញ្ជិកាមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ សម្រាប់គោលបំណងនៃការរៀបចំទិន្នន័យសារធាតុគ្រោះថ្នាក់ ការអង្កេតតាមដាន ការវាយតម្លៃពីហានិភ័យ និងការចាត់វិធានការបង្ការ ឬឆ្លើយតបនឹងហានិភ័យបង្កដោយសារធាតុគ្រោះថ្នាក់ និងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់ជូនសាធារណជន។

ROYAUME DU CAMBODGE
MINISTÈRE DU PALAIS ROYAL

**មាត្រា១៩១ .- ការចុះបញ្ជិកាផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់**

១- បុគ្គលអ្នកផលិត អ្នកនាំចូល ឬអ្នកចែកចាយផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលមានចែងក្នុងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវធ្វើការចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនៃការចុះបញ្ជិកាផលិតផល សម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា១៩២ .- ការបដិសេធការស្នើសុំចុះបញ្ជិកា**

ក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការបដិសេធការស្នើសុំចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលមានចែងក្នុងមាត្រា១៨៩(ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់) និងមាត្រា១៩១(ការចុះបញ្ជិកាផលិតផលឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់) នៃក្រមនេះ ប្រសិនបើ៖

ក- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ ស្ថិតក្នុងបញ្ជីហាមឃាត់នៅក្រោមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន សម្រាប់ការផលិត ការនាំចូល ការចែកចាយ ឬការប្រើប្រាស់។

ខ- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ ស្ថិតក្នុងការហាមឃាត់ការផលិត ឬប្រើប្រាស់ អនុលោមតាមលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- សារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលស្នើសុំចុះបញ្ជិកានោះ ត្រូវបានរកឃើញថាអាចនឹងបង្កឱ្យមានហានិភ័យខ្ពស់ដល់សុខភាពសាធារណៈ និងបរិស្ថាន។

ឃ- ឯកសារបញ្ជាក់ពីវត្តមានលក្ខណៈ ឬកម្រិតផ្ទុកនៃសារធាតុគ្រោះថ្នាក់មានលក្ខណៈមិនគ្រប់គ្រាន់។

**មាត្រា១៩៣ .- ការដកហូតវិញ្ញាបនបត្រចុះបញ្ជិកា**

ក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យនិងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវដកហូតវិញ្ញាបនបត្រចុះបញ្ជិកាសារធាតុគ្រោះថ្នាក់ និងផលិតផល សម្ភារៈប្រើប្រាស់ ឬសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ប្រសិនបើ៖

ក- មានការរកឃើញថាការប្រើប្រាស់ឬការសាយភាយសារធាតុគ្រោះថ្នាក់នោះ បានបង្កឱ្យមានហានិភ័យធ្ងន់ធ្ងរដល់សុខភាពសាធារណៈនិងបរិស្ថាន។

ខ- មានការហាមឃាត់ទាំងស្រុងដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៤

## ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់ សារព្រមានគ្រោះថ្នាក់ ស្លាកសញ្ញាគីមីនិងឯកសារព័ត៌មានពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់

**មាត្រា១៩៤ .- ការដាក់ស្លាកសញ្ញាគ្រោះថ្នាក់លើសម្ភារៈវេចខ្ចប់និងមធ្យោបាយដឹកជញ្ជូនសារធាតុគ្រោះថ្នាក់**

រាល់សម្ភារៈវេចខ្ចប់និងមធ្យោបាយដឹកជញ្ជូនសារធាតុគ្រោះថ្នាក់ ដែលមានចែងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ត្រូវមានដាក់ស្លាកសញ្ញាគ្រោះថ្នាក់និងសារព្រមានគ្រោះថ្នាក់ និងត្រូវភ្ជាប់ឯកសារព័ត៌មានពីសុវត្ថិភាពនៃសារធាតុគ្រោះថ្នាក់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៩៥ .-** ការដាក់សារព្រមានគ្រោះថ្នាក់លើផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

ផលិតផលឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវដាក់សារព្រមានគ្រោះថ្នាក់ មុននឹងចែកចាយឬលក់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា១៩៦ .-** ការដាក់ស្លាកសញ្ញាលើផលិតផលគីមីនិងផលិតផលគីមីប្រើប្រាស់

១- រាល់ផលិតផលគីមីនិងផលិតផលគីមីប្រើប្រាស់ ត្រូវដាក់ស្លាកសញ្ញាគីមីគ្រោះថ្នាក់ និងសារព្រមានគ្រោះថ្នាក់ផ្សេងៗ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ស្លាកសញ្ញាគីមីគ្រោះថ្នាក់និងសារព្រមានគ្រោះថ្នាក់ដែលបិទលើផលិតផលគីមី ត្រូវមានព័ត៌មានដូចខាងក្រោម៖

ក- ព័ត៌មានអំពីផលិតផលនិងប្រភពនៃផលិតផល។

ខ- រូបសញ្ញាអំពីការបង្កគ្រោះថ្នាក់។

គ- ពាក្យព្រមាន។

ឃ- ព័ត៌មានអំពីភាពងាយរងគ្រោះ ត្រូវរៀបចំតាមលំដាប់លេខរៀង ប្រភេទ និងកម្រិតនៃការបង្កគ្រោះថ្នាក់របស់ផលិតផលគីមី និងផលិតផលគីមីប្រើប្រាស់។

ង- ព័ត៌មានអំពីវិធានការបង្ការឬវិធីប្រើប្រាស់។

ច- ព័ត៌មានអំពីផលិតករឬអ្នកផ្គត់ផ្គង់។

ឆ- ស្លាកសញ្ញាមានភាពច្បាស់លាស់ ងាយស្រួលអាន មិនងាយរហែក មិនងាយរបេក ឬលុបសញ្ញា។

ជ- រាល់ព័ត៌មានទាំងអស់ខាងលើត្រូវសរសេរជាភាសាខ្មែរ។

## ជំពូកទី៥
## ភារកិច្ចបុគ្គលពាក់ព័ន្ធនឹងសារធាតុគ្រោះថ្នាក់

**មាត្រា១៩៧ .-** ការផ្ដល់របាយការណ៍ប្រចាំឆ្នាំអំពីសារធាតុគ្រោះថ្នាក់

និតិបុគ្គលដែលផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវផ្ដល់របាយការណ៍ប្រចាំឆ្នាំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពី៖

ក- ប្រភេទនិងបរិមាណសារធាតុគ្រោះថ្នាក់ដែលបានផលិត នាំចូល ចែកចាយ ប្រើប្រាស់ ឬត្រូវបោះបង់ចោល។

ខ- វិធានការនិងមធ្យោបាយសម្រាប់គ្រប់គ្រងនិងទប់ស្កាត់ការសាយភាយសារធាតុគ្រោះថ្នាក់ ឬការបង្កហានិភ័យដល់សុខភាពសាធារណៈនិងបរិស្ថាន។

គ- វិធានការនិងមធ្យោបាយសម្រាប់គ្រប់គ្រងសំណល់សារធាតុគ្រោះថ្នាក់និងសំណល់ ដែលមានផ្ទុកឬប្រឡាក់សារធាតុគ្រោះថ្នាក់។

**មាត្រា១៩៨ .-** ការផ្ដល់របាយការណ៍ប្រចាំឆ្នាំអំពីផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

និតិបុគ្គលដែលផលិត នាំចូល ចែកចាយផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវផ្ដល់របាយការណ៍ប្រចាំឆ្នាំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពី៖

ក- ប្រភេទ បរិមាណផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលបានផលិត នាំចូល ចែកចាយ ឬត្រូវបោះបង់ចោល។

ខ- ការអនុវត្តដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់។

**មាត្រា១៩៩ .- ការរៀបចំផែនការឆ្លើយតបបន្ទាន់**

ម្ចាស់ឬអ្នកគ្រប់គ្រងទីតាំងផលិតកម្ម ស្តុក ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ឬផលិតផល ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ត្រូវរៀបចំផែនការឆ្លើយតបសម្រាប់ការសង្គ្រោះបន្ទាន់ករណីគ្រោះឧបទ្ទវហេតុកំពប់ ឬលេចធ្លាយសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ និងត្រូវដាក់ជូនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២០០ .- កាតព្វកិច្ចរបស់បុគ្គលអ្នកផលិត នាំចូល ស្តុកទុក ដឹកជញ្ជូន ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម**

នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ប្រសិនបើកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ បុគ្គលអ្នកផលិត នាំចូល ស្តុកទុក ដឹកជញ្ជូន ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ក- ជូនដំណឹងជាបន្ទាន់មកក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ឬភ្នាក់ងារសេវាសង្គ្រោះអំពីហេតុការណ៍ ឬគ្រោះឧបទ្ទវហេតុ។

ខ- ចាត់វិធានការជាបន្ទាន់ ដើម្បីកាត់បន្ថយ ទប់ស្កាត់ ឬបញ្ឈប់ការកំពប់ ឬការលេចធ្លាយ និងធ្វើការប្រមូល វេចខ្ចប់ និងសម្អាតសារធាតុគ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ។

គ- ចូលរួមសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងសារធាតុគ្រោះថ្នាក់ដែលបានកំពប់ ឬលេចធ្លាយ សិក្សានិងវាយតម្លៃអំពីផលប៉ះពាល់ដល់សុខភាពសាធារណៈ ទ្រព្យសម្បត្តិ និងបរិស្ថាន។

**មាត្រា២០១ .- ការទទួលខុសត្រូវលើសារធាតុគ្រោះថ្នាក់ខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់**

១- បុគ្គលអ្នកផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ការធ្វើប្រព្រឹត្តិកម្ម ឬការបោះបង់ចោលសារធាតុគ្រោះថ្នាក់ដែលខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ អនុលោមតាមបញ្ញត្តិស្តីពីការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៃក្រមនេះ។

២- សារធាតុគ្រោះថ្នាក់ដែលខូចគុណភាពឬផុតកំណត់កាលបរិច្ឆេទប្រើប្រាស់ ត្រូវចាត់ទុកជាសំណល់គ្រោះថ្នាក់។

**មាត្រា២០២ .- ការទទួលខុសត្រូវលើការខូចខាត**

បុគ្គលដែលបង្កឱ្យមានការកំពប់ឬការលេចធ្លាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ត្រូវទទួលខុសត្រូវលើសំណងការខូចខាតទ្រព្យសម្បត្តិ ផលប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន និងការស្តារ ការបំពុលបរិស្ថានឡើងវិញ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា២០៣ .- ការបង់ថ្លៃបំពុលបរិស្ថាន**

១- បុគ្គលដែលនៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនមានការផលិតឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ត្រូវបង់ថ្លៃបំពុលបរិស្ថាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

២- ប្រភេទទីតាំងដែលតម្រូវឱ្យបង់ថ្លៃការបំពុលបរិស្ថាននិងអត្រាបង់ថ្លៃការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦

## ការហាមឃាត់

**មាត្រា២០៤ .- ការហាមឃាត់សារធាតុគ្រោះថ្នាក់**

បុគ្គលមិនត្រូវផលិត នាំចូល ចែកចាយ ឬប្រើប្រាស់សារធាតុគ្រោះថ្នាក់ ដែល៖

ក- ស្ថិតក្នុងបញ្ជីប្រភេទសារធាតុគ្រោះថ្នាក់ដែលត្រូវហាមឃាត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ពុំមានចុះបញ្ជិកានៅក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យ។

គ- ពុំមានដាក់ស្លាកសញ្ញា ឬសារព្រមានគ្រោះថ្នាក់នៅលើសម្ភារៈវេចខ្ចប់ ឬដាក់ស្លាកសញ្ញាគ្រោះថ្នាក់ក្លែងក្លាយ។

ឃ- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន។

**មាត្រា២០៥ .- ការហាមឃាត់ផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់**

បុគ្គលមិនត្រូវផលិត នាំចូល ឬចែកចាយផលិតផល សម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែល៖

ក- សារធាតុគ្រោះថ្នាក់នោះ ស្ថិតក្នុងបញ្ជីហាមឃាត់នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ខ- ការផលិតឬការនាំចូលពុំមានចុះបញ្ជិកានៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

គ- សារធាតុគ្រោះថ្នាក់ក្នុងផលិតផលមានកម្រិតលើសស្តង់ដារបរិមាណសារធាតុគ្រោះថ្នាក់ ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ឃ- ពុំមានដាក់ស្លាកសញ្ញាព្រមានគ្រោះថ្នាក់នៅលើផលិតផល។

ង- មានការរកឃើញពីភាពគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ ឬបរិស្ថាន។

**មាត្រា២០៦ .- ការហាមឃាត់ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់**

ហាមឃាត់ដាច់ខាតសកម្មភាព ដែលបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន មានជាអាទិ៍៖

ក- ការបញ្ចេញឬបោះបង់ចោលសារធាតុគ្រោះថ្នាក់នៅតាមទីសាធារណៈឬចូលទៅក្នុងប្រភពទឹកសាធារណៈ។

ខ- ការកម្ទេចចោល ឬការដុតសារធាតុគ្រោះថ្នាក់នៅក្នុងដីកម្មសិទ្ធិ នៅតាមទីវាលឬទីសាធារណៈ។

គ- ការបង្កឱ្យមានការកំពប់ឬលេចធ្លាយសារធាតុគ្រោះថ្នាក់។

**មាត្រា២០៧ .- ការចាប់យកសារធាតុគ្រោះថ្នាក់ ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិធ្វើការចាប់យកនូវសារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់ដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃគន្ថីទី៩នៃក្រមនេះ។

## មាតិកាទី៣
## ការគ្រប់គ្រងសំណល់រឹង
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា២០៨ .- គោលបំណង**

មាតិកានេះ មានគោលបំណងគ្រប់គ្រងសំណល់រឹង តាមរយៈការដាក់ចេញនូវវិធានការនានា ដើម្បីលុបបំបាត់ការចោលសំណល់រឹងចាប់ពីទីតាំងបង្កើតរហូតដល់ទីលានទុកដាក់ចុងក្រោយ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា២០៩ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនាំចូល នាំចេញ ញែក វេចខ្ចប់ ប្រមូល ដឹកជញ្ជូន កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម និងទុកដាក់សំរាម សំណល់រឹងទីប្រជុំជន សំណល់ប្លាស្ទិក និងសំណល់រឹងឧស្សាហកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា២១០ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវដឹកនាំនិងពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន សំណល់ប្លាស្ទិក និងសំណល់រឹងឧស្សាហកម្ម។

**មាត្រា២១១ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធការគ្រប់គ្រងសំណល់រឹង និងដឹកនាំសម្របសម្រួលការអនុវត្តរវាងក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ- សិក្សាស្រាវជ្រាវបច្ចេកវិទ្យាពាក់ព័ន្ធនឹងការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៃសំណល់រឹងប្រកបដោយសុវត្ថិភាពបរិស្ថាន។

គ- ផ្តល់ការគាំទ្រនិងជំរុញសកម្មភាពកែច្នៃនិងទាញយកធនធានពីសំណល់រឹង។

ឃ- ផ្តល់ការណែនាំបច្ចេកទេសនិងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពអនុវត្តមុខងារគ្រប់គ្រងសំណល់រឹង។

ង- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ក្នុងការកៀរគរធនធានហិរញ្ញវត្ថុ បច្ចេកទេស មធ្យោបាយ និងសម្ភារៈសម្រាប់គាំទ្រនិងធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងសំណល់រឹងពីដើមខ្សែដល់ចុងខ្សែ។

ច- ដឹកនាំ សម្របសម្រួល និងជំរុញការលើកកម្ពស់ការអប់រំក្នុងប្រព័ន្ធ និងការអប់រំផ្សព្វផ្សាយជាសាធារណៈពីការគ្រប់គ្រងសំណល់រឹង សំដៅជំរុញឱ្យមានការផ្លាស់ប្តូរឥរិយាបថលើការគ្រប់គ្រងសំណល់រឹង និងការចូលរួមប្រើប្រាស់និងបង់ថ្លៃសេវាសំណល់រឹង។

ឆ- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសលើការជ្រើសរើសទីតាំងដើម្បីបង្កើតទីលាន ការរៀបចំទីលាន និងវិធានការគាំពារបរិស្ថានក្នុងពេលប្រតិបត្តិការ និងការបិទបញ្ចប់ទីលានទុកដាក់សំណល់រឹង។

ជ- សហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តមុខងារគ្រប់គ្រងសំណល់រឹង។

## ជំពូកទី៣

## ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

**មាត្រា២១២ .- ការបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន**

១- ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ជាយន្តការថ្នាក់ជាតិដើម្បីដឹកនាំនយោបាយនិងយុទ្ធសាស្ត្រ និងផ្តល់ការគាំទ្រធនធានថវិកា និងបច្ចេកទេសសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

២- តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១៣ .- ការគ្រប់គ្រងទិន្នន័យសំរាម សំណល់រឹងទីប្រជុំជន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសំរាម សំណល់រឹងទីប្រជុំជន និងត្រូវកំណត់នូវវិធានការ តម្រូវការធនធានឬមធ្យោបាយចាំបាច់សម្រាប់ជំរុញការបង្កើនសមត្ថភាពនិងប្រសិទ្ធភាពសេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនឱ្យបានគ្របដណ្តប់នៅទូទាំងប្រទេស និងធានាបាននិរន្តរភាពសុវត្ថិភាពបរិស្ថាន។

**មាត្រា២១៤ .- ផែនការសកម្មភាពសម្រាប់ការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងគ្រប់ភាគីពាក់ព័ន្ធ ត្រូវកំណត់យុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តកម្មវិធីកាត់បន្ថយការបង្កើតសំរាមតាមរយៈការញែកសំណល់នៅនឹងប្រភព ការដឹកជញ្ជូនទៅតាមប្រភេទ និងលើកកម្ពស់សកម្មភាពការកែច្នៃការទាញយកធនធាន និងការធ្វើប្រព្រឹត្តិកម្មសំណល់។

**មាត្រា២១៥ .- រដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវអនុវត្តគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងមានភារកិច្ចដូចខាងក្រោម៖

ក- រៀបចំលិខិតបទដ្ឋានចាំបាច់នានា សម្រាប់ជំរុញការអនុវត្តវិធានការគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ខ- រៀបចំផែនការសកម្មភាពនិងផែនការថវិកាសម្រាប់ការគ្រប់គ្រង ការសម្អាត ការប្រមូល ការដឹកជញ្ជូន និងការលុបបំបាត់ការចោលរាយប៉ាយនូវសំរាម សំណល់រឹងទីប្រជុំជន។

គ- ជំរុញការអនុវត្តការញែកសំណល់និងកម្មវិធីកាត់បន្ថយការបង្កើត ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំរាម ការទាញយកធនធានពីសំរាម សំណល់រឹងទីប្រជុំជន។

ឃ- បង្កើត គ្រប់គ្រង និងចាត់ចែងសេវាសម្អាត ប្រមូល ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន និងសេវាទីលានទុកដាក់។

ង- អប់រំនិងផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងការធ្វើអនាម័យ ការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ការចូលរួមប្រើប្រាស់និងការបង់សេវាប្រមូលដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន។

ROYAUME DU CAMBODGE * SECRETARIAT DU PALAIS ROYAL

៦- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការផ្តល់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

៨- អនុវត្តវិធានការអប់រំ និងវិធានការច្បាប់លើបទល្មើសការចោលសំរាមរាយប៉ាយ ការគេចវេះការប្រើប្រាស់ និងការមិនបង់សេវាសំរាម សំណល់រឹងទីប្រជុំជន។

៨- រៀបចំរបាយការណ៍ប្រចាំឆ្នាំអំពីទិន្នន័យ ស្ថានភាពនិងដំណើរការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដើម្បីដាក់ជូនក្រសួងស្ថាប័នមានសមត្ថកិច្ច។

## ផ្នែកទី១

## ការទទួលខុសត្រូវរបស់អ្នកបង្កើតសំរាម សំណល់រឹងទីប្រជុំជន

### មាត្រា២១៦ .- កាតព្វកិច្ចម្ចាស់សំរាម សំណល់រឹងទីប្រជុំជន

បុគ្គលដែលបង្កើតសំរាម សំណល់រឹងទីប្រជុំជនត្រូវមានកាតព្វកិច្ចអនុវត្តតាមគោលការណ៍កំណត់របស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន មានជាអាទិ៍ ការញែក ការវេចខ្ចប់ ការទុកដាក់ ការបញ្ចេញ ការសម្អាត ការប្រើប្រាស់សេវា និងការបង់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

### មាត្រា២១៧ .- វិធានការលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈ

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ និងពិបាកមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់ តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទផលិតផលឬសម្ភារៈដែលតម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### មាត្រា២១៨ .- ការហាមឃាត់ការបោះចោលនិងការដុតសំរាម សំណល់រឹងទីប្រជុំជន

១- ហាមឃាត់ដាច់ខាតការបោះចោលសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ប្រឡាយទឹក ប្រភពទឹកសាធារណៈឬក្នុងដីកម្មសិទ្ធិ ដែលមិនត្រូវបានអនុញ្ញាតជាកន្លែងស្តុកទុកសំរាមជាបណ្តោះអាសន្ន ឬជាកន្លែងទុកដាក់ចុងក្រោយ។

២- ហាមឃាត់ដាច់ខាតការដុតសំរាម សំណល់រឹងទីប្រជុំជននៅតាមដងផ្លូវ ទីសាធារណៈ ក្នុងដីកម្មសិទ្ធិ ទីវាល ឬការដុតក្នុងឡដុតសំណល់ ដែលមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

### មាត្រា២១៩ .- ការទទួលខុសត្រូវចំពោះការខូចខាត

បុគ្គលដែលបង្កើតសំរាម សំណល់រឹងទីប្រជុំជន ដែលបង្កឱ្យមានការបំពុលបរិស្ថាន ការប៉ះពាល់ដល់សុខភាពសាធារណៈ ឬការខូចខាតទ្រព្យសម្បត្តិបណ្តាលពីសកម្មភាពគ្រប់គ្រងរបស់ខ្លួនត្រូវទទួលខុសត្រូវលើការខូចខាតនិងការស្តារការបំពុលបរិស្ថាន អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី២

## សេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

### មាត្រា២២០ .- ការរៀបចំសេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន

១- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវក្នុងការរៀបចំឱ្យមាននិងដំណើរការសេវាប្រមូល ដឹកជញ្ជូន និងសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនប្រកបដោយគុណភាព ប្រសិទ្ធភាព និងសុវត្ថិភាពបរិស្ថានក្នុងដែនរដ្ឋបាលរបស់ខ្លួន។

២- នីតិវិធីនិងលក្ខខណ្ឌតម្រូវសម្រាប់ការរៀបចំនិងការគ្រប់គ្រងសេវាប្រមូល ដឹកជញ្ជូន និងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា២២១ ._ កាតព្វកិច្ចអ្នកផ្ដល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងទីប្រជុំជន**

បុគ្គលដែលទទួលសិទ្ធិផ្ដល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងត្រូវជានាះ

ក- អនុវត្តលក្ខខណ្ឌតម្រូវដែលបានកំណត់ក្នុងកិច្ចសន្យាផ្ដល់សេវាសម្អាត ប្រមូល ដឹកជញ្ជូន និងសេវាទីលានសំរាម សំណល់រឹងទីប្រជុំជន។

ខ- ផ្ដល់សេវាដែលមិនបង្កផលប៉ះពាល់ដល់បរិស្ថាន សុខភាព ឬផលប្រយោជន៍សាធារណៈ។

គ- សហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាកកស្ទះសំរាម។

ឃ- ដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ដែលបានកំណត់។

ង- ទទួលខុសត្រូវលើការខូចខាតទ្រព្យសម្បត្តិ ការប៉ះពាល់ដល់សុខភាពសាធារណៈ និងការស្ដារការបំពុលបរិស្ថាន ដែលបង្កពីសកម្មភាពផ្ដល់សេវារបស់ខ្លួន។

ច- ផ្ដល់របាយការណ៍ទៀងទាត់អំពីប្រតិបត្តិការសេវាកម្មរបស់ខ្លួនជូនអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២២២ ._ ការអនុញ្ញាតបង្កើតសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន**

ការវិនិយោគបង្កើតសេវាទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន ត្រូវមានការអនុញ្ញាតពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិលើបច្ចេកទេស និងវិធានការគាំពារសុវត្ថិភាពបរិស្ថាននៃសេវាទីលាន។

## ជំពូកទី៤
## ការគ្រប់គ្រងសំណល់ប្លាស្ទិក

**មាត្រា២២៣ ._ ក្រសួងស្ថាប័នទទួលខុសត្រូវគ្រប់គ្រងសំណល់ប្លាស្ទិក**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវទទួលខុសត្រូវៈ

ក- រៀបចំសេចក្ដីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការគ្រប់គ្រងសំណល់ប្លាស្ទិក ក្នុងគោលដៅកាត់បន្ថយការប្រើប្រាស់ផលិតផលប្លាស្ទិក ការបង្កើតសំណល់ប្លាស្ទិក និងបង្កើនសកម្មភាពកែច្នៃ និងទាញយកធនធានពីសំណល់ប្លាស្ទិក។

ខ- ធ្វើការកំណត់អំពីប្រភេទ ស្តង់ដារ និងលក្ខខណ្ឌចាំបាច់នានានៃផលិតផល ឬសម្ភារៈប្លាស្ទិកដែលអាចអនុញ្ញាតឱ្យនាំចូល ឬធ្វើការផលិតនៅក្នុងស្រុក។

គ- ធ្វើការកំណត់ប្រភេទផលិតផល ឬសម្ភារៈប្លាស្ទិកដែលត្រូវហាមឃាត់ការប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ដោយមានលក្ខខណ្ឌ។

ឃ- ធ្វើការកំណត់ទីតាំង ឬបង្កើតតំបន់ដែលគ្មានថង់ប្លាស្ទិក ឬគោលដៅ ដែលតម្រូវឱ្យអនុវត្តវិធានការហាមឃាត់ការប្រើប្រាស់ ឬអនុញ្ញាតឱ្យប្រើប្រាស់ផលិតផល ឬសម្ភារៈប្លាស្ទិកដោយមានលក្ខខណ្ឌ។

ង- ជំរុញនិងផ្ដល់ការគាំទ្រការផលិតនិងការប្រើប្រាស់ផលិតផល ឬសម្ភារៈ ដែលអាចប្រើប្រាស់ជំនួសផលិតផល ឬសម្ភារៈប្លាស្ទិក។

ច- លើកទឹកចិត្ត និងផ្តល់ការគាំទ្រលើការកែច្នៃ និងការទាញយកធនធានពីសំណល់ប្លាស្ទិក។

ឆ- អប់រំនិងលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តគោលនយោបាយ កម្មវិធីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈការជៀសវាងប្រើថង់ប្លាស្ទិកលើសភាពចាំបាច់ ការប្រើថង់ក្រណាត់ជំនួស ឬថង់ដែលប្រើបានច្រើនដង ការបញ្ចូលទំនិញក្នុងថង់តែមួយ និងការប្រើប្រាស់សម្ភារៈងាយពុកផុយ។

**មាត្រា២២៤ ._ កាតព្វកិច្ចចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក**

ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចចូលរួមចំណែកក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក តាមរយៈការប្រើប្រាស់ឡើងវិញនូវថង់ប្លាស្ទិកដែលបានប្រើប្រាស់រួចឬប្រើវត្ថុផ្សេងជំនួសថង់ប្លាស្ទិក។

**មាត្រា២២៥ ._ ការលើកទឹកចិត្តលើការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក**

ម្ចាស់ទីតាំងអាជីវកម្ម ឬម្ចាស់សេវាកម្មនានា ម្ចាស់ផ្សារទំនើប ឬមជ្ឈមណ្ឌលពាណិជ្ជកម្ម ត្រូវបានលើកទឹកចិត្តឱ្យចូលរួមចំណែកដោយស្ម័គ្រចិត្តក្នុងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក។

**មាត្រា២២៦ ._ ការនាំចូលនិងការផលិតថង់ឬសម្ភារៈវេចខ្ចប់ពីវត្ថុធាតុងាយពុកផុយឬជីវប្លាស្ទិក**

ការនាំចូលនិងការផលិតថង់ឬសម្ភារៈវេចខ្ចប់ ដែលផលិតពីវត្ថុធាតុងាយពុកផុយឬជីវប្លាស្ទិក ត្រូវបានដាក់អាករពិសេសជាបន្ទុករបស់រដ្ឋ។ ធុរជនពាក់ព័ន្ធត្រូវស្នើសុំដាក់អាករពិសេសជាបន្ទុករបស់រដ្ឋទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២២៧ ._ វិធានការលើការនាំចូលនិងការផលិតផលិតផលឬសម្ភារៈប្លាស្ទិក**

ការនាំចូលនិងការផលិតផលិតផលឬសម្ភារៈប្លាស្ទិក ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ លើប្រភេទនិងលក្ខខណ្ឌតម្រូវនានា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា២២៨ ._ វិធានការដាក់តម្លៃលើអ្នកប្រើប្រាស់ផលិតផលឬសម្ភារៈប្លាស្ទិក**

១- ការប្រើប្រាស់ផលិតផលឬសម្ភារៈប្លាស្ទិកដែលអាចបង្កឱ្យមានហានិភ័យដល់បរិស្ថាន សុខភាពសាធារណៈ និងពិបាកនិងមិនអាចកែច្នៃបានក្រោយពេលក្លាយជាសំណល់ តម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទផលិតផលឬសម្ភារៈប្លាស្ទិកដែលតម្រូវឱ្យមានការដាក់តម្លៃលើអ្នកប្រើប្រាស់ និងទីតាំងគោលដៅត្រូវអនុវត្ត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២២៩ ._ វិធានការលើការគ្រប់គ្រងសំណល់ប្លាស្ទិកនៅតាមទីតាំងបង្កើត**

បុគ្គលឬម្ចាស់ទីតាំងដែលមានការប្រើប្រាស់ផលិតផល ឬសម្ភារៈប្លាស្ទិក រួមទាំងម្ចាស់លំនៅឋាន ត្រូវទទួលខុសត្រូវក្នុងការញែក ទុកដាក់ និងបញ្ចេញសំណល់ប្លាស្ទិកដែលបានបង្កើតតាមការតម្រូវដោយក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា២៣០ ._ ការហាមឃាត់ការបោលនិងការដុតសំណល់ប្លាស្ទិក**

១- ហាមឃាត់ដាច់ខាតការបោលសំណល់ប្លាស្ទិកនៅតាមដងផ្លូវ ទីសាធារណៈ ទីវាល ប្រព័ន្ធទឹកលូ ប្រព័ន្ធទឹក និងចូលប្រភពទឹកសាធារណៈ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ហាមឃាត់ជាដាច់ខាតការដុតសំណល់ប្លាស្ទិកនៅតាមទីសាធារណៈ តាមទីវាល តាមទីលានសំរាម ឬការដុតក្នុងឡដុតសំណល់ ដែលមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៥
## ការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម

**មាត្រា២៣១ .- ក្រសួងស្ថាប័នទទួលខុសត្រូវត្រួតពិនិត្យសំណល់រឹងឧស្សាហកម្ម**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាស្ថាប័នទទួលខុសត្រូវដឹកនាំត្រួតពិនិត្យលើការគ្រប់គ្រងសំណល់រឹងឧស្សាហកម្ម មានជាអាទិ៍ ការញែក ការស្តុកបណ្តោះអាសន្ន ការដឹកជញ្ជូន ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយ។

**មាត្រា២៣២ .- កាតព្វកិច្ចម្ចាស់ទីតាំងបង្កើតសំណល់រឹងឧស្សាហកម្ម**

បុគ្គលម្ចាស់ទីតាំងដែលបង្កើតសំណល់រឹងឧស្សាហកម្ម ត្រូវទទួលខុសត្រូវលើការគ្រប់គ្រងសំណល់របស់ខ្លួន មានជាអាទិ៍ ការញែក ការទុកដាក់ ការដឹកជញ្ជូន ការធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៅទីលានដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា២៣៣ .- លិខិតអនុញ្ញាតបញ្ចេញសំណល់រឹងឧស្សាហកម្ម**

ម្ចាស់សំណល់រឹងឧស្សាហកម្មដែលមានបំណងធ្វើការបញ្ចេញសំណល់រឹងឧស្សាហកម្មពីទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតបញ្ចេញសំណល់រឹងឧស្សាហកម្មជាមុន ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៣៤ .- លិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្ម**

ប្រតិបត្តិករដែលធ្វើអាជីវកម្មសេវាប្រមូល ដឹកជញ្ជូន សេវាប្រព្រឹត្តិកម្ម និងទីលានទុកដាក់ចុងក្រោយសំណល់រឹងឧស្សាហកម្ម ត្រូវមានលិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្មជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៦
## ការកែច្នៃ ការទាញយកធនធាន ការធ្វើប្រព្រឹត្តិកម្ម ការនាំចេញ និងការនាំចូលសំណល់រឹង

**មាត្រា២៣៥ .- លិខិតអនុញ្ញាតសេវាកម្មឬអាជីវកម្មកែច្នៃនិងទាញយកធនធានសំណល់រឹង**

ការធ្វើសេវាកម្មឬអាជីវកម្មកែច្នៃ ទាញយកធនធាន ឬធ្វើប្រព្រឹត្តិកម្មសំណល់រឹងត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៣៦ .- ការនាំចេញសំណល់រឹងឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹង**

ការនាំចេញសំណល់រឹងឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹង ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៣៧ .- ការនាំចូលសំណល់រឹង**

ការនាំចូលសំណល់រឹងពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានហាមឃាត់ លើកលែងតែសំណល់រឹង ដែលជាកម្មវត្ថុនាំចូលសម្រាប់បំពេញបន្ថែមដល់គម្រោងវិនិយោគកែច្នៃសំណល់ក្នុងស្រុក។ ក្នុងករណីនេះ ការនាំចូលសំណល់រឹង ត្រូវមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល ដោយអនុវត្តតាមនីតិវិធីជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



825

# មាតិកាទី៤
# ការគ្រប់គ្រងសំណល់គ្រោះថ្នាក់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា២៣៨ ._ គោលបំណង**

មាតិកានេះ មានគោលបំណងគ្រប់គ្រងសំណល់គ្រោះថ្នាក់ តាមរយៈការដាក់ចេញនូវវិធានការនានាដើម្បីលុបបំបាត់ការចោលសំណល់គ្រោះថ្នាក់ចាប់ពីការបង្កើតរហូតដល់ការទុកដាក់ចុងក្រោយ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា២៣៩ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពនាំចូល នាំចេញ ដឹកជញ្ជូន ប្រមូល ស្តុកទុក កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម និងការទុកដាក់ចុងក្រោយនៃសំណល់គ្រោះថ្នាក់ប្រកបដោយសុវត្ថិភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា២៤០ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងការត្រួតពិនិត្យសំណល់គ្រោះថ្នាក់។

**មាត្រា២៤១ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការគ្រប់គ្រងសំណល់គ្រោះថ្នាក់។

ខ- រៀបចំបញ្ជីប្រភេទសំណល់គ្រោះថ្នាក់ ដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- គ្រប់គ្រងទិន្នន័យនិងព័ត៌មានប្រភពបង្កើតសំណល់គ្រោះថ្នាក់ និងទីតាំងសេវាកម្មប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តិកម្ម និងទីលានទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់។

ឃ- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម រួមទាំងសកម្មភាពនាំចូល នាំចេញ និងដឹកឆ្លងកាត់នៃសំណល់គ្រោះថ្នាក់។

ង- ពិនិត្យនិងផ្តល់ការអនុញ្ញាតលើសំណើគម្រោងសេវាប្រមូល ដឹកជញ្ជូន កែច្នៃ ធ្វើប្រព្រឹត្តិកម្ម កម្ទេចចោល និងទីលានទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់ និងការស្នើសុំការអនុញ្ញាតបញ្ចេញ នាំចេញ និងដឹកឆ្លងកាត់នៃសំណល់គ្រោះថ្នាក់។

ច- សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយអំពីប្រភេទ កម្រិតគ្រោះថ្នាក់ ឬផលប៉ះពាល់នៃសំណល់គ្រោះថ្នាក់ដែលសាយភាយចូលទៅក្នុងបរិស្ថាន។

ឆ- សម្របសម្រួលជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ក្នុងការជំរុញការរៀបចំផែនការសកម្មភាព ការត្រៀមសម្ភារៈ មធ្យោបាយ និងធនធានសម្រាប់ការឆ្លើយតបបន្ទាន់ចំពោះករណីគ្រោះឧបទ្ទវហេតុនៃការឆេះ ការផ្ទុះ ការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់។



៧

ជ- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៣
## វិធានការគ្រប់គ្រងសំណល់អាគុយនិងសំណល់ថ្មពិល

**មាត្រា២៤២ ._ កាតព្វកិច្ចរៀបចំទុកដាក់សំណល់អាគុយនិងសំណល់ថ្មពិល**

លំនៅឋាន ទីផ្សារ ផ្សារទំនើប ទីកន្លែងកម្សាន្ត អគារសាធារណៈ គ្រឹះស្ថានសិក្សា សកម្មភាពអាជីវកម្មសេវាកម្ម និងសិប្បកម្ម ត្រូវមានកាតព្វកិច្ចទុកដាក់និងរៀបចំបែងចែកសំណល់អាគុយ និងសំណល់ថ្មពិលដាច់ដោយឡែកពីសំណល់ផ្សេងទៀត ទៅតាមគោលការណ៍ណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៤៣ ._ ការប្រមូល ការរក្សាទុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយនិងសំណល់ថ្មពិល**

ការប្រមូល ការរក្សាទុក ការដឹកជញ្ជូន ការដោះបំបែក និងការធ្វើប្រព្រឹត្តិកម្មសំណល់អាគុយ និងសំណល់ថ្មពិលគ្រប់ប្រភេទ និងការបោះបង់ចោល ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងត្រូវអនុវត្តតាមវិធានសុវត្ថិភាពបរិស្ថាន។

**មាត្រា២៤៤ ._ ការស្នើសុំលិខិតអនុញ្ញាត**

១- រាល់អាជីវកម្មលើសំណល់អាគុយដែលមានលក្ខណៈជាអាជីវកម្មគ្រួសារ ត្រូវសុំលិខិតអនុញ្ញាតពីស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត។

២- រាល់អាជីវកម្មសំណល់អាគុយដែលមានលក្ខណៈជាអាជីវកម្មខ្នាតតូចនិងមធ្យម ឬអាជីវកម្មខ្នាតធំ ត្រូវសុំលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៤៥ ._ ការនាំចេញសំណល់អាគុយនិងសំណល់ថ្មពិល**

រាល់ការនាំចេញសំណល់អាគុយនិងសំណល់ថ្មពិលពីព្រះរាជាណាចក្រកម្ពុជាទៅក្រៅប្រទេស អាចធ្វើបានលុះត្រាតែមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតអនុញ្ញាតឱ្យនាំចូលរបស់សាមីប្រទេសជាមុនសិន។

**មាត្រា២៤៦ ._ ហាមឃាត់ការដុតឬការវាយបំបែកសំណល់អាគុយនិងសំណល់ថ្មពិល**

ហាមឃាត់ដាច់ខាតរាល់ការដុត ឬការវាយបំបែកសំណល់អាគុយ និងសំណល់ថ្មពិល ដែលបង្កឱ្យប៉ះពាល់ឬគ្រោះថ្នាក់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

**មាត្រា២៤៧ ._ កម្រៃសេវានៃការស្នើសុំលិខិតអនុញ្ញាត**

កម្រៃសេវានៃការស្នើសុំលិខិតអនុញ្ញាតសម្រាប់ការប្រមូល ការស្តុក ការដឹកជញ្ជូន ការបំបែកសំណល់អាគុយនិងសំណល់ថ្មពិលក្នុងបំណងយកសំណ ឬសារធាតុផ្សេងៗ ការធ្វើប្រព្រឹត្តិកម្ម ការបោះបង់ចោល និងការបង្កើតទីលានសុវត្ថិភាព ត្រូវអនុលោមតាមប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៤៨ ._ កាតព្វកិច្ចរាយការណ៍**

ម្ចាស់អាជីវកម្ម ត្រូវមានកាតព្វកិច្ចរាយការណ៍ជូនស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់៦(ប្រាំមួយ)ខែម្តង ពីការវិវត្តនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយ និងសំណល់ថ្មពិលនៅក្នុងទីតាំងអាជីវកម្មរបស់ខ្លួន ដើម្បីធានានូវសុវត្ថិភាពបរិស្ថាននិងសុខភាពសាធារណៈ។

**មាត្រា២៤៩ .- កាតព្វកិច្ចតាមដាននិងរាយការណ៍**

ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិរាជធានី ខេត្ត ត្រូវមានកាតព្វកិច្ចតាមដាននិងរាយការណ៍ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់៦(ប្រាំមួយ)ខែម្តង ពីការវិវត្តនូវរាល់ការប្រមូល ការស្តុក ការទុកដាក់ ការដឹកជញ្ជូន ការដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម និងការបោះបង់ចោលសំណល់អាគុយនិងសំណល់ថ្មពិលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដើម្បីធានានូវសុវត្ថិភាពបរិស្ថាននិងសុខភាពសាធារណៈ។

**មាត្រា២៥០ .- ការត្រួតពិនិត្យតាមដាននិងការណែនាំ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានភារកិច្ចត្រួតពិនិត្យតាមដានការបំពុលដោយអាជីវកម្ម សំណល់អាគុយ និងសំណល់ថ្មពិល និងធ្វើការណែនាំទៅដល់ម្ចាស់អាជីវកម្ម លើវិធានការគ្រប់គ្រងឱ្យបានត្រឹមត្រូវ។

## ជំពូកទី៤
## វិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់
### ផ្នែកទី១
### ការបង្កើតសំណល់គ្រោះថ្នាក់

**មាត្រា២៥១ .- ការជូនដំណឹងពីការបង្កើតសំណល់គ្រោះថ្នាក់**

បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអំពីប្រភេទ ប្រភព និងបរិមាណសំណល់គ្រោះថ្នាក់ដែលបានបង្កើត និងវិធានការគ្រប់គ្រងដែលបានអនុវត្ត។

**មាត្រា២៥២ .- កាតព្វកិច្ចរបស់ម្ចាស់សំណល់គ្រោះថ្នាក់**

១- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់ត្រូវទទួលខុសត្រូវក្នុងការវេចខ្ចប់ ដាក់សញ្ញាព្រមាន ទុកដាក់ស្តុកទុក ធ្វើប្រព្រឹត្តិកម្ម និងបញ្ចេញសំណល់គ្រោះថ្នាក់ឱ្យស្របតាមវិធានសុវត្ថិភាពបរិស្ថាន។

២- វិធានសុវត្ថិភាពបរិស្ថានត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥៣ .- លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់**

១- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួន ដែលមានបំណងធ្វើការបញ្ចេញសំណល់គ្រោះថ្នាក់ចេញពីទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- បុគ្គលដែលបង្កើតសំណល់គ្រោះថ្នាក់នៅក្នុងផលិតកម្ម អាជីវកម្ម ឬសេវាកម្មរបស់ខ្លួន ដែលមានបំណងធ្វើប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់នៅលើទីតាំងរបស់ខ្លួន ត្រូវមានលិខិតអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

### ផ្នែកទី២
### ការទទួលខុសត្រូវអ្នកផលិត នាំចូល ឬអ្នកផ្គត់ផ្គង់ផ្តាច់មុខលើគ្រឿងបរិក្ខារ និងសម្ភារៈដែលបង្កើតជាសំណល់គ្រោះថ្នាក់

**មាត្រា២៥៤ .- ការទទួលខុសត្រូវប្រមូលយកសំណល់គ្រោះថ្នាក់**

១- នីតិបុគ្គលដែលផ្គត់ផ្គង់ផ្តាច់មុខលើឧបករណ៍ ឬគ្រឿងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវរៀបចំនិងអនុវត្តប្រព័ន្ធប្រមូលយកសំណល់នៃឧបករណ៍ឬគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកត្រឡប់ទៅប្រទេសដើម ឬធ្វើការកម្ទេចចោលនៅក្នុងស្រុកដោយមិនបង្កគ្រោះថ្នាក់បរិស្ថានឬសុខភាពសាធារណៈ។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

១៩០

២- ប្រភេទគ្រឿងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដែលតម្រូវឱ្យមានការប្រមូលយកត្រឡប់ទៅប្រទេសដើមវិញ ឬធ្វើការកម្ទេចចោលនៅក្នុងស្រុក ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៥៥ ._ ការអនុវត្តប្រាក់កក់សំណល់គ្រោះថ្នាក់**

១- នីតិបុគ្គលដែលផលិតឬនាំចូលឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ដែលក្រោយពេលប្រើប្រាស់រួចឬលែងប្រើបានក្លាយជាសំណល់គ្រោះថ្នាក់ ត្រូវអនុវត្តការដាក់បញ្ចូលតម្លៃប្រាក់កក់សំណល់បន្ថែមលើតម្លៃគ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ និងដែលត្រូវសងត្រឡប់នៅពេលយកសំណល់មកប្តូរសម្រាប់ការប្រមូលយកសំណល់ពីអតិថិជនឬអ្នកប្រើប្រាស់។

២- ប្រភេទឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ ដែលតម្រូវឱ្យមានការដាក់បញ្ចូលតម្លៃប្រាក់កក់សំណល់បន្ថែមលើតម្លៃឧបករណ៍ គ្រឿងបរិក្ខារ ឬសម្ភារៈប្រើប្រាស់ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៥៦ ._ ការស្នើសុំការអនុញ្ញាតប្រកបអាជីវកម្ម**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ការធ្វើប្រព្រឹត្តិកម្ម ឬឡដុតសំណល់ និងការបង្កើតទីលានបោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនិងបំពេញទម្រង់បែបបទនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៥៧ ._ កាតព្វកិច្ចចំពោះសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក**

បុគ្គលដែលមានសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវបំពេញកាតព្វកិច្ចទាំងអស់ដូចខាងក្រោម៖

ក- រក្សាទុកសំណល់នៅទីសុវត្ថិភាពនិងដាក់ដោយឡែកពីសំណល់លំនៅឋាន។

ខ- បញ្ជូនសំណល់ទៅទីតាំងកែច្នៃឬកន្លែងប្រមូលផ្តុំសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកតាមការកំណត់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៥៨ ._ កាតព្វកិច្ចរបស់ម្ចាស់អាជីវកម្ម**

ម្ចាស់ទីតាំងអាជីវកម្មប្រមូលទិញ ស្តុកទុក ដោះបំបែក ដំឡើង ឬកែច្នៃសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ត្រូវបំពេញកាតព្វកិច្ចទាំងអស់ដូចខាងក្រោម៖

ក- អនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាននៅក្នុងដំណើរការអាជីវកម្មរបស់ខ្លួន។

ខ- រៀបចំទិន្នន័យសំណល់ដែលត្រូវបានបង្កើតពីអាជីវកម្មរបស់ខ្លួន។

គ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលត្រូវបានបង្កើតពីការជួសជុល អនុលោមតាមការកំណត់របស់ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៥៩ ._ កាតព្វកិច្ចបុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក**

បុគ្គលដែលផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ប្រមូលនិងទុកដាក់សំណល់ចេញពីដំណើរការផលិតបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកដោយអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

ខ- បំពាក់ឧបករណ៍ត្រួតពិនិត្យការបំពុលបរិស្ថាន។

គ- រៀបចំទិន្នន័យសំណល់ដែលត្រូវបានបង្កើតពីផលិតកម្មរបស់ខ្លួន។

ឃ- ប្រើប្រាស់សេវាប្រមូលសំណល់ដែលត្រូវបានបង្កើតពីការជួសជុល អនុលោមតាមការកំណត់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៦០ ._ ការហាមឃាត់ការបោះចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក**

ហាមឃាត់ចំពោះការបោះបង់ចោលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិកទៅក្នុងប្រភពទឹក ឬទីលានចាក់សំរាម ឬនៅទីសាធារណៈនានា និងការដុត ឬការវាយបំបែកសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលបង្កឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាន ឬសុខភាពសាធារណៈ។

## ផ្នែកទី៣

## ការទទួលខុសត្រូវរបស់ប្រតិបត្តិករសំណល់គ្រោះថ្នាក់

**មាត្រា២៦១ ._ លិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់**

ប្រតិបត្តិករសំណល់គ្រោះថ្នាក់ដែលផ្តល់សេវាកម្មប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់សំណល់គ្រោះថ្នាក់ចុងក្រោយ ឬធ្វើអាជីវកម្មទិញ លក់ កែច្នៃ ឬទាញយកធនធានពីសំណល់គ្រោះថ្នាក់ត្រូវមានលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់ជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៦២ ._ កាតព្វកិច្ចរបស់ប្រតិបត្តិករសំណល់គ្រោះថ្នាក់**

ប្រតិបត្តិករសំណល់គ្រោះថ្នាក់ដែលផ្តល់សេវាកម្មឬធ្វើអាជីវកម្មសំណល់គ្រោះថ្នាក់ត្រូវទទួលខុសត្រូវៈ

ក- គ្រប់គ្រងសំណល់គ្រោះថ្នាក់នៅលើទីតាំងផ្តល់សេវារបស់ខ្លួនស្របតាមវិធានសុវត្ថិភាពបរិស្ថាន និងតាមលក្ខខណ្ឌនៃលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់។

ខ- ដាក់សញ្ញាព្រមានគ្រោះថ្នាក់នៅតាមមធ្យោបាយដឹកជញ្ជូននិងទីតាំងផ្តល់សេវាកម្ម ឬធ្វើអាជីវកម្ម។

គ- ផ្តល់របាយការណ៍អំពីប្រភេទនិងបរិមាណសំណល់គ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម ឬអាជីវកម្ម និងវិធានការគ្រប់គ្រងសំណល់គ្រោះថ្នាក់មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់១(មួយ)ឆ្នាំម្តង ឬតាមតម្រូវការចាំបាច់។

**មាត្រា២៦៣ ._ ការបង់ថ្លៃបំពុលបរិស្ថាន**

១- ប្រតិបត្តិករសំណល់គ្រោះថ្នាក់ដែលធ្វើអាជីវកម្មទាញយកធនធានឡើងវិញ ធ្វើប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់ចុងក្រោយសំណល់គ្រោះថ្នាក់ត្រូវបង់ថ្លៃការបំពុលបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប្រភេទទីតាំងដែលតម្រូវឱ្យបង់ថ្លៃការបំពុលបរិស្ថាន និងអត្រាបង់ថ្លៃការបំពុលបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌខាងលើ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៤

## ការនាំចូល ការនាំចេញ និងការដឹកជញ្ជូនឆ្លងកាត់សំណល់គ្រោះថ្នាក់

**មាត្រា២៦៤ ._ ការហាមឃាត់ការនាំចូលសំណល់គ្រោះថ្នាក់**

ការនាំចូលសំណល់គ្រោះថ្នាក់ពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានហាមឃាត់ លើកលែងតែសំណល់គ្រោះថ្នាក់ដែលជាកម្មវត្ថុនាំចូលសម្រាប់បំពេញបន្ថែម ដល់គម្រោងវិនិយោគកែច្នៃសំណល់គ្រោះថ្នាក់ក្នុងស្រុក។ ក្នុងករណីនេះ របៀបបទនិងនីតិវិធីនៃការនាំចូលសំណល់គ្រោះថ្នាក់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៦៥ ._ ការអនុញ្ញាតនាំចេញសំណល់គ្រោះថ្នាក់**

ការនាំចេញសំណល់គ្រោះថ្នាក់ពីព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាត លុះត្រាតែបានបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

ក- មានលិខិតអនុញ្ញាតឱ្យធ្វើការនាំចូលរបស់ប្រទេសសាមី។

ខ- មានលិខិតអនុញ្ញាតឱ្យនាំចេញរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

គ- មានលិខិតធានារបស់អ្នកនាំចេញដែលបញ្ជាក់ថា សំណល់គ្រោះថ្នាក់ដែលបាននាំចេញនិងមិនធ្វើការនាំត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

ឃ- បានបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ អនុលោមតាមលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងលក្ខខណ្ឌចាំបាច់ដទៃទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា២៦៦ ._ ការអនុញ្ញាតឱ្យដឹកជញ្ជូនសំណល់គ្រោះថ្នាក់ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា**

ការដឹកជញ្ជូនសំណល់គ្រោះថ្នាក់ពីប្រទេសមួយទៅប្រទេសមួយទៀត ដោយឆ្លងកាត់តាមព្រះរាជាណាចក្រកម្ពុជាត្រូវបានអនុញ្ញាត លុះត្រាតែបានបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម៖

ក- មានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច រយៈពេលយ៉ាងតិច ៣០(សាមសិប)ថ្ងៃ មុនការដឹកជញ្ជូនឆ្លងកាត់។

ខ- បានបង់ថ្លៃសេវាដឹកជញ្ជូនឆ្លងកាត់តាមការកំណត់របស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ- មានកិច្ចសន្យាទទួលសងការខូចខាតនិងការសម្អាតបរិស្ថាន ក្នុងករណីមានឧបទ្ទវហេតុលេចធ្លាយសំណល់គ្រោះថ្នាក់ដោយចៃដន្យក្នុងពេលដឹកជញ្ជូនឆ្លងកាត់។

ឃ- អាចធ្វើការស៊ុំចតបណ្តោះអាសន្នពេលដឹកជញ្ជូនឆ្លងកាត់រយៈពេលយ៉ាងយូរត្រឹម១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃចូលដល់ព្រះរាជាណាចក្រកម្ពុជា។

ង- បានបំពេញតាមនីតិវិធីនាំចេញសំណល់គ្រោះថ្នាក់ ដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងលក្ខខណ្ឌចាំបាច់ដទៃទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល។

## ផ្នែកទី៥
## វិធានការលើករណីកំពប់ឬលេចធ្លាយសំណល់គ្រោះថ្នាក់

**មាត្រា២៦៧ ._ ការរៀបចំផែនការឆ្លើយតបបន្ទាន់**

ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម ដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ ត្រូវរៀបចំផែនការឆ្លើយតបនិងសង្គ្រោះបន្ទាន់សម្រាប់ករណីគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសំណល់គ្រោះថ្នាក់ និងត្រូវដាក់ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីពិនិត្យនិងផ្តល់យោបល់សម្រេច។

**មាត្រា២៦៨ ._ កាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម**

នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ប្រសិនបើកើតមានគ្រោះថ្នាក់ ឬគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ផ្ទុះ ឆេះ ឬសាយភាយសំណល់គ្រោះថ្នាក់ ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្ម ដែលបង្កើតសំណល់គ្រោះថ្នាក់ និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៧៥

ក- ជូនដំណឹងជាបន្ទាន់និងស្នើសុំកិច្ចអន្តរាគមន៍ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងភ្នាក់ងារសេវាសង្គ្រោះអំពីហេតុការណ៍ ឬគ្រោះឧបទ្ទវហេតុ។

ខ- ចាត់វិធានការជាបន្ទាន់ដើម្បីរារាំង ឬបញ្ឈប់ការកំពប់ ឬការលេចធ្លាយ និងធ្វើការប្រមូល វេចខ្ចប់ និងសម្អាតសំណល់គ្រោះថ្នាក់ដែលបានកំពប់ឬលេចធ្លាយ។

គ- ចូលរួមសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ក្នុងការផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងសំណល់គ្រោះថ្នាក់ដែលបានកំពប់ លេចធ្លាយ ផ្ទុះ ឬឆេះ និងការវាយតម្លៃផលប៉ះពាល់ ឬគ្រោះថ្នាក់ទៅលើមនុស្ស សត្វ ឬបរិស្ថានពីករណីកំពប់ ឬលេចធ្លាយសំណល់គ្រោះថ្នាក់។

**មាត្រា២៦៩ .‒ ការទទួលខុសត្រូវលើការខូចខាតពីការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់**

ម្ចាស់សំណល់គ្រោះថ្នាក់ និងប្រតិបត្តិករសំណល់គ្រោះថ្នាក់ ត្រូវទទួលខុសត្រូវលើសំណងការខូចខាតដល់ផលប៉ះពាល់ដល់សុខភាពសាធារណៈ ទ្រព្យសម្បត្តិ ឬបរិស្ថាន និងការស្តារការបំពុលបរិស្ថានឡើងវិញ ដែលបណ្តាលមកពីការកំពប់ ការលេចធ្លាយសំណល់គ្រោះថ្នាក់ចូលទៅក្នុងបរិស្ថានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី៦
## ការហាមឃាត់

**មាត្រា២៧០ .‒ ការប្រើប្រាស់សេវាសំណល់គ្រោះថ្នាក់មិនមានការអនុញ្ញាត**

ហាមឃាត់ដាច់ខាតការប្រគល់ឱ្យ លក់ដូរ ឬផ្តល់ជាអំណោយឱ្យទៅបុគ្គល ដែលមិនមានច្បាប់អនុញ្ញាតផ្តល់សេវាសំណល់គ្រោះថ្នាក់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៧១ .‒ សកម្មភាពដោះបំបែកមិនមានការអនុញ្ញាត**

ហាមឃាត់ដាច់ខាតសកម្មភាពដោះបំបែកគ្រឿងបរិក្ខារឬសម្ភារៈប្រើប្រាស់ ដែលចាត់ទុកជាសំណល់គ្រោះថ្នាក់ដោយមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៧២ .‒ សកម្មភាពបង្កផលប៉ះពាល់**

ហាមឃាត់ដាច់ខាតសកម្មភាពស្តុកទុក បញ្ចេញ ដុត កប់ បោះចោលសំណល់គ្រោះថ្នាក់ ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ បរិស្ថាន ឬបង្កការខូចខាតទ្រព្យសម្បត្តិ។

## ជំពូកទី៥
## ការត្រួតពិនិត្យការគ្រប់គ្រងសំណល់គ្រោះថ្នាក់

**មាត្រា២៧៣ .‒ សមត្ថកិច្ចត្រួតពិនិត្យ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានភារកិច្ចត្រួតពិនិត្យរាល់មធ្យោបាយគ្រប់គ្រងសំណល់គ្រោះថ្នាក់នៅទីតាំងបង្កើតសំណល់គ្រោះថ្នាក់និងទីតាំងសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់ ដែលបានតម្រូវឱ្យធ្វើការបំពាក់ស្របតាមវិធានសុវត្ថិភាពបរិស្ថាននិងលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់ ឬលិខិតអនុញ្ញាតសេវាកម្ម អាជីវកម្មសំណល់គ្រោះថ្នាក់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



KS

**មាត្រា២៧៤ .- អធិការកិច្ចសំណល់គ្រោះថ្នាក់**

១- ក្នុងករណីមានសេចក្តីរាយការណ៍ ឬបណ្តឹងពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ ឬដំណើរការសេវាសំណល់គ្រោះថ្នាក់ដែលបង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ ជីវៈចម្រុះ និងបរិស្ថាន ឬបង្កឱ្យខូចខាតទ្រព្យសម្បត្តិសាធារណៈ ឬឯកជន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយមានការសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់អនុលោមតាមនីតិវិធីអធិការកិច្ចការបំពុលបរិស្ថានដូចមានចែងក្នុងក្រមនេះ។

២- ក្នុងករណីរកឃើញថា ភាពបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពសាធារណៈ បរិស្ថាន ឬទ្រព្យសម្បត្តិបណ្តាលពីការលួចបញ្ចេញចោលសំណល់គ្រោះថ្នាក់ និងការទុកដាក់ ឬក្នុងដំណើរការសេវាសំណល់គ្រោះថ្នាក់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសិទ្ធិចេញលិខិតជាលាយលក្ខណ៍អក្សរដើម្បីផ្អាកសកម្មភាពលួចបញ្ចេញ ឬសកម្មភាពផលិតកម្ម សេវាកម្ម ដែលមានការពាក់ព័ន្ធនឹងការបង្កឱ្យមានគ្រោះថ្នាក់ជាបន្ទាន់ និងត្រូវចាត់ការតាមនីតិវិធីច្បាប់ជាបន្ត។

## មាតិកាទី៥
## ការត្រួតពិនិត្យការបំពុលទឹក
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា២៧៥ .- គោលបំណង**

មាតិកានេះ មានគោលបំណងទប់ស្កាត់និងកាត់បន្ថយការបំពុលទឹក តាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសកម្មភាពពាក់ព័ន្ធដែលបង្កឱ្យមានការបំពុលទឹកសំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា២៧៦ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពបញ្ចេញសំណល់រាវឬសារធាតុបំពុលពីប្រភពជាក់លាក់ និងប្រភពមិនជាក់លាក់ចូលក្នុងប្រភពទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា២៧៧ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងការត្រួតពិនិត្យការបំពុលទឹកដែលបង្កពីប្រភពជាក់លាក់និងប្រភពមិនជាក់លាក់។

**មាត្រា២៧៨ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងសៀវភៅណែនាំបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងការបំពុលទឹក និងការគ្រប់គ្រងការបញ្ចេញសំណល់រាវ និងទឹកកខ្វក់ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ខ- រៀបចំវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការគ្រប់គ្រងសំណល់រាវ ទឹកកខ្វក់ និងសារធាតុបំពុល។

គ- អង្កេត តាមដាន និងវាយតម្លៃស្ថានភាពនៃការបំពុលទឹកសាធារណៈ និងតំបន់ងាយទទួលរងការបំពុលទឹក និងផ្សព្វផ្សាយជូនជាសាធារណៈ។

ឃ- គ្រប់គ្រងទិន្នន័យប្រភពបង្កការបំពុលទឹក ទិន្នន័យគុណភាពទឹកសាធារណៈ និងសារធាតុបំពុលដែលសាយភាយចូលក្នុងតំបន់ទឹកសាធារណៈ។

ង- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃបច្ចេកវិទ្យាប្រព្រឹត្តិកម្ម និងមធ្យោបាយគ្រប់គ្រងសំណល់រាវ ទឹកកខ្វក់ និងប្រព័ន្ធប្រព្រឹត្តិកម្មនៅតាមទីតាំងសកម្មភាពផលិតកម្ម អាជីវកម្ម និងសេវាកម្ម។

ច- ពិនិត្យនិងផ្ដល់យោបល់បច្ចេកទេសបរិស្ថាន និងការទទួលស្គាល់វិស្វកម្មបរិស្ថានលើប្រព័ន្ធប្រព្រឹត្តិកម្មសំណល់រាវ និងទឹកកខ្វក់។

ឆ- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាទប់ស្កាត់ការបំពុលតំបន់ទឹកសាធារណៈ និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលទៅលើសុខភាពសាធារណៈ ជីវៈចម្រុះ និងបរិស្ថាន។

ជ- រៀបចំផែនការសកម្មភាព សម្រាប់ការឆ្លើយតបបន្ទាន់ករណីគ្រោះឧបទ្ទវហេតុនៃការកំពប់ ការលេចធ្លាយសារធាតុបំពុលបរិស្ថាន ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ឈ- ផ្ដល់ការគាំទ្រ ការណែនាំបច្ចេកទេស និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ញ- បំពេញភារកិច្ចជាស្ថាប័នបង្គោលជាតិ នៃកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងការបំពុលទឹកដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា២៧៩ ._** តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនអនុលោមតាមក្រមនេះនិងលិខិតបទដ្ឋានជាធរមាន។

## ជំពូកទី៣
## ការត្រួតពិនិត្យការបំពុលទឹកសាធារណៈ

**មាត្រា២៨០ ._** ផែនការសកម្មភាពគ្រប់គ្រងការបំពុលទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំផែនការសកម្មភាពបង្ការ ទប់ស្កាត់ កាត់បន្ថយការបំពុលទឹកសាធារណៈនិងធ្វើឱ្យប្រសើរឡើងគុណភាពទឹកនៃប្រភពទឹកសាធារណៈ ដែលទទួលរងការបំពុល។

**មាត្រា២៨១ ._** ការរៀបចំស្តង់ដារនិងធ្វើចំណាត់ថ្នាក់គុណភាពទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំស្តង់ដារគុណភាពទឹកសាធារណៈនិងធ្វើចំណាត់ថ្នាក់និងសន្ទស្សន៍គុណភាពទឹកសម្រាប់កិច្ចគាំពារសុខភាពសាធារណៈ ជីវៈចម្រុះ និងការវាយតម្លៃស្ថានភាពគុណភាពទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៨២ ._** ការត្រួតពិនិត្យតាមដានការបំពុលទឹកសាធារណៈ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការត្រួតពិនិត្យតាមដានគុណភាពទឹកសាធារណៈនិងគុណភាពទឹកនៅតំបន់ងាយទទួលរងការបំពុល សម្រាប់ការវាយតម្លៃអំពីស្ថានភាពគុណភាពទឹកសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៨៣ .- ការផ្តល់ព័ត៌មានអំពីការបំពុលទឹកសាធារណៈ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំដាក់ឱ្យសាធារណជនអាចស្វែងរកព័ត៌មាន និងរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យ តាមដាន និងវាយតម្លៃការបំពុលទឹកសាធារណៈ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា២៨៤ .- ការចាត់វិធានការក្នុងករណីការបំពុលទឹកសាធារណៈ**

ក្នុងករណីស្ថានភាពគុណភាពទឹក ឬសមត្ថភាពស្វ័យសម្អាតនៃតំបន់ទឹកសាធារណៈណាមួយមានការថយចុះដែលអាចបង្កឱ្យមានបញ្ហាការបំពុលទឹក ឬការប៉ះពាល់ដល់សុខភាពសាធារណៈធ្ងន់ធ្ងរ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវ៖

ក- ចាត់វិធានការទប់ស្កាត់និងកាត់បន្ថយការបំពុលទឹកសាធារណៈនិងធ្វើឱ្យប្រសើរឡើងគុណភាពទឹកនៃតំបន់ទឹកសាធារណៈ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធ។

ខ- ពិនិត្យការបង្កើតស្តង់ដារបញ្ចេញសំណល់រាវ ឬទឹកកខ្វក់ដោយឡែក សម្រាប់អនុវត្តចំពោះតំបន់ទឹកសាធារណៈដែលងាយទទួលរងការបំពុល ឬតំបន់ទឹកដែលត្រូវធ្វើការអភិរក្ស។

**មាត្រា២៨៥ .- ការបំពុលទឹកឆ្លងដែន**

ករណីកើតមានការបំពុលទឹកឆ្លងដែន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធត្រូវចាត់វិធានការអន្តរាគមន៍ជាបន្ទាន់ អនុលោមតាមផែនការឆ្លើយតបបន្ទាន់និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងត្រូវកំណត់ពីវិសាលភាពនៃការខូចខាតបង្កពីការបំពុលទឹកឆ្លងដែន។

## ជំពូកទី៤

## ការត្រួតពិនិត្យការបំពុលទឹកពីប្រភពជាក់លាក់

**មាត្រា២៨៦ .- លិខិតអនុញ្ញាតបញ្ចេញសំណល់រាវ**

ការបញ្ចេញសំណល់រាវពីប្រភពជាក់លាក់ចូលទៅក្នុងតំបន់ទឹកសាធារណៈលើដីឬក្រោមដី និងចូលក្នុងប្រព័ន្ធលូសាធារណៈ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៨៧ .- ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពជាក់លាក់**

ម្ចាស់ឬប្រតិបត្តិករនៃប្រភពជាក់លាក់ត្រូវទទួលខុសត្រូវអនុវត្តការគ្រប់គ្រង និងការធ្វើប្រព្រឹត្តិកម្មសំណល់រាវ និងទឹកកខ្វក់របស់ខ្លួនមុនពេលបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈ និងត្រូវទទួលខុសត្រូវលើសកម្មភាពដូចខាងក្រោម៖

ក- បំពាក់និងដំណើរការបរិក្ខារប្រព្រឹត្តិកម្មសំណល់រាវតាមលក្ខណៈបច្ចេកទេស ដើម្បីឱ្យការបញ្ចេញសំណល់រាវឆ្លើយតបនឹងស្តង់ដារបញ្ចេញ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ខ- អនុវត្តវិធានការស្វ័យតាមដានត្រួតពិនិត្យនិងស្វ័យរាយការណ៍លើការគ្រប់គ្រង និងការបញ្ចេញសំណល់រាវ។

គ- រៀបចំឱ្យមានអ្នកទទួលខុសត្រូវអនុវត្តការគ្រប់គ្រងការបំពុលបរិស្ថាន សម្រាប់ប្រតិបត្តិការបរិក្ខារប្រព្រឹត្តិកម្មសំណល់រាវរបស់ខ្លួន។

### មាត្រា២៨៨ ._ ការតម្រូវឱ្យជូនដំណឹង

ម្ចាស់ឬប្រតិបត្តិករនៃប្រភពជាក់លាក់ ដែលបានទទួលលិខិតអនុញ្ញាតបញ្ចេញសំណល់រាវ ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្នុងករណី៖

ក- ដំណើរការប្រព័ន្ធបរិក្ខារប្រព្រឹត្តិកម្មសំណល់រាវមានភាពមិនប្រក្រតីឬមានឧបទ្ទវហេតុកើតឡើងជាយថាហេតុ។

ខ- ដំណើរការបរិក្ខារត្រួតពិនិត្យស្វ័យប្រវត្តិតាមដានគុណភាពសំណល់រាវ ដែលបញ្ចេញមានភាពមិនប្រក្រតី។

គ- ខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវដែលមានកំណត់ក្នុងលិខិតអនុញ្ញាតបញ្ចេញសំណល់រាវ។

### មាត្រា២៨៩ ._ ការវិភាគសំណាកសំណល់រាវ

១- សំណាកសំណល់រាវដែលប្រមូលយកក្នុងពេលត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ច និងក្នុងការអនុវត្តតាមដានត្រួតពិនិត្យដោយម្ចាស់សំណល់រាវ ត្រូវវិភាគដោយមន្ទីរពិសោធន៍របស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬមន្ទីរពិសោធន៍ផ្សេងទៀតដែលទទួលបានវិញ្ញាបនបត្រវិជ្ជាជីវៈវិភាគពីស្ថាប័នជាតិឬអន្តរជាតិ។

២- ម្ចាស់សំណល់រាវត្រូវទទួលខុសត្រូវបង់ថ្លៃសេវាវិភាគសំណាកសំណល់រាវរបស់ខ្លួន។

### មាត្រា២៩០ ._ វិធានការឆ្លើយតបករណីមានការបំពុល

១- ក្នុងករណីដែលការបញ្ចេញសំណល់រាវ ឬមានឧបទ្ទវហេតុការលេចធ្លាយសំណល់រាវពីប្រភពជាក់លាក់បង្កឱ្យមានផលប៉ះពាល់ដល់សុខភាពសាធារណៈ និងបរិស្ថាន ផលិតកម្ម កសិកម្ម ឧស្សាហកម្ម វារីវប្បកម្ម ឬសុវត្ថិភាពទឹកស្អាតសាធារណៈ ម្ចាស់ឬប្រតិបត្តិករប្រភពជាក់លាក់ត្រូវចាត់វិធានការឆ្លើយតបជាបន្ទាន់ ដើម្បីទប់ស្កាត់ និងកាត់បន្ថយគ្រោះថ្នាក់ ឬផលប៉ះពាល់ និងត្រូវជូនដំណឹងដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិជាបន្ទាន់។

២- ក្នុងករណីមានការបំពុលធ្ងន់ធ្ងរ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបញ្ជាឱ្យផ្អាកផ្នែកខ្លះ ឬផ្អាកទាំងស្រុងនៃដំណើរការរបស់ប្រភពជាក់លាក់ដែលទាក់ទងនឹងការបង្កឱ្យមានការបំពុលបរិស្ថាន។

### មាត្រា២៩១ ._ ការគ្រប់គ្រងសំណល់កកពីអាងប្រព្រឹត្តិកម្ម

ម្ចាស់ឬប្រតិបត្តិករនៃប្រភពជាក់លាក់ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់កក ដែលកើតចេញពីដំណើរការប្រព្រឹត្តិកម្មសំណល់រាវ ស្របតាមគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### មាត្រា២៩២ ._ ការតម្រូវបង់ថ្លៃបំពុលបរិស្ថាន

១- បុគ្គលដែលបញ្ចេញសំណល់រាវពីប្រភពជាក់លាក់ ហើយបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងបរិស្ថានត្រូវបង់ថ្លៃបំពុលបរិស្ថាន។

២- ប្រភេទប្រភពជាក់លាក់ដែលតម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាននិងអត្រាបង់ថ្លៃការបំពុលបរិស្ថានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## ការត្រួតពិនិត្យការបំពុលទឹកពីប្រភពមិនជាក់លាក់

**មាត្រា២៩៣ .-** ផែនការសកម្មភាពសម្រាប់ទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក- រៀបចំផែនការសកម្មភាពបង្ការនិងទប់ស្កាត់ការបំពុលទឹកពីប្រភពមិនជាក់លាក់។

ខ- ចាត់វិធានការឆ្លើយតបជាក់ស្តែងជាបន្ទាន់ សម្រាប់ការកាត់បន្ថយឬការស្តារការបំពុលទឹកពីប្រភពមិនជាក់លាក់។

គ- រៀបចំគោលការណ៍ណែនាំបច្ចេកទេសស្តីពីកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់។

**មាត្រា២៩៤ .-** លក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតចំពោះគម្រោងឬសកម្មភាព

ក្រសួងស្ថាប័នពាក់ព័ន្ធ ដែលមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតដល់គម្រោង ឬសកម្មភាពដែលអាចបង្កឱ្យមានការបំពុលទឹកត្រូវពិនិត្យដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃលិខិតអនុញ្ញាតគម្រោង ឬសកម្មភាពនោះឱ្យមានការអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរលើការគ្រប់គ្រងការបំពុលទឹកពីប្រភពមិនជាក់លាក់។

**មាត្រា២៩៥ .-** កាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរ

បុគ្គលដែលមានសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់ដី ឬការបង្កឱ្យមានការសាយភាយសារធាតុបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ត្រូវមានកាតព្វកិច្ចអនុវត្តកិច្ចប្រតិបត្តិបរិស្ថានដ៏ប្រសើរក្នុងការទប់ស្កាត់ការបំពុលទឹកពីសកម្មភាពគម្រោង ឬអាជីវកម្មរបស់ខ្លួន។

## ជំពូកទី៦
## ការត្រួតពិនិត្យការបំពុលសមុទ្រ

**មាត្រា២៩៦ .-** ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការត្រួតពិនិត្យការបំពុលសមុទ្រ និងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបង្ការ ការទប់ស្កាត់ និងការកាត់បន្ថយការបំពុលសមុទ្រ។

ខ- រៀបចំនិងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធការបំពុលសមុទ្រ។

គ- ត្រួតពិនិត្យសកម្មភាពប្រភពបំពុលពីដីគោក ដែនកោះ ទីតាំងបូមប្រេង និងជលយាន។

ឃ- សម្របសម្រួលការរៀបចំនិងការអនុវត្តផែនការឆ្លើយតបបន្ទាន់ ក្នុងករណីកើតមានឧបទ្ទវហេតុបំពុលសមុទ្រ។

ង- អនុវត្តការអប់រំផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់សាធារណជនពីផែនការ និងវិធានការឆ្លើយតបទប់ស្កាត់និងកាត់បន្ថយការបំពុលសមុទ្រ។

**មាត្រា២៩៧ .– ការសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការឆ្លើយតបបន្ទាន់ទាក់ទងនឹងការបំពុលសមុទ្រពីដីគោក ការដឹកជញ្ជូនតាមជលយាន ការធ្វើអាជីវកម្មប្រេង ឬរ៉ែបាតសមុទ្រ និងការដោះស្រាយបញ្ហាបំពុលបរិស្ថានសមុទ្រឆ្លងដែន។

**មាត្រា២៩៨ .– ការហាមឃាត់ការបញ្ចេញសំណល់**

ហាមឃាត់ដាច់ខាតចំពោះការបញ្ចេញសំណល់រឹង រាវ ទឹកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោក ដែនកោះ ទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា២៩៩ .– ការទទួលខុសត្រូវរបស់ម្ចាស់ជលយាន**

១- ម្ចាស់ជលយានត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់និងត្រូវនាំយកសំណល់ទាំងនោះមកទុកដាក់នៅដីគោកដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

២- ជលយានដូចបានកំណត់នៅក្នុងកថាខណ្ឌទី១ខាងលើនេះ មានជាអាទិ៍ ជលយានដឹកទំនិញ ដឹកប្រេងឥន្ធនៈ ដឹកអ្នកដំណើរ ទេសចរណ៍ នេសាទ ដចម្លង នាវាបូមដីនិងក្រួសខ្សាច់។

៣- ម្ចាស់ជលយានអន្តរជាតិត្រូវទទួលខុសត្រូវក្នុងការលេចធ្លាយសារធាតុគីមី ប្រេងឥន្ធនៈ និងសំណល់គ្រប់ប្រភេទដែលបង្កការបំពុលបរិស្ថានសមុទ្រ។

**មាត្រា៣០០ .– ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងអាជីវកម្មប្រេងឬរ៉ែបាតសមុទ្រ**

ម្ចាស់គម្រោងអាជីវកម្មប្រេងឬរ៉ែបាតសមុទ្រ ត្រូវទទួលខុសត្រូវៈ

- ក- រៀបចំផែនការឆ្លើយតបបន្ទាន់សម្រាប់ករណីគ្រោះឧបទ្ទវហេតុកំពប់ លេចធ្លាយ ឬឆេះប្រេង និងសារធាតុគីមី។
- ខ- សហការនិងផ្តល់ព័ត៌មានបន្ទាន់មកក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងករណីកើតមានឧបទ្ទវហេតុគ្រោះថ្នាក់។
- គ- បំពាក់មធ្យោបាយសម្រាប់ទុកដាក់សំណល់និងមធ្យោបាយឆ្លើយតបឧបទ្ទវហេតុ ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៣០១ .– ការទទួលខុសត្រូវរបស់ម្ចាស់កំពង់ផែសាធារណៈនិងឯកជន**

ម្ចាស់កំពង់ផែសាធារណៈនិងឯកជន ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំមធ្យោបាយសម្រាប់ទទួលនិងទុកដាក់សំណល់ពីជលយាន ដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៣០២ .– ការទទួលខុសត្រូវរបស់ម្ចាស់ទីតាំងសាងសង់ឬជួសជុលជលយាន**

ម្ចាស់ទីតាំងសាងសង់ឬជួសជុលជលយាន ត្រូវទទួលខុសត្រូវគ្រប់គ្រងសំណល់ដែលបានបង្កើតពីសកម្មភាពសាងសង់ ជួសជុល រុះរើ ឬលាងសម្អាតជលយានតាមវិធានសុវត្ថិភាពបរិស្ថានសម្រាប់ការគ្រប់គ្រងសំណល់និងសារធាតុបំពុលដូចបានកំណត់នៅក្នុងចំណុច ខ នៃមាត្រា២៧៨(តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ)នៃក្រមនេះ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣០៣ .– ការបំពុលសមុទ្រឆ្លងដែន**

ក្នុងករណីកើតមានការបំពុលសមុទ្រឆ្លងដែន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការឆ្លើយតបបន្ទាន់ដោយសហការជាមួយអង្គការពាក់ព័ន្ធថ្នាក់តំបន់និងអន្តរជាតិ អនុលោមតាមផែនការឆ្លើយតបបន្ទាន់ លិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៣០៤ .– ការទទួលខុសត្រូវចំពោះសំណងខូចខាតពីការបំពុលសមុទ្រ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងអង្គការពាក់ព័ន្ធថ្នាក់ជាតិ ត្រូវសហការជាមួយអង្គការថ្នាក់តំបន់និងអន្តរជាតិកំណត់ពីវិសាលភាពនៃការខូចខាតដែលបណ្តាលមកពីការបំពុលសមុទ្រ។

២- បែបបទនិងនីតិវិធីនៃការទាមទារនិងការទូទាត់សំណងខូចខាតពីការបំពុលសមុទ្រ និងការស្តារការខូចខាតបរិស្ថានឡើងវិញត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## មាតិកាទី៦
## ការត្រួតពិនិត្យការបំពុលខ្យល់ សំឡេង និងរំញ័រ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៣០៥ .– គោលបំណង**

មាតិកានេះ មានគោលបំណងទប់ស្កាត់និងកាត់បន្ថយការបំពុលខ្យល់ សំឡេង និងរំញ័រតាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសកម្មភាពដែលបង្កឱ្យមានការបំពុលខ្យល់ សំឡេង និងរំញ័រ សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា៣០៦ .– វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពបញ្ចេញសារធាតុបំពុលខ្យល់ សំឡេង និងរំញ័រពីប្រភពចល័តនិងអចល័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣០៧ .– ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវដឹកនាំការគ្រប់គ្រង និងសម្របសម្រួលការត្រួតពិនិត្យការបំពុលខ្យល់ សំឡេង និងរំញ័រ។

**មាត្រា៣០៨ .– តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសពាក់ព័ន្ធការគ្រប់គ្រងការបំពុលខ្យល់ សំឡេង និងរំញ័រ។

ខ- រៀបចំស្តង់ដារគុណភាពខ្យល់បរិយាកាស ស្តង់ដារគុណភាពខ្យល់ក្នុងអគារ ស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ និងស្តង់ដារសំឡេង និងរំញ័រ និងសន្ទស្សន៍គុណភាពខ្យល់បរិយាកាស។

គ- តាមដានត្រួតពិនិត្យនិងវាយតម្លៃគុណភាពខ្យល់បរិយាកាស និងផ្សព្វផ្សាយស្ថានភាពគុណភាពខ្យល់បរិយាកាស។

ឃ- គ្រប់គ្រងទិន្នន័យគុណភាពខ្យល់បរិយាកាស ប្រភពបំពុលខ្យល់ និងសារធាតុបំពុលដែលសាយភាយចូលទៅក្នុងខ្យល់។

ង- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃបរិក្ខារប្រព្រឹត្តិកម្មសារធាតុបំពុលខ្យល់ និងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់នៅតាមទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

ច- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យការបញ្ចេញសំឡេង និងរំញ័រនៅតាមប្រភពចល័តនិងអចល័ត។

ឆ- សិក្សាស្រាវជ្រាវនិងផ្សព្វផ្សាយបច្ចេកទេស បច្ចេកវិទ្យាគ្រប់គ្រងការបំពុលខ្យល់ពីប្រភពចល័តនិងអចល័ត និងភាពគ្រោះថ្នាក់នៃសារធាតុបំពុលខ្យល់ក្នុងខ្យល់បរិយាកាសនិងខ្យល់ក្នុងអគារ។

ជ- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងកិច្ចគាំពារ និងការត្រួតពិនិត្យការបំពុលខ្យល់ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៣

## ការត្រួតពិនិត្យការបំពុលខ្យល់ពីប្រភពចល័ត

**មាត្រា៣០៩ .–** ការហាមឃាត់ការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារពីប្រភពចល័ត

ហាមឃាត់ដាច់ខាត ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពចល័ត ដែលមិនឆ្លើយតបនឹងស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៨(ស្តង់ដារបញ្ចេញសំណល់)នៃក្រមនេះ។

**មាត្រា៣១០ .–** ការរៀបចំលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីប្រភេទយានយន្តដែលតម្រូវឱ្យបំពាក់ឧបករណ៍កាត់បន្ថយការបញ្ចេញសារធាតុបំពុលខ្យល់។

**មាត្រា៣១១ .–** វិញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់

យានយន្តដែលធ្វើចរាចរនៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានវិញ្ញាបនបត្របញ្ជាក់ការបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

## ជំពូកទី៤

## ការត្រួតពិនិត្យការបំពុលខ្យល់ពីប្រភពអចល័ត

**មាត្រា៣១២ .–** ការហាមឃាត់ការបញ្ចេញសារធាតុបំពុលខ្យល់លើសស្តង់ដារ

ហាមឃាត់ដាច់ខាតការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តទៅក្នុងខ្យល់បរិយាកាស ដែលមិនឆ្លើយតបទៅនឹងស្តង់ដារបញ្ចេញសារធាតុបំពុលខ្យល់ ដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៨(ស្តង់ដារបញ្ចេញសំណល់)នៃក្រមនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៣១៣ .– ការហាមឃាត់ការបញ្ចេញក្លិនអាក្រក់ប៉ះពាល់ការរស់នៅនិងសុខភាពសាធារណៈ**

ហាមឃាត់ដាច់ខាតចំពោះការបង្កើត ឬការបំភាយក្លិនអាក្រក់ដែលរំខានដល់ការរស់នៅ ឬធ្វើឱ្យប៉ះពាល់ដល់សុខភាពសាធារណៈ។

**មាត្រា៣១៤ .– លិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់**

ការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័តត្រូវមានលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣១៥ .– ការត្រួតពិនិត្យការបំពុលខ្យល់នៅតាមប្រភពអចល័ត**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទទួលខុសត្រូវត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់នៅតាមប្រភពអចល័ត។

**មាត្រា៣១៦ .– ការទទួលខុសត្រូវរបស់ម្ចាស់និងប្រតិបត្តិករចំពោះការបញ្ចេញសារធាតុបំពុលខ្យល់**

ម្ចាស់ ឬប្រតិបត្តិករប្រភពអចល័តត្រូវធ្វើការបំពាក់និងដំណើរការបរិក្ខារប្រព្រឹត្តិកម្ម និងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់ចូលទៅក្នុងខ្យល់បរិយាកាស នៅគ្រប់ចំណុចបញ្ចេញ។

**មាត្រា៣១៧ .– ការចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់**

ក្នុងករណីគ្រឿងបរិក្ខារប្រព្រឹត្តិកម្មនិងបរិក្ខារតាមដានត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់មិនដំណើរការ ឬបង្កឱ្យមានការបំពុលខ្យល់ ម្ចាស់ឬប្រតិបត្តិករប្រភពអចល័ត ត្រូវចាត់វិធានការទប់ស្កាត់ការបំពុលខ្យល់ជាបន្ទាន់ និងត្រូវជូនដំណឹងជាបន្ទាន់មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣១៨ .– ការរក្សាទុកនិងការផ្តល់ទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់**

ម្ចាស់ឬប្រតិបត្តិករប្រភពអចល័តត្រូវរក្សាទុកទិន្នន័យតាមដានការបញ្ចេញសារធាតុបំពុលខ្យល់ និងត្រូវផ្តល់ទិន្នន័យមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣១៩ .– ការតម្រូវបង់ថ្លៃបំពុលបរិស្ថាន**

១- បុគ្គលដែលបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពអចល័ត ហើយបង្កឱ្យមានកំណើនបន្ទុកសារធាតុបំពុលនៅក្នុងខ្យល់បរិយាកាស ត្រូវតម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាន។

២- ប្រភេទប្រភពអចល័តដែលតម្រូវឱ្យបង់ថ្លៃបំពុលបរិស្ថាន និងអត្រាបង់ថ្លៃការបំពុលបរិស្ថានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥

## ការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ

**មាត្រា៣២០ .– ក្រសួងស្ថាប័នទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទទួលខុសត្រូវៈ

ក- កំណត់លក្ខខណ្ឌតម្រូវសម្រាប់ការគ្រប់គ្រងគុណភាពខ្យល់ក្នុងអគារនិងកំណត់ស្តង់ដារគុណភាពខ្យល់ក្នុងអគារ។

ខ- ធ្វើការត្រួតពិនិត្យគុណភាពខ្យល់ក្នុងអគារ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៣២១ .- លក្ខខណ្ឌតម្រូវនៃការអនុម័តគម្រោងសាងសង់**

រាល់ការអនុម័តគម្រោងស្នើសុំសាងសង់អគារគ្រប់ប្រភេទ ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវ៖

ក- ដាក់បញ្ចូលលក្ខខណ្ឌតម្រូវពាក់ព័ន្ធគុណភាពខ្យល់ក្នុងអគារ សម្រាប់ធានាសុវត្ថិភាពសុខភាពនៃការស្នាក់នៅ ឬបម្រើការងាររយៈពេលយូរក្នុងអគារ។

ខ- តម្រូវឱ្យម្ចាស់ ឬប្រតិបត្តិករអគារបំពាក់បរិក្ខារដើម្បីធានាឱ្យគុណភាពខ្យល់ក្នុងអគារមានភាពល្អប្រសើរឆ្លើយតបនឹងកម្រិតស្តង់ដារ។

**មាត្រា៣២២ .- លិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារ**

១- ម្ចាស់ ឬប្រតិបត្តិករអគារត្រូវមានលិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ការកំណត់ប្រភេទទីតាំងអគារនិងនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់គុណភាពខ្យល់ក្នុងអគារត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ជំពូកទី៦

## ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាស

**មាត្រា៣២៣ .- ការអង្កេតតាមដានគុណភាពខ្យល់បរិយាកាស**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការតាមដានគុណភាពខ្យល់បរិយាកាស និងគុណភាពខ្យល់បរិយាកាសនៅតំបន់ងាយទទួលរងការបំពុលខ្យល់ និងជុំវិញប្រភព ឬទីតាំងដែលមានសក្តានុពលបំពុលខ្យល់ ដើម្បីវាយតម្លៃអំពីស្ថានភាពគុណភាពខ្យល់បរិយាកាស។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានទាក់ទងនឹងស្ថានភាពគុណភាពខ្យល់បរិយាកាសស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៣២៤ .- ការជូនដំណឹងអំពីហានិភ័យនៃការបំពុលខ្យល់**

ក្នុងករណីមានការរកឃើញហានិភ័យនៃការបំពុលខ្យល់ ដែលអាចបង្កផលប៉ះពាល់ដល់សុខភាពសាធារណៈ ឬបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការជូនដំណឹងដល់សាធារណជនអំពីស្ថានភាពនៃការបំពុលខ្យល់ ភាពអាចបង្កឱ្យមានគ្រោះថ្នាក់ និងពីវិធានការគាំពារសុខភាព។

**មាត្រា៣២៥ .- ការត្រួតពិនិត្យគុណភាពខ្យល់បរិយាកាសជុំវិញទីតាំងប្រភពអចល័ត**

បុគ្គល ម្ចាស់អាជីវកម្ម ឬប្រតិបត្តិករប្រភពអចល័ត ដែលទទួលបានលិខិតអនុញ្ញាតបញ្ចេញសារធាតុបំពុលខ្យល់ ត្រូវទទួលខុសត្រូវក្នុងការតាមដាន និងត្រួតពិនិត្យការបំពុលខ្យល់បរិយាកាសជុំវិញទីតាំងរបស់ខ្លួន និងផ្តល់របាយការណ៍តាមដានត្រួតពិនិត្យមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣២៦ .- ការហាមឃាត់សកម្មភាពបង្កឱ្យមានការបំពុលខ្យល់**

ហាមឃាត់ដាច់ខាតសកម្មភាពបង្កឱ្យមានការបំពុលខ្យល់ដូចខាងក្រោម៖

ក- ការដុតព្រៃឈើ វាលស្មៅ គល់ជញ្ជ្រាំង និងសំណល់កសិកម្ម និងការដុតសំរាម សំណល់រឹងនៅតាមទីវាល ឬទីលានចាក់សំណល់។

ខ- ការដុតសំណល់ ឬវត្ថុឆេះគ្រប់ប្រភេទនៅតាមទីសាធារណៈ ដងផ្លូវ ទីតាំងអគារសាធារណៈឬឯកជន ឬក្នុងទីតាំងដីកម្មសិទ្ធិ ដែលបង្កឱ្យមានការប៉ះពាល់សុខភាពសាធារណៈ និងការប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម។

គ- ការដឹកជញ្ជូនដី ខ្សាច់ ថ្ម ឬសម្ភារៈសំណង់ដែលបង្កឱ្យមានការហុយធូលីប៉ះពាល់ដល់គុណភាពខ្យល់ សុខភាពសាធារណៈ ការធ្វើចរាចរណ៍និងសណ្តាប់ធ្នាប់សាធារណៈ។

## ជំពូកទី៧
## ការត្រួតពិនិត្យសារធាតុបំពុលខ្យល់ក្នុងឥន្ធនៈផូស៊ីល

**មាត្រា៣២៧ ._** ស្ថាប័នត្រួតពិនិត្យសមាសធាតុបង្កើតសារធាតុបំពុលខ្យល់នៅក្នុងឥន្ធនៈផូស៊ីល

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវទទួលខុសត្រូវក្នុងការៈ

ក- រៀបចំស្តង់ដារកម្រិតសមាសធាតុគីមីក្នុងឥន្ធនៈផូស៊ីល ដែលបង្កើតឱ្យមានបញ្ហាបំពុលខ្យល់ធ្ងន់ធ្ងរ។

ខ- រៀបចំនីតិវិធីអនុវត្តការត្រួតពិនិត្យសមាសធាតុគីមី ក្នុងឥន្ធនៈផូស៊ីលបង្កើតឱ្យមានសារធាតុបំពុលខ្យល់។

**មាត្រា៣២៨ ._** ការអនុញ្ញាតនាំចូលឥន្ធនៈផូស៊ីល

១- ការនាំចូល ការផលិត ការចែកចាយ និងការប្រើប្រាស់ឥន្ធនៈផូស៊ីលត្រូវមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យប្រេងកាត។

២- នីតិវិធីក្នុងការពិនិត្យនិងការផ្តល់លិខិតអនុញ្ញាតនាំចូលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តស្របតាមបញ្ញត្តិនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យប្រេងកាត។

## ជំពូកទី៨
## ការបំពុលខ្យល់ឆ្លងដែន

**មាត្រា៣២៩ ._** ការបំពុលខ្យល់ឆ្លងដែន

ក្នុងករណីទទួលបានការជូនដំណឹង ការផ្តល់របាយការណ៍ ឬលទ្ធផលសិក្សាពីការបំពុលខ្យល់ឆ្លងដែនដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់បរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់ពីការបំពុលខ្យល់ឆ្លងដែនតាមរយៈយន្តការទ្វេភាគី ពហុភាគី និងតំបន់។

**មាត្រា៣៣០ ._** ការបំពុលខ្យល់ឆ្លងដែនពីប្រភពក្នុងស្រុក

ក្នុងករណីកើតមានការបំពុលខ្យល់ពីប្រភពក្នុងស្រុក ដែលស្ថានភាពនៃការបំពុលអាចបង្កឱ្យមានការឆ្លងដែនអាចប៉ះពាល់ដល់ប្រទេសជិតខាង និងតំបន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវចាត់វិធានការកាត់បន្ថយឱ្យអស់លទ្ធភាព និងត្រូវជូនដំណឹងទៅប្រទេសនិងតំបន់ដែលទទួលរងផលប៉ះពាល់។

## ជំពូកទី៩
## ការត្រួតពិនិត្យសំឡេងនិងរំញ័រ

**មាត្រា៣៣១ ._** ការហាមឃាត់ការបង្កសំឡេងឬរំញ័រលើសស្តង់ដារ

ហាមឃាត់ដាច់ខាតចំពោះសកម្មភាពដែលបង្កើតសំឡេង ឬរំញ័រលើសស្តង់ដារសំឡេង និងរំញ័រដូចបានបញ្ញត្តនៅក្នុងមាត្រា១៦៩(ស្តង់ដារសំឡេងនិងរំញ័រ)នៃក្រមនេះ។

**មាត្រា៣៣២ .- កាតព្វកិច្ចបំពាក់បរិក្ខារកាត់បន្ថយការបញ្ចេញសំឡេងឬរំញ័រ**

ម្ចាស់ឬប្រតិបត្តិករទីតាំងត្រូវទទួលខុសត្រូវក្នុងការបំពាក់គ្រឿងបរិក្ខារសម្រាប់កាត់បន្ថយការបញ្ចេញសំឡេង ឬរំញ័រ អនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៣៣ .- លក្ខខណ្ឌតម្រូវក្នុងការអង្កេតតាមដាន**

ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌតម្រូវនានា ទៅក្នុងលិខិតអនុញ្ញាតនៃគម្រោងស្នើសុំសាងសង់ ឬគម្រោងដែលអាចបង្កឱ្យមានផលប៉ះពាល់ដោយការបញ្ចេញសំឡេង ឬរំញ័រ ដើម្បីធានាបានការគោរពតាមស្តង់ដារបញ្ចេញសំឡេងនិងរំញ័រ។

**មាត្រា៣៣៤ .- ការទទួលខុសត្រូវចំពោះការខូចខាត**

បុគ្គលដែលបង្កឱ្យមានការបញ្ចេញសំឡេងឬរំញ័រលើសកម្រិតស្តង់ដារត្រូវទទួលខុសត្រូវចំពោះការខូចខាតទ្រព្យសម្បត្តិ ឬប៉ះពាល់ដល់សុខភាពសាធារណៈនិងបរិស្ថាន។

# មាតិកាទី៧

# ការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៣៣៥ .- គោលបំណង**

មាតិកានេះ មានគោលបំណងកាត់បន្ថយនិងលុបបំបាត់ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ តាមរយៈការដាក់ចេញនូវវិធានការត្រួតពិនិត្យសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលពាក់ព័ន្ធការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សំដៅធានាបានកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះនិងកិច្ចគាំពារសុខភាពសាធារណៈ។

**មាត្រា៣៣៦ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើសកម្មភាពផលិត នាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ស្តុកទុក លក់ ប្រើប្រាស់ ផ្ទេរ ប្រព្រឹត្តិកម្ម និងបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលពាក់ព័ន្ធការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣៣៧ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវក្នុងការដឹកនាំការគ្រប់គ្រង និងការត្រួតពិនិត្យ ការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

**មាត្រា៣៨ .– តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់។

ខ- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការត្រួតពិនិត្យនិងតាមដានការផលិត នាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ស្តុកទុក លក់ ប្រើប្រាស់ ផ្ទេរ ប្រព្រឹត្តិកម្ម និងបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់។

គ- គ្រប់គ្រងទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់។

ឃ- រៀបចំបញ្ជីប្រភេទសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់។

ង- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់។

ច- ពិនិត្យ និងសម្រេចលើសំណើធ្វើផលិតកម្ម អាជីវកម្ម ប្រើប្រាស់ និងកូតាប្រចាំឆ្នាំនៃការផលិត នាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ស្តុកទុក លក់ ប្រើប្រាស់ ផ្ទេរ ប្រព្រឹត្តិកម្ម និងបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុទាំងនេះ។

ឆ- បំពេញភារកិច្ចជាអង្គភាពបង្គោលជាតិនៃលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងកិច្ចគាំពារស្រទាប់អូហ្សូន ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី៣
## ការចុះបញ្ជី ការស្នើសុំកូតាប្រចាំឆ្នាំ ការនាំចូល ការនាំចេញ ការដឹកជញ្ជូនឆ្លងកាត់និងការដាក់ស្លាកសញ្ញា

**មាត្រា៣៩ .– ការស្នើសុំចុះបញ្ជីនិងលិខិតអនុញ្ញាតកូតាប្រចាំឆ្នាំ**

១- បុគ្គលដែលមានបំណងនាំចូល នាំចេញ ដឹកជញ្ជូនឆ្លងកាត់ ឬផលិតសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ត្រូវចុះបញ្ជី និងស្នើសុំលិខិតអនុញ្ញាតកូតាប្រចាំឆ្នាំនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

២- នីតិវិធីនិងបែបបទសម្រាប់ការចុះបញ្ជីនិងការស្នើសុំលិខិតអនុញ្ញាតកូតាប្រចាំឆ្នាំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៤០ .- ការស្នើសុំនាំចូល នាំចេញ និងដឹកជញ្ជូនឆ្លងកាត់**

ការនាំចូល ការនាំចេញ ការដឹកជញ្ជូនឆ្លងកាត់នូវសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៤១ .- ការបិទស្លាកសញ្ញាលើប្រដាប់សម្រាប់ដាក់សារធាតុបំផ្លាញស្រទាប់អូហ្សូនឬសារធាតុធ្វើឱ្យត្រជាក់**

បុគ្គលដែលបានធ្វើការនាំចូលសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ត្រូវជូនដំណឹងមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីត្រួតពិនិត្យនិងបិទស្លាកសញ្ញាសម្គាល់លើរាល់ប្រដាប់សម្រាប់ដាក់ ដែលមានផ្ទុកសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ដែលបាននាំចូល។

## ជំពូកទី៤

## ការធ្វើអាជីវកម្មនិងការប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់

**មាត្រា៣៤២ .- ការស្នើសុំលិខិតអនុញ្ញាតអាជីវកម្មលក់និងចែកចាយសារធាតុបំផ្លាញស្រទាប់អូហ្សូន**

បុគ្គលដែលលក់ ចែកចាយ ឬផ្ទេរប្រដាប់សម្រាប់ដាក់សារធាតុបំផ្លាញស្រទាប់អូហ្សូន ឬសារធាតុធ្វើឱ្យត្រជាក់ត្រូវស្នើសុំលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៤៣ .- ការត្រួតពិនិត្យការធ្វើអាជីវកម្មសារធាតុបំផ្លាញស្រទាប់អូហ្សូន**

១- ការលក់ ឬការចែកចាយសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ត្រូវមានបិទស្លាកសញ្ញាសម្គាល់ ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ទីតាំងលក់ ឬចែកចាយត្រូវមានបុគ្គលិកវិជ្ជាជីវៈយ៉ាងតិច១(មួយ)នាក់ ដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៤៤ .- ការចុះបញ្ជីកាអ្នកប្រើប្រាស់**

បុគ្គលដែលប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន សារធាតុធ្វើឱ្យត្រជាក់ និងផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់នៅក្នុងដំណើរការផលិតកម្មនិងអាជីវកម្មរបស់ខ្លួនត្រូវចុះបញ្ជីកាអ្នកប្រើប្រាស់នៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៥

## សេវាកម្មដំឡើង ថែទាំ និងជួសជុលផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់

**មាត្រា៣៤៥ .- ការចុះបញ្ជីសេវាកម្មដំឡើង ថែទាំនិងជួសជុលផលិតផល**

បុគ្គលដែលផ្តល់សេវាកម្មដំឡើង ថែទាំ និងជួសជុលផលិតផលដែលមានផ្ទុក ឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់គ្រប់ប្រភេទត្រូវចុះបញ្ជីសេវាកម្មនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៤៦ ._ លិខិតអនុញ្ញាតប្រព្រឹត្តិកម្មឬបំផ្លាញសារធាតុបំផ្លាញស្រទាប់អូហ្សូននិងសារធាតុធ្វើឱ្យត្រជាក់**

បុគ្គលដែលមានបំណងធ្វើប្រព្រឹត្តិកម្មឬបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ត្រូវមានលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៤៧ ._ បុគ្គលិកវិជ្ជាជីវៈ**

រាល់ទីតាំងនាំចូល ទីតាំងលក់ឬចែកចាយ និងសេវាកម្មដំឡើង ថែទាំ និងជួសជុលផលិតផលដែលមានផ្ទុកឬធ្វើឡើងសម្រាប់ប្រើប្រាស់សារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ និងទីតាំងបូមសម្អាត ឬបំផ្លាញចោលសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ត្រូវមានបុគ្គលិកវិជ្ជាជីវៈយ៉ាងតិច១(មួយ)នាក់ដែលបានទទួលការបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន និងសារធាតុធ្វើឱ្យត្រជាក់ពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## គន្ថីទី៤
## ការគ្រប់គ្រងតំបន់ការពារធម្មជាតិនិងការគ្រប់គ្រងធនធានធម្មជាតិ
## តំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ

### មាតិកាទី១
### ការគ្រប់គ្រងតំបន់ការពារធម្មជាតិ

#### ជំពូកទី១
#### បទប្បញ្ញត្តិទូទៅ

**មាត្រា៣៤៨ ._ គោលបំណង**

មាតិកានេះ មានគោលបំណងធានានូវការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាពដោយធ្វើការរក្សាឱ្យបាននូវបេតិកភណ្ឌវប្បធម៌និងធម្មជាតិ ភាពសម្បូរបែបនៃធនធានធម្មជាតិនិងជីវៈចម្រុះ មុខងារនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការវិវត្តនៃភាវៈរស់សម្រាប់ទ្រទ្រង់ប្រភពចំណូល ស្បៀងអាហារ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកគាំទ្រដល់ដំណើរការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។

**មាត្រា៣៤៩ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើកិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍនៅក្នុងតំបន់ការពារធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ព្រមទាំងគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

#### ជំពូកទី២
#### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣៥០ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវគ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។



៣៥

២- តួនាទី ការទទួលខុសត្រូវ និងកិច្ចសហការជាក់លាក់របស់ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយរាជរដ្ឋាភិបាល។

**មាត្រា៣៥១ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិនៅព្រះរាជាណាចក្រកម្ពុជា។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការគ្រប់គ្រង លិខិតបទដ្ឋានគតិយុត្តនានា និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។

ខ- សិក្សាវាយតម្លៃ និងកំណត់ព្រំប្រទល់ដែនតំបន់ការពារធម្មជាតិដើម្បីចុះបញ្ជិកា។

គ- រៀបចំផែនទីគម្របរុក្ខជាតិ ផែនទីទីជម្រាល និងផែនទីតំបន់ការពារធម្មជាតិនីមួយៗជាផ្លូវការ។

ឃ- លើកការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយតាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬអនុលោមតាមលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ង- រៀបចំវាយតម្លៃនិងធ្វើចំណាត់ថ្នាក់ប្រភេទធនធានព្រៃឈើ ជលផល និងជីវៈចម្រុះក្នុងតំបន់ការពារធម្មជាតិ។

ច- សិក្សា ប្រមូល ចងក្រង បង្កើតមូលដ្ឋានទិន្នន័យព័ត៌មានស្តីពីធនធានព្រៃឈើ ជលផល និងជីវៈចម្រុះ។

ឆ- អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

ជ- ចាត់វិធានការដើម្បីត្រួតពិនិត្យ ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងតាមនីតិវិធីជាធរមាន និងធ្វើជាអង្គភាពដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាត និងការជួសជុលស្តារការខូចខាតធនធានធម្មជាតិនៅចំពោះមុខតុលាការមានសមត្ថកិច្ច។

ឈ- អភិវឌ្ឍសមត្ថភាព និងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ញ- ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃទៅលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវមានអង្គភាពជំនាញទទួលបន្ទុកតំបន់ការពារធម្មជាតិជាសេនាធិការសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ។ អង្គភាពជំនាញទទួលបន្ទុកតំបន់ការពារធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥២ .- តួនាទីនិងភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

១- រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី គ្រប់គ្រង អភិរក្សជីវៈចម្រុះ និងធានាការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិនៃក្រមនេះ។

២- រដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

ក- ធានាដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយនិរន្តរភាព និងបង្កើនការដាំស្តារព្រៃឈើឡើងវិញនៅលើដីព្រៃរេចរឹល ឬដីទំនេរ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៣៥

ខ- រៀបចំនិងអនុវត្តផែនការសកម្មភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គ- ចាត់វិធានការដើម្បីត្រួតពិនិត្យ ទប់ស្កាត់ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងទៅតុលាការតាមនីតិវិធីច្បាប់។

ឃ- ទប់ស្កាត់ និងចាត់វិធានការនូវរាល់សកម្មភាពដែលធ្វើឱ្យខូចខាត ឬប៉ះពាល់អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិ ដែលបណ្ដាលមកពីសកម្មភាពនានា មានជាអាទិ៍ ការកាប់គាស់ រុករាន ទន្ទ្រានដីព្រៃ ព្រៃលិចទឹក ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ការប្រមូលផល អនុផលព្រៃឈើ ផលផល ការបំពុលទឹក ការដាក់ថ្នាំបំពុល ការប្រើប្រាស់សារធាតុគីមី ការបោលសំណល់រឹងរាវចូលក្នុងទឹក ឬលើដី ឬក្រោមដី ការប្រើប្រាស់ឧបករណ៍ឆក់ ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ភ្លើងឆេះតំបន់ដីមមោក ការធ្វើកសិកម្មពនេចរ ការនាំចូលជំងឺសត្វល្អិតចង្រៃ និងប្រភេទសត្វ រុក្ខជាតិ ឬគ្រាប់រុក្ខជាតិរាតត្បាត។

ង- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗដែលកំណត់ដោយក្រមនេះ។

ច- ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ។

ឆ- គាំទ្រការប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់របស់សហគមន៍មូលដ្ឋាននៅក្នុងតំបន់អភិរក្ស និងតំបន់ប្រើប្រាស់ដោយចីរភាព។

ជ- ផ្ដល់គោលការណ៍អនុញ្ញាត និងទទួលស្គាល់លើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដែលទទួលបានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឈ- គ្រប់គ្រង និងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ និងទេសចរណ៍ធម្មជាតិ។

ញ- អប់រំផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ ក៏ដូចជាការស្ដារប្រព័ន្ធមជ្ឈដ្ឋានធម្មជាតិ និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ដ- កៀរគរធនធាន សម្រាប់គាំទ្រដល់កិច្ចគាំពារ ការអភិរក្ស និងការស្ដារជីវៈចម្រុះ។

ឋ- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល និងសប្បុរសជន ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ។

៣- រាជរដ្ឋាភិបាល ឬក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិផ្ទេរបន្ថែម ឬកែប្រែមុខងារដែលបានផ្ទេរផ្សេងទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

៥- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានអង្គភាពទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ដើម្បីជាសេនាធិការក្នុងការគ្រប់គ្រង និងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**មាត្រា៣៥៣.- ការកម្រិតសិទ្ធិរដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងករណីគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិមិនអាចសម្រេចលើកិច្ចការដូចខាងក្រោម៖

ក- ការអនុញ្ញាតឱ្យធ្វើការកាប់គាស់ រុករាន ឈូសឆាយ ឆ្ការដុតដីព្រៃ ដើម្បីសង់ផ្ទះ សង់តូប សង់រោង យកដីធ្វើជាកម្មសិទ្ធិ ឬដាំដំណាំកសិកម្មនៅក្នុងតំបន់ការពារធម្មជាតិ។
ខ- ការអនុញ្ញាតឱ្យសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ។
គ- ការលក់ ជួល ផ្តល់ ឬផ្ទេរសិទ្ធិកាន់កាប់ដីនៅក្នុងតំបន់ការពារធម្មជាតិទោះបីមួយផ្នែក ឬទាំងមូលក្តី។
ឃ- ការអនុញ្ញាតឱ្យសិក្សារុករក ឬធ្វើអាជីវកម្មរ៉ែនិងថ្មគ្រប់ប្រភេទ និងជីកកាយឬដឹកចេញ ឬចូលក្នុងតំបន់ការពារធម្មជាតិ។
ង- ការចេញលិខិតបញ្ជាក់ ឬអនុញ្ញាតទិញ លក់ និងកាន់កាប់ដីគ្រប់ប្រភេទនៅតំបន់ការពារធម្មជាតិ។
ច- ការអនុញ្ញាតឱ្យធ្វើការដាំដុះនូវប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត ដែលមានសក្តានុពលបង្កការប៉ះពាល់ដល់កត្តាជីវសាស្ត្រនៃប្រភេទរុក្ខជាតិដើមក្នុងតំបន់ការពារធម្មជាតិ។
ឆ- ការប្រែក្លាយផ្នែកណាមួយនៃតំបន់ការពារធម្មជាតិឱ្យទៅជាដីលំនៅឋានឬភូមិ។
ជ- ការអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើក្នុងគោលបំណងមានលក្ខណៈសេដ្ឋកិច្ចក្នុងតំបន់ការពារធម្មជាតិ។

## ជំពូកទី៣
## គោលនយោបាយ ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

**មាត្រា៣៥៤ ._ គោលនយោបាយជាតិស្តីពីតំបន់ការពារធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីតំបន់ការពារធម្មជាតិ សម្រាប់តម្រង់ទិសក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយប្រសិទ្ធភាព។

២- គោលនយោបាយជាតិស្តីពីតំបន់ការពារធម្មជាតិត្រូវដាក់ឱ្យប្រើដោយរាជរដ្ឋាភិបាល។

**មាត្រា៣៥៥ ._ ការរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយជាតិស្តីពីតំបន់ការពារធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។

២- ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលតាមការស្នើសុំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៥៦ ._ ការពិនិត្យនិងកែសម្រួលផែនការយុទ្ធសាស្ត្រជាតិស្តីពីតំបន់ការពារធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំ ពិនិត្យ និងកែសម្រួលនូវផែនការយុទ្ធសាស្ត្រជាតិសម្រាប់តំបន់ការពារធម្មជាតិរៀងរាល់៥(ប្រាំ)ឆ្នាំម្តង ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនានា។

២- ផែនការយុទ្ធសាស្ត្រជាតិសម្រាប់តំបន់ការពារធម្មជាតិអាចត្រូវបានពិនិត្យ និងកែសម្រួលមុនរយៈពេល ៥(ប្រាំ)ឆ្នាំ ក្នុងករណីចាំបាច់ដូចខាងក្រោម៖

ក- មានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់ និងមានការយល់ដឹងអំពីធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី រួមទាំងប្រភេទសត្វ រុក្ខជាតិ ធនធានជីវសាស្ត្រ ធនធានពន្ធុ សេដ្ឋកិច្ច សង្គម និងវប្បធម៌។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ខ- មានការគំរាមកំហែងចំពោះមុខទៅលើតំបន់ការពារធម្មជាតិ។

គ- អនុវត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**មាត្រា៣៥៧ ._ ការរៀបចំផែនការសកម្មភាព**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការសកម្មភាពសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ដោយអនុលោមតាមផែនការយុទ្ធសាស្ត្រជាតិស្តីពីតំបន់ការពារធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ។

២- ផែនការសកម្មភាពសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវដាក់ឱ្យអនុវត្តដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៤
## ការបង្កើតនិងកែប្រែតំបន់ការពារធម្មជាតិ

**មាត្រា៣៥៨ ._ ការបង្កើតតំបន់ការពារធម្មជាតិ**

១- ការបង្កើតតំបន់ការពារធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬតាមសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

២- ការបង្កើតតំបន់ការពារធម្មជាតិណាមួយត្រូវផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈពិសេស តម្លៃ និងសក្តានុពលនៃធនធានធម្មជាតិ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ទីតាំងប្រវត្តិសាស្ត្រ កត្តាភូគព្ភសាស្ត្រ សេដ្ឋកិច្ចសង្គម និងបរិស្ថាន គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ និងកត្តាពាក់ព័ន្ធផ្សេងទៀតព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

៣- ការបង្កើតតំបន់ការពារធម្មជាតិ ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យមួយយ៉ាងតិចក្នុងចំណោមលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

ក- ទីជម្រកនៃអម្បូរសត្វនិងរុក្ខជាតិដែលជាប្រភេទកម្រ ជិតផុតពូជ ឬកំពុងរងការគំរាមកំហែង។

ខ- ជម្រករបស់សត្វមួយប្រភេទឬច្រើន ដែលរីកសាយទៅតំបន់ផ្សេងៗ។

គ- តំបន់ប្រភពទឹកឬទីជម្រាល សណ្ឋានដី តំបន់ដីមមោក និងតំបន់ព្រៃឈើ ដែលទ្រទ្រង់ដល់ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងបង្កើតបានជាទេសភាពប្លែកៗសម្រាប់ការកម្សាន្ត។

ឃ- លក្ខណៈពិសេសពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រដូចជាសម្បត្តិវប្បធម៌ ប្រវត្តិនៃដើមកំណើតដោយកត្តាភូគព្ភសាស្ត្រ រូបសាស្ត្រ ឬជីវសាស្ត្រឬដោយអន្តរាគមន៍ពីមនុស្ស។

ង- ជម្រកផ្កាថ្ម ឬរុក្ខជាតិសមុទ្រ ឬសម្បុកពងកូននៃមច្ឆជាតិ ឬជម្រកនៃប្រភេទសត្វសមុទ្រ ដែលផ្តល់សារប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវ ការអភិរក្ស និងការកម្សាន្ត។

៤- លក្ខណវិនិច្ឆ័យផ្សេងទៀតសម្រាប់បង្កើតតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥៩ ._ ប្រភេទនៃតំបន់ការពារធម្មជាតិ**

ប្រភេទតំបន់ការពារធម្មជាតិមានដូចខាងក្រោម៖

ក- ឧទ្យានជាតិ។

ខ- ឧទ្យានជាតិសមុទ្រ។

គ- ដែនជម្រកសត្វព្រៃ។
ឃ- តំបន់ការពារទេសភាព។
ង- តំបន់ប្រើប្រាស់ច្រើនយ៉ាង។
ច- តំបន់រ៉ាមសារ។
ឆ- តំបន់ស្នូលនៃបរិយាយដីវមណ្ឌល។
ជ- តំបន់បេតិកភណ្ឌធម្មជាតិ។
ឈ-ប្រភេទតំបន់ការពារធម្មជាតិផ្សេងទៀត។

**មាត្រា៣៦០ .- ការកែប្រែតំបន់ការពារធម្មជាតិ**

១- ការកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិឬតាមសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

២- ការកែប្រែតំបន់ការពារធម្មជាតិណាមួយត្រូវផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត។

៣- ការកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវអនុលោមតាម៖

ក- សារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្សតំបន់ដែលស្នើសុំកែប្រែតំបន់ការពារធម្មជាតិនោះ។

ខ- លក្ខខណ្ឌ និងស្ថានភាពតំបន់ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ ភ្ជាប់ជាមួយនូវផែនទីមានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញយ៉ាងច្បាស់អំពីទីតាំង ព្រំប្រទល់ និងទំហំនៃតំបន់ការពារធម្មជាតិនោះ។

គ- គោលបំណងនៃការគ្រប់គ្រងតំបន់ និងការគំរាមកំហែងចំពោះមុខ។

ឃ- ការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លីនៅក្នុងតំបន់ការពារធម្មជាតិ។

ង- លទ្ធផលនៃការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

ច- គោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

**មាត្រា៣៦១ .- ការដាក់បញ្ចូលតំបន់ការពារធម្មជាតិក្នុងក្របខ័ណ្ឌអន្តរជាតិ**

១- រាជរដ្ឋាភិបាលអាចកែប្រែតំបន់ការពារធម្មជាតិណាមួយ ដែលមានសារៈសំខាន់ចំពោះជាតិ និងអន្តរជាតិ ដើម្បីស្នើសុំចូលជាបេតិកភណ្ឌធម្មជាតិពិភពលោក ឬថ្នាក់តំបន់ស្របតាមលក្ខណវិនិច្ឆ័យ លិខិតុបករណ៍អន្តរជាតិ ឬថ្នាក់តំបន់។

២- តំបន់ការពារធម្មជាតិណាមួយ ដែលត្រូវបានចាត់បញ្ចូលជាតំបន់បេតិកភណ្ឌធម្មជាតិពិភពលោកឬបេតិកភណ្ឌធម្មជាតិថ្នាក់តំបន់រួចហើយ រាជរដ្ឋាភិបាលត្រូវមានវិធានការចាំបាច់ដើម្បីធានានូវការគ្រប់គ្រងអភិរក្សតំបន់ទាំងនោះ ដោយអនុលោមតាមលិខិតុបករណ៍អន្តរជាតិ ឬថ្នាក់តំបន់។

**មាត្រា៣៦២ .- ការកំណត់ទីតាំងការពារនិងអភិរក្សនៅក្នុងតំបន់ការពារធម្មជាតិ**

១- ក្នុងតំបន់ការពារធម្មជាតិនីមួយៗអាចមានការកំណត់ទីតាំងការពារ និងអភិរក្សប្រភពដើមធនធានពន្ធុ និងពូជចំណាត់ថ្នាក់ ក្រុម ប្រភេទធនធានព្រៃឈើ រុក្ខជាតិព្រៃ សត្វព្រៃ ផលផល និងជីវៈចម្រុះ។



៣៥

២- ទីតាំងការពារ និងអភិរក្សប្រភពដើមធនធានពន្ធុ និងចំណាត់ថ្នាក់ ក្រុម ប្រភេទធនធានព្រៃឈើ រុក្ខជាតិព្រៃ សត្វព្រៃ ផលផល និងជីវៈចម្រុះត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៦៣ ._ ការថែរក្សានិងការពារបេតិកភណ្ឌធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ត្រូវសហការគ្នាក្នុងការរៀបចំបង្កើតឬកែប្រែ កិច្ចគាំពារ ការថែរក្សា និងការអភិរក្សតំបន់បេតិកភណ្ឌធម្មជាតិ។

## ជំពូកទី៥

## ការកំណត់និងការបែងចែកតំបន់គ្រប់គ្រង

**មាត្រា៣៦៤ ._** ការបែងចែកតំបន់គ្រប់គ្រង

១- តំបន់ការពារធម្មជាតិនីមួយៗអាចបែងចែកជាតំបន់គ្រប់គ្រងដូចខាងក្រោម៖

ក- **តំបន់ស្នូល** គឺជាតំបន់គ្រប់គ្រង ដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គំរាមកំហែង ទីតាំងសត្វព្រៃបន្តពូជ និងប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។ ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងលើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។

ខ- **តំបន់អភិរក្ស** គឺជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។ ការចេញចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលទទួលខុសត្រូវនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខនិងការពារជាតិ។ ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះសម្រាប់ជីវភាពសហគមន៍មូលដ្ឋាន ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ។

គ- **តំបន់ប្រើប្រាស់ដោយចីរភាព** គឺជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ រាជរដ្ឋាភិបាលអាចអនុញ្ញាតឱ្យមានការអភិវឌ្ឍដោយធានានិរន្តរភាពជីវៈចម្រុះនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានដោយអនុលោមតាមនីតិវិធីច្បាប់។

ឃ- **តំបន់សហគមន៍** គឺជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍មូលដ្ឋានដែលមានសកម្មភាពស្រាប់ មានជាអាទិ៍ លំនៅឋាន ស្រែ ចម្ការ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ការផ្តល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ។

៣- តំបន់ការពារធម្មជាតិទាំងនេះមិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ។

**មាត្រា៣៦៥ ._ លក្ខណវិនិច្ឆ័យនៃការកំណត់និងបែងចែកតំបន់គ្រប់គ្រង**

១- ការបែងចែកតំបន់គ្រប់គ្រង និងការកែប្រែប្រភេទនៃតំបន់គ្រប់គ្រងដូចមានចែងក្នុងមាត្រា៣៦៤ (ការបែងចែកតំបន់គ្រប់គ្រង)នៃក្រមនេះ ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

ក- គោលបំណងនៃការគ្រប់គ្រងតំបន់។

ខ- តម្លៃមានសក្តានុពលធនធានធម្មជាតិនៅក្នុងតំបន់នីមួយៗ។

គ- សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលប៉ះពាល់ទៅលើតំបន់នោះ។

ឃ- លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ។

ង- ទីតាំងភូមិសាស្ត្រនៃតំបន់។

២- គោលការណ៍ណែនាំនៃការបែងចែក និងការគ្រប់គ្រងតំបន់គ្រប់គ្រងនីមួយៗ ក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៦៦ ._ ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រង**

ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រងនីមួយៗ ដូចមានចែងក្នុងមាត្រា៣៦៤(ការបែងចែកតំបន់គ្រប់គ្រង) នៃក្រមនេះ ធ្វើទៅបានអាស្រ័យដោយ៖

ក- មានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់និងប្រព័ន្ធអេកូឡូស៊ី រួមទាំងប្រភេទសត្វ រុក្ខជាតិ ធនធានជីវៈចម្រុះ ធនធានពន្ធុ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលមានការប្រែប្រួល ឬមានការគំរាមកំហែង។

ខ- អនុលោមតាមគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

**មាត្រា៣៦៧ ._ ការរៀបចំផែនទី បោះបង្គោលព្រំ និងចុះបញ្ជីដីសាធារណៈរបស់រដ្ឋ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំធ្វើផែនទីតំបន់ការពារធម្មជាតិនីមួយៗជាផ្លូវការ និងកំណត់លើផែនទី ដែលមាននិយាមកាគោលច្បាស់លាស់ ដោយមានការចូលរួមពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសិក្សារៀបចំបែងចែក និងកំណត់តំបន់គ្រប់គ្រងដូចមានចែងក្នុងមាត្រា៣៦៤ (ការបែងចែកតំបន់គ្រប់គ្រង) និងមាត្រា៣៦៥(លក្ខណវិនិច្ឆ័យនៃការកំណត់និងបែងចែកតំបន់គ្រប់គ្រង) នៃក្រមនេះ និងបោះបង្គោលព្រំប្រទល់និងចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋនៅតំបន់ការពារធម្មជាតិនីមួយៗទៅតាមចំណុចដៅលើផែនទីដែលបានកំណត់។

## ជំពូកទី៦

## ការចូលរួមនិងសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន

**មាត្រា៣៦៨ ._ ការចូលរួម**

សហគមន៍មូលដ្ឋាន សាធារណជន និងសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមផ្តល់ និងទទួលយកព័ត៌មានទាក់ទងនឹងការគ្រប់គ្រង ការការពារ ការអភិរក្ស និងការអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ។



៣៥

**មាត្រា៣៦៩ .– សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ**

១- រដ្ឋទទួលស្គាល់និងធានាសិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋានដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ។

២- សិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋានជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់អភិរក្ស ដោយអនុវត្តទៅតាមគោលការណ៍ណែនាំ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៧០ .– ការប្រើប្រាស់ធនធានធម្មជាតិ**

១- ការប្រើប្រាស់ធនធានធម្មជាតិស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ប្រព្រឹត្តទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិងតំបន់សហគមន៍។ លក្ខខណ្ឌនេះមិនរាំងចំពោះការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់អភិរក្ស ដែលត្រូវបានអនុញ្ញាតតាមមាត្រា៣៦៩(សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ)នៃក្រមនេះ។

២- ការប្រើប្រាស់ធនធានធម្មជាតិត្រូវអនុវត្តតាមផែនការគ្រប់គ្រង និងគោលការណ៍ណែនាំបច្ចេកទេសរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីធានានិរន្តរភាពនៃធនធានធម្មជាតិនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ។

**មាត្រា៣៧១ .– ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសមត្ថកិច្ចរៀបចំបង្កើតសហគមន៍តំបន់ការពារធម្មជាតិក្នុងតំបន់ប្រើប្រាស់ដោយចីរភាពដោយស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

២- រដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តួចផ្តើម សម្របសម្រួល គាំទ្រ ផ្តល់គោលការណ៍អនុញ្ញាត និងទទួលស្គាល់ដល់ការបង្កើតសហគមន៍តំបន់ការពារធម្មជាតិ បន្ទាប់ពីទទួលបានការយល់ព្រមពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសិក្សាពីលទ្ធភាពរៀបចំសហគមន៍តំបន់ការពារធម្មជាតិ កំណត់ទីតាំងច្បាស់លាស់ និងទំហំឱ្យបានសមស្របដោយមានការពិគ្រោះយោបល់ និងការសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធ។

៤- សហគមន៍តំបន់ការពារធម្មជាតិ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយកិច្ចព្រមព្រៀងនេះ មានសុពលភាពមិនលើសពីរយៈពេល២៥(ម្ភៃប្រាំ)ឆ្នាំ។

៥- ក្នុងករណីដែលសហគមន៍តំបន់ការពារធម្មជាតិ មិនអនុវត្តតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិផ្អាកដំណើរការរបស់សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីពិនិត្យ និងវាយតម្លៃឡើងវិញ។

៦- រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិលុបកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ បន្ទាប់ពីទទួលបានការយល់ព្រមពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្នុងករណីដែលសហគមន៍អនុវត្តផ្ទុយពីកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ។

៧- ក្នុងករណីដែលពិនិត្យឃើញថា សហគមន៍តំបន់ការពារធម្មជាតិមិនបានអនុវត្តត្រឹមត្រូវតាមកិច្ចព្រមព្រៀង ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិលុបកិច្ចព្រមព្រៀង។

៨- វិធានសម្រាប់ការបង្កើតនិងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

៩- គោលការណ៍ណែនាំស្តីពីនីតិវិធីនិងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។



MINISTÈRE DU PALAIS ROYAL

ms

មាត្រា៣៧២ .- សកម្មភាពហាមឃាត់សម្រាប់សហគមន៍តំបន់ការពារធម្មជាតិ

១- សហគមន៍តំបន់ការពារធម្មជាតិនិង/ឬសមាជិកនៃសហគមន៍តំបន់ការពារធម្មជាតិ ពុំមានសិទ្ធិកាប់គាស់ ឬឈូសឆាយដីព្រៃក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងបង្វែរធ្វើជាដីកសិកម្ម ឬធ្វើជាកម្មសិទ្ធិបុគ្គល ឬលក់ ប្តូរ ជួល បញ្ចាំ ធ្វើអំណោយ ប្រវាស់ បែងចែក ដោះដូរ ឬធ្វើការផ្ទេរតំបន់គ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិ ឱ្យទៅបុគ្គលណាមួយបានឡើយ។

២- ការផ្តល់ដីសម្រាប់បង្កបង្កើនផលបន្ថែមជូនដល់សហគមន៍មូលដ្ឋាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយមានការពិគ្រោះយោបល់ជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតាមសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

មាត្រា៣៧៣ .- ការចូលរួមរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

សប្បុរសជន វិស័យឯកជន និងសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឱ្យចូលរួមគាំទ្រ និងសម្របសម្រួលក្នុងការរៀបចំ និងកិច្ចដំណើរការរបស់សហគមន៍តំបន់ការពារធម្មជាតិ។

មាត្រា៣៧៤ .- ការរៀបចំផែនការសហគមន៍តំបន់ការពារធម្មជាតិ

សហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិដោយមានការទទួលស្គាល់ពីរដ្ឋបាលថ្នាក់ក្រោមជាតិ។ ផែនការនេះ ត្រូវពិនិត្យឡើងវិញរៀងរាល់៣(បី)ឆ្នាំម្តង ឬមុនពេលកំណត់ក្នុងករណីចាំបាច់។ ផែនការគ្រប់គ្រងធនធានធម្មជាតិនៃសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើសមាហរណកម្មជាមួយផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## ការអប់រំ ការផ្សព្វផ្សាយ ការស្តារនិងការកែលម្អតំបន់ការពារធម្មជាតិ

មាត្រា៣៧៥ .- ការចូលរួមការពារ អភិរក្ស និងស្តារធនធានធម្មជាតិ

ប្រជាពលរដ្ឋ ព្រះសង្ឃ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត និងបុគ្គលផ្សេងទៀត ជាអាទិ៍ មានករណីយកិច្ចចូលរួមការពារ អភិរក្ស និងស្តារធនធានធម្មជាតិឡើងវិញក្នុងតំបន់ការពារធម្មជាតិ។

មាត្រា៣៧៦ .- កម្មវិធីអប់រំផ្សព្វផ្សាយ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយតាមគ្រប់រូបភាពឱ្យបានទូលំទូលាយស្តីពីកិច្ចគាំពារ និងការអភិរក្សធនធានធម្មជាតិ ការស្តារ ការកែលម្អធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីដែលបានរេចរឹល និងបាត់បង់។

២- រៀងរាល់ឆ្នាំ ក្នុងទិវាបរិស្ថានជាតិ បរិស្ថានពិភពលោក និងទិវាអនុសញ្ញាអន្តរជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំសកម្មភាពស្តារធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ ក្នុងគោលបំណងអប់រំ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានយល់ដឹងពីតម្លៃនៃតំបន់ការពារធម្មជាតិ និងលើកកម្ពស់ការចូលរួមក្នុងកិច្ចគាំពារនិងការអភិរក្សធនធានធម្មជាតិ។

៣- ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោកត្រូវរៀបចំឡើងនៅថ្ងៃទី៥ ខែមិថុនា ជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬព្រះរាជតំណាងដោយមានការចូល



៣៥

រួមពីស្ថាប័នព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ស្ថានទូត មន្ត្រីរាជការថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ព្រះសង្ឃ ដៃគូអភិវឌ្ឍ និងសាធារណជន។ ព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ បង្ហាញនូវព្រះរាជហឫទ័យយកចិត្តទុកដាក់លើកិច្ចគាំពារបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាពមានជាអាទិ៍ ការដាំដើមឈើ ការព្រលែងមច្ឆជាតិ និងសត្វព្រៃ និងព្រះរាជសកម្មភាពផ្សេងៗទៀតដែលផ្ដល់ពហុឧត្តមប្រយោជន៍សម្រាប់មនុស្សជាតិនិងភពផែនដី។

**មាត្រា៣៧៧ .- ការកែលម្អបរិស្ថានក្នុងតំបន់ការពារធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើការស្ដារ និងការកែលម្អបរិស្ថានលើតំបន់រេចរឹលក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយសហគមន៍មូលដ្ឋាន សហគមន៍តំបន់ការពារធម្មជាតិ សប្បុរសជនវិស័យឯកជន និងសង្គមស៊ីវិល។

## ជំពូកទី៨
## ការអនុញ្ញាតនិងការហាមឃាត់

**មាត្រា៣៧៨ .- គម្រោងនិងសកម្មភាពអនុញ្ញាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិចេញលិខិតអនុញ្ញាតឬចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាក្នុងគោលដៅអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិដោយមានការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធនូវសកម្មភាពឬគម្រោងដូចខាងក្រោម៖

ក- គម្រោងសហប្រតិបត្តិការអភិរក្ស។

ខ- គម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិ។

គ- កីឡាប្រមាញ់។

ឃ- ការចិញ្ចឹមសត្វព្រៃក្នុងក្រុមប្រភេទដែលមានការអនុញ្ញាត។

ង- ដំណើរសិក្សាស្វែងយល់អំពីការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ច- គម្រោងសិក្សាស្រាវជ្រាវធនធានធម្មជាតិ ជីវៈចម្រុះ បេតិកភណ្ឌធម្មជាតិ និងវប្បធម៌។

ឆ- សកម្មភាព ឬគម្រោងដទៃទៀត ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២-រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចេញលិខិតអនុញ្ញាត ឬចុះកិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្រាប់សកម្មភាព ឬគម្រោងខាងលើដោយស្នើសុំការយល់ព្រមជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- នីតិវិធីនៃការស្នើសុំ និងទម្រង់បែបបទនៃលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬកិច្ចសន្យាសម្រាប់សកម្មភាព ឬគម្រោងខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៧៩ .- គម្រោងសាធារណៈឬឯកជន**

១- ការរៀបចំគម្រោងស្ថាបនានិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិត្រូវធ្វើការពិគ្រោះយោបល់ជាមុន ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- រាល់គម្រោងស្ថាបនា សាងសង់សំណង់ឯកជន នៅក្នុងតំបន់ការពារធម្មជាតិ ត្រូវទទួលការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

៣- រាល់គម្រោងស្ថាបនា សាងសង់ ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈកាត់តាម ឬក្នុងតំបន់ការពារធម្មជាតិ ត្រូវបានដាក់ស្លាកសញ្ញាសម្គាល់ទីតាំងតំបន់ការពារធម្មជាតិនីមួយៗឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ។



៣៥

៤- ស្លាកសញ្ញាសម្គាល់ ឬការកំណត់ការប្រើប្រាស់ស្លាកសញ្ញារបស់គម្រោងស្ថាបនា សាងសង់ ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈកាត់តាម ឬក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសាធារណការនិងដឹកជញ្ជូន។

**មាត្រា៣៨០ ._ ទីតាំងឈរជើងរបស់កងកម្លាំងប្រដាប់អាវុធ**

១- ការបោះឬការផ្លាស់ទីតាំងឈរជើងអចិន្ត្រៃយ៍ ឬបណ្តោះអាសន្នរបស់កងកម្លាំងប្រដាប់អាវុធក្នុងតំបន់ការពារធម្មជាតិ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យកងកម្លាំងប្រដាប់អាវុធត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការសិក្សា និងស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលតាមរយៈក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ទីតាំងមូលដ្ឋានកងកម្លាំងប្រដាប់អាវុធ ដែលបាននិងកំពុងឈរជើងនៅក្នុងតំបន់ការពារធម្មជាតិ ហើយត្រូវរំសាយ ឬផ្លាស់ទីតាំងទៅកន្លែងផ្សេងទៀត អង្គភាពកងកម្លាំងប្រដាប់អាវុធនេះ ត្រូវប្រគល់ទីតាំងមូលដ្ឋាននោះឱ្យមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងវិញ។

៣- ហាមការធ្វើសមយុទ្ធ ការហ្វឹកហាត់ និងការបោះជំរំកងកម្លាំងប្រដាប់អាវុធនៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ។ សកម្មភាពទាំងនេះអាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនិង/ឬតំបន់អភិរក្សដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៨១ ._ ការនាំចេញ ការនាំចូល និងការបង្កាត់ពូជសត្វនិងរុក្ខជាតិរាតត្បាត**

រាល់ការនាំចេញ ការនាំចូលគ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វ ប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត និងពូជមច្ឆជាតិគ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ វាយតម្លៃឱ្យបានច្បាស់លាស់ និងត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៨២ ._ ការនាំចេញ ការនាំចូល ឬការដោះដូរ**

រាល់ការនាំចេញ ការនាំចូល ឬការដោះដូរ ដែលពុំមានលក្ខណៈពាណិជ្ជកម្មនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនោះដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសដទៃត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិនិច្ឆ័យ និងវាយតម្លៃឱ្យបានច្បាស់លាស់ និងត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៨៣ ._ ការបង្ការភ្លើងឆេះព្រៃ**

១- ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ។

២- ការប្រើប្រាស់ភ្លើងអាចអនុគ្រោះបានចំពោះមន្ត្រីទទួលបន្ទុកវិស័យតំបន់ការពារធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬអនាម័យព្រៃ។

៣- ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានកាតព្វកិច្ចចូលរួមសហការក្នុងការថែរក្សា ការពារព្រៃឈើក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃ។

**មាត្រា៣៨៤ ._ ការហាមឃាត់សកម្មភាពបង្កផលប៉ះពាល់ដល់ធនធានធម្មជាតិ**

តំបន់ការពារធម្មជាតិនីមួយៗ ត្រូវការពារ ទប់ស្កាត់ និងហាមឃាត់នូវរាល់សកម្មភាពកាប់គាស់ រុករាន

ទន្រ្ទានដីព្រៃដោយរំលោភ ធ្វើអាជីវកម្ម បំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ភ្លើងឆេះតំបន់ដីមមោក ធ្វើកសិកម្មពនេចរ នាំចូលជំងឺ សត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬសត្វរាតត្បាត ដែលធ្វើឱ្យខូចខាត ឬប៉ះពាល់ក្នុងតំបន់ការពារធម្មជាតិ និងសកម្មភាពហាមឃាត់មួយចំនួនទៀតដូចខាងក្រោម៖

- ក- ការរំកិល ដកចេញ បំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ។
- ខ- ការប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពីសិទ្ធិដែលបានទទួលស្គាល់ឬបានអនុញ្ញាតដោយច្បាប់។
- គ- ការកាប់ ផ្តួល រំលំ គ្រៀរ កាប់បំផ្លាញដើមឈើ បំពុល ឬគាស់រម្លើងគល់ឈើ។
- ឃ- ការប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាបតាមគ្រប់រូបភាព។
- ង- ការបំពុលទឹកគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការចោលសំណល់រឹងរាវចូលក្នុងទឹក ឬលើដី ការប្រើប្រាស់ឧបករណ៍ឆក់។
- ច- ការជួញដូរ ការដឹកជញ្ជូន ការស្តុក ការទិញ ការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ ឬចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្ម និងរុក្ខជាតិព្រៃដោយគ្មានការអនុញ្ញាត។
- ឆ- ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ។
- ជ- ការលែងសត្វពាហនៈ និងបណ្តើរផ្តែប្រមាញ់។
- ឈ- ការនេសាទដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ។
- ញ- ការបង្កើតមូលដ្ឋាន និងកែច្នៃខ្លឹមចន្ទន៍ក្រស្នា ដើមម្រះព្រៅភ្នំ វល្លិរមៀត ឬអនុផលធនធានធម្មជាតិហាមឃាត់ផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបញ្ញត្តិនៃក្រមនេះ និងបច្ចេកទេស ដែលនាំដល់ការបំពុល ឬបំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។
- ដ- ការប្រើប្រាស់ឧបករណ៍នានាដែលបង្កការរំខានដោយសំឡេង រំញ័រ រលក និងផ្សេងដែលអាចបង្កការខូចខាតដល់ធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។
- ឋ- ការកម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតស្លាកសញ្ញាគ្រប់ប្រភេទ។
- ឌ- ការយកថ្ម គ្រួស ខ្សាច់ រ៉ែ ការគាស់ ឈូសឆាយ កកាយយកដី ដោយគ្មានការអនុញ្ញាត។
- ឍ- ការចាក់លុបឬចាក់បំពេញដី ដែនទឹក ផ្លូវរងទឹកភ្លៀង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាបទឹកផុសក្រោមដី ឬអាងទឹក ដោយគ្មានការអនុញ្ញាត។
- ណ- ការនាំចូលនូវរណារយន្ត និងគ្រឿងចក្រផ្សេងៗដោយគ្មានការអនុញ្ញាត។
- ត- ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។
- ថ- ការធ្វើឱ្យរាំងស្ទះដល់លំហូរបរិស្ថាននៃបឹងបួ ទន្លេ ស្ទឹង អូរ ព្រែក ដោយគ្មានការអនុញ្ញាត។
- ទ - ការបោះបង្គោលហ៊ុមព័ទ្ធ ដាក់សញ្ញាសម្គាល់លើដីដែលជាទ្រព្យសម្បត្តិរដ្ឋក្នុងតំបន់ការពារធម្មជាតិក្នុងគោលបំណងកាន់កាប់ ដើម្បីធ្វើលទ្ធកម្មលើកម្មសិទ្ធិ។

**មាត្រា៣៨៥ .‒ ការហាមឃាត់ការកែច្នៃផល អនុផលធនធានធម្មជាតិ**

១- ហាមឃាត់ការកែច្នៃផល អនុផលធនធានធម្មជាតិ ការបង្កើត និងដំណើរការមូលដ្ឋានរោងអារ ជៀកឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល និងអនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល និងអនុផលធនធានធម្មជាតិក្នុងតំបន់ស្នូល និងតំបន់អភិរក្ស លើកលែងតែតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- ហាមឃាត់ការកែច្នៃផល អនុផលធនធានធម្មជាតិ ការបង្កើត និងដំណើរការមូលដ្ឋានរោងអារជៀកឈើ រោងចក្រអារឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា៣៨៦ ._ ការហាមឃាត់សិទ្ធិរបស់បុគ្គល**

បុគ្គលពុំមានសិទ្ធិផ្តល់ការអនុញ្ញាតទោះដោយផ្ទាល់ក្តីឬប្រយោលក្តីឱ្យរានដីព្រៃ កាន់កាប់ដី កាប់ដើមឈើ ចាប់សត្វព្រៃគ្រប់ប្រភេទ ឬធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីប្រមូលផល អនុផលធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៣៨៧ ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

១- ដើម្បីកាត់បន្ថយជាអតិបរមានូវហេតុប៉ះពាល់បរិស្ថាននិងសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍឬវិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាមុនដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងឱ្យគម្រោងអភិវឌ្ឍ ឬវិនិយោគត្រូវបានអនុវត្តប្រកបដោយចីរភាព។

២- នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍ វិនិយោគ ឬសកម្មភាពណាមួយត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## មាតិកាទី២

## ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌និងទេសចរណ៍ធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៣៨៨ ._ គោលបំណង**

មាតិកានេះ មានគោលបំណងរៀបចំយន្តការ និងបែបបទគ្រប់គ្រង ការពារ និងអភិរក្សធនធានធម្មជាតិមានជាអាទិ៍ ទឹក ដី ព្រៃឈើ សត្វព្រៃ រុក្ខជាតិព្រៃ ផលផល ទីជម្រាល រ៉ែ ទេសចរណ៍ និងសម្បត្តិវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីជាឧត្តមប្រយោជន៍ដល់បរិស្ថាន ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម និងជីវភាពសហគមន៍មូលដ្ឋាន។

**មាត្រា៣៨៩ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពនៃការគ្រប់គ្រង កិច្ចគាំពារ ការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ សម្បត្តិវប្បធម៌ ទេសចរណ៍ធម្មជាតិ និងការអភិវឌ្ឍនៅក្នុងតំបន់ការពារធម្មជាតិ។

### ជំពូកទី២

### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៣៩០ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៩១ ._ តួនាទីនិងភារកិច្ច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទី និងភារកិច្ចលើការគ្រប់គ្រង កិច្ចគាំពារ ការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិ និងសម្បត្តិវប្បធម៌ព្រមទាំងការអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ ស្របតាមមាតិកាទី១(ការគ្រប់គ្រងតំបន់ការពារធម្មជាតិ) នៃគន្ថីទី៤នៃក្រមនេះ។

២- ក្រសួងស្ថាប័នមានសមត្ថកិច្ចមានតួនាទីនិងភារកិច្ចលើការគ្រប់គ្រងធនធានធម្មជាតិក្រៅតំបន់ការពារធម្មជាតិ និងសម្បត្តិវប្បធម៌ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យជាធរមាន។

៣- ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវសហការនិងពិគ្រោះយោបល់គ្នា ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមុននឹងធ្វើការចាត់ចែង ការដកហូត ឬការធ្វើសកម្មភាពណាមួយលើធនធានធម្មជាតិ ដែលអាចប៉ះពាល់ដល់តំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ។

## ជំពូកទី៣
## ការគ្រប់គ្រងតំបន់ទីជម្រាល

**មាត្រា៣៩២ .- កិច្ចសហការគ្រប់គ្រងទីជម្រាល**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ត្រូវចូលរួមសហការគ្នាដើម្បីគ្រប់គ្រងទីជម្រាលប្រកបដោយនិរន្តរភាព សំដៅធានាដល់ការគ្រប់គ្រង និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព ដើម្បីជាឧត្តមប្រយោជន៍ដល់បរិស្ថានការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងបរិស្ថាន។

២- ការធ្វើសេចក្តីសម្រេចក្នុងការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវធានាឱ្យមានការចូលរួមពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធ។

**មាត្រា៣៩៣ .- ការកំណត់តំបន់និងធ្វើចំណាត់ថ្នាក់តំបន់ទីជម្រាល**

១- ការកំណត់តំបន់និងធ្វើចំណាត់ថ្នាក់តំបន់ទីជម្រាលត្រូវធ្វើឡើងដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការប្រើប្រាស់ធនធានផ្សេងៗនៅក្នុងតំបន់ទីជម្រាល។

២- ការធ្វើចំណាត់ថ្នាក់តំបន់ទីជម្រាលត្រូវផ្អែកលើលក្ខណវិនិច្ឆ័យណាមួយដូចខាងក្រោម ៖

ក- លក្ខណៈរូបសាស្ត្រនិងស្ថានភាពភូមិសាស្ត្រដី។

ខ- កម្រិតជម្រាល រយៈកម្ពស់ ប្រភេទដី ទម្រង់ដី និងហានិភ័យនៃការហូរច្រោះដី។

គ- បរិមាណ គុណភាព និងកម្រិតលំហូរទឹកនៅគ្រប់ពេល រដូវ ប្រចាំឆ្នាំ។

ឃ- បរិមាណនិងគុណភាពព្រៃឈើ និងគម្របរុក្ខជាតិព្រៃផ្សេងៗទៀត។

ង- ការប្រើប្រាស់ មុខងារ និងសក្តានុពលនៃតំបន់ទីជម្រាល។

ច- ផ្ទៃរងទឹកភ្លៀងក្នុងតំបន់ទីជម្រាល។

ឆ- លក្ខណវិនិច្ឆ័យផ្សេងទៀតដែលកំណត់ដោយអនុក្រឹត្យ។

៣- ការកំណត់តំបន់និងធ្វើចំណាត់ថ្នាក់តំបន់ទីជម្រាលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិលើកសំណើទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៩៤ .- យន្តការសម្របសម្រួលថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាល**

១- យន្តការសម្របសម្រួលថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវបង្កើតឡើងដោយអនុក្រឹត្យក្នុងទិសដៅសម្របសម្រួលគ្រប់គ្រងលើកិច្ចប្រតិបត្តិការ និងរៀបចំយន្តការសម្រាប់ការងារគ្រប់គ្រងតំបន់ទីជម្រាលផ្ទៃរងទឹកភ្លៀង និងអាងទន្លេ។

២- សមាសភាពចូលរួមក្នុងយន្តការសម្របសម្រួលថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាលមានក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣៩៥ ._ យន្តការសម្របសម្រួលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាល**

១- យន្តការសម្របសម្រួលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិស្របតាមស្ថានភាពជាក់ស្តែង។

២- សមាសភាពចូលរួមក្នុងយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងតំបន់ទីជម្រាល មានរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានដែលនៅក្នុង ឬក្បែរតំបន់ទីជម្រាល។

**មាត្រា៣៩៦ ._ ការប្រតិបត្តិក្នុងការគ្រប់គ្រងតំបន់ទីជម្រាល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចក្នុងការសម្របសម្រួលជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ភាគីពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានដើម្បីរៀបចំផែនការគ្រប់គ្រងតំបន់ទីជម្រាលនីមួយៗដោយផ្អែកលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៣៩៧ ._ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាព**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់គ្រប់គ្រងតំបន់ទីជម្រាល ដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិនិងភាគីពាក់ព័ន្ធ។

២- ខ្លឹមសារនិងប្រភេទនៃសកម្មភាពពាក់ព័ន្ធនឹងការប្រើប្រាស់ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីដែលត្រូវបានអនុញ្ញាតនៅតាមផ្នែកនីមួយៗរបស់តំបន់ទីជម្រាល ត្រូវស្របតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៣៩៨ ._ ការពិនិត្យតាមដាន ការវាយតម្លៃ និងការធ្វើបច្ចុប្បន្នកម្ម**

១- ផែនការគ្រប់គ្រងតំបន់ទីជម្រាលត្រូវមានការពិនិត្យតាមដាននិងវាយតម្លៃជាប្រចាំតាមសូចនាករ ដែលមានលក្ខណៈសមស្របសម្រាប់តំបន់ទីជម្រាលនីមួយៗ។

២- ការពិនិត្យតាមដាន និងវាយតម្លៃផែនការ ត្រូវធ្វើឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធនៅក្នុងតំបន់ទីជម្រាល ហើយលទ្ធផលនៃការពិនិត្យតាមដាន និងវាយតម្លៃត្រូវរៀបចំឱ្យបានត្រឹមត្រូវ និងផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធ។

៣- ផែនការគ្រប់គ្រងតំបន់ទីជម្រាលត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំ ដោយឈរលើមូលដ្ឋាននៃលទ្ធផលនៃការពិនិត្យតាមដាននិងវាយតម្លៃផែនការ។

**មាត្រា៣៩៩ ._ សកម្មភាពធ្វើឱ្យខូចខាតទីជម្រាល**

សកម្មភាពដែលធ្វើឱ្យខូចខាតទីជម្រាលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៤
## ការអភិរក្សនិងការគ្រប់គ្រងសម្បត្តិវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ
## ផ្នែកទី១
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៤០០ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការក្នុងការថែរក្សា ការពារ និងកំណត់តំបន់បេតិកភណ្ឌវប្បធម៌ នៅក្នុងតំបន់

ការពារធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដោយអនុលោមតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤០១ .- តួនាទីនិងភារកិច្ច**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ចូលរួមសហការ និងកំណត់តំបន់បេតិកភណ្ឌវប្បធម៌ដែលមាននៅក្នុងតំបន់ការពារធម្មជាតិ។

ខ- ចូលរួមសហការក្នុងការថែរក្សាការពារ និងអភិរក្សសម្បត្តិវប្បធម៌ដែលមាននៅក្នុងតំបន់ការពារធម្មជាតិ។

គ- សិក្សា វាយតម្លៃ ប្រមូល ចងក្រងទិន្នន័យតំបន់បេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិ។

ឃ- ចូលរួមគ្រប់គ្រង ថែរក្សាការពារ និងអភិរក្សបេតិកភណ្ឌធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា៤០២ .- ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធមុននឹងធ្វើសេចក្តីសម្រេចដាក់តំបន់បេតិកភណ្ឌវប្បធម៌ណាមួយដែលនៅក្នុងតំបន់ការពារធម្មជាតិ ជារមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ តំបន់ការពារបុរាណស្ថាន ឬតំបន់ទីក្រុងបេតិកភណ្ឌដូចមានចែងក្នុងមាត្រា៤០៤(ការបែងចែកតំបន់ការពារបេតិកភណ្ឌវប្បធម៌)នៃក្រមនេះ។

## ផ្នែកទី២

## ការរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ

**មាត្រា៤០៣ .- ការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ**

១- តំបន់ការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ ត្រូវបង្កើតដោយលិខិតបទដ្ឋានគតិយុត្តតាមសំណើរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ឬតាមសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមកក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងភាគីពាក់ព័ន្ធ។

២- ការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ណាមួយក្នុងតំបន់ការពារធម្មជាតិ ត្រូវផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈពិសេស តម្លៃ និងសក្តានុពលនៃបេតិកភណ្ឌ សម្បត្តិវប្បធម៌ ជំនឿ ប្រវត្តិសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌ គោលបំណងនៃការគ្រប់គ្រង និងកត្តាពាក់ព័ន្ធផ្សេងទៀត ព្រមទាំងគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។

៣- លក្ខណវិនិច្ឆ័យក្នុងការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៤០៤ .- ការបែងចែកតំបន់ការពារបេតិកភណ្ឌវប្បធម៌**

តំបន់ការពារបេតិកភណ្ឌវប្បធម៌ត្រូវបែងចែកជា៣(បី)ប្រភេទ ដូចខាងក្រោម៖

ក- រមណីយដ្ឋានបេតិកភណ្ឌវប្បធម៌។

ខ- តំបន់បុរាណស្ថាន។

គ- តំបន់ទីក្រុងបេតិកភណ្ឌ។

**មាត្រា៤០៥ ._ ការស្នើសុំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌**

តំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤០៦ ._ កិច្ចសហការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីរៀបចំបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិក្នុងករណីតំបន់ការពារធម្មជាតិនោះមានបន្សល់ទុកនូវបេតិកភណ្ឌវប្បធម៌។

**មាត្រា៤០៧ ._ លក្ខណវិនិច្ឆ័យក្នុងការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌**

លក្ខណវិនិច្ឆ័យក្នុងការបង្កើតតំបន់ការពារបេតិកភណ្ឌវប្បធម៌ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

**មាត្រា៤០៨ ._ កិច្ចសហការបង្កើតតំបន់បុរាណស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីរៀបចំបង្កើតតំបន់បុរាណស្ថាននៅក្នុងតំបន់ការពារធម្មជាតិ ក្នុងករណីតំបន់ការពារធម្មជាតិនោះមានបន្សល់ទុកនូវសម្បត្តិវប្បធម៌។

**មាត្រា៤០៩ ._ ការការពារតំបន់បុរាណស្ថាន**

តំបន់បុរាណស្ថាន ជាតំបន់ការពារដាច់ខាត ដែលមិនអនុញ្ញាតឱ្យមានសកម្មភាពអភិវឌ្ឍផ្សេងៗ រួមបញ្ចូលទាំងសកម្មភាពនៃការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន លើកលែងតែក្នុងគោលដៅការពារជាតិ ដែលមានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា៤១០ ._ បរិវេណការពារតំបន់បុរាណស្ថាន**

ការកំណត់បរិវេណការពារតំបន់បុរាណស្ថានក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ផ្នែកទី៣

## ការប្រទះឃើញដោយចៃដន្យក្នុងកំលុងពេលធ្វើសកម្មភាពផ្សេងៗ

**មាត្រា៤១១ ._ កាតព្វកិច្ចទូទៅចំពោះការជូនដំណឹងអំពីការប្រទះឃើញដោយចៃដន្យ**

បុគ្គលដែលបានដឹងឬប្រទះឃើញដោយចៃដន្យនូវវត្ថុទាំងឡាយណា ដែលសង្ស័យថាជាសម្បត្តិវប្បធម៌ ឬចេនាសម្ព័ន្ធសំណង់បុរាណ ឬវត្ថុបុរាណផ្សេងៗ ក្នុងកំលុងពេលធ្វើសកម្មភាពផ្សេងៗត្រូវរាយការណ៍ជាបន្ទាន់ជូនក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤១២ ._ កាតព្វកិច្ចក្នុងការបញ្ឈប់ការងារនិងជូនដំណឹងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

បុគ្គលដែលប្រទះឃើញដោយចៃដន្យនូវសម្បត្តិវប្បធម៌ រចនាសម្ព័ន្ធសំណង់បុរាណ ឬវត្ថុបុរាណផ្សេងៗ នៅក្នុងកំឡុងពេលនៃការជីក គាស់កកាយ ការសាងសង់ ឬសកម្មភាពដទៃទៀត ត្រូវបញ្ឈប់ការងារនោះជាបណ្តោះអាសន្ន

ROYAUME DU CAMBODGE MINISTRE DU... ROYAL



៣៥

ហើយត្រូវរាយការណ៍ និងត្រូវបញ្ជូនសម្បត្តិវប្បធម៌នោះទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឬស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់។

**មាត្រា៤១៣ ._ ការជូនដំណឹងទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌**

១- រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរាយការណ៍ទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងចាត់វិធានការចាំបាច់ដើម្បីការពារសម្បត្តិវប្បធម៌ និងទីតាំងដែលមានសម្បត្តិវប្បធម៌ទាំងនោះ រហូតដល់ពេលក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ចុះធ្វើអធិការកិច្ចទីតាំងនោះ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងដល់ក្រសួងស្ថាប័នឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីចាត់វិធានការគាំពារ និងគ្រប់គ្រងសម្បត្តិវប្បធម៌ដែលបានរកឃើញនោះឱ្យបានគង់វង្ស។

**មាត្រា៤១៤ ._ ការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌នៅក្នុងរយៈពេល១៤(ដប់បួន)ថ្ងៃ ក្រោយពេលទទួលបានការជូនដំណឹងឬរបាយការណ៍។ រយៈពេលនេះអាចពន្យារបាន តែម្តងប៉ុណ្ណោះដោយមានរយៈពេល១៤(ដប់បួន)ថ្ងៃបន្ថែម។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការពន្យារពេលនេះដល់អ្នកកាន់កាប់ ឬកម្មសិទ្ធិករនៃអចលនវត្ថុដែលមានវត្ថុត្រូវបានប្រទះឃើញ និងសង្ស័យថាជាសម្បត្តិវប្បធម៌ ឬរចនាសម្ព័ន្ធសំណង់បុរាណ ឬវត្ថុបុរាណផ្សេងៗ។

**មាត្រា៤១៥ ._ សេចក្តីសម្រេចក្នុងការផ្អាកជាបណ្តោះអាសន្នឬបន្តផ្អាកការងារ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវចេញសេចក្តីសម្រេចក្នុងការផ្អាកជាបណ្តោះអាសន្ន ឬបន្តការព្យួរការងារនៅលើទីតាំងទាំងឡាយណាដែលមានការប្រទះឃើញសម្បត្តិវប្បធម៌ ដូចមានចែងក្នុងមាត្រា៤១១(កាតព្វកិច្ចទូទៅចំពោះការជូនដំណឹងអំពីការប្រទះឃើញដោយចៃដន្យ)នៃក្រមនេះ។

២- សេចក្តីសម្រេចផ្អាកបណ្តោះអាសន្ន ឬបន្តព្យួរការងារនេះមានសុពលភាពត្រឹមរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីបានធ្វើការកំណត់ជាបឋម ដូចមានចែងក្នុងមាត្រា៤១៤(ការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌)នៃក្រមនេះ។

៣- ក្នុងករណីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ពុំបានចេញសេចក្តីសម្រេចថ្មី ក្រោយរយៈពេល៣០(សាមសិប)ថ្ងៃខាងលើនេះបានកន្លងផុតនោះទេ អ្នកកាន់កាប់ ឬកម្មសិទ្ធិករអាចបន្តសកម្មភាពការងាររបស់ខ្លួនបាន។

**មាត្រា៤១៦ ._ កាតព្វកិច្ចធ្វើកំណត់ត្រា**

អ្នកកាន់កាប់ ឬកម្មសិទ្ធិករ ដូចមានចែងក្នុងមាត្រា៤១៤(ការកំណត់ជាបឋមអំពីសារៈសំខាន់នៃសម្បត្តិវប្បធម៌)នៃក្រមនេះត្រូវសហការជាមួយមន្ត្រីជំនាញក្នុងការធ្វើកំណត់ត្រា និងថតរូបសម្បត្តិវប្បធម៌ ឬវត្ថុបុរាណស្របតាមការណែនាំរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

**មាត្រា៤១៧ ._ ការចាត់វិធានការចំពោះករណីមិនរាយការណ៍**

ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវព្យួរ ដកហូត ឬលុបចោលលិខិតអនុញ្ញាត អាជ្ញាបណ្ណ ឬវិញ្ញាបនបត្រនានាចំពោះបុគ្គលទាំងឡាយណាដូចមានចែងក្នុងមាត្រា៤១១(កាតព្វកិច្ចទូទៅចំពោះការជូនដំណឹងអំពីការប្រទះឃើញដោយចៃដន្យ)នៃក្រមនេះដែលខកខានមិនរាយការណ៍អំពីការប្រទះឃើញដោយចៃដន្យមុនពេលធ្វើការកំណត់អំពីការចុះបញ្ជីនិងសារៈសំខាន់នៃសម្បត្តិវប្បធម៌នោះ។

## ផ្នែកទី៤
## កំណាយបង្ការ

**មាត្រា៤១៨ ._ ការតម្រូវឱ្យមានការធ្វើកំណាយបង្ការ**

ម្ចាស់គម្រោងវិនិយោគដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល ស្របតាមច្បាប់ស្ដីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឱ្យធ្វើការសាងសង់ ឬអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មានកាតព្វកិច្ចធ្វើកំណាយបង្ការ។

**មាត្រា៤១៩ ._ ការអនុវត្តការធ្វើកំណាយបង្ការ**

ម្ចាស់គម្រោងវិនិយោគ ត្រូវទាក់ទងមន្ត្រីជំនាញនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ឬអង្គភាពជំនាញខាងបុរាណវិទ្យា ដូចមានចែងក្នុងផ្នែកទី៥(នីតិបុគ្គលដែលជាអង្គភាពជំនាញខាងបុរាណវិទ្យា) ជំពូកទី៤(ការអភិរក្សនិងការគ្រប់គ្រងសម្បត្តិវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ) មាតិកាទី២(ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ) នៃគន្ថីទី៤នៃក្រមនេះ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីអនុវត្តការងារធ្វើកំណាយបង្ការ។

**មាត្រា៤២០ ._ ការទុកជាទ្រព្យសម្បត្តិរដ្ឋ**

បេតិកភណ្ឌវប្បធម៌ឬវត្ថុបុរាណផ្សេងៗ ដែលបានរកឃើញក្នុងកំលុងពេលនៃការធ្វើកំណាយបង្ការត្រូវទុកជាសម្បត្តិរដ្ឋ។

**មាត្រា៤២១ ._ បន្ទុកចំណាយលើការងារធ្វើកំណាយបង្ការ**

ម្ចាស់គម្រោងវិនិយោគត្រូវទទួលបន្ទុកលើការចំណាយសម្រាប់ការងារធ្វើកំណាយបង្ការ។

**មាត្រា៤២២ ._ កាតព្វកិច្ចធ្វើកំណត់ត្រា**

១- មន្ត្រីជំនាញនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ឬអង្គភាពជំនាញខាងបុរាណវិទ្យា ដែលត្រូវអនុវត្តការធ្វើកំណាយបង្ការមានកាតព្វកិច្ចកត់ត្រា និងថែរក្សានូវរាល់សម្បត្តិវប្បធម៌ឬវត្ថុបុរាណផ្សេងៗ ដែលប្រមូលបានពីការធ្វើកំណាយបង្ការ។

២- សម្បត្តិវប្បធម៌ជាចលនវត្ថុ ឬវត្ថុបុរាណត្រូវយកទៅរក្សាទុកនៅសារមន្ទីររបស់រដ្ឋ ដើម្បីជាប្រយោជន៍សាធារណៈ។

## ផ្នែកទី៥
## នីតិបុគ្គលដែលជាអង្គភាពជំនាញខាងបុរាណវិទ្យា

**មាត្រា៤២៣ ._ ការទទួលស្គាល់នីតិបុគ្គលដែលជាអង្គភាពជំនាញខាងបុរាណវិទ្យា**

១- ដើម្បីជាឧត្តមប្រយោជន៍ជាតិ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ត្រូវផ្តល់សិទ្ធិដល់នីតិបុគ្គលឯកជនជាតិ ដែលជាអង្គភាពជំនាញខាងបុរាណវិទ្យា ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ការអភិរក្ស ការជួសជុលសម្បត្តិវប្បធម៌ ឬការអនុវត្តការធ្វើកំណាយបង្ការ ឬកំណាយសង្គ្រោះលើទីតាំងនៃគម្រោងអភិវឌ្ឍ។

២-បែបបទ នីតិវិធី និងលក្ខខណ្ឌតម្រូវនៃការចុះបញ្ជីនីតិបុគ្គល ដែលជាអង្គភាពជំនាញខាងបុរាណវិទ្យាត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

**មាត្រា៤២៤ ._ ភារកិច្ចនៃនីតិបុគ្គលដែលជាអង្គភាពជំនាញខាងបុរាណវិទ្យា**

នីតិបុគ្គលដែលជាអង្គភាពជំនាញខាងបុរាណវិទ្យាទទួលអនុវត្ត៖

ក- ការសិក្សាស្រាវជ្រាវលើសម្បត្តិវប្បធម៌ និងសហការជាមួយស្ថាប័នវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិក្នុងការជាវជួសជុល និងអភិរក្សសម្បត្តិវប្បធម៌។

ខ- ការធ្វើកំណាយបង្ការ ឬកំណាយសង្គ្រោះ និងរៀបចំរបាយការណ៍នៃការធ្វើកំណាយ ជូនទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

គ- ការកត់ត្រារាល់សម្បត្តិវប្បធម៌ដែលបានរកឃើញ ឬជួបប្រទះ ហើយត្រូវប្រគល់សម្បត្តិវប្បធម៌ទាំងនោះទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ នៅពេលបញ្ចប់ដំណាក់កាលនៃការធ្វើកំណាយនីមួយៗ។

ឃ- ការផ្តល់របាយការណ៍ជាទៀងទាត់ដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការអនុវត្តនៃការធ្វើកំណាយនីមួយៗ។

ង- ការប្រមូល ចងក្រង និងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវ។

## ផ្នែកទី៦
## កិច្ចគាំពារបេតិកភណ្ឌវប្បធម៌ក្រោមទឹក

**មាត្រា៤២៥ .- បេតិកភណ្ឌវប្បធម៌ក្រោមទឹក**

បេតិកភណ្ឌវប្បធម៌ក្រោមទឹកសំដៅលើសម្បត្តិវប្បធម៌រូបីជាចលនវត្ថុ ឬអចលនវត្ថុដែលលិចចូលទៅក្នុងទឹកដោយផ្នែក ឬទាំងស្រុង មួយរយៈកាល ឬជានិរន្តរ៍ មានជាអាទិ៍៖

ក- ទីតាំង រចនាសម្ព័ន្ធ អគារ វត្ថុបុរាណ ឬសំណល់អដ្ឋិធាតុរបស់មនុស្ស និងសំណល់សត្វ។

ខ- សំពៅ ទូក នាវា យន្តហោះ យានយន្តដទៃទៀត ឬបំណែករបស់វា និងវត្ថុផ្សេងទៀត។

គ- វត្ថុនានា ដែលមានតម្លៃផ្នែកបុរេប្រវត្តិ ប្រវត្តិសាស្ត្រ ឬសិល្បៈ។

**មាត្រា៤២៦ .- កាតព្វកិច្ចរាយការណ៍**

បុគ្គលត្រូវរាយការណ៍ជូនក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ និងរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការរកឃើញ ឬជួបប្រទះដោយចៃដន្យនូវសម្បត្តិវប្បធម៌ណាមួយនៅក្រោមទឹក។

**មាត្រា៤២៧ .- ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់យក ឬបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្រោមទឹក**

ហាមឃាត់រាល់សកម្មភាពនៃការស្រង់ ការបង្កការខូចខាត ឬការបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្រោមទឹក។

**មាត្រា៤២៨ .- កិច្ចគាំពារការវាយតម្លៃផ្នែកវិទ្យាសាស្ត្រនិងការរុករកសម្បត្តិវប្បធម៌ក្រោមទឹក**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីអនុញ្ញាតឱ្យមានកិច្ចគាំពារ ការវាយតម្លៃផ្នែកវិទ្យាសាស្ត្រ និងការរុករកសម្បត្តិវប្បធម៌ក្រោមទឹក។

**មាត្រា៤២៩ .- ការចេញលិខិតអនុញ្ញាតដល់ការស្រាវជ្រាវសម្បត្តិវប្បធម៌ក្រោមទឹក ចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ដល់សម្បត្តិវប្បធម៌ក្រោមទឹក**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ អាចចេញលិខិតអនុញ្ញាតដល់ការស្រាវជ្រាវសម្បត្តិវប្បធម៌ក្រោមទឹក ចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ដល់សម្បត្តិវប្បធម៌ក្រោមទឹក។

២- លក្ខខណ្ឌនិងនីតិវិធី នៃការផ្តល់លិខិតអនុញ្ញាតដល់ការស្រាវជ្រាវសម្បត្តិវប្បធម៌ក្រោមទឹក ចំពោះសកម្មភាពដែលបង្កផលប៉ះពាល់ដល់សម្បត្តិវប្បធម៌ក្រោមទឹក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

**មាត្រា៤៣០ .– ការទុកដាក់ ថែរក្សា និងតាំងបង្ហាញនូវសម្បត្តិវប្បធម៌ក្រោមទឹក**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ត្រូវទុកដាក់ ថែរក្សា និងតាំងបង្ហាញនូវសម្បត្តិវប្បធម៌ក្រោមទឹកដែលបានរកឃើញជាចលនវត្ថុអាចបំលាស់ទី ឬដឹកជញ្ជូនចេញពីទីតាំងដើមបានដោយរក្សានូវតម្លៃដើមនៅសារមន្ទីរ។

២- បែបបទនិងនីតិវិធីនៃការគ្រប់គ្រងសារមន្ទីរ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌។

## ផ្នែកទី៧
## ការដោះស្រាយវិវាទនិងវិធានការទប់ស្កាត់

**មាត្រា៤៣១ .– ការធ្វើជាតំណាងក្នុងការដោះស្រាយវិវាទ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវធ្វើជាអង្គភាពដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងនីតិវិធីដោះស្រាយវិវាទ ដែលមានផលប៉ះពាល់លើសម្បត្តិវប្បធម៌។

**មាត្រា៤៣២ .– ការផ្អាកសកម្មភាពគំរាមកំហែងឬគ្រោះថ្នាក់ដល់សម្បត្តិវប្បធម៌**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្អាកការងារ ការសាងសង់ ឬការឈូសឆាយក្នុងករណីដែលទីតាំង ឬសម្បត្តិវប្បធម៌កំពុងរងគ្រោះថ្នាក់ឬបំផ្លិចបំផ្លាញ ទោះបីជាទីតាំងឬសម្បត្តិវប្បធម៌នោះបានឬមិនទាន់បានចុះនៅក្នុងបញ្ជីបេតិកភណ្ឌជាតិក៏ដោយ។

២- កំលុងពេលនៃការផ្អាកសកម្មភាពការងារនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៨
## ការលើកកម្ពស់និងកិច្ចគាំពារបេតិកភណ្ឌវប្បធម៌អរូបី

**មាត្រា៤៣៣ .– កិច្ចគាំពារនិងការលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី**

បេតិកភណ្ឌវប្បធម៌អរូបីត្រូវទទួលបាននូវកិច្ចគាំពារ និងការលើកកម្ពស់ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៣៤ .– វិធានការគាំពារនិងការលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបី**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីការពារ និងលើកកម្ពស់បេតិកភណ្ឌវប្បធម៌អរូបីស្របតាមលិខិតុបករណ៍អន្តរជាតិនានាពាក់ព័ន្ធនឹងបេតិកភណ្ឌវប្បធម៌អរូបី ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

**មាត្រា៤៣៥ .– ការលើកតម្លៃបេតិកភណ្ឌវប្បធម៌អរូបី**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជំរុញលើកតម្លៃ និងអភិរក្សបេតិកភណ្ឌវប្បធម៌អរូបីតាមរយៈការបង្កើតព្រឹត្តិការណ៍សំខាន់ៗថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិដូចជាមហោស្រព ការសម្ដែងសិល្បៈឬការតាំងពិព័រណ៍ជាដើម។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៣៦ ._ ការបណ្តុះបណ្តាលនិងផ្ទេរបន្តនូវទម្រង់បេតិកភណ្ឌវប្បធម៌អរូបី**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវលើកទឹកចិត្តឱ្យមានកម្មវិធីអប់រំ និងផ្សព្វផ្សាយ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងគោលបំណងចែករំលែកនូវទម្រង់បេតិកភណ្ឌវប្បធម៌អរូបី ដែលមាននៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសទម្រង់បេតិកភណ្ឌវប្បធម៌អរូបីដែលជិតបាត់បង់។

២- ក្រសួងស្ថាប័នទទួលបន្ទុកបេតិកភណ្ឌវប្បធម៌ត្រូវបង្កើតកម្មវិធីផ្សេងៗក្នុងន័យបណ្តុះបណ្តាល និងផ្ទេរចំណេះដឹងបេតិកភណ្ឌវប្បធម៌អរូបីទៅមនុស្សជំនាន់ក្រោយ ដើម្បីបន្តនិរន្តរភាព។

**មាត្រា៤៣៧ ._ ការគាំទ្រដល់ការសិក្សាស្រាវជ្រាវនិងការបោះពុម្ពផ្សព្វផ្សាយទម្រង់បេតិកភណ្ឌវប្បធម៌អរូបី**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យបេតិកភណ្ឌវប្បធម៌ ត្រូវជំរុញឱ្យមានការគាំទ្រនិងលើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ និងបោះពុម្ពផ្សព្វផ្សាយនូវទម្រង់បេតិកភណ្ឌវប្បធម៌អរូបី ជាពិសេសបេតិកភណ្ឌវប្បធម៌អរូបី ដែលត្រូវអភិរក្ស និងសង្គ្រោះបន្ទាន់។

## ជំពូកទី៥
## ការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៤៣៨ ._ ស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកមានសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យ និងអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងធនធានទឹក និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដោយពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងករណីចាំបាច់។

២- ក្នុងករណីមានការដកហូតទឹកដែលអាចបង្កផលប៉ះពាល់ដល់តំបន់ស្នូល ឬតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៤៣៩ ._ តួនាទីនិងភារកិច្ច**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រង ការត្រួតពិនិត្យ និងការអនុវត្តបញ្ញត្តិពាក់ព័ន្ធនឹងធនធានទឹកនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងធនធានទឹក។

ខ- រៀបចំសេចក្តីព្រាងគោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានទឹក ផែនការគ្រប់គ្រងផែនការមេ និងផែនទីទិន្នន័យសម្រាប់គ្រប់គ្រងធនធានទឹក។

គ- ពិនិត្យនិងលើកសំណើជូនរាជរដ្ឋាភិបាលក្នុងការចូលរួមអនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ។

ឃ- សិក្សា វាយតម្លៃ ប្រមូល ចងក្រង និងរក្សាទុកទិន្នន័យព័ត៌មានធនធានទឹក។

ង- គ្រប់គ្រងអាងទន្លេ អាងទន្លេង ទឹកលើទីជម្រាល ទឹកក្រោមដី និងល្អាងទឹកក្រោមដី។

ច- អប់រំផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សាការពារធនធានទឹក។

ឆ- អភិវឌ្ឍសមត្ថភាពនិងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍ក្នុងការគ្រប់គ្រងធនធានទឹក។

ជ- ធ្វើអធិការកិច្ច ពិនិត្យតាមដាន និងវាយតម្លៃទៅលើការគ្រប់គ្រងធនធានទឹក។

**មាត្រា៤៤០ .- គោលការណ៍នៃការគ្រប់គ្រងធនធានទឹករួមគ្នា**

ដើម្បីគ្រប់គ្រងនិងអភិវឌ្ឍធនធានទឹកដោយនិរន្តរភាព ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក- សមធម៌សង្គម៖ ធ្វើឱ្យមានសមភាពនៃការទទួលបានទឹកក្នុងបរិមាណ និងគុណភាពគ្រប់គ្រាន់ ដោយយកចិត្តទុកដាក់ជាពិសេសទៅលើក្រុមមនុស្ស ដែលមិនមានតំណាងគ្រប់គ្រាន់ក្នុងការទទួលបានទឹកក្នុងបរិមាណនិងគុណភាពគ្រប់គ្រាន់សម្រាប់ទ្រទ្រង់សុខុមាលភាព។

ខ- ប្រសិទ្ធផលសេដ្ឋកិច្ច៖ ផ្តល់ផលប្រយោជន៍បែបធនធានហិរញ្ញវត្ថុជាអតិបមាពីការប្រើប្រាស់ធនធានទឹកទៅអ្នកប្រើប្រាស់។

គ- និរន្តរភាពបរិស្ថាន៖ តម្រូវឱ្យធ្វើការបែងចែកទឹកគ្រប់គ្រាន់ ដើម្បីរក្សាឱ្យមាននិរន្តរភាពនៃមុខងារតាមធម្មជាតិនៃពពួកសត្វនិងរុក្ខជាតិដែលទទួលការគំរាមកំហែង និងប្រព័ន្ធអេកូឡូស៊ី។

**មាត្រា៤៤១ .- កត្តាដែលត្រូវពិចារណាសម្រាប់ការអនុវត្ត**

នៅពេលអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈអន្តរវិស័យ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកនិងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវពិចារណាចំណុចដូចខាងក្រោម៖

ក- គ្រប់ទិដ្ឋភាពនៃធនធានទឹក។

ខ- ទំនាក់ទំនងរវាងធនធានទឹកនិងសមាសភាគដទៃទៀតនៃបរិស្ថានធម្មជាតិមានជាអាទិ៍ ដីធ្លី ជលផល ព្រៃឈើ រុក្ខជាតិ សត្វ។

គ- លក្ខខណ្ឌតម្រូវសម្រាប់ការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋនិងបរិស្ថានធម្មជាតិឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព។

**មាត្រា៤៤២ .- ការសហការរវាងក្រសួងស្ថាប័នមានសមត្ថកិច្ច**

១- ក្រសួងស្ថាប័នមានសមត្ថកិច្ចទាំងអស់ដែលទទួលខុសត្រូវលើការប្រើប្រាស់ទឹក ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានវារីជាតិដោយនិរន្តរភាពលើធនធានសត្វនិងរុក្ខជាតិក្នុងទឹកដែលមានជីវិត និងប្រព័ន្ធអេកូឡូស៊ីដែលពាក់ព័ន្ធ ត្រូវសហការអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈរួមគ្នា។

២- កិច្ចសហការអនុវត្តការគ្រប់គ្រងធនធានទឹកជាលក្ខណៈរួមគ្នា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៤៣ .- ការរួមចំណែករបស់ភាគីពាក់ព័ន្ធ**

ក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវសហការជាមួយនីតិបុគ្គលសាធារណៈ និងឯកជនដើម្បីគ្រប់គ្រងវិនិយោគ ធ្វើអាជីវកម្ម អភិរក្ស និងអភិវឌ្ឍធនធានទឹក។

**មាត្រា៤៤៤ .- បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវរក្សាទុកនូវរាល់បញ្ជីសារពើភណ្ឌធនធានទឹកថ្នាក់ជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៤៥ ._ ទិន្នន័យធនធានទឹក**

១- ទិន្នន័យស្តីពីបរិមាណ គុណភាពទឹក និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទឹក ដែលប្រមូលបានដោយក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវបញ្ជូនមកក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ស្របតាមស្តង់ដាបច្ចេកទេសដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

២- ទិន្នន័យពាក់ព័ន្ធនឹងធនធានទឹកត្រូវបញ្ជូនទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកយ៉ាងហោចណាស់១(មួយ)ឆ្នាំម្តង។

**មាត្រា៤៤៦ ._ ទិន្នន័យដែលអាចស្វែងរកបាន**

១- ព័ត៌មាននិងទិន្នន័យត្រូវផ្តល់ជូនដោយឥតគិតថ្លៃដល់ក្រសួងស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធដែលមានចំណាប់អារម្មណ៍ក្នុងទិសដៅបម្រើផលប្រយោជន៍សាធារណៈ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចតម្រូវឱ្យមានការបង់ថ្លៃ ចំពោះពាក្យស្នើសុំទាំងឡាយដែលធ្វើឡើងក្នុងគោលបំណងអាជីវកម្ម។

៣- ព័ត៌មានដូចមានចែងខាងលើនេះ មិនរួមបញ្ចូលនូវព័ត៌មានដែលត្រូវបានចាត់ទុកថាជាព័ត៌មានសម្ងាត់។

**មាត្រា៤៤៧ ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចរៀបចំលិខិតបទដ្ឋានគតិយុត្ត ដោយដាក់បញ្ចូលនូវចំណុចមានជាអាទិ៍៖

ក- តំបន់ហាមឃាត់ការប្រើប្រាស់ទឹកឬការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។
ខ- ការរៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការយកទឹកឬប្រើប្រាស់ធនធានទឹក។
គ- ការបង្កើតនិងការគ្រប់គ្រងអាជ្ញាធរអាងទន្លេ។
ឃ- បញ្ហាជាអាទិភាពសម្រាប់ដាក់បញ្ចូលទៅក្នុងផែនការធនធានទឹកអាងទន្លេ។
ង- ការលើកទឹកចិត្តឱ្យមានការសិក្សាស្រាវជ្រាវឬការអភិវឌ្ឍនវានុវត្តន៍ ដែលចូលរួមចំណែកក្នុងការកាត់បន្ថយសំណល់ និងកែលម្អគុណភាពទឹក និងបង្កើនប្រសិទ្ធផលនៃការប្រើប្រាស់ទឹក។
ច- ការលើកទឹកចិត្តនិងមិនលើកទឹកចិត្តទាក់ទងនឹងយន្តការហិរញ្ញវត្ថុ មានជាអាទិ៍ការប្រើប្រាស់ប្រាក់កម្រៃ និងតារាងថ្លៃតាមអត្រាថយចុះ ដើម្បីលើកទឹកចិត្តឱ្យមានការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធផល។
ឆ- ការបង្កើតនិងការគ្រប់គ្រងសមាគមកសិករប្រើប្រាស់ទឹក។
ជ- ការប្រកាសស្តីពីតំបន់ប្រើប្រាស់ទឹកដែលត្រូវការពារជម្មជាតិ។
ឈ- ការកំណត់និងការគ្រប់គ្រងតំបន់ការពារគ្រោះទឹកជំនន់និងរាំងស្ងួត។
ញ- កាលុបឬផ្លាស់ប្តូរលំហូរទឹកតាមធម្មជាតិ។
ដ- ការរៀបចំបទប្បញ្ញត្តិស្តីពីការអភិវឌ្ឍទឹកក្រោមដី និងឧស្សាហកម្មអភិវឌ្ឍទឹកក្រោមដី មានជាអាទិ៍៖
- គុណវុឌ្ឍិសម្រាប់អ្នកម៉ៅការសាងសង់អណ្តូងនិងអ្នកសាងសង់អណ្តូងខួង
- លក្ខខណ្ឌតម្រូវដែលបញ្ជាក់ថា ម៉ាស៊ីនសាងសង់អណ្តូងបានធ្វើប្រតិបត្តិការ ស្របតាមវិញ្ញាបនបត្រទទួលស្គាល់សមត្ថភាពខួងអណ្តូងរបស់ក្រុមហ៊ុនម៉ៅការ
- ការយកសំណាក ធ្វើតេស្ត វិភាគ សិក្សា និងដាក់បញ្ចូលទិន្នន័យអណ្តូងខួង និងបញ្ជូនទិន្នន័យទាំងនេះទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យផ្គត់ផ្គង់ទឹកជនបទ
- ការស្តារអណ្តូងឡើងវិញ និងវិធីសាស្ត្រ និងលក្ខខណ្ឌតម្រូវ ដែលត្រូវអនុវត្តចំពោះប្រតិបត្តិការស្តារអណ្តូងឡើងវិញ

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



ហ

- សកម្មភាពសាងសង់និងជួសជុលអណ្តូង
- ការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសំណង់អណ្តូង
- វិធីសាស្ត្រនៃការសាងសង់អណ្តូងនិងការកំណត់ប្រភពទឹកក្រោមដី
- វិធានការនិងការប្រុងប្រយ័ត្នជាមុន ដែលត្រូវអនុវត្តមុនពេល និងក្នុងកំលុងពេលនៃការសាងសង់ និងការកែលម្អអណ្តូង
- គោរពតាមការថែរក្សានានាសម្រាប់អណ្តូង ដែលមិនដំណើរការ
- ជួសជុលនិងថែទាំអណ្តូងមិនដំណើរការ
- ការថែទាំនិងធ្វើប្រតិបត្តិជួសជុលអណ្តូងជាប្រចាំ។

ឋ- ការកំណត់បន្ទុកសេវានិងថ្លៃចំណាយនានាសម្រាប់ការគ្រប់គ្រងធនធានទឹក និងការទូទាត់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី២
## ការសម្របសម្រួលរបស់រាជរដ្ឋាភិបាល

**មាត្រា៤៤៨ ._** គណៈកម្មាធិការជាតិគ្រប់គ្រងនិងរៀបចំផែនការអាងទន្លេ

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងគណៈកម្មាធិការជាតិទន្លេមេគង្គត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងរៀបចំផែនការអាងទន្លេ។

២- តួនាទីនិងភារកិច្ចរបស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងរៀបចំផែនការអាងទន្លេត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី៣
## ការរៀបចំផែនការធនធានទឹក

**មាត្រា៤៤៩ ._** ផែនការយុទ្ធសាស្ត្រជាតិធនធានទឹកនិងផែនការធនធានទឹកអាងទន្លេ

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវរៀបចំផែនការសម្រាប់ការបែងចែកនិងការគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព ដើម្បីបំពេញតាមតម្រូវការទឹកក្នុងពេលអនាគតតាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹកនិងផែនការធនធានទឹកអាងទន្លេ។

**មាត្រា៤៥០ ._** ការចូលរួមរបស់ភាគីពាក់ព័ន្ធ

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិធនធានទឹក និងផែនការធនធានទឹកអាងទន្លេ។

**មាត្រា៤៥១ ._** ការធ្វើប្រតិភូកម្មអំណាច

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក អាចធ្វើប្រតិភូកម្មអំណាចឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងនិងរៀបចំផែនការអាងទន្លេ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីធនធានទឹក និងផែនការធនធានទឹកអាងទន្លេ។

**មាត្រា៤៥២ ._** ការរៀបចំនិងអនុវត្តផែនការធនធានទឹកអាងទន្លេ

អាជ្ញាធរអាងទន្លេដែលទទួលបន្ទុកក្នុងការរៀបចំនិងអនុវត្តផែនការធនធានទឹកអាងទន្លេត្រូវអនុវត្តតាមគោលការណ៍នៃមាតិកានេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៥៣ ._ ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវប្រមូលយក រក្សាទុក និងប្រើប្រាស់ព័ត៌មានសម្រាប់គោលបំណងនៃការរៀបចំផែនការដោយៈ

ក- ធ្វើការផ្ទៀងផ្ទាត់ជាប្រចាំនិងរក្សាទុកកំណត់ត្រាអំពីបរិមាណនិងគុណភាពទឹក។

ខ- ប្រមូលព័ត៌មានពីក្រសួងស្ថាប័នមានសមត្ថកិច្ច និងភាគីពាក់ព័ន្ធអំពីតម្រូវការទឹក និងព័ត៌មានស្ដីពីផលប៉ះពាល់នៃការគ្រប់គ្រងទឹកចំពោះប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ ធនធានជលផលទឹកសាប និងសមុទ្រ ដែលរងការគំរាមកំហែង។

គ- ប្រមូលព័ត៌មានអំពីការប្រើប្រាស់និងតម្រូវការទឹកនាពេលបច្ចុប្បន្ននិងអនាគត។

ឃ- ធ្វើការកែលម្អជាប្រចាំចំពោះបណ្ដាញជាតិសម្រាប់ការអង្កេតតាមដាន ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធ។

**មាត្រា៤៥៤ ._ ក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវបង្កើតក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេស។

២- សមាសភាពនៃក្រុមប្រឹក្សាពិគ្រោះយោបល់បច្ចេកទេសត្រូវមានអ្នកជំនាញបច្ចេកទេស ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់។ គុណវុឌ្ឍិនៃអ្នកជំនាញបច្ចេកទេសត្រូវកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

៣- អ្នកជំនាញបច្ចេកទេសត្រូវធ្វើការផ្ដល់យោបល់លើៈ

ក- សេចក្ដីព្រាងផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹក និងសេចក្ដីព្រាងផែនការធនធានទឹកអាងទន្លេ។

ខ- វិសោធនកម្មឬបច្ចុប្បន្នកម្ម នៃផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹកនិងផែនការធនធានទឹកអាងទន្លេ។

គ- ការផ្ដល់សិទ្ធិអំណាចផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៤

## ផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹកនិងផែនការធនធានទឹកអាងទន្លេ

**មាត្រា៤៥៥ ._ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹក**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងភាគីពាក់ព័ន្ធដើម្បីរៀបចំផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹកដែលកំណត់អំពីៈ

ក- សន្តិសុខនៃការផ្គត់ផ្គង់ទឹករយៈពេលវែង។

ខ- និរន្តរភាពនៃធនធានទឹក។

គ- កិច្ចគាំពារប្រព័ន្ធអេកូឡូស៊ីដែលពឹងផ្អែកលើលំហូទឹក និងបរិស្ថាន។

ឃ- ការបែងចែកនិងប្រើប្រាស់ធនធានទឹកដោយប្រសិទ្ធភាពនិងសមធម៌ ដើម្បីទប់ស្កាត់ហានិភ័យគ្រោះមហន្តរាយ និងវិបត្តិ។

២- លក្ខខណ្ឌតម្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្ដីពីធនធានទឹកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៥៦ ._ ផែនការធនធានទឹកអាងទន្លេ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវរៀបចំផែនការធនធានទឹកអាងទន្លេដើម្បីៈ

ក- ភាពអាចស្វែងរកបានទឹកសម្រាប់គោលបំណងនីមួយៗ។

ខ- ផ្តល់ក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រងនិងប្រើប្រាស់ទឹកដោយនិរន្តរភាព។

គ- កំណត់អាទិភាពនិងយន្តការសម្រាប់ដោះស្រាយតម្រូវការទឹកនាពេលអនាគត។

ឃ- ផ្តល់ក្របខ័ណ្ឌសម្រាប់បង្កើតការបែងចែកទឹក។

ង- ផ្តល់ក្របខ័ណ្ឌសម្រាប់ការបែងចែកទឹក។

ច- ផ្តល់ក្របខ័ណ្ឌសម្រាប់ស្តារឡើងវិញតំបន់ដែលទទួលរងការហូតហែងឬខូចខាត ដែលកើតឡើងពីការបំផ្លាញនៅក្នុងប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើមឬទន្លេដែលនាំឱ្យបាត់បង់ធនធានទឹក។

ឆ- កំណត់សិទ្ធិទទួលបានធនធានទឹក។

២- លក្ខខណ្ឌតម្រូវ បែបបទ និងនីតិវិធីក្នុងការរៀបចំផែនការធនធានទឹកអាងទន្លេ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

**មាត្រា៤៥៧ ._ ការប្រកាសផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន**

ការអភិវឌ្ឍនៅក្នុងតំបន់ទីជម្រាលនៃអាងទន្លេត្រូវផ្អាកជាបណ្តោះអាសន្ន ក្នុងករណីមានការជូនដំណឹងអំពីការរៀបចំផែនការធនធានទឹកអាងទន្លេដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។ ការផ្អាកជាបណ្តោះអាសន្នត្រូវមានសុពលភាពរហូតដល់ពេលដែល៖

ក- ផែនការធនធានទឹកទទួលការឯកភាព។

ខ- មានការជូនដំណឹងអំពីការលុបចោល និងកែប្រែការរៀបចំផែនការធនធានទឹកអាងទន្លេ ដីសើម និងតំបន់ទីជម្រាលវិញ។

**មាត្រា៤៥៨ ._ វិធាននៃការផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន**

១- ក្នុងករណីការអភិវឌ្ឍត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងមាត្រា៤៥៧(ការប្រកាសផ្អាកការអភិវឌ្ឍជាបណ្តោះអាសន្ន)នៃក្រមនេះ៖

ក- រាល់គម្រោងស្នើសុំអភិវឌ្ឍទាំងឡាយនឹងមិនត្រូវបានយកមកគិតពិចារណាឡើយ ដរាបណាផែនការធនធានទឹកមិនទាន់ទទួលការឯកភាពឬមិនទាន់មានការជូនដំណឹងអំពីការលុបចោល និងកែប្រែការរៀបចំផែនការធនធានទឹកអាងទន្លេ ដីសើម និងតំបន់ទីជម្រាលវិញ។

ខ- មិនអនុញ្ញាតឱ្យមានដំណើរការអភិវឌ្ឍឡើយ នៅក្នុងករណីដែលការអនុញ្ញាតនោះអាចបង្កផលប៉ះពាល់ដូចខាងក្រោម៖

- កំណើនបរិមាណទឹកដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរទីតាំងដែលត្រូវយកទឹកមកប្រើប្រាស់
- កំណើនអត្រាទឹកដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះលក្ខខណ្ឌលំហូរទឹកដែលត្រូវយកមកប្រើប្រាស់
- ការផ្លាស់ប្តូរចំពោះគោលដៅនៃការយកទឹកមកប្រើប្រាស់។

២- ការងារថ្មីមិនត្រូវអនុញ្ញាតឱ្យចាប់ផ្តើមដំណើរការឡើយនៅក្នុងតំបន់ហាមឃាត់ជាបណ្តោះអាសន្ន។

៣- ការងារដែលបានចាប់ផ្តើមដំណើរការរួចហើយអាចអនុញ្ញាតឱ្យដំណើរការរហូតដល់បញ្ចប់ ប៉ុន្តែត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងត្រូវគោរពតាមកាលបរិច្ឆេទនៃការបញ្ចប់ និងលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

៤- ការងារបញ្ចប់រួចហើយ មិនត្រូវពង្រីកបន្ថែមឬផ្លាស់ប្តូរឡើយ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៥៩ ._ សុពលភាពនៃផែនការធនធានទឹកអាងទន្លេ**

ផែនការធនធានទឹកអាងទន្លេនៃអាងទន្លេមួយ មានសុពលភាពបានតែចំពោះផែនការធនធានទឹកអាងទន្លេនៃអាងទន្លេតែមួយនោះប៉ុណ្ណោះ លើកលែងមានការរៀបចំផែនការដាច់ដោយឡែកសម្រាប់ធនធានទឹកលើដី និងទឹកក្រោមដី។

**មាត្រា៤៦០ ._ ការដាក់ឱ្យអនុវត្តផែនការធនធានទឹកអាងទន្លេ**

ផែនការធនធានទឹកអាងទន្លេដែលបានរៀបចំរួច ត្រូវដាក់សុំការឯកភាពពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាមុននឹងដាក់ឱ្យអនុវត្ត។

## ផ្នែកទី៥

## សិទ្ធិ ការអនុញ្ញាត និងការហាមឃាត់ក្នុងការប្រើប្រាស់ធនធានទឹក

**មាត្រា៤៦១ ._ សិទ្ធិប្រើប្រាស់ធនធានទឹក**

បុគ្គលមានសិទ្ធិប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាតចំពោះចំណុចដូចខាងក្រោម៖

ក- តម្រូវការចាំបាច់របស់មនុស្សជាមូលដ្ឋាន មានជាអាទិ៍ ការហូបចុក របោកគក់ ការងូតទឹក អនាម័យ ការស្រោចស្រពសួនច្បារ និងផឹកគោលបំណងជាលក្ខណៈគ្រួសារដទៃទៀត។

ខ- ការពន្លត់អគ្គិភ័យនិងគោលបំណងនៃការសង្គ្រោះបន្ទាន់ដទៃទៀត។

**មាត្រា៤៦២ ._ កិច្ចគាំពារសិទ្ធិស្របច្បាប់របស់បុគ្គលដទៃ**

ការយកនិងការប្រើប្រាស់ធនធានទឹកមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្របច្បាប់របស់បុគ្គលដទៃឡើយ។

**មាត្រា៤៦៣ ._ សកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត**

១- រាល់សកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកនិងក្រសួងស្ថាប័នពាក់ព័ន្ធ។

២- ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក និងក្រសួងស្ថាប័នពាក់ព័ន្ធសកម្មភាពដូចខាងក្រោមនេះត្រូវបានអនុញ្ញាត៖

ក- ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកទឹកមិនស្របតាមគោលបំណងមាត្រា៤៦១(សិទ្ធិប្រើប្រាស់ធនធានទឹក) និងមាត្រា៤៦២(កិច្ចគាំពារសិទ្ធិស្របច្បាប់របស់បុគ្គលដទៃ)នៃក្រមនេះ។

ខ- ការសាងសង់ឬប្រតិបត្តិការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដែលនាំឱ្យមានការប្រើប្រាស់ ការបង្វែរទឹក និងការយកទឹកមិនស្របតាមគោលបំណងមាត្រា៤៦១(សិទ្ធិប្រើប្រាស់ធនធានទឹក) និងមាត្រា៤៦២(កិច្ចគាំពារសិទ្ធិស្របច្បាប់របស់បុគ្គលដទៃ)នៃក្រមនេះ។

គ- ការទាញយកខ្សាច់ ដី ថ្ម ក្រួស រ៉ែ ប្រេងកាត និងឧស្ម័ន ពីបាត ច្រាំងឬឆ្នេរសមុទ្រ ទន្លេ ស្ទឹង ព្រែក អូរ បឹងបួ។

ឃ- ការលុប ការរៀបចំប្រព័ន្ធលំហូរទឹក ការជីកប្រឡាយ ការបង្វែរទឹកនៃទន្លេ ស្ទឹង ព្រែក អូរ បឹងបួ ប្រឡាយ អាងទឹក ប្រភពទឹកស្អាត និងអាងទឹកធម្មជាតិ។

**មាត្រា៤៦៤ ._ កម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកអាចរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីកម្រិតនៃការប្រើប្រាស់ ការបង្វែរទឹក និងការយកធនធានទឹក។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៤៦៥ .– ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាតលើការប្រើប្រាស់ធនធានទឹក**

ការផ្តល់ការឯកភាពលើការស្នើសុំលិខិតអនុញ្ញាតលើការប្រើប្រាស់ធនធានទឹក ត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានាដែលកំណត់ដោយក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤៦៦ .– ការចេញលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ត្រូវចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនៃការប្រើប្រាស់ធនធានទឹក ស្របតាមផែនការធនធានទឹកអាងទន្លេ។

២- លក្ខខណ្ឌតម្រូវ បែបបទ និងនីតិវិធីក្នុងការចេញលិខិតអនុញ្ញាតពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនៃការប្រើប្រាស់ធនធានទឹក ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៦៧ .– បញ្ជីសិទ្ធិទទួលបានទឹក**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវរក្សាទុកនូវបញ្ជីសិទ្ធិទទួលបានទឹក ដែលអាចដាក់ឱ្យសាធារណជនអាចស្វែងរកបាន។

**មាត្រា៤៦៨ .– លក្ខខណ្ឌសម្រាប់សិទ្ធិទទួលបានទឹក**

ការប្រើប្រាស់ទឹក ការបង្វែរទឹក និងការយកធនធានទឹកត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌសម្រាប់សិទ្ធិទទួលបានទឹក ដែលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៦៩ .– សិទ្ធិស្របច្បាប់ក្នុងការទទួលបានទឹក**

១- ម្ចាស់កម្មសិទ្ធិដីឬអ្នកកាន់កាប់ដីអាចដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដើម្បីយកទឹកមកប្រើប្រាស់ពី៖

- ក- ប្រភពទឹកនានា បឹងបួ ឬប្រភពទឹកក្រោមដី ដែលស្ថិតនៅលើឬនៅជាប់ដីណាមួយ។
- ខ- អាងទឹកក្រោមដី។
- គ- លំហូរទឹកកាត់តាមដី។
- ឃ- ហេដ្ឋារចនាសម្ព័ន្ធ ដែលអនុវត្តតាមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ផ្គត់ផ្គង់ទឹកដល់ដីដែលពាក់ព័ន្ធ។

២- លក្ខខណ្ឌតម្រូវ បែបបទ និងនីតិវិធីនៃការដាក់ពាក្យស្នើសុំសិទ្ធិទទួលបានទឹកត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៧០ .– អញ្ញត្រកម្មសម្រាប់លំហូរបរិស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវធានាឱ្យមានការបែងចែកទឹកឱ្យបានគ្រប់គ្រាន់ក្នុងកម្រិតអតិបរមា សម្រាប់លំហូរបរិស្ថាន ដើម្បីធ្វើឱ្យមានលំនឹងមុខងារប្រព័ន្ធអេកូឡូស៊ី។

**មាត្រា៤៧១ .– ការប្រកាសអំពីសិទ្ធិទទួលបានទឹក**

មុនការិយបរិច្ឆេទដលសាស្ត្រនីមួយៗ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវប្រកាសអំពីសិទ្ធិទទួលបានទឹកសម្រាប់ឆ្នាំបន្ទាប់ស្របតាមប្រភេទអាទិភាព និងវិធាននៃការបែងចែងទឹកដែលកំណត់នៅក្នុងផែនការធនធានទឹកអាងទន្លេ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL



ᥔ

**មាត្រា៤៧២ .- ការកែសម្រួលទៅលើបរិមាណជាផ្លូវការ**

១- បរិមាណជាផ្លូវការក្នុងការបែងចែកទឹកនិងលក្ខខណ្ឌផ្សេងទៀតអាចត្រូវធ្វើការកែសម្រួលនៅចុងបញ្ចប់នៃការអនុវត្តផែនការធនធានទឹកអាងទន្លេ។

២- ការកែសម្រួលទៅលើបរិមាណជាផ្លូវការក្នុងការបែងចែកទឹកនិងលក្ខខណ្ឌផ្សេងទៀតខាងលើនេះមិនមានការសងសំណងការខូចខាតនោះទេ។

**មាត្រា៤៧៣ .- ការព្រមព្រៀងផ្គត់ផ្គង់ទឹកស្របតាមការអនុញ្ញាតសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ**

ក្នុងករណីមានការអនុញ្ញាតឱ្យប្រើប្រាស់ធនធានទឹកសម្រាប់ផ្គត់ផ្គង់លើហេដ្ឋារចនាសម្ព័ន្ធ ដែលកំពុងធ្វើប្រតិបត្តិការនៅក្រោមលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ អ្នកកាន់កាប់លិខិតអនុញ្ញាតប្រើប្រាស់ធនធានទឹក និងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធត្រូវចុះកិច្ចព្រមព្រៀងផ្គត់ផ្គង់ធនធានទឹកជាមួយគ្នា លើកលែងតែភាគីទាំងពីរជានីតិបុគ្គលតែមួយ។

**មាត្រា៤៧៤ .- កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកត្រូវរៀបចំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកសម្រាប់ការរក្សាទុក និង/ឬការចែកចាយទឹកដល់អ្នកកាន់អាជ្ញាបណ្ណទឹក និងលិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធស្របតាមបញ្ញត្តិស្តីពីសិទ្ធិទទួលបានទឹក។

២- កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក អាចមានលក្ខណៈខុសគ្នាពីទីតាំងមួយទៅទីតាំងមួយ។

**មាត្រា៤៧៥ .- ពាក្យសុំកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹក**

កិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកសម្រាប់ទីតាំងចំពោះសិទ្ធិទទួលបានទឹក ត្រូវអនុវត្តស្របតាមសិទ្ធិទទួលបានទឹក លើកលែងតែមានកិច្ចព្រមព្រៀងស្តង់ដារផ្គត់ផ្គង់ទឹកដែលបាន៖

ក- យល់ស្របរវាងអ្នកកាន់លិខិតអនុញ្ញាតហេដ្ឋារចនាសម្ព័ន្ធ និងអ្នកកាន់សិទ្ធិទទួលបានទឹក។

ខ- ដាក់បញ្ជូនទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៧៦ .- ការដាក់ពាក្យសុំអាជ្ញាបណ្ណទឹកឬលិខិតអនុញ្ញាត**

១- បុគ្គលអាចដាក់ពាក្យសុំអាជ្ញាបណ្ណទឹកឬលិខិតអនុញ្ញាតទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ដើម្បីធ្វើសកម្មភាពដូចខាងក្រោម៖

ក- ជីកផ្លូវទឹក បឹង ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក។

ខ- ចាក់បំពេញលុបផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក។

គ- អ្នកសាងសង់អណ្តូង។

ឃ- អ្នកតំឡើងម៉ាស៊ីនបូមទឹកក្រោមដី។

២- លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការដាក់ពាក្យស្នើសុំឬដកហូតអាជ្ញាបណ្ណទឹក លិខិតអនុញ្ញាត និងវិញ្ញាបនបត្រត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៧៧ .- ភស្តុតាងនៃអាជ្ញាបណ្ណទឹក លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ**

នៅពេលចុះធ្វើអធិការកិច្ច មន្ត្រីមានសមត្ថកិច្ចអាចតម្រូវឱ្យបុគ្គលបង្ហាញអាជ្ញាបណ្ណទឹក លិខិតអនុញ្ញាត និងវិញ្ញាបនបត្រក្នុងករណីមានការសង្ស័យដូចខាងក្រោម៖

ក- ការសាងសង់ ការធ្វើឱ្យជ្រៅ ការពង្រីក ឬការដាក់បំពង់ទប់ដីក្នុងប្រតិបត្តិការសាងសង់អណ្តូងស្នប់។

ខ- ការដកចេញ ការដាក់ជំនួស ការប្តូរ ឬការជួសជុលបំពង់ទប់ដី និងបំពង់ហ្វីលក្នុងប្រតិបត្តិការសាងសង់អណ្តូងស្នប់។

គ- ការបញ្ឈប់ដំណើរការនៃការសាងសង់អណ្តូងខួង។

ឃ- ការដំឡើង ការដាក់ជំនួស ការប្តូរឬការដកចេញម៉ូទ័របូមទឹកពីអណ្តូងស្នប់។

**មាត្រា៤៧៨ ._ លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍**

១- បុគ្គលដែលធ្វើការទាក់ទងនឹងអណ្តូងខួង សម្រាប់គោលបំណងមុខរបរឬអាជីវកម្មត្រូវរៀបចំរបាយការណ៍ទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

២- ព័ត៌មានលម្អិតសម្រាប់ដាក់បញ្ចូលក្នុងរបាយការណ៍ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៧៩ ._ កំណត់ត្រាសកម្មភាព**

១- អ្នកកាន់អាជ្ញាបណ្ណទឹក លិខិតអនុញ្ញាត និងវិញ្ញាបនបត្រត្រូវរក្សាទុកព័ត៌មានអំពីសកម្មភាពដែលបានអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- អ្នកកាន់អាជ្ញាបណ្ណទឹក លិខិតអនុញ្ញាត និងវិញ្ញាបនបត្រត្រូវផ្តល់ព័ត៌មានដូចមានចែងក្នុងកថាខណ្ឌខាងលើ ទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក ក្នុងករណីមានការស្នើសុំ។

**មាត្រា៤៨០ ._ ការអនុញ្ញាតចំពោះការផ្គត់ផ្គង់និងប្រើប្រាស់ទឹក**

បុគ្គលមិនត្រូវអនុញ្ញាតឱ្យផ្គត់ផ្គង់ ឬប្រើប្រាស់ទឹកលើកលែងតែទទួលបានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៤៨១ ._ ការរំលោភបំពានទៅលើលិខិតអនុញ្ញាត**

អ្នកកាន់លិខិតអនុញ្ញាតមិនត្រូវបំពានទៅលើលក្ខខណ្ឌដូចបានកំណត់នៅក្នុងលិខិតអនុញ្ញាត។

**មាត្រា៤៨២ ._ សិទ្ធិចេញចូលបរិវេណដីឯកជនរបស់មន្ត្រីមានសមត្ថកិច្ច**

មន្ត្រីមានសមត្ថកិច្ចនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក មានសិទ្ធិចេញចូលដីឯកជនរបស់ម្ចាស់កម្មសិទ្ធិដីឬអ្នកកាន់កាប់ដីឯកជន ដើម្បីបំពេញភារកិច្ចក្នុងការធ្វើការសិក្សាផ្នែកបច្ចេកទេស ការវាយតម្លៃ ឬការអង្កេតតាមដាន លើកលែងតែ៖

ក- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹកមិនបានជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនដល់ម្ចាស់កម្មសិទ្ធិដីឬអ្នកកាន់កាប់ដីឯកជន។

ខ- មន្ត្រីមានសមត្ថកិច្ចមិនបានផ្តល់ភស្តុតាងអំពីអត្តសញ្ញាណនិងពុំមានលិខិតអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានទឹក។

**មាត្រា៤៨៣ ._ ករណីលើកលែងចំពោះសិទ្ធិទទួលបានទឹក**

បុគ្គលមានសិទ្ធិប្រើប្រាស់ធនធានទឹក ដោយពុំចាំបាច់មានលិខិតអនុញ្ញាតចំពោះសកម្មភាពដូចខាងក្រោម៖

ក- ការស្រោចស្រពដីនៃតំបន់ទាំងមូលដែលតិចជាង១០(ដប់)ហិកតា។

ខ- ការផ្គត់ផ្គង់ទឹកស្អាត ដែលប្រើប្រាស់ទឹកតិចជាង៤០(សែសិប)ម៉ែត្រគូបក្នុងមួយថ្ងៃ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គ- ថាមពលវារីអគ្គិសនីដើរដោយលំហូរទឹកទន្លេឬបរច្ចកទេសថាមពលវារីអគ្គិសនី ដែលមិនតម្រូវឱ្យមានការបង្ខាំង ការបង្វែរ ឬការទាញយកទឹកមកប្រើ។

**មាត្រា៤៨៤ ._ ការកំណត់អំពីច្រាំងទន្លេឬឆ្នេរសមុទ្រ**

ការកំណត់អំពីច្រាំងទន្លេ និងឆ្នេរសមុទ្រ និងសមាសភាគនៃអាងទន្លេត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៤៨៥ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវគ្រប់គ្រង ការពារ អភិរក្ស និងត្រួតពិនិត្យធនធានព្រៃឈើប្រកបដោយនិរន្តរភាពក្នុងតំបន់ការពារធម្មជាតិ។

២- ការគ្រប់គ្រងធនធានព្រៃឈើ ធនធានសត្វព្រៃ និងដីព្រៃឈើនៅក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យព្រៃឈើ។

**មាត្រា៤៨៦ ._ តួនាទីនិងភារកិច្ច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្ត និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី។

ខ- គ្រប់គ្រង ការពារ អភិរក្ស និងត្រួតពិនិត្យធនធានព្រៃឈើប្រកបដោយនិរន្តរភាព ដោយមានជាអាទិ៍ការរៀបចំផែនការប្រើប្រាស់ប្រភពថាមពលពីព្រៃឈើប្រកបដោយនិរន្តរភាព ការផ្តល់លិខិតអនុញ្ញាតការគ្រប់គ្រង និងការត្រួតពិនិត្យគោលការណ៍បច្ចេកទេសព្រៃឈើប្រកបដោយនិរន្តរភាព។

គ- សិក្សានិងប្រមូលទិន្នន័យព្រៃឈើទាក់ទងនឹងគោលដៅវិទ្យាសាស្ត្រ សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដើម្បីបង្កើតម៉ាទ្រីកនិងបមាណីយ និងបង្កើតផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

ឃ- ធ្វើការវាយតម្លៃពេញលេញ និងទាន់ពេលវេលាសម្រាប់ធនធានព្រៃឈើទាំងអស់ និងការអភិវឌ្ឍផ្សេងៗទាក់ទងនឹងសកម្មភាពដែលអាចមានផលប៉ះពាល់បរិស្ថាន និងសង្គមមុននឹងផ្តល់ការឯកភាពទៅលើសកម្មភាពទាំងនោះ។

ង- រៀបចំសំណើសម្រាប់ការបង្កើត ការផ្លាស់ប្តូរ និងការលុបក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន និងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

ច- លើកកម្ពស់ការអប់រំនិងការផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការគ្រប់គ្រង ការថែរក្សា និងកិច្ចគាំពារធនធានព្រៃឈើដល់សាធារណជន ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការអភិរក្ស និងកិច្ចគាំពារធនធានធម្មជាតិក្នុងតំបន់ព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឆ- ស្តារនូវប្រព័ន្ធអេកូឡូស៊ីដីព្រៃតាមរយៈការដាំដើមឈើ ដែលកំពុងរងការគំរាមកំហែងដើម្បីលើកកម្ពស់ និងសម្រេចបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ។

ជ- កំណត់ន័យច្បាស់លាស់ នៃស្ថានភាពស្របច្បាប់នៃដីទាំងអស់ដែលត្រូវបានចាត់ជាដីព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាព។

ឈ- កំណត់ព្រំប្រទល់ដែនព្រៃឈើនិងចុះបញ្ជីដីព្រៃឈើ វិភាគ រក្សាទុកទិន្នន័យ និងធ្វើបច្ចុប្បន្នកម្មទិន្នន័យសម្រាប់ប្រើប្រាស់ ដើម្បីធ្វើការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

ញ- បង្កើតនិងអនុវត្តវិធានការដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ចដទៃទៀត ដើម្បីការពារព្រៃឈើជាលក្ខណៈប្រព័ន្ធពីការប្រើប្រាស់ធនធានព្រៃឈើដែលគ្មានការអនុញ្ញាត ឬការតាំងទីលំនៅមិនស្របច្បាប់ និងសកម្មភាពមិនស្របច្បាប់ដទៃទៀត។

ដ- ធ្វើការពិគ្រោះយោបល់លើគម្រោងស្ថាបនាផ្លូវសាធារណៈនៅក្នុងតំបន់ព្រៃឈើ។

ឋ- ផ្សព្វផ្សាយជាសាធារណៈនិងអនុវត្តប្រកបដោយតម្លាភាពនៅគ្រប់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

ឌ- ចូលរួមនៅក្នុងកម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រងនិងផលិតផលព្រៃឈើអន្តរជាតិ។

ឍ- សហការជាមួយក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋានដើម្បីពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

ណ- ធ្វើការស៊ើបអង្កេត ស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាប កសាងសំណុំរឿង និងធ្វើជាអង្គភាពដើមបណ្តឹងនៅចំពោះមុខតុលាការមានសមត្ថកិច្ច។

ត- ពង្រឹងសមត្ថភាពក្នុងការឆ្លើយតបឱ្យទាន់ពេលវេលាចំពោះបទល្មើសព្រៃឈើ។

ថ- ចងក្រង គ្រប់គ្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យធនធានព្រៃឈើ។

២- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៨៧ ._ ភារកិច្ចក្នុងការអភិរក្សនិងស្តារព្រៃឈើឡើងវិញ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើឱ្យប្រសើរឡើងវិញនូវកិច្ចគាំពារ ការអភិរក្ស ការស្តារឡើងវិញនូវតម្លៃបរិស្ថានធម្មជាតិ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ីស្ថិតក្នុងតំបន់ព្រៃឈើ ដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពដោយត្រូវការជួសជុលនិងកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានចំពោះ៖

ក- ព្រៃឈើដែលមានផលប៉ះពាល់តំបន់ទីជម្រាល។

ខ- គុណភាពបរិស្ថានដី ទឹក និងខ្យល់។

គ- គុណភាពអេកូឡូស៊ីនិងប្រព័ន្ធអេកូឡូស៊ី។

**មាត្រា៤៨៨ ._ ភារកិច្ចផ្សេងទៀត**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានា៖

ក- ផលឈើត្រូវបានប្រមូលត្រឹមកម្រិតឬក្រោមកម្រិតដែលមាននិរន្តរភាព។

ខ- ការកែច្នៃ សេវា និងតម្លៃបន្ថែមពាក់ព័ន្ធផលឈើត្រូវបានប្រើប្រាស់នៅទីតាំងដែលបានអនុញ្ញាត។

គ- ការចូលរួមក្នុងកម្មវិធីផលិតផលព្រៃឈើអន្តរជាតិនិងវិញ្ញាបនបត្រគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ដែលមានការគាំទ្រពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ។

ឃ- ការអនុវត្តនីតិវិធីរក្សាភស្តុតាងត្រូវបានអនុវត្តសម្រាប់ផលិតផលដែលមិនត្រូវបានប្រើប្រាស់ក្នុងស្រុក។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ផ្នែកទី២
## ការធ្វើចំណាត់ថ្នាក់ព្រៃឈើ

**មាត្រា៤៨៩ ._ ព្រៃឈើ**

ព្រៃឈើគ្រប់ប្រភេទដែលជាសមាសភាគនៃធនធានធម្មជាតិត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែមានបញ្ញត្តិពិសេសក្នុងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៤៩០ ._ ការធ្វើចំណាត់ថ្នាក់ព្រៃឈើ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់អត្តសញ្ញាណ ធ្វើចំណាត់ថ្នាក់និងធ្វើផែនទីព្រៃឈើស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ការធ្វើចំណាត់ថ្នាក់ព្រៃឈើត្រូវផ្អែកលើទិន្នន័យបច្ចុប្បន្នកម្មផែនទី ការវាយតម្លៃវិទ្យាសាស្ត្រដូចខាងក្រោម៖

ក- មុខងារអេកូឡូស៊ីព្រៃឈើ សេដ្ឋកិច្ច និងសង្គម។

ខ- ភាពសម្បូរបែបនៃព្រៃឈើ។

គ- មុខងារនិងសារៈសំខាន់នៃតំបន់។

ឃ- តំបន់សក្ដានុពលសន្និធិកាបូនព្រៃឈើនិងទិសដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ពីការកាប់បំផ្លាញព្រៃឈើ ការរេចរឹលព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ការអភិរក្ស ការធ្វើឱ្យប្រសើរឡើងសន្និធិកាបូនព្រៃឈើតាមរយៈកម្មវិធីរេដបូក និងកម្មវិធីផ្សេងៗទៀត។

ង- តំបន់សក្ដានុពលសម្រាប់រក្សាប្រភពទឹកនិងទីជម្រាល។

ច- ការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន។

ឆ- លក្ខខណ្ឌពាក់ព័ន្ធផ្សេងទៀតត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត។

៣- ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព ត្រូវបានធ្វើចំណាត់ថ្នាក់ជាព្រៃឯកជន ព្រៃផ្ដល់ផលប្រកបដោយនិរន្តរភាព ព្រៃស្ដារឡើងវិញ ព្រៃបម្រុងទុក និងសម្បទានដីសេដ្ឋកិច្ច៖

ក- ព្រៃឯកជន៖ ជាប្រភេទដីព្រៃឈើទាំងឡាយណាស្ថិតនៅលើដីជាកម្មសិទ្ធិរបស់បុគ្គលឯកជន។

ខ- ព្រៃផ្ដល់ផលប្រកបដោយនិរន្តរភាព៖ ជាប្រភេទដីព្រៃឈើទាំងឡាយណាស្ថិតលើដីសាធារណៈរបស់រដ្ឋមានជាអាទិ៍ ចម្ការព្រៃជាំ ចម្ការពូជ សហគមន៍តំបន់ការពារធម្មជាតិ ព្រៃគុប ព្រៃសម្បទាន និងដីព្រៃទាំងឡាយដែលអាចធ្វើការដាំដុះព្រៃឈើបាន។

គ- ព្រៃស្ដារឡើងវិញ៖ ជាប្រភេទដីព្រៃឈើទាំងឡាយណាស្ថិតលើដីសាធារណៈរបស់រដ្ឋ និងជាដីព្រៃបាត់បង់ និងរេចរឹលព្រៃឈើ និងដីដាំស្ដារព្រៃឈើឡើងវិញដែលបង្កើតគម្របព្រៃឈើដោយធម្មជាតិ ឬសិប្បនិម្មិត។

ឃ- ព្រៃបម្រុងទុក៖ ជាប្រភេទដីព្រៃឈើទាំងឡាយណាស្ថិតលើដីសាធារណៈរបស់រដ្ឋ ដែលការពារប្រព័ន្ធមជ្ឈដ្ឋាន និងធនធានធម្មជាតិ មានជាអាទិ៍៖

- ព្រៃជម្រកជីវៈចម្រុះ
- ព្រៃសម្រាប់សិក្សាស្រាវជ្រាវ
- ព្រៃការពារតំបន់ទីជម្រាលនិងប្រភពទឹក
- សួនរុក្ខគាមសាស្ត្រ
- ព្រៃកីឡាប្រមាញ់
- ព្រៃជំនឿសាសនា
- ផ្ទៃដីព្រៃបម្រុងទុកសម្រាប់ការអភិរក្សនាពេលអនាគត។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★



៤៥

៤- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចបង្កើតចំណាត់ថ្នាក់ព្រៃឈើបន្ថែមសម្រាប់ព្រៃដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព មានជាអាទិ៍ ព្រៃលម្ហែកម្សាន្ត ព្រៃសហគមន៍ផ្តល់ផល ព្រៃពិសោធន៍ និងព្រៃស្តារឡើងវិញ។ ចំណាត់ថ្នាក់ព្រៃឈើបន្ថែមត្រូវទទួលការវាយតម្លៃស្របតាមគោលការណ៍និរន្តរភាព សារៈសំខាន់ផ្នែកសិក្សាស្រាវជ្រាវ និងគោលដៅនៃផែនការគ្រប់គ្រង។

**មាត្រា៤៩១ ._ ការផ្លាស់ប្តូរចំណាត់ថ្នាក់ព្រៃឈើ**

១- រាល់សំណើសុំធ្វើការកែប្រែចំណាត់ថ្នាក់ព្រៃឈើ ឬផ្នែកណាមួយនៃព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវមានលក្ខខណ្ឌតម្រូវ ដូចខាងក្រោម៖

ក- ហេតុផលវិទ្យាសាស្ត្រនិងសេដ្ឋកិច្ចសង្គមសម្រាប់ការកែប្រែចំណាត់ថ្នាក់។

ខ- កិច្ចប្រឹងប្រែងដែលធ្វើឡើងដើម្បីរក្សាស្ថានភាពនៃការធ្វើចំណាត់ថ្នាក់នាពេលថ្មីៗ។

គ- លក្ខណៈនៃការកែប្រែចំណាត់ថ្នាក់ត្រូវលើកស្ទួយជីវភាពរស់នៅនិងសិទ្ធិជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន។

ឃ- លទ្ធផលរំពឹងទុកនៃការកើនឡើងក្នុងតម្លៃអភិរក្សនិងប្រព័ន្ធអេកូឡូស៊ី ឬតាមមធ្យោបាយណាមួយដែលធ្វើឱ្យបាត់បង់តម្លៃអភិរក្ស និងប្រព័ន្ធអេកូឡូស៊ីត្រូវធ្វើការទូទាត់សងមកវិញនូវតម្លៃខូចខាតទាំងនោះ។

ង- ការពិគ្រោះយោបល់សមស្របជាមួយភាគីពាក់ព័ន្ធនិងសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់។

ច- ព័ត៌មានផ្សេងៗខាងលើត្រូវបានកែសម្រួលឱ្យស្របទៅតាមសំណើសុំ។

២- រាល់សំណើសុំកែប្រែ ការបែងចែកចំណាត់ថ្នាក់ព្រៃឈើ ឬផ្នែកណាមួយនៃព្រៃឈើដែលត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

៣- ការឯកភាពលើការកែសម្រួលចំណាត់ថ្នាក់ព្រៃឈើ ត្រូវទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៤៩២ ._ ការផលិតផែនទីសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព**

ការអនុវត្តសកម្មភាពគ្រប់គ្រងធនធានព្រៃឈើ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបន្ទុករៀបចំផលិតផែនទី ដូចខាងក្រោម៖

ក- ផែនទីវាយតម្លៃធនធានព្រៃឈើនិងបម្រែបម្រួលដីព្រៃឈើ។

ខ- ផែនទីចំណាត់ថ្នាក់ព្រៃឈើ។

គ- ផែនទីវាយតម្លៃសន្និធិកាបូនព្រៃឈើ។

ឃ- ផែនទីផ្ទៃរងទឹកភ្លៀង ទីជម្រាល និងចំណាត់ថ្នាក់ទីជម្រាល។

ង- ផែនទីវត្តមានទីជម្រកសត្វព្រៃនិងជីវៈចម្រុះងាយរងគ្រោះ។

ច- ផែនទីចម្ការឈើដាំនិងឈើពូជ។

ឆ- ផែនទីរោងសន្និធិនិងរោងចក្រកែច្នៃឈើ។

ជ- ផែនទីកសាងផ្លូវកាត់តំបន់ព្រៃឈើនិងផែនទីសក្តានុពលផ្សេងៗទៀត។

**មាត្រា៤៩៣ ._ ផែនទីប្រើប្រាស់ដីព្រៃឈើនិងការចុះបញ្ជី**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបន្ទុកដឹកនាំផលិតទិន្នន័យនិងផែនទីប្រើប្រាស់ដីព្រៃឈើសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

២- ដំណើរការនៃការដឹកនាំផលិតទិន្នន័យ និងផែនទីប្រើប្រាស់ដីព្រៃឈើសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពត្រូវធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងត្រូវសិក្សាវាយតម្លៃ និងកំណត់ព្រំប្រទល់ដែនព្រៃឈើ ដើម្បីចុះបញ្ជីដីព្រៃឈើជាតិ ដោយយោងតាមការបែងចែកចំណាត់ថ្នាក់និងផែនទីប្រើប្រាស់ដីព្រៃឈើ។

**មាត្រា៤៩៤ ._ ការគ្រប់គ្រងទិន្នន័យ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ទទួលបន្ទុកដឹកនាំ បង្កើត ប្រមូល ចងក្រងព័ត៌មាន ទិន្នន័យមូលដ្ឋាន ធនធានព្រៃឈើ និងរក្សាទុកទិន្នន័យទាំងនេះដើម្បីរៀបចំផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

## ផ្នែកទី៣
## ការរៀបចំផែនការប្រើប្រាស់និងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

**មាត្រា៤៩៥ ._ ការរៀបចំផែនការប្រើប្រាស់និងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាពរយៈពេល៥(ប្រាំ)ឆ្នាំ និងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពរយៈពេល៥(ប្រាំ)ឆ្នាំ ឬតាមការចាំបាច់។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំកិច្ចពិគ្រោះយោបល់ដោយឡែកនិងពិសេសសម្រាប់តំបន់ដែលមានសហគមន៍មូលដ្ឋានតាំងនៅ ឬដែលមានជាប់ពាក់ព័ន្ធនឹងផលប្រយោជន៍សហគមន៍មូលដ្ឋាន ដើម្បីបញ្ជាក់ថាមានការឱ្យតម្លៃចំពោះផលប្រយោជន៍និងសិទ្ធិជាលក្ខណៈប្រពៃណីនិងទំនៀមទម្លាប់។

**មាត្រា៤៩៦ ._ ផែនការប្រើប្រាស់ព្រៃឈើប្រកបដោយនិរន្តរភាព**

ផែនការប្រើប្រាស់ធនធានព្រៃឈើប្រកបដោយនិរន្តរភាពត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម៖

ក- ប្រភេទ បរិមាណ និងគុណភាពព្រៃឈើ ដោយផ្អែកលើទិន្នន័យធនធានព្រៃឈើ។

ខ- តម្លៃអេកូឡូស៊ីព្រៃឈើ។

គ- ទីតាំងរបស់សហគមន៍មូលដ្ឋាននិងតម្រូវការសម្រាប់ជីវភាពរស់នៅ។

ឃ- ផ្អែកខាងក្រៅនៃប្រតិបត្តិការវិជ្ជមាននិងអវិជ្ជមាន។

## ផ្នែកទី៤
## លិខិតអនុញ្ញាត

**មាត្រា៤៩៧ ._ សកម្មភាពពាក់ព័ន្ធ**

បុគ្គលដែលស្នើសុំធ្វើសកម្មភាពក្នុងតំបន់ព្រៃឈើ ដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

ក- ការដេកហូតផល អនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម។

ខ- ការគ្រប់គ្រងផល អនុផលព្រៃឈើ សម្រាប់ការប្រើប្រាស់ផ្នែកពាណិជ្ជកម្ម។

គ- ការប្រមូលផលនិងលក់ផល អនុផលព្រៃឈើសម្រាប់គោលបំណងពាណិជ្ជកម្ម។

ឃ- ការដឹកជញ្ជូនផល អនុផលព្រៃឈើ។

ង- ការនាំចេញផល អនុផលព្រៃឈើ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៣៥

ច- ការប្រើប្រាស់ព្រៃឈើដើម្បីស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រឬបច្ចេកទេស។

ឆ- ការបង្កើតទីតាំងរោងសន្និធិដើម្បីលក់និងចែកចាយផល អនុផលព្រៃឈើ។

ជ- ការបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ។

ឈ- ការបង្កើតឃ្លាំងដុតផ្សេងៗដែលប្រើប្រាស់វត្ថុធាតុដើមជាផល អនុផលព្រៃឈើ។

ញ- ផលិតធ្យូងនិងឈើអុស។

ដ- ការធ្វើសកម្មភាពផ្នែកពាណិជ្ជកម្មផ្សេងៗ ត្រូវស្របតាមបញ្ញត្តិនៃក្រមនេះ។

ឋ- សកម្មភាពពាណិជ្ជកម្មទាំងឡាយដែលមានទីតាំងស្ថិតនៅក្នុងព្រៃផ្តល់ផលដោយនិរន្តរភាពត្រូវមានលិខិតអនុញ្ញាតជាមុន។

**មាត្រា៤៩៨ .-** ការពិនិត្យលើពាក្យសុំលិខិតអនុញ្ញាត

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យពាក្យសុំលិខិតអនុញ្ញាតដោយគោរពលក្ខខណ្ឌដូចខាងក្រោម៖

ក- មានសង្គតិភាពជាមួយគោលបំណងអភិរក្សទេសភាពនៅជុំវិញ។

ខ- មានការគាំទ្រនិងជួយបង្កើនជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងតំបន់។

គ- មានការចូលរួមចំណែកក្នុងកិច្ចគាំពារតម្លៃជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

ឃ- មានសង្គតិភាពជាមួយផែនការប្រើប្រាស់ដីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងផែនការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

ង- អនុវត្តតាមគោលការណ៍ណែនាំនៅក្នុងដំណាក់កាលរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងបិទគម្រោងរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

ច- បំពេញលក្ខខណ្ឌផ្សេងៗទៀតតាមស្ថានភាពជាក់ស្តែង។

## ផ្នែកទី៥

## សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

**មាត្រា៤៩៩ .-** កាតព្វកិច្ចធានារបស់រដ្ឋ

រដ្ឋត្រូវទទួលស្គាល់និងធានានូវសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿ សាសនា និងការរស់នៅរបស់សហគមន៍មូលដ្ឋានដែលនៅក្នុង ឬក្បែរតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៥០០ .-** សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី

១- សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានសម្រាប់ផល អនុផលព្រៃឈើមិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ។

២- សិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី មានជាអាទិ៍៖

ក- ការរើសប្រមូលឈើងាប់ ការបេះផ្លែឈើព្រៃ ការប្រមូលទឹកឃ្មុំ ការចោះយកជ័រទឹក និងការប្រមូលអនុផលព្រៃឈើដទៃៗទៀត។

ខ- ការកាត់ស្មៅនិងការព្រលែងសត្វពាហនៈឱ្យស៊ីចំណី។

គ- ការប្រើប្រាស់ផល អនុផលព្រៃឈើឱ្យស្របតាមការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងប្រពៃណី។

ឃ- សិទ្ធិដោះដូរឬលក់អនុផលព្រៃឈើជាលក្ខណៈប្រពៃណីក្នុងសហគមន៍មូលដ្ឋាន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតនោះទេ។ បុគ្គលដែលមានបំណងធ្វើពាណិជ្ជកម្មអនុផលព្រៃឈើជាមួយសហគមន៍មូលដ្ឋានត្រូវមានលិខិតអនុញ្ញាតដូចមានចែងក្នុងមាត្រា៤៩៧(សកម្មភាពពាក់ព័ន្ធ)នៃក្រមនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



M5

## ផ្នែកទី៦

## ផែនការនិងរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រកបដោយនិរន្តរភាព

**មាត្រា៥០១ .– វិសាលភាពនៃផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ**

ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ ដែលបង្កើតឡើងសម្រាប់រាល់សកម្មភាពពាណិជ្ជកម្មព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវសមាមាត្រទៅនឹងទំហំ ដង់ស៊ីតេ និងហានិភ័យសកម្មភាពពាណិជ្ជកម្មទាំងនោះ។ ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើត្រូវអនុវត្តនិងធ្វើបច្ចុប្បន្នកម្មជាទៀងទាត់ ដោយផ្អែកលើព័ត៌មានអង្កេតត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។

**មាត្រា៥០២ .– ខ្លឹមសារនៃផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ**

ផែនការគ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រកបដោយនិរន្តរភាពត្រូវ៖

ក- កំណត់និយមន័យពាណិជ្ជកម្មព្រៃឈើនៃតំបន់ជាក់លាក់ ដោយអនុលោមតាមសកម្មភាពពាណិជ្ជកម្មដែលមានជាអាទិ៍ ការពិពណ៌នា និងទីតាំងនៃសកម្មភាពជាក់លាក់ដែលគ្រោងទុក។

ខ- កំណត់នូវគោលដៅ គោលបំណង និងលទ្ធផលនៃសកម្មភាពពាណិជ្ជកម្មទាក់ទងនឹងធនធានដែលត្រូវបានប្រើប្រាស់ និងលក្ខណវិនិច្ឆ័យ សង្គម និងចំណូល។

គ- កំណត់តួនាទីនិងការទទួលខុសត្រូវសម្រាប់ភាគីពាក់ព័ន្ធ។

ឃ- កំណត់កូតាសម្រាប់ការប្រមូលផល អនុផលព្រៃឈើ។

ង- កំណត់កាលបរិច្ឆេទនិងពេលវេលាសម្រាប់ការអនុវត្ត។

ច- កំណត់ផែនការថវិកា។

ឆ- កំណត់ការអនុវត្តការគ្រប់គ្រងឱ្យបានត្រឹមត្រូវ ដោយផ្អែកលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ជ- កំណត់ផែនការនៃការអនុវត្តវុឌ្ឍវប្បកម្ម។

ឈ- កំណត់នីតិវិធីសម្រាប់វិញ្ញាបនបត្រផលិតផលព្រៃឈើ ប្រសិនបើអាចអនុវត្តបាន។

ញ- កំណត់ការកែច្នៃនិងការដឹកជញ្ជូនផលិតផលព្រៃឈើ។

ដ- កំណត់វិធីសាស្ត្រ ការពិនិត្យតាមដាន និងវាយតម្លៃ និងការរៀបចំរបាយការណ៍។

**មាត្រា៥០៣ .– របាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើប្រចាំឆ្នាំដោយមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ។

២- ផែនការនិងរបាយការណ៍គ្រប់គ្រងពាណិជ្ជកម្មព្រៃឈើត្រូវដាក់ផ្សព្វផ្សាយជាសាធារណៈស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី៧

## ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ

**មាត្រា៥០៤ .– ការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ**

១- បុគ្គលដែលប្រមូលផល អនុផលព្រៃឈើ ក្នុងគោលបំណងពាណិជ្ជកម្មក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាពត្រូវបង់ថ្លៃសួយសារ និងបុព្វលាភព្រៃឈើទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- វិធានសម្រាប់ការវាយតម្លៃគុណភាពនិងបរិមាណត្រូវធ្វើការវាយតម្លៃមុននឹងធ្វើការដឹកជញ្ជូន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៥០៥ ._ ការបែងចែកថ្លៃសួយសារនិងបុព្វលាភព្រៃឈើ**

ការបែងចែកថ្លៃសួយសារនិងបុព្វលាភព្រៃឈើដែលប្រមូលបាន ត្រូវអនុវត្តស្របតាមប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥០៦ ._ លក្ខខណ្ឌលើកលែងការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ**

ការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ ត្រូវបានលើកលែងក្នុងករណីដូចខាងក្រោម៖

ក- ការប្រមូលផល អនុផលព្រៃឈើពីព្រៃឯកជន។

ខ- ការប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋាន។

គ- គោលដៅវិទ្យាសាស្ត្រ។

**មាត្រា៥០៧ ._ ការពន្យារពេលបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ**

១- ក្នុងករណីម្ចាស់លិខិតអនុញ្ញាតមិនបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើទៅតាមកាលបរិច្ឆេទកំណត់តាមកិច្ចព្រមព្រៀងជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ផលអនុផលព្រៃឈើទាំងនោះត្រូវឃាត់ទុក។

២- ការពន្យារពេលបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើត្រូវស្របតាមលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៥០៨ ._ នីតិវិធីនៃការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើ**

នីតិវិធីនៃការបង់ថ្លៃសួយសារនិងបុព្វលាភព្រៃឈើត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី៨

## យន្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

**មាត្រា៥០៩ ._ យន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់និងរេចរឹលព្រៃឈើ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តយន្តការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ និងរេចរឹលព្រៃឈើ (រេដបូក) ដើម្បីលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព បង្កើនសន្និធិកាបូនព្រៃឈើ និងលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

**មាត្រា៥១០ ._ ការដាំស្តារព្រៃឈើឡើងវិញ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជំរុញ និងលើកកម្ពស់ការដាំស្តារព្រៃឈើឡើងវិញក្នុងតំបន់ដីព្រៃរេចរឹល ដើម្បីធ្វើឱ្យប្រសើរឡើងនូវតម្លៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រងប្រកបដោយនិរន្តរភាព។

**មាត្រា៥១១ ._ ការដាំដុះដើមឈើ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំគោលការណ៍ណែនាំបច្ចេកទេស ដើម្បីកំណត់វិធាននានា ស្តីពីការដាំដុះដើមឈើក្នុងគោលបំណងលើកទឹកចិត្តដល់បុគ្គលក្នុងការដាំ និងរក្សាការដាំដុះដើមឈើសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព និងសមស្របទៅនឹងគោលដៅបរិស្ថាន សេដ្ឋកិច្ច និងសង្គម។

**មាត្រា៥១២ .- ការទប់ស្កាត់និងការត្រួតពិនិត្យភ្លើងឆេះព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទប់ស្កាត់និងត្រួតពិនិត្យភ្លើងឆេះព្រៃ ដោយរៀបចំបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងភ្លើងឆេះព្រៃសម្រាប់ការអនុវត្តក្នុងតំបន់ព្រៃឈើ។

២- ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានកាតព្វកិច្ចគាំពារ ថែរក្សាព្រៃឈើ និងទប់ស្កាត់ភ្លើងឆេះព្រៃ។

**មាត្រា៥១៣ .- ការផ្ដល់វិញ្ញាបនបត្រព្រៃឈើតាមស្តង់ដារអន្តរជាតិនិងការគ្រប់គ្រង**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចរៀបចំប្រកាសដែលពាក់ព័ន្ធទៅនឹងការផ្ដល់វិញ្ញាបនបត្រព្រៃឈើតាមស្តង់ដារអន្តរជាតិដែលក្នុងនោះមានជាអាទិ៍៖

ក- ការអនុវត្តនីតិវិធីតាមដាននិងវាយត្រាលើឈើហ៊ុប។

ខ- ជាផលិតផលឈើនិងសាច់ឈើ អនុផលព្រៃឈើដែលបានមកពីការរើបអូស ឬឃាត់ទុកផលដែលមិនអាចប្រើប្រាស់ក្នុងស្រុក។

**មាត្រា៥១៤ .- ប្រព័ន្ធផ្ដល់លិខិតអនុញ្ញាតនិងការអង្កេតតាមដានទូទាំងប្រទេស**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចរៀបចំប្រព័ន្ធផ្ដល់លិខិតអនុញ្ញាត និងការតាមដានលើសកម្មភាពផលិត និងការប្រើប្រាស់នូវរាល់ផលិតផលព្រៃឈើដែលចេញពីតំបន់ព្រៃឈើគ្រប់គ្រងប្រកបដោយនិរន្តរភាព។

២- ការរៀបចំប្រព័ន្ធផ្ដល់លិខិតអនុញ្ញាត និងការតាមដានជាលក្ខខណ្ឌតម្រូវសម្រាប់បុគ្គលដែលធ្វើប្រតិបត្តិការត្រូវស្របតាមលិខិតអនុញ្ញាត ដូចមានចែងក្នុងក្រមនេះ។

## ជំពូកទី៧
## កិច្ចគាំពាររុក្ខជាតិព្រៃ
## ផ្នែកទី១
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥១៥ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើកិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងរុក្ខជាតិព្រៃក្នុងតំបន់ការពារធម្មជាតិ។ ការគ្រប់គ្រងរុក្ខជាតិព្រៃក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យព្រៃឈើ។

**មាត្រា៥១៦ .- តួនាទីនិងភារកិច្ច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្ដីព្រាងគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនិងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរុក្ខជាតិព្រៃ។

ខ- សិក្សា តាមដាន និងវាយតម្លៃផ្នែកសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន របស់រុក្ខជាតិព្រៃ ។

គ- សិក្សាវាយតម្លៃ និងគ្រប់គ្រងប្រភេទរាតត្បាតមិនមានដើមកំណើតក្នុងស្រុក ឬដែលមិនមានក្នុងធម្មជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៥

ឃ- រៀបចំបញ្ជីចាត់ថ្នាក់ គ្រប់គ្រង និងការពាររុក្ខជាតិព្រៃ ជាពិសេសប្រភេទកំពុងរងការគំរាមកំហែង។

ង- រៀបចំចុះបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងត្រូវបានចុះក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

ច- ចាត់វិធានការនិងយន្តការសម្រាប់ការអភិរក្ស ការគ្រប់គ្រង និងការប្រើប្រាស់រុក្ខជាតិព្រៃ ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

ឆ- ស្តារឡើងវិញនូវរុក្ខជាតិព្រៃនិងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែងអាចឈានទៅផុតពូជ។

ជ- ចងក្រង គ្រប់គ្រង និងផ្សព្វផ្សាយប្រព័ន្ធទិន្នន័យរុក្ខជាតិព្រៃនិងព័ត៌មានប្រព័ន្ធអេកូឡូស៊ី។

២- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥១៧ ._ កិច្ចសហការរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការចែករំលែកព័ត៌មាន និងទិន្នន័យអំពីបទល្មើសរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង ដូចខាងក្រោម៖

ក- លទ្ធផលនៃការស៊ើបអង្កេតថ្នាក់ជាតិ និងថ្នាក់អន្តរជាតិស្តីពីការជួញដូរ និងដឹកជញ្ជូនរុក្ខជាតិព្រៃ និងប្រភេទឈើខុសច្បាប់។

ខ- របាយការណ៍នៃការរឹបអូសរុក្ខជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងដូចមានចែងនៅក្នុងក្រមនេះ និងប្រភេទឈើខុសច្បាប់ ដូចមានចែងនៅក្នុងបទប្បញ្ញត្តិពាក់ព័ន្ធ។

គ- ឯកសារបណ្តឹងផ្លូវច្បាប់ពាក់ព័ន្ធនឹងរុក្ខជាតិព្រៃ និងប្រព័ន្ធអេកូឡូស៊ីដែលកំពុងរងការគំរាមកំហែង។

## ផ្នែកទី២
## ការធ្វើចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ

**មាត្រា៥១៨ ._ រុក្ខជាតិព្រៃ**

រុក្ខជាតិព្រៃគ្រប់ប្រភេទដែលជាសមាសភាគនៃធនធានធម្មជាតិត្រូវចាត់ទុកជាសម្បត្តិរដ្ឋ លើកលែងតែមានបញ្ញត្តិពិសេសក្នុងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៥១៩ ._ បញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រានិងគ្រប់គ្រងបញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃរួមទាំងប្រភេទ ដែលកំពុងរងការគំរាមកំហែងសម្រាប់គ្រប់គ្រងនិងការពារ។ បញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៥២០ ._ ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ**

១- រុក្ខជាតិព្រៃដែលមានក្នុងបញ្ជីចំណាត់ថ្នាក់សម្រាប់ប្រភេទនីមួយៗ ដែលកំពុងរងគ្រោះថ្នាក់ត្រូវបានបែងចែកជា ៨ ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក- ចំណាត់ថ្នាក់ទី១ ៖ ប្រភេទផុតពូជទាំងស្រុង។

ខ- ចំណាត់ថ្នាក់ទី២ ៖ ប្រភេទផុតពូជពីក្នុងព្រៃ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ- ចំណាត់ថ្នាក់ទី៣ ៖ ប្រភេទជិតផុតពូជបំផុត។

ឃ- ចំណាត់ថ្នាក់ទី៤ ៖ ប្រភេទជិតផុតពូជ។

ង- ចំណាត់ថ្នាក់ទី៥ ៖ ប្រភេទងាយទទួលរងគ្រោះ។

ច- ចំណាត់ថ្នាក់ទី៦ ៖ ប្រភេទជិតទទួលរងគ្រោះ។

ឆ- ចំណាត់ថ្នាក់ទី៧ ៖ ប្រភេទមិនទាន់រងការគំរាមកំហែង។

ជ- ចំណាត់ថ្នាក់ទី៨ ៖ ប្រភេទមិនមានទិន្នន័យគ្រប់គ្រាន់។

២- ការចាត់ថ្នាក់ខាងលើត្រូវធ្វើឡើងស្របទៅតាមស្ថានភាពជាក់ស្តែង ដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងអ្នកជំនាញការបច្ចេកទេស។

៣- ការកំណត់និយមន័យ និងលក្ខណវិនិច្ឆ័យរបស់ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃនីមួយៗខាងលើត្រូវផ្អែកតាមស្ថានភាពជាក់ស្តែងនិងស្របតាមលក្ខណៈវិទ្យាសាស្ត្រ។

៤- បញ្ជីចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ត្រូវធ្វើបច្ចុប្បន្នកម្មផ្អែកលើស្ថានភាពជាក់ស្តែងនិងលក្ខណវិនិច្ឆ័យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៥២១ .‒ ការដំឡើងចំណាត់ថ្នាក់នៃប្រភេទរុក្ខជាតិព្រៃ**

គ្រប់ប្រភេទរុក្ខជាតិព្រៃអាចត្រូវដំឡើងចំណាត់ថ្នាក់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតហានិភ័យ ការគំរាមកំហែងស្ថានភាពប្រភេទរុក្ខជាតិព្រៃ និងតម្លៃបេតិកភណ្ឌវប្បធម៌ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ស្របតាមចំណាត់ថ្នាក់ដូចមានចែងក្នុងមាត្រា៥២០នៃក្រមនេះ។

## ផ្នែកទី៣
## សកម្មភាពហាមឃាត់ប៉ះពាល់ទីជម្រកប្រភេទរុក្ខជាតិព្រៃ

**មាត្រា៥២២ .‒ សកម្មភាពហាមឃាត់ដែលប៉ះពាល់ដល់ទីជម្រកប្រភេទរុក្ខជាតិព្រៃ**

ហាមឃាត់ចំពោះសកម្មភាពបំផ្លិចបំផ្លាញឬធ្វើឱ្យប្រែប្រួលទីជម្រកធម្មជាតិរបស់ប្រភេទរុក្ខជាតិព្រៃ ដែលកំពុងរងការគំរាមកំហែងដោយផ្ទាល់ឬប្រយោល លើកលែងតែទទួលបានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី៧(កិច្ចគាំពាររុក្ខជាតិព្រៃ) មាតិកាទី២(ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌និងទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ) នៃគន្ថីទី៤នៃក្រមនេះ។

**មាត្រា៥២៣ .‒ សកម្មភាពហាមឃាត់ចំពោះប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង**

ហាមឃាត់ចំពោះសកម្មភាពប្រមូល ធ្វើសន្និធិ បំផ្លិចបំផ្លាញ ប្រើប្រាស់ លក់ ធ្វើពាណិជ្ជកម្ម ឬដឹកជញ្ជូនរុក្ខជាតិព្រៃ ឬបំណែករុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង ដូចមានចែងក្នុងបញ្ជីប្រភេទរុក្ខជាតិព្រៃថ្នាក់ជាតិ លើកលែងតែទទួលបានការអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមបញ្ញត្តិនៃជំពូកទី៧(កិច្ចគាំពាររុក្ខជាតិព្រៃ) នៃមាតិកាទី២(ការគ្រប់គ្រងធនធានធម្មជាតិ សម្បត្តិវប្បធម៌ និងទេសចរណ៍ធម្មជាតិក្នុងតំបន់ការពារធម្មជាតិ) នៃគន្ថីទី៤នៃក្រមនេះ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★



៨៥

# ផ្នែកទី៤

# ការផ្តល់លិខិតអនុញ្ញាត ការប្រមូលយក និងការធ្វើពាណិជ្ជកម្ម

**មាត្រា៥២៤ .- លិខិតអនុញ្ញាតសម្រាប់ធ្វើសកម្មភាពជាលក្ខណៈអន្តរជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធទៅនឹងសកម្មភាពជាលក្ខណៈអន្តរជាតិទៅលើប្រភេទរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី៣ដល់ទី៨ នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ)នៃក្រមនេះ និងសំណាករុក្ខជាតិព្រៃទាំងនោះ ដូចខាងក្រោម៖

ក- ការថែរក្សា។

ខ- ការដឹកជញ្ជូន។

គ- ការតាំងពិព័រណ៍។

ឃ- ការធ្វើសន្និធិ។

ង- ការផ្តល់ជាអំណោយថ្នាក់រដ្ឋ។

ច- ការចូលរួមសកម្មភាពអន្តរជាតិដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥២៥ .- ការតម្រូវឱ្យមានលិខិតអនុញ្ញាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់លិខិតអនុញ្ញាតការជួញដូរ ឬការដឹកជញ្ជូនរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ប្រភេទទី៦និងទី៧នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ)នៃក្រមនេះ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងជាឱសថ។

២- ការផ្តល់លិខិតអនុញ្ញាតណាមួយត្រូវដាក់កម្រិតសមស្រប និងតាមពេលវេលានៃសកម្មភាពនោះ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ធម្មជាតិឬការស្តារឡើងវិញ។

**មាត្រា៥២៦ .- ការលើកលែងលិខិតអនុញ្ញាត**

សកម្មភាពខាងក្រោមនេះមិនតម្រូវឱ្យមានលិខិតអនុញ្ញាត៖

ក- ការប្រមូល ការដឹកជញ្ជូន និងការប្រើប្រាស់ប្រភេទរុក្ខជាតិព្រៃក្នុងចំណាត់ថ្នាក់ប្រភេទទី៧ សម្រាប់ការប្រើប្រាស់ជាលក្ខណៈគ្រួសារនិងជាលក្ខណៈប្រពៃណី។

ខ- ការប្រមូលផល អនុផលព្រៃឈើពីចម្ការដាំដុះលើដីឯកជន។

**មាត្រា៥២៧ .- លក្ខខណ្ឌមិនចេញលិខិតអនុញ្ញាត**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រូវចេញលិខិតអនុញ្ញាតក្នុងករណីដែលមិនមានព័ត៌មានបញ្ជាក់គ្រប់គ្រាន់ពីផ្នែកវិទ្យាសាស្ត្រ។

**មាត្រា៥២៨ .- ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្តល់ការអនុញ្ញាតពិសេសនៅក្នុងការប្រមូលប្រភេទរុក្ខជាតិព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់ប្រភេទទី៣ដល់ទី៨នៃមាត្រា៥២០ (ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ)នៃក្រមនេះ ពីកន្លែងណាមួយសម្រាប់គោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ក្នុងករណីការប្រមូលនោះ មិនបង្កផលប៉ះពាល់ដល់ការអភិរក្សសារព័ន្ធរុក្ខជាតិព្រៃនៅក្នុងនិងក្រៅព្រះរាជាណាចក្រកម្ពុជា។

២- ការផ្តល់លិខិតអនុញ្ញាតនេះអាចផ្តល់ឱ្យតាមការស្នើសុំពីស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស [illegible]សន្និធិរុក្ខជាតិព្រៃស្ងួតសម្រាប់ការសិក្សាស្រាវជ្រាវ ឬសួនភូគគាមសាស្ត្រ។

**មាត្រា៥២៩ ._ ព័ត៌មានវិទ្យាសាស្ត្រមិនគ្រប់គ្រាន់**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចបដិសេធក្នុងការផ្តល់លិខិតអនុញ្ញាតពិសេស ដូចមានចែងក្នុងមាត្រា៥២៨(ការផ្តល់លិខិតអនុញ្ញាតសម្រាប់គោលបំណងផ្នែកស្រាវជ្រាវវិទ្យាសាស្ត្រ)នៃក្រមនេះ ក្នុងករណីមិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ ដើម្បីធ្វើការកំណត់អំពីផលប៉ះពាល់លើប្រភេទរុក្ខជាតិព្រៃដែលទទួលរងការគំរាមកំហែង។

២- ក្នុងករណីលិខិតអនុញ្ញាតត្រូវបានផ្តល់សម្រាប់គោលបំណងវិទ្យាសាស្ត្រ មិនមានព័ត៌មានវិទ្យាសាស្ត្រគ្រប់គ្រាន់ដើម្បីធ្វើការកំណត់ច្បាស់លាស់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចធ្វើការវិនិច្ឆ័យ ដើម្បីដាក់កំហិតទៅលើកម្រិតដែលកាត់បន្ថយលទ្ធភាព និងសកម្មភាពនៃការប្រមូលទាំងនេះ ដែលនឹងបង្កឱ្យមានការផុតពូជនៃប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងឬបង្កការខូចខាតដែលមិនអាចជំនួសបាន។

**មាត្រា៥៣០ ._ លិខិតអនុញ្ញាតប្រមូលប្រភេទរុក្ខជាតិព្រៃ**

ការស្នើសុំលិខិតអនុញ្ញាតប្រមូលយកប្រភេទរុក្ខជាតិព្រៃ ត្រូវដាក់សំណើសុំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៣១ ._ ការព្យួរឬការលុបលិខិតអនុញ្ញាត**

ក្នុងករណីចាំបាច់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិព្យួរជាបណ្តោះអាសន្នដោយមិនមានកាលកំណត់ ឬលុបលិខិតអនុញ្ញាតដោយផ្អែកលើទិន្នន័យថ្មីៗ ព័ត៌មានវិទ្យាសាស្ត្រ ឬការគំរាមកំហែងដែលបានរកឃើញថ្មីៗទៅលើប្រភេទរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង និងទីជម្រក។

## ផ្នែកទី៥
## ផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃ

**មាត្រា៥៣២ ._ ផែនការគ្រប់គ្រងរុក្ខជាតិព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងរយៈពេលខ្លី មធ្យម និងវែង នូវប្រភេទដែលកំពុងរងការគំរាមកំហែងមានដើមកំណើតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដែលបានកំណត់ក្នុងចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ដូចមានចែងក្នុងមាត្រា៥២០(ចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ)នៃក្រមនេះ។

២- ផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃត្រូវរៀបចំឡើងក្នុងរយៈពេលខ្លី មធ្យម និងវែង ហើយអាចគ្របដណ្តប់ទៅលើប្រភេទរុក្ខជាតិព្រៃច្រើនប្រភេទ និងរួមបញ្ចូលទាំងប្រភេទសត្វព្រៃផងដែរ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញបច្ចេកទេស ដើម្បីរៀបចំផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង។

៤- ផែនការគ្រប់គ្រងនិងស្តារប្រភេទរុក្ខជាតិព្រៃ សារព័ន្ធរុក្ខជាតិព្រៃអាចត្រូវបញ្ចូលទៅក្នុងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

**មាត្រា៥៣៣ ._ ផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃ**

ផែនការគ្រប់គ្រងនិងស្តាររុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែងត្រូវកំណត់នូវខ្លឹមសារជាក់លាក់ដូចខាងក្រោម៖

ក- គោលបំណង លក្ខណវិនិច្ឆ័យ វិធានការ និងលទ្ធផលរំពឹងទុក។

ខ- សកម្មភាពគ្រប់គ្រងនិងអភិរក្សដើម្បីធានានូវមុខងារ និងតួនាទីក្នុងប្រព័ន្ធអេកូឡូស៊ី។

គ- ការគំរាមកំហែងដោយផ្ទាល់និងប្រយោល ដោយមានវិធានការឆ្លើយតបចាំបាច់ក្នុងការកាត់បន្ថយការគំរាមកំហែង និងធានាសុវត្ថិភាពប្រភេទរុក្ខជាតិព្រៃទាំងនោះ។

ឃ- ទីជម្រកសំខាន់ៗឬពិសេសសម្រាប់ការអភិរក្សរុក្ខជាតិព្រៃ។

ង- ការបញ្ជ្រាបទៅក្នុងផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ច- ការបញ្ជ្រាបផែនការយុទ្ធសាស្ត្រជាតិនិងផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះនិងផែនការអភិរក្សនានា។

ឆ- ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត។

**មាត្រា៥៣៤ .- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើការស្តាររុក្ខជាតិព្រៃដែលកំពុងរងការគំរាមកំហែង**

គម្រោងផែនការឬសកម្មភាពស្តាររុក្ខជាតិព្រៃត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាតិកាទី២ (ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) នៃគន្ថីទី៥នៃក្រមនេះ ក្នុងករណីដែលមានផលប៉ះពាល់ខ្លាំងដល់ទីជម្រក មុខងារនិងតួនាទីប្រព័ន្ធអេកូឡូស៊ី។

**មាត្រា៥៣៥ .- ការរៀបចំរបាយការណ៍និងការអង្កេតតាមដាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយភាគីពាក់ព័ន្ធត្រូវរៀបចំប្រព័ន្ធអង្កេតតាមដាននិងការរៀបចំរបាយការណ៍អំពីការអនុវត្តផែនការគ្រប់គ្រងនិងស្តារប្រភេទរុក្ខជាតិព្រៃនិងសារពើភ័ន្ធរុក្ខជាតិព្រៃ។

## ផ្នែកទី៦
## ការគ្រប់គ្រងប្រភេទរាតត្បាត

**មាត្រា៥៣៦ .- បញ្ជីប្រភេទរាតត្បាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រា និងគ្រប់គ្រងបញ្ជីប្រភេទរាតត្បាតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រោយទទួលបញ្ជីពីរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវពិនិត្យផ្ទៀងផ្ទាត់បញ្ជីប្រភេទរាតត្បាតមុនដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

២- ហាមឃាត់ការនាំចូលប្រភេទរាតត្បាតទាំងឡាយណាដែលមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៣៧ .- ការគ្រប់គ្រងប្រភេទរាតត្បាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំសកម្មភាពគ្រប់គ្រងប្រភេទរាតត្បាត ដោយពិចារណាទៅលើផលប៉ះពាល់អវិជ្ជមាននិងហានិភ័យចំពោះសត្វ រុក្ខជាតិព្រៃ ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញបច្ចេកទេសត្រូវរៀបចំសកម្មភាពគ្រប់គ្រងប្រភេទរាតត្បាត ដើម្បីកំណត់៖

ក- ផ្លូវដែលប្រភេទរុក្ខជាតិព្រៃរាតត្បាតនោះចូលមកកាន់ដែនសមត្ថកិច្ចរបស់ខ្លួន។

ខ- វិធីសាស្ត្រនៃការគ្រប់គ្រងប្រភេទរុក្ខជាតិព្រៃដែលរាតត្បាតដែលមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គ- វិធីសាស្ត្រលុបបំបាត់ប្រភេទរុក្ខជាតិព្រៃដែលរាតត្បាត និងបង្កមហន្តរាយ។



ЖБ

**មាត្រា៥៣៨ .‒ ផែនការគ្រប់គ្រងប្រភេទរាតត្បាត**

ផែនការគ្រប់គ្រងប្រភេទរាតត្បាតត្រូវកំណត់ខ្លឹមសារជាក់លាក់ ដូចខាងក្រោម៖

ក- គោលបំណង លក្ខណវិនិច្ឆ័យ វិធានការ សូចនាករតាមដាន និងលទ្ធផលរំពឹងទុក។

ខ- សកម្មភាពគ្រប់គ្រង វិធានការ វិធីសាស្ត្រកំចាត់ ទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត។

គ- ទំហំ ទីតាំង ភូមិសាស្ត្រ ប្រភព និងប្រភេទរាតត្បាត។

ឃ- ធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទីជម្រកសំខាន់ៗនៅទីតាំងត្រូវគ្រប់គ្រងប្រភេទរាតត្បាត។

ង- ផ្លូវចម្លងដោយផ្ទាល់និងប្រយោល វិធានការឆ្លើយតបនិងចាំបាច់ក្នុងការទប់ស្កាត់ និងរារាំងប្រភេទរាតត្បាត។

ច- ការបញ្ជ្រាបផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាពជាតិស្តីពីជីវៈចម្រុះ និងផែនការអភិរក្ស។

ឆ- ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្ត។

**មាត្រា៥៣៩ .‒ បញ្ជីសម្រាប់ប្រភេទរុក្ខជាតិព្រៃរាតត្បាត**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំបញ្ជីថ្នាក់ជាតិសម្រាប់ប្រភេទរុក្ខជាតិព្រៃរាតត្បាតដែលបង្កគ្រោះថ្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬការនាំចូលប្រភេទរុក្ខជាតិព្រៃទាំងនោះមកក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥៤០ .‒ ផែនការលុបបំបាត់ប្រភេទរុក្ខជាតិព្រៃរាតត្បាត**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបផែនការលុបបំបាត់ប្រភេទរុក្ខជាតិព្រៃរាតត្បាត ដើម្បីកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ពីប្រភេទរុក្ខជាតិព្រៃរាតត្បាតដែលប៉ះពាល់បរិស្ថាន សេដ្ឋកិច្ច និងសង្គម។

**មាត្រា៥៤១ .‒ លក្ខខណ្ឌតម្រូវនៃការអនុញ្ញាត**

ការនាំចូលប្រភេទរុក្ខជាតិព្រៃរាតត្បាតណាមួយ ចូលទៅក្នុងតំបន់ការពារធម្មជាតិត្រូវមានការឯកភាពជាមុនពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៨
## ការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សសត្វព្រៃ
### ផ្នែកទី១
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥៤២ .‒ ស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើកិច្ចគាំពារ ការអភិរក្ស និងការគ្រប់គ្រងសត្វព្រៃគ្រប់ប្រភេទស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ។

២- ការគ្រប់គ្រងសត្វព្រៃដែលស្ថិតក្រៅតំបន់ការពារធម្មជាតិ ជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យព្រៃឈើ។

**មាត្រា៥៤៣ .‒ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងនីតិវិធីគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សសត្វព្រៃ។

ខ- បង្កើតនិងអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ផែនការគ្រប់គ្រង និងផែនការសកម្មភាពអភិរក្សប្រភេទសត្វព្រៃដែលទទួលរងការគំរាមកំហែង ស្របតាមលិខិតបទដ្ឋានគតិយុត្តឬលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

គ- តាមដាន ស្រាវជ្រាវ ទប់ស្កាត់បទល្មើសសត្វព្រៃគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិរួមទាំងការនាំចេញ ការនាំចូល ការធ្វើសន្និធិ ការចរាចរ ការធ្វើអាជីវកម្ម ការប្រើប្រាស់សត្វព្រៃ និងការបរិភោគសាច់សត្វព្រៃ ដែលត្រូវបានប្រមូលផលដោយគ្មានលិខិតអនុញ្ញាត។

ឃ- ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធនានា ស៊ើបអង្កេតតាមដាន ត្រួតពិនិត្យ កសាងសំណុំរឿងបទល្មើសសត្វព្រៃនិងធ្វើជាអង្គភាពដើមបណ្តឹងរដ្ឋប្បវេណីតាមនីតិវិធីច្បាប់។

ង- បង្កើត គ្រប់គ្រង និងរក្សាប្រព័ន្ធទិន្នន័យពាក់ព័ន្ធនឹងបទល្មើសសត្វព្រៃ។

ច- ពង្រឹងយន្តការមានស្រាប់ដើម្បីទប់ស្កាត់ការជួញដូរសត្វព្រៃ និងបង្កើតវិធីសាស្ត្រថ្មីបន្ថែមទៀតសម្រាប់ប្រយុទ្ធប្រឆាំងនឹងបទល្មើសសត្វព្រៃឆ្លងដែន ឬប្រើប្រាស់ព្រះរាជាណាចក្រកម្ពុជាជាគោលដៅឆ្លងកាត់ទៅកាន់ប្រទេសដទៃទៀត។

ឆ- ធ្វើបច្ចុប្បន្នកម្មចំណាត់ថ្នាក់ប្រភេទសត្វព្រៃ។

ជ- បង្កើតនិងអនុវត្តកម្មវិធីការពារ អភិរក្ស ពិនិត្យតាមដាន និងស្រាវជ្រាវសត្វព្រៃដែលជាប្រភេទទទួលរងគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា៩៤៦ (ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ) នៃក្រមនេះ។

ឈ- រៀបចំលិខិតបទដ្ឋានគតិយុត្ត ការងារគ្រប់គ្រង និងការចេញលិខិតអនុញ្ញាតបរបាញ់សត្វព្រៃសម្រាប់សហគមន៍មូលដ្ឋានដែលនៅក្នុងឬក្រៅតំបន់ការពារធម្មជាតិ។

ញ- ពិនិត្យឡើងវិញ បដិសេធ ឬអនុញ្ញាតការប្រមាញ់សត្វព្រៃតាមលក្ខខណ្ឌនានាស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ដ- ត្រួតពិនិត្យ តាមដាន និង/ឬចេញបទបញ្ជាប្រតិបត្តិការនៅឧទ្យានសត្វព្រៃ មជ្ឈមណ្ឌលបង្កាត់ពូជអភិរក្ស មជ្ឈមណ្ឌលសង្គ្រោះ និងស្តារសមត្ថភាពសត្វព្រៃ និងកន្លែងប្រមូលផលសត្វព្រៃដើម្បីធ្វើអាជីវកម្ម។

ឋ- ពិនិត្យឡើងវិញ បដិសេធ ឬអនុញ្ញាតសំណើចាប់សត្វព្រៃរស់សម្រាប់គោលបំណងបង្កាត់ពូជដើម្បីអភិរក្ស។

ឌ- ធានាថាលិខិតអនុញ្ញាតនិងដំណើរការផ្តល់លិខិតអនុញ្ញាតត្រូវមានតម្លាភាពនិងត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

ឍ- រៀបចំយុទ្ធសាស្ត្រស្តីពីការតាមដាននិងថែទាំសុខភាពសត្វព្រៃ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងសម្របសម្រួលឱ្យមានការឆ្លើយតប ចំពោះករណីជំងឺរាតត្បាត ជំងឺឆ្លង និងសុខភាពសត្វព្រៃ។

ណ- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ភាគីពាក់ព័ន្ធ និងចូលរួមនៅក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ។

ត- លើកកម្ពស់ការអប់រំជាសាធារណៈនិងផ្សព្វផ្សាយកម្មវិធីដែលបង្ហាញពីសារៈសំខាន់នៃការគ្រប់គ្រងកិច្ចគាំពារ និងការអភិរក្សសត្វព្រៃដោយនិរន្តរភាព។

ថ- ហាមឃាត់ចំពោះការបំផ្លាញឬការកែប្រែទីជម្រកធម្មជាតិរបស់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

២- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៤៥

## ផ្នែកទី២
## ការធ្វើចំណាត់ថ្នាក់ប្រភេទសត្វព្រៃ

**មាត្រា៥៤៤ .‒ សត្វព្រៃ**

សត្វព្រៃគ្រប់ប្រភេទដែលជាសមាសភាគនៃធនធានធម្មជាតិ ត្រូវចាត់ទុកជាសម្បត្តិរដ្ឋលើកលែងតែមានបញ្ញត្តិពិសេសក្នុងក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៥៤៥ .‒ បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំកត់ត្រានិងគ្រប់គ្រងបញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃរួមទាំងប្រភេទសត្វ ដែលកំពុងរងការគំរាមកំហែង សម្រាប់គ្រប់គ្រងនិងការពារក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៥៤៦ .‒ ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ**

១- សត្វព្រៃ ដែលមានក្នុងបញ្ជីចំណាត់ថ្នាក់សម្រាប់ប្រភេទនីមួយៗ ដែលកំពុងរងគ្រោះថ្នាក់ត្រូវបានបែងចែកជា៨(ប្រាំបី)ចំណាត់ថ្នាក់ដូចខាងក្រោម៖

- ក- ចំណាត់ថ្នាក់ទី១៖ ប្រភេទផុតពូជទាំងស្រុង។
- ខ- ចំណាត់ថ្នាក់ទី២៖ ប្រភេទផុតពូជពីក្នុងព្រៃ។
- គ- ចំណាត់ថ្នាក់ទី៣៖ ប្រភេទជិតផុតពូជបំផុត។
- ឃ- ចំណាត់ថ្នាក់ទី៤៖ ប្រភេទជិតផុតពូជ។
- ង- ចំណាត់ថ្នាក់ទី៥៖ ប្រភេទងាយទទួលរងគ្រោះ។
- ច- ចំណាត់ថ្នាក់ទី៦៖ ប្រភេទជិតទទួលរងគ្រោះ។
- ឆ- ចំណាត់ថ្នាក់ទី៧៖ ប្រភេទមិនទាន់រងការគំរាមកំហែង។
- ជ- ចំណាត់ថ្នាក់ទី៨៖ ប្រភេទមិនមានទិន្នន័យគ្រប់គ្រាន់។

២- ការចាត់ថ្នាក់ខាងលើ ត្រូវធ្វើឡើងស្របទៅតាមស្ថានភាពជាក់ស្តែងដោយមានការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនិងអ្នកជំនាញការបច្ចេកទេស។

៣- ការកំណត់និយមន័យនិងលក្ខណវិនិច្ឆ័យរបស់ចំណាត់ថ្នាក់ប្រភេទសត្វព្រៃនីមួយៗខាងលើត្រូវផ្អែកតាមស្ថានភាពជាក់ស្តែងនិងស្របតាមលក្ខណៈវិទ្យាសាស្ត្រ។

៤- បញ្ជីចំណាត់ថ្នាក់ប្រភេទសត្វព្រៃត្រូវធ្វើបច្ចុប្បន្នកម្មផ្អែកលើស្ថានភាពជាក់ស្តែងនិងលក្ខណវិនិច្ឆ័យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៥៤៧ .‒ ការដំឡើងចំណាត់ថ្នាក់នៃប្រភេទសត្វព្រៃ**

គ្រប់ប្រភេទសត្វព្រៃអាចត្រូវដំឡើងចំណាត់ថ្នាក់ដោយផ្អែកលើមូលដ្ឋាននៃកម្រិតហានិភ័យ ការគំរាមកំហែងស្ថានភាពប្រភេទសត្វព្រៃ និងតម្លៃបេតិកភណ្ឌវប្បធម៌ឬសារៈសំខាន់ផ្នែកសេដ្ឋកិច្ច ស្របតាមចំណាត់ថ្នាក់ដូចមានចែងក្នុងមាត្រា៥៤៦នៃក្រមនេះ។

## ផ្នែកទី៣
## ការហាមឃាត់ចំពោះការបរបាញ់សត្វព្រៃ

**មាត្រា៥៤៨ ._ ការហាមឃាត់ការបរបាញ់សត្វព្រៃ**

១- ហាមឃាត់រាល់ការបរបាញ់ ការទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ឬការយាយីបំផ្លិចបំផ្លាញ តាមមធ្យោបាយនានា និងប្រភេទសត្វព្រៃ ដូចខាងក្រោម៖

ក- ប្រភេទសត្វព្រៃចំណាត់ថ្នាក់ទី២ដល់ទី៦ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ) នៃក្រមនេះ។

ខ- ប្រភេទសត្វព្រៃដូចមានចែងក្នុងចំណាត់ថ្នាក់ទី៧ ដោយប្រើមធ្យោបាយដែលច្បាប់ហាមឃាត់។

គ- ការបរបាញ់ដោយសហគមន៍មូលដ្ឋាន ដោយពុំមានលិខិតអនុញ្ញាតកំណត់កូតា ដែលចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ឃ- ការកាន់កាប់ ការផលិត ការរក្សាទុក ការដឹកជញ្ជូន ឬការនាំយកឧបករណ៍ដែលអាចប្រើប្រាស់សម្រាប់បរបាញ់សត្វព្រៃ តាមមធ្យោបាយគ្រប់រូបភាព មានជាអាទិ៍ អន្ទាក់ អង្គប់ កាំភ្លើង ឬអាវុធកែច្នៃ ខ្សែលួស ខ្សែហ្វ្រាំងកង់ ឬខ្សែហ្វ្រាំងម៉ូតូ ឧបករណ៍ឆក់ សំណាញ់ ឬឧបករណ៍ផ្សេងៗទៀត។

ង- ការដឹកជញ្ជូនឬយកធ្វើជាកម្មសិទ្ធិ ចំពោះសត្វព្រៃក្នុងចំណាត់ថ្នាក់ទី៨ ដូចមានចែងក្នុងមាត្រា៥៤៦ (ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ ដោយគ្មានលិខិតអនុញ្ញាតបរបាញ់និងគ្មានលិខិតអនុញ្ញាតដឹកជញ្ជូន។

ច- ទាក់ចាប់ ប្រមូល ទិញសត្វព្រៃដោយខុសច្បាប់ពីក្នុងតំបន់ការពារធម្មជាតិ សម្រាប់គោលដៅបង្កើតឬរក្សាទុកក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ការចាប់ប្រមូលមករក្សាទុកជាឯកជន។

ឆ- ការនាំសត្វចិញ្ចឹមចូលទៅក្នុងតំបន់ស្នូលនិងតំបន់អភិរក្ស។

២- រាល់សកម្មភាពដូចមានចែងខាងលើនេះ ត្រូវបានលើកលែង ចំពោះសកម្មភាពអនុវត្តក្នុងគោលដៅគ្រប់គ្រង និងអភិរក្សសត្វព្រៃ ឬបង្កើតទីតាំងបង្កាត់ពូជអភិរក្ស និងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងគោលបំណងរក្សាទុកសត្វព្រៃគ្រប់ប្រភេទ ដែលត្រូវបានអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៥៤៩ ._ ការហាមឃាត់ទូទៅ**

១- ហាមឃាត់ការបរបាញ់ ការទាក់ ការដាក់អន្ទាក់ ការចាប់ ការបំពុល ការសម្លាប់សត្វព្រៃ ឬការយាយីបំផ្លិចបំផ្លាញទៅលើប្រភេទសត្វព្រៃ និងតាមមធ្យោបាយនានា ដូចខាងក្រោម៖

ក- ប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ លើកលែងតែករណីដូចបានកំណត់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ខ- ប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ទី៧ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ) នៃក្រមនេះ ដោយប្រើមធ្យោបាយដែលច្បាប់ហាមឃាត់។

គ- ការផលិត ការកែច្នៃ ទិញ ជួញដូរ ដឹកជញ្ជូន ដាក់អន្ទាក់ អង្គប់ សំណាញ់នៅជាប់នឹងដី ឬលើអាកាស ប្រើអាវុធកែច្នៃ អាវុធជាតិផ្ទុះ ថ្នាំពុល និងមធ្យោបាយផ្សេងទៀត។

ឃ- ការបរបាញ់ ការចាប់ ឬខានសត្វព្រៃដោយប្រើយានយន្តគ្រប់ប្រភេទមិនថាលើទឹក លើដី ឬលើអាកាស។

២- ការហាមឃាត់ដូចមានចែងខាងលើនេះ ត្រូវបានលើកលែង ចំពោះប្រភេទសត្វព្រៃស្ថិតក្នុងចំណាត់ថ្នាក់ទី៧ ដូចមានចែងក្នុងមាត្រា៥៤៦(ចំណាត់ថ្នាក់ប្រភេទសត្វព្រៃ)នៃក្រមនេះ ដែលប្រើប្រាស់ដោយសហគមន៍

មូលដ្ឋានជាលក្ខណៈគ្រួសារនិងប្រពៃណី។ ប្រភេទសត្វព្រៃដែលប្រើប្រាស់ដោយសហគមន៍មូលដ្ឋានជាលក្ខណៈគ្រួសារ និងប្រពៃណីត្រូវកំណត់ដោយប្រកាសអន្តរក្រសួង។

## ផ្នែកទី៤
## ករណីលើកលែងសម្រាប់ការហាមឃាត់សត្វព្រៃ
## អនុផ្នែកទី១
## ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស

**មាត្រា៥៥០ ._ ការកំណត់ការគ្រប់គ្រងលើការបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស**

១- ក្នុងករណីសត្វព្រៃបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចចាត់វិធានការសមស្របក្នុងការសម្លាប់សត្វព្រៃដែលបង្កហេតុនោះក្នុងករណីចាំបាច់។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំប្រកាសស្ដីពីការត្រួតពិនិត្យសត្វព្រៃដែលបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្ស។

**មាត្រា៥៥១ ._ វិធីសាស្ត្រគ្រប់គ្រងប្រភេទសត្វព្រៃបង្កគ្រោះថ្នាក់**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំវិធីសាស្ត្រក្នុងការគ្រប់គ្រងប្រភេទសត្វព្រៃបង្កគ្រោះថ្នាក់ស្របតាមលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាដល់សុខុមាលភាពរបស់សត្វព្រៃ និងការកាត់បន្ថយហានិភ័យទៅលើសត្វព្រៃដទៃទៀតឬជីវិតមនុស្ស។

**មាត្រា៥៥២ ._ សត្វព្រៃដែលត្រូវបានអនុញ្ញាតឱ្យសម្លាប់ឬបំផ្លាញចោល**

សត្វព្រៃដែលបានបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្សត្រូវបានអនុញ្ញាតឱ្យសម្លាប់ឬធ្វើឱ្យរបួស។ ក្នុងករណីសត្វព្រៃរងរបួសមិនអាចជាសះស្បើយវិញបានត្រូវបំផ្លាញ ឬសម្លាប់ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥៥៣ ._ សិទ្ធិក្នុងការគ្រប់គ្រងប្រភេទសត្វក្នុងចំណាត់ថ្នាក់ទី២ដល់ទី៨**

បុគ្គលអាចគ្រប់គ្រងប្រភេទសត្វព្រៃស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ដល់ទី៨ ដែលអាចបង្កគ្រោះថ្នាក់ដល់ជីវិតមនុស្សដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៥៥៤ ._ ប្រភេទសត្វព្រៃដែលមិនមានដើមកំណើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា**

ប្រភេទសត្វព្រៃស្ថិតនៅក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ និង/ឬមិនមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិដែលអាចបង្កគ្រោះថ្នាក់ឬគគ្បាតដល់ជីវៈចម្រុះត្រូវធ្វើការគ្រប់គ្រងទាំងនៅក្នុងឬក្រៅតំបន់ការពារធម្មជាតិ។ ក្នុងករណីសត្វព្រៃដែលបានបង្កឱ្យមានគ្រោះថ្នាក់ដល់ជីវិតមនុស្សឬគគ្បាតដល់ជីវៈចម្រុះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុញ្ញាតឱ្យសម្លាប់ឬធ្វើឱ្យរបួស។

**មាត្រា៥៥៥ ._ ការចាប់សត្វព្រៃរស់សម្រាប់គោលដៅអភិរក្ស**

ការចាប់សត្វព្រៃរស់តាមប្រភេទដូចបានកំណត់ក្នុងចំណាត់ថ្នាក់ណាមួយ សម្រាប់គោលដៅបង្កាត់ពូជអភិរក្ស ឬការគ្រប់គ្រងលើការងារអភិរក្សត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★



ጥ

**មាត្រា៥៥៦ ._ ការគ្រប់គ្រងលើការអភិរក្ស**

ការគ្រប់គ្រងលើការអភិរក្សមាន៖

ក- ការប្តូរទីកន្លែងសម្រាប់សត្វព្រៃប្រភេទណាមួយទៅកាន់ទីជម្រកសមស្រប ក្នុងគោលបំណងស្តារប្រភេទសត្វព្រៃ ការដាក់ចិញ្ចឹមសត្វព្រៃឡើងវិញ ឬការបំពេញបន្ថែមនូវក្រុមសត្វព្រៃ ឬដើម្បីទប់ស្កាត់ការវិនាសផុតពូជក្រុមសត្វព្រៃដែលមិនអាចជៀសវាងបាន។

ខ- ការស្រាវជ្រាវឬការគ្រប់គ្រងក្រុមការរស់នៅដោយពុំចាំបាច់សម្លាប់ឬបំផ្លាញសត្វព្រៃ។

គ- ការចាប់សត្វព្រៃសម្រាប់គោលដៅធ្វើឱ្យមានលំនឹងនៃប្រភេទក្រុមសត្វព្រៃនិងបង្កាត់ពូជដើម្បីអភិរក្សប្រភេទសត្វដែលទទួលរងការគំរាមកំហែងនៅក្នុងកន្លែងបង្កាត់ពូជដែលបានចុះបញ្ជី។

**មាត្រា៥៥៧ ._ ការបន្លាស់ទីកន្លែង**

ការបន្លាស់ទីកន្លែងនិងការចាប់សត្វព្រៃសម្រាប់ការបង្កាត់ពូជដើម្បីអភិរក្ស ឬគ្រប់គ្រងលើការងារអភិរក្សប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ អាចអនុញ្ញាតដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៥៨ ._ ការធ្វើចត្តាឡីស័កនិងការអង្កេតតាមដានពីសុខភាពសត្វព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិតម្រូវឱ្យធ្វើចត្តាឡីស័កសត្វព្រៃដើម្បីអង្កេតតាមដានពីសុខភាពក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃ នៅមុនពេលដែលសត្វព្រៃទាំងនោះត្រូវបានប្តូរទីតាំង នាំមកបញ្ចូល ឬផ្ទេររវាងកន្លែងចត្តាឡីស័ក និងជម្រកធម្មជាតិ ឬកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬកន្លែងបង្កាត់ពូជអភិរក្ស ឬមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ។ ក្រោយពីការធ្វើចត្តាឡីស័ក និងការអង្កេតតាមដានពីសុខភាពរបស់សត្វព្រៃ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចេញលិខិតបញ្ជាក់ដូចខាងក្រោម៖

ក- សត្វព្រៃត្រូវបានធ្វើចត្តាឡីស័កនិងអង្កេតតាមដានពីសុខភាពមិនឱ្យលើសពី១៤(ដប់បួន)ថ្ងៃ និងត្រូវពិនិត្យនៅមុនពេលប្តូរទីតាំងនាំចូលទៅជម្រកធម្មជាតិវិញឬផ្ទេរទៅកន្លែងផ្សេង។

ខ- សត្វព្រៃនោះមិនបង្ហាញពីរោគសញ្ញាជំងឺឬមានរបួស។

គ- សត្វព្រៃដែលមានសុខភាពល្អនិងសត្វដែលមានជំងឺដោយមានស្លាកសម្គាល់។

២- ក្នុងករណីដែលសត្វព្រៃនោះមានជំងឺឬស្លាប់នៅក្នុងកំលុងពេលធ្វើចត្តាឡីស័ក ម្ចាស់ទីតាំងឬអ្នកគ្រប់គ្រងទីតាំងត្រូវជូនដំណឹងជាបន្ទាន់ទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៥៩ ._ វិធីសាស្ត្រអង្កេតតាមដានសុខភាពសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ៖

ក- កំណត់អត្តសញ្ញាណជំងឺសត្វព្រៃនិងត្រូវផ្សព្វផ្សាយជាសាធារណៈអំពីជំងឺដែលបានរកឃើញ។

ខ- រៀបចំវិធីសាស្ត្រអង្កេតតាមដានសុខភាពនិងជំងឺសត្វព្រៃ។

គ- ស៊ើបអង្កេត ចងក្រងឯកសារ និងឆ្លើយតបចំពោះការរាតត្បាតនៃជំងឺសត្វព្រៃ។

ឃ- របាយការណ៍អំពីលទ្ធផលនៃការសិក្សា ការអង្កេតតាមដានសុខភាពសត្វព្រៃ និងការស៊ើបអង្កេតជំងឺសត្វព្រៃ។

**មាត្រា៥៦០ .- ការតាមដានសុខភាពសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ អាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ ប្រមូល ទិញសត្វព្រៃ ប្រគល់នូវសំណាកសត្វព្រៃដែលបរបាញ់ ឬប្រមូលបានដើម្បីធ្វើការតាមដានពីសុខភាពសត្វព្រៃ។

## អនុផ្នែកទី២

## គ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៥៦១ .- លក្ខខណ្ឌតម្រូវ**

១- គ្រឹះស្ថានឧទ្យានសត្វព្រៃត្រូវស្នើសុំការអនុញ្ញាតបង្កើតគ្រឹះស្ថានឧទ្យានសត្វព្រៃ និងការនាំចូល ការនាំចេញសត្វព្រៃរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ប្រាក់ចំណូលដែលប្រមូលបានពីការចេញអាជ្ញាបណ្ណឬលិខិតអនុញ្ញាតត្រូវប្រើប្រាស់គាំទ្រដល់ការអភិរក្សសត្វព្រៃ និងជីវៈចម្រុះរួមទាំងការអនុវត្តផែនការស្តារនិងគ្រប់គ្រងសត្វព្រៃឬការប្រើប្រាស់ដទៃទៀតសម្រាប់គោលដៅអភិរក្ស។

**មាត្រា៥៦២ .- ការហាមឃាត់**

ហាមឃាត់ចំពោះការបរបាញ់ ការទាក់ ការចាប់ ឬការប្រមូលសត្វព្រៃ និងសកម្មភាពផ្សេងទៀតពីព្រៃធម្មជាតិនូវប្រភេទសត្វព្រៃ ដូចបានកំណត់ក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ នៃបញ្ជីចំណាត់ថ្នាក់សត្វព្រៃសម្រាប់បម្រើឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងមានការអនុញ្ញាតពិសេសពីរាជរដ្ឋាភិបាល។

**មាត្រា៥៦៣ .- ការស្នើសុំ**

ការស្នើសុំការប្រមូល ការទាក់ ការចាប់សត្វព្រៃ តាមប្រភេទដូចបានកំណត់ក្នុងបញ្ជីចំណាត់ថ្នាក់ទី៧និងទី៨ សម្រាប់គោលដៅរបស់គ្រឹះស្ថានឧទ្យានសត្វព្រៃ ត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៦៤ .- ការផ្តល់និងការផ្អាកបណ្តោះអាសន្ននៃលិខិតអនុញ្ញាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតអនុញ្ញាតឱ្យគ្រឹះស្ថានឧទ្យានសត្វព្រៃធ្វើអាជីវកម្មសត្វព្រៃស្របតាមនីតិវិធីច្បាប់ជាធរមាននិងបទប្បញ្ញត្តិនៃក្រមនេះ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតផ្អាកជាបណ្តោះអាសន្ន លិខិតបិទទីតាំង ឬលិខិតប្រមូលដកហូតសត្វព្រៃក្នុងបរិវេណនិងក្នុងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងករណីប្រតិបត្តិករឬម្ចាស់គ្រឹះស្ថានឧទ្យានសត្វព្រៃមិនអនុវត្តតាមលិខិតអនុញ្ញាតនិងលិខិតបទដ្ឋានគតិយុត្តដែលចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិបានចេញឱ្យ។

## ផ្នែកទី៥

## លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ

**មាត្រា៥៦៥ .- លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ**

១- ការបរបាញ់សត្វព្រៃដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៧និងទី៨ ត្រូវមានលិខិតអនុញ្ញាតចេញដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ការកំណត់ទីតាំង ឧបករណ៍ ប្រភេទអាវុធ ប្រភេទសត្វព្រៃ និងចំនួនសត្វព្រៃដែលត្រូវបរបាញ់ត្រូវកំណត់ដោយអនុក្រឹត្យ។

៣- រូបវន្តបុគ្គលដែលទទួលបានការអនុញ្ញាតឱ្យបរបាញ់មានសិទ្ធិយកសំណាកសត្វព្រៃដែលបានមកពីការបរបាញ់នោះ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវពិនិត្យចំនួនសត្វព្រៃដែលបានបរបាញ់ជាក់ស្តែង ដើម្បីកំណត់តម្លៃបង់ចូលថវិកាជាតិ។

៤- កម្រៃសេវានៃការផ្តល់លិខិតអនុញ្ញាតឱ្យបរបាញ់និងតម្លៃប្រភេទសត្វត្រូវបរបាញ់កំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៦៦ ._ ការបរបាញ់សត្វព្រៃ**

១- អ្នកបរបាញ់ត្រូវយកលិខិតអនុញ្ញាតបរបាញ់តាមខ្លួនជានិច្ច។

២- អ្នកបរបាញ់ត្រូវបង្ហាញលិខិតអនុញ្ញាតបរបាញ់ដល់អង្គភាពមានសមត្ថកិច្ចមុនចូលក្នុងតំបន់អនុញ្ញាតឱ្យបរបាញ់។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចតម្រូវឱ្យអ្នកកាន់កាប់លិខិតអនុញ្ញាតបរបាញ់ក្នុងគោលបំណងសិក្សាស្រាវជ្រាវ ឬអង្កេតតាមដានសុខភាពសត្វព្រៃត្រូវផ្តល់គំរូសំណាក ឬផ្នែកណាមួយនៃសត្វព្រៃដែលបាញ់បាន។

**មាត្រា៥៦៧ ._ ការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាត**

១- បុគ្គលដែលមានបំណងស្នើសុំលិខិតអនុញ្ញាតបរបាញ់ត្រូវដាក់ពាក្យស្នើសុំទៅកាន់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ពាក្យស្នើសុំលិខិតអនុញ្ញាតបរបាញ់ត្រូវបានត្រួតពិនិត្យស្របតាមការណែនាំ មុនផ្តល់ការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៦៨ ._ លក្ខខណ្ឌចេញឬការមិនចេញលិខិតអនុញ្ញាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំបង្កើតទម្រង់បែបបទនៃការស្នើសុំលិខិតអនុញ្ញាតបរបាញ់សត្វព្រៃនិងផ្តល់លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ។

២- ការចេញឬការមិនចេញលិខិតអនុញ្ញាតបរបាញ់សត្វព្រៃត្រូវធ្វើឡើង ដូចខាងក្រោម៖

ក- ការចេញលិខិតអនុញ្ញាតត្រូវតម្លាភាព។

ខ- ការចេញលិខិតអនុញ្ញាតបានតែមួយចំពោះមួយគ្រួសារ ឬមួយក្រុម។

គ- ការមិនចេញលិខិតអនុញ្ញាតដល់បុគ្គលដែលមានប្រវត្តិពាក់ព័ន្ធនឹងការបរបាញ់សត្វព្រៃខុសច្បាប់។

ឃ- ការមិនអនុញ្ញាតដល់បុគ្គលក្នុងការផ្ទេរលិខិតអនុញ្ញាត ឬលក់សិទ្ធិបរបាញ់សត្វព្រៃទៅបុគ្គលម្នាក់ផ្សេងទៀត។

៣- លិខិតអនុញ្ញាតបរបាញ់មានសុពលភាពមិនលើសពី៦(ប្រាំមួយ)ខែ។ អ្នកបរបាញ់អាចស្នើសុំបន្តលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ដោយភ្ជាប់ជាមួយលិខិតអនុញ្ញាតដែលហួសសុពលភាព។

៤- ក្នុងករណីបាត់លិខិតអនុញ្ញាត អ្នកកាន់កាប់លិខិតអនុញ្ញាតត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៣៥

**មាត្រា៥៦៩ .– ការផ្អាកនិងការដកហូតលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចផ្អាក ឬដកហូតលិខិតអនុញ្ញាតបរបាញ់សត្វព្រៃពីបុគ្គលដែលទទួលបានលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ហើយបានប្រព្រឹត្តផ្ទុយពីលិខិតអនុញ្ញាត។

២- រដ្ឋបាលថ្នាក់ក្រោមជាតិអាចផ្អាកលិខិតអនុញ្ញាតបរបាញ់សត្វព្រៃ ពីបុគ្គលដែលទទួលបានលិខិតអនុញ្ញាតបរបាញ់សត្វព្រៃហើយបានប្រព្រឹត្តផ្ទុយពីលិខិតអនុញ្ញាត។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវជូនដំណឹងមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៥៧០ .– ប្រព័ន្ធគ្រប់គ្រងទិន្នន័យសត្វព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសត្វព្រៃ លិខិតអនុញ្ញាតបរបាញ់សត្វព្រៃ និងអ្នកបរបាញ់ក្នុងគោលដៅអង្កេត តាមដាន ត្រួតពិនិត្យ និងនិយ័តកម្មទៅលើសកម្មភាព បរបាញ់សត្វព្រៃ។

២- ព័ត៌មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ អាចអនុញ្ញាតឱ្យសាធារណជនរកបានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

## ផ្នែកទី៦
## ការចិញ្ចឹមសត្វព្រៃនិងការធ្វើពាណិជ្ជកម្មសត្វព្រៃ

**មាត្រា៥៧១ .– ការចិញ្ចឹមសត្វព្រៃ**

១- បុគ្គលគ្រប់រូបអាចចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្មដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ បញ្ជីប្រភេទសត្វព្រៃដែលអាចចិញ្ចឹមបានដោយមានលិខិតអនុញ្ញាតនិងនីតិវិធីក្នុងការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ការដឹកជញ្ជូន និងការសម្លាប់សត្វព្រៃចិញ្ចឹមត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២-បុគ្គលគ្រប់រូបអាចចិញ្ចឹមសត្វព្រៃសម្រាប់ការកម្សាន្ត ដោយពុំចាំបាច់មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ បញ្ជីប្រភេទសត្វព្រៃដែលអាចចិញ្ចឹមបានសម្រាប់ការកម្សាន្តដោយពុំចាំបាច់មានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៧២ .– ការធ្វើពាណិជ្ជកម្មក្នុងស្រុក**

១- បុគ្គលអាចធ្វើពាណិជ្ជកម្មក្នុងស្រុកនូវប្រភេទសត្វព្រៃឬបំណែកសរីរាង្គ ឬផលិតផលពីសត្វព្រៃគ្រប់ប្រភេទដែលមានប្រភពចេញពីកសិដ្ឋានចិញ្ចឹមសត្វព្រៃ ដូចខាងក្រោម៖

ក- ការទិញឬការទទួលយកមកធ្វើជាកម្មសិទ្ធិ កាន់កាប់ ចម្អិន ឬលក់សាច់សត្វព្រៃ។

ខ- ការដាក់លក់ឬការផ្សព្វផ្សាយដើម្បីលក់ទំនិញឬផលិតផលមានប្រភពពីសត្វព្រៃ។

គ- ការផលិតសត្វព្រៃសិប្បនិម្មិតដោយប្រើប្រាស់បំណែកសរីរាង្គសត្វព្រៃ។

ឃ- ការផលិតនូវផលិតផលដែលមានប្រភពពីសត្វព្រៃ។

២- ការធ្វើពាណិជ្ជកម្មក្នុងស្រុកនូវប្រភេទសត្វព្រៃ ការដឹកជញ្ជូន និងផលិតផលពីសត្វព្រៃគ្រប់ប្រភេទត្រូវមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៧៣ .– ការធ្វើពាណិជ្ជកម្មអន្តរជាតិ**

១- បុគ្គលអាចធ្វើសកម្មភាពពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើប្រភេទសត្វព្រៃឬបំណែកសរីរាង្គ ឬសត្វព្រៃដែលបានកែច្នៃរស់ផ្សេងៗទៀត ដូចខាងក្រោម៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក- ការកាន់កាប់។

ខ- ការដឹកជញ្ជូន។

គ- ការតាំងពិព័រណ៍។

ឃ- ការធ្វើសន្និធិ។

ង- ការដោះដូរនិងអំណោយ។

ច- ការសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ។

ឆ- សកម្មភាពដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មអន្តរជាតិទៅលើសំណាកបំណែកសរីរាង្គសត្វព្រៃ។

២- នីតិវិធីនៃការចេញលិខិតអនុញ្ញាតសម្រាប់ពាណិជ្ជកម្មអន្តរជាតិ ឬសកម្មភាពពាក់ព័ន្ធអន្តរជាតិលើប្រភេទសត្វព្រៃ សំណាកសត្វព្រៃ និងសព៌ាង្គកាយកែច្នៃរស់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- នីតិវិធីនិងបែបបទនៃការធ្វើពាណិជ្ជកម្មអន្តរជាតិត្រូវអនុវត្តតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យពាណិជ្ជកម្ម។

**មាត្រា៥៧៤ ._ សកម្មភាពហាមឃាត់**

១- ហាមឃាត់ចំពោះការជួញដូរ ការដឹកជញ្ជូន ការនាំចូល ការនាំចេញ ការនាំចេញបន្ត ការកាន់កាប់ ការលក់ ការទិញ ការទទួលយក ការផ្ទេរ ការធ្វើសន្និធិ ការផ្តល់ជាអំណោយ ការបរិភោគ ការចិញ្ចឹម និងការប្រើប្រាស់តាមរូបភាពពាណិជ្ជកម្មនូវបំណែកសរីរាង្គសត្វព្រៃនិងផលិតផលពីសត្វព្រៃគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

២- ហាមឃាត់ចំពោះរាល់ការផ្តល់ព័ត៌មានផ្សព្វផ្សាយឬការផ្សព្វផ្សាយសម្រាប់លក់សត្វព្រៃ វត្ថុតាំងលម្អបំណែកសរីរាង្គសត្វព្រៃ សាច់សត្វព្រៃ ឬផលិតផលពីសត្វព្រៃគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត។

៣- ការផលិត ផលិតផលក្លែងក្លាយ ដែលមានការផ្សព្វផ្សាយថាជាផលិតផលពីសត្វព្រៃ ឬបំណែកសរីរាង្គសត្វព្រៃត្រូវចាត់ទុកជាបទល្មើសដូចគ្នានឹងបទល្មើសដែលពាក់ព័ន្ធនឹងសត្វព្រៃនិងបំណែកសរីរាង្គសត្វព្រៃពិតប្រាកដ។

**មាត្រា៥៧៥ ._ ការមិនទទួលខុសត្រូវរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមិនទទួលខុសត្រូវក្នុងករណីដូចខាងក្រោម៖

ក- រាល់ការខូចខាតទ្រព្យសម្បត្តិឬការប៉ះពាល់ទាំងឡាយណាដែលបង្កដោយសត្វព្រៃចិញ្ចឹម ឬដោយការរួចពីការបង្ខាំងរបស់កសិដ្ឋានចិញ្ចឹមសត្វព្រៃ។

ខ- រាល់ការបាត់បង់ឬការស្លាប់សត្វព្រៃចិញ្ចឹមណាមួយមិនថាដោយការរួច ឬការស្លាប់ដោយសារជំងឺ បើទោះជាក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចតម្រូវឱ្យមានការសម្លាប់សត្វព្រៃចិញ្ចឹមណាមួយដែលរួច ឬដោយសារស្ថានភាពនៃជំងឺ ឬស្ថានភាពផ្សេងៗទៀត។

## ផ្នែកទី៧
## អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ (សាយតេស)

**មាត្រា៥៧៦ ._ ការអនុវត្តលើប្រភេទសត្វព្រៃនិងរុក្ខជាតិព្រៃ**

១- យោងតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ដូចមានចែងក្នុងក្រមនេះ អាចអនុវត្តចំពោះប្រភេទសត្វព្រៃនិងរុក្ខជាតិព្រៃនៅក្នុង៖

ROYAUME DU CAMBODGE · MINISTRE DU PALAIS ROYAL

ក- ឧបសម្ព័ន្ធ១ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

ខ- ឧបសម្ព័ន្ធ២ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

គ- ឧបសម្ព័ន្ធ៣ នៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។

២- ព្រះរាជាណាចក្រកម្ពុជាត្រូវសហការជាមួយបណ្តាប្រទេសនានា ដែលជាភាគីនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដើម្បីលើកកម្ពស់ការអនុវត្តដោយប្រសិទ្ធភាព។

**មាត្រា៥៧៧ ._ ការហាមឃាត់**

ហាមឃាត់ចំពោះសកម្មភាពដូចខាងក្រោម៖

ក- ការនាំចូល ការនាំចេញ នូវប្រភេទសត្វព្រៃ ពីក្រៅព្រះរាជាណាចក្រកម្ពុជា មកក្នុងព្រះរាជាណាចក្រកម្ពុជា ឬពីក្នុងព្រះរាជាណាចក្រកម្ពុជា ទៅក្រៅព្រះរាជាណាចក្រកម្ពុជាដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា។

ខ- ការនាំចេញបន្ត ផ្ទេរ ឬដឹកជញ្ជូនឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅកាន់បរទេសនូវប្រភេទសត្វព្រៃ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតពីសមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា។

## ផ្នែកទី៨
## កិច្ចសហប្រតិបត្តិការអន្តរជាតិ

**មាត្រា៥៧៨ ._ កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការបង្ក្រាបបទល្មើសសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវសហការផ្តល់ព័ត៌មានទៅឱ្យអាជ្ញាធរអនុវត្តច្បាប់នៃរដ្ឋឬប្រទេសពាក់ព័ន្ធដើម្បីទប់ស្កាត់ កំណត់អត្តសញ្ញាណ និងបង្ក្រាបបទល្មើសសត្វព្រៃនៅក្រោមយុត្តាធិការនៃរដ្ឋឬប្រទេសពាក់ព័ន្ធ ដោយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមានផ្សេងទៀត។

**មាត្រា៥៧៩ ._ ការស៊ើបអង្កេតនិងនីតិវិធី**

១- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចសហការជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ និងអង្គការអន្តរជាតិ និង/ឬអង្គការថ្នាក់តំបន់សម្រាប់កិច្ចការដូចតទៅ៖

ក- ផ្តល់ភស្តុតាងជាឯកសារ សក្ខីកម្ម សាក្សី សារធាតុផ្សេងៗ និងការធ្វើបទបង្ហាញស្រាយបំភ្លឺសម្រាប់ការវិភាគ និងការស៊ើបអង្កេត។

ខ- ការផ្តល់ឬការដោះដូរបុគ្គលិក មន្ត្រីជំនាញ និងមន្ត្រីមុខងារផ្សេងៗ។

គ- ធ្វើការស៊ើបអង្កេតដោយឡែក ឬធ្វើការស៊ើបអង្កេតរួមគ្នា។

ឃ- ការចាត់នីតិវិធី។

ង- ផ្តល់ជំនួយផ្សេងទៀតតាមការស្នើសុំសម្រាប់ករណីនីមួយៗ។

២- ការផ្តល់ជំនួយដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងបទប្បញ្ញត្តិនៃច្បាប់ជាធរមានផ្សេងទៀត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



ฅ

## ផ្នែកទី៩
## ផែនការស្តារនិងគ្រប់គ្រងសត្វព្រៃ

**មាត្រា៥៨០ .- ផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃគ្រប់ចំណាត់ថ្នាក់ ជាពិសេសប្រភេទក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ដែលមានដើមកំណើត នៅក្នុងតំបន់ការពារធម្មជាតិ។ ផែនការនេះត្រូវមានរយៈពេល១០(ដប់)ឆ្នាំយ៉ាងតិច។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្របសម្រួល ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ បន្ទាប់ពីធ្វើការពិគ្រោះយោបល់ ជាសាធារណៈ។

**មាត្រា៥៨១ .- លក្ខខណ្ឌនៃផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់លក្ខខណ្ឌៈ

ក- សកម្មភាពការពារនិងអភិរក្សនៅក្នុងផែនការស្តារនិងគ្រប់គ្រងប្រភេទសត្វព្រៃ។

ខ- ទីជម្រកសំខាន់ៗសម្រាប់ការអភិរក្សប្រភេទសត្វព្រៃមានវិធានការគ្រប់គ្រងទៅតាមប្រភេទទីជម្រក និងតំបន់ក្នុងគោលដៅការពារនិងអភិរក្ស។

គ- សកម្មភាពគ្រប់គ្រងទីជម្រកនិងតំបន់ទេសភាពនៅក្នុងផែនការស្តារ និងគ្រប់គ្រងតំបន់ការពារធម្មជាតិ។

ឃ- សូចនាករដែលអាចវាស់វែងបានដែលអាចធ្វើឱ្យប្រភេទគោលដៅមានភាពប្រសើរឡើង។ ផែនការស្តារ និងគ្រប់គ្រងប្រភេទសត្វព្រៃត្រូវកំណត់ពេលវេលានិងធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តសកម្មភាព និង វិធានការនានា។

ង- ការបន្លាស់ទីកន្លែង វិធានការអភិរក្សក្រៅដែនជម្រកធម្មជាតិ ការបង្កាត់ពូជដើម្បីអភិរក្ស និងការស្តារ សម្រាប់ការអភិរក្ស។

**មាត្រា៥៨២ .- លិខិតអនុញ្ញាត**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចចេញលិខិតអនុញ្ញាត សម្រាប់គម្រោងស្តារសត្វព្រៃ ឬសកម្មភាពសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យ ថតរូបភាព ថតយកសំឡេងសត្វព្រៃ ប្រើម៉ាស៊ីនថតរូបភាពស្វ័យប្រវត្តិ ឬផ្សាយផ្ទាល់ ផលិតខ្សែភាពយន្ត ឬរឿងអ្វីពាក់ព័ន្ធនឹងការកំណត់ប្រភេទសត្វព្រៃ ក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦។

២- មុនចេញលិខិតអនុញ្ញាតក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពិនិត្យទៅលើផែនការស្តារ ការគ្រប់គ្រងប្រភេទសត្វព្រៃ។

**មាត្រា៥៨៣ .- ការអង្កេតតាមដានស្ថានភាពនៃប្រភេទសត្វព្រៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសហការជាមួយភាគី ពាក់ព័ន្ធ ដើម្បីអង្កេតតាមដានស្ថានភាពនៃប្រភេទសត្វព្រៃក្នុងចំណាត់ថ្នាក់ទី២ដល់ទី៦ ក្នុងរយៈពេល១០(ដប់)ឆ្នាំ បន្ទាប់ពីស្ថានភាពចំណាត់ថ្នាក់នៃប្រភេទសត្វព្រៃមានការប្រែប្រួល ស្របតាមលិខិតបទដ្ឋានគតិយុត្ត ឬបទប្បញ្ញត្តិ នៃក្រមនេះ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ផ្នែកទី១០
# ការគ្រប់គ្រងទីតាំងបង្កាត់ពូជអភិរក្ស ធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ

**មាត្រា៥៨៤ ._ ការចុះបញ្ជី**

ការបង្កើតទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃក្នុងគោលបំណងរក្សាទុកសត្វព្រៃគ្រប់ប្រភេទត្រូវមានលិខិតអនុញ្ញាត និងចុះបញ្ជីនៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៨៥ ._ ការធ្វើអធិការកិច្ច**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើអធិការកិច្ចទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃ។

**មាត្រា៥៨៦ ._ ការដកហូតលិខិតអនុញ្ញាតឬការបញ្ឈប់ប្រតិបត្តិការបណ្ដោះអាសន្ន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិដកហូតលិខិតអនុញ្ញាត ឬបញ្ឈប់ប្រតិបត្តិការទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ និងគ្រឹះស្ថានឧទ្យានសត្វព្រៃជាបណ្ដោះអាសន្ន ព្រមទាំងរឹបអូសរាល់សត្វព្រៃ ក្នុងករណីអនុវត្តផ្ទុយខ្លឹមសារលិខិតអនុញ្ញាតស្ដីពីការរក្សាឬប្រមូលទុកសត្វព្រៃ។

**មាត្រា៥៨៧ ._ ការអង្កេតតាមដាននិងធ្វើកំណត់ត្រា**

ប្រតិបត្តិករឬម្ចាស់ទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ មានភារកិច្ចធ្វើរបាយការណ៍អំពីការកើត ការស្លាប់ និងការផ្ទេរសត្វព្រៃជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៨៨ ._ ការផ្ទេរឬការប្ដូរទីតាំងសត្វព្រៃ**

១- រាល់ការផ្ទេរឬការប្ដូរទីតាំងសត្វព្រៃត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូន និង/ឬត្រូវជូនដំណឹងជាមុនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- ការផ្ទេរឬការប្ដូរទីតាំងសត្វព្រៃពីកន្លែងមួយទៅកន្លែងមួយទៀត ត្រូវកត់ត្រាឱ្យបានច្បាស់លាស់ ហើយត្រូវជូនដំណឹងនិងផ្ដល់ឯកសារដល់មន្ត្រីអនុវត្តច្បាប់នៃក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥៨៩ ._ ការបោះបង់ចោលបំណែកសាច់ សំណាក ឬវត្ថុតាំងលម្អសត្វព្រៃ**

១- ការបោះបង់ចោលបំណែកសរីរាង្គ សាច់ សំណាក ឬវត្ថុតាំងលម្អសត្វព្រៃដែលរក្សាទុកឬចិញ្ចឹមត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២- ហាមឃាត់ចំពោះការរក្សាទុកសរីរាង្គទាំងមូលឬជាផ្នែកនៃសត្វព្រៃ ក្នុងទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬគ្រឹះស្ថានឧទ្យានសត្វព្រៃ លើកលែងតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៥៩០ .- លក្ខខណ្ឌនៃការព្យាបាលសត្វព្រៃនិងទីកន្លែង**

សត្វព្រៃដែលបានរក្សាទុកនៅតាមទីតាំងបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ឬកន្លែងសន្និធិសត្វព្រៃ ត្រូវទទួលការថែទាំប្រកបដោយមនុស្សធម៌និងត្រូវអនុលោមតាមពិធីសារនៃសុខុមាលភាពសត្វឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥៩១ .- លក្ខណៈធម្មជាតិរបស់សត្វព្រៃ**

១- រាល់ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ គ្រឹះស្ថានឧទ្យានសត្វព្រៃ ឬកន្លែងសន្និធិសត្វព្រៃ ចំពោះប្រភេទសត្វព្រៃត្រូវធានាឱ្យបាននូវលក្ខណៈធម្មជាតិរបស់សត្វព្រៃ ហើយទ្រុងត្រូវមានលក្ខណៈសមស្របតាមស្តង់ដារដែលអាចទទួលយកបានសម្រាប់ សុខុមាលភាពរបស់សត្វ។

២- ទីកន្លែងដែលអនុវត្តការបង្កាត់ពូជអភិរក្សនិងអភិរក្សធនធានពន្ធុ ត្រូវរៀបចំសៀវភៅកំណត់ត្រាសម្រាប់ប្រភេទសត្វព្រៃ ដោយបញ្ជាក់ពីកម្មវិធីបង្កាត់ពូជឬការចិញ្ចឹម ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- ប្រភេទនៃការបន្តពូជ ព្រឹត្តិការណ៍បង្កាត់ពូជ និងពពួកពូជនីមួយៗ ត្រូវធ្វើការកត់ត្រាឱ្យបានត្រឹមត្រូវអំពីចំនួនសត្វព្រៃមេបាដើមនិងកូនដែលកើតពីមេបាដើម។ កូនដែលកើតពីមេបាដើមត្រូវដាក់សញ្ញាសម្គាល់ជាអចិន្ត្រៃយ៍ដែលអាចសម្គាល់បានអំពីចំនួនភាគរយនិងដើមកំណើតកូន។

**មាត្រា៥៩២ .- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់ការអង្កេត តាមដាន ត្រួតពិនិត្យ និងការគ្រប់គ្រងសត្វព្រៃដែលត្រូវរក្សាទុក និងទីតាំងរក្សាទុកសត្វព្រៃ។

**មាត្រា៥៩៣ .- ការដោះលែងសត្វព្រៃ**

១- ទីកន្លែងដែលមានសត្វព្រៃរស់នៅដោយការរក្សាទុកឬបានកើតក្នុងទីកន្លែងរក្សាទុកដែលតម្រូវឱ្យមានការដោះលែង ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

២- នៅមុនការដោះលែង ត្រូវធ្វើការពិនិត្យសុខភាពសត្វព្រៃ កំណត់អត្តសញ្ញាណ និងរៀបចំកន្លែងដោះលែងឱ្យសមស្របតាមលក្ខណៈធម្មជាតិ និងអង្កេតតាមដាន ត្រួតពិនិត្យ ក្រោយការដោះលែងក្នុងករណីចាំបាច់។

## ផ្នែកទី១១

## ការគ្រប់គ្រងសត្វព្រៃនិងបំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន

**មាត្រា៥៩៤ .- នីតិវិធីគ្រប់គ្រង**

ការគ្រប់គ្រងសត្វព្រៃឬបំណែកសរីរាង្គសត្វព្រៃដែលរឹបអូសបាន ត្រូវអនុវត្តដូចខាងក្រោម៖

ក- សត្វព្រៃរស់ ហើយមានដើមកំណើតក្នុងស្រុក ត្រូវវាយតម្លៃសុខភាពនិងភាពសមស្របនានាមុនដោះលែងចូលទៅក្នុងព្រៃធម្មជាតិ។ ក្នុងករណីមិនសមស្របត្រូវបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលទទួលបានការអនុញ្ញាតដើម្បីព្យាបាលនិងថែទាំ។

ខ- សត្វព្រៃស្លាប់ បំណែកសរីរាង្គ ឬសំណាកសត្វព្រៃ អាចបំផ្លាញចោលឬរក្សាទុកស្របតាមលិខិតបទដ្ឋានគតិយុត្ត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។



ភ

គ- សត្វព្រៃរស់មិនមានដើមកំណើតក្នុងតំបន់ការពារធម្មជាតិ អាចបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃដែលទទួលបានការអនុញ្ញាត ប៉ុន្តែក្នុងករណីចាំបាច់អាចផ្តល់ទៅកន្លែងដើមវិញ ឬអាចចាត់វិធានការតាមស្ថានភាពជាក់ស្តែង។

**មាត្រា៥៩៥ .– ការរៀបចំរបាយការណ៍តាមអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានធ្វើការចាប់យកប្រភេទសត្វព្រៃជិតផុតពូជ ជាសត្វព្រៃទាំងមូល ឬជាបំណែកសរីរាង្គសត្វព្រៃដូចបានកំណត់ក្នុងអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ ត្រូវរាយការណ៍ជូនដល់អាជ្ញាធរទទួលបន្ទុកគ្រប់គ្រងប្រចាំប្រទេសសាមី។

២- អាជ្ញាធរគ្រប់គ្រងដែលទទួលបន្ទុកលើអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ប្រចាំប្រទេសសាមីត្រូវរាយការណ៍ជូនដល់លេខាធិការដ្ឋានសម្រាប់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះ ស្របតាមកាតព្វកិច្ចស្តីពីការរាយការណ៍ដូចបានកំណត់នៅក្នុងអនុសញ្ញានេះ។

៣- ក្នុងករណីមានប្រភេទសត្វព្រៃដែលបានកំណត់ក្នុងអនុសញ្ញានេះត្រូវបានចាប់យកក្នុងពេលកំពុងឆ្លងកាត់ ឬកំពុងចែកចាយក្នុងព្រះរាជាណាចក្រកម្ពុជា នោះក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិអាចរក្សាទុកឬចាត់វិធានការបំផ្លាញវត្ថុចាប់យកស្របតាមគន្ថីទី៩ នៃក្រមនេះ។

**មាត្រា៥៩៦ .– កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចអាចស្នើសុំទៅរាជរដ្ឋាភិបាលធ្វើការចរចានិងកំណត់អំពីកិច្ចព្រមព្រៀងនានាជាមួយអាជ្ញាធរពង្រឹងការអនុវត្តច្បាប់អន្តរជាតិ ឬអង្គការអន្តរជាតិ ឬអង្គការថ្នាក់តំបន់ក្នុងគោលបំណងលើកកម្ពស់កិច្ចសហប្រតិបត្តិការពង្រឹងការអនុវត្តច្បាប់អន្តរជាតិ។

## ជំពូកទី៩
## ការគ្រប់គ្រងជលផល
## ផ្នែកទី១
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៥៩៧ .– ស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលស្ថិតក្នុងតំបន់ការពារធម្មជាតិ។

២- ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្រៅតំបន់ការពារធម្មជាតិជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

**មាត្រា៥៩៨ .– តួនាទីនិងភារកិច្ច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមានតួនាទីនិងភារកិច្ចគ្រប់គ្រងការអភិរក្ស និងការអភិវឌ្ឍធនធានជលផលក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL



៣៥

ក- រៀបចំសេចក្ដីព្រាងគោលនយោបាយគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ផែនការគ្រប់គ្រង ផែនការមេ និងផែនទីទិន្នន័យសម្រាប់គ្រប់គ្រងជលផល។

ខ- កំណត់ដែននេសាទដើម្បីអនុញ្ញាតឱ្យមានសកម្មភាពនេសាទ និងតំបន់ដែលត្រូវធ្វើការអភិរក្សធនធានជលផល។

គ- គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផល ដើម្បីលើកកម្ពស់សន្តិសុខស្បៀង និងថែរក្សាមច្ឆជាតិសម្រាប់ឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា។

ឃ- គ្រប់គ្រងនិងកំណត់ឱ្យមានសកម្មភាពធ្វើវារីវប្បកម្ម។

ង- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេសជលផល សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

ច- សហការនិងចែករំលែកទិន្នន័យស្ដីពីការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ឆ- អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សាការពារជលផល។

ជ- ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃលើការគ្រប់គ្រងជលផល។

ឈ- ធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និងចាត់វិធានការផ្លូវច្បាប់លើបទល្មើសជលផល កសាងសំណុំរឿង និងតាំងខ្លួនជាអង្គភាពដើមបណ្ដឹងទៅតុលាការមានសមត្ថកិច្ច។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផលមានសិទ្ធិអំណាចអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនស្របតាមក្រមនេះ ឬច្បាប់តាមវិស័យរបស់ខ្លួន។

៣- ការបែងចែកមុខងារ តួនាទី និងភារកិច្ចជាក់លាក់ទៅឱ្យថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

## ផ្នែកទី២

## និរន្តរភាពនៃការគ្រប់គ្រងជលផល

**មាត្រា៥៩៩ .-** គោលការណ៍គ្រប់គ្រងជលផល

ការគ្រប់គ្រងជលផលត្រូវគោរពគោលការណ៍ដូចខាងក្រោម៖

ក- គ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាពដោយផ្អែកលើព័ត៌មាននិងទិន្នន័យវិទ្យាសាស្ត្រ។

ខ- ប្រើប្រាស់និងបែងចែកធនធានជលផលប្រកបដោយសមធម៌។

គ- លើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយតម្លាភាពនិងបរិយាបន្ន។

ឃ- លើកកម្ពស់ការអភិវឌ្ឍវារីវប្បកម្មនៅតំបន់ដែលមានសក្ដានុពល។

ង- គោរពកិច្ចព្រមព្រៀងអន្តរជាតិ និងលិខិតុបករណ៍អន្តរជាតិនិងថ្នាក់តំបន់ពាក់ព័ន្ធផ្សេងទៀតដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគីឱ្យមានប្រសិទ្ធភាព។

ច- ធានាបាននូវលក្ខខណ្ឌការងារសមស្របក្នុងការងារជលផលនៅលើនាវានេសាទឬនាវាពាក់ព័ន្ធការនេសាទដើម្បីការពារពលករប្រឆាំងនឹងការជួញដូរមនុស្សឬប្រើពលករដោយបង្ខំ។

ឆ- ធានាសុវត្ថិភាពចំណីអាហារ។

ជ- លើកកម្ពស់ជីវភាពអ្នកនេសាទឱ្យបានល្អប្រសើរ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

## ផ្នែកទី៣
## កិច្ចគាំពារនិងការអភិរក្សជលផល

**មាត្រា៦០០ .- ចំណាត់ថ្នាក់តំបន់គ្រប់គ្រងជលផល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវកំណត់តំបន់សម្រាប់ធ្វើកិច្ចគាំពារនិងការអភិរក្សធនធានជលផលក្នុងតំបន់ការពារធម្មជាតិស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ពាក់ព័ន្ធតាមវិស័យផ្សេងទៀត ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សធនធានជលផល។

**មាត្រា៦០១ .- សកម្មភាពហាមឃាត់ក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្សនិងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិ**

ហាមឃាត់សកម្មភាពក្នុងតំបន់អភិរក្សជលផលដូចខាងក្រោម៖

ក- ការធ្វើនេសាទគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ធ្វើការពិសោធន៍ សិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល។

ខ- ការធ្វើនាវាចរណ៍ឆ្លងកាត់ដោយរៀបចំឧបករណ៍នេសាទ ដែលមានលក្ខណៈប៉ុនប៉ងធ្វើការនេសាទ ឬសកម្មភាពផ្សេងទៀតដែលប៉ះពាល់ដល់ធនធានជលផល។

គ- ការប្រើប្រាស់ឧបករណ៍នេសាទ ឬសកម្មភាពផ្សេងទៀតដែលច្បាប់ស្ដីពីជលផលបានហាមឃាត់។

**មាត្រា៦០២ .- សកម្មភាពដែលត្រូវមានការអនុញ្ញាតក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្សនិងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិ**

សកម្មភាពដែលអាចអនុញ្ញាតក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលក្នុងតំបន់ការពារធម្មជាតិមានដូចខាងក្រោម៖

ក- ការនេសាទនៅក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលដែលមិនប៉ះពាល់ដល់គោលដៅនៃការអភិរក្សធនធានជលផលអាចធ្វើបាន ដោយមានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

ខ- ការគាស់ ការកកាយយកថ្ម ដីខ្សាច់ និងរ៉ែដែលមាននៅក្នុងកន្លែងអភិរក្សជលផលនៃតំបន់អភិរក្ស និងតំបន់ស្នូលអាចធ្វើបាន ដោយត្រូវមានការពិគ្រោះយោបល់ជាមុន និងសម្រេចរួមគ្នារវាងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យធនធានរ៉ែ។

**មាត្រា៦០៣ .- ការរៀបចំអេកូទេសចរណ៍ជលផល**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានសិទ្ធិបង្កើតតំបន់ទេសចរណ៍ជលផលនៅក្នុងតំបន់អភិរក្ស និងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី៤
## ការគ្រប់គ្រងការនេសាទក្នុងតំបន់សហគមន៍និងតំបន់ប្រើប្រាស់ដោយចីរភាព

**មាត្រា៦០៤ .- សិទ្ធិប្រជាពលរដ្ឋ**

ប្រជាពលរដ្ឋខ្មែរឬបុគ្គលដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់មានសិទ្ធិធ្វើនេសាទ និងចូលរួមក្នុងសកម្មភាពពាក់ព័ន្ធនឹងការនេសាទក្នុងតំបន់សហគមន៍និងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិស្របតាមក្រមនេះនិងច្បាប់ស្ដីពីជលផល។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៦០៥ .- ប្រភេទនៃការធ្វើនេសាទ**

១- ការធ្វើនេសាទត្រូវកំណត់ប្រភេទដូចខាងក្រោម៖

ក- ការធ្វើនេសាទខ្នាតតូច។

ខ- ការធ្វើនេសាទខ្នាតមធ្យម។

គ- ការធ្វើនេសាទខ្នាតធំ។

២- ប្រភេទនៃការធ្វើនេសាទត្រូវកំណត់តាមប្រភេទឧបករណ៍នេសាទនិងនាវានេសាទ។ ប្រភេទឧបករណ៍នេសាទត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

**មាត្រា៦០៦ .- ការធ្វើនេសាទ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យធ្វើការនេសាទឬការធ្វើអាជីវកម្មផល ផលិតផលជលផល ឬការធ្វើវារីវប្បកម្មស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ស្តីពីជលផលនៅក្នុងតំបន់សហគមន៍និងតំបន់ប្រើប្រាស់ដោយចីរភាព លើកលែងតែការអនុញ្ញាតទាំងនោះប៉ះពាល់ដល់គោលបំណងនៃការគ្រប់គ្រងតំបន់ទាំងនេះ។

២- នីតិវិធីនៃការផ្តល់លិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងស្ថាប័នទទួលបន្ទុកវិស័យជលផល។

## ជំពូកទី១០

## ទេសចរណ៍ធម្មជាតិ

**មាត្រា៦០៧ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការសម្របសម្រួល និងសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងគម្រោងទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា៦០៨ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រង ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគម្រោងអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិ។

ខ- សម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនក្នុងការគ្រប់គ្រងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ។

គ- សិក្សា សម្របសម្រួល និងគ្រប់គ្រងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគម្រោងអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ឃ- សម្របសម្រួលការរៀបចំបង្កើត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកញ្ចប់ទេសចរណ៍ធម្មជាតិ ដើម្បីទាក់ទាញភ្ញៀវជាតិនិងអន្តរជាតិមកលេងកម្សាន្តនៅក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ង- សម្របសម្រួលសិក្សាកំណត់ទីតាំងនិងបោះបង្គោលព្រំប្រទល់ដី សម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



ស

**មាត្រា៧៣៦ ._ យន្តការសម្របសម្រួលការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន**

ការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន ត្រូវសម្របសម្រួលដោយយន្តការអន្តរក្រសួងទទួលបន្ទុកការងារគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន ដែលត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលដើម្បីជំរុញការបញ្ជ្រាបផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានទៅក្នុងផែនការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**មាត្រា៧៣៧ ._ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន**

ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការងារអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ បរិស្ថានក្នុងបរិបទនៃដែនសមត្ថកិច្ចរបស់ខ្លួនដោយអនុលោមតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន។ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ និងតម្រូវការជាក់ស្តែង។

**មាត្រា៧៣៨ ._ ការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាព ឬគ្រឹះស្ថានក្រោមឱវាទក្រសួងស្ថាប័នសាមី និងភាគីពាក់ព័ន្ធត្រូវអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាននេះ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន សំដៅធានាឱ្យបាននូវគុណភាពបរិស្ថាន គុណភាពនៃប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព។

## ជំពូកទី៤

## ការអប់រំនិងការស្រាវជ្រាវបរិស្ថាន

### ផ្នែកទី១

### ការអប់រំនិងបណ្តុះបណ្តាលបរិស្ថានក្នុងប្រព័ន្ធអប់រំ

**មាត្រា៧៣៩ ._ កម្មវិធីអប់រំនិងបណ្តុះបណ្តាលបរិស្ថាន**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈសម្រាប់ការអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមអង្គភាពរៀងៗខ្លួន។ ការរៀបចំកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈឧបទេសត្រូវឱ្យស្របតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន និងដំណើរវិវឌ្ឍន៍របស់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។

**មាត្រា៧៤០ ._ ធនធានគ្រូឧទ្ទេសនិងសាស្ត្រាចារ្យ**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកសាង និងអភិវឌ្ឍធនធានគ្រូឧទ្ទេស និងសាស្ត្រាចារ្យប្រកបដោយគុណវុឌ្ឍិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃក្រសួងស្ថាប័នសាមី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៧៤១ ._ តម្រូវការអប់រំនិងបណ្តុះបណ្តាល**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកំណត់កម្មវិធីអប់រំបណ្តុះបណ្តាលអប្បបរមា ស្របតាមគោលដៅ និងតម្រូវការនៃការអប់រំបណ្តុះបណ្តាលរបស់អង្គភាពសាមី។

## ផ្នែកទី២

## ការស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍

**មាត្រា៧៤២ ._ មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបង្កើតមជ្ឈមណ្ឌលធនធានបរិស្ថានដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ ព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បរិស្ថាន ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងសាធារណជន។

**មាត្រា៧៤៣ ._ ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

ក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រតិបត្តិករពាក់ព័ន្ធនឹងវិស័យបរិស្ថានត្រូវសហការរៀបចំវេទិកាវិទ្យាសាស្ត្រ កម្មវិធីឬសកម្មភាពសិក្សាស្រាវជ្រាវរួមគ្នាក្នុងលក្ខណៈជាការសំយោគគំនិតរវាងអ្នកធ្វើគោលនយោបាយ អ្នកវិទ្យាសាស្ត្រ និងអ្នកប្រតិបត្តិ ដើម្បីមានមូលដ្ឋានពុទ្ធិវិទ្យាសាស្ត្រសម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងការធ្វើសេចក្តីសម្រេចក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

# ជំពូកទី៥

# ការយល់ដឹងអំពីបរិស្ថាននិងមេត្រីបរិស្ថាន

## ផ្នែកទី១

## ការផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន

**មាត្រា៧៤៤ ._ កម្មវិធីផ្សព្វផ្សាយចំណេះដឹងបរិស្ថាន**

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធត្រូវមានផែនការសកម្មភាព និងកម្មវិធីផ្សព្វផ្សាយចំណេះដឹងអំពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

**មាត្រា៧៤៥ ._ សកម្មភាពផ្សព្វផ្សាយចំណេះដឹងបរិស្ថាន**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាពជំនាញមានសមត្ថកិច្ច គ្រឹះស្ថានសាធារណៈ វិស័យឯកជន និងអ្នកពាក់ព័ន្ធ មានភារកិច្ចនិងភារកិច្ចផ្សព្វផ្សាយគោលនយោបាល យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងចំណេះដឹងពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព។

**មាត្រា៧៤៦ ._ ការចូលរួមលើកកម្ពស់ការយល់ដឹងបរិស្ថាន**

ពលរដ្ឋគ្រប់រូបត្រូវមានករណីយកិច្ចចូលរួមលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីភាពចាំបាច់ និងសារប្រយោជន៍នៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## មេត្រីបរិស្ថាន

### មាត្រា៧៤៧ ._ ការទទួលស្គាល់និងលើកទឹកចិត្តប្រតិបត្តិមេត្រីបរិស្ថាន

បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវទទួលស្គាល់ និងលើកទឹកចិត្ត។

### មាត្រា៧៤៨ ._ សមត្ថកិច្ចផ្តល់ការទទួលស្គាល់និងលើកទឹកចិត្ត

ការទទួលស្គាល់និងការលើកទឹកចិត្តដល់បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ដែលរៀបចំដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

### មាត្រា៧៤៩ ._ ការប្រឡងប្រណាំងមេត្រីបរិស្ថាន

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវជានាទិផ្តួចផ្តើមនៃការរៀបចំឱ្យមានកម្មវិធីប្រឡងប្រណាំង និងលើកទឹកចិត្តដល់បុគ្គល ដែលបានប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាននិងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន។

## ផ្នែកទី៣
## សាលាមេត្រីបរិស្ថាន

### មាត្រា៧៥០ ._ សាលាមេត្រីបរិស្ថាន

១- កម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាន ត្រូវបានដាក់ឱ្យអនុវត្ត និងប្រឡងប្រជែងគ្នារៀងរាល់២(ពីរ)ឆ្នាំម្តង ដើម្បីលើកទឹកចិត្តដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ មានជាអាទិ៍ បឋមសិក្សា និងមធ្យមសិក្សាឱ្យ៖

- ក- បង្កើតគោលការណ៍ និងរដ្ឋបាលរបស់សាលាលើការងារបរិស្ថាន។
- ខ- បង្កើតការបង្រៀនមេរៀនបរិស្ថាន និងសកម្មភាពអប់រំបរិស្ថានក្នុងសាលា និងតំបន់ដែលនៅជុំវិញជាកម្មវិធីសិក្សាបន្ថែម ឬបញ្ជ្រាប។
- គ- ដាក់ឱ្យមាននូវសម្ភារៈបរិក្ខារអប់រំបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធនានា និងការប្រតិបត្តិបរិស្ថានក្នុងគ្រឹះស្ថានសិក្សាចំណេះទូទៅ។
- ឃ- សហការជាមួយភាគីពាក់ព័ន្ធ និងផ្សព្វផ្សាយពីការអប់រំបរិស្ថាន និងការប្រតិបត្តិបរិស្ថាននៅតាមតំបន់ដែលនៅជុំវិញគ្រឹះស្ថានសិក្សាចំណេះទូទៅ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យអប់រំ យុវជន និងកីឡាមានភារកិច្ច ដឹកនាំ គ្រប់គ្រង វាយតម្លៃ និងសម្រេចលើរាល់កិច្ចការដែលពាក់ព័ន្ធនឹងកម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាននេះ។

### មាត្រា៧៥១ ._ សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលារមេត្រីបរិស្ថាន

គ្រឹះស្ថានសិក្សានីមួយៗ ដែលជាបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាននឹងត្រូវបានវាយតម្លៃលើសូចនាករចំនួន១៨(ដប់ប្រាំបី)មានជាអាទិ៍៖

- ក- ទស្សនវិស័យនិងបេសកកម្មដែលឆ្លុះបញ្ចាំងអំពីការលើកស្ទួយបរិស្ថាន។
- ខ- គោលការណ៍ប្រតិបត្តិបរិស្ថាន។

គ- រចនាសម្ព័ន្ធដឹកនាំ ការអនុវត្តកម្មវិធី សាលាមេត្រីបរិស្ថាន។
ឃ- ផែនការថវិកាសម្រាប់អនុវត្តសកម្មភាពបរិស្ថាន។
ង- ប្រព័ន្ធរាយការណ៍ សកម្មភាពបរិស្ថាន និងហិរញ្ញវត្ថុ។
ច- កម្មវិធីសិក្សាគោលនិងបន្ថែមឬបញ្ជ្រាប ដែលបានដាក់បញ្ចូលមេរៀនស្តីពីការអប់រំបរិស្ថាន។
ឆ- ការកសាងសមត្ថភាពគ្រូបង្រៀនពីបរិស្ថាននិងធនធានធម្មជាតិ។
ជ- មេរៀននិងសកម្មភាពរៀនដែលសមស្របទៅនឹងបរិបទក្នុងស្រុកនិង/ឬតំបន់។
ឈ- សម្ភារៈឧបទេសបង្រៀនទាក់ទងនឹងបរិស្ថាន។
ញ- ក្រុមការងារ សកម្មភាព ដែលផ្សព្វផ្សាយអប់រំពីបរិស្ថាន។
ដ- បរិក្ខារប្រើប្រាស់ដែលធ្វើឱ្យមានមេត្រីភាពបរិស្ថាន។
ឋ- ការច្នៃប្រឌិតនិងការបង្កើតគំនិតសកម្មភាពថ្មីដែលមានមេត្រីភាពបរិស្ថាន។
ឌ- ទីផ្លាបៃតង ផ្ទៃបៃតង។
ឍ- សម្ភារៈឧបទេស សម្រាប់ការអនុវត្តផ្ទាល់នៅក្រៅថ្នាក់។
ណ- ការប្រតិបត្តិសកម្មភាពមេត្រីភាពបរិស្ថាន ឥរិយាបថរបស់សិស្សក្នុងការចូលរួមអនុវត្តមេត្រីភាពបរិស្ថាន។
ត- ដៃគូសហការនិងភាគីពាក់ព័ន្ធ។
ថ- កម្រិតនៃភាពជាដៃគូនិងការគាំទ្រ។
ទ- សកម្មភាពផ្សព្វផ្សាយតាមតំបន់។

**មាត្រា៧៥២ ._ សកម្មភាពសាលាមេត្រីបរិស្ថាន**

បន្ថែមពីលើសូចនាករ ដូចមានចែងក្នុងមាត្រា៧៥១(សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាន)នៃក្រមនេះ ការវាយតម្លៃលើបេក្ខភាពជ័យលាភីនៃពានរង្វាន់សាលាមេត្រីបរិស្ថាន នឹងត្រូវគិតផងដែរទៅលើសកម្មភាពផ្សេងទៀត មានជាអាទិ៍៖

ក- ការដាំស្មៅ ដាំដើមឈើ និងបន្លែ។
ខ- ការកាត់បន្ថយ ការបញ្ឈប់ការប្រើប្រាស់ថាមពលតន្ទនៈ ហ្វូស៊ីលមកប្រើប្រាស់ថាមពលស្អាតដោយការប្រើប្រាស់ថាមពលកកើតឡើងវិញ។
គ- ការសន្សំសំចៃទឹក។
ឃ- ការគ្រប់គ្រងសំណល់ដោយត្រូវបែងចែកតាមប្រភេទសំណល់ និងត្រូវកាត់បន្ថយសំណល់ប្រើសំណល់ឡើងវិញ និងកែច្នៃសំណល់ឡើងវិញ។
ង- ហាមការលក់ចំណីអាហារ ដែលមានរសជាតិ ពណ៌ ក្លិនសិប្បនិម្មិត ក្នុងបរិវេណសាលា។
ច- ហាមការប្រើប្រាស់ថង់ប្លាស្ទិច ក្នុងការវេចខ្ចប់ចំណីអាហារ និងភេសជ្ជៈនៅតាមតូបលក់ចំណីអាហារក្នុងបរិវេណសាលា។
ឆ- សម្អាតបន្ទប់រៀននិងបង្គន់ជាប្រចាំ ធានានូវអនាម័យល្អនិងសុខភាព។
ជ- ផ្សព្វផ្សាយទិវាភពផែនដី ទិវាគ្មានថង់ប្លាស្ទិច ទិវារុក្ខទិវា ជាអាទិ៍។
ឈ- ផ្តល់រង្វាន់ដល់សិស្ស ដែលមានស្នាដៃនិងប្រតិបត្តិការងារអប់រំបរិស្ថានបានល្អ ។
ញ- ការប្រកួតសិល្បៈបរិស្ថាន ដូចជាការបង្ហាញម៉ូតដែលប្រើសម្ភារៈ កែច្នៃឡើងវិញ ការប្រកួតរូបថត និងការប្រកួតគំនូរ ជាដើម។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា៧៥៣ ._ ពានរង្វាន់សាលាមេត្រីបរិស្ថាន**

១- ពានរង្វាន់ត្រូវបានចែកជាបីផ្នែក មានជាអាទិ៍៖

ក- ពានរង្វាន់មាសមានសុពលភាព៤(បួន)ឆ្នាំ។

ខ- ពានរង្វាន់ប្រាក់មានសុពលភាព២(ពីរ)ឆ្នាំ។

គ- ពានរង្វាន់សំរិទ្ធិមានសុពលភាព២(ពីរ)ឆ្នាំ។

២- ម្ចាស់ជ័យលាភីពានរង្វាន់មិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតប្រជែង ពានរង្វាន់សាលាមេត្រីទៀតទេ ដរាបណាពានរង្វាន់របស់ខ្លួននៅមានសុពលភាព។

## គន្ថីទី៨

## វិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃនិងមូលនិធិផ្នែកបរិស្ថាន

## មាតិកាទី១

## វិធានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៥៤ ._ គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់អំពីវិធាន នីតិវិធី នៃការគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម ដែលគាំទ្រដល់វិស័យបរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

**មាត្រា៧៥៥ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះវិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន និងសង្គម ដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាល រួមបញ្ចូលទាំងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៧៥៦ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការរៀបចំ កំណត់វិធានការសេដ្ឋកិច្ច មូលនិធិហិរញ្ញវត្ថុ កម្រៃពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ។

**មាត្រា៧៥៧ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

ក- ធ្វើការសម្របសម្រួលការងារហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធវិស័យបរិស្ថាននិងធនធានធម្មជាតិជាមួយស្ថាប័នពាក់ព័ន្ធ។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគោលការណ៍ហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ- ទទួលខុសត្រូវ និងសម្របសម្រួលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំស្របតាមគោលនយោបាយ និងផែនការរបស់រាជរដ្ឋាភិបាល។

ឃ- តាមដាន និងវាយតម្លៃការអនុវត្តគម្រោងផែនការថវិកា។

ង- រៀបចំរបាយការណ៍ថវិកា និងវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

ច- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តប្រមូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម។

ឆ- គ្រប់គ្រង និងប្រើប្រាស់មូលនិធិតំបន់ការពារ និងមូលនិធិទាយជ្ជទានបរិស្ថាន។

## ជំពូកទី៣

## វិធានសេដ្ឋកិច្ច

**មាត្រា៧៥៨ ._ ការវាយតម្លៃលើឱកាសនិងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដឹកនាំក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគទៅលើផ្នែកកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្ដារឡើងវិញនូវធនធានធម្មជាតិ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការរបាយការណ៍ និងលើកសំណើចំពោះវិធានសេដ្ឋកិច្ចស្របតាមគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ដើម្បីពិនិត្យ សហការ និងឯកភាពឬក្នុងករណីចាំបាច់ត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចចំពោះការលើកទឹកចិត្ត និងវិធានទាំងនេះ។

**មាត្រា៧៥៩ ._ វិធានសេដ្ឋកិច្ចដើម្បីគាំទ្រគោលនយោបាយបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរៀបចំសេចក្ដីព្រាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្ដីពីវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកពាក់ព័ន្ធនឹងសារពើពន្ធនិងកិច្ចលទ្ធកម្ម។

២- ការរៀបចំសេចក្ដីព្រាងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងត្រូវរៀបចំឱ្យមានវិធានសេដ្ឋកិច្ចពាក់ព័ន្ធនឹង៖

ក- ការដាក់បញ្ចូលស្តង់ដារពាក់ព័ន្ធការអនុវត្តការងារបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យទៅក្នុងការធ្វើសេចក្ដីសម្រេចរបស់នីតិបុគ្គលពីវិស័យធុរកិច្ច និងហិរញ្ញវត្ថុ។

ខ- ការវិនិយោគលើវិស័យឯកជនពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ។

គ- ការកាត់បន្ថយការធ្វើអាជីវកម្មលើព្រៃឈើ ធនធានធម្មជាតិ និងការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ឃ- ការផលិតត្បូងនិងខ្សាច់ដោយនិរន្តរភាព។

ង- វារីវប្បកម្មនិងនេសាទដោយនិរន្តរភាព។

ច- ការអភិរក្សទឹកសាប មានជាអាទិ៍ ការលើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធផល និងការស្រាវជ្រាវដើម្បីការពារនិងគ្រប់គ្រងគុណភាពទឹក និងកាត់បន្ថយការបញ្ចេញសំណល់ទឹកកខ្វក់ និងសំណល់រាវ។

ឆ- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍មានជាអាទិ៍ ការលើកលែងអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតលើប្រាក់ចំណូល ប្រាក់កម្រៃ មូលនិធិ ឬប្រាក់រួមវិភាគទានផ្សេងៗ ដែលទទួលបានពីការអនុវត្តការគ្រប់គ្រងរួមគ្នា។

ជ- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ អគ្គិសនីខ្នាតតូច។

ឈ-ការលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធថាមពលពីប្រភពកកើតឡើងវិញ មានជាអាទិ៍ ព្រះអាទិត្យ ខ្យល់ ទឹក និងរលកសមុទ្រ និងគ្រឿងជំរឿងដទៃទៀត។

ញ- ការប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលមានប្រសិទ្ធផលធនធាន និងមានការបញ្ចេញកាបូនតិច និងការកាត់បន្ថយការបំពុលបរិស្ថាន និងសុខភាពសាធារណៈ។

ដ- ការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានប្រសើរបំផុត ដែលបានពិសោធនិងផ្ទៀងផ្ទាត់រួច។

ឋ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាក្នុងគោលបំណងការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។

ឌ- ការបែងចែកដោយសមធម៌នូវប្រាក់ចំណូលបានមកពីយន្តការទូទាត់ការបញ្ចេញកាបូនដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ឍ- ការបង់ថ្លៃលើការផលិត ឬការថែទាំសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីទៅកាន់រូបវន្តបុគ្គល និងសហគមន៍ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ណ- ការលើកកម្ពស់ការនាំចូល ការទិញយានយន្តមេត្រីបរិស្ថាន និងទប់ស្កាត់ការនាំចូលយានយន្ត ដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន និងសុខភាពសាធារណៈ។

ត- ការលើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ ការគាំទ្រដល់ការប្រើប្រាស់ក្នុងធុរកិច្ចនូវប្រភពថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលធ្វើពាណិជ្ជកម្មជំរឿង ឬផ្គត់ផ្គង់ផ្នែកបច្ចេកទេស ឬថែទាំឧបករណ៍ថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល ដែលមានលក្ខណសម្បត្តិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធសុខភាព សុវត្ថិភាព និងបរិស្ថាន និងការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល។

ថ- ការអភិរក្ស និងកិច្ចគាំពារបេតិកភណ្ឌវប្បធម៌។

ទ- ការអភិរក្សថាមពល តាមរយៈការបង្កើនចំហេះ និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ចំពោះការបាត់បង់ថាមពល ការកែច្នៃសំណល់ថាមពល ការជំនួសមកវិញនូវថាមពលកកើតឡើងវិញ និងមធ្យោបាយនានានៃការអភិរក្សថាមពល ដែលបានកំណត់ដោយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ធ- វិធានការសេដ្ឋកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៦០ ._ សំណើសម្រាប់ក្រុមហ៊ុនឯកជនឬសាធារណៈ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច អាចចេញលិខិតអនុញ្ញាតចំពោះសំណើរបស់ក្រុមហ៊ុនឯកជន ឬសាធារណៈដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៨៥

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចតម្រូវឱ្យក្រុមហ៊ុនដាក់សំណើសុំដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ដាក់បញ្ចូលភស្តុតាងនិងឯកសារគាំទ្រដែលបញ្ជាក់ពីធនធាន និងស្ថានភាពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់ប្រភពដោយនិរន្តរភាព ការបង្ហាញពីការចូលរួមភាគទានរបស់គម្រោងចំពោះការអភិវឌ្ឍប្រកបដោយចីរភាពដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសមត្ថភាពក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដែលកំពុងតែដំណើរការ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវអនុវត្តតាមដំណើរការនៃកិច្ចលទ្ធកម្មដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំនៃគោលនយោបាយពាក់ព័ន្ធនានាស្តីពីក្រុមហ៊ុនឯកជន ឬសាធារណៈ។

## ជំពូកទី៤

## វិធានហិរញ្ញវត្ថុ

**មាត្រា៧៦១ .– ការបង់ថ្លៃរាល់ប្រភេទចំណូល**

ការបង់ថ្លៃរាល់ប្រភេទចំណូលទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះត្រូវបង់ចូលគណនីទោលរតនាគារ ឬធនាគារដៃគូតាមការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការព្រមព្រៀងដោយឡែករវាងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៧៦២ .– ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំយន្តការកំណត់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីទៅឱ្យបុគ្គល ដែលបានចូលរួមចំណែកក្នុងការត្រួតពិនិត្យ ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រសើរបំផុត ដែលស្វែងរកបានពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលបានវាយតម្លៃរួចរាល់។

**មាត្រា៧៦៣ .– កិច្ចសហប្រតិបត្តិការរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច**

ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវគាំទ្រនិងសហការ ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីរៀបចំអនុវត្តនិងគ្រប់គ្រងយន្តការ ដូចមានចែងក្នុងមាត្រា៧៦២(ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី)នៃក្រមនេះ។

## មាតិកាទី២

## ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម

## ជំពូកទី១

## ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន

**មាត្រា៧៦៤ .– ការទទួលខុសត្រូវក្នុងការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន**

បុគ្គលត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ បុព្វលាភបរិស្ថាន ឬថ្លៃផ្សេងទៀតស្របតាមប្រកាសអន្តរក្រសួងរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៦៥ .– ការរៀបចំប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីចំនួន

ទឹកប្រាក់ នីតិវិធីនៃការគ្រប់គ្រង និងការលើកលែងការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថានណាមួយ ដែលពាក់ព័ន្ធនឹងក្រមនេះ មានជាអាទិ៍៖

ក- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- យន្តការគ្រប់គ្រងនិងនិរន្តរភាពបរិស្ថាន។

គ- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ឃ- ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ។

ង- ការគ្រប់គ្រងសំណល់និងការបំពុលបរិស្ថាន។

ច- ការអប់រំនិងការយល់ដឹងពីបរិស្ថាន។

ឆ- ការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ។

ជ- វិស័យពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៦៦ ._ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចអាចតម្រូវឱ្យបុគ្គលដែលមានកាតព្វកិច្ចបង់ប្រាក់កម្រៃ សួយសារ បុព្វលាភ ឬថ្លៃផ្សេងទៀត ផ្តល់ការធានា ផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការបង់ថ្លៃទាំងនេះនៅមុនពេលទទួលបានសិទ្ធិអនុវត្តសកម្មភាពឬគម្រោងជាផ្លូវការ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណវិនិច្ឆ័យ និងនីតិវិធីសម្រាប់ការធានាចំពោះការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ។

## ជំពូកទី២
## ការបង់និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម
### ផ្នែកទី១
### ការបង់មូលនិធិបរិស្ថាន

**មាត្រា៧៦៧ ._ ការបង់មូលនិធិទាយជ្ជទានបរិស្ថាន**

បុគ្គលត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

**មាត្រា៧៦៨ ._ ការបង់មូលនិធិតំបន់ការពារធម្មជាតិ**

បុគ្គលត្រូវបង់មូលនិធិតំបន់ការពារធម្មជាតិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីយន្តការនិងការប្រើប្រាស់មូលនិធិតំបន់ការពារធម្មជាតិនិងបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

**មាត្រា៧៦៩ ._ ការបង់មូលនិធិបរិស្ថាននិងសង្គម**

បុគ្គលត្រូវបង់មូលនិធិបរិស្ថាននិងសង្គមស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



ហ

## ផ្នែកទី២
## មូលនិធិបរិស្ថាននិងសង្គម

**មាត្រា៧៧០ .- ប្រភពចំណូលនៃមូលនិធិបរិស្ថាននិងសង្គម**

មូលនិធិបរិស្ថាននិងសង្គមមានប្រភពចំណូលមកពីៈ

ក- ទុនដំបូងរបស់រាជរដ្ឋាភិបាល។

ខ- ភាគទានបានមកពីអាករពិសេសពាក់ព័ន្ធវិស័យបរិស្ថានតាមការកំណត់របស់រាជរដ្ឋាភិបាល។

គ- ភាគទានបានមកពីកម្រៃសេវាវិស័យអាកាសចរស៊ីវិលតាមការកំណត់របស់រាជរដ្ឋាភិបាល។

ឃ- បុព្វលាភបានមកពីម្ចាស់គម្រោងអភិវឌ្ឍឯកជននិងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬកិច្ចសន្យាការពារបរិស្ថាន។

ង- ប្រាក់ចំណូលបានមកពីកិច្ចគាំពារបរិស្ថាន សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងអភិរក្សជីវៈចម្រុះ។

ច- ភាគទានបានមកពីមូលនិធិទាយជ្ជទានបរិស្ថាន។

ឆ- ភាគទានបានមកពីមូលនិធិតំបន់ការពារធម្មជាតិ។

ជ- ភាគទានបានមកពីកម្រៃសេវាលក់សំបុត្រចូលទស្សនាតំបន់ការពារធម្មជាតិ។

ឈ- កម្រៃសេវាកម្មជួលទីតាំងដំឡើងបង្គោលអង់តែន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ញ- ភាគទានបានមកពីកម្រៃសេវាកម្មជួលទីតាំងដំឡើងបណ្តាញអគ្គិសនី និងបណ្តាញកាបអុបទិក ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ដ- ភាគទានបានមកពីកម្រៃជួលទីតាំងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិទំហំក្រោម១០(ដប់)ហិកតា ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឋ- ភាគទានបានមកពីការលក់ឥណទានកាបូន។

ឌ- ប្រាក់ដែលបានមកពីការដោះស្រាយបណ្តឹងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ឍ- អំណោយឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា។

ណ- ភាគទានបានមកពីកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងវិស័យបរិស្ថាន។

ត- ប្រភពផ្សេងៗទៀត។

**មាត្រា៧៧១ .- ការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម**

មូលនិធិបរិស្ថាននិងសង្គមត្រូវប្រើប្រាស់ក្នុងសកម្មភាពដូចខាងក្រោមៈ

ក- កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព។

ខ- ការស្តារបរិស្ថាននិងការកែលម្អធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីឡើងវិញ។

គ- ការសិក្សាស្រាវជ្រាវលើបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ឃ- ការចូលរួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលនៅក្នុងនិងក្បែរតំបន់គម្រោងវិនិយោគឬតំបន់ផ្សេងទៀត។

ង- ការចូលរួមគាំទ្រដល់ការរៀបចំបង្កើតនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន។

ច- ការចូលរួមគម្រោងអភិវឌ្ឍសហគមន៍មូលដ្ឋាន រួមទាំងការផ្តល់ឥណទានខ្នាតតូចជាលក្ខណៈទុនបង្វិល។

ច- ការអប់រំនិងផ្សព្វផ្សាយអំពីបរិស្ថាន ធនធានធម្មជាតិនិងវប្បធម៌ ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

ជ- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឈ-សកម្មភាពផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៧២ ._ គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម**

១- មូលនិធិបរិស្ថាននិងសង្គមត្រូវគ្រប់គ្រងដោយគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមដែលបង្កើតឡើងដោយអនុក្រឹត្យ។

២- តួនាទី ភារកិច្ច និងសមាសភាពរបស់គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

៣- គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមត្រូវរៀបចំយុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងមូលនិធិរយៈពេលវែង។ យុទ្ធសាស្ត្រនេះ ត្រូវដាក់បញ្ចូលការពិចារណាលើវិធីសាស្ត្រលទ្ធកម្ម ការគ្រប់គ្រងមូលនិធិ មានជាអាទិ៍ មូលធនកម្ម ការវិនិយោគ វិធានការរដ្ឋបាល វិធានការផ្លូវច្បាប់ និងគោលនយោបាយពាក់ព័ន្ធដទៃទៀត។ គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការគ្រប់គ្រងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គមត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ការចំណាយពាក់ព័ន្ធការបំពេញភារកិច្ច និងតួនាទីរបស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## ការបង្កើតនិងការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន

**មាត្រា៧៧៣ ._ សិទ្ធិរបស់បរធនបាលទាយក**

បរធនបាលទាយកមានសិទ្ធិជាអាទិ៍៖

ក- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច មានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ខ- តែងតាំងនិងបញ្ឈប់បរធនបាលស្របតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា៧៧៤ ._ កាតព្វកិច្ចរបស់បរធនបាលទាយក**

១- បរធនបាលទាយកមានកាតព្វកិច្ចជាអាទិ៍៖

ក- ផ្ទេរទ្រព្យសម្បត្តិឬមូលនិធិបរធនទៅឱ្យបរធនបាល គ្រប់គ្រង និងចាត់ចែងជំនួសសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ។

ខ- ចូលរួមសម្របសម្រួលក្នុងកិច្ចការផ្ទេរបរធនឱ្យទៅបរធនបាលគ្រប់គ្រងនិងចាត់ចែង។

គ- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំពោះការផ្លាស់ប្តូរបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬការកែប្រែលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

ឃ- អនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាពឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារមួយចំនួន ជាបរធនបាលទាយកជំនួស។

**មាត្រា៧៧៥ .– សិទ្ធិរបស់អត្ថគាហកៈ**

១- អត្ថគាហកៈមានសិទ្ធិជាអាទិ៍៖

ក- ទទួលអត្ថប្រយោជន៍ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

ខ- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច និងតាមបទប្បញ្ញត្តិជាធរមាន។

គ- ទទួលព័ត៌មានពាក់ព័ន្ធការគ្រប់គ្រងនិងចាត់ចែងនៃបរធនបាលកិច្ច។

ឃ- មានសិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិជាធរមាន។

២- អត្ថគាហកៈអាចទទួលផលពីបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ច លើកលែងតែមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣- ក្នុងករណីដែលមានអត្ថគាហកៈច្រើន អត្ថគាហកៈទាំងនេះអាចទទួលផលដូចគ្នា ឬផ្សេងៗពីគ្នាតាមរបៀប ឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។ ក្នុងករណីដែលគ្មានរបៀប ឬវិធីទទួលផលត្រូវសន្មតថាអត្ថគាហកៈទាំងនេះទទួលផលស្មើៗគ្នា។

**មាត្រា៧៧៦ .– សិទ្ធិរបស់បរធនបាល**

បរធនបាលមានសិទ្ធិជាអាទិ៍៖

ក- ទទួលលាភការប្រូកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ចដែលអាចប្រែប្រួលទៅតាមបទពិសោធការងារ និង/ឬគុណវឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន។

ខ- ស្វែងរកជំនួយឬមូលនិធិផ្សេងៗ និងឱកាសវិនិយោគបន្ថែមដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ច។

គ- តំណាងឱ្យបរធនបាលទាយកឬអត្ថគាហកៈនៅចំពោះមុខច្បាប់ឬអាជ្ញាធរមានសមត្ថកិច្ច។

ឃ- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ង- គ្រប់គ្រងនិងចាត់ចែងបរធនតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

ច- ចំណាយក្នុងសកម្មភាពសង្គមស្របតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

**មាត្រា៧៧៧ .– កាតព្វកិច្ចរបស់បរធនបាល**

បរធនបាលមានកាតព្វកិច្ចជាអាទិ៍៖

ក- ដាក់ពាក្យចុះបញ្ជីបរធនតាមបែបបទនិងនីតិវិធីរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ- រាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ។

គ- រក្សាកំណត់ហេតុនៃកិច្ចប្រជុំសម្រាប់ការគ្រប់គ្រងគណនីប្រចាំឆ្នាំ។

ឃ- ឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ។

ង- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច។

ច- ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ចនិងអត្ថគាហកៈ។

ឆ- ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងមុខងារជាបរធនបាល។

ជ- បរធនបាលមិនអាចផ្ទេរមុខងាររបស់ខ្លួនឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឈ-បែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងទ្រព្យសម្បត្តិបរធនបាលកិច្ច។
ញ- គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយយកចិត្តទុកដាក់និងដោយប្រុងប្រយ័ត្ន។
ដ- រក្សាភាពស្មោះត្រង់និងសុចរិតក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច។
ឋ- គ្រប់គ្រងនិងចាត់ចែងលើទ្រព្យសម្បត្តិបរធនបាលកិច្ចឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ដើម្បីជាប្រយោជន៍របស់អត្ថគាហកៈ។
ឌ- ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិបរធនបាលកិច្ច។
ឍ- ផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធ និងទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
ណ- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍។
ត- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា៧៧៨ .– ការទទួលខុសត្រូវរបស់បរធនបាល**

បរធនបាលត្រូវទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោម៖
ក- ការធ្វើឱ្យបាត់បង់និងថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ។
ខ- ការប្រើប្រាស់បរធនខុសពីបំណងបរធនបាលកិច្ច។
គ- កំហុសដែលបានប្រព្រឹត្តដោយចេតនាឬអចេតនាក្នុងការបំពេញការងាររបស់ខ្លួន។
ឃ- ការចំណាយណាមួយផ្ទុយពីបំណងបរធនបាលកិច្ច។
ង- ចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់និងប្រយោលដែលនាំឱ្យប៉ះពាល់ឬខូចខាតដល់ប្រយោជន៍របស់បរធនបាលកិច្ច។
ច- ការទទួលខុសត្រូវផ្សេងទៀតតាមលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា៧៧៩ .– ការបង្កើត ការលុបចោល និងគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានត្រូវបានបង្កើតឡើងស្របតាមនីតិវិធីនិងទម្រង់ដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បរធនបាលទាយកដែលមានបំណងបង្កើតឬធ្វើប្រតិបត្តិការបរធនបាលកិច្ចបរិស្ថានត្រូវរៀបចំលិខិតបរធនបាលកិច្ច និងចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីបរធនបាលកិច្ច។

២- បរធនបាលទាយកអាចធ្វើដោយខ្លួនឯងឬដោយសហការជាមួយសមាគមក្នុងស្រុក ឬសមាគមបរទេស ដើម្បីបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ច។

៣- បរធនបរិស្ថានអាចលុបចោលបានស្របតាមលក្ខខណ្ឌដែលបានកំណត់។

៤- បរធនបាលកិច្ចបរិស្ថានត្រូវប្រើប្រាស់សម្រាប់សកម្មភាព ដែលបានកំណត់ជាអាទិភាពនៅក្នុងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងគោលបំណង៖
ក- គាំពារ អភិរក្ស និងស្តារឡើងវិញនូវបរិស្ថាននិងធនធានធម្មជាតិ។
ខ- ការពារបេតិកភណ្ឌវប្បធម៌ឬជីវៈចម្រុះ។
គ- លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។
ឃ- លើកកម្ពស់ការស្រាវជ្រាវនិងការអប់រំបរិស្ថាន។
ង- អភិវឌ្ឍសមត្ថភាពឬពង្រឹងស្ថាប័ន។

ច- គាំទ្រទៅលើសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ។

ឆ- ជាប្រយោជន៍សាធារណៈនិងសម្រាប់ផលប្រយោជន៍បរិស្ថាន ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៨០ .– ការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានមានជាអាទិ៍ បរធនសម្រាប់គាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យសមស្រប មាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព និងទម្រង់ផ្សេងទៀតនៃការបែងចែកផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- បរធនបាលកិច្ចបរិស្ថានត្រូវបានគ្រប់គ្រងដោយបរធនបាលតាមរយៈការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដែលជាបរធនពីបរធនបាលទាយកទៅឱ្យបរធនបាល ដើម្បីគ្រប់គ្រងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈស្របតាមការកំណត់របស់បរធនបាលទាយក។

**មាត្រា៧៨១ .– លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងនិងការត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយសម្របសម្រួលជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីវិធាននិងនីតិវិធីសម្រាប់ការបង្កើត គ្រប់គ្រងនិងត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន និងគណនីមូលនិធិនេះ។

**មាត្រា៧៨២ .– ការចុះបញ្ជីនៃបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានមានសុពលភាពលុះត្រាតែបានចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ចបរិស្ថាន។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើសេចក្តីសម្រេចលើពាក្យស្នើសុំចុះបញ្ជីនេះក្នុងរយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី។

២- បែបបទនិងនីតិវិធីស្តីពីការចុះបញ្ជីបរធនបាលកិច្ចបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧៨៣ .– ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន**

១- ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានអាចបង្កើតមកពី៖

ក- ថវិកាជាតិ។

ខ- ជំនួយអភិវឌ្ឍជាផ្លូវការដែលបានផ្តល់ឱ្យដោយអង្គការជាតិនិងអន្តរជាតិ។

គ- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ឃ- សេវាកម្មគ្រប់គ្រងធនធានធម្មជាតិ។

ង- អំណោយផ្ទាល់ពីវិស័យឯកជន សប្បុរសជន និងប្រភពផ្សេងៗទៀត។

២- ប្រយោជន៍ទាំងអស់ដែលកើតចេញពីបរធនបាលកិច្ចបរិស្ថានត្រូវបង្ចូលនិងត្រូវបង្កើតជាផ្នែកនៃបរធនបាលកិច្ចបរិស្ថាន។

**មាត្រា៧៨៤ .– ទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថាន**

១- ក្នុងកំលុងពេលបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន បរធនបាលត្រូវរាយការណ៍អំពីទំនាស់ផលប្រយោជន៍ទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ក្នុងករណីដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភស្តុតាងនិងហេតុផលគ្រប់គ្រាន់ ដែលអាចជឿជាក់ថាបរធនបាលកំពុងតែប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថានឬកំពុងតែប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍បរិស្ថានឬសាធារណៈ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសម្របសម្រួលជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតទៅលើបញ្ហានេះ។

៣- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវព្យួរមុខងាររបស់បរធនបាល ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា បរធនបាលមានទំនាស់ផលប្រយោជន៍ជាមួយនឹងបរធនបាលកិច្ចរបស់ខ្លួន។ ក្នុងករណីនេះ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវតែងតាំងបរធនបាលបណ្តោះអាសន្នដោយគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមនេះនិងស្របតាមលិខិតបរធនបាលកិច្ច។

**មាត្រា៧៨៥ .- បញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលសាធារណជនអាចស្វែងរកបាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរក្សាទុកបញ្ជីរបាយការណ៍ប្រចាំឆ្នាំនៃគ្រប់បរធនបាលកិច្ចបរិស្ថានដែលអាចឱ្យសាធារណជនស្វែងរកបាន។

**មាត្រា៧៨៦ .- ការប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន**

បរធនបាលអាចប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដើម្បី៖

ក- ផ្តល់មូលនិធិដល់សកម្មភាពឬគម្រោងនានាដែលបំពេញតាមគោលបំណងនៃបរធនបាលកិច្ចបរិស្ថានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ខ- បង់ថ្លៃលើប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថានដែលមានជាអាទិ៍ លាភការរបស់បរធនបាលនិងថ្លៃចំណាយនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន។

គ- ចំណាយទៅលើសកម្មភាពសង្គមស្របតាមគោលបំណងនៃលិខិតបរធនបាលកិច្ច។

ឃ- ធ្វើការបណ្តាក់ទុនលើការវិនិយោគនិងមូលបត្រដែលទទួលខុសត្រូវផ្នែកបរិស្ថាននិងសង្គម។

**មាត្រា៧៨៧ .- ការបញ្ចប់បរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

ខ- ការសម្រេចគោលបំណងរបស់បរធនបាលកិច្ច។

គ- ការសម្រេចដោយឆន្ទានុសិទ្ធិឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក។

ឃ- តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច។

ង- តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលបាននូវការជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការបញ្ចប់បរធនបាលកិច្ចនេះ។

**មាត្រា៧៨៨ .- ការចាត់តាំងអភិបាលបណ្តោះអាសន្ន**

បរធនបាលទាយកឬបរធនបាលទាយកជំនួស មានសិទ្ធិចាត់តាំងអភិបាលបណ្តោះអាសន្នសម្រាប់គ្រប់គ្រងបរធនបាលកិច្ច ក្នុងករណីយល់ឃើញថាមានហានិភ័យលើសាធនភាពលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា៧៨៩ .– ការជ្រើសតាំងអ្នកជម្រះបញ្ជី**

១- ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់បរធនបាលទាយកឬបរធនបាលទាយកជំនួសត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី ដែលមានវិជ្ជាជីវៈដើម្បីគ្រប់គ្រងនិងវាយតម្លៃបរធននោះ។ អ្នកជម្រះបញ្ជីត្រូវមានភារកិច្ចដូចខាងក្រោម៖

ក- បំពេញនិងបញ្ចប់កិច្ចការដែលនៅសល់របស់បរធនបាល។

ខ- ប្រមូលនិងសងបំណុលដែលនៅសល់។

គ- វាយតម្លៃបរធនដែលនៅសល់។

២- នៅពេលបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះរួចរាល់ហើយ អ្នកជម្រះបញ្ជីត្រូវផ្តល់នូវគណនេយ្យចុងក្រោយនិងរបាយការណ៍ឱ្យទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ត្រូវបែងចែកស្របតាមលិខិតបរធនបាលកិច្ចបរិស្ថាន។

៣- ប្រាក់កម្រៃសម្រាប់អ្នកជម្រះបញ្ជីត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃអត្រាវិជ្ជាជីវៈស្តង់ដារនិងត្រូវបង់ដោយកាត់យកចេញពីបរធនបាលកិច្ចបរិស្ថាន។

**មាត្រា៧៩០ .– អានុភាពនៃការបញ្ចប់បរធនបាលកិច្ចបរិស្ថាន**

១- បន្ទាប់ពីបានជម្រះបញ្ជីបរធនបាលកិច្ចបរិស្ថាន បរធនបាលត្រូវ៖

ក- ផ្ទេររាល់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ ស្របតាមលក្ខខណ្ឌនៃបរធនបាលកិច្ចបរិស្ថាន។

ខ- ផ្ទេរទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានទាំងអស់ ទៅអត្ថគាហកៈដែលនៅមានជីវិតរស់នៅទាំងអស់ក្នុងចំណែកស្មើៗគ្នា ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថាននោះមិនកំណត់អំពីបុគ្គល ដែលត្រូវទទួលទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាននោះទេ។

២- បន្ទាប់ពីការបញ្ចប់បរធនបាលកិច្ចបរិស្ថាន បរធនបាលនៅតែទទួលខុសត្រូវចំពោះការបាត់បង់ឬខូចខាតដែលបានបង្កឡើងឬដែលបណ្តាលមកពីកំហុសដោយចេតនា ការធ្វេសប្រហែស ការក្លែងបន្លំ ឬភាពមិនស្មោះត្រង់របស់បរធនបាល។

**មាត្រា៧៩១ .– វិវាទពាក់ព័ន្ធប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន**

១- វិវាទពាក់ព័ន្ធប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថានត្រូវដោះស្រាយ ដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយបញ្ញត្តិករពាក់ព័ន្ធ។

២- ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចដាក់បណ្តឹងរដ្ឋបាល ឬបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

៣- លទ្ធផលនៃនីតិវិធីដោះស្រាយវិវាទទាំងអស់ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន។

**មាត្រា៧៩២ .– ការគ្រប់គ្រងឬការប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប**

បរធនបាលណាដែលគ្រប់គ្រងឬប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប ឬផ្ទុយពីគោលបំណងនៃបរធនបាលកិច្ចបរិស្ថានដែលបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតស្តីពីបរធនបាលកិច្ច។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៧៩៣ ._ បរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា**

១- បរធនបាលកិច្ចបរិស្ថាន សម្រាប់ការគ្រប់គ្រងរួមគ្នាត្រូវបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់សកម្មភាពនៃការគ្រប់គ្រងរួមគ្នាដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរួមគ្នានីមួយៗ។ បរធនបាលកិច្ចបរិស្ថាននេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងរួមគ្នានៃតំបន់គ្រប់គ្រងរួមគ្នាដោយមានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ប្រកបដោយតម្លាភាពស្របតាមបញ្ញត្តិដូចមានចែងក្នុងក្រមនេះ។

២- គណៈកម្មការគ្រប់គ្រងរួមគ្នាអាចទទួលបានថវិកានិងរកចំណូលពីប្រភពដែលមានជាអាទិ៍៖

- ក- មូលនិធិសង្គមនិងបរិស្ថាន។
- ខ- ប្រភពឯកជននិងសាធារណៈផ្សេងៗ។
- គ- សេវានានា ការយកថ្លៃឈ្នួល ថ្លៃប្រើប្រាស់ ថ្លៃកម្សាន្ត ឬការយកថ្លៃចូលទស្សនាក្នុងតំបន់សហគមន៍ដែលគ្រប់គ្រងរួមគ្នាជាដើម។
- ឃ- វិភាគទាន អំណោយ និងជំនួយ។

**មាត្រា៧៩៤ ._ ការប្រើប្រាស់ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ**

១- ការប្រើប្រាស់ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗដែលទទួលបានតាមរយៈការអនុវត្តនៃការគ្រប់គ្រងរួមគ្នាត្រូវបានប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ដែលនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាសម្រាប់ការគាំទ្រដល់ការអនុវត្តលើការគ្រប់គ្រងរួមគ្នា និងសម្រាប់ការអភិរក្សនៃតំបន់គ្រប់គ្រងរួមគ្នា និងបណ្តាតំបន់នៅជាប់ដែលមានការអភិរក្ស។ វិធីសាស្ត្រច្បាស់លាស់ក្នុងការបែងចែកប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា។

២- ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗដែលទទួលបានពីការងារគ្រប់គ្រងនៃសហគមន៍គ្រប់គ្រងរួមគ្នាត្រូវទទួលអាទិភាពក្នុងការលើកលែងពន្ធអាករនិងបន្ទុកផ្សេងៗដូចបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី៤
## ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

**មាត្រា៧៩៥ ._ ធនធានហិរញ្ញវត្ថុសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន**

១- ម្ចាស់គម្រោងស្នើសុំដែលតម្រូវឱ្យមានផែនការគ្រប់គ្រងបរិស្ថានស្របតាមបទប្បញ្ញត្តិក្នុងមាតិកាទី២ (ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្ថីទី៥នៃក្រមនេះ ត្រូវផ្តល់ការធានាថាខ្លួនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងជាមុនសិន មុនពេលមានការចេញលិខិត ឬវិញ្ញាបនបត្រឯកភាពលើគម្រោងនេះ។

២- ប្រភេទនិងចំនួននៃការធានាផ្នែកហិរញ្ញវត្ថុ លក្ខណវិនិច្ឆ័យ នីតិវិធីដោះស្រាយ និងការសម្រួលដល់ការអនុវត្តរបស់ម្ចាស់គម្រោងដែលមានស្រាប់និងគម្រោងដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧៩៦ .– ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន**

១- ថវិកាលម្អិតដែលត្រូវបានប៉ាន់ប្រមាណសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ត្រូវដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន មានជាអាទិ៍៖

ក- ថវិកាសម្រាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ធនធានធម្មជាតិ និងសង្គម។

ខ- ថវិកាសម្រាប់ការអង្កេតតាមដាន។

គ- ថវិកាសម្រាប់កិច្ចដំណើរការយន្តការបណ្តឹងនិងប្រតិបត្តិការគម្រោង។

ឃ- ថវិកាសម្រាប់ទទួលខុសត្រូវដល់ការផ្លាស់ប្តូរទីតាំងនិងសំណងចំពោះបុគ្គលដែលរងផលប៉ះពាល់ដោយសារគម្រោង។

ង- ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីណាមួយដូចមានចែងក្នុងក្រមនេះ។

ច- ថវិកាសម្រាប់ការបិទការស្តារការដ្ឋាន នីតិសម្បទា ដំណោះស្រាយ ឬការបញ្ឈប់សកម្មភាពគម្រោង។

ឆ- ថវិកាបម្រុងផ្សេងទៀតពាក់ព័ន្ធការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង។

២- ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានដោយប្រើប្រាស់ថវិកាដោយខ្លួនឯង ដែលមិនមែនជាកញ្ចប់ថវិកាមូលនិធិបរិស្ថាននិងសង្គម។

**មាត្រា៧៩៧ .– នីតិវិធីនៃការធានាផ្នែកហិរញ្ញវត្ថុ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណវិនិច្ឆ័យ និងនីតិវិធីសម្រាប់កំណត់ការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដែលបានស្នើសុំមានជាអាទិ៍៖

ក- វិសាលភាពនៃការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការ។

ខ- ទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុដែលអាចទទួលយកបាន។

គ- ចំនួនទឹកប្រាក់ដែលតម្រូវឱ្យមាននៅក្នុងការធានាផ្នែកហិរញ្ញវត្ថុដោយផ្អែកលើ ទំហំ ខ្នាត ទីតាំង និងផលប៉ះពាល់ដែលអាចកើតមាន។

ឃ- ក្របខ័ណ្ឌពេលវេលាសម្រាប់ការប្តឹងចំពោះធនធានហិរញ្ញវត្ថុដែលយកមកដាក់ធានាឬបើគ្មានការប្តឹងណាមួយទេ ត្រូវដាក់ឱ្យធនធានហិរញ្ញវត្ថុនេះអាចស្វែងរកបាន។

**មាត្រា៧៩៨ .– ការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

១- ម្ចាស់គម្រោងដែលតម្រូវឱ្យផ្តល់ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍។

២- ម្ចាស់គម្រោងត្រូវធ្វើការពិនិត្យប្រចាំឆ្នាំឡើងវិញនូវការប៉ាន់ប្រមាណតម្លៃនានាពាក់ព័ន្ធផែនការគ្រប់គ្រងបរិស្ថាននិងដាក់ជូនការប៉ាន់ប្រមាណនេះមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ ការប៉ាន់ប្រមាណនេះត្រូវធ្វើឡើងដោយសវនកម្មឯករាជ្យ។

៣- ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថា ពុំមានការគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ ម្ចាស់គម្រោងត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។

៤- ម្ចាស់គម្រោងត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុដែលបានធ្វើបច្ចុប្បន្នកម្មក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីការជូនដំណឹង។

៥- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចតម្រូវឱ្យមានរបាយការណ៍ឬឯកសារបន្ថែមទៀតក្នុងករណីចាំបាច់។

៦- ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថាមានការធានាផ្នែកហិរញ្ញវត្ថុដែលលើសពីលក្ខខណ្ឌតម្រូវ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចដាក់សំណើមកក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីអនុញ្ញាតសុំបង្វិលសងមូលនិធិ ដែលលើសតាមការស្នើសុំរបស់ម្ចាស់គម្រោង។

# គន្ថីទី៩

# ការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

## មាតិកាទី១

## យន្តការនិងនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៩៩ ._ គោលបំណង**

គន្ថីនេះកំណត់អំពីយន្តការនិងនីតិវិធីសម្រាប់ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨០០ ._ វិសាលភាព**

គន្ថីនេះមានវិសាលភាពអនុវត្តលើការដោះស្រាយវិវាទទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិទៅលើពាក្យប្តឹងឬការទាមទារដូចខាងក្រោម៖

ក- ទាមទារឱ្យសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ខ- ទាមទារឱ្យស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ។

គ- ទាមទារឱ្យកំណត់វិធានការ ដើម្បីធានាថានឹងមិនបង្កការបំពុលបរិស្ថានឬធនធានធម្មជាតិឬការធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិសាជាថ្មីឡើងវិញ។

ឃ- ទាមទារឱ្យកំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតមានចំពោះបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៨០១ ._ គោលការណ៍ទូទៅនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- ចំពោះការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទនោះទៅយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដើម្បីសម្រុះសម្រួលមុននឹងប្តឹងទៅតុលាការដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប៉ុន្តែបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនរារាំងដល់ការប្រើប្រាស់សិទ្ធិក្នុងការប្តឹងទៅតុលាការដោយផ្ទាល់នោះទេ។ ក្នុងករណីចាំបាច់ តុលាការដែលទទួលពាក្យបណ្តឹងទាក់ទងនឹងវិវាទបរិស្ថាននិងធនធានធម្មជាតិអាចបញ្ជូនសំណុំរឿងនេះទៅយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដើម្បីធ្វើការសម្រុះសម្រួលជាមុន។ ក្នុងករណីដែលពុំមានដំណោះស្រាយតាមការស្រុះស្រួលគ្នា នៅចំពោះមុខយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ភាគីមានសិទ្ធិស្នើសុំឱ្យតុលាការដើម្បីបន្តអនុវត្តនីតិវិធីរបស់ខ្លួនស្របតាមច្បាប់និងនីតិវិធីជាធរមាន។

៣- ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើមិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ មិនរាំងការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអង្គហេតុដែលជាកម្មវត្ថុនៃការសម្រុះសម្រួលនេះបង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះឬច្បាប់ព្រហ្មទណ្ឌជាធរមានដទៃទៀត។

**មាត្រា៨០២ .- ភាគីនៃវិវាទបរិស្ថាននិងធនធានធម្មជាតិ**

ភាគីដែលមានសិទ្ធិធ្វើបណ្តឹងបរិស្ថាននិងធនធានធម្មជាតិមាន ដូចខាងក្រោម៖

ក- ភាគីដែលរងផលប៉ះពាល់ អាចធ្វើសកម្មភាពបណ្តឹងដើម្បីទាមទារសំណងការខូចខាតឬសំណងជំងឺចិត្ត។

ខ- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសកម្មភាពបណ្តឹង ដើម្បីទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ឬស្តារបរិស្ថានឡើងវិញ ឬទប់ស្កាត់សកម្មភាពណាមួយដែលបង្កផលប៉ះពាល់ឬបំពុលបរិស្ថាន និងខូចខាតលើធនធានធម្មជាតិ។

គ- សមាគមនិងអង្គការដែលបានចុះបញ្ជីស្របច្បាប់ និងទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចធ្វើសកម្មភាពបណ្តឹងដើម្បីបញ្ឈប់ឬទប់ស្កាត់សកម្មភាពណាមួយទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ឬទាមទារសំណងការខូចខាតឬជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍។ ប៉ុន្តែចំពោះការទាមទារសំណងការខូចខាត ឬជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍ត្រូវមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ។

## ជំពូកទី២
## យន្តការសម្រាប់ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨០៣ .- រចនាសម្ព័ន្ធគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ។

ខ- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត។

២-ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការ ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨០៤ .- សមត្ថកិច្ចរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិមានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាននិងធនធានធម្មជាតិ ដែលភាគីណាមួយនៃវិវាទប្តឹងតវ៉ាមិនសុខចិត្តនឹងការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ឬក្នុងករណីដែលទទួលបណ្តឹងដោយផ្ទាល់ពីភាគីណាមួយនៃវិវាទ។

២- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាននិងធនធានធម្មជាតិ នៅក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរបស់ខ្លួន។

## ជំពូកទី៣
## នីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨០៥ .- ការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- ការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើដោយផ្អែកលើច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៧៤

២- បែបបទនិងនីតិវិធីនៃការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិដោយគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា៨០៦ .- កិច្ចព្រមព្រៀងសះជា**

១- កិច្ចព្រមព្រៀងសះជា ត្រូវធ្វើឡើងនៅចំពោះមុខគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត និងត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវឱ្យភាគីនៃវិវាទទាំងអស់ចុះហត្ថលេខា ឬផ្ដិតស្រាមមេដៃ ព្រមទាំងចុះហត្ថលេខា ឬផ្ដិតស្រាមមេដៃបញ្ជាក់លើកិច្ចព្រមព្រៀងសះជានោះ ដោយសមាជិកទាំងអស់នៃគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត។

២- កិច្ចព្រមព្រៀងសះជា ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវមានអានុភាពអនុវត្តដូចគ្នាទៅនឹងលិខិតអនុវត្ត លើកលែងតែកិច្ចព្រមព្រៀងនេះមានវិការៈ។

៣- កិច្ចព្រមព្រៀងសះជានេះ មិនមែនជាឧបសគ្គសម្រាប់តតិយជនក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនឡើយ។

**មាត្រា៨០៧ .- ការប្ដឹងបន្តក្នុងករណីមិនសះជា**

ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់រាជធានី ខេត្ត ភាគីនៃវិវាទមានសិទ្ធិប្ដឹងបន្តទៅគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលបានកំណត់ហេតុមិនសះជា។ ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់ជាតិ ភាគីនៃវិវាទមានសិទ្ធិប្ដឹងបន្តទៅតុលាការមានសមត្ថកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

## មាតិកាទី២

## មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៨០៨ .- គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់បែបបទនិងនីតិវិធីក្នុងការបំពេញតួនាទីរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន។

**មាត្រា៨០៩ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពការងាររបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

### ផ្នែកទី១

### មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ

**មាត្រា៨១០ .- ការតាំងនិងការបំពេញភារកិច្ចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិនិងការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌**

១- រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់

ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការចាត់តាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធ្វើដោយផ្អែកលើលក្ខណសម្បត្តិ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិមានភារកិច្ចតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងការអនុវត្តច្បាប់ក្នុងតំបន់ការពារធម្មជាតិ។

៣- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសធនធានធម្មជាតិនៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ហើយមានអំណាចឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀតដោយអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤- ការផ្តល់នីតិសម្បទា និងដែនសមត្ថកិច្ចចំពោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៥- ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសធនធានធម្មជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨១១ .– កិច្ចសហការនិងការពិនិត្យបទល្មើសរបស់នគរបាលយុត្តិធម៌**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិមានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីចូលរួមពិនិត្យ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ឬការថែរក្សាវត្ថុចាប់យកនៃបទល្មើសជាបណ្ដោះអាសន្ន។

**មាត្រា៨១២ .– ឯកសណ្ឋានក្នុងការបំពេញបេសកកម្ម**

១- នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

២- ឯកសណ្ឋាន ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨១៣ .– ការប្រើប្រាស់អាវុធ**

១- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិប្រើប្រាស់អាវុធស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

២- អាវុធត្រូវបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## មន្ត្រីអធិការកិច្ចបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨១៤ .– ការតែងតាំងមន្ត្រីអធិការកិច្ចបរិស្ថាន**

១-ការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាននិងកិច្ចគាំពារបរិស្ថាន ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬមន្ត្រីអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមសមត្ថកិច្ចរៀងៗខ្លួនស្របតាមក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ច- រៀបចំ តាមដាន និងពិនិត្យវឌ្ឍនភាពនៃការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងគម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិរបស់សហគមន៍។

ឆ- ពិនិត្យនិងកែសម្រួលផែនការមេ និងកម្មវិធីអភិវឌ្ឍសម្រាប់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ។

ជ- សម្របសម្រួលដោះស្រាយទំនាស់និងភាពមិនប្រក្រតីផ្សេងៗ ដែលកើតឡើងពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីនិងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ។

ឈ- រៀបចំយន្តការប្រមូលចំណូលពីសេវាកម្មទេសចរណ៍ធម្មជាតិ សម្រាប់ចូលរួមទ្រទ្រង់សកម្មភាពអភិរក្សតំបន់ការពារធម្មជាតិ។

ញ- កៀរគរជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសពីដៃគូអភិវឌ្ឍ និងវិស័យឯកជននានាសម្រាប់គាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិប្រកបដោយប្រសិទ្ធភាព។

ដ- សិក្សារៀបចំបង្កើតផលិតផលទេសចរណ៍ក្នុងតំបន់ការពារធម្មជាតិនិងការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍មូលដ្ឋានលើការអភិវឌ្ឍទេសចរណ៍ធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័ននិងដៃគូអភិវឌ្ឍពាក់ព័ន្ធ។

**មាត្រា៦០៩ .- តួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយនិងផែនការអភិវឌ្ឍទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

ខ- រៀបចំផែនការទេសចរណ៍ថ្នាក់ជាតិនិងថ្នាក់តំបន់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច និងដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

គ- ធ្វើការគ្រប់គ្រងនិងត្រួតពិនិត្យលើឧស្សាហកម្មទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឃ- ចេញអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតដល់ឧស្សាហកម្មទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

ង- សហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសិក្សាកំណត់តំបន់ដែលមានសក្តានុពល ក្នុងការអនុវត្តទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ។

ច- តាមដាន ត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើការអនុវត្តអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតរបស់ឧស្សាហកម្មទេសចរណ៍ធម្មជាតិ។

ឆ- អនុវត្តតួនាទីនិងភារកិច្ចបន្ថែមទៀតស្របតាមបទប្បញ្ញត្តិច្បាប់ស្តីពីទេសចរណ៍។

**មាត្រា៦១០ .- កាតព្វកិច្ចរបស់ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិ**

១- ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិមានកាតព្វកិច្ចគាំពារ ថែរក្សាបរិស្ថាន គ្រប់គ្រង និងអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិស្របតាមអាជ្ញាបណ្ណនិងលិខិតអនុញ្ញាត។

២- ម្ចាស់គម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិត្រូវចូលរួមចំណែកក្នុងការដាំដើមឈើនៅក្នុងតំបន់គម្រោងដែលទទួលបានការអនុញ្ញាត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៦១១ .- ការវាយតម្លៃប្រសិទ្ធផលធនធាន**

១- រាល់សកម្មភាពឬគម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិដែលបង្កផលប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាននិងធនធានធម្មជាតិលើសពីកម្រិតដែលបានអនុញ្ញាត ឬមិនបានអនុវត្តតាមស្តង់ដារទេសចរណ៍ធម្មជាតិត្រូវធ្វើការវាយតម្លៃលើប្រសិទ្ធផលធនធានដើម្បីធានាបាននូវការការពារបរិស្ថាននិងអភិរក្សធនធានធម្មជាតិ។

២- បែបបទនិងនីតិវិធីនៃការវាយតម្លៃលើប្រសិទ្ធផលធនធាន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ដោយធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៦១២ .- ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនិរន្តរភាពនៃការអភិវឌ្ឍទេសចរណ៍ធម្មជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ដោយសហការជាមួយ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យស្តីពីការពិនិត្យលើនិរន្តរភាព ដែលអនុវត្តចំពោះគម្រោងនិងសកម្មភាពអភិវឌ្ឍទេសចរណ៍។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍ ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិ អនុលោមតាមស្តង់ដារទេសចរណ៍ធម្មជាតិថ្នាក់ជាតិ និងអន្តរជាតិ។

**មាត្រា៦១៣ .- ការយកថ្លៃចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចយកថ្លៃចូលទស្សនាសហគមន៍ ទេសចរណ៍ធម្មជាតិដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីបម្រើគោលដៅការពារនិងអភិរក្សធនធានធម្មជាតិ។

២- កម្រៃសេវាចូលទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិដែលស្ថិតនៅក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យទេសចរណ៍។

**មាត្រា៦១៤ .- សកម្មភាពហាមឃាត់**

ហាមឃាត់រាល់សកម្មភាពរបស់គម្រោងអភិវឌ្ឍទេសចរណ៍ធម្មជាតិដូចខាងក្រោម៖

ក- បំពុលឬកាប់បំផ្លាញធនធានធម្មជាតិនៅក្នុងតំបន់គម្រោងដែលទទួលបានការអនុញ្ញាត។

ខ- បំប្លែងឬកែប្រែទ្រង់ទ្រាយដើមនៃតំបន់ដែលបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់មុខងាររបស់តំបន់ការពារធម្មជាតិ។

គ- កាប់គាស់ ឈូសឆាយ និងកាប់រំលំដើមឈើក្នុងតំបន់គម្រោង លើកលែងតែមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឃ- កាប់គាស់ឬឈូសឆាយដីព្រៃក្នុងគោលបំណងបំប្លែងយកដីនោះមកធ្វើជាកម្មសិទ្ធិឯកជន។

## ជំពូកទី១១

## ការគ្រប់គ្រងធនធានរ៉ែ

**មាត្រា៦១៥ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងសកម្មភាពគម្រោងអាជីវកម្មធនធានរ៉ែនៅ

ក្នុងតំបន់ការពារធម្មជាតិ។ ការគ្រប់គ្រងសកម្មភាពគម្រោងអាជីវកម្មធនធានរ៉ែគ្រប់ប្រភេទជាសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែ។

**មាត្រា៦១៦ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- សម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការគ្រប់គ្រងគម្រោងវិនិយោគធនធានរ៉ែដែលអាចបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។

ខ- សម្របសម្រួលការរៀបចំបង្កើត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគម្រោងអាជីវកម្មធនធានរ៉ែនៅក្នុងតំបន់ការពារធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

គ- ធ្វើការអង្កេត តាមដាន និងពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថានឬកិច្ចសន្យាការពារបរិស្ថានរបស់គម្រោងអាជីវកម្មធនធានរ៉ែ។

ឃ- ចេញលិខិតអនុញ្ញាតនិងការឯកភាពនានាស្របតាមបទប្បញ្ញត្តិស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ង- សិក្សានិងលើកសំណើជូនរាជរដ្ឋាភិបាល ក្នុងករណីគម្រោងអាជីវកម្មធនធានរ៉ែបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន បើធៀបនឹងផលចំណេញផ្នែកសេដ្ឋកិច្ចកើតចេញពីគម្រោងអាជីវកម្មធនធានរ៉ែ។

ច- ពិគ្រោះយោបល់និងសម្រេចរួមគ្នា មុននឹងលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេចលើគម្រោងអាជីវកម្មធនធានរ៉ែទាំងឡាយណាដែលធ្វើឡើងក្នុងតំបន់អភិរក្ស និងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ។

**មាត្រា៦១៧ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែ**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការគ្រប់គ្រងផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងគម្រោងវិនិយោគអាជីវកម្មធនធានរ៉ែ។

ខ- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគម្រោងអាជីវកម្មធនធានរ៉ែ។

គ- ចេញអាជ្ញាបណ្ណធនធានរ៉ែឬលិខិតអនុញ្ញាតផ្សេងៗស្របតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ឃ- ធ្វើការសិក្សានិងវាយតម្លៃពីផលចំណេញផ្នែកសេដ្ឋកិច្ចដែលកើតចេញពីគម្រោងអាជីវកម្មធនធានរ៉ែ។

ង- តាមដាន ត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់។

ច- ចុះធ្វើអធិការកិច្ចលើគម្រោងអាជីវកម្មធនធានរ៉ែស្របតាមអាជ្ញាបណ្ណនិងលិខិតអនុញ្ញាតផ្សេងៗ។

ឆ- ពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងករណីគម្រោងអាជីវកម្មធនធានរ៉ែ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាននិងតំបន់បេតិកភណ្ឌវប្បធម៌។

ជ- ពិគ្រោះយោបល់និងសម្រេចរួមជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មុនលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេចលើគម្រោងអាជីវកម្មធនធានរ៉ែស្ថិតនៅក្នុងតំបន់អភិរក្សនិងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិ។

**មាត្រា៦១៨ ._ កាតព្វកិច្ចបញ្ចៀសការខូចខាតបរិស្ថាន**

១- ម្ចាស់គម្រោងអាជីវកម្មធនធានរ៉ែមានកាតព្វកិច្ចបញ្ចៀសការបំពុលឬខូចខាតបរិស្ថានធ្ងន់ធ្ងរដែលកើតចេញពីប្រតិបត្តិការ ឬគម្រោងអាជីវកម្មធនធានរ៉ែ។

២- ការប្រើប្រាស់បច្ចេកវិទ្យាមេត្រីបរិស្ថានទំនើបក្នុងការធ្វើអាជីវកម្មធនធានរ៉ែត្រូវបានលើកទឹកចិត្ត។

៣- ម្ចាស់គម្រោងអាជីវកម្មធនធានរ៉ែត្រូវទទួលខុសត្រូវលើការសងសំណងការខូចខាតដល់ប្រជាពលរដ្ឋ ដែលទទួលផលប៉ះពាល់ដោយសារគម្រោងអាជីវកម្មធនធានរ៉ែ។

**មាត្រា៦១៩ ._ កាតព្វកិច្ចរាយការណ៍**

១- ម្ចាស់គម្រោងអាជីវកម្មធនធានរ៉ែ ត្រូវរាយការណ៍ជាបន្ទាន់ដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែ ក្នុងករណីមានការលេចធ្លាយឬកំពប់អាស៊ីត សារធាតុលោហៈ ឬសំណល់គ្រោះថ្នាក់ ដែលបង្កផលប៉ះពាល់ដល់បរិស្ថាននិងសង្គម។

២- ការចំណាយលើការស្តារបរិស្ថានឡើងវិញដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវទទួលបន្ទុកដោយម្ចាស់គម្រោងអាជីវកម្មធនធានរ៉ែ។

**មាត្រា៦២០ ._ បញ្ជីបច្ចេកវិទ្យាមេត្រីបរិស្ថានទំនើប**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យរ៉ែ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីបញ្ជីបច្ចេកវិទ្យាមេត្រីបរិស្ថានទំនើប ដែលត្រូវប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការគម្រោងអាជីវកម្មរ៉ែ។

**មាត្រា៦២១ ._ សកម្មភាពហាមឃាត់**

ហាមឃាត់ចំពោះសកម្មភាពដូចខាងក្រោម៖

ក- សាងសង់អាងស្តុកសំណល់រ៉ែនៅជិតទន្លេ សមុទ្រ ឬប្រភពទឹកដែលចាំបាច់សម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋ និងមានជម្រាលកំព្រមទាំងមិនស្របតាមបញ្ញត្តិស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- ការហូរឬលេចធ្លាយអាស៊ីត សារធាតុលោហៈពីគម្រោងអាជីវកម្មធនធានរ៉ែដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាននិងសង្គម។

គ- ការធ្វើបុរេសនា ស្វែងរុករក និងការធ្វើអាជីវកម្មធនធានរ៉ែដោយគ្មានលិខិតអនុញ្ញាត។

ឃ- ការបញ្ចេញសំណល់រាវ រឹង ឬសំណល់គ្រោះថ្នាក់គ្រប់ប្រភេទដែលកើតចេញពីសកម្មភាពអាជីវកម្មធនធានរ៉ែដែលបង្កផលប៉ះពាល់ដល់បរិស្ថាននិងសង្គម។

## ជំពូកទី១២

## ការគ្រប់គ្រងវិស័យថាមពល

**មាត្រា៦២២ ._ ការលើកទឹកចិត្តការប្រើប្រាស់ថាមពលប្រកបដោយការទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ លើកទឹកចិត្តឱ្យមានគម្រោងប្រើប្រាស់ថាមពលប្រកបដោយការទទួលខុសត្រូវ ថាមពលកកើតឡើងវិញនៅក្នុងតំបន់ការពារធម្មជាតិ ដើម្បីធានាឱ្យបាននូវនិរន្តរភាពថាមពល និងចូលរួមចំណែកកាត់បន្ថយការប្រើប្រាស់ថាមពលអគ្គិសនីដែលអាចបង្កផលប៉ះពាល់ដល់បរិស្ថាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



ក៥

**មាត្រា៦២៣ ._ ការអូសបណ្ដាញអគ្គិសនីកាត់តាមតំបន់អភិរក្សឬតំបន់ស្នូល**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មុននឹងចាប់ផ្ដើមអនុវត្តគម្រោងអូសបណ្ដាញអគ្គិសនីកាត់តាមតំបន់អភិរក្ស ឬតំបន់ស្នូល។

**មាត្រា៦២៤ ._ ការអនុវត្តបទប្បញ្ញត្តិដូចគ្នា**

១- លើកលែងតែមានបញ្ញត្តិក្នុងជំពូកនេះ បញ្ញត្តិក្នុងមាតិកាទី១០(ថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ) នៃគន្ថីទី២នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាចំពោះការគ្រប់គ្រងវិស័យថាមពលក្នុងតំបន់ការពារធម្មជាតិ។

២- ថាមពលប្រកបដោយការទទួលខុសត្រូវ ដូចមានចែងក្នុងមាតិកាទី១០ (ថាមពលអគ្គិសនីប្រកបដោយការទទួលខុសត្រូវ) នៃគន្ថីទី២នៃក្រមនេះ មិនត្រូវយកមកធ្វើការគ្រប់គ្រងនិងប្រើប្រាស់ទេ ក្នុងករណីការគ្រប់គ្រងនិងប្រើប្រាស់ថាមពល ប្រកបដោយការទទួលខុសត្រូវផ្ទុយនឹងគោលបំណងនៃកិច្ចគាំពារបរិស្ថាននិងគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ។

## មាតិកាទី៣
## ការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៦២៥ ._ គោលបំណង**

មាតិកានេះ មានគោលបំណងគ្រប់គ្រងធនធាននៅតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ តាមរយៈកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការប្រើប្រាស់ធនធានធម្មជាតិ និងការអភិវឌ្ឍសំដៅធានាបាននូវតុល្យភាព ឬលំនឹងប្រព័ន្ធអេកូឡូស៊ី តំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ និងលើកកម្ពស់សេដ្ឋកិច្ចសហគមន៍មូលដ្ឋាន។

**មាត្រា៦២៦ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

### ជំពូកទី២
### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៦២៧ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សធនធានធម្មជាតិ តំបន់ឆ្នេរ តំបន់កោះ និងសមុទ្រក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។

២- រាជរដ្ឋាភិបាលអាចកំណត់អំពីតួនាទី ការទទួលខុសត្រូវ និងកិច្ចសហការជាក់លាក់សម្រាប់ក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៦២៨ ._ តួនាទីនិងភារកិច្ច**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងកិច្ចគាំពារ និងការអភិរក្សធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក- រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការសកម្មភាព លិខិតបទដ្ឋានគតិយុត្តនានានិងគោលការណ៍ណែនាំបច្ចេកទេសសម្រាប់គ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

ខ- រៀបចំសេចក្តីព្រាងគោលនយោបាយ ផែនការគ្រប់គ្រង ផែនការមេ និងផែនទីភូមិសាស្ត្រ សម្រាប់គ្រប់គ្រងបរិស្ថាននិងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

គ- ពិនិត្យនិងលើកសំណើជូនរាជរដ្ឋាភិបាលក្នុងការចូលរួមអនុវត្តលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធ។

ឃ- សិក្សា វាយតម្លៃ ប្រមូល ចងក្រង និងរក្សាទុកទិន្នន័យព័ត៌មានធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

ង- អប់រំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនក្នុងការចូលរួមថែរក្សានិងការពារធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

ច- អភិវឌ្ឍសមត្ថភាពនិងគាំទ្របច្ចេកទេសដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

ឆ- ធ្វើអធិការកិច្ច តាមដាន និងវាយតម្លៃទៅលើការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

**មាត្រា៦២៩ ._ គោលការណ៍ណែនាំបច្ចេកទេស**

បែបបទ នីតិវិធី និងគោលការណ៍ណែនាំបច្ចេកទេសស្តីពីការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រក្នុងតំបន់ការពារធម្មជាតិត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយធ្វើការពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៦៣០ ._ ការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ**

ការបង្កើតតំបន់ការពារធម្មជាតិពាក់ព័ន្ធតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រត្រូវធ្វើឡើងដូចមានចែងក្នុងមាត្រា៣៥៨(ការបង្កើតតំបន់ការពារធម្មជាតិ)នៃក្រមនេះ។

**មាត្រា៦៣១ ._ ការពិនិត្យតាមដាននិងវាយតម្លៃ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអង្កេត ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងការអភិរក្ស និងការស្តារធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រក្នុងតំបន់ការពារធម្មជាតិ។

**មាត្រា៦៣២ ._ លក្ខខណ្ឌសម្រាប់សកម្មភាពឬគម្រោងអភិវឌ្ឍ**

ការផ្តល់ការឯកភាពចំពោះសកម្មភាពឬគម្រោងអភិវឌ្ឍនៅតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រត្រូវផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

ក- សកម្មភាព ឬគម្រោងស្នើសុំដោយបុគ្គលស្របតាមផែនការប្រើប្រាស់ដីក្នុងតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

ខ- សកម្មភាពឬគម្រោងស្នើសុំរបស់បុគ្គលត្រូវដាក់បញ្ចូលនូវវិធានក្នុងការបញ្ចៀស និងកាត់បន្ថយដល់កម្រិតអប្បបរមានូវផលប៉ះពាល់ចំពោះតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ។

គ- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយត្រូវបានព្យាករទុក ដើម្បីទប់ស្កាត់និងកាត់បន្ថយការហូរច្រោះ គ្រោះថ្នាក់ដោយទឹកជំនន់ និងភាពរាំងស្ងួតនៅតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ ដោយរៀបចំនីតិវិធីនៃការជម្លៀសប្រជាពលរដ្ឋនិងការពារហេដ្ឋារចនាសម្ព័ន្ធ។

ឃ- ផលប៉ះពាល់ពីការបញ្ចេញសំណល់រឹង សំណល់រាវចូលតំបន់ឆ្នេរត្រូវបានកាត់បន្ថយដល់កម្រិតអប្បបរមា ឬបញ្ចៀសដោយមានការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធផល។

ង- ការងារចាក់បំពេញដើម្បីយកដីមកប្រើប្រាស់ត្រូវបានកាត់បន្ថយឱ្យដល់កម្រិតអប្បបរមា។

ច- សកម្មភាពឬគម្រោងត្រូវធ្វើស្របតាមវិធានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។

ឆ- លក្ខខណ្ឌផ្សេងៗទៀតដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៣៣ .– គម្រោងហាមឃាត់**

១- ហាមឃាត់ចំពោះសកម្មភាពសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ អាជីវកម្មរ៉ែ និងគម្រោងវិនិយោគដែលបង្កឱ្យមានការបាត់បង់ ការបំពុល ឬការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រដូចខាងក្រោម៖

ក- តំបន់ជម្រកសត្វសមុទ្រនិងប្រភេទសត្វកម្រ។

ខ- តំបន់ស្មៅសមុទ្រនិងផ្កាថ្ម។

គ- តំបន់ប្រភពចំណីសត្វព្រៃនិងមច្ឆជាតិ។

ឃ- តំបន់ព្រៃកោងកាង។

ង- តំបន់ព្រៃឈើ វាលស្មៅ បឹង និងប្រភពទឹកសាបនៅតាមតំបន់កោះ។

ច- តំបន់បង្កកំណើតមច្ឆជាតិ និងទឹកសមុទ្រ និងធនធានជលផលដទៃទៀត។

២- សកម្មភាព ឬគម្រោងដូចមានចែងខាងលើ អាចអនុវត្តបានក្នុងករណីមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។

## មាតិកាទី៤
## ការអនុវត្តបទប្បញ្ញត្តិតាមវិស័យនីមួយៗ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៦៣៤ .– គោលបំណង**

មាតិកានេះមានគោលបំណងរៀបចំយន្តការនៃការសម្របសម្រួល ការសហការ និងការធ្វើឱ្យមានសង្គតិភាពគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យនីមួយៗពាក់ព័ន្ធវិស័យជលផល ព្រៃឈើ សត្វព្រៃ រុក្ខជាតិព្រៃ ទេសចរណ៍ រ៉ែ ធនធានទឹក ថាមពល បេតិកភណ្ឌវប្បធម៌ ទីជម្រាល និងវិស័យពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិនិងធនធានធម្មជាតិទាំងអស់នៅក្នុងតំបន់ការពារធម្មជាតិ ដូចមានចែងក្នុងមាតិកាទី១(ការគ្រប់គ្រងតំបន់ការពារធម្មជាតិ) ដល់មាតិកាទី៣(ការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះនិងសមុទ្រ)នៃគន្ថីទី៤នៃក្រមនេះ។

**មាត្រា៦៣៥ .– វិសាលភាព**

មាតិកានេះមានវិសាលភាពអនុវត្តលើការបំពេញតួនាទីនិងមុខងាររបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលច្បាប់ដោយឡែកតាមវិស័យនីមួយៗ និងក្រមនេះបានប្រគល់ភារកិច្ចជូន។

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL ★

## ជំពូកទី២

## ការអនុវត្តបទបញ្ញត្តិច្បាប់ដោយឡែកតាមវិស័យពាក់ព័ន្ធ

**មាត្រា៦៣៦ ._** ការអនុវត្តបទបញ្ញត្តិពាក់ព័ន្ធ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តតាមវិស័យ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យជលផល ព្រៃឈើ សត្វព្រៃ រុក្ខជាតិព្រៃ ទេសចរណ៍ រ៉ែ ធនធានទឹក ថាមពល បេតិកភណ្ឌវប្បធម៌ ទីជម្រាល និងវិស័យពាក់ព័ន្ធផ្សេងទៀត ដើម្បីបំពេញបន្ថែមលើការអនុវត្តតួនាទីនិងភារកិច្ចក្នុងការគ្រប់គ្រង កិច្ចគាំពារ និងការអភិរក្សធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិដូចមានបញ្ញត្តក្នុងក្រមនេះ ដើម្បីរក្សាឱ្យបាននូវនិរន្តរភាពធនធានធម្មជាតិ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់ជាឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា។

២- ក្រសួងស្ថាប័នទទួលបន្ទុកតាមវិស័យពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលច្បាប់ដោយឡែកបានប្រគល់ភារកិច្ចជូនមានសិទ្ធិអនុវត្តបទបញ្ញត្តិនៃក្រមនេះ ដើម្បីបំពេញបន្ថែមលើការអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនតាមវិស័យរៀងៗខ្លួន។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវសហការនិងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តបទបញ្ញត្តិនៃក្រមនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការថែរក្សា កិច្ចគាំពារ ការអភិរក្សតំបន់ការពារធម្មជាតិ និងធនធានធម្មជាតិនៅក្នុងតំបន់ការពារធម្មជាតិសម្រាប់ជាឧត្តមប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា ក្រោមដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៦៣៧ ._** ការកំណត់សិទ្ធិក្នុងការដកហូតធនធានធម្មជាតិនិងគម្រោងវិនិយោគ

ក្រសួងស្ថាប័នពាក់ព័ន្ធដែលច្បាប់ដោយឡែកតាមវិស័យនីមួយៗបានប្រគល់សិទ្ធិអំណាចជូនពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាអាចធ្វើការដកហូតធនធានធម្មជាតិ និងអនុញ្ញាតឱ្យគម្រោងវិនិយោគណាមួយបានក្នុងតំបន់សហគមន៍និងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ បន្ទាប់ពីធ្វើការពិគ្រោះយោបល់ជាមុនជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។ រាល់ការដកហូតធនធានធម្មជាតិនិងការសម្រេចឱ្យមានគម្រោងវិនិយោគនៅក្នុងតំបន់អភិរក្ស និងតំបន់ស្នូល អាចអនុវត្តបានលុះត្រាតែស្របតាមបញ្ញត្តិនៃមាតិកាទី១(ការគ្រប់គ្រងតំបន់ការពារធម្មជាតិ) ដល់មាតិកាទី៣(ការគ្រប់គ្រងធនធានតំបន់ឆ្នេរ តំបន់កោះ និងសមុទ្រ)នៃគន្ថីទី៤នៃក្រមនេះ។

## គន្ថីទី៥

## ការវាយតម្លៃបរិស្ថាន

## មាតិកាទី១

## ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា៦៣៨ ._** គោលបំណង

មាតិកានេះ មានគោលបំណងធានាប្រសិទ្ធភាពនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រទៅលើគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាលតាមវិស័យនានា ដោយមានការចូលរួមជាសាធារណៈ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៦៣៩ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តទៅលើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក្នុងក្របខ័ណ្ឌគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យឧស្សាហកម្ម រ៉ែ ថាមពល កសិកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធទូរគមនាគមន៍ និងវិស័យសំខាន់ៗផ្សេងទៀត។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៦៤០ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការរៀបចំឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រក្នុងក្របខ័ណ្ឌគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។

**មាត្រា៦៤១ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- កំណត់វិស័យអាទិភាពដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ខ- ធ្វើការពិនិត្យនិងសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

គ- សហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ឃ- កំណត់គោលការណ៍ណែនាំសម្រាប់រៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

**មាត្រា៦៤២ .- ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

រាល់ការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធីអភិវឌ្ឍរបស់រាជរដ្ឋាភិបាល ចាំបាច់ត្រូវដាក់បញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

## ជំពូកទី៣

## នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

**មាត្រា៦៤៣ .- ការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីផ្តល់នូវព័ត៌មានលម្អិតបន្ថែមទៀត ស្តីពីនីតិវិធីនៃការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៅក្នុងមាតិកានេះ ដែលមានជាអាទិ៍៖

ក- ប្រតិបត្តិការលម្អិតនៃនីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ខ- លក្ខណវិនិច្ឆ័យសម្រាប់កំណត់សក្តានុពលនៃសំណើដែលអាចមានផលប៉ះពាល់គួរឱ្យកត់សម្គាល់។

គ- ការអនុវត្តបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មានអំពីបរិស្ថានដែលមានចែងនៅក្នុងក្រមនេះ។

ឃ- ខ្លឹមសារនិងទម្រង់នៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

**មាត្រា៦៤៤ .- នីតិវិធី**

១- នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវដាក់បញ្ចូលនូវដំណាក់កាលដូចខាងក្រោម៖

ក- ការធ្វើចំណាត់ថ្នាក់គោលនយោបាយ ផែនការ និងកម្មវិធី។

ខ- ការកំណត់វិសាលភាពគោលនយោបាយ ផែនការ និងកម្មវិធី។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ- ការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ឃ- ការពិនិត្យលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ង- ការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

ច- ការតាមដានការអនុវត្តការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

២- នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៦៤៥ .- ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

១- នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវមានការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលនៃដំណើរការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

២- នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៤៦ .- ការទទួលខុសត្រូវក្នុងរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

ក្រសួងស្ថាប័នដទៃផ្សេងទៀត និង/ឬរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងដាក់ជូនរាជរដ្ឋាភិបាលសម្រេច បន្ទាប់ពីមានការពិនិត្យនិងផ្តល់យោបល់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៤៧ .- ការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

១- ក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវអនុវត្តតាមរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលបានឯកភាពដោយរាជរដ្ឋាភិបាល។

២- ប្រភេទគម្រោង ដែលស្ថិតក្នុងវិសាលភាពនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវបន្តរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាតិកាទី២(ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្ថីទី៥នៃក្រមនេះ។

**មាត្រា៦៤៨ .- ការអង្កេតតាមដាន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអង្កេត តាមដានលើបរិស្ថាននិងសង្គម ដូចមានចែងក្នុងរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

២- ក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបញ្ជូនរបាយការណ៍អង្កេតតាមដាន វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ មកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ រៀងរាល់៣(បី)ឆ្នាំម្តង ឬ៥(ប្រាំ)ឆ្នាំម្តង។

៣- នីតិវិធីនៃការអង្កេតតាមដាន វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវកំណត់ដោយអនុក្រឹត្យ។

## មាតិកាទី២

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៦៤៩ .- គោលបំណង**

មាតិកានេះ មានគោលបំណងធានាប្រសិទ្ធភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជន ដោយមានការចូលរួមជាសាធារណៈ សំដៅបង្ការ បញ្ចៀស ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានលើបរិស្ថាននិងសង្គម ដែលបង្កឡើងដោយគម្រោងវិនិយោគ។

មាត្រា៦៥០ ._ វិសាលភាព

១- មាតិកានេះ មានវិសាលភាពអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោងវិនិយោគទាំងសាធារណៈ និងឯកជន មានជាអាទិ៍ គម្រោងស្នើសុំ គម្រោងមានស្រាប់ និងគម្រោងកំពុងដំណើរការ ដែលអាចបង្កហេតុប៉ះពាល់ដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌។

២- ក្នុងករណីដែលគម្រោងអភិវឌ្ឍអាចបង្កឱ្យមានហេតុប៉ះពាល់ឆ្លងដែនដល់បរិស្ថាន សុខភាព សេដ្ឋកិច្ច សង្គម និងវប្បធម៌ ម្ចាស់គម្រោងត្រូវធ្វើការសិក្សាបន្ថែមលើហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

មាត្រា៦៥១ ._ គម្រោងលើកលែង

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនអនុវត្តចំពោះគម្រោងអភិវឌ្ឍឬសកម្មភាពរបស់រដ្ឋ ដែលបានសម្រេចឬអនុម័តដោយរាជរដ្ឋាភិបាលឬរដ្ឋសភាហើយដែលចាត់ទុកជាគម្រោងចាំបាច់ និងបន្ទាន់ទាក់ទងនឹងសន្តិសុខជាតិ បូរណភាពទឹកដី អធិបតេយ្យភាពជាតិ ឬគ្រោះមហន្តរាយនានា។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

មាត្រា៦៥២ ._ ក្រសួងស្ថាប័នទទួលខុសត្រូវ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់រាល់គម្រោងវិនិយោគសាធារណៈ និងឯកជន។

មាត្រា៦៥៣ ._ តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំបច្ចេកទេស និងនីតិវិធីនានាសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- ធ្វើចំណាត់ថ្នាក់គម្រោងវិនិយោគ កំណត់លក្ខខណ្ឌការងារ កំណត់វិសាលភាពនៃការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

គ- ពិនិត្យ ផ្តល់យោបល់ ឯកភាព និង/ឬបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងចេញលិខិតនានាពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ឃ- ជំរុញឱ្យមានការចូលរួមជាសាធារណៈពីបុគ្គល ដែលពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ។

ង- ចុះអង្កេតតាមដាន ត្រួតពិនិត្យ ធ្វើអធិការកិច្ច អង្កេតស្រាវជ្រាវ ណែនាំ និងចាត់វិធានការចំពោះការអនុវត្តរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងគម្រោងវិនិយោគ។

ច- រៀបចំនិងចេញលិខិតបទដ្ឋានគតិយុត្តស្តីពីការចូលរួមជាសាធារណៈក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ឆ- កំណត់លក្ខខណ្ឌ លក្ខណសម្បត្តិ បែបបទ និងនីតិវិធីសម្រាប់ការចុះបញ្ជីជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជារូបវន្តបុគ្គលឬនីតិបុគ្គល។

ឍ- រៀបចំបង្កើតក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

ណ-កំណត់សមាសភាពមន្ត្រីដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌។

## ជំពូកទី៣
## គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៦៥៤ .-** គោលការណ៍គ្រឹះនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

១- រាល់គម្រោងអភិវឌ្ឍ ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិជាមុន មុននឹងដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចឬក្រសួងសាមី និង/ឬរាជរដ្ឋាភិបាលសម្រេច។

២- រាល់ការចេញអាជ្ញាបណ្ណ លិខិតអនុញ្ញាត ឬសេចក្ដីសម្រេចលើគម្រោងអភិវឌ្ឍនានាដោយអាជ្ញាធរមានសមត្ថកិច្ចឬក្រសួងសាមីនិង/ឬរាជរដ្ឋាភិបាល ត្រូវធ្វើឡើងអនុលោមតាមលក្ខខណ្ឌដែលកំណត់នៅក្នុងលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានឬកិច្ចសន្យាការពារបរិស្ថាន។

៣-រាល់អាជ្ញាបណ្ណ លិខិតអនុញ្ញាតឬសេចក្ដីសម្រេចនានាដែលផ្ទុយនឹងបញ្ញត្តិនៃមាត្រានេះត្រូវទុកជាមោឃៈ។

**មាត្រា៦៥៥ .-** គោលការណ៍ទូទៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសុពលភាព លុះត្រាតែកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះធ្វើឡើងស្របតាមលក្ខខណ្ឌនិងគោលការណ៍នៃការចូលរួមជាសាធារណៈ នៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងនៅក្នុងមាតិកាទី២(ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្ថីទី៥នៃក្រមនេះ។

## ជំពូកទី៤
## កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

**មាត្រា៦៥៦ .-** ការធ្វើចំណាត់ថ្នាក់គម្រោងអភិវឌ្ឍ

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវកំណត់ចំណាត់ថ្នាក់គម្រោងអភិវឌ្ឍដើម្បីតម្រូវឱ្យម្ចាស់គម្រោង រៀបចំនូវឯកសារដូចខាងក្រោម៖

ក- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

ខ- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។

គ- កិច្ចសន្យាការពារបរិស្ថាន។

២-ប្រភេទគម្រោងដែលតម្រូវឱ្យរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៥៧ .-** លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬកិច្ចសន្យាការពារបរិស្ថាន

១- លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវធ្វើឡើងសម្រាប់គម្រោងដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬគម្រោងអភិវឌ្ឍដែលមានការប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាននិងសង្គម។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

២- លក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងសម្រាប់គម្រោង ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬគម្រោងអភិវឌ្ឍដែលមានការប៉ះពាល់មធ្យមដល់បរិស្ថាននិងសង្គម។

៣- លក្ខខណ្ឌតម្រូវក្នុងការរៀបចំកិច្ចសន្យាការពារបរិស្ថានត្រូវធ្វើឡើងសម្រាប់គម្រោង ដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬគម្រោងអភិវឌ្ឍដែលមានការប៉ះពាល់តិចតួចដល់បរិស្ថាននិងសង្គម។

**មាត្រា៦៥៨ ._ លក្ខខណ្ឌតម្រូវឱ្យមានឬគ្មានក្រុមហ៊ុនទីប្រឹក្សាសម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញនិងដំបូង**

១- នៅពេលដែលគម្រោងស្នើសុំតម្រូវឱ្យធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវសហការជាមួយក្រុមហ៊ុនទីប្រឹក្សា ដែលបានចុះបញ្ជីទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីរៀបចំលក្ខខណ្ឌការងារសម្រាប់ការសិក្សានិងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញដោយអនុលោមតាមបទប្បញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងត្រូវស្នើសុំការសម្រេចឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នៅពេលដែលគម្រោងស្នើសុំតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយខ្លួនឯងនិង/ឬតាមរយៈទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គល និងត្រូវស្នើសុំការសម្រេចឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- នៅពេលដែលគម្រោងស្នើសុំតម្រូវឱ្យធ្វើត្រឹមកិច្ចសន្យាការពារបរិស្ថាន ម្ចាស់គម្រោងត្រូវចុះកិច្ចសន្យាការពារបរិស្ថានដោយត្រូវភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថាននិងឯកសារពាក់ព័ន្ធ និងត្រូវស្នើសុំការសម្រេចឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៥៩ ._ ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គល**

១- ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គល ត្រូវមានការចុះបញ្ជីទទួលស្គាល់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មុននឹងប្រកបវិជ្ជាជីវៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២- ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវប្រកបវិជ្ជាជីវៈដោយឯករាជ្យ និងទទួលខុសត្រូវលើរាល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។

៣- លក្ខខណ្ឌ និងនីតិវិធីសម្រាប់ចុះបញ្ជីដើម្បីទទួលបាននីតិសម្បទាជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គលត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៦០ ._ ការពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានរបាយការណ៍។ រយៈពេល៩០(កៅសិប)ថ្ងៃនេះ ត្រូវអស់សុពលភាពនៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានផ្តល់យោបល់ ទោះបីជាយោបល់នោះជាយោបល់បដិសេធ ឬជាយោបល់ឯកភាព ឬជាយោបល់បង្គាប់ឱ្យមានការកែតម្រូវ ឬកែសម្រួលលើរបាយការណ៍ក៏ដោយ។

២- រយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការសម្រាប់ពិនិត្យនិងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មីនៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបានពាក្យស្នើសុំឱ្យពិនិត្យព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ ឬណែនាំដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានផ្តល់ជូនកាលពីពេលមុនៗ។

៣- ករណីដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ខកខានមិនបានបញ្ជូនយោបល់ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រសួងស្ថាប័នមានសមត្ថកិច្ចនិង/ឬរាជរដ្ឋាភិបាលអាចកំណត់ថាគម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃក្រមនេះ។

៤- ម្ចាស់គម្រោងត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុស ដែលបណ្តាលមកពីការយឺតយ៉ាវឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ឬសេចក្តីណែនាំខាងលើ។

**មាត្រា៦៦១ .- គណៈកម្មការជំនាញត្រួតពិនិត្យ**

១- រាល់គម្រោងអភិវឌ្ឍនានាដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ចាំបាច់ត្រូវមានមតិយោបល់បច្ចេកទេសរបស់គណៈកម្មការជំនាញត្រួតពិនិត្យ។

២- គណៈកម្មការជំនាញត្រួតពិនិត្យ មានសមាសភាពមកពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកជំនាញឯករាជ្យដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្របក្នុងការពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

៣- តួនាទីនិងភារកិច្ចនៃគណៈកម្មការជំនាញត្រួតពិនិត្យនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៦២ .- កិច្ចប្រជុំពិគ្រោះយោបល់របស់គណៈកម្មការជំនាញត្រួតពិនិត្យ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ បន្ទាប់ពី៖

ក- ស្តាប់និងពិចារណាលើបទបង្ហាញនិងកិច្ចតាំងការពារជាផ្លូវការរបស់ម្ចាស់គម្រោងនិងក្រុមហ៊ុនទីប្រឹក្សា។

ខ- ពិចារណាលើមតិយោបល់របស់អ្នកដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬដោយប្រយោលនិងមតិសាធារណជនពាក់ព័ន្ធ។

គ- ពិចារណាលើមតិរបស់គណៈកម្មការជំនាញត្រួតពិនិត្យ ដែលបានស្នើឡើងសម្រាប់តែករណីរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈអនុលោមតាមបញ្ញត្តិក្នុងជំពូកទី៦(ការចូលរួមជាសាធារណៈក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន) មាតិកាទី២(ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្ថីទី៥នៃក្រមនេះ។

**មាត្រា៦៦៣ .- ការពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលទទួលបានរបាយការណ៍។ រយៈពេល៦០(ហុកសិប)ថ្ងៃនេះត្រូវអស់សុពលភាពនៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានផ្តល់យោបល់ ទោះបីជាយោបល់នោះជាយោបល់បដិសេធ ឯកភាព ឬបង្គាប់ឱ្យមានការកែតម្រូវលើរបាយការណ៍ក៏ដោយ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *



ᨵ

២- រយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការសម្រាប់ពិនិត្យនិងផ្តល់យោបល់ខាងលើ ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ព្រមទាំងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរ ស្របតាមសេចក្តីបង្គាប់ឬសេចក្តីណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដែលបានផ្តល់យោបល់។

៣- ករណីដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ខកខានមិនបានបញ្ជូនយោបល់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រសួងស្ថាប័នមានសមត្ថកិច្ចនិង/ឬរាជរដ្ឋាភិបាលអាចសម្រេចកំណត់ថាគម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃក្រមនេះ។

៤- ម្ចាស់គម្រោងត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនានា ដែលបង្កឡើងដោយកំហុសរបស់ខ្លួននិងដែលនាំឱ្យមានការយឺតយ៉ាវឬការខកខានមិនបានធ្វើការកែសម្រួលឱ្យត្រូវតាមសេចក្តីបង្គាប់ឬសេចក្តីណែនាំខាងលើ។

**មាត្រា៦៦៤ ._ ការពិនិត្យនិងផ្តល់យោបល់លើកិច្ចសន្យាការពារបរិស្ថាន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីពិនិត្យ ផ្តល់យោបល់ ឯកភាព បដិសេធ ឬកែតម្រូវលើកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង។ រយៈពេលនេះគិតចាប់ពីកាលបរិច្ឆេទដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបានពាក្យសុំពិនិត្យលើកិច្ចសន្យាការពារបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន និងឯកសារពាក់ព័ន្ធ។

២- រយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ សម្រាប់ពិនិត្យនិងផ្តល់យោបល់លើកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន ត្រូវចាប់ផ្តើមរាប់សាជាថ្មី នៅពេលដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទទួលបានពាក្យស្នើសុំឱ្យពិនិត្យ ដែលម្ចាស់គម្រោងបានធ្វើការកែតម្រូវរួចជាស្ថាពរស្របតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដែលបានផ្តល់យោបល់។

៣- ករណីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ខកខានមិនបានបញ្ជូនយោបល់ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រសួងស្ថាប័នមានសមត្ថកិច្ច និង/ឬរាជរដ្ឋាភិបាលសម្រេចអាចកំណត់ថា គម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃក្រមនេះ។

៤- ម្ចាស់គម្រោងត្រូវទទួលខុសត្រូវចំពោះព្យសនកម្មនានាដែលបង្កឡើងដោយកំហុស ដែលបណ្តាលមកពីការយឺតយ៉ាវឬការខកខានមិនបានធ្វើការកែសម្រួលកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថានឱ្យត្រូវតាមសេចក្តីបង្គាប់ ឬសេចក្តីណែនាំខាងលើ។

**មាត្រា៦៦៥ ._ ការឯកភាព បដិសេធ ឬកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង**

១- ការផ្តល់យោបល់ឯកភាព បដិសេធ ឬកែតម្រូវផ្សេងៗទៅលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ត្រូវធ្វើឡើងដោយពិចារណាលើហេតុប៉ះពាល់អវិជ្ជមាននិងវិជ្ជមានទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងផលចំណេញផ្នែកសេដ្ឋកិច្ច និងតម្លៃនៃការខូចខាតបរិស្ថាន។

២- ក្នុងករណីដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវចេញលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនៃគម្រោងនោះដោយភ្ជាប់ជាមួយកិច្ចសន្យាការពារបរិស្ថាន។



៧៥

៣- ក្នុងករណីដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបដិសេធលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវបញ្ជាក់ពីហេតុផលនៃសេចក្ដីសម្រេចរបស់ខ្លួន។

៤- ក្នុងករណីដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ផ្ដល់យោបល់ឱ្យធ្វើការកែតម្រូវលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង នោះក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវភ្ជាប់ហេតុផល និងចង្អុលបង្ហាញដោយច្បាស់ៗពីចំណុចដែលត្រូវកែតម្រូវ។

**មាត្រា៦៦៦ ._ សុពលភាពនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងកិច្ចសន្យាការពារបរិស្ថាន**

១- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញមានសុពលភាព លុះត្រាតែរបាយការណ៍នោះត្រូវបានរៀបចំឡើងដោយក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលទទួលបាននីតិសម្បទាពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយអនុលោមតាមនីតិវិធី លក្ខខណ្ឌ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានា។

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងមានសុពលភាព លុះត្រាតែរបាយការណ៍នោះត្រូវបានរៀបចំឡើងដោយម្ចាស់គម្រោង និង/ឬតាមរយៈទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គល ដោយអនុលោមតាមនីតិវិធី លក្ខខណ្ឌ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣- កិច្ចសន្យាការពារបរិស្ថានមានសុពលភាពលុះត្រាតែកិច្ចសន្យានោះអនុលោមតាមនីតិវិធី លក្ខខណ្ឌ បទប្បញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តនានារបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៦៧ ._ សុពលភាពនៃលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

១- លិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន មានសុពលភាពទៅតាមគម្រោងអភិវឌ្ឍដូចមានកំណត់ក្នុងអនុក្រឹត្យ។

២- ក្នុងករណីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិពិនិត្យឃើញថាមានការផ្លាស់ប្ដូរផែនការមេ និង/ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ពុំមានលក្ខណៈសមស្រប ឬមិនមានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិ តម្រូវឱ្យម្ចាស់គម្រោងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឡើងវិញ និង/ឬធ្វើបច្ចុប្បន្នកម្មរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ដើម្បីទទួលបានជាថ្មីនូវលិខិតនិងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។

**មាត្រា៦៦៨ ._ ការហាមឃាត់ចំពោះសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោង**

១- ម្ចាស់គម្រោងមិនត្រូវចាប់ផ្ដើមសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងមុនពេលទទួលបានលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន។ ក្នុងករណីដែលគម្រោងអភិវឌ្ឍគ្មានលិខិត និងវិញ្ញាបនបត្រ

ROYAUME DU CAMBODGE ★ LE MINISTRE DU PALAIS ROYAL



HS

ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិសម្រេចផ្អាកសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងទាំងស្រុង។

២- ម្ចាស់គម្រោងត្រូវលើកស្លាកសញ្ញា ឬបិទវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាននៅខាងមុខការដ្ឋាន។

៣- រាល់កិច្ចព្រមព្រៀងសម្បទានដែលផ្តល់ជូនដោយរាជរដ្ឋាភិបាលកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន។

**មាត្រា៦៦៩ .- ការផ្ទេរឬការផ្លាស់ប្តូរម្ចាស់គម្រោង**

១- ក្នុងករណីដែលមានការផ្ទេរឬផ្លាស់ប្តូរម្ចាស់គម្រោង លិខិតឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និង/ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និង/ឬកិច្ចសន្យាការពារបរិស្ថាន និងលក្ខខណ្ឌទាំងអស់ ត្រូវផ្ទេរទៅម្ចាស់គម្រោងថ្មីដោយស្វ័យប្រវត្តិ។

២- ការផ្ទេរឬការផ្លាស់ប្តូរម្ចាស់គម្រោងទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសុពលភាពអនុវត្តលុះត្រាតែការផ្ទេរ ឬការផ្លាស់ប្តូរនោះទទួលបានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៥
## ការវាយតម្លៃបរិស្ថានបន្ថែម

**មាត្រា៦៧០ .- គោលបំណងនៃការវាយតម្លៃហានិភ័យ**

ការវាយតម្លៃហានិភ័យត្រូវអនុវត្តដើម្បី៖

ក- កំណត់អត្តសញ្ញាណនិងផ្តល់អាទិភាពដល់សកម្មភាពនានាដែលត្រូវអនុវត្ត។

ខ- ជួយនៅក្នុងការបែងចែកធនធានដើម្បីកាត់បន្ថយជាអប្បបរមានូវការខូចខាតបរិស្ថាន។

គ- កំណត់អំពីកម្រិតនៃការស្តារបរិស្ថានឡើងវិញដែលចាំបាច់ ដើម្បីជួសជុលហេតុប៉ះពាល់បរិស្ថានអវិជ្ជមាន។

ឃ- កំណត់អំពីពេលវេលាដែលការស្តារបរិស្ថានឡើងវិញអាចត្រូវបានបញ្ចប់និងបំពេញចប់សព្វគ្រប់។

ង- ធានាតម្លាភាព ឬធានាភាពរឹងប៉ឹងលើការគ្រប់គ្រងហានិភ័យដែលបង្កឡើងដោយសកម្មភាព ឬគម្រោង។

ច- ជូនដំណឹងដល់សាធារណជន។

ឆ- ទប់ស្កាត់និងកាត់បន្ថយជាអប្បបរមានូវហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម។

**មាត្រា៦៧១ .- គោលដៅនៃការវាយតម្លៃហានិភ័យ**

ការវាយតម្លៃហានិភ័យមានគោលដៅកំណត់អត្តសញ្ញាណ និងវាយតម្លៃហានិភ័យជាក់ស្តែងដែលអាចកើតឡើងចំពោះបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្សដែលបណ្តាលមកពីការសម្រេចចិត្ត ការឯកភាពសកម្មភាព ឬគម្រោង ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៤៥

**មាត្រា៦៧២ .- សុពលភាពនៃការវាយតម្លៃហានិភ័យ**

១- ការវាយតម្លៃហានិភ័យត្រូវធ្វើឡើងដោយម្ចាស់គម្រោង និងបញ្ជូនមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ ឬរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចមុននឹងចេញសេចក្តីសម្រេចនិងការឯកភាពទាំងអស់ មានជាអាទិ៍ ការចេញលិខិតអនុញ្ញាតឬការឯកភាព ដូចមានចែងនៅក្នុងក្រមនេះ សម្រាប់សកម្មភាពឬគម្រោងដែលមានហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម។

២- ការវាយតម្លៃហានិភ័យជាផ្នែកមួយ នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន។

**មាត្រា៦៧៣ .- លក្ខខណ្ឌតម្រូវសម្រាប់ទីប្រឹក្សាដែលមានការទទួលស្គាល់**

រាល់ការវាយតម្លៃហានិភ័យទាំងអស់ ត្រូវរៀបចំដោយក្រុមហ៊ុនទីប្រឹក្សាដែលមានការទទួលស្គាល់ឬដែលទទួលបានការឯកភាព ដើម្បីអនុវត្តការងារនេះពីសំណាក់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចដទៃទៀត។

**មាត្រា៦៧៤ .- លិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ ដែលមានជាអាទិ៍ គោលការណ៍ណែនាំស្តីពីខ្លឹមសារនិងទម្រង់នៃរបាយការណ៍វាយតម្លៃហានិភ័យ ការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងលក្ខណសម្បត្តិដែលតម្រូវឱ្យមានសម្រាប់ទីប្រឹក្សាវាយតម្លៃហានិភ័យដែលមានការទទួលស្គាល់និងដែលទទួលបានការឯកភាព ដោយប្រើប្រាស់នូវទម្លាប់អនុវត្តដ៏ប្រសើរបំផុត គោលការណ៍ផ្នែកវិទ្យាសាស្ត្រ និងគោលការណ៍វាយតម្លៃហានិភ័យដែលត្រឹមត្រូវ។

**មាត្រា៦៧៥ .- របាយការណ៍ស្តីពីការវាយតម្លៃហានិភ័យ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត ត្រូវធានាថារបាយការណ៍នៃលទ្ធផលនៃការវាយតម្លៃហានិភ័យនីមួយៗត្រូវបានរៀបចំស្របតាមលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហានិភ័យ។ របាយការណ៍វាយតម្លៃហានិភ័យបែបនេះត្រូវរៀបចំ និងសម្រេចជាចុងក្រោយដោយទីប្រឹក្សាដែលមានការទទួលស្គាល់ ឬទទួលបានការឯកភាពក្នុងការអនុវត្តការងារនេះពីសំណាក់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**មាត្រា៦៧៦ .- ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ**

ទីប្រឹក្សាដែលរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយអនុលោមតាមគោលការណ៍ ដែលបានចែងក្នុងក្រមនេះ។

**មាត្រា៦៧៧ .- ការទទួលបានព័ត៌មានពីការវាយតម្លៃហានិភ័យ**

ប្រព័ន្ធគ្រប់គ្រងទិន្នន័យអំពីសកម្មភាពនៃការវាយតម្លៃហានិភ័យទាំងអស់ និងរបាយការណ៍វាយតម្លៃហានិភ័យដែលបានបញ្ចប់ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន ស្របតាមបញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យត្រូវរក្សាដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

**មាត្រា៦៧៨ ._ ការវាយតម្លៃហានិភ័យនិរន្តរភាព**

រាល់ស្ថាប័នហិរញ្ញវត្ថុនិងនីតិបុគ្គលដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចីចំពោះសកម្មភាពឬគម្រោង ត្រូវអនុវត្តការវាយតម្លៃហានិភ័យនិរន្តរភាព ដើម្បីកំណត់ថាសកម្មភាពឬគម្រោងដែលបានស្នើឡើងត្រូវបានវាយតម្លៃ និងពិចារណាដោយពេញលេញអំពីហេតុប៉ះពាល់បរិស្ថាន ដែលអាចកើតឡើងនៅក្នុងការរចនា ការគ្រប់គ្រងបរិស្ថាន ប្រតិបត្តិការ និងការបិទសកម្មភាពឬគម្រោងដែលបានស្នើឡើង។

**មាត្រា៦៧៩ ._ ការវាយតម្លៃពីថ្លៃចំណាយលើហានិភ័យនិរន្តរភាព**

ការវាយតម្លៃហានិភ័យនិរន្តរភាពត្រូវធានាថាការសិក្សាបុរេលទ្ធភាពសម្រាប់សកម្មភាព ឬគម្រោងដែលបានស្នើឡើងមានដាក់បញ្ចូលនូវថ្លៃចំណាយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន រួមបញ្ចូលថ្លៃចំណាយសម្រាប់អនុវត្តផែនការគ្រប់គ្រងបរិស្ថាន ការទទួលខុសត្រូវទាំងអស់សម្រាប់ការដោះស្រាយ និងសំណងសម្រាប់ការខូចខាតបរិស្ថាន ការបង់ប្រាក់ទាំងអស់ដែលតម្រូវឱ្យមានសម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី និងការធានាផ្នែកហិរញ្ញវត្ថុដែលគ្រប់គ្រាន់សម្រាប់ការបិទ ការស្តារបរិស្ថានឡើងវិញ ការជួសជុល ឬការបញ្ចប់គម្រោង តាមភាពចាំបាច់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ដែលពាក់ព័ន្ធ។

**មាត្រា៦៨០ ._ ការទទួលខុសត្រូវនៅក្នុងករណីដែលគ្មានការវាយតម្លៃហានិភ័យនិរន្តរភាព**

រាល់ស្ថាប័នហិរញ្ញវត្ថុនិងនីតិបុគ្គលដែលផ្តល់ការធានាផ្នែកហិរញ្ញវត្ថុ ការធានារ៉ាប់រងហិរញ្ញវត្ថុ ឬកម្ចីចំពោះសកម្មភាព ឬគម្រោងដែលមិនអនុវត្តការវាយតម្លៃហានិភ័យនៃនិរន្តរភាពត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬសំណងលើការខូចខាត សម្រាប់ហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់លើបរិស្ថាន ដែលបង្កឡើងដោយសកម្មភាព ឬគម្រោងនានា។

**មាត្រា៦៨១ ._ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការប្រែប្រួលអាកាសធាតុ**

១- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវដាក់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់នៃគម្រោងស្នើសុំដែលបង្កឱ្យមានការប្រែប្រួលអាកាសធាតុ មានជាអាទិ៍ ការគណនាបរិមាណនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់គម្រោងអភិវឌ្ឍ រួមបញ្ចូលការវិភាគលើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

២- ម្ចាស់គម្រោងត្រូវសិក្សាអំពីជម្រើសថាមពលនានាដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាប និងសិក្សាអំពីតម្រូវការក្នុងការកាត់បន្ថយការប្រែប្រួលចំពោះការផ្គត់ផ្គង់ទឹកដែលបណ្តាលមកពីកត្តាអាកាសធាតុ។

**មាត្រា៦៨២ ._ ការវិភាគនិងការវាយតម្លៃពីសក្តានុពលហេតុប៉ះពាល់ចំពោះការប្រែប្រួលអាកាសធាតុ**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគ និងវាយតម្លៃពីភាពងាយរងគ្រោះនៃគម្រោង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសកម្មភាពរបស់គម្រោងទៅលើបរិស្ថាន សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដើម្បីសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច ដោយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់តិច។

**មាត្រា៦៨៣ ._ ការវាយតម្លៃហេតុប៉ះពាល់សុខភាព**

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវរាប់បញ្ចូលនូវការវាយតម្លៃហេតុប៉ះពាល់សុខភាពដែលមានជាអាទិ៍៖

ក- ទិន្នន័យមូលដ្ឋានស្តីពីសុខភាពនៅក្នុងតំបន់គម្រោងនិងរបស់ប្រជាជនដែលរងហេតុប៉ះពាល់។

ខ- ការពណ៌នាអំពីហេតុប៉ះពាល់នៃគម្រោងដែលអាចមាន ដោយសារការសាងសង់ លំហូរប្រជាជន និងការផ្លាស់ប្តូរចំពោះបរិស្ថាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

គ- វិធានការកាត់បន្ថយហេតុប៉ះពាល់ ដើម្បីកាត់បន្ថយឬលុបបំបាត់ហេតុប៉ះពាល់អវិជ្ជមាននៃគម្រោង និងវិធានការដែលត្រូវដាក់ឱ្យអនុវត្តដោយម្ចាស់គម្រោង ដើម្បីកែលម្អសុខភាពរបស់សហគមន៍មូលដ្ឋាន។

ឃ- បញ្ហានានាទាក់ទងនឹងការអង្កេតតាមដានសុខភាព និងការគ្រប់គ្រងហេតុប៉ះពាល់ដែលនៅសល់ក្នុងរយៈពេលខ្លីនិងវែងសម្រាប់គម្រោង។

**មាត្រា៦៨៤.- ការវិភាគពីហានិភ័យនៃការវាយតម្លៃហេតុប៉ះពាល់សុខភាព**

ក្នុងការវាយតម្លៃហេតុប៉ះពាល់សុខភាព ម្ចាស់គម្រោងត្រូវ៖

ក- លើកផែនការគ្រប់គ្រងសុវត្ថិភាព និងសុខភាពជាផ្នែកមួយនៃការវាយតម្លៃហេតុប៉ះពាល់សុខភាពសម្រាប់បរិស្ថានការងារ ដោយវិភាគពីហានិភ័យដែលពាក់ព័ន្ធ និងប្រភេទនៃកត្តាគ្រោះថ្នាក់ក្នុងទីតាំងគម្រោង ជាអាទិ៍ កត្តាគ្រោះថ្នាក់ផ្នែករូបសាស្ត្រ គីមីសាស្ត្រ ជីវសាស្ត្រ និងវិទ្យុសកម្ម។

ខ- កំណត់និងវាយតម្លៃហានិភ័យនិងសក្ដានុពលនៃហេតុប៉ះពាល់ទៅលើសុវត្ថិភាព និងសុខភាពរបស់សហគមន៍មូលដ្ឋានក្នុងដំណាក់កាលរចនាគម្រោង សាងសង់គម្រោង អនុវត្តគម្រោង និងបញ្ចប់គម្រោង ព្រមទាំងលើកវិធានការគាំពារនិងផែនការគ្រប់គ្រងហេតុប៉ះពាល់នៅក្នុងដំណាក់កាលទាំងនេះ។

**មាត្រា៦៨៥.- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្ដុំ**

១- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវវិភាគ និងវាយតម្លៃពីបណ្ដុំនៃហេតុប៉ះពាល់ដែលបង្កឡើងដោយគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគត នៅជុំវិញទីតាំងគម្រោងទាំងនោះ ដែលអាចបង្កើតឱ្យមានហេតុប៉ះពាល់គួរឱ្យកត់សម្គាល់ដល់បរិស្ថាន សេដ្ឋកិច្ចសង្គម និងវប្បធម៌។

២- នៅក្នុងរបាយការណ៍វាយតម្លៃបណ្ដុំនៃហេតុប៉ះពាល់ ម្ចាស់គម្រោងត្រូវវាយតម្លៃសមត្ថភាពនៃធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដើម្បីគិតគូរអំពីហេតុប៉ះពាល់បន្ថែម ដោយផ្អែកលើកត្តាពេលវេលា ស្ថានភាពភូមិសាស្ត្រ និងសកម្មភាពរបស់គម្រោងនានាដែលនៅជុំវិញទីតាំងគម្រោង។

៣- ម្ចាស់គម្រោងត្រូវពិចារណាអំពីជម្រើសនៃវិធានការកាត់បន្ថយបណ្ដុំនៃហេតុប៉ះពាល់ផ្សេងៗ ដើម្បីកាត់បន្ថយ ឬបញ្ចៀសបណ្ដុំនៃហេតុប៉ះពាល់ដែលគួរឱ្យកត់សម្គាល់ទាំងនោះ។

**មាត្រា៦៨៦.- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន**

១- គម្រោងអភិវឌ្ឍដែលអាចមានហេតុប៉ះពាល់បរិស្ថានឆ្លងដែន ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដោយអនុលោមតាមច្បាប់ និងលិខិតុបករណ៍អន្តរជាតិពាក់ព័ន្ធនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។ ក្នុងករណីនេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនត្រូវបញ្ចូលក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីលក្ខណវិនិច្ឆ័យកំណត់ពីសញ្ញាណនៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន និងឈានទៅដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

៣- បែបបទនិងនីតិវិធីនៃការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែនត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី៦
## ការចូលរួមជាសាធារណៈក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

### មាត្រា៦៨៧ .- គោលបំណងនៃការចូលរួមជាសាធារណៈ

១- គោលបំណងចម្បងនៃការចូលរួមជាសាធារណៈ ត្រូវធានាថាគ្រប់ភាគីពាក់ព័ន្ធត្រូវបានចូលរួមនៅក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការរស់នៅប្រកបដោយចីរភាព និងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

២- នីតិវិធីនៃការចូលរួមជាសាធារណៈ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

### មាត្រា៦៨៨ .- សិទ្ធិរបស់អ្នកចូលរួមជាសាធារណៈក្នុងការធ្វើសកម្មភាព

ភាគីពាក់ព័ន្ធដែលមានសិទ្ធិក្នុងការចូលរួមជាសាធារណៈអាចធ្វើសកម្មភាព ដូចខាងក្រោម៖

ក- រាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធនិងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាននិងធនធានធម្មជាតិ។

ខ- លើកសំណួរស្នើឱ្យមានការស្រាយបំភ្លឺ ធ្វើការតវ៉ា និងចូលរួមពិភាក្សាអំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាននិងធនធានធម្មជាតិ។

គ- ដាក់ពាក្យប្តឹងឬបណ្តឹងប្រឆាំងនឹងសេចក្តីសម្រេចស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដូចមានចែងក្នុងមាតិកាទី១(នីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ)នៃគន្ថីទី៩នៃក្រមនេះ។

### មាត្រា៦៨៩ .- កាតព្វកិច្ចរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោង

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងម្ចាស់គម្រោងទាំងអស់ មុននឹងធ្វើសេចក្តីសម្រេចឬការឯកភាពលើករណីណាមួយដែលពាក់ព័ន្ធនឹងក្រមនេះត្រូវ៖

ក- ជូនដំណឹងនិងផ្តល់ព័ត៌មានចាំបាច់នានា ព្រមទាំងផ្តល់ពេលវេលាសមស្របដល់ភាគីពាក់ព័ន្ធសម្រាប់ការចូលរួមជាសាធារណៈ។

ខ- ផ្តល់ព័ត៌មានចាំបាច់នានាដល់ភាគីពាក់ព័ន្ធដោយក្នុងការផ្តល់ព័ត៌មានទាំងនោះ ត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាននិងវប្បធម៌របស់ភាគីពាក់ព័ន្ធទាំងនោះ។

គ- ពិចារណាលើចំណេះដឹងខាងផ្នែកបច្ចេកទេសនិង/ឬវិទ្យាសាស្ត្រ ធ្វើជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការសកម្មភាពនិងការធ្វើសេចក្តីសម្រេច។

ឃ- យកចិត្តទុកដាក់លើតម្រូវការនិងតម្លៃរបស់ភាគីពាក់ព័ន្ធ ក្នុងដំណើរការនៃការចូលរួមជាសាធារណៈ។

ង- ផ្តល់ពេលវេលាសមស្រប ដើម្បីធ្វើការវាយតម្លៃនិងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្តីសម្រេចណាមួយ។

ច- ពិចារណាអំពីទំហំនៃការចូលរួមជាសាធារណៈឱ្យមានភាពសមស្របជាមួយផលប្រយោជន៍ និងការខូចខាតរបស់ភាគីពាក់ព័ន្ធ។

ឆ- ធានាថាកិច្ចដំណើរការនៃការចូលរួមជាសាធារណៈមានលក្ខណៈបត់បែន និងអាចកែសម្រួលបានតាមការរំពឹងទុករបស់ភាគីពាក់ព័ន្ធ។

ជ- ធ្វើការពិចារណាគ្រប់មតិយោបល់របស់សាធារណជននៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ ការទទួលយកឬបដិសេធចំពោះមតិយោបល់ខាងលើនេះត្រូវបញ្ជាក់ពីហេតុផលសមរម្យ។

ROYAUME DU CAMBODGE LE MINISTRE du PALAIS ROYAL

**មាត្រា៦៩០ .- មតិយោបល់របស់សាធារណជនក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន**

ការចូលរួមជាសាធារណៈនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវៈ

ក- កត់ត្រាទុកនូវយោបល់របស់សាធារណជនដែលបានចូលរួម នៅក្នុងដំណាក់កាលរៀបចំផែនការនិងក្នុងដំណាក់កាលអនុវត្តលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- ផ្តោតលើបញ្ហានានា ដែលលើកឡើងដោយភាគីដែលទទួលរងហេតុប៉ះពាល់ ដែលអាចកើតមានពីគម្រោងដែលបានស្នើឡើង។

គ- ដាក់បញ្ចូលនូវសេចក្តីលម្អិតអំពីហេតុប៉ះពាល់របស់គម្រោងដល់សាធារណជន និងការទទួលយក ឬបដិសេធសំណើរបស់សាធារណជន។

ឃ- ផ្តល់ហេតុផលនៃការបដិសេធឱ្យបានច្បាស់លាស់ នៅក្នុងករណីដែលម្ចាស់គម្រោងបដិសេធសំណើរបស់សាធារណជន។

**មាត្រា៦៩១ .- ការពិគ្រោះយោបល់ជាមុន**

១- កិច្ចដំណើរការចូលរួមជាសាធារណៈត្រូវធានាថាមានការពិគ្រោះយោបល់ជាមុនពីអ្នកទទួលរងផលប៉ះពាល់ដោយសារគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើងដោយផ្អែកលើការពិគ្រោះយោបល់ និងបន្ទាប់ពីទទួលបានព័ត៌មានជាមុន។

២- ក្នុងវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននេះ ម្ចាស់គម្រោងត្រូវៈ

ក- កំណត់វិធានការនានា ក្នុងការលើកកម្ពស់ជីវភាពនិងជួយដល់អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង។

ខ- ធានាថាអ្នកដែលទទួលរងផលប៉ះពាល់បានចូលរួមក្នុងការរៀបចំការផ្លាស់ទីលំនៅថ្មី ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការផ្លាស់ទីលំនៅថ្មីឱ្យនៅត្រឹមកម្រិតអប្បបរមា និងធានាថាសំណងលើការបាត់បង់ទ្រព្យសម្បត្តិត្រូវបានដោះស្រាយដោយសមរម្យ ត្រឹមត្រូវ និងយុត្តិធម៌ជាមុនសិន ហើយវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានមានលក្ខណៈត្រឹមត្រូវ។

៣- ក្នុងករណីដែលសហគមន៍មូលដ្ឋានដែលរងផលប៉ះពាល់មិនយល់ស្រប ចំពោះវិធានការកាត់បន្ថយនានាដែលម្ចាស់គម្រោងបានស្នើខាងលើ គម្រោងអភិវឌ្ឍនៅតែបន្តដំណើរ តែម្ចាស់គម្រោងត្រូវកំណត់រកវិធានការកាត់បន្ថយហេតុប៉ះពាល់ផ្សេងទៀត ឬដោះស្រាយរាល់ហេតុប៉ះពាល់នោះដល់សហគមន៍មូលដ្ឋាន។

៤- នីតិវិធីនៃការដោះស្រាយសំណងដល់សហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ និងនីតិវិធីនៃការផ្លាស់ប្តូរលំនៅថ្មី ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៥- បែបបទនិងនីតិវិធីនៃការទូទាត់សំណងការខូចខាតដល់សហគមន៍មូលដ្ឋាន ដែលទទួលរងផលប៉ះពាល់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៦៩២ .- ការចូលរួមជាសាធារណៈលើវិធានការកាត់បន្ថយ**

១- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈត្រូវស្វែងរកនូវការយល់ព្រម ពីអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង។ ម្ចាស់គម្រោងត្រូវផ្តល់ផែនការគ្រប់គ្រងបរិស្ថានដែលត្រូវអនុញ្ញាតឱ្យមានការចូលរួមជាសាធារណៈ នៅក្នុងដំណើរការអង្កេតតាមដាន និងការគោរពតាមលក្ខខណ្ឌដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថានត្រូវពិចារណាអំពីមតិយោបល់នានារបស់អ្នកទទួលរងផលប៉ះពាល់ ចំពោះវិធានការកាត់បន្ថយហេតុប៉ះពាល់ដែលបានស្នើឡើង។

**មាត្រា៦៩៣ .- ការផ្សព្វផ្សាយជាសាធារណៈ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធានាថាព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងនិងឯកសារពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយជាសាធារណៈ ហើយភាគីពាក់ព័ន្ធនិងសហគមន៍មូលដ្ឋានដែលទទួលរងផលប៉ះពាល់ដោយសារគម្រោងអាចទទួលបានព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់ ។

២- ម្ចាស់គម្រោងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់ខ្លួនយ៉ាងហោចណាស់នូវឯកសារ ឬព័ត៌មានថតចម្លងនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងផែនការនៃគម្រោង ព្រមទាំងបណ្តាវិធានការកាត់បន្ថយហេតុប៉ះពាល់នៃគម្រោងដែលត្រូវបានស្នើឡើង។

៣- នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈនិងសិទ្ធិទទួលបានព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ជំពូកទី៧
## ផែនការគ្រប់គ្រងបរិស្ថាននិងការអង្កេតតាមដានគម្រោង

**មាត្រា៦៩៤ .- ការត្រួតពិនិត្យនិងអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ជាអាជ្ញាធរត្រួតពិនិត្យ និងអង្កេតតាមដានការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោង ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងភាគីពាក់ព័ន្ធ។

២- ម្ចាស់គម្រោងត្រូវអនុវត្តតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថានក្នុងរយៈពេល ៦(ប្រាំមួយ)ខែ ចាប់ពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន និង/ឬផែនការគ្រប់គ្រងបរិស្ថាន។

**មាត្រា៦៩៥ .- ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន**

១- ផែនការគ្រប់គ្រងបរិស្ថានត្រូវរៀបចំដោយម្ចាស់គម្រោង។

២- ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលលក្ខខណ្ឌតម្រូវនៃវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងឬកិច្ចសន្យាការពារបរិស្ថាន។

៣- ផែនការគ្រប់គ្រងបរិស្ថានត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំដោយអនុលោមតាមការវិវត្តជាក់ស្តែងនៃស្តង់ដារបរិស្ថាន ការអនុវត្តជាក់ស្តែងដែលទទួលស្គាល់ជាទូទៅក្នុងវិស័យនីមួយៗ ឬការប្រែប្រួលស្ថានភាពផ្សេងៗនៃគម្រោង។

**មាត្រា៦៩៦ .- ប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុង**

១- រាល់គម្រោងអភិវឌ្ឍ និងអ្នកប្រតិបត្តិការគម្រោងត្រូវបង្កើតក្រុមការងារទទួលបន្ទុកវិស័យត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងបរិស្ថាន និងរក្សាប្រព័ន្ធគ្រប់គ្រងបរិស្ថានផ្ទៃក្នុងដែលត្រូវធានាឱ្យមាននូវនីតិវិធី និងវិធីសាស្ត្រអង្កេតតាមដានដោយខ្លួនឯង ដូចមានចែងក្នុងផែនការគ្រប់គ្រងបរិស្ថាន។

២- ក្នុងករណីហេតុប៉ះពាល់បរិស្ថាន មានទំហំធំជាងហេតុប៉ះពាល់ដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬផែនការគ្រប់គ្រងបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវចាត់វិធានការកែតម្រូវហេតុប៉ះពាល់ភ្លាមៗឬកែតម្រូវផែនការគ្រប់គ្រងបរិស្ថាន។

៣- ផែនការគ្រប់គ្រងបរិស្ថាននិងកម្មវិធីអង្កេតតាមដានដែលបានកែតម្រូវរួច ត្រូវទទួលបានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការកែតម្រូវ ឬកែលម្អជាថ្មីឡើងវិញ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- ម្ចាស់គម្រោងត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានរៀងរាល់ត្រីមាស ឬឆមាស ហើយបញ្ជូនមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីពិនិត្យនិងវាយតម្លៃ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានសិទ្ធិចុះត្រួតពិនិត្យដល់កន្លែង និងផ្ទៀងផ្ទាត់លទ្ធផលនៃការអង្កេតតាមដានរបស់ម្ចាស់គម្រោង។

**មាត្រា៦៩៧ .- សិទ្ធិរាយការណ៍ពីបញ្ហាបរិស្ថាន**

១- អ្នកដែលទទួលរងផលប៉ះពាល់ដោយសារគម្រោង និងភាគីពាក់ព័ន្ធមានសិទ្ធិរាយការណ៍ពីបញ្ហា និងក្ដីកង្វល់ បរិស្ថាន និងសង្គម ជូនដល់ម្ចាស់គម្រោង និងដាក់ពាក្យបណ្ដឹងទៅក្រសួងស្ថាប័នមានសមត្ថកិច្ច។

២- ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវឆ្លើយតបចំពោះបណ្ដឹងឬញត្តិ ហើយដោះស្រាយបញ្ហាបរិស្ថាននិងសង្គមដែលពាក់ព័ន្ធ តាមពេលវេលាសមស្រប និងផ្ដល់ព័ត៌មានដល់ភាគីពាក់ព័ន្ធតាមស្ថានភាពជាក់ស្ដែង។

៣- បែបបទនិងនីតិវិធីនៃការដោះស្រាយបណ្ដឹងឬញត្តិ ត្រូវកំណត់យោងតាមនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិដែលមានចែងក្នុងក្រមនេះ។

**មាត្រា៦៩៨ .- ការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាន**

១- ម្ចាស់គម្រោងនីមួយៗត្រូវរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថាននៃគម្រោង ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការរៀបចំរបាយការណ៍អង្កេតតាមដានបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៦៩៩ .- ការរៀបចំបញ្ជូនរបាយការណ៍ប្រចាំត្រីមាសឬឆមាស**

១- ម្ចាស់គម្រោងដែលមានលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថានត្រូវបញ្ជូនរបាយការណ៍ប្រចាំត្រីមាសឬឆមាស ទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិទាក់ទងនឹងការអង្កេតតាមដាន និងការគ្រប់គ្រងបរិស្ថានរបស់ខ្លួន។

២- ម្ចាស់គម្រោងត្រូវសិក្សាឡើងវិញនូវរាល់ចំណុចខ្វះខាតក្នុងរបាយការណ៍ប្រចាំត្រីមាស ឬឆមាសដែលក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបានពិនិត្យនិងផ្ដល់យោបល់ ហើយត្រូវបញ្ចូលចំណុចខ្វះខាតនេះក្នុងរបាយការណ៍ប្រចាំត្រីមាសឬឆមាសបន្ទាប់ រួចបញ្ជូនមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីពិនិត្យនិងវាយតម្លៃឡើងវិញ។ ម្ចាស់គម្រោងត្រូវរាយការណ៍ភ្លាមៗអំពីផលប៉ះពាល់បរិស្ថានអវិជ្ជមានដល់ក្រសួងស្ថាប័នពាក់ព័ន្ធ និងដល់សាធារណជន ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមានមកលើបរិស្ថាននិងសង្គម។

៣- ម្ចាស់គម្រោងត្រូវផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាននៃគម្រោង ដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ តាមការណែនាំរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី៨
# សវនកម្មបរិស្ថាន

**មាត្រា៧០០ ._ សវនកម្មបរិស្ថាន**

១- ការអនុវត្តគម្រោង ឬសកម្មភាពណាមួយដែលទទួលបានការឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង កិច្ចសន្យាការពារបរិស្ថាន ឬលិខិតអនុញ្ញាតត្រូវធ្វើសវនកម្មបរិស្ថានដែលមានលក្ខណៈឯករាជ្យនិងត្រូវបានចងក្រងទុកជាឯកសារ។

២- ការធ្វើសវនកម្មបរិស្ថានមានដូចខាងក្រោម៖

ក- ពិនិត្យ និងបញ្ជាក់ពីគម្រោង ឬសកម្មភាពណាមួយដែលអនុលោមតាមលក្ខខណ្ឌតម្រូវរបស់ក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ខ- កំណត់និងបង្ហាញពីហេតុប៉ះពាល់បរិស្ថានរបស់គម្រោងឬសកម្មភាពណាមួយ។

គ- កំណត់និងបង្ហាញពីវិធានការណាមួយដែលអាចអនុវត្តបាន ដើម្បីធ្វើការកែតម្រូវឱ្យស្របតាមលក្ខខណ្ឌតម្រូវ។

ឃ- កាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថានឱ្យនៅត្រឹមកម្រិតអប្បបរមា។

**មាត្រា៧០១ ._ វិសាលភាពនៃគម្រោងឬសកម្មភាពដែលត្រូវធ្វើសវនកម្មបរិស្ថាន**

ប្រភេទគម្រោងឬសកម្មភាពដែលជាកម្មវត្ថុនៃការធ្វើសវនកម្មបរិស្ថាន នីតិវិធីនិងរយៈពេលជាក់លាក់នៃការធ្វើសវនកម្មបរិស្ថាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧០២ ._ គម្រោងតម្រូវធ្វើសវនកម្មបរិស្ថានខាងក្រៅ**

គម្រោងនានាដែលត្រូវបានកំណត់ នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែករបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ស្តីពីបញ្ជីនៃគម្រោងដែលតម្រូវឱ្យមានការធ្វើសវនកម្មបរិស្ថានខាងក្រៅត្រូវធ្វើសវនកម្មដោយសវនករបរិស្ថានឯករាជ្យដែលមានលក្ខណសម្បត្តិ ដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិស្តីពីការធ្វើសវនកម្មបរិស្ថានខាងក្រៅ។

**មាត្រា៧០៣ ._ ការតែងតាំងនិងលក្ខណសម្បត្តិរបស់សវនករបរិស្ថាន**

១- បុគ្គលដែលទទួលបាននីតិសម្បទាជាសវនករបរិស្ថាន អាចអនុវត្តសវនកម្មបរិស្ថានបានដោយមានការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- នីតិវិធីនិងគោលការណ៍ណែនាំក្នុងការទទួលស្គាល់សវនកម្មបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧០៤ ._ តួនាទីនិងភារកិច្ចរបស់សវនករបរិស្ថានឯករាជ្យ**

សវនករបរិស្ថានឯករាជ្យមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ជួយជ្រោមជ្រែងក្នុងការធ្វើកំណត់ត្រាបរិស្ថានឱ្យបានត្រឹមត្រូវនិងពេញលេញ។

ខ- ផ្តល់មតិយោបល់សវនកម្មវិជ្ជាជីវៈជាអាទិ៍ របាយការណ៍បរិស្ថានដែលបង្ហាញនូវទិដ្ឋភាពពេញលេញ និងសមស្របអំពីការគ្រប់គ្រងបរិស្ថាននៃគម្រោងឬប្រតិបត្តិការរបស់គម្រោង។



ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

គ- ពិនិត្យភាពគ្រប់គ្រាន់នៃការអនុវត្តនីតិវិធីនៃការគ្រប់គ្រង និងការអង្កេតតាមដានបរិស្ថានផ្ទៃក្នុងព្រមទាំងការផ្តល់អនុសាសន៍ដើម្បីកែលម្អ។

ឃ- ផ្តល់ព័ត៌មានអំពីភាពមិនប្រក្រតីនិងការខ្វះចន្លោះក្នុងការគ្រប់គ្រងបរិស្ថានផ្ទៃក្នុងរបស់ខ្លួន។

ង- ត្រូវផ្តល់សំណៅច្បាប់ដើមមួយច្បាប់នៃរបាយការណ៍សវនកម្ម ជូនក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។

**មាត្រា៧០៥ .- ការចំណាយចំពោះការធ្វើសវនកម្មបរិស្ថាន**

រាល់ការចំណាយដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មបរិស្ថាន ត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ប្រតិបត្តិករ ឬម្ចាស់គម្រោង។

**មាត្រា៧០៦ .- ការខកខានមិនបានធ្វើតាមបទបញ្ញត្តិឬលក្ខខណ្ឌតម្រូវ**

១- ក្នុងករណីដែលម្ចាស់គម្រោង ខកខានមិនបានធ្វើតាមបទបញ្ញត្តិឬលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវណែនាំឱ្យម្ចាស់គម្រោងជ្រើសរើសសវនករបរិស្ថានដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីរៀបចំរបាយការណ៍សវនកម្មបរិស្ថានលើគម្រោង ឬសកម្មភាពណាមួយនោះ។

២- រាល់ការចំណាយដែលទាក់ទងទៅនឹងសវនកម្មបរិស្ថាន ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ជាបន្ទុករបស់ម្ចាស់គម្រោង។

**មាត្រា៧០៧ .- ការអង្កេតតាមដាននិងការរៀបចំរបាយការណ៍**

ម្ចាស់គម្រោងដែលទទួលបានការឯកភាពលើ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង កិច្ចសន្យាការពារបរិស្ថាន ឬលិខិតអនុញ្ញាត ត្រូវអនុវត្តការអង្កេតតាមដាន និងរៀបចំរបាយការណ៍សវនកម្មបរិស្ថាន ស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងក្រមនេះនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀត។

**មាត្រា៧០៨ .- ដំណោះស្រាយផលប៉ះពាល់**

ក្នុងករណីដែលសវនកម្មបរិស្ថានបង្ហាញឱ្យឃើញថាផលប៉ះពាល់របស់គម្រោង និង/ឬសកម្មភាពនោះធំជាងអ្វីដែលបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវចាត់វិធានការភ្លាមៗដើម្បីដោះស្រាយផលប៉ះពាល់ទាំងនោះ និងបញ្ជាឱ្យធ្វើការកែតម្រូវលើផែនការគ្រប់គ្រងបរិស្ថានឱ្យបានសមស្រប ដើម្បីបញ្ចៀសផលប៉ះពាល់នៅពេលអនាគត។

**មាត្រា៧០៩ .- ការស្វែងរកបាននូវព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍សវនកម្ម**

ព័ត៌មានពាក់ព័ន្ធនឹងរបាយការណ៍សវនកម្មបរិស្ថានត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ក្រោយពេលដែលរបាយការណ៍នោះត្រូវបានដាក់បញ្ជូនទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ ៚

## ជំពូកទី៩

## សិទ្ធិទទួលព័ត៌មាននិងបញ្ជីបរិស្ថានជាតិ

### ផ្នែកទី១

### សិទ្ធិទទួលបានព័ត៌មានបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៧១០ .- ការដាក់បង្ហាញព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានាថាព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចដាក់បង្ហាញឱ្យសាធារណជនស្វែងរកបាន។

២- ទម្រង់បែបបទនិងនីតិវិធីនៃការដាក់បង្ហាញព័ត៌មាន ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៧១១ .- សិទ្ធិទទួលព័ត៌មានពីក្រសួងស្ថាប័នសាធារណៈ**

១- បុគ្គលមានសិទ្ធិស្នើសុំព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែព័ត៌មានសម្ងាត់។

២- សិទ្ធិទទួលព័ត៌មានដូចបានបញ្ញត្តក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវអនុវត្តស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧១២ .- សិទ្ធិទទួលព័ត៌មានពីគម្រោងឯកជន**

បុគ្គលមានសិទ្ធិស្នើសុំព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តគម្រោងឯកជន ពីម្ចាស់គម្រោងលើកលែងតែព័ត៌មានសម្ងាត់។

**មាត្រា៧១៣ .- ការស្នើសុំដាក់ជាព័ត៌មានសម្ងាត់របស់គម្រោងវិនិយោគឯកជន**

១- ម្ចាស់គម្រោងវិនិយោគឯកជន មានសិទ្ធិស្នើសុំទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នពាក់ព័ន្ធ ឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកំណត់ព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការគម្រោងណាមួយជាព័ត៌មានសម្ងាត់។

២- បែបបទនិងនីតិវិធីក្នុងការកំណត់ព័ត៌មានសម្ងាត់របស់គម្រោងវិនិយោគឯកជន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ផ្នែកទី២
## បញ្ជីព័ត៌មានបរិស្ថានជាតិ

**មាត្រា៧១៤ .- ការរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំបញ្ជីព័ត៌មានបរិស្ថានជាតិដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៧១៥ .- ការទទួលបានព័ត៌មានជាសាធារណៈពីបញ្ជីព័ត៌មានបរិស្ថានជាតិ**

បញ្ជីព័ត៌មានបរិស្ថានជាតិជាព័ត៌មានដែលសាធារណជនអាចស្វែងរកបាន លើកលែងតែព័ត៌មានទាំងឡាយណាដែលជាព័ត៌មានសម្ងាត់សម្រាប់កិច្ចគាំពារដល់ប្រភេទសត្វ រុក្ខជាតិព្រៃ ឬសម្បត្តិវប្បធម៌ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

## ផ្នែកទី៣
## មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ

**មាត្រា៧១៦ .- មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ**

១- ត្រូវបង្កើតមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ ដើម្បីចងក្រងរក្សាទុករាល់ព័ត៌មានពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ។

LE MINISTRE DU PALAIS ROYAL



៨៥

២- ការរៀបចំ និងការប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧១៧ .- ការទទួលបានព័ត៌មានពីមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ**

ទិន្នន័យទាំងអស់ដែលរៀបចំដោយមជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន លើកលែងតែទិន្នន័យដែលចាត់ទុកជាព័ត៌មានសម្ងាត់ សម្រាប់ការពារប្រភេទសត្វ និងរុក្ខជាតិព្រៃ ឬសម្បត្តិវប្បធម៌ និងបេតិកភណ្ឌធម្មជាតិ។

## គន្ថីទី៦
## ការទទួលខុសត្រូវលើការខូចខាតបរិស្ថាននិងធនធានធម្មជាតិ
## មាតិកាទោល
## ការស្តារឡើងវិញ និងសំណងលើការខូចខាតបរិស្ថាននិងធនធានធម្មជាតិ
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧១៨ .- គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់អំពីកាតព្វកិច្ចរបស់ម្ចាស់គម្រោង និងប្រតិបត្តិករក្នុងការជួសជុល ការស្តារ និងការសងសំណងលើការបង្កផលប៉ះពាល់អវិជ្ជមាន ឬការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៧១៩ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពរបស់ម្ចាស់គម្រោង និងប្រតិបត្តិករ ដែលបង្កផលប៉ះពាល់អវិជ្ជមាន ឬខូចខាតបរិស្ថានឬធនធានធម្មជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៧២០ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវទទួលខុសត្រូវលើការគ្រប់គ្រង និងចាត់វិធានការលើរាល់សកម្មភាពរបស់ម្ចាស់គម្រោងឬប្រតិបត្តិករ ដែលបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៧២១ .- តួនាទីនិងភារកិច្ច**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិមានតួនាទី និងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំបច្ចេកទេស ដើម្បីគ្រប់គ្រង កំណត់អំពីទំហំ និងប្រភេទនៃការខូចខាតដល់បរិស្ថានឬធនធានធម្មជាតិ។

ខ- ចាត់វិធានការ បញ្ចៀស បង្ការ និងទប់ស្កាត់ ការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

គ- រៀបចំផែនការ និងនីតិវិធីបែបបទនៃការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ឃ- ចាត់វិធានការផ្លូវច្បាប់ ឬកសាងសំណុំរឿងទៅតុលាការដោយតាំងខ្លួនជាអង្គភាពដើមបណ្តឹងក្នុងការទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ង- ប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថានឬធនធានធម្មជាតិ។

ច- ធ្វើអធិការកិច្ច តាមដាន និងពិនិត្យវាយតម្លៃលើការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ឆ- ធ្វើការផ្សព្វផ្សាយជាសាធារណៈ ក្នុងករណីដែលការបំពុលបរិស្ថានឬធនធានធម្មជាតិ អាចបង្កឱ្យមានផលប៉ះពាល់ដល់សុខុមាលភាពសាធារណៈ។

ជ- រៀបចំចងក្រងរបាយការណ៍ពាក់ព័ន្ធនឹងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

## ជំពូកទី៣

## ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងឬប្រតិបត្តិករនៅមុនពេលមាន ការខូចខាតបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៧២២ .–** កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិករក្នុងការអនុវត្តវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ

១- ក្នុងករណីមានហានិភ័យកើតឡើងបន្ទាន់ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមាន ឬការខូចខាតដល់បរិស្ថានឬធនធានធម្មជាតិ ដោយសារការអនុវត្តសកម្មភាពគម្រោងរបស់ខ្លួន ម្ចាស់គម្រោងឬប្រតិបត្តិករ ត្រូវតែចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះភ្លាមៗ។ ក្នុងករណីដែលម្ចាស់គម្រោង ឬប្រតិបត្តិករមិនបានចាត់វិធានការ ឬចាត់វិធានការមិនបានគ្រប់គ្រាន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចតម្រូវឱ្យម្ចាស់គម្រោង ឬប្រតិបត្តិករ ចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះបាន។

២- វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងឱ្យបានសមស្របទៅតាមទំហំ និងប្រភេទនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ។ រាល់ការចំណាយទាក់ទងនឹងការចាត់វិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិ ជាបន្ទុករបស់ម្ចាស់គម្រោង ឬប្រតិបត្តិករ។

៣- ក្រោយពីបានអនុវត្តនូវវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិ ហើយម្ចាស់គម្រោងឬប្រតិបត្តិករត្រូវជូនដំណឹងអំពីការអនុវត្តវិធានការនោះទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិជាបន្ទាន់។

## ជំពូកទី៤

## ការទទួលខុសត្រូវរបស់ម្ចាស់គម្រោងឬប្រតិបត្តិករនៅពេលមាន ការខូចខាតបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៧២៣ .–** កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិករដែលធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិ

១- ក្នុងករណីមានការខូចខាតបរិស្ថានឬធនធានធម្មជាតិកើតឡើង ម្ចាស់គម្រោងឬប្រតិបត្តិករដែលធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិមានកាតព្វកិច្ចត្រូវទទួលខុសត្រូវចំពោះការខូចខាតនោះ។

២- ទោះបីមានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះក៏ដោយ ម្ចាស់គម្រោងឬប្រតិបត្តិករអាចរួចផុតពីកាតព្វកិច្ចទទួលខុសត្រូវ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការខូចខាតបណ្តាលមកពីសង្គ្រាមឬក្នុងករណីប្រធានសក្តិ។

ខ- ការខូចខាតត្រូវបានបង្កឡើងទាំងស្រុងដោយសារទង្វើ ឬការខកខានរបស់តតិយជនក្រៅពីបុគ្គលិកនិយោជិត ឬភ្នាក់ងាររបស់ម្ចាស់គម្រោងឬប្រតិបត្តិករ។

គ- ការខូចខាតដែលបានបង្កឡើងដោយសារតែសកម្មភាពដែលបានអនុញ្ញាតដោយច្បាប់។

ឃ- ការខូចខាតដែលបានបង្កឡើងដោយសកម្មភាពដែលបានអនុញ្ញាតជាពិសេស និងដែលបានពណ៌នាពីភាពជាក់លាក់ទាក់ទងនឹងប្រភេទ និងទំហំនៃការខូចខាតនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននិងធនធាន

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ធម្មជាតិ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬវិញ្ញាបនបត្រ និងលិខិតសម្រេចលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរួចហើយ។

៣- ការលើកលែងនូវការទទួលខុសត្រូវដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើម្ចាស់គម្រោងឬប្រតិបត្តិករបានបំពានធ្ងន់ធ្ងរនៅក្នុងការអនុវត្តនីតិវិធីស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត ឬបានបំពានធ្ងន់ធ្ងរទៅលើលក្ខខណ្ឌដែលបានកំណត់នៅក្នុងអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាត។

**មាត្រា៧២៤ ._ កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ**

ក្នុងករណីការខូចខាតបរិស្ថានឬធនធានធម្មជាតិបង្កឡើងដោយការអនុវត្តគម្រោង ដែលអាចស្តារឡើងវិញឱ្យមានលក្ខណៈល្អប្រសើរ ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវធ្វើការស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៧២៥ ._ កាតព្វកិច្ចទទួលខុសត្រូវសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ**

១- ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវសងសំណងនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដែលបង្កឡើងដោយការអនុវត្តគម្រោងរបស់ខ្លួន ក្នុងករណីណាមួយដូចខាងក្រោម៖

ក- មិនអាចធ្វើការស្តារឡើងវិញឱ្យមានលក្ខណៈល្អប្រសើរ។

ខ- ម្ចាស់គម្រោងឬប្រតិបត្តិករ ខកខានមិនបានអនុវត្តការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ ដូចបានបញ្ញត្តនៅក្នុងមាត្រា៧២៤ (កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ) នៃក្រមនេះ។

២- សំណងនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវកម្រិតត្រឹមទំហំនៃការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៧២៦ ._ កាតព្វកិច្ចជូនដំណឹងអំពីការខូចខាតបរិស្ថានឬធនធានធម្មជាតិ**

ក្នុងករណីដែលមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ម្ចាស់គម្រោងឬប្រតិបត្តិករត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិជាបន្ទាន់ អំពីព័ត៌មាននៃការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះ។

**មាត្រា៧២៧ ._ នីតិវិធីនៃការស្តារឡើងវិញនិងការសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ**

បែបបទ នីតិវិធីនៃការស្តារឡើងវិញ និងការសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដូចបានបញ្ញត្តនៅក្នុងមាត្រា៧២៤ (កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ) និងមាត្រា៧២៥ (កាតព្វកិច្ចទទួលខុសត្រូវសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ) នៃក្រមនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៧២៨ ._ សិទ្ធិទាមទារថ្លៃចំណាយនៃការអនុវត្តវិធានការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ**

បុគ្គលដែលមិនបានបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ តែបានចំណាយលើការអនុវត្តវិធានការស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ អាចទាមទារថ្លៃចំណាយនោះពីម្ចាស់គម្រោង ឬប្រតិបត្តិករដែលបានបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ដោយអនុលោមតាមក្រមរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលកំពុងនៅជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## វិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថាននិងធនធានធម្មជាតិឡើងវិញ

**មាត្រា៧២៩ ._ ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ**

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា៧២២(កាតព្វកិច្ចរបស់ម្ចាស់គម្រោងឬប្រតិបត្តិករក្នុងការអនុវត្តវិធានការទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិភ្លាមៗ)នៃក្រមនេះក៏ដោយ ក្នុងករណីមានហានិភ័យបន្ទាន់កើតឡើងដែលបង្កឱ្យមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចចាត់វិធានការចាំបាច់ ដើម្បីទប់ស្កាត់ការខូចខាតបរិស្ថានឬធនធានធម្មជាតិដោយខ្លួនឯង។

២- ទោះបីជាមានបញ្ញត្តិនៃមាត្រា៧២៤(កាតព្វកិច្ចស្តារឡើងវិញនូវការខូចខាតបរិស្ថានឬធនធានធម្មជាតិ)នៃក្រមនេះក៏ដោយ ក្នុងករណីមានការខូចខាតបរិស្ថានឬធនធានធម្មជាតិ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចចាត់វិធានចាំបាច់ ដើម្បីស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិនោះដោយខ្លួនឯង។

**មាត្រា៧៣០ ._ ការទាមទារថ្លៃចំណាយនៃការអនុវត្តវិធានការទប់ស្កាត់និងស្តារឡើងវិញ**

ក្នុងករណីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បានអនុវត្តវិធានការទប់ស្កាត់ដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី១នៃមាត្រា៧២៩(ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ) ឬវិធានការស្តារឡើងវិញដូចបានបញ្ញត្តនៅក្នុងកថាខណ្ឌទី២នៃមាត្រា៧២៩(ការអនុវត្តវិធានការទប់ស្កាត់និងស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ)នៃក្រមនេះ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចទាមទារថ្លៃចំណាយទៅលើការអនុវត្តវិធានការនោះ ពីម្ចាស់គម្រោងឬប្រតិបត្តិករ។

## គន្ថីទី៧
## ការអប់រំ ការស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍
## និងការយល់ដឹងអំពីបរិស្ថាន
## មាតិកាទោល
## គោលនយោបាយនិងយុទ្ធសាស្ត្រអប់រំ ស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា
## នវានុវត្តន៍និងយល់ដឹងអំពីបរិស្ថាន
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា៧៣១ ._ គោលបំណង**

មាតិកានេះ មានគោលបំណងលើកកម្ពស់ការអប់រំ ការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ និងការយល់ដឹងពាក់ព័ន្ធវិស័យបរិស្ថាន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព សុខដុមរមនាក្នុងបរិស្ថានល្អ ស្អាត សុវត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ី និងការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របតាមរយៈការពង្រឹង និងពង្រីកសមត្ថភាពស្រាវជ្រាវ អប់រំ កិច្ចសហប្រតិបត្តិការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ។

**មាត្រា៧៣២ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះក្រសួងស្ថាប័ន វិស័យឯកជន គ្រឹះស្ថានសិក្សា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល សហជីព និងអង្គភាពនានា ដែលបំពេញកិច្ចការពាក់ព័ន្ធនឹងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ ការងារអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងផ្តល់ការយល់ដឹងជាសាធារណៈអំពីបរិស្ថាន។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា៧៣៣ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ទទួលខុសត្រូវលើការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ ការគ្រប់គ្រងទិន្នន័យបរិស្ថាន និងដឹកនាំសម្របសម្រួលការងារអប់រំ និងការផ្សព្វផ្សាយព័ត៌មានបរិស្ថាន ព្រមទាំងចាត់ចែងរៀបចំព្រឹត្តិការណ៍បរិស្ថានសំខាន់ៗ។

**មាត្រា៧៣៤ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- រៀបចំសេចក្តីព្រាងគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព ផែនការថវិកា គោលការណ៍ណែនាំ និងកម្មវិធីនានាពាក់ព័ន្ធនឹងសកម្មភាពស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ពាក់ព័ន្ធវិស័យបរិស្ថាន ការគ្រប់គ្រងទិន្នន័យ ការអប់រំ និងការផ្សព្វផ្សាយ ព័ត៌មានបរិស្ថាន ព្រមទាំងការវាយតម្លៃការប្រតិបត្តិមេត្រីបរិស្ថាន។

ខ- ប្រមូល វិភាគ ចងក្រង និងគ្រប់គ្រងព័ត៌មាននិងទិន្នន័យបរិស្ថាន រួមទាំងកសាងនិងគ្រប់គ្រងប្រព័ន្ធប្រមូលផ្តុំទិន្នន័យបរិស្ថាន។

គ- រៀបចំ និងគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរិស្ថាន។

ឃ- រៀបចំរបាយការណ៍ស្តីពីស្ថានភាពបរិស្ថានជាតិ ដោយសហការនិងសម្របសម្រួលជាក្រសួងស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ង- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់សាធារណជន តាមរយៈការបញ្ជ្រាបការអប់រំបរិស្ថានក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ការផ្សព្វផ្សាយចំណេះដឹងអំពីបរិស្ថាន និងការលើកទឹកចិត្តការប្រតិបត្តិមេត្រីបរិស្ថាន។

ច- ផលិតនិងផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីសកម្មភាព ស្ថានភាព និងសមិទ្ធផលទាក់ទងនឹងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព។

ឆ- រៀបចំ និងចាត់ចែងព្រឹត្តិការណ៍ជាសាធារណៈពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន។

ជ- សម្របសម្រួលនិងសហការជាមួយអង្គភាពនានាក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជនដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពការងារគ្រប់គ្រងទិន្នន័យបរិស្ថាន និងការងារអប់រំផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មានស្តីពីបរិស្ថាន។

## ជំពូកទី៣

## គោលនយោបាយ យុទ្ធសាស្ត្រនិងយន្តការសម្របសម្រួល

**មាត្រា៧៣៥ .- គោលនយោបាយជាតិអប់រំបរិស្ថាន**

ក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ត្រូវសហការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិអប់រំបរិស្ថាន ដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំក្នុងប្រព័ន្ធគ្រប់កម្រិតបណ្តុះបណ្តាលវិជ្ជាជីវៈ សិក្សាស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា សមត្ថភាពនវានុវត្តន៍ និងការផ្សព្វផ្សាយចំណេះដឹងបរិស្ថានតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព។ គោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានអាចត្រូវបានពិនិត្យនិងកែសម្រួលឡើងវិញ តាមការវិវឌ្ឍ និងភាពជាក់ស្តែងនៃដំណើរវិវឌ្ឍន៍របស់សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

**មាត្រា៧៣៦ .‒ យន្តការសម្របសម្រួលការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន**

ការអនុវត្តគោលនយោបាយជាតិអប់រំបរិស្ថាន ត្រូវសម្របសម្រួលដោយយន្តការអន្តរក្រសួងទទួលបន្ទុកការងារគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន ដែលត្រូវបង្កើតឡើងដោយរាជរដ្ឋាភិបាលដើម្បីជំរុញការបញ្ជ្រាបផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានទៅក្នុងផែនការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**មាត្រា៧៣៧ .‒ ផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន**

ក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធនឹងការងារអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន ត្រូវរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ បរិស្ថានក្នុងបរិបទនៃដែនសមត្ថកិច្ចរបស់ខ្លួនដោយអនុលោមតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន។ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថានត្រូវធ្វើបច្ចុប្បន្នកម្មតាមការចាំបាច់ និងតម្រូវការជាក់ស្តែង។

**មាត្រា៧៣៨ .‒ ការអនុវត្តផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពអប់រំបរិស្ថាន**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាព ឬគ្រឹះស្ថានក្រោមឱវាទក្រសួងស្ថាប័នសាមី និងភាគីពាក់ព័ន្ធត្រូវអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាននេះ ឱ្យបានសមស្របទៅតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួនសំដៅធានាឱ្យបាននូវគុណភាពបរិស្ថាន កុល្យភាពនៃប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព។

## ជំពូកទី៤
## ការអប់រំនិងការស្រាវជ្រាវបរិស្ថាន
### ផ្នែកទី១
### ការអប់រំនិងបណ្តុះបណ្តាលបរិស្ថានក្នុងប្រព័ន្ធអប់រំ

**មាត្រា៧៣៩ .‒ កម្មវិធីអប់រំនិងបណ្តុះបណ្តាលបរិស្ថាន**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវមានកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈសម្រាប់ការអប់រំ ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមអង្គភាពរៀងៗខ្លួន។ ការរៀបចំកម្មវិធីសិក្សាគោលអំពីបរិស្ថាន និងសម្ភារៈឧបទេសត្រូវឱ្យស្របតាមគោលនយោបាយជាតិអប់រំស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍បរិស្ថាន និងដំណើរវិវឌ្ឍន៍របស់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។

**មាត្រា៧៤០ .‒ ធនធានគ្រូឧទ្ទេសនិងសាស្ត្រាចារ្យ**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកសាង និងអភិវឌ្ឍធនធានគ្រូឧទ្ទេស និងសាស្ត្រាចារ្យប្រកបដោយគុណវុឌ្ឍិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃក្រសួងស្ថាប័នសាមី។

**មាត្រា៧៤១ ._ តម្រូវការអប់រំនិងបណ្តុះបណ្តាល**

គ្រប់គ្រឹះស្ថានសិក្សាស្រាវជ្រាវក្រោមឱវាទក្រសួងស្ថាប័នពាក់ព័ន្ធនឹងការងារអប់រំបរិស្ថានទាំងអស់ ត្រូវកំណត់កម្មវិធីអប់រំបណ្តុះបណ្តាលអប្បបរមា ស្របតាមគោលដៅ និងតម្រូវការនៃការអប់រំបណ្តុះបណ្តាលរបស់អង្គភាពសាមី។

## ផ្នែកទី២

## ការស្រាវជ្រាវ វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍

**មាត្រា៧៤២ ._ មជ្ឈមណ្ឌលទិន្នន័យបរិស្ថានជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវបង្កើតមជ្ឈមណ្ឌលធនធានបរិស្ថានដែលជាមជ្ឈមណ្ឌលប្រមូលផ្តុំទិន្នន័យ ព័ត៌មាន វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បរិស្ថាន ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងសាធារណជន។

**មាត្រា៧៤៣ ._ ការស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

ក្រសួងស្ថាប័ន គ្រឹះស្ថានសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងប្រតិបត្តិករពាក់ព័ន្ធនឹងវិស័យបរិស្ថានត្រូវសហការរៀបចំវេទិកាវិទ្យាសាស្ត្រ កម្មវិធីឬសកម្មភាពសិក្សាស្រាវជ្រាវរួមគ្នាក្នុងលក្ខណៈជាការសំយោគគំនិតរវាងអ្នកធ្វើគោលនយោបាយ អ្នកវិទ្យាសាស្ត្រ និងអ្នកប្រតិបត្តិ ដើម្បីមានមូលដ្ឋានពុទ្ធិវិទ្យាសាស្ត្រសម្រាប់ការរៀបចំយុទ្ធសាស្ត្រ និងការធ្វើសេចក្តីសម្រេចក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

## ជំពូកទី៥

## ការយល់ដឹងអំពីបរិស្ថាននិងមេត្រីបរិស្ថាន

## ផ្នែកទី១

## ការផ្សព្វផ្សាយជាសាធារណៈអំពីបរិស្ថាន

**មាត្រា៧៤៤ ._ កម្មវិធីផ្សព្វផ្សាយចំណេះដឹងបរិស្ថាន**

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធត្រូវមានផែនការសកម្មភាព និងកម្មវិធីផ្សព្វផ្សាយចំណេះដឹងអំពីកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

**មាត្រា៧៤៥ ._ សកម្មភាពផ្សព្វផ្សាយចំណេះដឹងបរិស្ថាន**

រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ អង្គភាពជំនាញមានសមត្ថកិច្ច គ្រឹះស្ថានសាធារណៈ វិស័យឯកជន និងអ្នកពាក់ព័ន្ធ មានកាតព្វកិច្ចនិងភារកិច្ចផ្សព្វផ្សាយគោលនយោបាល យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងចំណេះដឹងពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ឱ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព។

**មាត្រា៧៤៦ ._ ការចូលរួមលើកកម្ពស់ការយល់ដឹងបរិស្ថាន**

ពលរដ្ឋគ្រប់រូបត្រូវមានករណីយកិច្ចចូលរួមលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីភាពចាំបាច់ និងសារប្រយោជន៍នៃកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅប្រកបដោយចីរភាព។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## មេត្រីបរិស្ថាន

**មាត្រា៧៤៧ .– ការទទួលស្គាល់និងលើកទឹកចិត្តប្រតិបត្តិមេត្រីបរិស្ថាន**

បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវទទួលស្គាល់ និងលើកទឹកចិត្ត។

**មាត្រា៧៤៨ .– សមត្ថកិច្ចផ្តល់ការទទួលស្គាល់និងលើកទឹកចិត្ត**

ការទទួលស្គាល់និងការលើកទឹកចិត្តដល់បុគ្គលដែលបានចូលរួមប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាន និងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ដែលរៀបចំដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៤៩ .– ការប្រឡងប្រណាំងមេត្រីបរិស្ថាន**

ក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងវិស័យឯកជនត្រូវធានានិរន្តរភាពនៃការរៀបចំឱ្យមានកម្មវិធីប្រឡងប្រណាំង និងលើកទឹកចិត្តដល់បុគ្គល ដែលបានប្រតិបត្តិសកម្មភាពមេត្រីបរិស្ថាននិងប្រើប្រាស់បច្ចេកវិទ្យាទ្រទ្រង់បរិស្ថាន។

## ផ្នែកទី៣
## សាលាមេត្រីបរិស្ថាន

**មាត្រា៧៥០ .– សាលាមេត្រីបរិស្ថាន**

១- កម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាន ត្រូវបានដាក់ឱ្យអនុវត្ត និងប្រឡងប្រជែងគ្នារៀងរាល់២(ពីរ)ឆ្នាំម្តង ដើម្បីលើកទឹកចិត្តដល់គ្រឹះស្ថានសិក្សាចំណេះទូទៅ មានជាអាទិ៍ បឋមសិក្សា និងមធ្យមសិក្សាឱ្យ៖

ក- បង្កើតគោលការណ៍ និងរដ្ឋបាលរបស់សាលាលើការងារបរិស្ថាន។

ខ- បង្កើតការបង្រៀនមេរៀនបរិស្ថាន និងសកម្មភាពអប់រំបរិស្ថានក្នុងសាលា និងតំបន់ដែលនៅជុំវិញជាកម្មវិធីសិក្សាបន្ថែម ឬបម្រាប។

គ- ដាក់ឱ្យមាននូវសម្ភារៈបរិក្ខាអប់រំបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធនានា និងការប្រតិបត្តិបរិស្ថានក្នុងគ្រឹះស្ថានសិក្សាចំណេះទូទៅ។

ឃ- សហការជាមួយភាគីពាក់ព័ន្ធ និងផ្សព្វផ្សាយពីការអប់រំបរិស្ថាន និងការប្រតិបត្តិបរិស្ថាននៅតាមតំបន់ដែលនៅជុំវិញគ្រឹះស្ថានសិក្សាចំណេះទូទៅ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យអប់រំ យុវជន និងកីឡាមានភារកិច្ច ដឹកនាំ គ្រប់គ្រង វាយតម្លៃ និងសម្រេចលើរាល់កិច្ចការដែលពាក់ព័ន្ធនឹងកម្មវិធីពានរង្វាន់សាលាមេត្រីបរិស្ថាននេះ។

**មាត្រា៧៥១ .– សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាន**

គ្រឹះស្ថានសិក្សានីមួយៗ ដែលជាបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាននឹងត្រូវបានវាយតម្លៃលើសូចនាករចំនួន១៨(ដប់ប្រាំបី)មានជាអាទិ៍៖

ក- ទស្សនវិស័យនិងបេសកកម្មដែលឆ្លុះបញ្ចាំងអំពីការលើកស្ទួយបរិស្ថាន។

ខ- គោលការណ៍ប្រតិបត្តិបរិស្ថាន។

គ- រចនាសម្ព័ន្ធដឹកនាំ ការអនុវត្តកម្មវិធី សាលាមេត្រីបរិស្ថាន។
ឃ- ផែនការថវិកាសម្រាប់អនុវត្តសកម្មភាពបរិស្ថាន។
ង- ប្រព័ន្ធរាយការណ៍ សកម្មភាពបរិស្ថាន និងហិរញ្ញវត្ថុ។
ច- កម្មវិធីសិក្សាគោលនិងបន្ថែមឬបញ្ជ្រាប ដែលបានដាក់បញ្ចូលមេរៀនស្តីពីការអប់រំបរិស្ថាន។
ឆ- ការកសាងសមត្ថភាពគ្រូបង្រៀនពីបរិស្ថាននិងធនធានធម្មជាតិ។
ជ- មេរៀននិងសកម្មភាពរៀនដែលសមស្របទៅនឹងបរិបទក្នុងស្រុកនិង/ឬតំបន់។
ឈ- សម្ភារៈឧបទេសបង្រៀនទាក់ទងនឹងបរិស្ថាន។
ញ- ក្រុមការងារ សកម្មភាព ដែលផ្សព្វផ្សាយអប់រំពីបរិស្ថាន។
ដ- បរិក្ខារប្រើប្រាស់ដែលធ្វើឱ្យមានមេត្រីភាពបរិស្ថាន។
ឋ- ការច្នៃប្រឌិតនិងការបង្កើតគំនិតសកម្មភាពថ្មីដែលមានមេត្រីភាពបរិស្ថាន។
ឌ- ទីធ្លាបៃតង ផ្ទៃបៃតង។
ឍ- សម្ភារៈឧបទេស សម្រាប់ការអនុវត្តផ្ទាល់នៅក្រៅថ្នាក់។
ណ- ការប្រតិបត្តិសកម្មភាពមេត្រីភាពបរិស្ថាន ឥរិយាបថរបស់សិស្សក្នុងការចូលរួមអនុវត្តមេត្រីភាពបរិស្ថាន។
ត- ដៃគូសហការនិងភាគីពាក់ព័ន្ធ។
ថ- កម្រិតនៃភាពជាដៃគូនិងការគាំទ្រ។
ទ- សកម្មភាពផ្សព្វផ្សាយតាមតំបន់។

**មាត្រា៧៥២ ._ សកម្មភាពសាលាមេត្រីបរិស្ថាន**

បន្ថែមពីលើសូចនាករ ដូចមានចែងក្នុងមាត្រា៧៥១(សូចនាករនៃបេក្ខភាពប្រឡងប្រជែងពានរង្វាន់សាលាមេត្រីបរិស្ថាន)នៃក្រមនេះ ការវាយតម្លៃលើបេក្ខភាពជ័យលាភីនៃពានរង្វាន់សាលាមេត្រីបរិស្ថាន នឹងត្រូវគិតផងដែរទៅលើសកម្មភាពផ្សេងទៀត មានជាអាទិ៍៖

ក- ការដាំស្មៅ ដាំដើមឈើ និងបន្លែ។
ខ- ការកាត់បន្ថយ ការបញ្ឈប់ការប្រើប្រាស់ថាមពលគីនូនៈ ហ្វូស៊ីលមកប្រើប្រាស់ថាមពលស្អាតដោយការប្រើប្រាស់ថាមពលកកើតឡើងវិញ។
គ- ការសន្សំសំចៃទឹក។
ឃ- ការគ្រប់គ្រងសំណល់ដោយត្រូវបែងចែកតាមប្រភេទសំណល់ និងត្រូវកាត់បន្ថយសំណល់ប្រើសំណល់ឡើងវិញ និងកែច្នៃសំណល់ឡើងវិញ។
ង- ហាមការលក់ចំណីអាហារ ដែលមានរសជាតិ ពណ៌ ក្លិនសិប្បនិម្មិត ក្នុងបរិវេណសាលា។
ច- ហាមការប្រើប្រាស់ថង់ប្លាស្ទិច ក្នុងការវេចខ្ចប់ចំណីអាហារ និងភេសជ្ជៈនៅតាមតូបលក់ចំណីអាហារក្នុងបរិវេណសាលា។
ឆ- សម្អាតបន្ទប់រៀននិងបង្គន់ជាប្រចាំ ធានានូវអនាម័យល្អនិងសុខភាព។
ជ- ផ្សព្វផ្សាយទិវាភពផែនដី ទិវាគ្មានថង់ប្លាស្ទិច ទិវាព្រៃទិវា ជាអាទិ៍។
ឈ- ផ្តល់រង្វាន់ដល់សិស្ស ដែលមានស្នាដៃនិងប្រតិបត្តិការងារអប់រំបរិស្ថានបានល្អ ។
ញ- ការប្រកួតសិល្បៈបរិស្ថាន ដូចជាការបង្ហាញម៉ូតដែលប្រើសម្ភារៈ កែច្នៃឡើងវិញ ការប្រកួតរូបថត និងការប្រកួតគំនូរ ជាដើម។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៧៥៣ .- ពានរង្វាន់សាលាមេត្រីបរិស្ថាន**

១- ពានរង្វាន់ត្រូវបានចែកជាបីផ្នែក មានជាអាទិ៍៖

ក- ពានរង្វាន់មាសមានសុពលភាព៤(បួន)ឆ្នាំ។

ខ- ពានរង្វាន់ប្រាក់មានសុពលភាព២(ពីរ)ឆ្នាំ។

គ- ពានរង្វាន់សំរិទ្ធិមានសុពលភាព២(ពីរ)ឆ្នាំ។

២- ម្ចាស់ជ័យលាភីពានរង្វាន់មិនត្រូវបានអនុញ្ញាតឱ្យចូលរួមប្រកួតប្រជែង ពានរង្វាន់សាលាមេត្រីទៀតទេ ដរាបណាពានរង្វាន់របស់ខ្លួននៅមានសុពលភាព។

# គន្ថីទី៨

# វិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃនិងមូលនិធិផ្នែកបរិស្ថាន

## មាតិកាទី១

## វិធានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៥៤ .- គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់អំពីវិធាន នីតិវិធី នៃការគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម ដែលគាំទ្រដល់វិស័យបរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

**មាត្រា៧៥៥ .- វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តចំពោះវិធានសេដ្ឋកិច្ច ហិរញ្ញវត្ថុ ប្រាក់កម្រៃ និងមូលនិធិផ្នែកបរិស្ថាន និងសង្គម ដែលត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយ ច្បាប់ និងបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាល រួមបញ្ចូលទាំងលិខិតុបករណ៍អន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី។

### ជំពូកទី២

### ស្ថាប័នទទួលខុសត្រូវ

**មាត្រា៧៥៦ .- ក្រសួងស្ថាប័នទទួលខុសត្រូវ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលខុសត្រូវក្នុងការរៀបចំ កំណត់វិធានការសេដ្ឋកិច្ច មូលនិធិហិរញ្ញវត្ថុ កម្រៃពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ ។

**មាត្រា៧៥៧ .- តួនាទីនិងភារកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

ក- ធ្វើការសម្របសម្រួលការងារហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធវិស័យបរិស្ថាននិងធនធានធម្មជាតិជាមួយស្ថាប័នពាក់ព័ន្ធ។

ខ- រៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគោលការណ៍ហិរញ្ញវត្ថុ មូលនិធិ ពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ ដើម្បីស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ឬក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

គ- ទទួលខុសត្រូវ និងសម្របសម្រួលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមគោលនយោបាយ និងផែនការរបស់រាជរដ្ឋាភិបាល។

ឃ- តាមដាន និងវាយតម្លៃការអនុវត្តគម្រោងផែនការថវិកា។

ង- រៀបចំរបាយការណ៍ថវិកា និងវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌។

ច- តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តប្រមូល និងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គម។

ឆ- គ្រប់គ្រង និងប្រើប្រាស់មូលនិធិតំបន់ការពារ និងមូលនិធិទាយជ្ជទានបរិស្ថាន។

## ជំពូកទី៣

## វិធានសេដ្ឋកិច្ច

**មាត្រា៧៥៨ .- ការវាយតម្លៃលើឱកាសនិងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដឹកនាំក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការវាយតម្លៃជាប្រចាំទៅលើឱកាស និងយន្តការលើកទឹកចិត្តឱ្យមានការវិនិយោគទៅលើផ្នែកកិច្ចគាំពារបរិស្ថាន ការអភិរក្ស ការគ្រប់គ្រង និងការស្តារឡើងវិញនូវធនធានធម្មជាតិ។

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការ របាយការណ៍ និងលើកសំណើចំពោះវិធានសេដ្ឋកិច្ចស្របតាមគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័នសាមី និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ដើម្បីពិនិត្យ សហការ និងឯកភាពក្នុងករណីចាំបាច់ត្រូវដាក់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេចចំពោះការលើកទឹកចិត្ត និងវិធានទាំងនេះ។

**មាត្រា៧៥៩ .- វិធានសេដ្ឋកិច្ចដើម្បីគាំទ្រគោលនយោបាយបរិស្ថាននិងធនធានធម្មជាតិ**

១- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវរៀបចំសេចក្តីព្រាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តស្តីពីវិធានសេដ្ឋកិច្ចក្នុងការគាំទ្រដល់បរិស្ថាន ធនធានធម្មជាតិ សង្គម និងវប្បធម៌ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពិសេសដោយឡែកពាក់ព័ន្ធនឹងសារពើពន្ធនិងកិច្ចលទ្ធកម្ម។

២- ការរៀបចំសេចក្តីព្រាងគោលនយោបាយនិងលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងក្នុងកថាខណ្ឌខាងលើនេះត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាជារដ្ឋភាគី និងត្រូវរៀបចំឱ្យមានវិធានសេដ្ឋកិច្ចពាក់ព័ន្ធនឹង៖

ក- ការដាក់បញ្ចូលស្តង់ដារពាក់ព័ន្ធការអនុវត្តល្អផ្នែកបរិស្ថាន និងសង្គម និងការគ្រប់គ្រងហានិភ័យទៅក្នុងការធ្វើសេចក្តីសម្រេចរបស់នីតិបុគ្គលពីវិស័យធុរកិច្ច និងហិរញ្ញវត្ថុ។

ខ- ការវិនិយោគលើវិស័យឯកជនពាក់ព័ន្ធនឹងបរិស្ថាននិងធនធានធម្មជាតិ។

គ- ការកាត់បន្ថយការធ្វើអាជីវកម្មលើព្រៃឈើ ធនធានធម្មជាតិ និងការលើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ឃ- ការផលិតថាមពលនិងអុសដោយនិរន្តរភាព។

ង- រុក្ខប្រមាញ់និងជលផលដោយនិរន្តរភាព។

ច- ការអភិរក្សទឹកសាប មានជាអាទិ៍ ការលើកកម្ពស់ការប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធផល និងការស្រាវជ្រាវដើម្បីការពារនិងគ្រប់គ្រងគុណភាពទឹក និងកាត់បន្ថយការបញ្ចេញសំណល់ទឹកកខ្វក់ និងសំណល់រាវ។

ឆ- ការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍មានជាអាទិ៍ ការលើកលែងអាករលើតម្លៃបន្ថែម និងពន្ធដទៃទៀតលើប្រាក់ចំណូល ប្រាក់កម្រៃ មូលនិធិ ឬប្រាក់រួមវិភាគទានផ្សេងៗ ដែលទទួលបានពីការអនុវត្តការគ្រប់គ្រងរួមគ្នា។

ជ- ការអភិវឌ្ឍ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ អគ្គិសនីខ្នាតតូច។

ឈ-ការលើកកម្ពស់ការប្រើប្រាស់ប្រព័ន្ធថាមពលពីប្រភពកកើតឡើងវិញ មានជាអាទិ៍ ព្រះអាទិត្យ ខ្យល់ ទឹក និងរលកសមុទ្រ និងគ្រឿងជំឡើងដទៃទៀត។

ញ- ការប្រើប្រាស់ថាមពលស្អាត ប្រភេទនៃផលិតកម្មដែលមានប្រសិទ្ធផលធនធាន និងមានការបញ្ចេញកាបូនតិច និងការកាត់បន្ថយការបំពុលបរិស្ថាន និងសុខភាពសាធារណៈ។

ដ- ការប្រើប្រាស់បច្ចេកវិទ្យាបរិស្ថានប្រសើរបំផុត ដែលបានពិសោធនិងផ្ទៀងផ្ទាត់រួច។

ឋ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានាក្នុងគោលបំណងការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ។

ឌ- ការបែងចែកដោយសមធម៌នូវប្រាក់ចំណូលបានមកពីយន្តការទូទាត់ការបញ្ចេញកាបូនដែលកំណត់ដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព។

ឍ- ការបង់ថ្លៃលើការផលិត ឬការថែទាំសេវាកម្មធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ីទៅកាន់រូបវន្តបុគ្គល និងសហគមន៍ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។

ណ- ការលើកកម្ពស់ការនាំចូល ការទិញយានយន្តមេត្រីបរិស្ថាន និងទប់ស្កាត់ការនាំចូលយានយន្ត ដែលមានផលប៉ះពាល់ខ្ពស់ដល់បរិស្ថាន និងសុខភាពសាធារណៈ។

ត- ការលើកកម្ពស់ការប្រើប្រាស់ថាមពលប្រកបដោយការទទួលខុសត្រូវមានជាអាទិ៍ ការគាំទ្រដល់ការប្រើប្រាស់ក្នុងធុរកិច្ចនូវប្រភពថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលធ្វើពាណិជ្ជកម្មដំឡើង ឬផ្គត់ផ្គង់ផ្នែកបច្ចេកទេស ឬថែទាំឧបករណ៍ថាមពលប្រកបដោយការទទួលខុសត្រូវ ធុរកិច្ចដែលនាំចូល ផលិត ចែកចាយ ឬលក់ឧបករណ៍ដែលផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល ដែលមានលក្ខណសម្បត្តិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធសុខភាព សុវត្ថិភាព និងបរិស្ថាន និងការនាំចូលឧបករណ៍សម្រាប់ផលិតថាមពលប្រកបដោយការទទួលខុសត្រូវ ឬបង្កើនប្រសិទ្ធផលថាមពល។

ថ- ការអភិរក្ស និងកិច្ចគាំពារបេតិកភណ្ឌវប្បធម៌។

ទ- ការអភិរក្សថាមពល តាមរយៈការបង្កើនចំហេះ និងប្រសិទ្ធផលនៃការប្រើប្រាស់អគ្គិសនី ការទប់ស្កាត់ចំពោះការបាត់បង់ថាមពល ការកែច្នៃសំណល់ថាមពល ការជំនួសមកវិញនូវថាមពលកកើតឡើងវិញ និងមធ្យោបាយនានានៃការអភិរក្សថាមពល ដែលបានកំណត់ដោយក្រសួងស្ថាប័នមានសមត្ថកិច្ច។

ធ- វិធានការសេដ្ឋកិច្ចពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៦០ .- សំណើសម្រាប់ក្រុមហ៊ុនឯកជនឬសាធារណៈ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយសហការជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច អាចចេញលិខិតអនុញ្ញាតចំពោះសំណើរបស់ក្រុមហ៊ុនឯកជន ឬសាធារណៈដើម្បីរៀបចំហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្នែកបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៨៥

២- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចតម្រូវឱ្យក្រុមហ៊ុនដាក់សំណើសុំដូចមានចែងក្នុងកថាខណ្ឌខាងលើនេះ ដាក់បញ្ចូលភស្តុតាងនិងឯកសារគាំទ្រដែលបញ្ជាក់ពីធនធាន និងស្ថានភាពហិរញ្ញវត្ថុ ការសិក្សាទីផ្សារ ការប្រើប្រាស់ផែនការកំណត់ប្រភពដោយនិរន្តរភាព ការបង្ហាញពីការចូលវិភាគទានរបស់គម្រោងចំពោះការអភិវឌ្ឍប្រកបដោយចីរភាពដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងសមត្ថភាពក្នុងការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដែលកំពុងតែដំណើរការ។

៣- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវអនុវត្តតាមដំណើរការនៃកិច្ចលទ្ធកម្មដូចបានកំណត់នៅក្នុងគោលការណ៍ណែនាំនៃគោលនយោបាយពាក់ព័ន្ធនានាស្តីពីក្រុមហ៊ុនឯកជន ឬសាធារណៈ។

## ជំពូកទី៤
## វិធានហិរញ្ញវត្ថុ

**មាត្រា៧៦១ .– ការបង់ថ្លៃរាល់ប្រភេទចំណូល**

ការបង់ថ្លៃរាល់ប្រភេទចំណូលទាំងអស់ ស្របតាមបទប្បញ្ញត្តិនៃក្រមនេះត្រូវបង់ចូលគណនីទោលរតនាគារ ឬធនាគារដៃគូតាមការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការព្រមព្រៀងដោយឡែករវាងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នមានសមត្ថកិច្ច។

**មាត្រា៧៦២ .– ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំយន្តការកំណត់ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីទៅឱ្យបុគ្គល ដែលបានចូលរួមចំណែកក្នុងការត្រួតពិនិត្យ ការពារ ឬគ្រប់គ្រងសេវាកម្មប្រព័ន្ធអេកូឡូស៊ីដោយផ្អែកលើទិន្នន័យ និងស្ថិតិប្រសើរបំផុត ដែលស្វែងរកបានពាក់ព័ន្ធនឹងស្ថានភាព និងតម្លៃនៃសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលបានវាយតម្លៃរួចរាល់។

**មាត្រា៧៦៣ .– កិច្ចសហប្រតិបត្តិការរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច**

ក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវគាំទ្រនិងសហការ ជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីរៀបចំអនុវត្តនិងគ្រប់គ្រងយន្តការ ដូចមានចែងក្នុងមាត្រា៧៦២(ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ី)នៃក្រមនេះ។

## មាតិកាទី២
## ប្រាក់កម្រៃ មូលនិធិ និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម
## ជំពូកទី១
## ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន

**មាត្រា៧៦៤ .– ការទទួលខុសត្រូវក្នុងការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន**

បុគ្គលត្រូវទទួលបន្ទុកក្នុងការបង់ប្រាក់កម្រៃ សួយសារ បុព្វលាភបរិស្ថាន ឬថ្លៃផ្សេងទៀតស្របតាមប្រកាសអន្តរក្រសួងរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៦៥ .– ការរៀបចំប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ចត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់ពីចំនួន

ROYAUME DU CAMBODGE * THE ROYAL PALACE * DU PALAIS ROYAL

ទឹកប្រាក់ នីតិវិធីនៃការគ្រប់គ្រង និងការលើកលែងការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភបរិស្ថានណាមួយ ដែលពាក់ព័ន្ធនឹងក្រមនេះ មានជាអាទិ៍៖

ក- ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ខ- យន្តការគ្រប់គ្រងនិងនិរន្តរភាពបរិស្ថាន។

គ- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

ឃ- ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ។

ង- ការគ្រប់គ្រងសំណល់និងការបំពុលបរិស្ថាន។

ច- ការអប់រំនិងការយល់ដឹងពីបរិស្ថាន។

ឆ- ការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ។

ជ- វិស័យពាក់ព័ន្ធដទៃទៀត ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៦៦ ._ ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការបង់ប្រាក់កម្រៃ សួយសារ ឬបុព្វលាភ**

១- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចអាចតម្រូវឱ្យបុគ្គលដែលមានភាតព្វកិច្ចបង់ប្រាក់កម្រៃ សួយសារ បុព្វលាភ ឬថ្លៃផ្សេងទៀត ផ្តល់ការធានា ផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការបង់ថ្លៃទាំងនេះនៅមុនពេលទទួលបានសិទ្ធិអនុវត្តសកម្មភាពឬគម្រោងជាផ្លូវការ។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយសហការជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ច ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណវិនិច្ឆ័យនិងនីតិវិធីសម្រាប់ការធានាចំពោះការបង់ប្រាក់កម្រៃ សួយសារ និងបុព្វលាភ។

## ជំពូកទី២
## ការបង់និងការគ្រប់គ្រងមូលនិធិបរិស្ថាននិងសង្គម
### ផ្នែកទី១
### ការបង់មូលនិធិបរិស្ថាន

**មាត្រា៧៦៧ ._ ការបង់មូលនិធិទាយជ្ជទានបរិស្ថាន**

បុគ្គលត្រូវបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

**មាត្រា៧៦៨ ._ ការបង់មូលនិធិតំបន់ការពារធម្មជាតិ**

បុគ្គលត្រូវបង់មូលនិធិតំបន់ការពារធម្មជាតិស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីយន្តការនិងការប្រើប្រាស់មូលនិធិតំបន់ការពារធម្មជាតិនិងបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

**មាត្រា៧៦៩ ._ ការបង់មូលនិធិបរិស្ថាននិងសង្គម**

បុគ្គលត្រូវបង់មូលនិធិបរិស្ថាននិងសង្គមស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវធ្វើការគ្រប់គ្រងមូលនិធិនេះស្របតាមបញ្ញត្តិស្តីពីមូលនិធិបរិស្ថាននិងសង្គមនៃក្រមនេះ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

## ផ្នែកទី២
## មូលនិធិបរិស្ថាននិងសង្គម

**មាត្រា៧៧០ .– ប្រភពចំណូលនៃមូលនិធិបរិស្ថាននិងសង្គម**

មូលនិធិបរិស្ថាននិងសង្គមមានប្រភពចំណូលមកពី៖

ក- ទុនដំបូងរបស់រាជរដ្ឋាភិបាល។

ខ- ភាគទានបានមកពីអាករពិសេសពាក់ព័ន្ធវិស័យបរិស្ថានតាមការកំណត់របស់រាជរដ្ឋាភិបាល។

គ- ភាគទានបានមកពីកម្រៃសេវាវិស័យអាកាសចរស៊ីវិលតាមការកំណត់របស់រាជរដ្ឋាភិបាល។

ឃ- បុព្វលាភបានមកពីម្ចាស់គម្រោងអភិវឌ្ឍឯកជននិងសាធារណៈ ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាននៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង/ឬកិច្ចសន្យាការពារបរិស្ថាន។

ង- ប្រាក់ចំណូលបានមកពីកិច្ចគាំពារបរិស្ថាន សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងអភិរក្សជីវៈចម្រុះ។

ច- ភាគទានបានមកពីមូលនិធិទាយជ្ជទានបរិស្ថាន។

ឆ- ភាគទានបានមកពីមូលនិធិតំបន់ការពារធម្មជាតិ។

ជ- ភាគទានបានមកពីកម្រៃសេវាលក់សំបុត្រចូលទស្សនាតំបន់ការពារធម្មជាតិ។

ឈ- កម្រៃសេវាកម្មជួលទីតាំងដំឡើងបង្គោលអង់តែន និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ញ- ភាគទានបានមកពីកម្រៃសេវាកម្មជួលទីតាំងដំឡើងបណ្ដាញអគ្គិសនី និងបណ្ដាញកាបអុបទិក ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ដ- ភាគទានបានមកពីកម្រៃជួលទីតាំងគម្រោងវិនិយោគអភិវឌ្ឍទេសចរណ៍ធម្មជាតិទំហំក្រោម១០(ដប់)ហិកតា ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ឋ- ភាគទានបានមកពីការលក់ឥណទានកាបូន។

ឌ- ប្រាក់ដែលបានមកពីការដោះស្រាយបណ្ដឹងស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ឍ- អំណោយឬជំនួយថវិកា សម្ភារៈ ឧបករណ៍នានាពីសប្បុរសជន ដៃគូអភិវឌ្ឍ ស្ថាប័នឯកជនជាតិ ឬអន្តរជាតិនានា។

ណ- ភាគទានបានមកពីកម្រៃសេវាផ្សេងៗពាក់ព័ន្ធនឹងវិស័យបរិស្ថាន។

ត- ប្រភពផ្សេងៗទៀត។

**មាត្រា៧៧១ .– ការប្រើប្រាស់មូលនិធិបរិស្ថាននិងសង្គម**

មូលនិធិបរិស្ថាននិងសង្គមត្រូវប្រើប្រាស់ក្នុងសកម្មភាពដូចខាងក្រោម៖

ក- កិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី និងការរស់នៅប្រកបដោយចីរភាព។

ខ- ការស្ដារបរិស្ថាននិងការកែលម្អធនធានជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ីឡើងវិញ។

គ- ការសិក្សាស្រាវជ្រាវលើបរិស្ថាន ធនធានធម្មជាតិ និងវប្បធម៌ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។

ឃ- ការចូលរួមការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងការលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានដែលនៅក្នុងនិងក្បែរតំបន់គម្រោងវិនិយោគឬតំបន់ផ្សេងទៀត។

ង- ការចូលរួមគាំទ្រដល់ការរៀបចំបង្កើតនិងការអភិវឌ្ឍសហគមន៍មូលដ្ឋាន។

ច- ការចូលរួមគម្រោងអភិវឌ្ឍសហគមន៍មូលដ្ឋាន រួមទាំងការផ្ដល់ឥណទានខ្នាតតូចជាលក្ខណៈទុនបង្វិល។

ច- ការអប់រំនិងផ្សព្វផ្សាយអំពីបរិស្ថាន ធនធានធម្មជាតិនិងវប្បធម៌ ជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។

ឆ- ការបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យបរិស្ថាននិងធនធានធម្មជាតិ។

ជ-សកម្មភាពផ្សេងៗទៀតពាក់ព័ន្ធនឹងវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៧២ ._ គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម**

១- មូលនិធិបរិស្ថាននិងសង្គមត្រូវគ្រប់គ្រងដោយគណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមដែលបង្កើតឡើងដោយអនុក្រឹត្យ។

២- តួនាទី ភារកិច្ច និងសមាសភាពរបស់គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

៣- គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមត្រូវរៀបចំយុទ្ធសាស្ត្រ ដើម្បីគ្រប់គ្រងមូលនិធិរយៈពេលវែង។ យុទ្ធសាស្ត្រនេះ ត្រូវដាក់បញ្ចូលការពិចារណាលើវិធីសាស្ត្រលទ្ធកម្ម ការគ្រប់គ្រងមូលនិធិ មានជាអាទិ៍ មូលធនកម្ម ការវិនិយោគ វិធានការរដ្ឋបាល វិធានការផ្លូវច្បាប់ និងគោលនយោបាយពាក់ព័ន្ធដទៃទៀត។ គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គមត្រូវមានលេខាធិការដ្ឋានមួយជាសេនាធិការ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៤- នីតិវិធីនៃការគ្រប់គ្រងការប្រមូលចំណូល និងការគ្រប់គ្រងការប្រើប្រាស់មូលនិធិបរិស្ថាន និងសង្គមត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៥- ការចំណាយពាក់ព័ន្ធការបំពេញភារកិច្ច និងតួនាទីរបស់គណៈកម្មាធិការមូលនិធិបរិស្ថាន និងសង្គមត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣

## ការបង្កើតនិងការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន

**មាត្រា៧៧៣ ._ សិទ្ធិរបស់បរធនបាលទាយក**

បរធនបាលទាយកមានសិទ្ធិជាអាទិ៍៖

ក- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ច មានជាអាទិ៍ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត។

ខ- តែងតាំងនិងបញ្ឈប់បរធនបាលស្របតាមលក្ខខណ្ឌ ដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា៧៧៤ ._ កាតព្វកិច្ចរបស់បរធនបាលទាយក**

១- បរធនបាលទាយកមានកាតព្វកិច្ចជាអាទិ៍៖

ក- ផ្ទេរទ្រព្យសម្បត្តិឬមូលនិធិបរធនទៅឱ្យបរធនបាល គ្រប់គ្រង និងចាត់ចែងជំនួសសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈ។

ខ- ចូលរួមសម្របសម្រួលក្នុងកិច្ចការផ្ទេរបរធនឱ្យទៅបរធនបាលគ្រប់គ្រងនិងចាត់ចែង។

គ- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំពោះការផ្លាស់ប្តូរបរធនបាលទាយក ឬអ្នកផ្តល់វិភាគទានបរធនបាលកិច្ច ឬការកែប្រែលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

ឃ- អនុវត្តតាមលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ចនិងបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

២- ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាពឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារមួយចំនួន ជាបរធនបាលទាយកជំនួស។

**មាត្រា៧៧៥ .– សិទ្ធិរបស់អត្ថគាហកៈ**

១- អត្ថគាហកៈមានសិទ្ធិដូចតទៅ៖

ក- ទទួលអត្ថប្រយោជន៍ដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

ខ- ទាមទារឱ្យបរធនបាលបំពេញភារកិច្ចដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច និងតាមបទប្បញ្ញត្តិជាធរមាន។

គ- ទទួលព័ត៌មានពាក់ព័ន្ធការគ្រប់គ្រងនិងចាត់ចែងនៃបរធនបាលកិច្ច។

ឃ- មានសិទ្ធិផ្សេងៗទៀត ដែលមានចែងក្នុងលិខិតបរធនបាលកិច្ចនិងតាមបទប្បញ្ញត្តិជាធរមាន។

២- អត្ថគាហកៈអាចទទួលផលពីបរធនបាលកិច្ចចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃបរធនបាលកិច្ច លើកលែងតែមានបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

៣- ក្នុងករណីដែលមានអត្ថគាហកៈច្រើន អត្ថគាហកៈទាំងនេះអាចទទួលផលដូចគ្នា ឬផ្សេងៗពីគ្នាតាមរបៀប ឬវិធីដែលមានចែងក្នុងលិខិតបរធនបាលកិច្ច។ ក្នុងករណីដែលគ្មានរបៀប ឬវិធីទទួលផលត្រូវសន្មតថាអត្ថគាហកៈទាំងនេះទទួលផលស្មើៗគ្នា។

**មាត្រា៧៧៦ .– សិទ្ធិរបស់បរធនបាល**

បរធនបាលមានសិទ្ធិដូចតទៅ៖

ក- ទទួលលាភការឬកម្រៃនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ចដែលអាចប្រែប្រួលទៅតាមបទពិសោធការងារ និង/ឬគុណវឌ្ឍិវិជ្ជាជីវៈរបស់ខ្លួន។

ខ- ស្វែងរកជំនួយឬមូលនិធិផ្សេងៗ និងឱកាសវិនិយោគបន្ថែមដើម្បីជាប្រយោជន៍របស់បរធនបាលកិច្ច។

គ- តំណាងឱ្យបរធនបាលទាយកឬអត្ថគាហកៈនៅចំពោះមុខច្បាប់ឬអាជ្ញាធរមានសមត្ថកិច្ច។

ឃ- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

ង- គ្រប់គ្រងនិងចាត់ចែងបរធនតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

ច- ចំណាយក្នុងសកម្មភាពសង្គមស្របតាមគោលបំណងនិងលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ច។

**មាត្រា៧៧៧ .– ភារកិច្ចរបស់បរធនបាល**

បរធនបាលមានភារកិច្ចដូចតទៅ៖

ក- ដាក់ពាក្យចុះបញ្ជីបរធនតាមបែបបទនិងនីតិវិធីរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ- រាយការណ៍និងផ្តល់ព័ត៌មានពាក់ព័ន្ធការគ្រប់គ្រងបរធនបាលកិច្ចឱ្យបរធនបាលទាយក អត្ថគាហកៈ និងបញ្ញត្តិករពាក់ព័ន្ធ។

គ- រក្សាកំណត់ហេតុនៃកិច្ចប្រជុំសម្រាប់ការគ្រប់គ្រងគណនីប្រចាំឆ្នាំ។

ឃ- ឆ្លើយតបទៅនឹងបញ្ញត្តិករពាក់ព័ន្ធ។

ង- បង់ពន្ធគ្រប់ប្រភេទដែលទាក់ទងនឹងទ្រព្យសម្បត្តិបរធនបាលកិច្ច។

ច- ចាត់វិធានការសមស្របដើម្បីការពារទ្រព្យសម្បត្តិបរធនបាលកិច្ចនិងអត្ថគាហកៈ។

ឆ- ចុះកិច្ចសន្យាធានារ៉ាប់រងលើការទទួលខុសត្រូវក្នុងមុខងារជាបរធនបាល។

ជ- បរធនបាលមិនអាចផ្ទេរមុខងាររបស់ខ្លួនឱ្យទៅបុគ្គលផ្សេងទៀតបានឡើយ។



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឈ-បែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួននិងទ្រព្យសម្បត្តិបរធនបាលកិច្ច។

ញ- គ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ចដោយយកចិត្តទុកដាក់និងដោយប្រុងប្រយ័ត្ន។

ដ- រក្សាភាពស្មោះត្រង់និងសុចរិតក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនបាលកិច្ច។

ឋ- គ្រប់គ្រងនិងចាត់ចែងលើទ្រព្យសម្បត្តិបរធនបាលកិច្ចឱ្យមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ដើម្បីជាប្រយោជន៍របស់អត្ថគាហក:។

ឌ- ចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិបរធនបាលកិច្ច។

ឍ- ផ្តល់របាយការណ៍ហិរញ្ញវត្ថុជាប្រចាំទៅបញ្ញត្តិករពាក់ព័ន្ធ និងទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ណ- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍។

ត- គោរពតាមលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា៧៧៨ ._ ការទទួលខុសត្រូវរបស់បរធនបាល**

បរធនបាលត្រូវទទួលខុសត្រូវចំពោះសកម្មភាពដូចខាងក្រោម៖

ក- ការធ្វើឱ្យបាត់បង់និងថយចុះនៃបរធនដោយគ្មានមូលហេតុត្រឹមត្រូវ។

ខ- ការប្រើប្រាស់បរធនខុសពីបំណងបរធនបាលកិច្ច។

គ- កំហុសដែលបានប្រព្រឹត្តដោយចេតនាឬអចេតនាក្នុងការបំពេញការងាររបស់ខ្លួន។

ឃ- ការចំណាយណាមួយផ្ទុយពីបំណងបរធនបាលកិច្ច។

ង- ចៀសវាងទំនាស់ផលប្រយោជន៍ដោយផ្ទាល់និងប្រយោលដែលនាំឱ្យប៉ះពាល់ឬខូចខាតដល់ប្រយោជន៍របស់បរធនបាលកិច្ច។

ច- ការទទួលខុសត្រូវផ្សេងទៀតតាមលក្ខខណ្ឌនៃលិខិតបរធនបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

**មាត្រា៧៧៩ ._ ការបង្កើត ការលុបចោល និងគោលបំណងនៃបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានត្រូវបានបង្កើតឡើងស្របតាមនីតិវិធីនិងទម្រង់ដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បរធនបាលទាយកដែលមានបំណងបង្កើតឬធ្វើប្រតិបត្តិការបរធនបាលកិច្ចបរិស្ថានត្រូវរៀបចំលិខិតបរធនបាលកិច្ចនិងចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីបរធនបាលកិច្ច។

២- បរធនបាលទាយកអាចធ្វើដោយខ្លួនឯងឬដោយសហការជាមួយសមាគមក្នុងស្រុក ឬសមាគមបរទេសដើម្បីបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ច។

៣- បរធនបរិស្ថានអាចលុបចោលបានស្របតាមលក្ខខណ្ឌដែលបានកំណត់។

៤- បរធនបាលកិច្ចបរិស្ថានត្រូវប្រើប្រាស់សម្រាប់សកម្មភាព ដែលបានកំណត់ជាអាទិភាពនៅក្នុងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងគោលបំណង៖

ក- គាំពារ អភិរក្ស និងស្តារឡើងវិញនូវបរិស្ថាននិងធនធានធម្មជាតិ។

ខ- ការពារបេតិកភណ្ឌវប្បធម៌ឬជីវៈចម្រុះ។

គ- លើកកម្ពស់ការគ្រប់គ្រងធនធានធម្មជាតិនិងសេវាកម្មប្រព័ន្ធអេកូឡូស៊ីប្រកបដោយនិរន្តរភាព។

ឃ- លើកកម្ពស់ការស្រាវជ្រាវនិងការអប់រំបរិស្ថាន។

ង- អភិវឌ្ឍសមត្ថភាពឬពង្រឹងស្ថាប័ន។



ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ច- គាំទ្រទៅលើសហគមន៍ដែលរងផលប៉ះពាល់ដោយផ្ទាល់ពីការអភិវឌ្ឍ។

ឆ- ជាប្រយោជន៍សាធារណៈនិងសម្រាប់ផលប្រយោជន៍បរិស្ថាន ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៧៨០ .‒ ការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានមានជាអាទិ៍ បរធនសម្រាប់គាំពារបរិស្ថាន អភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យសមស្រប មាននិរន្តរភាព និងការរស់នៅប្រកបដោយចីរភាព និងទម្រង់ផ្សេងទៀតនៃការបែងចែកផលប្រយោជន៍ផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២- បរធនបាលកិច្ចបរិស្ថានត្រូវបានគ្រប់គ្រងដោយបរធនបាលតាមរយៈការផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិដែលជាបរធនពីបរធនបាលទាយកទៅឱ្យបរធនបាល ដើម្បីគ្រប់គ្រងសម្រាប់ជាប្រយោជន៍ដល់អត្ថគាហកៈស្របតាមការកំណត់របស់បរធនបាលទាយក។

**មាត្រា៧៨១ .‒ លិខិតបទដ្ឋានគតិយុត្តស្ដីពីការគ្រប់គ្រងនិងការត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន**

ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយសម្របសម្រួលជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្ដីពីវិធាននិងនីតិវិធីសម្រាប់ការបង្កើត គ្រប់គ្រង និងត្រួតពិនិត្យបរធនបាលកិច្ចបរិស្ថាន និងគណនីមូលនិធិនេះ។

**មាត្រា៧៨២ .‒ ការចុះបញ្ជីនៃបរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានមានសុពលភាពលុះត្រាតែបានចុះបញ្ជីនៅក្រសួងស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី៣(បី)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ចបរិស្ថាន។ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើសេចក្ដីសម្រេចលើពាក្យស្នើសុំចុះបញ្ជីនេះក្នុងរយៈពេល៩០(កៅសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់សម្រាប់ការចុះបញ្ជី។

២- បែបបទនិងនីតិវិធីស្ដីពីការចុះបញ្ជីបរធនបាលកិច្ចបរិស្ថានត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៧៨៣ .‒ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន**

១- ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានអាចបង្កើតមកពី៖

ក- ថវិកាជាតិ។

ខ- ជំនួយអភិវឌ្ឍជាដៃគូការដែលបានផ្ដល់ឱ្យដោយអង្គការជាតិនិងអន្តរជាតិ។

គ- ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី។

ឃ- សេវាកម្មគ្រប់គ្រងធនធានធម្មជាតិ។

ង- អំណោយផ្ទាល់ពីវិស័យឯកជន សប្បុរសជន និងប្រភពផ្សេងៗទៀត។

២- ប្រយោជន៍ទាំងអស់ដែលកើតចេញពីបរធនបាលកិច្ចបរិស្ថានត្រូវបង់ចូលនិងត្រូវបង្កើតជាផ្នែកនៃបរធនបាលកិច្ចបរិស្ថាន។

**មាត្រា៧៨៤ .‒ ទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថាន**

១- ក្នុងកំលុងពេលបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន បរធនបាលត្រូវរាយការណ៍អំពីទំនាស់ផលប្រយោជន៍ទៅកាន់ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- ក្នុងករណីដែលក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភស្តុតាងនិងហេតុផលគ្រប់គ្រាន់ ដែលអាចជឿជាក់ថាបរធនបាលកំពុងតែប្រព្រឹត្តអំពើដែលមានទំនាស់ផលប្រយោជន៍ចំពោះបរធនបាលកិច្ចបរិស្ថានឬកំពុងតែប្រព្រឹត្តផ្ទុយទៅនឹងផលប្រយោជន៍បរិស្ថានឬសាធារណៈ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវសម្របសម្រួលជាមួយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដើម្បីផ្តួចផ្តើមការស៊ើបអង្កេតទៅលើបញ្ហានេះ។

៣- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវព្យួរមុខងាររបស់បរធនបាល ក្នុងករណីដែលការស៊ើបអង្កេតរកឃើញថា បរធនបាលមានទំនាស់ផលប្រយោជន៍ជាមួយនឹងបរធនបាលកិច្ចរបស់ខ្លួន។ ក្នុងករណីនេះ ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវតែងតាំងបរធនបាលបណ្តោះអាសន្នដោយគោរពតាមលក្ខខណ្ឌតម្រូវនៃក្រមនេះនិងស្របតាមលិខិតបរធនបាលកិច្ច។

**មាត្រា៧៨៥ .- បញ្ជីរបាយការណ៍ប្រចាំឆ្នាំដែលសាធារណជនអាចស្វែងរកបាន**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវរក្សាទុកបញ្ជីរបាយការណ៍ប្រចាំឆ្នាំនៃគ្រប់បរធនបាលកិច្ចបរិស្ថានដែលអាចឱ្យសាធារណជនស្វែងរកបាន។

**មាត្រា៧៨៦ .- ការប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាន**

បរធនបាលអាចប្រើប្រាស់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដើម្បី៖

ក- ផ្តល់មូលនិធិដល់សកម្មភាពឬគម្រោងនានាដែលបំពេញតាមគោលបំណងនៃបរធនបាលកិច្ចបរិស្ថានស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

ខ- បង់ថ្លៃលើប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថានដែលមានជាអាទិ៍ ណាភការរបស់បរធនបាលនិងថ្លៃចំណាយនានាក្នុងការគ្រប់គ្រងបរធនបាលកិច្ចបរិស្ថាន។

គ- ចំណាយទៅលើសកម្មភាពសង្គមស្របតាមគោលបំណងនៃលិខិតបរធនបាលកិច្ច។

ឃ- ធ្វើការបណ្តាក់ទុនលើការវិនិយោគនិងមូលបត្រដែលទទួលខុសត្រូវផ្នែកបរិស្ថាននិងសង្គម។

**មាត្រា៧៨៧ .- ការបញ្ចប់បរធនបាលកិច្ចបរិស្ថាន**

១- បរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់ ក្នុងករណីណាមួយដូចខាងក្រោម៖

ក- ការមកដល់នៃកាលាវសានដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ច។

ខ- ការសម្រេចគោលបំណងរបស់បរធនបាលកិច្ច។

គ- ការសម្រេចដោយឆន្ទានុសិទ្ធិឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក។

ឃ- តាមសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ច។

ង- តាមករណីផ្សេងទៀតដូចមានចែងក្នុងលិខិតបរធនបាលកិច្ច។

២- ក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវទទួលបាននូវការជូនដំណឹងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការបញ្ចប់បរធនបាលកិច្ចនេះ។

**មាត្រា៧៨៨ .- ការចាត់តាំងអភិបាលបណ្តោះអាសន្ន**

បរធនបាលទាយកឬបរធនបាលទាយកជំនួស មានសិទ្ធិចាត់តាំងអភិបាលបណ្តោះអាសន្នសម្រាប់គ្រប់គ្រងបរធនបាលកិច្ច ក្នុងករណីយល់ឃើញថាមានហានិភ័យលើសាធនភាពលក្ខខណ្ឌដែលបានកំណត់ក្នុងលិខិតបរធនបាលកិច្ច។

**មាត្រា៧៨៩ .- ការជ្រើសតាំងអ្នកជម្រះបញ្ជី**

១- ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថានត្រូវបានបញ្ចប់បរធនបាលទាយកឬបរធនបាលទាយកជំនួសត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី ដែលមានវិជ្ជាជីវៈដើម្បីគ្រប់គ្រងនិងវាយតម្លៃបរធននោះ។ អ្នកជម្រះបញ្ជីត្រូវមានភារកិច្ចដូចខាងក្រោម៖

ក- បំពេញនិងបញ្ចប់កិច្ចការដែលនៅសល់របស់បរធនបាល។

ខ- ប្រមូលនិងសងបំណុលដែលនៅសល់។

គ- វាយតម្លៃបរធនដែលនៅសល់។

២- នៅពេលបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះរួចរាល់ហើយ អ្នកជម្រះបញ្ជីត្រូវផ្ដល់នូវគណនេយ្យចុងក្រោយនិងរបាយការណ៍ឱ្យទៅក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ត្រូវបែងចែកស្របតាមលិខិតបរធនបាលកិច្ចបរិស្ថាន។

៣- ប្រាក់កម្រៃសម្រាប់អ្នកជម្រះបញ្ជីត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃអត្រាវិជ្ជាជីវៈស្តង់ដារនិងត្រូវបង់ដោយកាត់យកចេញពីបរធនបាលកិច្ចបរិស្ថាន។

**មាត្រា៧៩០ .- អានុភាពនៃការបញ្ចប់បរធនបាលកិច្ចបរិស្ថាន**

១- បន្ទាប់ពីបានជម្រះបញ្ជីបរធនបាលកិច្ចបរិស្ថាន បរធនបាលត្រូវ៖

ក- ផ្ទេររាល់ទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានដែលនៅសល់ ស្របតាមលក្ខខណ្ឌនៃបរធនបាលកិច្ចបរិស្ថាន។

ខ- ផ្ទេរទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថានទាំងអស់ ទៅអត្ថគាហកៈដែលនៅមានជីវិតរស់នៅទាំងអស់ក្នុងចំណែកស្មើៗគ្នា ក្នុងករណីដែលបរធនបាលកិច្ចបរិស្ថាននោះមិនកំណត់អំពីបុគ្គល ដែលត្រូវទទួលទ្រព្យសម្បត្តិបរធនបាលកិច្ចបរិស្ថាននោះទេ។

២- បន្ទាប់ពីការបញ្ចប់បរធនបាលកិច្ចបរិស្ថាន បរធនបាលនៅតែទទួលខុសត្រូវចំពោះការបាត់បង់ឬខូចខាតដែលបានបង្កឡើងឬដែលបណ្តាលមកពីកំហុសដោយចេតនា ការធ្វេសប្រហែស ការក្លែងបន្លំ ឬភាពមិនស្មោះត្រង់របស់បរធនបាល។

**មាត្រា៧៩១ .- វិវាទពាក់ព័ន្ធប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថាន**

១- វិវាទពាក់ព័ន្ធប្រតិបត្តិការនៃបរធនបាលកិច្ចបរិស្ថានត្រូវដោះស្រាយ ដោយក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយបញ្ញត្តិករពាក់ព័ន្ធ។

២- ភាគីណាមួយមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាដោះស្រាយវិវាទបរធនបាលកិច្ចនៃក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចដាក់បណ្តឹងរដ្ឋបាល ឬបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

៣- លទ្ធផលនៃនីតិវិធីដោះស្រាយវិវាទទាំងអស់ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន។

**មាត្រា៧៩២ .- ការគ្រប់គ្រងឬការប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប**

បរធនបាលណាដែលគ្រប់គ្រងឬប្រើប្រាស់បរធនបាលកិច្ចបរិស្ថានមិនសមស្រប ឬផ្ទុយពីគោលបំណងនៃបរធនបាលកិច្ចបរិស្ថានដែលបណ្តាលឱ្យមានការខូចខាតដល់បរិស្ថាន ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតស្តីពីបរធនបាលកិច្ច។



ស

**មាត្រា៧៩៣ .– បរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា**

១- បរធនបាលកិច្ចបរិស្ថាន សម្រាប់ការគ្រប់គ្រងរួមគ្នាត្រូវបង្កើតឡើងដើម្បីផ្តល់ការគាំទ្រដល់សកម្មភាពនៃការគ្រប់គ្រងរួមគ្នាដែលស្ថិតនៅក្នុងតំបន់គ្រប់គ្រងរួមគ្នានីមួយៗ។ បរធនបាលកិច្ចបរិស្ថាននេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការគ្រប់គ្រងរួមគ្នានៃតំបន់គ្រប់គ្រងរួមគ្នាដោយមានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃពីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ប្រកបដោយតម្លាភាពស្របតាមបញ្ញត្តិដូចមានចែងក្នុងក្រមនេះ។

២- គណៈកម្មការគ្រប់គ្រងរួមគ្នាអាចទទួលបានថវិកានិងកម្រៃចំណូលពីប្រភពដែលមានជាអាទិ៍៖

ក- មូលនិធិសង្គមនិងបរិស្ថាន។

ខ- ប្រភពឯកជននិងសាធារណៈផ្សេងៗ។

គ- សេវានានា ការយកថ្លៃឈ្នួល ថ្លៃប្រើប្រាស់ ថ្លៃកម្សាន្ត ឬការយកថ្លៃចូលទស្សនាក្នុងតំបន់សហគមន៍ដែលគ្រប់គ្រងរួមគ្នាជាដើម។

ឃ- វិភាគទាន អំណោយ និងជំនួយ។

**មាត្រា៧៩៤ .– ការប្រើប្រាស់ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗ**

១- ការប្រើប្រាស់ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗដែលទទួលបានតាមរយៈការអនុវត្តនៃការគ្រប់គ្រងរួមគ្នាត្រូវបានប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន ដែលនៅក្នុងតំបន់គ្រប់គ្រងរួមគ្នាសម្រាប់ការគាំទ្រដល់ការអនុវត្តលើការគ្រប់គ្រងរួមគ្នា និងសម្រាប់ការអភិរក្សនៃតំបន់គ្រប់គ្រងរួមគ្នា និងបណ្តាតំបន់នៅជាប់ដែលមានការអភិរក្ស។ វិធីសាស្ត្រច្បាស់លាស់ក្នុងការបែងចែកប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗត្រូវកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា។

២- ប្រាក់ចំណូល ការចំណាយ ឬវិភាគទានផ្សេងៗដែលទទួលបានពីការងារគ្រប់គ្រងនៃសហគមន៍គ្រប់គ្រងរួមគ្នាត្រូវទទួលអាទិភាពក្នុងការលើកលែងពន្ធអាករនិងបន្ទុកផ្សេងៗដូចបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

## ជំពូកទី៤
## ហិរញ្ញប្បទានសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន

**មាត្រា៧៩៥ .– ធនធានហិរញ្ញវត្ថុសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន**

១- ម្ចាស់គម្រោងស្នើសុំដែលតម្រូវឱ្យមានផែនការគ្រប់គ្រងបរិស្ថានស្របតាមបទប្បញ្ញត្តិក្នុងមាតិកាទី២ (ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)នៃគន្ថីទី៥នៃក្រមនេះ ត្រូវផ្តល់ការធានាថាខ្លួនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោងជាមុនសិន មុនពេលមានការចេញលិខិត ឬវិញ្ញាបនបត្រឯកភាពលើគម្រោងនេះ។

២- ប្រភេទនិងចំនួននៃការធានាផ្នែកហិរញ្ញវត្ថុ លក្ខណវិនិច្ឆ័យ នីតិវិធីដោះស្រាយ និងការសម្រួលដល់ការអនុវត្តរបស់ម្ចាស់គម្រោងដែលមានស្រាប់និងគម្រោងដែលទទួលបានការឯកភាពពីរាជរដ្ឋាភិបាលត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ROYAUME DU CAMBODGE SECRÉTARIAT DU PALAIS ROYAL

**មាត្រា៧៩៦ ._ ថវិកាសម្រាប់ផែនការគ្រប់គ្រងបរិស្ថាន**

១- ថវិកាលម្អិតដែលត្រូវបានប៉ាន់ប្រមាណសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់ម្ចាស់គម្រោងត្រូវដាក់បញ្ចូលក្នុងផែនការគ្រប់គ្រងបរិស្ថាន មានជាអាទិ៍៖

ក- ថវិកាសម្រាប់វិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ធនធានធម្មជាតិ និងសង្គម។

ខ- ថវិកាសម្រាប់ការអង្កេតតាមដាន។

គ- ថវិកាសម្រាប់កិច្ចដំណើរការយន្តការបណ្តឹងនិងប្រតិបត្តិការគម្រោង។

ឃ- ថវិកាសម្រាប់ទទួលខុសត្រូវដល់ការផ្លាស់ប្តូរទីតាំងនិងសំណងចំពោះបុគ្គលដែលរងផលប៉ះពាល់ដោយសារគម្រោង។

ង- ការបង់ថ្លៃលើសេវាកម្មប្រព័ន្ធអេកូឡូស៊ីណាមួយដូចមានចែងក្នុងក្រមនេះ។

ច- ថវិកាសម្រាប់ការបិទការស្តារការដ្ឋាន នីតិសម្បទា ដំណោះស្រាយ ឬការបញ្ឈប់សកម្មភាពគម្រោង។

ឆ- ថវិកាបម្រុងផ្សេងទៀតពាក់ព័ន្ធការអនុវត្តផែនការគ្រប់គ្រងបរិស្ថានរបស់គម្រោង។

២- ម្ចាស់គម្រោងជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថានដោយប្រើប្រាស់ថវិកាដោយខ្លួនឯង ដែលមិនមែនជាកញ្ចប់ថវិកាមូលនិធិបរិស្ថាននិងសង្គម។

**មាត្រា៧៩៧ ._ នីតិវិធីនៃការធានាផ្នែកហិរញ្ញវត្ថុ**

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណវិនិច្ឆ័យនិងនីតិវិធីសម្រាប់កំណត់ការធានាផ្នែកហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការអនុវត្តផែនការគ្រប់គ្រងបរិស្ថាននៃគម្រោង ដែលបានស្នើសុំមានជាអាទិ៍៖

ក- វិសាលភាពនៃការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការ។

ខ- ទម្រង់បែបបទនៃការធានាផ្នែកហិរញ្ញវត្ថុដែលអាចទទួលយកបាន។

គ- ចំនួនទឹកប្រាក់ដែលតម្រូវឱ្យមាននៅក្នុងការធានាផ្នែកហិរញ្ញវត្ថុដោយផ្អែកលើ ទំហំ ខ្នាត ទីតាំង និងផលប៉ះពាល់ដែលអាចកើតមាន។

ឃ- ក្របខ័ណ្ឌពេលវេលាសម្រាប់ការប្តឹងចំពោះធនធានហិរញ្ញវត្ថុដែលយកមកដាក់ធានាឬបើគ្មានការប្តឹងណាមួយទេ ត្រូវដាក់ឱ្យធនធានហិរញ្ញវត្ថុនេះអាចស្វែងរកបាន។

**មាត្រា៧៩៨ ._ ការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

១- ម្ចាស់គម្រោងដែលតម្រូវឱ្យផ្តល់ការធានាផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការគ្រប់គ្រងបរិស្ថានត្រូវអនុលោមតាមលក្ខខណ្ឌតម្រូវក្នុងការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធស្តីពីការធ្វើសវនកម្មនិងការរៀបចំរបាយការណ៍។

២- ម្ចាស់គម្រោងត្រូវធ្វើការពិនិត្យប្រចាំឆ្នាំឡើងវិញនូវការប៉ាន់ប្រមាណតម្លៃនានាពាក់ព័ន្ធផែនការគ្រប់គ្រងបរិស្ថាននិងដាក់ជូនការប៉ាន់ប្រមាណនេះមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ ការប៉ាន់ប្រមាណនេះត្រូវធ្វើឡើងដោយសវនកម្មឯករាជ្យ។

៣- ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថា ពុំមានការគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុ ម្ចាស់គម្រោងត្រូវជូនដំណឹងទៅក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត។

៤- ម្ចាស់គម្រោងត្រូវគោរពតាមលក្ខខណ្ឌតម្រូវសម្រាប់ការធានាផ្នែកហិរញ្ញវត្ថុដែលបានធ្វើបច្ចុប្បន្នកម្មក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ បន្ទាប់ពីការជូនដំណឹង។

៥- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចតម្រូវឱ្យមានរបាយការណ៍ឬឯកសារបន្ថែមទៀតក្នុងករណីចាំបាច់។

៦- ក្នុងករណីដែលរបាយការណ៍សវនកម្មប្រចាំឆ្នាំបង្ហាញថាមានការធានាផ្នែកហិរញ្ញវត្ថុដែលលើសពីលក្ខខណ្ឌតម្រូវ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិអាចដាក់សំណើមកក្រសួងស្ថាប័នទទួលបន្ទុកវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីអនុញ្ញាតសុំបង្វិលសងមូលនិធិ ដែលលើសតាមការស្នើសុំរបស់ម្ចាស់គម្រោង។

# គន្ថីទី៩
# ការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ
## មាតិកាទី១
## យន្តការនិងនីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ
### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា៧៩៩ .- គោលបំណង**

គន្ថីនេះកំណត់អំពីយន្តការនិងនីតិវិធីសម្រាប់ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨០០ .- វិសាលភាព**

គន្ថីនេះមានវិសាលភាពអនុវត្តលើការដោះស្រាយវិវាទទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិទៅលើពាក្យប្តឹងឬការទាមទារដូចខាងក្រោម៖

ក- ទាមទារឱ្យសងសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ។

ខ- ទាមទារឱ្យស្តារការខូចខាតបរិស្ថានឬធនធានធម្មជាតិឡើងវិញ។

គ- ទាមទារឱ្យកំណត់វិធានការ ដើម្បីធានាថានឹងមិនបង្កការបំពុលបរិស្ថានឬធនធានធម្មជាតិឬការធ្វើឱ្យខូចខាតបរិស្ថានឬធនធានធម្មជាតិសាជាថ្មីឡើងវិញ។

ឃ- ទាមទារឱ្យកំណត់វិធានការទប់ស្កាត់ផលប៉ះពាល់ជាអវិជ្ជមាន ដែលកើតមានចំពោះបរិស្ថានឬធនធានធម្មជាតិ។

**មាត្រា៨០១ .- គោលការណ៍ទូទៅនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- ចំពោះការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទនោះទៅយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដើម្បីសម្រុះសម្រួលមុននឹងប្តឹងទៅតុលាការដោយអនុវត្តស្របតាមបទប្បញ្ញត្តិនៃក្រមនេះ។

២- ប៉ុន្តែបញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនរារាំងដល់ការប្រើប្រាស់សិទ្ធិក្នុងការប្តឹងទៅតុលាការដោយផ្ទាល់នោះទេ។ ក្នុងករណីចាំបាច់ តុលាការដែលទទួលពាក្យបណ្តឹងទាក់ទងនឹងវិវាទបរិស្ថាននិងធនធានធម្មជាតិអាចបញ្ជូនសំណុំរឿងនេះទៅយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដើម្បីធ្វើការសម្រុះសម្រួលជាមុន។ ក្នុងករណីដែលពុំមានដំណោះស្រាយតាមការស្រុះស្រួលគ្នា នៅចំពោះមុខយន្តការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ភាគីមានសិទ្ធិស្នើសុំឱ្យតុលាការដើម្បីបន្តអនុវត្តនីតិវិធីរបស់ខ្លួនស្របតាមច្បាប់និងនីតិវិធីជាធរមាន។

៣- ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើមិនត្រូវយកមកអនុវត្តឡើយចំពោះបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

៤- ការសម្រុះសម្រួលដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ មិនរាំងការអនុវត្តបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត ប្រសិនបើអង្គហេតុដែលជាកម្មវត្ថុនៃការសម្រុះសម្រួលនេះបង្កើតបានជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយយោងតាមក្រមនេះឬច្បាប់ព្រហ្មទណ្ឌជាធរមានដទៃទៀត។

**មាត្រា៨០២ ._ ភាគីនៃវិវាទបរិស្ថាននិងធនធានធម្មជាតិ**

ភាគីដែលមានសិទ្ធិធ្វើបណ្តឹងបរិស្ថាននិងធនធានធម្មជាតិមាន ដូចខាងក្រោម៖

ក- ភាគីដែលរងផលប៉ះពាល់ អាចធ្វើសកម្មភាពបណ្តឹងដើម្បីទាមទារសំណងការខូចខាតឬសំណងជំងឺចិត្ត។

ខ- ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសកម្មភាពបណ្តឹង ដើម្បីទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ឬស្តារបរិស្ថានឡើងវិញ ឬទប់ស្កាត់សកម្មភាពណាមួយដែលបង្កផលប៉ះពាល់ឬបំពុលបរិស្ថាន និងខូចខាតលើធនធានធម្មជាតិ។

គ- សមាគមនិងអង្គការដែលបានចុះបញ្ជីស្របច្បាប់ និងទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ អាចធ្វើសកម្មភាពបណ្តឹងដើម្បីបញ្ឈប់ឬទប់ស្កាត់សកម្មភាពណាមួយ ទាមទារសំណងការខូចខាតបរិស្ថានឬធនធានធម្មជាតិ ឬទាមទារសំណងការខូចខាតឬជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍។ ប៉ុន្តែចំពោះការទាមទារសំណងការខូចខាត ឬជំងឺចិត្តជូនជនរងគ្រោះ ឬសហគមន៍ត្រូវមានលិខិតប្រគល់សិទ្ធិត្រឹមត្រូវ។

## ជំពូកទី២

## យន្តការសម្រាប់ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨០៣ ._ រចនាសម្ព័ន្ធគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ មានរចនាសម្ព័ន្ធដូចខាងក្រោម៖

ក- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ។

ខ- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត។

២-ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការ ដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨០៤ ._ សមត្ថកិច្ចរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិមានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាននិងធនធានធម្មជាតិ ដែលភាគីណាមួយនៃវិវាទប្តឹងតវ៉ាមិនសុខចិត្តនឹងការសម្រុះសម្រួលរបស់គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ឬក្នុងករណីដែលទទួលបណ្តឹងដោយផ្ទាល់ពីភាគីណាមួយនៃវិវាទ។

២- គណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត មានសមត្ថកិច្ចសម្រុះសម្រួលលើវិវាទបរិស្ថាននិងធនធានធម្មជាតិ នៅក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរបស់ខ្លួន។

## ជំពូកទី៣

## នីតិវិធីនៃការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨០៥ ._ ការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិ**

១- ការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិត្រូវធ្វើដោយផ្អែកលើច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- បែបបទនិងនីតិវិធីនៃការសម្រុះសម្រួលវិវាទបរិស្ថាននិងធនធានធម្មជាតិដោយគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ និងគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់រាជធានី ខេត្ត ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា៨០៦ ._ កិច្ចព្រមព្រៀងសះជា**

១- កិច្ចព្រមព្រៀងសះជា ត្រូវធ្វើឡើងនៅចំពោះមុខគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាននិងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត និងត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយត្រូវឱ្យភាគីនៃវិវាទទាំងអស់ចុះហត្ថលេខា ឬផ្តិតស្រាមដៃ ព្រមទាំងចុះហត្ថលេខា ឬផ្តិតស្រាមដៃបញ្ជាក់លើកិច្ចព្រមព្រៀងសះជានោះ ដោយសមាជិកទាំងអស់នៃគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ឬថ្នាក់រាជធានី ខេត្ត។

២- កិច្ចព្រមព្រៀងសះជា ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវមានអានុភាពអនុវត្តដូចគ្នាទៅនឹងលិខិតអនុវត្ត លើកលែងតែកិច្ចព្រមព្រៀងនេះមានមោឃៈ។

៣- កិច្ចព្រមព្រៀងសះជានេះ មិនមែនជារបសគ្គសម្រាប់តតិយជនក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនឡើយ។

**មាត្រា៨០៧ ._ ការប្តឹងបន្តក្នុងករណីមិនសះជា**

ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់រាជធានី ខេត្ត ភាគីនៃវិវាទមានសិទ្ធិប្តឹងបន្តទៅគណៈកម្មាធិការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិថ្នាក់ជាតិ ក្នុងរយៈពេល៩០(កៅសិប)ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលបានកំណត់ហេតុមិនសះជា។ ក្នុងករណីដែលការសម្រុះសម្រួលមិនសះជានៅថ្នាក់ជាតិ ភាគីនៃវិវាទមានសិទ្ធិប្តឹងបន្តទៅតុលាការមានសមត្ថកិច្ច ដោយអនុវត្តស្របតាមច្បាប់ និងនីតិវិធីជាធរមាន។

## មាតិកាទី២

## មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា៨០៨ ._ គោលបំណង**

មាតិកានេះ មានគោលបំណងកំណត់បែបបទនិងនីតិវិធីក្នុងការបំពេញតួនាទីរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន។

**មាត្រា៨០៩ ._ វិសាលភាព**

មាតិកានេះ មានវិសាលភាពអនុវត្តលើរាល់សកម្មភាពការងាររបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ និងមន្ត្រីអធិការកិច្ចបរិស្ថាន។

## ជំពូកទី២

## ស្ថាប័នទទួលខុសត្រូវ

### ផ្នែកទី១

### មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ

**មាត្រា៨១០ ._ ការចាត់តាំងនិងការបំពេញភារកិច្ចរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិនិងការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌**

១- រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ជាតិ។ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវចាត់តាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់

ក្រោមជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការចាត់តាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធ្វើដោយផ្អែកលើលក្ខណសម្បត្តិ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

២- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិមានការកិច្ចតាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងការអនុវត្តច្បាប់ក្នុងតំបន់ការពារធម្មជាតិ។

៣- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសធនធានធម្មជាតិនៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ហើយមានអំណាចឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀតដោយអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤- ការផ្តល់នីតិសម្បទា និងដែនសមត្ថកិច្ចចំពោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិជានគរបាលយុត្តិធម៌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៥- ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសធនធានធម្មជាតិ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨១១ .- កិច្ចសហការនិងការពិនិត្យបទល្មើសរបស់នគរបាលយុត្តិធម៌**

មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិមានសិទ្ធិស្នើសុំជំនួយពីរដ្ឋបាលថ្នាក់ក្រោមជាតិ កងកម្លាំងប្រដាប់អាវុធ និងស្ថាប័នពាក់ព័ន្ធដទៃទៀតដើម្បីចូលរួមពិនិត្យ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ឬការថែរក្សាវត្ថុចាប់យកនៃបទល្មើសជាបណ្តោះអាសន្ន។

**មាត្រា៨១២ .- ឯកសណ្ឋានក្នុងការបំពេញបេសកកម្ម**

១- នៅពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម។

២- ឯកសណ្ឋាន ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨១៣ .- ការប្រើប្រាស់អាវុធ**

១- មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសិទ្ធិប្រើប្រាស់អាវុធស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតជាធរមាន។

២- អាវុធត្រូវបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ។

## ផ្នែកទី២
## មន្ត្រីអធិការកិច្ចបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨១៤ .- ការតែងតាំងមន្ត្រីអធិការកិច្ចបរិស្ថាន**

១-ការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាននិងកិច្ចគាំពារបរិស្ថាន ត្រូវអនុវត្តដោយមន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬមន្ត្រីអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមសមត្ថកិច្ចរៀងៗខ្លួនស្របតាមក្រមនេះ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២-បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាននិងកិច្ចគាំពារបរិស្ថាន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ និងក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដទៃទៀត។

**មាត្រា៨១៥ .- តួនាទីនិងភារកិច្ចរបស់មន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ**

មន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

ក- ធ្វើអធិការកិច្ច តាមដាន ស្រាវជ្រាវ ត្រួតពិនិត្យ និងជំរុញការអនុវត្តបញ្ញត្តិនៃក្រមនេះពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន និងកិច្ចគាំពារបរិស្ថាន ក្រោមសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ខ- ធ្វើរបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអធិការកិច្ចដាក់ជូនថ្នាក់ដឹកនាំដើម្បីពិនិត្យនិងសម្រេច។

គ- ចាត់វិធានការផ្សេងទៀតក្នុងក្របខ័ណ្ឌនៃការអនុវត្តក្រមនេះ។

ឃ- អនុវត្តតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨១៦ .- ការចាត់តាំងនិងការបំពេញភារកិច្ចរបស់មន្ត្រីអធិការកិច្ចបរិស្ថាន និងការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌**

១- មន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬមន្ត្រីអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសបរិស្ថាននៅក្នុងវង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន ហើយមានអំណាចឆែកឆេរ ចាប់យកវត្ថុតាង កោះហៅបុគ្គលពាក់ព័ន្ធ និងបំពេញកិច្ចនីតិវិធីដទៃទៀត ដោយអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

២- ការផ្តល់នីតិសម្បទានិងសមត្ថកិច្ចចំពោះមន្ត្រីអធិការកិច្ចបរិស្ថានដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។ បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចបរិស្ថាន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

៣-ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសបរិស្ថាន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងយុត្តិធម៌ និងក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

**មាត្រា៨១៧ .- ការប្រើប្រាស់ឯកសណ្ឋានរបស់មន្ត្រីអធិការកិច្ចបរិស្ថាន**

១- មន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬមន្ត្រីអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានលិខិតបញ្ជាបេសកកម្ម និងស្លៀកពាក់ឯកសណ្ឋាន ពាក់ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិ នៅពេលចុះបំពេញតួនាទីនិងភារកិច្ច។

២- ឯកសណ្ឋាន ស្លាកសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ មន្ត្រីអធិការកិច្ចរបស់ក្រសួងស្ថាប័នមានសមត្ថកិច្ច ឬមន្ត្រីអធិការកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE LE DIRECTEUR DU PALAIS ROYAL

## ផ្នែកទី៣

## វត្ថុចាប់យកនៃបទល្មើសបរិស្ថាននិងធនធានធម្មជាតិ

**មាត្រា៨១៨ .-** ប្រភេទវត្ថុចាប់យកនៃបទល្មើសបរិស្ថាននិងធនធានធម្មជាតិ

១- វត្ថុចាប់យកនៃបទល្មើសដែលមានចែងនៅក្នុងក្រមនេះ មានជាអាទិ៍៖

ក- ផលនិងអនុផលធនធានធម្មជាតិ សារធាតុគ្រោះថ្នាក់ ឬផលិតផលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដែលជាវត្ថុចាប់យកដែលពាក់ព័ន្ធនឹងបទល្មើស។

ខ- សម្ភារៈ ឧបករណ៍ បរិក្ខារ និងមធ្យោបាយដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។

គ- ផលទុនឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

២- ផលនិងអនុផលធនធានធម្មជាតិដែលបានចាប់យក ហើយងាយខូចខាត មន្ត្រីទទួលបន្ទុកគ្រប់គ្រងតំបន់ការពារធម្មជាតិ មានសិទ្ធិលែង បំផ្លាញចោល ឬរក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវដោយត្រូវមានការយល់ព្រមពីព្រះរាជអាជ្ញា។

**មាត្រា៨១៩ .-** ការចំណាយលើវត្ថុចាប់យកដែលជាសារធាតុគ្រោះថ្នាក់ឬផលិតផលដែលមានផ្ទុកសារធាតុគ្រោះថ្នាក់

ការចំណាយលើការដឹកជញ្ជូន រក្សាទុក និងកម្ទេចចោលសារធាតុគ្រោះថ្នាក់ឬផលិតផល ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ដែលវត្ថុចាប់យកត្រូវជាបន្ទុករបស់ម្ចាស់វត្ថុចាប់យក។

**មាត្រា៨២០ .-** ការថែរក្សានិងគ្រប់គ្រងវត្ថុចាប់យកនៃរុក្ខជាតិនិងបំណែករុក្ខជាតិព្រៃ

ការថែរក្សានិងគ្រប់គ្រងវត្ថុចាប់យកនៃរុក្ខជាតិ និងបំណែករុក្ខជាតិព្រៃកំពុងរងការគំរាមកំហែង ឬផលដែលបានកើតចេញពីរុក្ខជាតិព្រៃត្រូវ៖

ក- ករណីរុក្ខជាតិរស់៖ ត្រូវយករុក្ខជាតិព្រៃទាំងនេះទៅទីជម្រកដើមឬត្រូវប្រគល់ឱ្យទៅស្ថាប័នណាមួយក្នុងគោលបំណងបង្កាត់ ផ្សាំ ឬស្ថាប័នសិក្សា ស្ថាប័នស្រាវជ្រាវ អង្គការអភិរក្ស កន្លែងរក្សាសំណាករុក្ខជាតិព្រៃ ឬរុក្ខឧទ្យាន ដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ។

ខ- ករណីរុក្ខជាតិព្រៃងាប់ ឬបំណែករុក្ខជាតិព្រៃដែលមិនអាចផ្សាំបាន៖ ត្រូវរក្សាទុកនៅទីតាំងដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ បន្ទាប់ពីមានការយល់ព្រមពីព្រះរាជអាជ្ញា។

**មាត្រា៨២១ .-** ការថែរក្សានិងការគ្រប់គ្រងវត្ថុចាប់យកដែលជាសត្វព្រៃ បំណែក ឬសំណាកសត្វព្រៃ

១- ការថែរក្សា និងការគ្រប់គ្រងវត្ថុចាប់យក ដែលជាសត្វព្រៃដែលស្លាប់ បំណែកសរីរាង្គ ឬសំណាកសត្វព្រៃត្រូវរក្សាទុកនៅទីសុវត្ថិភាព ឬនៅទីតាំងដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិបន្ទាប់ពីមានការយល់ព្រមពីព្រះរាជអាជ្ញា។

២- ក្នុងករណីវត្ថុចាប់យកជាសត្វព្រៃរស់ត្រូវទទួលការថែទាំ សង្គ្រោះបន្ទាន់ និងជំនួយបឋម ហើយត្រូវប្រគល់ទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃដែលកំណត់ដោយក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ។ ការអនុវត្តវិធីសាស្ត្រនេះ ត្រូវមានកំណត់ហេតុច្បាស់លាស់ និងមានថតរូប ឬវីដេអូ ទុកជាឯកសារ។

**មាត្រា៨២២ .-** ការរឹបអូសវត្ថុចាប់យកនៃបទល្មើសបរិស្ថាននិងធនធានធម្មជាតិជាទ្រព្យសម្បត្តិរដ្ឋ

វត្ថុចាប់យកនៃបទល្មើសបរិស្ថាននិងធនធានធម្មជាតិ ដែលមានចែងនៅក្នុងក្រមនេះ ត្រូវរឹបអូសជាទ្រព្យសម្បត្តិរដ្ឋដោយសេចក្តីសម្រេចរបស់តុលាការ លើកលែងតែមានបទប្បញ្ញត្តិចែងផ្សេងពីនេះ។

# គន្ថីទី១០
# ទោសប្បញ្ញត្តិ
## មាតិកាទី១
## បទប្បញ្ញត្តិទូទៅ
## ជំពូកទោល
## បទប្បញ្ញត្តិរួម

**មាត្រា៨២៣ ._ ប្រភេទទណ្ឌកម្ម**

ទណ្ឌកម្មនៅក្នុងក្រមនេះ រួមមាន ទណ្ឌកម្មរដ្ឋបាលនិងទណ្ឌកម្មព្រហ្មទណ្ឌ។

**មាត្រា៨២៤ ._ ទណ្ឌកម្មរដ្ឋបាល**

១- ទណ្ឌកម្មរដ្ឋបាល មានជាអាទិ៍៖

ក- ការព្រមាន។

ខ- ការផ្អាកសកម្មភាព ការព្យួរ ឬការដកហូតជាបណ្ដោះអាសន្ននូវអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ កិច្ចសន្យា កិច្ចព្រមព្រៀង ឬគម្រោង។

គ- ការលុបចោល ឬការដកអាជ្ញាប័ណ្ណ លិខិតអនុញ្ញាត វិញ្ញាបនបត្រ កិច្ចសន្យា ឬកិច្ចព្រមព្រៀង។

២- ការព្រមាន ការផ្អាកសកម្មភាព ការព្យួរ ការដកហូត ឬការលុបចោលលិខិតអនុញ្ញាត ឬវិញ្ញាបនបត្រ ឬកិច្ចសន្យា ឬកិច្ចព្រមព្រៀង ឬគម្រោងជាបណ្ដោះអាសន្ន ការដកហូតអាជ្ញាប័ណ្ណ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ច ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

៣- អំពើល្មើសដែលត្រូវរងទណ្ឌកម្មរដ្ឋបាលខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬប្រកាសរបស់រដ្ឋមន្ត្រីក្រសួងដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

៤- បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងចំណុច ខ និង គ នៃកថាខណ្ឌទី១ខាងលើនេះ មានសិទ្ធិប្ដឹងទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេច។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចត្រូវសម្រេចលើពាក្យប្ដឹងតវ៉ាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានពាក្យប្ដឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬរដ្ឋមន្ត្រីក្រសួងមានសមត្ថកិច្ចលើពាក្យប្ដឹងតវ៉ា មានសិទ្ធិប្ដឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធី ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេច។ ការដាក់ពាក្យប្ដឹងតវ៉ារបស់បុគ្គលខាងលើ មិនមានអានុភាពផ្អាកការអនុវត្តសេចក្ដីសម្រេចអំពីទណ្ឌកម្មរដ្ឋបាលនោះទេ។

**មាត្រា៨២៥ ._ ទណ្ឌកម្មព្រហ្មទណ្ឌ**

១- ទណ្ឌកម្មព្រហ្មទណ្ឌ មានជាអាទិ៍៖

ក- ការពិន័យអន្តរការណ៍។

ខ- ទោសពិន័យជាប្រាក់។

គ- ទោសដាក់ពន្ធនាគារ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

២- ការពិន័យអន្តរការណ៍ចំពោះអំពើល្មើសបរិស្ថាន និងធនធានធម្មជាតិ ជាសមត្ថកិច្ចរបស់មន្ត្រីដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីពិនិត្យបទល្មើសបរិស្ថាននិងធនធានធម្មជាតិ ស្របតាមក្រមនេះ និងច្បាប់ពាក់ព័ន្ធជាធរមានផ្សេងទៀត។

៣- ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យបណ្តឹងអាជ្ញារលត់។ ការបង់ប្រាក់ពិន័យអន្តរការណ៍មិនមែនជាឧបសគ្គដល់ការអនុវត្តទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មព្រហ្មទណ្ឌស្របតាមបទប្បញ្ញត្តិនៃក្រមនេះ និងច្បាប់ព្រហ្មទណ្ឌជាធរមានផ្សេងទៀតឡើយ។

៤- បែបបទ និងនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃនៃការបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែងនៅក្នុងក្រមនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ឬក្រសួងស្ថាប័នមានសមត្ថកិច្ច ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តជូនមន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសដែលមានចែងក្នុងក្រមនេះ។

**មាត្រា៨២៦ ._ បទល្មើសដែលត្រូវពិន័យអន្តរការណ៍**

១- ការបំពានទៅនឹងមាត្រា១៥៦(អនុលោមភាពស្តង់ដារបញ្ចេញសំណល់) មាត្រា១៦១(កាតព្វកិច្ចមិនបង្កការរំខានដោយសំឡេង រំញ័រ ឬក្លិន) មាត្រា១៧៣(ការស្នើសុំនិងប្រភេទនៃលិខិតអនុញ្ញាតសំណល់) មាត្រា១៨៩(ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់) មាត្រា១៩១(ការចុះបញ្ជិកាផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់) មាត្រា២០៦(ការហាមឃាត់ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់) មាត្រា២៣៤(លិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្ម) មាត្រា២៣៥(លិខិតអនុញ្ញាតសេវាកម្មឬអាជីវកម្មកែច្នៃនិងទាញយកធនធានសំណល់រឹង) មាត្រា២៣៦(ការនាំចេញសំណល់រឹងឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹង) មាត្រា២៨៧(ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពជាក់លាក់) មាត្រា២៩៨(ការហាមឃាត់ការបញ្ចេញសំណល់) មាត្រា២៩៩(ការទទួលខុសត្រូវរបស់ម្ចាស់ដំណើរការ) មាត្រា៣១៧(ការចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់) មាត្រា៦៥៨(ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គលឬរូបវន្តបុគ្គល) និងមាត្រា៦៦៨(ការហាមឃាត់ចំពោះសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោង)នៃក្រមនេះ ត្រូវកំណត់ជាបទល្មើសដែលត្រូវពិន័យអន្តរការណ៍ ដែលចំនួនទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវកំណត់ក្នុងអនុក្រឹត្យ។

២- ក្រៅពីបទល្មើសដែលត្រូវពិន័យអន្តរការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ បទល្មើសផ្សេងទៀតក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ដែលត្រូវពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

## មាតិកាទី២

## បទល្មើសបរិស្ថាននិងធនធានធម្មជាតិ

### ជំពូកទី១

### បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងបរិស្ថាន

**មាត្រា៨២៧ ._ ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសត្វ/ង្គកាយកែច្នៃរស់**

១- បុគ្គលដែលបានធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសព៌ាង្គកាយកែច្នៃរស់ ហើយបានបង្កផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម សេដ្ឋកិច្ច ជីវៈចម្រុះ សុខភាពមនុស្ស ឬទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ដល់៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

២- បុគ្គលដែលបានបង្កផលប៉ះពាល់ឬការខូចខាតបរិស្ថាន សង្គម សេដ្ឋកិច្ច ជីវៈចម្រុះ សុខភាពមនុស្ស ឬទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ហើយមិនបានបំពេញកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៤៦ (កាតព្វកិច្ចដែលត្រូវបំពេញដោយបុគ្គលដែលបង្កផលប៉ះពាល់ឬការខូចខាត)នៃក្រមនេះ ត្រូវផ្តន្ទាទោសទ្វេដង។

**មាត្រា៨២៨ ._ ការបំពានកាតព្វកិច្ចក្នុងការបញ្ចៀសការខូចខាតបរិស្ថាន**

បុគ្គលដែលមិនបានប្រើប្រាស់បច្ចេកវិទ្យាល្អដែលអាចស្វែងរកបាន និងការអនុវត្តល្អៗ ដើម្បីបញ្ចៀសការបង្កឱ្យមានការបំពុលឬការខូចខាតដល់បរិស្ថានធ្ងន់ធ្ងរ ដូចមានចែងក្នុងមាត្រា១៤៧(ការបញ្ចៀសការខូចខាតបរិស្ថាន) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០ (ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

## ជំពូកទី២

## បទល្មើសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន

**មាត្រា៨២៩ ._ ការបញ្ចេញសំណល់ឬសារធាតុបំពុលទៅក្នុងបរិស្ថានមិនស្របតាមស្តង់ដារបញ្ចេញសំណល់**

បុគ្គលដែលបានបញ្ចេញចោលសំណល់ ឬសារធាតុបំពុលទៅក្នុងបរិស្ថាន ដោយមិនអនុវត្តតាមស្តង់ដារបញ្ចេញសំណល់ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១៥៦(អនុលោមភាពស្តង់ដារបញ្ចេញសំណល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន ២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣០ ._ ការបំពានកាតព្វកិច្ចដែលបង្កការរំខានដោយសំឡេង រំញ័រ ឬក្លិន**

បុគ្គលដែលបានធ្វើសកម្មភាពបញ្ចេញសំឡេង រំញ័រ ឬក្លិន ដែលបង្កឱ្យមានការរំខានដល់ការរស់នៅ ឬការប៉ះពាល់ដល់សុខភាពមនុស្ស ឬផលប្រយោជន៍សាធារណៈ ឬឯកជន ដូចមានចែងក្នុងមាត្រា១៦១(កាតព្វកិច្ចមិនបង្កការរំខានដោយសំឡេង រំញ័រ ឬក្លិន)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣១ ._ ការបញ្ចេញឬការធ្វើអាជីវកម្មសំណល់ដោយគ្មានលិខិតអនុញ្ញាត**

បុគ្គលដែលបានបញ្ចេញសំណល់ ឬធ្វើអាជីវកម្មសំណល់ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រា១៧៣(ការស្នើសុំនិងប្រភេទលិខិតអនុញ្ញាតសំណល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣២ ._ ការមិនចុះបញ្ជិកាសារធាតុគ្រោះថ្នាក់**

បុគ្គលដែលមិនបានចុះបញ្ជិកាលើការផលិត ការនាំចូល ឬការចែកចាយសារធាតុគ្រោះថ្នាក់ ឬផលិតផលគីមីដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និង

ធនធានធម្មជាតិ ដូចមានចែងក្នុងមាត្រា១៨៩(ការចុះបញ្ជិកាសារធាតុគ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣៣ .- ការផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី**

១- បុគ្គលដែលធ្វើការផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយគ្មានការអនុញ្ញាតស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៣០០ ០០០ ០០០(បីរយលាន)រៀល។

២- បុគ្គលដែលធ្វើការផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ដោយគ្មានការអនុញ្ញាតស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ហើយបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ជីវៈចម្រុះ ឬសុខភាពសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០ ០០០ ០០០(ពីររយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

**មាត្រា៨៣៤ .- ការមិនចុះបញ្ជិកាផលិតផល ឬសម្ភារៈប្រើប្រាស់ និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់**

បុគ្គលដែលមិនបានចុះបញ្ជិកានៅលើការផលិត ការនាំចូល ឬការចែកចាយផលិតផល ឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេង ដែលមានផ្ទុកសារធាតុគ្រោះថ្នាក់ ដូចមានចែងក្នុងមាត្រា១៩១(ការចុះបញ្ជិកាផលិតផលឬសម្ភារៈប្រើប្រាស់និងសម្ភារៈក្មេងលេងដែលមានផ្ទុកសារធាតុគ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣៥ .- ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់**

១- បុគ្គលដែលធ្វើសកម្មភាពបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ដូចមានចែងក្នុងមាត្រា២០៦(ការហាមឃាត់ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

២- បុគ្គលដែលធ្វើសកម្មភាពបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់ចូលទៅក្នុងបរិស្ថាន ហើយបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ជីវៈចម្រុះ ឬសុខភាពសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

**មាត្រា៨៣៦ .- ការអនុវត្តសេវាប្រមូល ដឹកជញ្ជូន សេវាប្រព្រឹត្តិកម្ម និងសេវាទីលានទុកដាក់សំណល់រឹងឧស្សាហកម្ម ដោយគ្មានការអនុញ្ញាត**

បុគ្គលដែលបានធ្វើសេវាប្រមូល ដឹកជញ្ជូន សេវាប្រព្រឹត្តិកម្ម និងទីលានទុកដាក់ចុងក្រោយសំណល់រឹងឧស្សាហកម្មដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា២៣៤(លិខិតអនុញ្ញាតអាជីវកម្មសំណល់រឹងឧស្សាហកម្ម)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ដល់១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣៧ .- ការអនុវត្តសេវាកម្មឬអាជីវកម្មកែច្នៃនិងទាញយកធនធានសំណល់រឹងដោយគ្មានការអនុញ្ញាត**

បុគ្គលដែលបានធ្វើសេវាកម្ម ឬអាជីវកម្មកែច្នៃ ទាញយកធនធាន ឬធ្វើប្រព្រឹត្តិកម្មសំណល់រឹង ដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា២៣៥(លិខិតអនុញ្ញាតសេវាកម្មឬអាជីវកម្មកែច្នៃនិងទាញយកធនធានសំណល់រឹង)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ដល់១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល ១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣៨ .- ការនាំចេញសំណល់ឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹងដោយគ្មានការអនុញ្ញាត**

បុគ្គលដែលបានធ្វើការនាំចេញសំណល់រឹង ឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹងដោយគ្មានលិខិតអនុញ្ញាត ដូចមានចែងក្នុងមាត្រា២៣៦(ការនាំចេញសំណល់រឹងឬវត្ថុធាតុដើមពីការកែច្នៃសំណល់រឹង)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ដល់ ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន ២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៣៩ .- ការនាំចូលសំណល់រឹង**

បុគ្គលដែលបាននាំចូលសំណល់រឹងពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបំពាននឹងបញ្ញត្តិនៃមាត្រា២៣៧(ការនាំចូលសំណល់រឹង)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

**មាត្រា៨៤០ .- ការមិនអនុវត្តកាតព្វកិច្ចរបស់ម្ចាស់សំណល់គ្រោះថ្នាក់**

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា២៥២(កាតព្វកិច្ចរបស់ម្ចាស់សំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០ (មួយរយលាន)រៀល ទៅ៣០០ ០០០ ០០០(បីរយលាន)រៀល។

**មាត្រា៨៤១ .- ការបញ្ចេញសំណល់គ្រោះថ្នាក់ដោយគ្មានលិខិតអនុញ្ញាត**

បុគ្គលដែលមិនអនុវត្តតាមមាត្រា២៥៣(លិខិតអនុញ្ញាតបញ្ចេញសំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី២០០ ០០០ ០០០(ពីររយលាន) រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា៨៤២ .- ការនាំចូលសំណល់គ្រោះថ្នាក់**

បុគ្គលដែលនាំចូលសំណល់គ្រោះថ្នាក់ពីក្រៅប្រទេសចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដោយបំពាននឹងបញ្ញត្តិនៃមាត្រា២៦៤(ការហាមឃាត់ការនាំចូលសំណល់គ្រោះថ្នាក់)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ដល់៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

**មាត្រា៨៤៣ .- ការមិនបំពេញកាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់**

បុគ្គលដែលមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា២៦៨(កាតព្វកិច្ចរបស់ម្ចាស់ទីតាំងផលិតកម្ម អាជីវកម្ម និងសេវាកម្មដែលបង្កើតសំណល់គ្រោះថ្នាក់និងប្រតិបត្តិករសំណល់គ្រោះថ្នាក់នៅក្នុងសកម្មភាពផលិតកម្ម អាជីវកម្ម ឬសេវាកម្ម)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល។

**មាត្រា៨៤៤ .- សកម្មភាពបង្កផលប៉ះពាល់ដល់បរិស្ថាន**

បុគ្គលដែលធ្វើសកម្មភាពស្តុកទុក បញ្ចេញ ដុត កប់ បោះចោលសំណល់គ្រោះថ្នាក់ ហើយបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន សុខភាពសាធារណៈ ឬបង្កការខូចខាតទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា២៧២(សកម្មភាពបង្កផលប៉ះពាល់)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

**មាត្រា៨៤៥ .- ការមិនអនុវត្តកាតព្វកិច្ចក្នុងការគ្រប់គ្រងសំណល់រាវ និងទឹកកខ្វក់**

បុគ្គលដែលមិនអនុវត្តការគ្រប់គ្រងសំណល់រាវ និងទឹកកខ្វក់របស់ខ្លួនមុនពេលបញ្ចេញចូលទៅក្នុងតំបន់ទឹកសាធារណៈតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា២៨៧(ការទទួលខុសត្រូវរបស់ម្ចាស់ប្រភពដាក់លាក់)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៤៦ .- ការបញ្ចេញសំណល់ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាត**

១-បុគ្គលដែលបញ្ចេញសំណល់រឹង រាវ ទឹកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោក ដែនកោះ ទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុន ឬគ្មានការអនុញ្ញាត ដូចមានចែងក្នុងមាត្រា២៩៨(ការហាមឃាត់ការបញ្ចេញសំណល់)នៃក្រមនេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

២- បុគ្គលដែលបញ្ចេញសំណល់រឹង រាវ ទឹកកខ្វក់ សំណល់ប្រេង សំណល់គីមីពីដីគោក ដែនកោះ ទីតាំងបូមប្រេង ឧបករណ៍នេសាទ ចូលទៅក្នុងសមុទ្រ ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុន ឬគ្មានការអនុញ្ញាត ហើយបានបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន ជីវៈចម្រុះ ឬសុខភាពសាធារណៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ



៨៥

ពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ។

**មាត្រា៨៤៧ .– ការមិនទទួលខុសត្រូវរបស់ម្ចាស់ជលយាន**

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី៣នៃមាត្រា២៩៩(ការទទួលខុសត្រូវរបស់ម្ចាស់ជលយាន)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន ២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៤៨ .– ការមិនចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់**

បុគ្គលដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៣១៧(ការចាត់វិធានការនិងជូនដំណឹងពីករណីបង្កបញ្ហាបំពុលខ្យល់)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

## ជំពូកទី៣
## បទល្មើសពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ

**មាត្រា៨៤៩ .– បទល្មើសធនធានធម្មជាតិថ្នាក់ទី១ក្នុងតំបន់ការពារធម្មជាតិ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- ការនាំចេញ ការនាំចូលគ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វ ប្រភេទរុក្ខជាតិរាតត្បាត ឬប្រភេទរុក្ខជាតិចំណូលថ្មីរាតត្បាត និងពូជមច្ឆជាតិគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត។

ខ- ធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដីមមោក។

គ- ប្រើប្រាស់ឧបករណ៍នានា ដែលបង្ករំខានដោយសំឡេង រំញ័រ រលក និងផ្សេងដែលអាចបង្កការខូចខាតដល់ធនធានធម្មជាតិ និងកិច្ចគាំពារបរិស្ថានក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

ឃ- ការរុករករ៉ែដោយគ្មានលិខិតអនុញ្ញាត។

**មាត្រា៨៥០ .– បទល្មើសធនធានធម្មជាតិថ្នាក់ទី២ក្នុងតំបន់ការពារធម្មជាតិ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- បង្កើតឡគ្រប់ប្រភេទឬបង្កើតមូលដ្ឋានកែច្នៃផលនិងអនុផលព្រៃឈើ រុក្ខជាតិព្រៃ និងធនធានធម្មជាតិគ្រប់ប្រភេទក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ខ- បង្កើតមូលដ្ឋានសម្រាប់កែច្នៃខ្លឹមច័ន្ទន៍ក្រស្នា ម្រះព្រៅភ្នំ ឬវល្លិរមៀត ឬសម្រាប់ចម្រាញ់រុក្ខជាតិហាមឃាត់ផ្សេងទៀតក្នុងតំបន់ស្នូល និងតំបន់អភិរក្ស។

គ- កាប់ ផ្តួល រំលំ គ្រៀវ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត។

ឃ- ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្លឹង លប់ បង្កៃ ឬដោយប្រមាញ់ដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី៥ និងទី៦ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

ង- ដឹកជញ្ជូន ប្រមូល ធ្វើសន្និធិ ឬប្រមូលសន្និធិផល និងអនុផលធនធានធម្មជាតិដោយគ្មានការអនុញ្ញាត។

ច- ប្រើប្រាស់អាវុធជាតិផ្ទុះ សារធាតុគីមី ថ្នាំពុល ឬឧបករណ៍ឆក់ ដែលធ្វើឱ្យខូចខាតឬបំពុលដល់ធនធានធម្មជាតិ។

ឆ- ជួញដូរសត្វព្រៃ ឬសំណាកសត្វព្រៃគ្រប់ប្រភេទ ឬចិញ្ចឹមសត្វព្រៃសម្រាប់ការធ្វើពាណិជ្ជកម្មដោយគ្មានការអនុញ្ញាត។

ជ- យាយី ឬបំផ្លាញជម្រកពង កូន កន្លែងបន្តពូជសត្វព្រៃ និងមច្ឆជាតិ។

ឈ- រំកិល ដកចេញ ឬបំផ្លាញគោលសីមា ឬសញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ។

ញ- បំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ដ- ចាក់លុប ឬចាក់បំពេញដី ដែនទឹក ផ្លែរងទឹកភ្លៀង ផ្លូវទឹក បឹងធម្មជាតិ ដីសើម តំបន់ទំនាប ទឹកផុសក្រោមដី ឬអាងទឹក ដោយគ្មានការអនុញ្ញាត។

ឋ- ធ្វើឱ្យរាំងស្ទះដល់លំហូរបរិស្ថាននៃបឹងបួ ទន្លេ ស្ទឹង អូរ ឬព្រែក ដោយគ្មានការអនុញ្ញាត។

ឌ- បោះបង្គោលហ៊ុមព័ទ្ធ ឬដាក់សញ្ញាសម្គាល់លើដីដែលជាទ្រព្យសម្បត្តិរដ្ឋក្នុងតំបន់ការពារធម្មជាតិក្នុងគោលបំណងកាន់កាប់ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

ឍ- នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍មូលដ្ឋាន។

ណ- យកថ្ម គ្រួស ខ្សាច់ ឬរ៉ែ ឬការគាស់ ឈូសឆាយ ឬកកាយយកដី ដោយគ្មានការអនុញ្ញាត។

**មាត្រា៨៥១._ បទល្មើសធនធានធម្មជាតិថ្នាក់ទី៣ក្នុងតំបន់ការពារធម្មជាតិ**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ចំពោះបុគ្គលដែលប្រព្រឹត្តអំពើណាមួយនៅក្នុងតំបន់ការពារធម្មជាតិ ដូចខាងក្រោម៖

ក- នាំចូល ឬនាំចេញនូវប្រភេទសត្វ ឬគ្រាប់រុក្ខជាតិគ្រប់ប្រភេទ ដែលជាសត្វ ឬរុក្ខជាតិដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ និងរុក្ខជាតិព្រៃ ដោយគ្មានការអនុញ្ញាត។

ខ- កាប់ ផ្តួល រំលំ គ្រៀវ ចងរឹត បំពុល ធ្វើឱ្យរបួស ធ្វើឱ្យខូចខាត គាស់រម្លើង រុករាន ឬបំផ្លាញព្រៃឈើ និងរុក្ខជាតិព្រៃ ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទរុក្ខជាតិព្រៃ។

គ- បង្កឱ្យមានភ្លើងឆេះព្រៃ ឬភ្លើងឆេះដីមមោកដោយចេតនា។

ឃ- នេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ដែលធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ ទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ង- ចាប់ដោយដាក់អន្ទាក់ ខ្នារ អង្គប់ បន្លឹង លប់ បង្កៃ ឬដោយប្រមាញ់ដែលធ្វើឱ្យរបួស បំពុល សម្លាប់ ឬ ប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ តាមគ្រប់រូបភាព ដែលស្ថិតក្នុងចំណាត់ថ្នាក់ទី២ ដល់ទី៤ នៃចំណាត់ថ្នាក់ប្រភេទសត្វព្រៃ ដោយគ្មានការអនុញ្ញាត។

ច- កាប់គាស់ ឬរុករានដីព្រៃ ឬឆ្ការ ដុត ឬឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ។

**មាត្រា៨៥២ ._ ការធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនា**

បុគ្គលដែលបង្កការខូចខាត ការបំផ្លិចបំផ្លាញ ឬការស្រង់យកសម្បត្តិវប្បធម៌ក្រោមទឹកដោយចេតនា ដូចមានចែងនៅក្នុងមាត្រា៤២៧(ការហាមឃាត់ចំពោះការធ្វើឱ្យខូចខាត ការស្រង់យក ឬបំផ្លិចបំផ្លាញសម្បត្តិវប្បធម៌ក្រោមទឹក)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៥០០ ០០០ ០០០(ប្រាំរយលាន)រៀល។

## ជំពូកទី៤

## បទល្មើសពាក់ព័ន្ធនឹងការវាយតម្លៃបរិស្ថាន

**មាត្រា៨៥៣ ._ ការប្រកបវិជ្ជាជីវៈរបស់ក្រុមហ៊ុនទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមិនបានចុះបញ្ជី**

បុគ្គលដែលមិនអនុវត្តតាមកថាខណ្ឌទី១នៃមាត្រា៦៥៩(ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថានជានីតិបុគ្គល ឬរូបវន្តបុគ្គល)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល ១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

**មាត្រា៨៥៤ ._ ការបំពានលក្ខខណ្ឌការងារដោយក្លែងបន្លំឬលួចចម្លងទិន្នន័យ**

បុគ្គលដែលប្រគល់ឬផ្តល់របាយការណ៍ ទិន្នន័យ ឬព័ត៌មានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ឬការវាយតម្លៃហានិភ័យក្នុងគោលបំណងបំភ័ន្ត ឬធ្វើឱ្យមានការយល់ខុសដល់ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំ ទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៣០០ ០០០ ០០០(បីរយលាន)រៀល។

**មាត្រា៨៥៥ ._ ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់**

បុគ្គលដែលបានធ្វើសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោងមុនពេលទទួលបានលិខិត ឬវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬកិច្ចសន្យាការពារបរិស្ថាន ដូចមានចែងក្នុងមាត្រា៦៦៨(ការហាមឃាត់ចំពោះសកម្មភាពសាងសង់ ឬប្រតិបត្តិការគម្រោង)នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀល ដល់១០០ ០០០ ០០០(មួយរយលាន)រៀល ក្នុងករណីដែលជនល្មើសធ្លាប់ទទួលរងនូវការពិន័យអន្តរការណ៍ចំនួន២(ពីរ)ដង ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែលក្នុងអំឡុងពេល១(មួយ)ឆ្នាំ គិតចាប់ពីការពិន័យអន្តរការណ៍លើកមុន។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី៥
## ស្ថានទម្ងន់ទោស ទោសបន្ថែមចំពោះរូបវន្តបុគ្គល ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល និងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត

**មាត្រា៨៥៦ ._ ស្ថានទម្ងន់ទោស**

អំពើដូចមានចែងក្នុងមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់) កថាខណ្ឌទី២នៃមាត្រា៨៣៣(ការផលិត នាំចូល ឬចែកចាយសារធាតុគ្រោះថ្នាក់ឬផលិតផលសារធាតុគីមី) កថាខណ្ឌទី២នៃមាត្រា៨៣៥(ការបង្កឱ្យមានការសាយភាយសារធាតុគ្រោះថ្នាក់) មាត្រា៨៣៩(ការនាំចូលសំណល់រឹង) មាត្រា៨៤១(ការបញ្ចេញសំណល់គ្រោះថ្នាក់ដោយគ្មានលិខិតអនុញ្ញាត) មាត្រា៨៤២(ការនាំចូលសំណល់គ្រោះថ្នាក់) មាត្រា៨៤៤(សកម្មភាពបង្កផលប៉ះពាល់ដល់បរិស្ថាន) កថាខណ្ឌទី២នៃមាត្រា៨៤៦(ការបញ្ចេញសំណល់ដោយមិនបានឆ្លងកាត់ការធ្វើប្រព្រឹត្តិកម្មជាមុនឬមិនមានការអនុញ្ញាត)នៃក្រមនេះ ត្រូវផ្តន្ទាទោសដោយមានស្ថានទម្ងន់ទោសក្នុងករណីដូចខាងក្រោម៖

ក- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ជីវៈចម្រុះ សុខភាពមនុស្ស ឬធ្វើឱ្យមានពិការភាពអចិន្ត្រៃយ៍ដល់បុគ្គលដទៃ។

ខ- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យបុគ្គលដទៃស្លាប់ដោយគ្មានចេតនាសម្លាប់។

គ- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥(ដប់ប្រាំ)ឆ្នាំ ទៅ៣០(សាមសិប)ឆ្នាំ ក្នុងករណីដែលអំពើណាមួយដូចមានចែងខាងលើ បណ្តាលឱ្យស្លាប់មនុស្សច្រើននាក់ ឬក្នុងករណីដែលអំពើខាងលើត្រូវបានប្រព្រឹត្តក្នុងគោលបំណងបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់បរិស្ថាន ជីវៈចម្រុះ សុខភាព ឬអាយុជីវិតអ្នកដទៃ ឬត្រូវបានធ្វើឡើងដោយក្រុមឧក្រិដ្ឋជនមានការចាត់តាំង។

**មាត្រា៨៥៧ ._ ការប្រកាសទោសបន្ថែមចំពោះរូបវន្តបុគ្គល**

១- ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដែលមានចែងចាប់ពីមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់) ដល់មាត្រា៨៥៥(ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់)នៃក្រមនេះ តុលាការអាចប្រកាសទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា៥៣(ប្រភេទទោសបន្ថែម)នៃក្រមព្រហ្មទណ្ឌ។

២- ខ្លឹមសារ របៀបបទ និងនីតិវិធីសម្រាប់ការអនុវត្តទោសបន្ថែមទាំងនេះត្រូវអនុលោមតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៥៨ ._ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គលអាចប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២(ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងចាប់ពីមាត្រា៨២៧(ការធ្វើសកម្មភាពឬប្រតិបត្តិការពាក់ព័ន្ធនឹងសរីរាង្គកាយកែច្នៃរស់) ដល់មាត្រា៨៥៥(ការធ្វើសកម្មភាពសាងសង់ឬប្រតិបត្តិការគម្រោងបំពានការហាមឃាត់)នៃក្រមនេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១ ០០០ ០០០ ០០០(មួយពាន់លាន)រៀល ទៅ២ ០០០ ០០០ ០០០(ពីរពាន់លាន)រៀល និងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨(ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

**មាត្រា៨៥៩ .- ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត**

ការអនុវត្តបញ្ញត្តិនៃគន្ថីទី១០នៃក្រមនេះ មិនរារាំងដល់ការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលកំណត់ថាជាបទល្មើសដែលមានចែងក្នុងក្រមនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌផ្សេងទៀត និងដោយពុំទាន់គិតដល់សំណងនៃការខូចខាតដទៃទៀត។

## គន្ថីទី១១

## អន្តរប្បញ្ញត្តិ

**មាត្រា៨៦០ .- វិធានការអន្តរកាលចំពោះគម្រោងដែលបានដាក់ពាក្យសុំនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ**

ចំពោះគម្រោងដែលបានដាក់ពាក្យសុំនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ ត្រូវចាត់ទុកថាបានដាក់ពាក្យសុំនិងត្រូវបន្តនីតិវិធីដែលនៅសេសសល់ទៅតាមបទប្បញ្ញត្តិនៃក្រមនេះ។

**មាត្រា៨៦១ .- វិធានការអន្តរកាលចំពោះគម្រោងដែលបានអនុវត្តមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ**

ចំពោះគម្រោងដែលបានអនុវត្តនៅមុនកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ ត្រូវបន្តមានសុពលភាពបន្ទាប់ពីកាលបរិច្ឆេទនៃការអនុវត្តក្រមនេះ។

**មាត្រា៨៦២ .- វិធានការអន្តរកាលចំពោះបទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថាន**

បទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថាន ដែលមានជាធរមានកន្លងមកនៅតែបន្តមានអានុភាពអនុវត្តរហូតដល់មានបទប្បញ្ញត្តិដែលទាក់ទងនឹងស្តង់ដារបរិស្ថានថ្មី លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងក្រមនេះ។

## គន្ថីទី១២

## អវសានប្បញ្ញត្តិ

**មាត្រា៨៦៣ .- អានុភាពនៃបទប្បញ្ញត្តិច្បាប់**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយក្រោមច្បាប់ក្នុងវិស័យបរិស្ថាននិងធនធានធម្មជាតិ ត្រូវមានអានុភាពអនុវត្តរហូតមានបទដ្ឋានថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងក្រមនេះ។

**មាត្រា៨៦៤ .- និរាករណ៍**

១- ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលក្រមនេះត្រូវបានអនុវត្ត ចំពោះច្បាប់និងបទប្បញ្ញត្តិពីមុនពាក់ព័ន្ធនឹងវិស័យបរិស្ថាន និងធនធានធម្មជាតិ ដែលបានកំណត់ដូចខាងក្រោម៖

- ក- ច្បាប់ស្តីពីកិច្ចគាំពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦.៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។
- ខ- ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។
- គ- ច្បាប់ស្តីពីជីវសុវត្ថិភាព ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨។

២- បទប្បញ្ញត្តិនៃច្បាប់ផ្សេងទៀតដែលមានអានុភាពនៅពេលក្រមនេះ ត្រូវបានអនុវត្តហើយផ្ទុយនឹងបទប្បញ្ញត្តិនៃក្រមនេះ ត្រូវចាត់ទុកថាគ្មានអានុភាពត្រឹមទំហំដែលផ្ទុយនឹងក្រមនេះ ចាប់ពីថ្ងៃដែលក្រមនេះត្រូវបាន

៣- ប៉ុន្តែ បទប្បញ្ញត្តិដែលកំណត់អំពីបទល្មើសបរិស្ថាននិងធនធានធម្មជាតិក្នុងកថាខណ្ឌទី១និងទី២ ខាងលើនេះ ត្រូវបន្តមានអានុភាពអនុវត្តក្រោយការអនុវត្តនៃក្រមនេះ ចំពោះបទល្មើសដែលត្រូវបានប្រព្រឹត្តមុនពេលក្រមនេះត្រូវបានអនុវត្ត។

៤- រាល់បទប្បញ្ញត្តិនៃក្រមនេះត្រូវយកមកអនុវត្ត កាលណាពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។

**មាត្រា៨៦៥ ._** ការអនុវត្តក្រម

ក្រមនេះត្រូវយកទៅអនុវត្តក្នុងរយៈពេល១(មួយ)ឆ្នាំ ក្រោយការចូលជាធរមាននៃក្រមនេះ។

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០២៣

នស.រកម.០៦២៣.០០៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ឧបសម្ព័ន្ធនៃក្រមបរិស្ថាននិងធនធានធម្មជាតិ
## សទ្ទានុក្រម

# ក

**ការកសាងសមត្ថភាព (Capacity Building)**

សំដៅដល់ការអនុវត្តក្នុងការពង្រឹងភាពខ្លាំង លក្ខណៈសម្បត្តិ និងធនធានដែលមានចំពោះបុគ្គលម្នាក់ៗ សហគមន៍ ស្ថាប័ន ឬសង្គមដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល។

**ការការពារសុវត្ថិភាពនុយក្លេអ៊ែរ (Nuclear Safeguard)**

សំដៅដល់ប្រព័ន្ធនៃការធ្វើអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ថាសារធាតុនុយក្លេអ៊ែររួមទាំងបច្ចេកវិទ្យា សកម្មភាព ឧបករណ៍ សម្ភារៈ និងបរិក្ខារពាក់ព័ន្ធត្រូវបានប្រើប្រាស់ក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ។

**ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gas Mitigation)**

សំដៅដល់អន្តរាគមន៍របស់មនុស្ស ដើម្បីឱ្យប្រភពបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថយចុះ ឬដើម្បីបង្កើនអាងស្រូបឧស្ម័នផ្ទះកញ្ចក់។

**ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (Disaster Risk Reduction)**

សំដៅដល់ការចង្អុលបង្ហាញនូវគោលដៅនិងគោលបំណងផ្នែកគោលនយោបាយ វិធានការជាយុទ្ធសាស្ត្រ និងឧបករណ៍នានា ដែលបានប្រើប្រាស់ដើម្បីប៉ាន់ប្រមាណហានិភ័យគ្រោះមហន្តរាយនាពេលអនាគតដោយការកាត់បន្ថយការប្រឈមមុខសញ្ញាគ្រោះថ្នាក់ ឬភាពងាយរងគ្រោះ ដែលកំពុងកើតមាននិងដោយការបង្កើនភាពធន់ទៅនឹងហានិភ័យទាំងនោះ។

**ការកៀរគរធនធាន (Resources Mobilization)**

សំដៅដល់ការប្រមូលធនធានហិរញ្ញវត្ថុនិងមិនមែនហិរញ្ញវត្ថុ ដើម្បីសម្រេចគោលដៅនិងគោលបំណងរបស់ស្ថាប័ន/អង្គភាព។ ធនធានហិរញ្ញវត្ថុរួមមានប្រាក់ ចំណែកធនធានមិនមែនហិរញ្ញវត្ថុរួមមាន សម្ភារៈរូបវន្ត ធនធានមនុស្ស និងពេលវេលាដែលផ្តល់ជូន។

**ការកែច្នៃសារពាង្គកាយរស់/ការកែច្នៃហ្សែន( Genetic Modification)**

សំដៅដល់បច្ចេកទេសក្នុងការផ្លាស់ប្តូរលក្ខណៈធម្មជាតិរបស់សត្វ រុក្ខជាតិ ឬមីក្រូសរីរាង្គកាយដោយបញ្ចូលចំណែកណាមួយនៃសម្ភារពន្ធុ ( ឌី អិន អេ) ពីសារពាង្គកាយមួយទៅសារពាង្គកាយមួយទៀត។

**ការកែច្នៃឡើងវិញ/សារវត្តកម្ម (Recycling)**

សំដៅដល់សកម្មភាព ដំណើរការបំបែក ឬការបំប្លែងសំរាម សំណល់រឹងទៅជាវត្ថុធាតុដើមសម្រាប់បម្រើការផលិតឡើងវិញ។

**ការខូចខាតបរិស្ថាន (Environmental Degradation)**

សំដៅដល់ផលប៉ះពាល់អវិជ្ជមានលើបរិស្ថានរួមមាន ការធ្វើឱ្យអន់ថយ ការបំផ្លិចបំផ្លាញ ការបាត់បង់ ឬការបាត់បង់នៃការប្រើប្រាស់សមាសភាគរបស់បរិស្ថានដូចជាធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ជាដើម និងផលប៉ះពាល់អវិជ្ជមានលើសុខភាព និងសុខុមាលភាពរបស់មនុស្ស ដូចជាការបាត់បង់ប្រាក់ឈ្នួល ប្រាក់ចំណូល ប្រាក់ចំណេញពន្ធ ប្រាក់កម្រៃ ចំណូលសួយសារនានារបស់ជាតិជាដើម។

**ការខូចខាតបរិស្ថានធ្ងន់ធ្ងរ (Severe Environmental Degradation)**

សំដៅដល់វិសាលភាពនៃការធ្វើឱ្យអន់ថយ ការបំផ្លិចបំផ្លាញ ការបាត់បង់ ឬ ការថយចុះនូវគុណភាព ឬមុខងារបរិស្ថាន ដូចជា ទឹក ដី ខ្យល់ ធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងបេតិកភណ្ឌវប្បធម៌ ក៏ដូចជា ផលប៉ះពាល់



ROYAUME DU CAMBODGE CABINET DU MINISTRE DU PALAIS ROYAL

អវិជ្ជមានលើសុខភាពមនុស្ស សេដ្ឋកិច្ចនិងសង្គម ដូចជាការបាត់បង់ប្រាក់ឈ្នួល ប្រាក់ចំណូល ប្រាក់ចំណេញពន្ធ ប្រាក់កម្រៃ ចំណូលសួយសារនានារបស់ជាតិជាដើម។

**ការគ្រប់គ្រងហិរញ្ញវត្ថុ (Financial Management)**

សំដៅដល់ការរៀបចំផែនការថវិកា ការត្រួតពិនិត្យនិងតម្រង់ទិសសកម្មភាពហិរញ្ញវត្ថុ ដូចជាការត្រួតពិនិត្យប្រព័ន្ធគណនេយ្យ លទ្ធកម្ម ប្រាក់កម្ចី ជាដើម និងការចាត់ចែងនិងសម្រេចលើការប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ស្ថាប័ន/អង្គភាព។

**ការគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តរភាព (Sustainably Forest Resources Management/Sustainable Forest Management)**

សំដៅដល់ការគ្រប់គ្រងធនធានព្រៃឈើស្របតាមគោលបំណង គោលការណ៍ណែនាំ និងបទដ្ឋានបច្ចេកទេស ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន រួមទាំងការអភិរក្សជីវៈចម្រុះ។

**ការគ្រប់គ្រងព្រៃឈើ (Forest Management)**

សំដៅដល់ប្រព័ន្ធមួយនៃការប្រតិបត្តិសម្រាប់ការកាន់កាប់ និងប្រើប្រាស់ដីព្រៃឈើក្នុងបំណងបំពេញមុខងារអេកូឡូស៊ី (រួមទាំងនានាភាពជីវសាស្ត្រ) សេដ្ឋកិច្ច និងសង្គមរបស់ព្រៃឈើប្រកបដោយចីរភាព។

**ការគ្រប់គ្រងធនធានជីវៈចម្រុះ (Biodiversity Resources Management)**

សំដៅដល់សកម្មភាពថែរក្សា និងការពារនានាភាពនៃសពាង្គកាយរស់នៅលើដី ក្នុងទឹក និងក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងៗទៀត ដែលមាននានាភាពសេនេទិក នានាភាពប្រភេទ និងនានាភាពប្រព័ន្ធអេកូឡូស៊ី។

**ការគណនាបរិមាណបញ្ចេញឧស្ម័នផ្ទះកញ្ចក់/កូតានៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Emission quota)**

សំដៅដល់បរិមាណឬចំណែកនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សរុបដែលកំណត់ឱ្យប្រទេស ឬបណ្តាក្រុមប្រទេសអាចបញ្ចេញឧស្ម័ននៅក្រោមក្របខ័ណ្ឌនៃការបញ្ចេញឧស្ម័នសរុបជាអតិបរមា និងទៅតាមការវិភាជធនធានកាតព្វកិច្ច។

**ការអប់រំបរិស្ថាន (Environmental Education)**

សំដៅដល់ការអនុវត្តវិធីសាស្ត្រ ដើម្បីអប់រំប្រជាជនឱ្យយល់ដឹងពីទំនាក់ទំនងផ្នែកសីលធម៌របស់ពួកគេជាមួយនឹងបរិស្ថាន លើកកម្ពស់នូវចំណេះដឹង ជំនាញ អាកប្បកិរិយា និងតម្លៃរបស់ប្រជាជនក្នុងកិច្ចគាំពារបរិស្ថាន ព្រមទាំងដើម្បីលើកទឹកចិត្តពួកគេឱ្យចូលរួមក្នុងវិស័យនេះ។

**ការអប់រំបរិស្ថានក្នុងប្រព័ន្ធ (Formal Environmental Education)**

សំដៅដល់ការអប់រំបរិស្ថាន ដែលមានរចនាសម្ព័ន្ធតាមឋានានុក្រមនៃប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ដោយរួមទាំងការសិក្សាជំនាញឯកទេសទូទៅ កម្មវិធីជំនាញវិជ្ជាជីវៈ និងវិទ្យាស្ថានឯកទេសផ្សេងៗដែលមានការបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងជំនាញវិជ្ជាជីវៈពេញម៉ោង។

**ការអប់រំបរិស្ថានក្រៅប្រព័ន្ធ (Informal Environmental Education)**

សំដៅដល់សកម្មភាពអប់រំបរិស្ថានទាំងឡាយ ដែលរៀបចំឡើងផ្សេងពីការអប់រំក្នុងប្រព័ន្ធ ទាំងមាននិងគ្មានកម្រិតក្នុងលក្ខណៈជំទូលាយបែបណាក៏ដោយ ដើម្បីជូនក្រុមគោលដៅនានាដែលមកសិក្សាក្នុងកម្មវិធីអប់រំបរិស្ថាន។

**ការិយបរិច្ឆេទជលសាស្ត្រ (Hydrological Period)**

សំដៅដល់ការកំណត់រយៈពេលនៃប្រតិបត្តិការខាងហិរញ្ញវត្ថុ ដែលមានក្នុងផែនការស្តីពីធនធានទឹកអាងទន្លេ ឬផែនការស្តីពីសិទ្ធិប្រើប្រាស់ទឹក និងលិខិតបទដ្ឋានគតិយុត្ត។

**ការចិញ្ចឹមសត្វព្រៃ (Wildlife Farm/ Wildlife Raising/ Wildlife Breeding)**

សំដៅដល់ការរក្សាទុកសត្វព្រៃក្នុងទីបង្ខាំង ដោយការថែទាំ និងផ្តល់ចំណី ក្នុងគោលបំណងផ្សេងៗ ដូចជាការបង្កាត់ពូជ ការលក់ដូរ ជាដើម។

**ការប្រើប្រាស់ជាលក្ខណៈប្រពៃណី (Customary Uses)**

សំដៅដល់ការអនុវត្ត ឬរបៀបអនុវត្តលើការប្រើប្រាស់ធនធានធម្មជាតិសម្រាប់ចិញ្ចឹមគ្រួសារ ឬផលប្រយោជន៍សហគមន៍តាមទំនៀមទម្លាប់ ឬប្រពៃណី។

**ការប្រើប្រាស់ប្រកបដោយនិរន្តរភាព (Sustainable Consumption/ Sustainable Uses)**

សំដៅដល់ការប្រើប្រាស់ធនធានធម្មជាតិ ដោយការថែរក្សាបាននូវបរិមាណ ប្រភេទ និង/ឬពូជនៃធនធានធម្មជាតិឬធនធានជីវៈចម្រុះ ដើម្បីបម្រើប្រយោជន៍ដល់អ្នកជំនាន់ក្រោយ។

**ការប្រើប្រាស់ក្នុងព្រំដែនកំណត់(សពាង្គកាយកែច្នៃរស់) (Contained Uses)**

សំដៅដល់ប្រតិបត្តិការ ឬសកម្មភាពណាមួយដែលទាក់ទងនឹងសពាង្គកាយកែច្នៃរស់ដែលធ្វើឡើងនៅក្នុងទីកន្លែង ឬមធ្យោបាយ ឬឧបករណ៍ណាមួយ ហើយស្ថិតនៅក្រោមវិធានការដាក់លាក់ដែលទប់ស្កាត់មិនឱ្យសពាង្គកាយកែច្នៃរស់ទាំងនោះប៉ះពាល់ដល់បរិស្ថានខាងក្រៅ។

**ការដាំព្រៃឈើ (Afforestation)**

សំដៅដល់ការដាំដើមឈើដើម្បីបង្កើតព្រៃឈើនៅលើផ្ទៃដី ដែលមានប្រវត្តិគ្មានដើមឈើពីមុន(រយៈពេលយ៉ាងហោចណាស់៥០ឆ្នាំ)។

**ការបរបាញ់សត្វព្រៃ (Wildlife Hunting/Wildlife Poaching)**

សំដៅដល់សកម្មភាពទាំងឡាយណាដែលតាមរក តាមចាប់ យាយី បំផ្លិចបំផ្លាញឬសម្លាប់សត្វព្រៃ ដោយការប្រើប្រាស់មធ្យោបាយគ្រប់ប្រភេទ។

**ការអភិរក្សសត្វព្រៃ (Wildlife Conservation)**

សំដៅដល់ការរៀបចំផែនការ ចាត់ចែង តម្រង់ទិស ត្រួតពិនិត្យ តាមដាន និងស្រាវជ្រាវសត្វព្រៃ ក្នុងតំបន់និងក្រៅតំបន់ក្នុងគោលបំណងទប់ស្កាត់ការផុតពូជ ដោយស្តារចំនួនសត្វ ប្រភេទសត្វ និងការបង្កាត់ពូជសត្វព្រៃ។

**ការប្រើប្រាស់ជាលក្ខណៈគ្រួសារ (Family Uses)**

សំដៅដល់ការបរបាញ់ ការនេសាទ ការប្រមូលរុក្ខជាតិព្រៃ និងអនុផលព្រៃឈើផ្សេងទៀត និងការដោះដូរទំនិញជាលក្ខណៈប្រពៃណី សម្រាប់គោលបំណងផ្តល់ស្បៀងអាហារដល់បុគ្គលម្នាក់ ឬគ្រួសាររបស់គេ នៅក្នុងកម្រិតអប្បបរមាដែលចាំបាច់សម្រាប់តែការរស់រានមានជីវិត និងមិនរាប់បញ្ចូលការលក់ ឬការធ្វើពាណិជ្ជកម្មនៃសំណាកប្រភេទសត្វឬរុក្ខជាតិនានា ដែលបរបាញ់ នេសាទ ឬប្រមូលបានឡើយ។

**ការស្តារប្រព័ន្ធអេកូឡូស៊ី (Ecosystem Restoration)**

សំដៅដល់ការធ្វើឱ្យប្រសើរឡើងវិញនូវបណ្តុំមុខងារនៃប្រព័ន្ធមួយដែលរួមផ្សំឡើងដោយភាវៈមានជីវិត និងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងអន្តរកម្មទៅវិញទៅមក(អន្តរកម្មរវាងភាវៈមានជីវិត និងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ)។

**ការខូចខាតប្រព័ន្ធអេកូឡូស៊ី (Ecosystem Degradation)**

សំដៅដល់ផលប៉ះពាល់អវិជ្ជមានទៅលើបណ្តុំមុខងារនៃប្រព័ន្ធមួយដែលរួមផ្សំឡើងដោយភាវៈមានជីវិត និងបរិស្ថានគ្មានជីវិតដែលនៅជុំវិញភាវៈមានជីវិតទាំងនោះ ព្រមទាំងអន្តរកម្មទៅវិញទៅមក(អន្តរកម្មរវាងភាវៈមានជីវិត និងបរិស្ថានគ្មានជីវិត និងអន្តរកម្មរវាងភាវៈមានជីវិតទាំងនោះ)។

**ការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព (Sustainable Production and Consumption)**

សំដៅដល់ការប្រើប្រាស់សេវានិងផលិតផលពាក់ព័ន្ធនានា ដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការជាមូលដ្ឋាន និងនាំមកនូវគុណភាពជីវិតដ៏ប្រសើរ ដោយធ្វើការកាត់បន្ថយនូវការប្រើប្រាស់ធនធានធម្មជាតិនិងសារធាតុពុល ព្រមទាំងការបញ្ចេញសំណល់ និងសារធាតុបំពុលនានាឱ្យនៅកម្រិតអប្បបរមា នៅក្នុងវដ្តជីវិតនៃសេវាឬផលិតផល ដើម្បីកុំឱ្យបង្កហានិភ័យដល់តម្រូវការរបស់មនុស្សជំនាន់ក្រោយ។

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (Strategic Environmental Assessment)

សំដៅដល់អភិក្រមដែលមានការវិភាគនិងការចូលរួម ក្នុងគោលបំណងរួមបញ្ចូលការពិនិត្យពិច័យផ្នែកសេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធីផ្សេងៗ។

ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ (Hazardous Waste Management)

សំដៅដល់សកម្មភាពទាំងឡាយណាដែលធ្វើដើម្បីការពារ កាត់បន្ថយ ញែក ប្រមូល ដឹកជញ្ជូន ស្តុកទុក ធ្វើប្រព្រឹត្តិកម្ម កែច្នៃ ទាញយកមកប្រើឡើងវិញ និងបោះចោលសំណល់គ្រោះថ្នាក់។

ការចូលរួមជាសាធារណៈ (Public Participation)

សំដៅដល់ការផ្សព្វផ្សាយ ការពិគ្រោះយោបល់ កិច្ចសហការ ការចូលរួម និងការសម្រេចចិត្តនៅក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីធ្វើការផ្លាស់ប្តូរគំនិត មតិយោបល់ ការទទួលយកព័ត៌មានពីគ្រប់ភាគីដែលនឹងទទួលរងហេតុប៉ះពាល់ដោយផ្ទាល់និងដោយប្រយោល និងរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានពីគម្រោងអភិវឌ្ឍនៅក្នុងដំណាក់កាលមុនប្រតិបត្តិគម្រោង (ការរចនាគម្រោងនិងការសាងសង់) ដំណាក់កាលប្រតិបត្តិគម្រោង និងដំណាក់កាលបញ្ចប់គម្រោង។

ការញែកសំណល់ (Waste Sorting)

សំដៅដល់សកម្មភាពបែងចែកសំណល់ទៅតាមប្រភេទនៅនឹងប្រភពបង្កើតសំណល់ ទីកន្លែងចោលសំណល់ ឬនៅតាមទីតាំងកែច្នៃ ឬទាញយកធនធានពីសំណល់។

ការប្រើប្រាស់មានលក្ខណៈ/ផ្នែកពាណិជ្ជកម្ម (Commercial Uses)

សំដៅដល់ការប្រើប្រាស់ធនធានជីវៈចម្រុះ ឬធនធានធម្មជាតិក្នុងគោលបំណងទទួលបានប្រាក់ចំណេញ ផលប្រយោជន៍សេដ្ឋកិច្ច ឬការជួញដូរបែបពាណិជ្ជកម្ម។

ការដុតសំណល់នៅតាមទីវាល (Open burning)

សំដៅដល់ការដុតសំណល់ កម្ទេចកម្ទី ឬវត្ថុផ្សេងៗ នៅតាមទីវាល ទីសាធារណៈ ឬក្នុងបរិវេណដីកម្មសិទ្ធិ រួមទាំងការដុតនៅក្នុងឡដែលមិនមានបំពាក់ឧបករណ៍បញ្ចេញផ្សែងឬកាត់បន្ថយសារធាតុបំពុលខ្យល់។

ការទាញយកធនធានពីសំណល់ (Extracting Fesources from Waste)

សំដៅដល់សកម្មភាពជ្រើសរើសឬប្រើប្រាស់សំណល់ឱ្យក្លាយទៅជារបស់ វត្ថុធាតុ ឬផលិតផលដែលមានតម្លៃសម្រាប់ការប្រើប្រាស់ឡើងវិញឬការផលិតជាថ្មី ក្នុងគោលបំណងកាត់បន្ថយបរិមាណសំណល់ដែលបង្កើតឡើង ឬដែលត្រូវបោះចោល ឬបញ្ចេញចោលទៅក្នុងបរិស្ថាន។

ការបញ្ចេញសំណល់ (Waste Disposal /Waste Discharge)

សំដៅដល់សកម្មភាពឬដំណើរការបង្ហូរចេញ បំភាយចេញ ឬដឹកចេញនូវសំណល់ពីប្រភព ឬទីតាំងបង្កើតសំណល់ចូលទៅក្នុងបរិស្ថាន ឬទៅកាន់ទីតាំងដទៃក្នុងគោលបំណងណាមួយ។

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (Green House Gas Emission)

សំដៅដល់ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និង/ឬបុរេករ និងអេរ៉ូស៊ូលទៅក្នុងបរិយាកាសនៅក្នុងតំបន់ណាមួយ និងក្នុងកំលុងពេលកំណត់មួយ។

ការប្រែប្រួលអាកាសធាតុ (Climate Change)

សំដៅដល់ការប្រែប្រួលស្ថានភាពអាកាសធាតុ ដែលអាចកំណត់អត្តសញ្ញាណបាន (តាមរយៈការវិភាគស្ថិតិ) តាមរយៈការប្រែប្រួលតួលេខមធ្យមនិងតួលេខថេរនៃអាកាសធាតុ ហើយការប្រែប្រួលនោះបន្តកើតឡើងក្នុងរយៈពេលវែងជាច្រើនទសវត្សរ៍ឬយូរជាងនេះ។

**ការផ្ទេរបច្ចេកវិទ្យា** (Technology Transfer)

សំដៅដល់ការផ្លាស់ប្តូរចំណេះដឹងផ្នែករឹង និងទន់ រូបិយវត្ថុ និងទំនិញក្នុងចំណោមភាគីពាក់ព័ន្ធ ដែលនាំឱ្យមានការរីកសាយបច្ចេកវិទ្យាសម្រាប់បន្សាំឬការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និង/ឬការផ្សព្វផ្សាយបច្ចេកវិទ្យា និងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យាទាំងក្នុងនិងក្រៅប្រទេស។

**ការផ្ទៀងផ្ទាត់** (Verification)

សំដៅដល់ការវាយតម្លៃជាទៀងទាត់ដោយស្ថាប័នឯករាជ្យនៅមុន និងបន្ទាប់ពីការកំណត់របស់អង្គភាពទទួលបន្ទុកប្រតិបត្តិលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្ស ដែលបានតាមដានសម្រាប់ប្រភពឧស្ម័នផ្ទះកញ្ចក់ដែលកើតឡើងជាលទ្ធផលនៃសកម្មភាព គម្រោងយន្តការអភិវឌ្ឍស្អាត ដែលបានចុះបញ្ជីឬសកម្មភាពតាមកម្មវិធី(ក្រៅពីគម្រោងព្រៃឈើ)។

**ការស្តារព្រៃឡើងវិញ** (Reforestation)

សំដៅដល់ការដាំដើមឈើនៅលើដីដែលពីមុនធ្លាប់មានព្រៃ ប៉ុន្តែត្រូវបានប្រែក្លាយសម្រាប់គោលបំណងផ្សេងទៀត។

**ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់** (Measurement, Reporting and Verification)

សំដៅដល់វិធានបច្ចេកទេសមួយដើម្បីបញ្ជាក់ពីការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសត្យានុម័ត ហើយអាចប្រើប្រាស់ដើម្បីកំណត់ហិរញ្ញវត្ថុអាកាសធាតុ។

**ការបង់ថ្លៃបំពុលបរិស្ថាន** (Payment for Environmental Pollution)

សំដៅដល់វិធានការហិរញ្ញវត្ថុសម្រាប់ជួយកាត់បន្ថយការបំពុលបរិស្ថាន តាមរយៈការតម្រូវឱ្យបង់ថ្លៃចូលថវិការដ្ឋទៅលើការបញ្ចេញបន្ទុកសារធាតុបំពុលពីទីតាំងផលិតកម្ម អាជីវកម្ម ឬសេវាកម្ម ចូលទៅក្នុងបរិស្ថាន។

**ការបំពុលបរិស្ថាន** (Environmental Pollution)

សំដៅដល់ការធ្លាក់ចូលនូវសារធាតុបំពុលពីសកម្មភាពរបស់មនុស្សឬធម្មជាតិ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់ជីវៈចម្រុះ សុខភាពមនុស្ស សត្វ ឬប៉ះពាល់ដល់ដំណើរការផលិតកម្ម អាជីវកម្ម សេវាកម្ម និងការប្រើប្រាស់ ដែលប្រែប្រួលនូវលក្ខណៈរូប គីមី ឬជីវសាស្ត្ររបស់បរិស្ថានខុសពីលក្ខណៈដើមនៃធម្មជាតិ។

**ការបំពុលបរិស្ថានធ្ងន់ធ្ងរ** (Severity of Environmental Pollution)

សំដៅដល់ការបំពុលបរិស្ថានដែលបង្កឱ្យមានហានិភ័យកម្រិតខ្លាំងទៅដល់សុខភាពឬអាយុជីវិតមនុស្ស សត្វ ឋានប្រព័ន្ធ(ឬប្រព័ន្ធអេកូឡូស៊ី) ជីវៈចម្រុះ ឬផលប្រយោជន៍សាធារណៈ មានជាអាទិ៍ ការបង្កឱ្យមានជំងឺធ្ងន់ធ្ងរ ជំងឺរ៉ាំរ៉ៃ ឬរហូតដល់បង្កឲ្យស្លាប់ ការបង្កឱ្យខូចខាតធនធានបរិស្ថាន ដោយធ្វើឱ្យទឹក ដី ខ្យល់ មានផ្ទុកជាតិពុលកម្រិតខ្ពស់ ដែលធ្វើឲ្យបាត់បង់ជីវៈចម្រុះ បាត់បង់ការប្រើប្រាស់ធនធានទឹក ដី ឬផលដំណាំនានាជាដើម។

**ការបំពុលសមុទ្រ** (Marine Pollution)

សំដៅដល់ការធ្លាក់ចូល ឬការបង្ហូរចូលទៅក្នុងសមុទ្រនូវសំណល់ សារធាតុបំពុល ផលិតផលប្រេង សារធាតុគីមី ។ល។ ដែលអាចបង្កឱ្យប៉ះពាល់ដល់គុណភាពទឹកសមុទ្រ ឬគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ និងសត្វ។

**ការអភិវឌ្ឍប្រកបដោយចីរភាព** (Sustainable Development)

សំដៅដល់ការអភិវឌ្ឍដែលបំពេញសេចក្តីត្រូវការបច្ចុប្បន្ន ដោយមិនប៉ះពាល់ដល់លទ្ធភាពរបស់មនុស្សជំនាន់ក្រោយក្នុងការបំពេញសេចក្តីត្រូវការរបស់ពួកគេផ្ទាល់។

**ការអភិវឌ្ឍបៃតង** (Green Growth)

សំដៅដល់ការអភិវឌ្ឍដែលប្រើប្រាស់ធនធានប្រកបដោយចីរភាព រួមមាន ការងារបរិស្ថានបៃតងនិងធនធានធម្មជាតិ ទឹកនិងអនាម័យ សេដ្ឋកិច្ចនិងវិនិយោគ ទូរគមនាគមន៍និងដឹកជញ្ជូន ឧស្សាហកម្មនិងថាមពល ទេសចរណ៍បៃតង សន្តិសុខស្បៀងនិងសុវត្ថិភាពចំណីអាហារ និងការប្រើប្រាស់ដីធ្លី។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



៦៥

**ការអភិរក្សក្រៅដែនជម្រកធម្មជាតិ (Ex-situ Conservation)**

សំដៅដល់ការថែរក្សាការពារជីវៈចម្រុះដែលស្ថិតនៅក្រៅជម្រកធម្មជាតិ ដូចជា ការបង្កើតជាសួនសត្វ ថ្នាលបណ្តុះកូនឈើជាដើម។

**ការអភិរក្សជីវៈចម្រុះ (Biodiversity Conservation)**

សំដៅដល់ការថែរក្សាការពារបាននូវនានាភាពនៃសពាង្គកាយរស់នៅលើដី ក្នុងទឹក និងក្នុងប្រព័ន្ធអេកូឡូស៊ីផ្សេងៗទៀត ដែលរួមមាន នានាភាពសេនេទិច នានាភាពប្រភេទ និងនានាភាពប្រព័ន្ធអេកូឡូស៊ី។

**ការអភិរក្សធនធានពន្ធុ (Genetic Resources Conservation)**

សំដៅដល់ការថែរក្សាការពារពិពិធភាពពន្ធុដែលអាចបន្តពូជនៃប្រភេទរុក្ខជាតិ សត្វ មីក្រុប... រួមនឹងគុណតម្លៃរបស់វាដែលយើងបានដឹងឬមានសក្តានុពល ដើម្បីធានាឱ្យមានភាពសម្បូរបែបនៅពេលបច្ចុប្បន្ននិងអនាគត។

**ការធ្វើចំណាត់ថ្នាក់គម្រោង (Project Screening)**

សំដៅដល់ការកំណត់សញ្ញាណនៃហេតុប៉ះពាល់ ឬទំហំនៃគម្រោងស្នើសុំ ដែលតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមពេញលេញ ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមដំបូង ឬត្រូវធ្វើកិច្ចសន្យាការពារបរិស្ថាន។

**ការនេសាទ (Fishing)**

សំដៅដល់ការប៉ុនប៉ង ការស្រាវជ្រាវ ការធ្វើសកម្មភាព ដោយប្រើមធ្យោបាយនានា ដើម្បីទាក់ទាញ ចាប់ដាក់អន្ទាក់ ធ្វើឱ្យរបួស ធ្វើឱ្យងីងើ សម្លាប់ និងប្រមូលយកវារីសត្វពីក្នុងដែននេសាទ។

**ការវាយតម្លៃហានិភ័យ (Risk Assessment)**

សំដៅដល់ការសិក្សានិងការវិភាគគម្រោងអភិវឌ្ឍន៍ ឬគម្រោងវិនិយោគ ដើម្បីកំណត់អត្តសញ្ញាណគ្រោះថ្នាក់ និងកត្តាហានិភ័យពីសកម្មភាពគម្រោងទៅលើបរិស្ថាន សុវត្ថិភាពសាធារណៈ និងសុខភាពមនុស្ស រួមទាំងគ្រោះធម្មជាតិ ឬប្រធានសក្តិទៅលើគម្រោងអភិវឌ្ឍ ឬគម្រោងវិនិយោគ មុននឹងឈានដល់ការកំណត់មធ្យោបាយសមស្របក្នុងការគ្រប់គ្រង ការកាត់បន្ថយ ការការពារ និងការលុបបំបាត់គ្រោះថ្នាក់ ឬហានិភ័យដែលអាចកើតឡើងដោយចៃដន្យ។

**ការសាយភាយសារធាតុបំពុល (Pollutant Release)**

សំដៅដល់ការបញ្ចេញ ការបន្សាយ ឬការធ្លាក់ចូលសារធាតុបំពុលទៅក្នុងទឹក ដី ខ្យល់ តាមរយៈសកម្មភាពដោយផ្ទាល់ឬប្រយោលរបស់មនុស្ស ចេតនាឬអចេតនា ជាប្រចាំឬម្តងម្កាល។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (Initial Environmental Impact Assessment )**

សំដៅដល់ការសិក្សាដំបូងលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធានសេដ្ឋកិច្ចសង្គម និងសម្បត្តិវប្បធម៌ ហើយភាគច្រើនពឹងផ្អែកលើទិន្នន័យមានស្រាប់ដែលនៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងការវិភាគនូវសក្តានុពលហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារសកម្មភាពគម្រោង ដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កម្រិតអតិបរមា។

**ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (Full Environmental Impact Assessement)**

សំដៅដល់ការសិក្សាលម្អិតលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ ធនធាន សេដ្ឋកិច្ចសង្គម និងសម្បត្តិវប្បធម៌ ហើយភាគច្រើនពឹងផ្អែកលើទិន្នន័យចម្បងដែលនៅក្នុងនិងជុំវិញតំបន់គម្រោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករណ៍ និងការវិភាគនូវសក្តានុពលហេតុប៉ះពាល់បរិស្ថាននិងសង្គមធ្ងន់ធ្ងរ ដែលអាចកើតមានឡើងដោយសារសកម្មភាពគម្រោង ដើម្បីរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កម្រិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កម្រិតអតិបរមា។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**កិច្ចគាំពារបរិស្ថាន** (Environmental Protection)

សំដៅដល់បច្ចេកទេសនិងវិធានការនានា ដើម្បីថែរក្សាបរិស្ថានធម្មជាតិនិងកាត់បន្ថយឥទ្ធិពលអវិជ្ជមានដែលបណ្តាលមកពីសកម្មភាពរបស់មនុស្ស។

**កីឡាប្រមាញ់** (Game Hunting)

សំដៅលើការបរបាញ់សត្វព្រៃសម្រាប់ការកំសាន្ត នៅក្នុងតំបន់ការពារធម្មជាតិដែលមានគោលការណ៍កំណត់ និងការអនុញ្ញាតពីក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

**ក្រសួងស្ថាប័នមានសមត្ថកិច្ច** (Competent Institution or Ministry)

សំដៅដល់ក្រសួង ស្ថាប័នដែលទទួលបន្ទុកលើការគ្រប់គ្រង ដឹកនាំ ចាត់ចែងលើវិស័យណាមួយស្របច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

**ក្រសួងស្ថាប័នទទួលបន្ទុកគ្រប់គ្រងលើការផលិត ការបញ្ជូន ការចែកចាយអគ្គិសនី និងគ្រប់គ្រងលើការប្រើប្រាស់ថាមពលអគ្គិសនី** (Ministries and Intitution responsible for electricity production, distribution, and management of use of electricity services)

សំដៅដល់ស្ថាប័នដែលទទួលខុសត្រូវក្នុងការធានាការផ្តល់សេវាអគ្គិសនីមានដូចជា អាជ្ញាធរអគ្គិសនីកម្ពុជា ជាអាទិ៍។

**កម្រៃសេវាប្រើប្រាស់ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** (Payment for waste water treatment service)

សំដៅដល់ថ្លៃសេវាដែលត្រូវបង់សម្រាប់សម្អាតទឹកកខ្វក់។

**កម្រៃសេវាប្រើប្រាស់ប្រព័ន្ធលូ** (Payment for waste water discharge service)

សំដៅដល់ថ្លៃសេវាដែលត្រូវបង់សម្រាប់ថែទាំ ជួសជុល ស្តារ និងពង្រីកអណ្តូងលូ បណ្តាញលូ ប្រឡាយចំហ អាងស្តុក និងដំណើរការស្ថានីយបូមទឹកកខ្វក់។

**កម្មវិធីផ្តល់វិញ្ញាបនបត្រគ្រប់គ្រងនិងផលិតផលព្រៃឈើអន្តរជាតិ** (Program for International Management and Forest Product Certification)

សំដៅដល់បែបបទនៃការផ្តល់វិញ្ញាបនបត្រដែលធានាដល់អ្នកទិញថា ផលិតផលព្រៃឈើត្រូវបានវាយតម្លៃ និងការចេញវិញ្ញាបនបត្របញ្ជាក់ថា ផលិតផលព្រៃឈើនោះមានប្រភពពីព្រៃឈើដែលមានការគ្រប់គ្រងតាមស្តង់ដារសង្គម សេដ្ឋកិច្ច និងបរិស្ថាន។

**កសិកម្មពនេចរ** (Shifting Cultivation/ Traditional Practice Shifting Cultivation)

សំដៅដល់ការធ្វើកសិកម្មតាមបែបប្រពៃណីរបស់ជនជាតិដើមភាគតិចដោយកាប់ និងដុតព្រៃដើម្បីដាំដុះ ហើយបន្ទាប់មកត្រូវបោះបង់មួយរយៈពេល ដើម្បីរក្សាគុណភាពដីតាមរយៈការទុកឱ្យដុះល្បាស់រុក្ខជាតិឡើងវិញ។ ការដាំដុះដំណាំត្រូវបានអនុវត្តតាមខួបវិលជុំនៅលើដីនោះ។

# គ ខ ឃ ង

**គណៈកម្មាធិការមូលនិធិបរិស្ថាននិងសង្គម** (Environmental and Social Fund Committee)

សំដៅដល់គណៈកម្មាធិការដែលបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងគោលបំណងគ្រប់គ្រងមូលនិធិរយៈពេលវែង។

**គម្របព្រៃឈើ** (Forest Cover)

សំដៅដល់មជ្ឈដ្ឋានធម្មជាតិឬសិប្បនិមិត្ត ជាទម្រង់ដីសើម ដីលិចទឹក ឬដីស្ងួត ដែលគ្របដណ្តប់ដោយរុក្ខជាតិដុះតាម ធម្មជាតិ ឬដាំ មានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅលើផ្ទៃដីលើសពី០,៥ហិកតា និងមានកម្រិត

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

គ្របដណ្តប់របស់កន្សោមស្លឹកលើសពី១០% ចម្ការឈើដាំដូចជា កៅស៊ូ ដូងប្រេង អាកាស្យា ម៉ៃសាក់ ប្រេងខ្យល់ និងប្រភេទរុក្ខជាតិផ្តល់ឈើដទៃទៀតដែលមានលក្ខណៈដូចរៀបរាប់ ខាងលើក៏ត្រូវបានចាត់ចូលជាគម្របព្រៃដែរ។

ជីវៈចម្រុះ (Biodiversity or Biological Resources)

សំដៅដល់បណ្តាសពាង្គកាយខុសគ្នានៅក្នុងប្រភេទតែមួយ ឬប្រភេទផ្សេងគ្នា និងបណ្តាសពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់និងប្រភពទាំងអស់រួមទាំងប្រព័ន្ធអេកូឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រព័ន្ធអេកូឡូស៊ីទាំងនេះ។

ជីវបច្ចេកវិទ្យាទំនើប (Modern Biotechnology)

សំដៅដល់ការអនុវត្តនូវ៖

ក. បច្ចេកទេសអាស៊ីតនុយក្លេអ៊ិកអាំងវីត្រូ រួមមានការប្រមូលផ្តុំអាស៊ីតឌីអុកស៊ីរីបូនុយក្លេអ៊ិក និងការចាក់អាស៊ីតនុយក្លេអ៊ិកដោយផ្ទាល់ទៅក្នុងកោសិកាឬសរីរាង្គ។

ខ. ការលាយចូលគ្នានៃកោសិកាដែលមិនមែនគ្រួសារតែមួយ ដែលមានលទ្ធភាពយកឈ្នះនៅការផលិតឡើងវិញតាមលក្ខណៈរូបសាស្ត្រធម្មជាតិ ឬជាឧបសគ្គដល់ការផ្គុំបញ្ចូលគ្នាឡើងវិញ ហើយក៏មិនមែនជាបច្ចេកទេសប្រើប្រាស់នៅក្នុងការបង្កាត់ពូជ ឬការជ្រើសរើសតាមរបៀបបុរាណ។

ដែនជម្រកសត្វព្រៃ (Wildlife Sanctuary )

សំដៅដល់តំបន់ក្នុងដែនដីគោក ឬដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រក និង/ឬដើម្បីបំពេញលក្ខខណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វឬរុក្ខជាតិ។

ឋបនីយជីវមណ្ឌល (Biosphere Reserve)

សំដៅដល់តំបន់តំណាងឱ្យប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់ និងពុំរងនូវការខូចខាតខ្លាំង ហើយព័ទ្ធជុំវិញទៅដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាព ដែលអនុញ្ញាតឱ្យមានសកម្មភាពមនុស្សក្នុងកម្រិតមួយជាកំណត់។

## ត ថ ទ

តំបន់ជម្រាលនៃអាងទន្លេ (Basin Catchment)

សំដៅដល់តំបន់ភូមិសាស្ត្រនៃអាងទន្លេដែលប្រព័ន្ធលំហូរទឹកហូរចូលទៅក្នុងអាងទន្លេដោយរាប់បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

តំបន់សហគមន៍មូលដ្ឋាន (Local Community Area)

សំដៅដល់តំបន់បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់សហគមន៍មូលដ្ឋាន ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ ។ ការចេញលិខិតបណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

តំបន់ការពារទេសភាព (Protected Landscape Area)

សំដៅដល់តំបន់នៃដែនដីគោក និង/ឬដែនទឹក ដែលតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្ស ទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ ដែលមានលក្ខណៈប្លែកខាងផ្នែកសោភណភាពធម្មជាតិ ឬកែច្នៃអេកូឡូស៊ី ឬវប្បធម៌ និងជាទូទៅសម្បូរដោយជីវៈចម្រុះ។ ការថែរក្សាអន្តរអំពើជាប្រពៃណីបែបនេះ មានសារៈសំខាន់ជាអាយុជីវិតចំពោះកិច្ចការពារ ថែរក្សា និងការវិវឌ្ឍតំបន់បែបនេះ។

**តំបន់ការពារធម្មជាតិ** (Protected Area)

សំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន ដែនដីគោក ឬដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបទប្បញ្ញត្តិនៃច្បាប់ ឬតំបន់ដែលបង្កើតថ្មី ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រ និងផ្នែកជីវសាស្ត្រ ដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ក្នុងបំណងការពារ និងថែទាំ ជីវៈចម្រុះ ធនធានធម្មជាតិ និងធនធានវប្បធម៌ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**តំបន់បេតិកភណ្ឌធម្មជាតិ** (Natural Heritage Site)

សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹកដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិ ឬពាក់កណ្តាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោឬប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រមានគុណភាពជាតំណាងឱ្យប្រព័ន្ធធម្មជាតិនានា ឬមានគុណភាពខាងផ្នែកសោភណភាព ឬសារៈសំខាន់ខាងផ្នែកវប្បធម៌។

**តំបន់ដីសើម** (Wetland)

សំដៅដល់តំបន់មានលក្ខណៈជាវាលភក់ វាលល្បាប់ តំបន់មានរុក្ខជាតិពុករលួយ ទីដែលមានទឹកក្នុងលក្ខណៈធម្មជាតិ ឬសិប្បនិម្មិត តំបន់មានទឹកលិចជាអចិន្ត្រៃយ៍ឬតាមរដូវ ទឹកនឹង ទឹកហូរ ឬទឹកភ្លាវ រួមទាំងតំបន់សមុទ្រដែលមានជម្រៅលើសពី៦ (ប្រាំមួយ) ម៉ែត្រ ក្នុងពេលទឹកនាចទាបបំផុត។

**តំបន់ប្រើប្រាស់ច្រើនយ៉ាង** (Multiple-Use Area)

សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬដែនទឹក ដែលក្នុងនោះមានសម្បូរដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងដែលតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ និងការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីសម្រាប់ពេលយូរអង្វែង។ ទន្ទឹមនឹងនោះដែរអាចផ្តល់ផលិតផល និងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍។

**តំបន់ដីមរោក** (Humus Soil Area)

សំដៅដល់តំបន់ដីសើម ដែលមានស្រទាប់ដីមរោកមានកម្រាស់ច្រើនជាង៤០សង់ទីម៉ែត្រដោយកើតចេញពីការពុកផុយនៃបំណែករុក្ខជាតិក្នុងស្ថានភាពជាំទឹក និងកង្វះអុកស៊ីសែន ហើយសម្បូរដោយសារធាតុសរីរាង្គកាបូន (ច្រើនជាង១៨ភាគរយនៃម៉ាស់ស្ងួត)។

**តំបន់ស្នូល** (Core Zone)

សំដៅដល់តំបន់ដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង ហើយនិងប្រព័ន្ធអេកូឡូស៊ីផុយស្រួយ។

ការចេញចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ដែលមានភារកិច្ច។

អ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិ ក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថានត្រូវមានការអនុញ្ញាតជាមុនពីក្រសួងទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ។

**តំបន់អភិរក្ស** (Conservation Zone)

សំដៅដល់តំបន់ស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ទីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ។

ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង។

ការប្រើប្រាស់អនុផលធនធានធម្មជាតិសម្រាប់ជីវភាពរបស់សហគមន៍មូលដ្ឋាន និងមិនធ្វើឱ្យប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុត។

តំបន់ប្រើប្រាស់ដោយចីរភាព (Sustainable Use Zone)

១- សំដៅដល់តំបន់ដែលមានតម្លៃផ្នែកសេដ្ឋកិច្ចជាតិខ្ពស់ បម្រើដល់ការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន។

២- តំបន់ប្រើប្រាស់ដោយចីរភាពរួមមាន៖

ក- តំបន់អភិរក្សវប្បធម៌ធម្មជាតិនិងបេតិកភណ្ឌ។

ខ- តំបន់ទេសចរណ៍ធម្មជាតិ។

គ- តំបន់អភិរក្សសត្វព្រៃ និងសេវាកំសាន្ត។

ឃ- តំបន់ស្តារធនធានជីវៈចម្រុះ។

ង- សហគមន៍តំបន់ការពារធម្មជាតិ។

ច- តំបន់រុក្ខឧទ្យាន។

ឆ- តំបន់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមាន ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក។

ជ- រ៉ែអគ្គិសនី បង្គោលចរន្តអគ្គិសនី។

ឈ- តំបន់ភូគព្ភសាស្ត្រ។

៣- តំបន់អាជីវកម្មដីរុក្ខជាតិ អនុគ្រោះដល់បរិស្ថានធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិនិងតំបន់ជុំវិញ។

តំបន់ឆ្នេរ (Coastal Zone)

សំដៅដល់តំបន់ដីគោកដែលស្ថិតនៅជាប់សមុទ្រ និងទទួលឥទ្ធិពលនៃសមុទ្រ មាននៅខេត្តកំពត ខេត្តកោះកុង ខេត្តព្រះសីហនុ និងខេត្តកែប ដោយរួមបញ្ចូលបូរណភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។

តំបន់រ៉ាមសារ (Ramsar Site)

សំដៅដល់តំបន់ដីសើម ដែលគេចាត់ទុកថា ជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬជីវៈចម្រុះជាលក្ខណៈអន្តរជាតិ។

តំបន់ទីជម្រាល (Watershed Area)

ជាតំបន់ភ្នំឬខ្ពង់រាបឬតំបន់មានរយៈកំពស់ខ្ពស់ ជាផ្ទៃរងទឹកភ្លៀងដែលមានលក្ខណៈភូមិសាស្ត្រស្ថិតនៅជុំវិញ ឬជាផ្លូវទឹកតភ្ជាប់ហូរចាក់ទៅទន្លេ អាងទន្លេ ឬសមុទ្រ។ ទីជម្រាលគឺជាតំបន់មួយនៅលើដី ដែលទឹកទាំងអស់មកពីទឹកភ្លៀងនិងព្រិល ហូរចុះក្រោមទៅកន្លែងទឹកតែមួយ ដូចជាអូរ ទន្លេ បឹង ឬជីឈ្វាយខ្សាច់។ ទីជម្រាលក៏ត្រូវបានហៅថាកន្លែងប្រមូលទឹកភ្លៀងផងដែរ ព្រោះដីដែលស្ថិតនៅលើខ្សែទឹក ប្រមូលទឹកទាំងអស់ បន្ទាប់មកវាក៏ហូរចុះទៅក្រោម។

ថាមពលនុយក្លេអ៊ែរ (Nuclear Energy)

សំដៅដល់ថាមពលដែលបញ្ចេញពីណ្វៃយ៉ូនៃអាតូមតាមរយៈប្រតិកម្មបំបែក(Fission) ឬប្រតិកម្មលាយ (Fusion)។

ប្រតិកម្មបំបែក គឺជាប្រភេទប្រតិកម្មដែលកើតឡើងនៅក្នុងណ្វៃយ៉ូនៃអាតូម ដែលក្នុងនោះណ្វៃយ៉ូនៃអាតូមធ្ងន់ (ដូចជាអ៊ុយរ៉ាញ៉ូមជាដើម) ត្រូវបានបំបែកជាណ្វៃយ៉ូស្រាលជាង ចំនួនពីរ ឬច្រើនជាងនេះ ដែលត្រូវបានហៅថាផលិតផលបំបែក (Fission Products) និងមានបញ្ចេញនូវថាមពលដែលមានទម្រង់ជារលកអេឡិចត្រូម៉ាញ៉េទិច (កាំរស្មីហ្គាម៉ាឬកាំរស្មីអ៊ិច)ឬភាគល្អិត (អាល់ហ្វា បេតា ឬណឺត្រុង) ដែលមានកម្លាំងគ្រប់គ្រាន់អាចធ្វើអ៊ីយ៉ុងកម្មនៅពេលដែលឆ្លងកាត់មជ្ឈដ្ឋានណាមួយ។

ប្រតិកម្មលាយ គឺជាប្រភេទប្រតិកម្មដែលកើតឡើងនៅក្នុងណ្វៃយ៉ូនៃអាតូម ដែលក្នុងនោះណ្វៃយ៉ូនៃអាតូមស្រាលចំនួនពីរ (ដូចជាអ៊ីដ្រូសែនជាដើម) ត្រូវបានបញ្ចូលគ្នាបង្កើតបានជាណ្វៃយ៉ូនៃអាតូមធ្ងន់ជាងចំនួនមួយ ដោយមានបញ្ចេញនូវបរិមាណថាមពលជាច្រើនសន្ធឹកសន្ធាប់។

**ថាមពលប្រកបដោយការទទួលខុសត្រូវ** (Responsible Energy)

សំដៅដល់គោលការណ៍ផលិតនិងការផ្គត់ផ្គង់ថាមពល ដែលមានលក្ខណៈ៦(ប្រាំមួយ)យ៉ាងជាមួយគ្នាគឺ មានគ្រប់គ្រាន់ មាននិរន្តរភាព មានស្ថិរភាព មានគុណភាព មានតម្លៃសមរម្យ និងមាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា។

**ថ្លៃសួយសារ** (Royalty)

សំដៅដល់បរិមាណទឹកប្រាក់ដែលត្រូវបង់ជូនរដ្ឋដោយបុគ្គលគ្រប់រូប ចំពោះផល អនុផលព្រៃឈើ រុក្ខជាតិព្រៃ និងសំណាករុក្ខជាតិព្រៃ និងសត្វព្រៃនិងសំណាកសត្វព្រៃ ដែលបានប្រមូល ឬធ្វើអាជីវកម្ម។

**ទិន្នន័យ** (Database)

សំដៅដល់ព័ត៌មានទាំងអស់ដែលបានប្រមូល ចងក្រង និងវិភាគសម្រាប់ការប្រើប្រាស់តាមតម្រូវការ។

**ទីជម្រក** (Habitat)

សំដៅដល់ទីកន្លែងឬទីតាំងដែលមានពពួកតាមប្រភេទតែមួយទៅតាមធម្មជាតិជាជម្រក ជាកន្លែងរកចំណី និងជាកន្លែងបង្កាត់ពូជរបស់ពពួកសត្វនិងរុក្ខជាតិទាំងនោះ។

**ទីតាំងការពារនិងអភិរក្សប្រភពដើមធនធានពន្ធុ** (Genetic Resources Protection and Conservation Area)

សំដៅទីតាំងដែលមានសមាសភាគរុក្ខជាតិ សត្វ មីក្រុប ឬសមាសភាគប្រភពដើមផ្សេងៗដែលមានផ្ទុកមុខងារនៃឯកតាតំណពូជ ដែលមានគុណតម្លៃ សម្រាប់ការសិក្សាស្រាវជ្រាវ ការការពារ និងការអភិរក្ស។

**ទេសចរណ៍ធម្មជាតិ** (Eco-Tourism)

សំដៅដល់សេវាកម្មទេសចរណ៍នានា ដែលមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានធម្មជាតិជុំវិញតំបន់ទេសចរណ៍ និងមានរូបភាពនិន្នាការបម្រើឱ្យសកម្មភាពអភិរក្ស។

# ធ ឆ ប

**ធុរកិច្ចនូវប្រភពថាមពលប្រកបដោយការទទួលខុសត្រូវ** (Responsible Energy Business)

សំដៅដល់ធុរកិច្ច ដែលបង្កើតប្រព័ន្ធថាមពលប្រកបដោយការទទួលខុសត្រូវ សម្រាប់ការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ខ្លួនដោយត្រូវទទួលខុសត្រូវលើគោលការណ៍ផ្សេងទៀតក្រៅពី "ទទួលខុសត្រូវ" ដោយខ្លួនឯង បន្ទាប់មកប្រសិនបើចង់តភ្ជាប់ជាមួយបណ្តាញផ្គត់ផ្គង់រួមត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសសេដ្ឋកិច្ចនិងសុវត្ថិភាព ដែលកំណត់ដោយក្រសួងស្ថាប័នទទួលបន្ទុកវិស័យថាមពល។

**ធនធានធម្មជាតិ** (Natural Resources)

សំដៅដល់ចំណែកមួយនៃបរិស្ថានធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆជាតិ ធនធានជលផល។

**ធនធានពន្ធុ** (Genetic Resources)

សំដៅដល់ពិពិធភាពពន្ធុនៃហ្សែនរបស់ប្រភេទរុក្ខជាតិ សត្វ មីក្រុប ជាអាទិ៍។

**និរន្តរភាព** (Sustainability)

សំដៅដល់ការមិនបង្កឱ្យមានភាពរេចរឹលជាអចិន្ត្រៃយ៍ឬជាបន្តបន្ទាប់ ឬការថយចុះនូវគុណភាពនៃប្រភេទសព៌ាង្គកាយរស់ ឬគុណភាពនៃធនធានដទៃទៀតដែលស្ថិតនៅក្រោមរូបភាពនៃការប្រើប្រាស់ជាទ្រង់ទ្រាយតូចក្តី ធំក្តី។

**និទស្សន៍វត្ថុនៃធនធានពន្ធុ** (Genetic Resource Proof)

សំដៅដល់វត្ថុនានាដែលជាតឹកតាងឬភស្តុតាងនៃធនធានពន្ធុ។

ប្រភេទកម្រ (Rare Species)

សំដៅដល់ប្រភេទទាំងឡាយណាដែលមានចំនួនតិចតួច ប៉ុន្តែវាពុំស្ថិតនៅក្នុងភាពគ្រោះថ្នាក់ផុតពូជភ្លាមៗទេ។ ជាទូទៅប្រភេទទាំងនោះ គេតែងជួបប្រទះក្នុងបណ្តាភាវៈប្រចាំទីក្នុងជម្រកពិសេសណាមួយ ឬស្ថិតនៅរាយប៉ាយយ៉ាងរង្វើលនៅលើតំបន់ដ៏ធំល្វឹងល្វើយ។

ប្រភេទជិតផុតពូជ (Endangered Species)

សំដៅដល់ពពួកសត្វ ឬរុក្ខជាតិ ដែលអាចវិនាសសាបសូន្យបណ្តាលមកពីការប្រែប្រួលបរិស្ថានដោយធម្មជាតិ ឬការធ្វើអាជីវកម្មផ្ទាល់របស់មនុស្ស ការខូចខាតហិនហោចជម្រក ការគំរាមកំហែងពីប្រភេទដទៃទៀត ការប្រែប្រួលបណ្តាញអាហារ ការបំពុល ឬបណ្តាលមកពីបន្សំនៃកត្តាទាំងនេះ។

បច្ចេកវិទ្យាមេត្រីបរិស្ថាន (Environment Friendly Technology)

សំដៅដល់បច្ចេកទេសវិទ្យាថ្មីដែលមានបំណងការពារ តាមដានត្រួតពិនិត្យ ឬកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន លើបច្ចេកវិទ្យាបរិស្ថាននិងការប្រើប្រាស់ធនធាននានា។

បណ្តុំនៃហេតុប៉ះពាល់ (Cumulative Impact)

សំដៅដល់ហេតុប៉ះពាល់ទាំងឡាយណា ដែលកើតមានឡើងពីសកម្មភាពរួមគ្នារវាងគម្រោងដែលមានស្រាប់ និងគម្រោងក្នុងពេលអនាគតដែលស្ថិតនៅជុំវិញតំបន់គម្រោងទាំងនោះ ដោយផ្តោតទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម។

បន្លាស់ទីសារធាតុបំពុល (Pollutant Substance(s) Movement)

សំដៅដល់ការបញ្ជូនចេញនូវសំណល់ សារធាតុគីមីពុល ឬសារធាតុគ្រោះថ្នាក់ ទៅក្រៅបរិវេណប្រភពឬទីតាំងបង្កើត ក្នុងគោលបំណងប្រើប្រាស់ កែច្នៃ ទាញយកធនធាន ធ្វើប្រព្រឹត្តិកម្ម ឬបោះចោល រួមបញ្ចូលការបញ្ចេញទឹកកខ្វក់ ឬសំណល់រាវ ចូលទៅក្នុងប្រព័ន្ធប្រព្រឹត្តិកម្មទឹកកខ្វក់សាធារណៈ។

បមាណីយ/ស្តង់ដារមេត្រីបរិស្ថាន (Environmentally Friendly Standard)

សំដៅដល់បទដ្ឋានបច្ចេកទេសសម្រាប់កំណត់លក្ខណវិនិច្ឆ័យ និងសូចនាករដែលត្រូវយកមកវាយតម្លៃសកម្មភាពប្រតិបត្តិមេត្រីបរិស្ថាន។

បរធនបាលកិច្ចបរិស្ថាន (Environmental Trust)

សំដៅដល់កិច្ចការគ្រប់គ្រងនិងចាត់ចែងបរធនដែលផ្តល់ដោយបរធនបាលទាយក សម្រាប់ជាប្រយោជន៍ផ្នែកបរិស្ថានដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធានបាលកិច្ចឬបទប្បញ្ញត្តិជាធរមាន។

បរិក្ខារតាមដានត្រួតពិនិត្យ (Monitoring Equipment)

សំដៅដល់ឧបករណ៍ឬគ្រឿងម៉ាស៊ីន ដែលបំពាក់សម្រាប់វាស់ស្ទង់និងកត់ត្រាទិន្នន័យកំហាប់សារធាតុបំពុល ឬបរិមាណសំណល់បញ្ចេញទៅក្នុងបរិស្ថាន។

បរិស្ថានឆ្លងដែន (Transboundary Environment)

សំដៅដល់ការគ្រប់គ្រងបរិស្ថាន ដែលជាកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងប្រទេសនិងប្រទេសដែលមានផលប៉ះពាល់នៃការបំពុលបរិស្ថានជះឥទ្ធិពលលើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដូចជា ការបំពុលខ្យល់ ផ្សែងអ័ព្ទ ការបំពុលទឹកជាដើម។

បុគ្គល (Person)

សំដៅដល់រូបបុគ្គលឬនីតិបុគ្គល។

បុព្វលាភ (Premiums)

សំដៅដល់បរិមាណទឹកប្រាក់ដែលអ្នកកាន់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតត្រូវបង់បន្ថែមលើថ្លៃសួយសារ (បុព្វលាភព្រៃឈើ)។

ប្រព័ន្ធអេកូឡូស៊ី (Eco-system)

សំដៅដល់សំណុំអន្តរអំពើចម្រុះនៅលើផ្ទៃដីមួយជាក់លាក់រវាងបណ្តាភាវៈមានជីវិត(សារព័ន្ធរុក្ខជាតិ សត្វមីក្រូសរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត(អាកាសធាតុ មីក្រូអាកាសធាតុ ដី ទឹក) ដែលបង្កនូវស្ថាបនកម្មរបស់បរិស្ថាន និងជាឯកតាបំពេញមុខងារមួយនៅលើសំបកផែនដី។ មនុស្សរួមជាមួយសំបកផែនដី មនុស្សរួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និងបរិស្ថាន ក៏ជាផ្នែកចម្រុះរួមមួយនៃបណ្តាប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែរ។

ប្រព្រឹត្តិកម្មសំណល់ (Waste Treatment)

សំដៅដល់សកម្មភាព ឬលំនាំសម្អាត ដកយកចេញ ឬកម្ទេចចោលនូវសារធាតុគីមីពុល សារធាតុគ្រោះថ្នាក់ ឬភ្នាក់ងារចម្លងជំងឺ ដែលមាននៅក្នុងសំណល់តាមរយៈវិធីរូប គីមី ឬជីវសាស្ត្រ។

ប្រតិបត្តិករសំណល់ (Waste Operator)

សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែល៖

- ផ្តល់សេវាប្រមូល ដឹកជញ្ជូន ប្រព្រឹត្តិកម្ម កម្ទេចចោល ឬទុកដាក់សំណល់ចុងក្រោយ
- ធ្វើអាជីវកម្មទិញ លក់ កែច្នៃ ឬទាញយកធនធានពីសំណល់។

ប្រភពជាក់លាក់ (Point Source(s))

សំដៅដល់ទីតាំងជាក់លាក់ មានជាអាទិ៍ រោងចក្រ សហគ្រាស ទីតាំងផលិតកម្ម ទីតាំងអាជីវកម្ម ឬទីតាំងសេវាកម្ម ដែលបង្កើតនិងបញ្ចេញសំណល់រាវ សារធាតុបំពុល ឬទឹកកខ្វក់ចូលទៅក្នុងបណ្តាញលូសាធារណៈ ឬតំបន់ទឹកសាធារណៈ។

ប្រភពបំពុលខ្យល់ (Air Pollution Sources)

សំដៅដល់ទីតាំង ទីកន្លែង និងមធ្យោបាយដឹកជញ្ជូន ដែលបង្កើតឬបញ្ចេញសំណល់ សារធាតុបំពុល ក្លិនផ្សែង កម្តៅ ការរំខានដោយសំឡេងនិង រំញ័រ ជាអាទិ៍ ទៅក្នុងបរិយាកាស។

ប្រភពបំពុលខ្យល់ចល័ត (Mobile Air Pollution Sources)

សំដៅដល់ប្រភពបំពុលជាប្រភេទយានយន្ត ដែលបញ្ចេញផ្សែង ឧស្ម័ន សារធាតុបំពុលខ្យល់ ក្លិន កម្តៅ ការរំខានដោយសំឡេង និងរំញ័រ ជាដើម ចូលទៅក្នុងខ្យល់បរិយាកាស។

ប្រភពបំពុលខ្យល់អចល័ត (Constant Air Pollution Sources)

សំដៅដល់ប្រភពបំពុលមានទីតាំងជាក់លាក់ មានជាអាទិ៍ រោងចក្រ សហគ្រាស សិប្បកម្ម កសិដ្ឋាន ឃ្លាំងស្តុកសម្ភារៈ ការដ្ឋានសំណង់ ឡដុតសំរាម ដែលបញ្ចេញផ្សែង ឧស្ម័ន សារធាតុបំពុលខ្យល់ ក្លិន កម្តៅ ការរំខានដោយសំឡេងនិងរំញ័រចូលទៅក្នុងបរិយាកាស។

ប្រភពមិនជាក់លាក់ (Non-Point Source(s))

សំដៅដល់ប្រភពបំពុលមានវិសាលភាពធំទូលាយ មានជាអាទិ៍ ទីក្រុង វាលស្រែចម្ការ ដែលសំណល់រាវ សារធាតុបំពុល ឬទឹកកខ្វក់បានហូរចេញនៅពេលមានជំនន់ទឹកភ្លៀង។

ប្រភេទកំពុងរងការគំរាមកំហែង (Threatened Species)

សំដៅដល់ប្រភេទសត្វ និងរុក្ខជាតិដែលបានចុះបញ្ជីជាប្រភេទកំពុងរងគ្រោះថ្នាក់ឈានទៅរកការវិនាសផុតពូជបំផុតកំពុងរងគ្រោះថ្នាក់ជិតផុតពូជ ឬងាយរងគ្រោះថ្នាក់ ដូចមានចុះនៅក្នុងបញ្ជីក្រហមនៃប្រភេទកំពុងទទួលរងការគំរាមកំហែង។

ប្រភេទកំពុងរងគ្រោះថ្នាក់ (Endangered Species)

សំដៅដល់ប្រភេទសត្វ និង/ឬរុក្ខជាតិទាំងឡាយ ដែលចាត់ទុកថាប្រឈមនឹងហានិភ័យខ្ពស់បំផុតនៃការផុតពូជនៅក្នុងព្រៃ យោងទៅតាមភស្តុតាងស្វែងរកប្រសើរបំផុត។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



៣៥

**ប្រភេទជិតផុតពូជ/ប្រភេទកំពុងរងគ្រោះថ្នាក់ខ្លាំង (Critically Endangered Species)**

សំដៅដល់ប្រភេទសត្វ និងរុក្ខជាតិទាំងឡាយនៅក្នុងធម្មជាតិ ដែលជង់ស៊ីតេ និងភូមិសាស្ត្រនៃទីជម្រករបស់វាត្រូវបានថយចុះ យ៉ាងឆាប់រហ័សក្នុងរយៈពេល១០(ដប់)ឆ្នាំចុងក្រោយ ឬក្នុងរយៈពេល៣(បី)ជំនាន់តំណពូជនៅក្នុងធម្មជាតិ និងប្រភេទដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ព្រមទាំងមានតម្លៃសេដ្ឋកិច្ចខ្ពស់។ ឈ្មោះប្រភេទសត្វព្រៃនិងរុក្ខជាតិក្នុងក្រុមប្រភេទជិតផុតពូជ ត្រូវបានកំណត់ក្នុងបញ្ជីក្រហមនៃប្រភេទកំពុងទទួលរងការគំរាមកំហែង។

**ប្រភេទមានដើមកំណើតក្នុងស្រុក (Native Species)**

សំដៅដល់ប្រភេទសត្វ ឬរុក្ខជាតិទាំងឡាយណា ដែលមានដើមកំណើត ធ្លាប់បានរស់នៅឬបន្តរស់នៅ ឬមានផ្នែកណាមួយនៃវដ្ដជីវិតរបស់វា ឬការផ្លាស់ទីជាប្រចាំ នៅក្នុងតំបន់ភូមិសាស្ត្រនៃប្រទេសកម្ពុជា មិនមែនជាលទ្ធផលនៃការនាំចូលមកថ្មី ទោះមានចេតនា ឬមិនមានចេតនាក៏ដោយ។

**ប្រភេទមានដើមកំណើតក្រៅស្រុក (Alien Species)**

សំដៅដល់ប្រភេទសត្វ និង/ឬរុក្ខជាតិណាមួយដែលមិនមានដើមកំណើតដំបូងនៅប្រទេសកម្ពុជា ជាអាទិ៍ សត្វព្រៃរស់និងងាប់ ព្រមទាំងផ្នែកផ្សេងៗរបស់សត្វព្រៃ រុក្ខជាតិទាំងឡាយដែលត្រូវបានប្រមែប្រមូលមក។

**ប្រភេទមិនទាន់រងការគំរាមកំហែង (Least Concerned Species)**

សំដៅដល់ប្រភេទសត្វ និងរុក្ខជាតិដែលត្រូវបានចាត់ដោយសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ ដែលត្រូវបានវាយតម្លៃថាជាប្រភេទមិនត្រូវបានជាកម្មវត្ថុនៃការអភិរក្សទេ។

**ប្រភេទរាតត្បាតមានដើមកំណើតក្រៅស្រុក (Alien Invasive Species)**

សំដៅដល់រុក្ខជាតិ សត្វ ភ្នាក់ងារបង្កជំងឺ និងមីក្រូសរីរាង្គកាយដទៃទៀតដែលពុំមានដើមកំណើតក្នុងព្រះរាជាណាចក្រកម្ពុជា ហើយអាចបង្កការខូចខាតដល់សេដ្ឋកិច្ចឬបរិស្ថាន ឬអាចមានផលប៉ះពាល់អវិជ្ជមានដល់សុខភាពមនុស្ស។ ជាងនេះ ប្រភេទរាតត្បាតមិនមានដើមកំណើតក្នុងស្រុកមានឥទ្ធិពលអវិជ្ជមានលើជីវៈចម្រុះក្នុងនោះ រួមទាំងការធ្លាក់ចុះ ឬការលុបបំបាត់ទាំងស្រុងនូវប្រភេទក្នុងស្រុក ឬការចម្លងភ្នាក់ងារបង្កជំងឺ និងការរំខានប្រព័ន្ធអេកូឡូស៊ី និងមុខងារប្រព័ន្ធអេកូឡូស៊ីក្នុងស្រុក។

**ប្រសិទ្ធផលធនធាន (Resource Efficiency)**

សំដៅដល់ការប្រើប្រាស់ធនធានដូចជា ថវិកា សម្ភារៈ ធនធានបរិស្ថាន ធនធានមនុស្ស ឬធនធានផ្សេងទៀត ដើម្បីបំពេញមុខងារប្រកបដោយប្រសិទ្ធភាពតាមរយៈការប្រើប្រាស់ធនធានតិចជាងមុន កាត់បន្ថយសំណល់ និងសន្សំសំចៃផ្នែកសេដ្ឋកិច្ច សំដៅរក្សាបានចីរភាពបរិស្ថាន។

## ផ

**ផលិតផលព្រៃឈើ (Forest Products)**

សំដៅដល់វត្ថុធាតុណាមួយដែលបានមកពីព្រៃឈើសម្រាប់ការប្រើប្រាស់ដោយផ្ទាល់ ឬការប្រើប្រាស់ជាលក្ខណៈពាណិជ្ជកម្ម រួមមាន ផលព្រៃឈើ អនុផលព្រៃឈើ ចំណីសត្វ ជាអាទិ៍។

**ផែនការគ្រប់គ្រងបរិស្ថាន (Environmental Management Plan)**

សំដៅដល់ផែនការដែលមានចែងនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ដែលបានកំណត់ពីវិធានការការពារ និងកាត់បន្ថយហេតុប៉ះពាល់ ការទទួលខុសត្រូវ និងកាលវិភាគសម្រាប់អនុវត្ត តាមដាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថានពីគម្រោង ដោយរួមបញ្ចូលទាំងផែនការហិរញ្ញវត្ថុសម្រាប់សកម្មភាពបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោង។

**មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ** (Wildlife Rescue Center)

សំដៅដល់ទីតាំងមួយដែលមានគោលបំណង៖

- ស្តារ (ព្យាបាល) សត្វព្រៃដែលរងរបួស និងលែងសត្វព្រៃនោះទៅក្នុងព្រៃវិញ
- ទទួលសត្វព្រៃដែលរឹបអូសបាន និងថែទាំពួកវារហូតដល់ពេល ដែលគេអាចនាំពួកវាទៅកាន់កន្លែងដើមវិញ ឬអាចលែងបាន
- ផ្តល់ការថែទាំរយៈពេលវែងសម្រាប់សត្វព្រៃ ដែលមិនអាចបញ្ជូនត្រឡប់ទៅក្នុងព្រៃវិញ និង
- អនុវត្តការបង្កាត់ពូជសត្វបង្ខាំងទុកសម្រាប់គោលបំណងអភិរក្ស។

**មុខងារកម្មប្រព័ន្ធអេកូឡូស៊ី** (Ecosystem functioning)

សំដៅដល់ការបង្កើតឡើងនូវដំណើរការនានា ដែលកំណត់ដោយអន្តរកម្មផ្សេងៗក្នុងចំណោមសហគមន៍ជីវសាស្ត្រ ទាំងប្រភេទក្នុងស្រុក ទាំងប្រភេទក្រៅស្រុក ទាំងដំណើរការជីវរូបសាស្ត្រ ដូចជា និយ័តកម្មទឹកនិងការបង្កើតឡើងវិញនូវវត្ថុសារជាតុចិញ្ចឹម។

**មូលនិធិបរិស្ថាននិងសង្គម** (Environmental and Social Fund)

សំដៅដល់មូលនិធិដែលទទួលបានពីកិច្ចគាំពារបរិស្ថាន ដៃគូអភិវឌ្ឍ អំណោយសប្បុរសជន ម្ចាស់គម្រោងវិនិយោគ ដែលបានដាក់ពាក្យស្នើសុំមកក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដើម្បីសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងដែលបានស្នើសុំ និងពីកម្រៃផ្សេងៗទៀត។

**មេត្រីបរិស្ថាន** (Environmentally Friendly)

សំដៅដល់ការអនុវត្តច្បាប់ ផលិតកម្ម សេវាកម្ម និងបច្ចេកវិទ្យាដែលទ្រទ្រង់ដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងការរស់នៅប្រកបដោយចីរភាព។

**ម្ចាស់សំណល់** (Waste Owner)

សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបង្កើតសំណល់ពីសកម្មភាពផលិតកម្ម អាជីវកម្ម សេវាកម្ម រួមទាំងសកម្មភាពរស់នៅប្រចាំថ្ងៃ។

**រដ្ឋបាលថ្នាក់ក្រោមជាតិ** (Sub-national Administration)

សំដៅដល់រដ្ឋបាលនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ដែលទទួលបន្ទុកគ្រប់គ្រងកិច្ចការណាមួយដែលស្របច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

**រុក្ខជាតិព្រៃ** (Wild flora)

សំដៅដល់ប្រភេទរុក្ខជាតិដែលមិនត្រូវបានគេដាំរួមទាំងរូបធាតុលូតលាស់របស់វា កកើតឡើងនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងជម្រកធម្មជាតិ ដោយពុំមានឬមានក្នុងកម្រិតកំណត់នូវឥទ្ធិពលរបស់មនុស្សក្នុងការកកើតមាននិងការបន្តពូជរបស់វា។

# ល ខ ស

**លិខិតុបករណ៍អន្តរជាតិ** (Internation Instrument)

សំដៅដល់សន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ ឬអន្តរជាតិ ឬ ច្បាប់អន្តរជាតិផ្សេងទៀត។

**លិខិតអនុញ្ញាតបញ្ចេញឧស្ម័នផ្ទះកញ្ចក់** (Emission Permit)

សំដៅដល់ការកំណត់កម្រិតនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (មិនអាចផ្ទេរ តែអាចធ្វើពាណិជ្ជកម្មបាន) ដោយអាជ្ញាធរមានសមត្ថកិច្ចដូចជា ស្ថាប័នអន្តររដ្ឋាភិបាល ស្ថាប័នថ្នាក់កណ្តាលឬមូលដ្ឋាន ទៅកាន់អង្គភាពថ្នាក់តំបន់ (ប្រទេស ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ) ឬអង្គភាពតាមវិស័យ (ក្រុមហ៊ុន) ក្នុងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងបរិមាណជាក់លាក់មួយ។



ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

លំហូរបរិស្ថាន (Environmental flow)

សំដៅដល់បរិមាណ ពេលវេលា និងគុណភាពនៃលំហូរទឹកចាំបាច់សម្រាប់ទ្រទ្រង់ប្រព័ន្ធអេកូឡូស៊ី ជីវភាពរស់នៅ និងសុខុមាលភាពរបស់ភាវៈរស់ ដែលពឹងផ្អែកលើប្រព័ន្ធអេកូឡូស៊ីទាំងនោះ។

លទ្ធកម្ម (Procurement)

សំដៅដល់ដំណើរការនៃការជាវរហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។

វិញ្ញាបនបត្រឯកភាពលើកិច្ចសន្យាការពារបរិស្ថាននិងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម (Certificate on Environmental Protection Contract and Social Impact Assessment Report)

សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិ ដោយផ្អែកទៅលើការវាយតម្លៃបរិស្ថានរបស់គម្រោង ដែលមានចែងនៅក្នុងផែនការគ្រប់គ្រងបរិស្ថាន ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

វិទ្យុសកម្ម (Radioactive)

សំដៅដល់ធាតុដែលបញ្ចេញថាមពលខ្ពស់ ក្នុងទម្រង់ជារលកអេឡិចត្រូម៉ាញេទិក(កាំរស្មីហ្គាម៉ាឬកាំរស្មីអ៊ិច) ឬភាគល្អិត(អាល់ហ្វា បេតា ឬណឺត្រុង) ដែលមានថាមពលគ្រប់គ្រាន់អាចធ្វើអ៊ីយ៉ុងកម្មនៅពេលដែលឆ្លងកាត់មជ្ឈដ្ឋានណាមួយ។

សហគមន៍មូលដ្ឋាន (Local Community)

សំដៅដល់សហគមន៍ដែលជាជនជាតិដើមភាគតិច ឬមិនមែនជាជនជាតិដើមភាគតិចដែលរស់នៅទីតាំងណាមួយជាក់លាក់ ហើយបានបង្កើត ឬចងក្រង ឬមិនបានចងក្រងជាសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ឬសហគមន៍ផ្សេងទៀតដែលកំណត់ដោយច្បាប់។

សហគមន៍តំបន់ការពារធម្មជាតិ (Community Protected Area)

សំដៅដល់សហគមន៍មូលដ្ឋានដែលមានឆន្ទៈស្ម័គ្រចិត្តរៀបចំរដ្ឋបាលមួយ ដែលមានការទទួលស្គាល់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងគោលបំណងចូលរួមរៀបចំ គ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ជាក់លាក់ណាមួយនៃតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព សំដៅចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋាន។

សហគមន៍ទេសចរណ៍ធម្មជាតិ (Ecotourism Community)

សំដៅដល់សហគមន៍មូលដ្ឋានមួយ ដែលជាម្ចាស់និងជាអ្នកគ្រប់គ្រងដ៏សំខាន់លើហេដ្ឋារចនាសម្ព័ន្ធនិងសកម្មភាពទេសចរណ៍ធម្មជាតិ ហើយសកម្មភាពទេសចរណ៍ទាំងនោះត្រូវធ្វើប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននៃការបែងចែកផលប្រយោជន៍ដោយផ្ទាល់ជាមួយនឹងសហគមន៍។

សារធាតុគីមីពុល (Toxic Chemical(s))

សំដៅដល់សារធាតុគីមី ឬក្រុមសារធាតុគីមី ដែលអាចបង្កការពុលដល់មនុស្ស សត្វ ឬបង្កគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ នៅពេលមានវត្តមាននៅក្នុងបរិស្ថាន។

សារធាតុគ្រោះថ្នាក់ (Hazardous Substance(s))

សំដៅដល់សារធាតុគីមី ឬក្រុមសារធាតុគីមី ដែលបង្កការពុលភ្លាមៗឬរ៉ាំរ៉ៃ បង្កគ្រោះថ្នាក់ បង្កការប៉ះពាល់ដល់កំណើតថ្មី ហើយដែលមានលក្ខណៈធន់នឹងការបំបែកធាតុក្នុងបរិស្ថាន ភាពអាចចម្លងចូលទៅក្នុងវដ្តអាហារ និងភាពអាចកកកុំនៅក្នុងសរីរាង្គកាយមនុស្ស សត្វ និងជីវៈចម្រុះ។

សារធាតុបំពុល (Pollutant(s) / Pollutant Substance(s))

សំដៅដល់សារធាតុគីមី ក្រុមសារធាតុគីមី សំណល់ ផ្សែង ឧស្ម័ន ក្លិន ធូលី ឬកម្តៅ ដែលធ្លាក់ចូលទៅក្នុងបរិស្ថានដោយសកម្មភាពរបស់មនុស្សតាមរយៈការបញ្ចេញចោល ការលេចធ្លាយ ឬដោយសកម្មភាពធម្មជាតិ ធ្វើឱ្យគុណភាពបរិស្ថានថយចុះ ឬអាចបង្កគ្រោះថ្នាក់ដល់បរិស្ថាន ជីវៈចម្រុះ មនុស្ស និងសត្វ។

**សុពលភាព/សុពលកម្ម (Validation)**

សំដៅដល់ដំណើរការនៃការវាយតម្លៃឯករាជ្យមួយទៅលើសកម្មភាពគម្រោងយន្តការអភិវឌ្ឍស្អាត ឬសកម្មភាពតាមកម្មវិធីដោយអង្គភាពទទួលបន្ទុកប្រតិបត្តិដោយធ្វើការផ្ទៀងផ្ទាត់វិធាន និងលក្ខខណ្ឌតម្រូវរបស់យន្តការអភិវឌ្ឍស្អាតទៅនឹងលក្ខខណ្ឌតម្រូវនៃការរៀបចំឯកសារគម្រោង ឬឯកសារសកម្មភាពលម្អិតរបស់កម្មវិធី និងឯកសារសកម្មភាពលម្អិតនៃគម្រោងតាមផ្នែក។

**សួនរុក្ខសាស្ត្រ (Botanic Garden)**

សំដៅដល់សួនរុក្ខជាតិដែលត្រូវបានដាំក្នុងគោលបំណងសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងដាក់តាំងបង្ហាញសម្រាប់សាធារណជនទស្សនា ឬជាសួនដែលធ្វើការប្រមូល ការដាំដុះ ការអភិរក្ស និងការតាំងបង្ហាញបណ្ដាប្រភេទរុក្ខជាតិដែលមានពាសពេញសកលលោក ដោយមានដាក់ស្លាកឈ្មោះ និងប្រភពរបស់វា។

**សេវាអគ្គិសនី (Electricity Services)**

សំដៅដល់ការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនី ព្រមទាំងសេវាបន្ថែមឬបន្ទាប់បន្សំភ្ជាប់ជាមួយសកម្មភាពទាំងនេះ។

**សំណល់គ្រោះថ្នាក់ (Hazardous Waste)**

សំដៅដល់សំណល់ ដែលមានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរភ្លាមៗ ឬរ៉ាំរ៉ៃដល់សុខភាពមនុស្ស សត្វ បរិស្ថាន ឬបង្កការខូចខាតទ្រព្យសម្បត្តិ មានជាអាទិ៍ ភាពងាយឆាបឆេះ ភាពងាយបង្កប្រតិកម្ម ភាពងាយបង្កច្រែះកាត់ ងាយបង្កជំងឺឆ្លង ដែលតម្រូវឱ្យធ្វើការគ្រប់គ្រងដាច់ដោយឡែកពីសំណល់ធម្មតា។

**ស្លាកមេត្រីបរិស្ថាន (Environmentally Friendly Label(s))**

សំដៅដល់រូបសញ្ញា ដែលមានលក្ខណៈជាកំណត់តូចៗបញ្ជាក់ពីការចូលរួមប្រតិបត្តិបមាណីយមេត្រីបរិស្ថាន ដែលចេញដោយក្រសួងស្ថាប័នទទួលបន្ទុកបរិស្ថាននិងធនធានធម្មជាតិសម្រាប់បិទភ្ជាប់លើផលិតផលនានា។

**ស្វ័យតាមដានត្រួតពិនិត្យ(សំណល់) (Self-Monitoring)**

សំដៅដល់សកម្មភាពត្រួតពិនិត្យការបំពុលបរិស្ថាន ដែលអនុវត្តដោយម្ចាស់ ឬអ្នកទទួលខុសត្រូវប្រភពបំពុលតាមរយៈការបំពាក់ឧបករណ៍តាមដានស្វ័យប្រវត្តិ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ជាអាទិ៍។

## ហ អ ឧ

**ហិរញ្ញវត្ថុបៃតង (Green Finance)**

សំដៅដល់ការវិនិយោគហិរញ្ញវត្ថុ ចូលទៅក្នុងគម្រោងអភិវឌ្ឍនិង/ឬគំនិតផ្តួចផ្តើមប្រកបដោយចីរភាព សម្រាប់ផលិតផលបរិស្ថាន និងគោលនយោបាយដែលមានការលើកទឹកចិត្តដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

**ហេតុប៉ះពាល់បរិស្ថាន (Environmental Impact)**

សំដៅដល់ហេតុប៉ះពាល់អវិជ្ជមាននិងវិជ្ជមានសំខាន់ៗទៅលើធនធានរូបសាស្ត្រ ធនធានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ចសង្គម ដែលបង្កឡើងពីសកម្មភាពគម្រោងដោយផ្ទាល់ក្តីឬដោយប្រយោលក្តី។

**អគារបៃតង (Green Building)**

សំដៅដល់សំណង់ឬអគារដែលមាននិរន្តរភាព ទាំងរចនាសម្ព័ន្ធ ទាំងការអនុវត្តដំណើរការដែលមានការទទួលខុសត្រូវដល់បរិស្ថាននិងធនធាន ដែលមានប្រសិទ្ធភាពនៅក្នុងវដ្តជីវិតរបស់អគារពីការប្រើប្រាស់ទឹកនិងអគ្គិសនីដោយសន្សំសំចៃ ការរៀបចំផែនការរចនាអគារ ការសាងសង់ ការថែទាំ ការជួសជុល និងការបំផ្លាញ។

**អនុផលធនធានធម្មជាតិ (Natural Resource By-products)**

សំដៅដល់ផលឬផលិតផលដែលបានពីតំបន់ការពារធម្មជាតិ ដែលរាប់បញ្ចូលអនុផលព្រៃឈើ ជាអាទិ៍ វល្លិ ឫស្សី ស្លឹក ផ្កា ឬផ្លែរុក្ខជាតិ រុក្ខជាតិឱសថ ស្មៅ ត្រពាំង សម្រាប់បម្រើឱ្យជីវភាពរបស់ប្រជាជន។

**អាជ្ញាធរមានសមត្ថកិច្ច (Competent Authority)**

សំដៅដល់អាជ្ញាធរនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានសមត្ថកិច្ចក្នុងការគ្រប់គ្រងដែនដី ឬដឹកនាំ គ្រប់គ្រង និងចាត់ចែងកិច្ចការអ្វីមួយតាមវិស័យជាក់លាក់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ឧទ្យានជាតិ (National Park)**

សំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោកនិង/ឬដែនទឹក ដែលត្រូវបានកំណត់ដើម្បី៖

ក- ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយឬច្រើនរបស់តំបន់ដែលបានកំណត់ សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

ខ- កម្រិតដល់ការប្រើប្រាស់ដែលអាចធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញដល់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះជាមួយនឹងគោលបំណងនៃការកំណត់តំបន់។

គ- ផ្តល់ជាមូលដ្ឋានសម្រាប់ការកម្សាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគម្រាមកំហែងដល់បរិស្ថានធម្មជាតិនិងវប្បធម៌នៅក្នុងមូលដ្ឋាន។

**ឧទ្យានជាតិសមុទ្រ (National Marine Park)**

សំដៅដល់តំបន់ឆ្នេរសមុទ្រទទួលឥទ្ធិពលជំនោរសមុទ្រលាយឡំជាមួយនឹងទឹកពីព្រៃភ្នំ រួមទាំងកោះគ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆជាតិគ្រប់ប្រភេទមានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ហើយតំបន់នេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

**ឧស្ម័នផ្ទះកញ្ចក់ (Greenhouse Gas)**

១- សំដៅដល់ឧស្ម័នដែលមាននៅក្នុងបរិយាកាស ដែលកើតឡើងដោយធម្មជាតិឬដោយសកម្មភាពមនុស្ស ហើយស្រូបយកនិងបញ្ចេញរស្មីតាមជំហានរលកជាក់លាក់ ក្នុងជំហានរលកនៃកាំរស្មីកម្តៅក្រហមអាំងហ្វ្រាដែលភាយចេញពីផ្ទៃផែនដី បរិយាកាស និងពពក។ បាតុភូតទាំងនេះបង្កឱ្យមានផលផ្ទះកញ្ចក់។

២- ចំហាយទឹក ឧស្ម័នកាបូនិក ឌីអាសូតម៉ូណូអុកស៊ីត មេតាន និងអូហ្សូន ជាឧស្ម័នផ្ទះកញ្ចក់ចម្បងៗនៅក្នុងបរិយាកាសរបស់ផែនដី។ ក្រៅពីនេះ មានឧស្ម័នផ្ទះកញ្ចក់មួយចំនួនក្នុងបរិយាកាស ដែលបង្កើតឡើងដោយមនុស្សទាំងស្រុងដូចជា ហាឡូកាបូ និងសារធាតុដទៃទៀតដែលផ្ទុកក្លរនិងប្រូម គឺស្ថិតក្រោមការគ្រប់គ្រងនៃពិធីសារម៉ុងរ៉េអាល់។ ក្រៅពីឧស្ម័នកាបូនិក ឌីអាសូតម៉ូណូអុកស៊ីត និងមេតាន ពិធីសារក្យូតូ គ្រប់គ្រងឧស្ម័នផ្ទះកញ្ចក់ដទៃទៀត ដូចជា ស៊ុលភួ អ៊ិចសាភ្លុយអរីត និងពែរភ្លុយអរ៉ូកាបួ។

**ឧស្សាហកម្មនិស្សារណកម្ម (Extractive Industry)**

សំដៅដល់ឧស្សាហកម្មប្រេង ឧស្ម័ន រ៉ែ និងលោហៈនានា។